# មហោសថជាតក



កាលព្រះមហោសថដោះប្រស្នា យក្សស្រីដណ្តើមកូនគេ


ដឹកនាំការរៀបរៀងដោយ
ខ្ញុំព្រះករុណាខ្ញុំបាទ
**កុល ផេង**



ព.ស. ២៥៦៣

# ព្រះមហោសថជាតកពិស្តារ

## អធិបតីក្នុងការរៀបរៀង
## បណ្ឌិត **កុល ផេង**

*ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*និងជាប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

## អ្នកបកប្រែពីអដ្ឋកថាភាសាបាលី

*លោក* **គង់ សំអឿន** *និស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

## ក្រុមជំនុំពិនិត្យ

*បណ្ឌិត* **កុល ផេង** *ប្រធាន*

*ព្រះភិក្ខុ វជិរប្បញ្ញោ* **គូ សុភាព**

*ព្រះភិក្ខុ កិត្តិបាលោ* **ពេញ វិបុល**

*បណ្ឌិត* **ប៉ក់ ថាវិន**

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ**

*ឧបាសក* **ធូ សុធា**

*លោកគ្រូ* **លឹម លឿម**

*លោកគ្រូ* **ដុង សុភឿន**

*លោកគ្រូ* **ទិព្វ សៅ**

*លោកគ្រូ* **សំណាង សំណាក់**

*លោក* **ហាន សុខេមន្ទ** *លេខាធិការ*

## ក្រុមបច្ចេកទេស និងរចនា

*លោក* **អ៊ិន ស៊ីយ៉ុន្ដា** *ប្រធាន*

*លោក* **ឃុន សុវណ្ណរិទ្ធិ** *វិចិត្រករ សមាជិក*

*លោក* **ផុន សុគង់** *សមាជិក*

*លោក* **មម មានិត** *សមាជិក*

## រចនាសម្ពន្ធពុទ្ធិកបណ្ឌិតសភា
## នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា
## ក្រុមប្រឹក្សាភិបាល និងស្ថាបនិក

*បណ្ឌិត* **គុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **សុន្ទរ៍ សាម៉ៀន** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*បណ្ឌិត* **សំ សុខ** *សមាជិក*

*បណ្ឌិត* **ជា សានចាន់ថន** *សមាជិក*

*បណ្ឌិត* **ប៉ក់ ថាវិន** *សមាជិក*

*សាស្ត្រាចារ្យ* **ម៉ក់ វ៉ាន់** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ហេង គឹមហោ** *សមាជិក*

*សាស្ត្រាចារ្យ* **រស់ សាវេន** *សមាជិក*

*សាស្ត្រាចារ្យ* **ឌិត ជន** *សមាជិក*

*សាស្ត្រាចារ្យ* **ជា ត្រិស្នា** *សមាជិក*

*សាស្ត្រាចារ្យ* **អ៊ុង សុវណ្ណ** *សមាជិក*

*សាស្ត្រាចារ្យ* **នួច ងឹម** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ** *សមាជិក*

*លោកគ្រូជម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការ*

## ក្រុមជំនុំប្រតិបត្តិ

*បណ្ឌិត* **កុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះញាណវង្ស* **ឃឹម សន** *ឧត្តមប្រឹក្សាពុទ្ធិកបណ្ឌិតសភា*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*លោកគ្រូជម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការ*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធានគណៈកម្មការត្រួតពិនិត្យ*

*ព្រះមហា* **គូ សុភាព** *ប្រធានគណៈកម្មការបច្ចេកទេស*

*លោកគ្រូ* **ហ៊ាត ណាហាំ** *ប្រធានរដ្ឋបាល*

*លោក* **ហាន សុខេមនុ** *សមាជិកគណៈកម្មការបច្ចេកទេស*

## ក្រុមជំនុំអប់រំសីលធម៌ និងស្រាវជ្រាវអក្សរសិល្ប៍

*បណ្ឌិត* **កុល ផេង** *អធិបតីក្រុមជំនុំ*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *សមាជិក*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*លោកគ្រូជម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *សមាជិក*

*លោកគ្រូ* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **គង់ សំអឿន** *សមាជិក*

## ក្រុមជំនុំផ្សាយព្រះធម៌ និងភាសាបាលី

*លោកគ្រូ ធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *ប្រធាន*

*ព្រះមហា សក្យមុនីបុត្តោ* **ជា សុមាលា** *សមាជិក*

*លោកគ្រូ* **ហ៊ាត ណាហំ** *សមាជិក*

*លោកគ្រូ* **ចាន់ ឃួរ** *សមាជិក*

*លោកគ្រូ* **ឃួយ វ៉ាន់ថន** *សមាជិក*

*លោក* **សំ សុផល** *សមាជិក*

## ក្រុមជំនុំពិនិត្យ និងបោះពុម្ពផ្សាយសៀវភៅធម៌

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធាន*

*ព្រះមហា* **គូ សុភាព** *អនុប្រធានទី ១*

*លោក* **គង់ សំអឿន** *អ្នកបកប្រែពីភាសាបាលី អនុប្រធានទី ២*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ ភុយ** *សមាជិក*

*ធម្មាចារ្យ* **ហ៊ាត ណាហំ** *សមាជិក*

*លោក* **លឹម លឿម** *សមាជិក*

*លោក* **ដុង សុភឿន** *សមាជិក*

*លោក* **រស់ សិរីវណ្ណាត** *សមាជិក*

# សូមថ្វាយព្រះរាជកុសល
# ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង
# ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
# ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

***បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង***

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរ បវរមហាប្រសើរ និង ប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ បំពោះ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំយើងខ្ញុំបានប្រែសម្រួលនិងរៀបរៀងនូវសៀវភៅ* **ព្រះមហោសថជាតកពិស្តារ** *នេះ ដើម្បីតម្កល់ទុកក្នុងព្រះពុទ្ធសាសនា។ បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមព្រះករុណាជាអម្ចាស់អនុមោទនានូវមហាកុសលនេះដោយព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត។ សូមឧទ្ទិសចំពោះបារមីនៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គដែលបានត្រាស់ដឹងកន្លងមកក្នុងលោក ហើយ*

នឹងត្រាស់ដឹងក្នុងអនាគត និងដោយអានុភាពគុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមីនៃព្រះអតីតមហាក្សត្រ ព្រះមហាក្សត្រិយានីគ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយអភិបាលរក្សា **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មយឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ។

សេចក្តីគួរពុំគួរ សូម **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត។

ក្រោមបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ

ថ្ងៃសុក្រ ៨ រោច ខែកត្តិក ព.ស.២៥៥៥

**ភូល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# សូមថ្វាយព្រះរាជកុសល

## ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ និង

## សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

***បពិត្រព្រះករុណា និង សម្តេចព្រះមហាក្សត្រី ជាអម្ចាស់ជីវិតតម្កល់លើត្បូង***

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យា-ល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរ បវរមហាប្រសើរ និង ប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ចំពោះ* **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ និង សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំយើងខ្ញុំបានប្រែសម្រួលនិងរៀបរៀងនូវសៀវភៅ* **ព្រះមហោសថជាតកពិស្តារ** *នេះ ដើម្បីតម្កល់ទុកក្នុងពុទ្ធសាសនា។ បពិត្រព្រះករុណា និង សម្តេចព្រះមហាក្សត្រី ជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមទ្រង់អនុមោទនានូវមហាកុសលនេះ ដោយព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត។ សូមឧទ្ទិសចំពោះបារមីនៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គដែលបានត្រាស់ដឹងកន្លងមក*

ក្នុងលោក ហើយនឹងគ្រាស់ដឹងក្នុងអនាគត និងដោយអានុភាពនៃគុណបុណ្យព្រះរតនត្រ័យ សូមទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមីនៃព្រះអតីតមហាក្សត្រ ព្រះមហាក្សត្រិយានីគ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយអភិបាលរក្សា **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ និង សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មយឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ។

សេចក្តីគួរពុំគួរ សូម **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និង សម្តេចព្រះមហាក្សត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ
ថ្ងៃសុក្រ ៨ រោច ខែកត្តិក ព.ស.២៥៥៥

**ភុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# សូមគោរពជូនមហាកុសល

# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

***សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់***

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់និងភរិយាព្រមទាំងបុត្រ សូមគោរពជូនបុណ្យកុសល និងសព្ទសាធុការពរ បវរមហាប្រសើរ សិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការចំពោះ*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង លោកជំទាវ កិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** *ជាទីគោរពដ៏ខ្ពង់ខ្ពស់។*

*ខ្ញុំបាទសូមគោរពជូននូវមហាកុសល ដែលខ្ញុំបាទយើងខ្ញុំបានប្រែសម្រួលនិងរៀបរៀងនូវសៀវភៅ* **ព្រះមហោសថជាតកពិស្តារ** *នេះ ដើម្បីតម្កល់ទុកក្នុងព្រះពុទ្ធសាសនា។ សូម* **សម្តេច** *និង* **លោកជំទាវ** *មេត្តាទទួលអនុមោទនានូវមហាកុសលនេះ។ សូមគុណបុណ្យនៃព្រះរតនត្រ័យ និងបារមីនៃវត្ថុសក្តិសិទ្ធិក្នុងលោកជួយបីបាច់ថែរក្សា និងប្រសិទ្ធពរជ័យជូន* **សម្តេច** *និង* **លោកជំទាវ** *ព្រមទាំង* **បុត្រាបុត្រី** *និង* **ចៅៗ** *ជាទីស្រឡាញ់របស់* **សម្តេច** *និង* **លោកជំទាវ** *សូមប្រកប*

ដោយជន្មាយុយឺនយូរ សុខភាពល្អបរិបូណ៌ បញ្ញាញាណវាងវៃ ដើម្បី ដឹកនាំប្រទេសជាតិ ក្នុងការពង្រឹងសុខសន្តិភាព និងការអភិវឌ្ឍឲ្យបាន សម្បូរសប្បាយរុងរឿងដ៏បរិបូណ៌តទៅអនាគត។

ខ្ញុំបាទសូមកោតសរសើរដោយសុទ្ធចិត្ត នូវវីរភាពនិងវីរិយភាព ដ៏អង់អាចរបស់ **សម្តេច** ដែលបានបំពេញនូវបេសកកម្មដ៏លំបាក ក្នុង ការស្វែងរកសេចក្តីសុខសន្តិភាពជូនប្រជាពលរដ្ឋ និងការអភិវឌ្ឍក្នុង ព្រះរាជាណាចក្រកម្ពុជាយើង នាំមកនូវភាពចម្រុងចម្រើនរុងរឿងនា សម័យបច្ចុប្បន្ននេះ និងក្នុងអនាគតកាល។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ និង លោកជំទាវ កិត្តិព្រឹទ្ធបណ្ឌិត** ប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខ មហាប្រសើរ ព្រមទាំងទទួលបាននូវឧត្តមពរ ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ

ថ្ងៃសុក្រ ៨ រោច ខែកត្តិក ព.ស.២៥៥៥

**ក្មុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# បុព្វកថា

*មហោសថជាតក គឺជាដំណើររឿងតំណាលពីបុព្វជាតិរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូ កាលព្រះអង្គយោនយកកំណើតជា* **មហោសថ** *មានប្រាជ្ញាមោះមុត ល្បីរន្ទឺខ្ទរខ្ទារ ហើយក៏ជារឿងដែលពុទ្ធសាសនិកខ្មែរគ្រប់ជំនាន់បានដឹងបានឮ និងសិក្សាស្ទើរតែគ្រប់គ្នា។ ខុសគ្នាត្រង់ថា អ្នកខ្លះចេះចាំច្រើន អ្នកខ្លះចេះចាំតិច យ៉ាងហោចណាស់ក៏បានឮត្រឹមឈ្មោះថា* **មហោសថ និង នាងអមរា** *ដែរ តែការយល់ឲ្យបានស៊ីជម្រៅក្នុងខ្លឹមសាររឿងនោះ នៅមានកំណត់ទៅតាមកម្រិតយល់ដឹងរបស់ជនម្នាក់ៗនៅឡើយ។*

*រឿងមហោសថនេះ ក៏ជារឿងមួយមានប្រជាប្រិយភាព នៅក្នុងប្រទេសខ្មែរយើង ដោយអ្នកប្រាជ្ញខ្មែរបុរាណ បានចារទុកក្នុងសាស្ត្រាស្លឹករឹត មានរបៀបរៀបចំពាក្យជាកម្រងកែវ ការប្រើពាក្យពេចន៍ និងអក្ខរាវិរុទ្ធ ក៏ជាពាក្យពេចន៍អក្ខរាវិរុទ្ធក្នុងសម័យនោះ។ លុះក្រោយមកក្នុងព.ស.២៥០៥, គ.ស.១៩៦២ វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យបានចម្លងបោះពុម្ពជាសៀវភៅ* **មហោសថ** *ដោយរក្សាពាក្យពេចន៍តាមច្បាប់ដើម គ្រាន់តែបានកែអក្ខរាវិរុទ្ធមកប្រើតាមវចនានុក្រមខ្មែរសម័យនោះប៉ុណ្ណោះ។*

*ក្នុងព.ស.២៥០២,គ.ស.១៩៥៩លោក* **ឈឹមស៊ុម** *បានរៀបរៀងសៀវភៅសង្ខេបទសជាតក ដែលនិយាយពីអតីតប្រវត្តិរបស់ព្រះពុទ្ធ*

បរមត្ថ ១០ ជាតិ ក្នុងនោះក៏មានរឿងមហោសថផងដែរ ជាសេចក្តីសង្ខេបល្មមស្តាប់បានស្រួលស្របតាមកម្មវិធីសិក្សាក្នុងកម្រិតមធ្យមរបស់ក្រសួងអប់រំជាតិនាសម័យនោះ។

ពុទ្ធិកបណ្ឌិតសភា បានសម្រេចចិត្តបកប្រែរឿង **ព្រះមហោសថជាតកពិស្តារ** នេះពីអដ្ឋកថាភាសាបាលីពិស្តារជាថ្មីម្តងទៀត ដោយប្រើពាក្យតាម **វចនានុក្រមខ្មែរ** របស់ **សម្តេចព្រះមហាសុមេធាធិបតី ជួន ណាត ជោតញ្ញាណោ**។ វិធីសាស្ត្រក្នុងការបកប្រែ ពុំបានលើកយកមេពាក្យបាលីក្នុងគាថាមកដាក់ទេ គឺប្រែយកសេចក្តីទាំងក្នុងបាលីគាថា រួមផ្សំជាមួយសេចក្តីអធិប្បាយក្នុងអដ្ឋកថា ឲ្យចេញជាភាសាខ្មែរល្មមស្តាប់បានតែម្តង។ ដើម្បីឲ្យងាយស្រួលក្នុងការចងចាំរឿង យើងខ្ញុំបានបែងចែករឿងជា ១១ ជំពូកធំៗ។

គោលបំណងនៃការបកប្រែរៀបរៀង **ព្រះមហោសថជាតកពិស្តារ** គឺដើម្បី៖

១-ជាជំនួយក្នុងកម្មវិធីអប់រំជាតិកម្រិតមធ្យមនិងឧត្តមសិក្សា
២-ជាឯកសារសិក្សាស្រាវជ្រាវសម្រាប់ពុទ្ធសាសនិកជនទូទៅ
៣-ជាការអភិរក្ស ផ្សព្វផ្សាយអក្សរសាស្ត្រ វប្បធម៌ អរិយធម៌ខ្មែរ
៤-ជាកេរមត៌កតម្កល់ទុកសម្រាប់កុលបុត្រ កុលធីតាជំនាន់ក្រោយ
៥-ជាការផ្សព្វផ្សាយព្រះពុទ្ធសាសនាក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យរឹតតែបានទូលំទូលាយ។

ព្រះមហោសថជាតកពិស្តារនេះ ក្រុមជំនុំបានត្រួតពិនិត្យលើខ្លឹមសារ ន័យសេចក្តី អក្ខរាវិរុទ្ធ ឃ្លាល្បះ ដោយយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នបំផុត តែទោះជាយ៉ាងនេះក៏ដោយ សៀវភៅនេះអាចនៅមានខុសឆ្គងខ្លះជាមិនខាន។ យើងខ្ញុំសូមអភ័យទោសអំពីសំណាក់លោកអ្នកប្រាជ្ញ កវីបណ្ឌិត ព្រឹទ្ធាចារ្យ និងលោកអ្នកអានជាទីគោរពទាំងអស់ ដោយក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់។

ត្រង់ចំណុចនេះ ខ្ញុំព្រះករុណា ខ្ញុំបាទនឹកឃើញនូវចំណាររបស់ **សម្តេចព្រះមហាសុមេធាធិបតី ជួន ណាត ជោតញ្ញាណោ** មួយប្រយោគថា៖

"ធម្មតាការងារអ្វីទាំងអស់ក្នុងលោក តែងតែមានភ្លាំងភ្លាត់ខ្លះ បើមិនច្រើន ក៏តិចតួចពុំខាន នេះជាទម្លាប់នៃការងាររបស់បុថុជ្ជន ព្រោះ ត្រូវជាគួគ្នានឹងខុស ប៉ុន្តែបើមានត្រូវច្រើន មានខុសតែបន្តិចបន្តួច ក៏គង់អាចប្រើការកើត គ្រាន់បើជាងគ្មានសោះទៅដែរ។"

ជាទីអវសាននៃបុព្វកថានេះ ដោយអានុភាពនៃកុសលដែលកើតឡើងពីការខិតខំប្រឹងប្រែងឲ្យបានចេញជាស្នាដៃដ៏ប្រពៃនេះ យើងខ្ញុំសូមឧទ្ទិសឥដ្ឋមនុញ្ញផល ជូនចំពោះបុព្វបុរសខ្មែរ មាតាបិតា ជីដូនជីតា បងប្អូន និងញាតិសាច់សាលោហិតទាំងអស់ក្នុងសង្សារវដ្ដ ទាំងអតីត បច្ចុប្បន្ន និងអនាគត សូមឲ្យមានសុខភាពល្អ អាយុយឺនយូរ កម្លាំងកាយមាំមួន ប្រាជ្ញាវាងវៃ កុំបីមានជំងឺតម្កាត់មកបៀតបៀនយាយីធ្វើទុក្ខបុកម្នេញឲ្យដល់សេចក្តីលំបាកដ៏តិចតួចឡើយ និងសូមបានជា

ឧបនិស្ស័យកំពូលគឺ ការរួចផុតចាកទុក្ខដល់នូវបរមសុខ ពោលគឺ ព្រះនិព្វានកុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ព.ស. ២៥៥៥ / គ.ស. ២០១២

**ក្មុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# មាតិកា

## ជំពូកទី ១

កំណើតព្រះមហោសថ ........................................................................ ១
សុបិននិមិត្តរបស់ព្រះបាទវិទេហរាជ ........................................... ៣
ទីប្រឹក្សាទស្សន៍ទាយសុបិន ............................................................ ៥
ព្រះមហាសត្តច្យុតចាកឋានត្រៃត្រិង្ស ........................................... ៧
ព្រះមហាសត្តចេះនិយាយពេលប្រសូត ........................................ ៧
ពិធីតាំងនាមព្រះមហាសត្ត .............................................................. ៩
មហោសថកុមារនិងសម្ភាញ់សាងមណ្ឌលកីឡា ......................១១
សមិទ្ធផលរបស់មហោសថកុមារ .................................................១៤
ព្រះបាទវិទេហរាជស្វែងរកបណ្ឌិតទី ៥.......................................១៧
សេនកបណ្ឌិតបដិសេធការនាំបណ្ឌិតទី ៥ ចូលព្រះរាជវាំង.....១៨

## ជំពូកទី ២

សត្តទារកបញ្ហា មហោសថកុមារអាយុ ៧ ឆ្នាំ ដោះប្រស្នា ៧ ខ......២០
ប្រស្នាទី ១ មំសបញ្ហា = ប្រស្នាខ្លែងពាំសាច់ ..........................២០
ប្រស្នាទី ២ គោណបញ្ហា = ប្រស្នាចោរលួចគោ .....................២២
ប្រស្នាទី ៣ គន្ថិបញ្ហា = ស្ត្រីលួចសង្វារ .................................២៩
ប្រស្នាទី ៤ សុត្តំ = ស្ត្រីលួចអំបោះ...........................................៣២
ប្រស្នាទី ៥ បុត្តោ = យក្ខិនីបន្លំលួចកូន ....................................៣៤

ប្រស្នាទី ៦ គោតោ = ចោរលួចប្រពន្ធរបស់បុរសតឿ ..........៣៨
ប្រស្នាទី ៧ រថេន = ព្រះឥន្ទ្រប្រណាំងរទេះ ..........................៤៧

## ជំពូកទី ៣

គទ្រភបញ្ហា (ប្រស្នា ១២ ខ បន្ថែមទៀត)......................................៥២
ប្រស្នាទី ៨ ទណ្ឌោ = ប្រស្នាដំបង ........................................៥២
ប្រស្នាទី ៩ សីសំ = ប្រស្នាទាយលលាដ៍ក្បាល ...................៥៥
ប្រស្នាទី ១០ អហិ = ប្រស្នាពស់ញីពស់ឈ្មោល .................៥៥
ប្រស្នាទី ១១ កុក្កុដោ = ប្រស្នាគោដុះស្នែងជើង....................៥៦
ប្រស្នាទី ១២ មណី = ប្រស្នាដោតអំបោះថ្មីចងកែវមណី........៥៧
ប្រស្នាទី ១៣ វិជាយនំ = ប្រស្នាគោឈ្មោលកើតកូន ............៥៩
ប្រស្នាទី ១៤ ឱទនំ = ប្រស្នាដាំបាយអត់អង្ករ........................៦១
ប្រស្នាទី ១៥ វាលុកំ = ប្រស្នាខ្សែដីខ្សាច់ ..............................៦៣
ប្រស្នាទី ១៦ តឡាក = ប្រស្នាសែងស្រះថ្វាយស្ដេច ............៦៥
ប្រស្នាទី ១៧ ឧយ្យាន = ប្រស្នាសែងឧទ្យានថ្វាយស្ដេច ........៦៧
ប្រស្នាទី ១៨ អស្សតរ = ប្រស្នាសេះអស្សតរ និងសត្វលា ...៦៧
មហោសថចូលវាំង ...................................................................៧៨
ប្រស្នាទី ១៩ កែវមណីក្នុងសំបុកក្អែក....................................៨១

## ជំពូកទី ៤

មហោសថគាល់បម្រើព្រះបាទវិទេហរាជ ..........................................៨៥
សត្វបង្កួយចេះគោរពព្រះរាជា ..........................................៨៥
សត្វបង្កួយមិនគោរពព្រះរាជា ..........................................៨៦
សិរិកាឡកណ្ណិបញ្ហា ..........................................៨៩
ប្រពៃណីអាចារ្យទិសាបាមោក្ខ ..........................................៨៩
រៀបការរួចហើយឥតសំណាង ..........................................៩០
បង្គិត្តរមាណពចោលប្រពន្ធលើដើមល្វា ..........................................៩១
សំណាងស្រីប្តីរត់ចោល ..........................................៩២
ឧទុម្ពរទេវីជួបប្តីដើម ..........................................៩៣
មហោសថជួយព្រះមហេសី ..........................................៩៤
ឧទុម្ពរទេវីសូមមហោសថធ្វើបុនធម៌ ..........................................៩៥
មេណ្ឌកបញ្ហា ..........................................៩៧
សត្វពពែនិងសត្វសុនខយកគ្នាជាមិត្ត ..........................................៩៧
ព្រះបាទវិទេហរាជចោទប្រស្នា ..........................................១០១
បណ្ឌិតទាំង ៥ សូមពន្យារពេលដោះប្រស្នា ..........................................១០២
ព្រះបាទវិទេហរាជគំរាមបណ្ឌិតទាំង ៥ ..........................................១០៤
មហោសថស្វែងយល់ប្រស្នា ..........................................១០៥
មហោសថជួយបង្រៀនប្រស្នាដល់បណ្ឌិតទាំង ៤ ..........................................១០៨

ព្រះរាជាប្រទានរាជអំណោយដល់បណ្ឌិតទាំង ៥ ................ ១១៣
សិរិមន្តបញ្ហា ................................................................ ១១៥
ប្រស្នាអ្នកមានទ្រព្យនិងអ្នកមានប្រាជ្ញា ................................ ១១៥
យោបល់ខ្វែងគ្នារវាងសេនកៈនិងមហោសថ ........................ ១១៦
មហោសថផ្ចាញ់សេនកៈដោយកម្លាំងបញ្ញា .......................... ១៣០
សេនកៈទាល់តម្រិះ ........................................................... ១៣១

## ជំពូកទី ៥

នាងអមរា និងមហោសថ ........................................................... ១៣៤
មហោសថស្វែងរកកិរិយា ................................................... ១៣៤
មហោសថជួបនាងអមរា ...................................................... ១៣៥
សំណួរឆ្លើយឆ្លងល្បងប្រាជ្ញា................................................ ១៣៧
ផ្លូវទៅផ្ទះនាងអមរា .......................................................... ១៤០
មហោសថឃ្លាំមើលចរិតនាងអមរា...................................... ១៤១
មហោសថស្តីដណ្តឹងនាងអមរា ........................................... ១៤៦
ផ្លែពុទ្រាក្តៅនិងត្រជាក់........................................................ ១៤៧
មហោសថពិសោធចិត្តនាងអមរា......................................... ១៤៩
អាពាហ៍ពិពាហ៍មហោសថនិងនាងអមរា ............................. ១៥១
សព្វរតនថេនវណ្ណនា ......................................................... ១៥៤
បណ្ឌិតទាំង ៤ ទម្លាក់កំហុសលើមហោសថ ........................ ១៥៤

ព្រះបាទវិទេហៈជឿការញុះញង់ ............................................ ១៥៨
មហោសថភៀសខ្លួន ............................................................ ១៥៩
បណ្ឌិតទាំង ៤ ធ្លាក់រណ្ដៅលាមក ........................................ ១៦០
នាងអមរាចាប់ចោរ ៤ នាក់ ទៅថ្វាយស្ដេច ............................ ១៦៣
នាងអមរាជួយប្ដី ............................................................. ១៦៤

## ជំពូកទី ៦

មហោសថដោះប្រស្នាទេវតារក្សាមហាស្វេតច្ឆត្រ .............................. ១៦៦
ទេវតាសួរប្រស្នាព្រះរាជា ................................................... ១៦៦
ទេវតាគំរាមព្រះរាជាឲ្យរកមហោសថ .................................... ១៧១
ស្ដេចស្វែងរកមហោសថឲ្យចូលវាំងវិញ ............................... ១៧៥
មហោសថផ្ដល់អនុសាសន៍ថ្វាយព្រះរាជា .............................. ១៨០
ទេវតាចោទប្រស្នា ............................................................ ១៨៤
មហោសថឆ្លើយប្រស្នាទេវតា ............................................... ១៨៤
មហោសថទទួលតំណែងជាសេនាប្រមុខ ................................ ១៩១

## ជំពូកទី ៧

ផ្ចាញ់សត្រូវដោយមេត្តាធម៌ ................................................. ១៩២
បណ្ឌិតទាំង ៤ សួរប្រស្នាអាថ៌កំបាំង ...................................... ១៩២
បណ្ឌិតទាំង ៤ ញុះញង់ព្រះរាជា .......................................... ១៩៣
មហោសថរកឃើញរឿងអាថ៌កំបាំងរបស់បណ្ឌិតទាំង ៤ ...... ១៩៩

រឿងអាថ៌កំបាំងរបស់សេនកៈ ............ ២០២
រឿងអាថ៌កំបាំងរបស់បុក្កុសៈ ............ ២០៤
រឿងអាថ៌កំបាំងរបស់កាមិន្ទៈ ............ ២០៥
រឿងអាថ៌កំបាំងរបស់ទេវិន្ទៈ ............ ២០៥
ឧទុម្ពរទេវីបញ្ជូនសារទៅមហោសថ ............ ២០៦
មហោសថថ្កោលទោសស្តេច ............ ២១១
មហោសថទម្លាយរឿងអាថ៌កំបាំងរបស់អាចារ្យទាំង៤ ............ ២១៤
រឿងអាថ៌កំបាំងគួរប្រាប់អ្នកដទៃពេលណា? ............ ២១៨
មហោសថលើកលែងទោសបណ្ឌិតទាំង ៤ ............ ២២១

## ជំពូកទី ៨

យុទ្ធសាស្ត្រទប់ទល់នឹងសង្គ្រាមពង្រីកវាតទីរបស់កបិលរដ្ឋ ............ ២២៤
មហោសថអភិវឌ្ឍប្រទេសជាតិ ............ ២២៤
ទំនាក់ទំនងអន្តរជាតិ ............ ២២៥
សេកនាំសារ ............ ២២៨
ចូឡនីព្រហ្មទត្តស្តេចបញ្ចាលនគរ ............ ២៣១
នយោបាយកាន់កាប់ទឹកដី ............ ២៣៣
សេកផ្តល់ដំណឹង ............ ២៣៦
ផែនការការពារប្រទេសជាតិរបស់មហោសថ ............ ២៣៩
ស្តេចចូឡនីវាតទីកាន់កាប់សកលជម្ពូទ្វីប ............ ២៣៩

គម្រោងលុកលុយក្រុងមិថិលា ................................................ ២៤១
ផែនការធ្វើគុតស្តេច ១០១ អង្គដោយថ្នាំពិស ...................... ២៤៤
សង្គ្រាមនៅក្រុងមិថិលា ........................................................ ២៥០
ព្រះបាទវិទេហៈខ្លាចចម្បាំងស្តេចចូឡនី ................................ ២៥៥
មហោសថបង្អើលសត្រូវ ........................................................ ២៦១
សង្គ្រាមធម៌ ........................................................................ ២៧៣
បណ្ឌិតមហោសថយកកែវមណីបញ្ឆោតបណ្ឌិតកេវដ្ដៈ ........ ២៨១
អនុកេវដ្តព្រាហ្មណ៍បំពេញបេសកកម្មពិសេស .................... ២៨៧
ជយកណ្ឌក្រោយសង្គ្រាម ........................................................ ២៩៨

## ជំពូកទី ៩

ល្បិចទល់ល្បិច ........................................................................ ៣០០
សុវកណ្ឌ(សេកមាធុរៈប្រលោមស្នេហ៍សារិកា) .................... ៣០០
ល្បិចទាក់ស្តេចវិទេហៈ .......................................................... ៣០០
ចម្រៀងមន្តស្នេហ៍ .................................................................. ៣០៤
កេវដ្តព្រាហ្មណ៍ទៅជេញពេលារៀបអភិសេក ........................ ៣០៦
កេវដ្តព្រាហ្មណ៍ទៅផ្ទះមហោសថ ............................................ ៣១១
មហោសថជំទាស់នឹងការរៀបអភិសេក ................................ ៣១៩
ព្រះបាទវិទេហៈមើលងាយមហោសថ .................................. ៣២៣
សេកធ្វើជាឈ្លបពិសេសស៊ើបមូលហេតុនៃការអភិសេក .... ៣២៤

សេកប្រើល្បិចមន្តស្នេហ៍ទាក់ចិត្តសារិកា ............................ ៣២៨
សារិកាប្រាប់មូលហេតុនៃការរៀបអភិសេក ............................ ៣៤១
សេកមាធុរៈរាយការណ៍ដល់មហោសថ ............................ ៣៤៥

## ជំពូកទី ១០

សត្រូវក្លាយជាមិត្រ ............................ ៣៤៨
មហាឧម្មង្គកណ្ឌ ............................ ៣៤៨
មហោសថជួយរៀបចំផែនការអភិសេក ............................ ៣៤៨
មហោសថយកអ្នកទោស៤គុកធ្វើទាហាន ............................ ៣៥១
មហោសថត្រៀមការពារសុវត្ថិភាពព្រះរាជាតាមផ្លូវ ............................ ៣៥៣
មហោសថត្រួតពិនិត្យដែនដីស្តេចចូឡនី ............................ ៣៥៤
ស្តេចចូឡនីទទួលមហោសថ ............................ ៣៥៥
មហោសថធ្វើទ្វារឧម្មង្គ ............................ ៣៥៧
មហោសថជ្រើសរើសទីតាំងសាងសង់រាជដំណាក់ ............................ ៣៥៨
មហោសថស្នើសាងសង់រាជដំណាក់ខាងក្រៅទីក្រុង ............................ ៣៦៦
ការរៀបចំមហាឧម្មង្គ ............................ ៣៦៩
ព្រះបាទវិទេហៈយាងមករាជដំណាក់ថ្មី ............................ ៣៧៣
ព្រះបាទវិទេហៈបញ្ជូនរាជទូតទៅសម្នាក់ព្រះបាទចូឡនី ............................ ៣៧៥
ស្តេចចូឡនីឡោមព័ទ្ធរាជដំណាក់ថ្មី ............................ ៣៧៨
មហោសថចាប់រាជវង្សស្តេចចូឡនី ............................ ៣៧៩

ព្រះបាទវិទេហៈដឹងខ្លួនថាជាប់អន្ទាក់គេ ................................ ៣៨៣
មហោសថពង្រាងស្តេច ........................................................ ៣៨៦
មហោសថជួយរំដោះព្រះរាជានិងពួកមន្ត្រីចេញពីសត្រូវ ...... ៣៩៩
ពិធីអភិសេកស្តេចវិទេហៈនឹងរាជធីតាបញ្ចាលចន្ទី ............... ៤០៣
ឱវាទមហោសថផ្តាំចំពោះព្រះបាទវិទេហៈ ............................. ៤០៥
មហោសថជាមេទ័ពមិនរត់ចោលកូនទាហាន ........................ ៤០៦
ព្រះបាទវិទេហៈយាងដល់នគរដោយសុវត្ថិភាព .................... ៤០៨
ព្រះបាទចូឡនីបញ្ចោកងទ័ពវាយលុករាជដំណាក់ថ្មី............... ៤១០
មហោសថគំរាមស្តេចចូឡនី.................................................. ៤១២
មហោសថពណ៌នាសម្រស់មហេសីស្តេចចូឡនី.................... ៤២៤
មហោសថលួងលោមស្តេចចូឡនី ........................................ ៤២៨
មហោសថយាងស្តេចចូឡនីទតឧម្មង្គ .................................... ៤៣០
មហោសថឆាដាវគំរាមស្តេចចូឡនី ....................................... ៤៣២
មហោសថនិងស្តេចចូឡនីធ្វើសម្បថ ..................................... ៤៣៤
ស្តេច ១០១ អង្គស្ងើចសរសើរមហោសថ .......................... ៤៣៥
មហោសថសន្យានឹងស្តេចចូឡនី............................................ ៤៣៩
មហោសថធ្វើមាតុភូមិនិវត្តន៍.................................................. ៤៤១
ពិធីស្វាគមន៍លោកសេនាប្រមុខមហោសថ ......................... ៤៤៦
រាជវង្សស្តេចចូឡនីត្រឡប់ទៅនគរវិញ ................................ ៤៤៩

## ជំពូកទី ១១


កក្តីភាពរបស់មហោសថចំពោះស្តេចចូឡនីព្រហ្មទត្ត ........................ ៤៥២
ទករក្ខសបញ្ហា(ប្រស្នាអារក្សទឹក) ........................................... ៤៥២
មហោសថចូលគាល់បម្រើស្តេចចូឡនី ...................................... ៤៥២
ជូនជីបរិញ្វាជិកាកេរី ........................................................... ៤៥៤
មហាក្សត្រីនន្ទាទេវីរកកំហុសមហោសថ ................................ ៤៥៤
មហោសថឆ្លើយសំណួរបរិញ្វាជិកាកេរី .................................... ៤៥៥
ពួកស្ត្រីជំនិតញុះញង់ព្រះបាទចូឡនី ....................................... ៤៥៧
ព្រះបាទចូឡនីសួរបរិញ្វាជិកានិងមហោសថ ............................. ៤៥៨
មហោសថទទួលតំណែងជាសេនាប្រមុខជាលើកទី ២......... ៤៦១
បរិញ្វាជិកាសួរប្រស្នាអារក្សទឹកចំពោះស្តេចចូឡនី ................. ៤៦២
ប្រវត្តិព្រះមាតានៃស្តេចចូឡនី .................................................. ៤៦៦
មូលហេតុឲ្យព្រះមាតាដល់អារក្សទឹកក្នុងលំដាប់ទី ១........... ៤៧៤
មូលហេតុឲ្យកិរិយាដល់អារក្សទឹកក្នុងលំដាប់ទី ២ ............... ៤៧៨
មូលហេតុឲ្យប្អូនដល់អារក្សទឹកក្នុងលំដាប់ទី ៣ .................... ៤៧៩
មូលហេតុឲ្យសម្លាញ់ដល់អារក្សទឹកក្នុងលំដាប់ទី ៤ ............ ៤៨៣
មូលហេតុឲ្យបុរោហិតដល់អារក្សទឹកក្នុងលំដាប់ទី ៥ ........... ៤៨៤
មូលហេតុឲ្យខ្ទួនព្រះអង្គដល់អារក្សទឹកក្នុងលំដាប់ទី ៦......... ៤៨៦
ព្រះសាស្តាប្រជុំជាតក ........................................................... ៤៨៩

# ជំពូកទី ១

## កំណើតព្រះមហោសថ

កាលព្រះសាស្តាគង់នៅក្នុងវត្តជេតពន ទ្រង់លើកយកបញ្ញាបារមីរបស់ព្រះអង្គ ហើយបានសម្តែងនូវព្រះធម្មទេសនានេះ មានគាថាផ្តើមថា "**បញ្ញាហោ សព្វសេនាយ**" ជាដើមៗ

មានរឿងទាក់ទងនឹងពុទ្ធតម្រាស់នោះថា ក្នុងថ្ងៃមួយ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងសាលាធម្មសភា និយាយសរសើរអំពីគុណនៃព្រះបញ្ញាបារមីរបស់ព្រះតថាគតថា៖

"ម្នាលអាវុសោទាំងឡាយ! ព្រះតថាគត ទ្រង់មានបញ្ញាច្រើន បញ្ញាក្រាស់ បញ្ញាជ្រាលជ្រៅ បញ្ញាគួរស្ញើច បញ្ញារហ័ស បញ្ញាមុត បញ្ញាស្រួច អាចសង្កត់សង្កិនសម្តីរបស់អ្នកដទៃដែលពោលផ្ចាញ់ព្រះអង្គបានៗ ដោយអានុភាពនៃបញ្ញាបារមីដ៏ខ្លាំងក្លានេះ ព្រះអង្គបានទូន្មាននូវព្រាហ្មណ៍ទាំងឡាយ មានកូដទន្តព្រាហ្មណ៍ជាដើម នូវបរិព្វាជកទាំងឡាយ មានសកិយៈជាដើម នូវចោរទាំងឡាយមានអង្គុលិមាលជាដើម នូវយក្ខទាំងឡាយ មានអាឡវកយក្ខជាដើម នូវទេវតាទាំងឡាយ

មានសក្កទេវរាជជាដើម នូវព្រហ្មទាំងឡាយ មានពកាព្រហ្មជាដើមៗ ព្រះអង្គបានទូន្មានអ្នកទាំងអស់នោះ មិនឲ្យធ្វើអ្វីតាមទំនើងចិត្តខ្លួនឯងៗ ព្រះអង្គបានប្រទានផ្នួសដល់ពពួកជនជាច្រើន ញុំាំងពួកគេឲ្យតាំងនៅស៊ប់ក្នុងមគ្គនិងផលៗ ម្នាលអាវុសោ ព្រះសាស្តានៃយើងមានបញ្ញាច្រើនយ៉ាងនេះ”ៗ

ពេលនោះព្រះសាស្តាទ្រង់យាងមកដល់ហើយត្រាស់សួរថា៖

“ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ តើអ្នកទាំងឡាយប្រជុំគ្នាសន្ទនាអំពីរឿងអ្វី?”

ភិក្ខុទាំងឡាយក្រាបទូលថា៖

“ទូលព្រះបង្គំយើងខ្ញុំ កំពុងសរសើរអំពីគុណព្រះបញ្ញាដ៏មោះមុតរបស់ព្រះបរមសាស្តាចារ្យ”ៗ

កាលនោះ ព្រះសាស្តាទ្រង់ត្រាស់តបថា៖

“ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនមានបញ្ញាតែក្នុងជាតិនេះទេ សូម្បីក្នុងអតីតជាតិ កាលដែលញាណមិនទាន់ចាស់ក្លា តថាគតកំពុងប្រព្រឹត្តចរិយា ដើម្បីប្រយោជន៍ពោធិញ្ញាណនៅឡើយ ក៏ធ្លាប់មានបញ្ញាអ៊ីចឹងដែរ”ៗ

**សុបិននិមិត្តរបស់ព្រះបាទវិទេហរាជ**

*ពេលភិក្ខុទាំងឡាយក្រាបទូលអាពធនាហើយ ព្រះសាស្តាទ្រង់បាននាំអតីតនិទានមកសម្តែងមានអត្ថន័យដូចតទៅនេះ ៖*

*ក្នុងកាលកន្លងទៅយូរលង់ណាស់មកហើយ មានព្រះរាជាមួយអង្គ ព្រះនាមថា **ព្រះបាទវិទេហរាជ** ទ្រង់សោយរាជសម្បត្តិក្នុងក្រុងមិថិលាក្នុងដែន[១]វិទេហៈ។ ស្តេចអង្គនោះ មានអ្នកប្រាជ្ញបណ្ឌិតជាទីប្រឹក្សា ៤ រូបគឺ អាចារ្យសេនកៈ១ អាចារ្យបុក្កុសៈ១ អាចារ្យកាមិន្ទៈ១*

---

*[១] ក្រុងនិងនគរមានអត្ថន័យដូចគ្នា គឺជាទីប្រជុំជនធំរបស់ប្រទេសនីមួយៗក្នុងសកលលោក ឧទាហរណ៍ ក្រុងភ្នំពេញរបស់ប្រទេសកម្ពុជា, ក្រុងប៉ារីសរបស់ប្រទេសបារាំង, ក្រុងប៉េកាំងរបស់ប្រទេសចិន។ល។ មានពាក្យ **ធានី** មួយទៀតប្រើន័យដូចគ្នានឹងក្រុងឬនគរនេះដែរ។ ពាក្យនេះច្រើនប្រើជា **រាជធានី** យ៉ាងនេះបាន ចំពោះតែទីក្រុង ដែលមានក្សត្រិយ៍ទ្រង់រាជ្យគង់នៅជាប្រធាន, ប៉ុន្តែ ចំពោះទីក្រុងដែលឥតមានក្សត្រិយ៍គង់នៅ ហៅថា **រដ្ឋធានី** វិញ។ ឯពាក្យ **ដែន** ឬ **ដែនដី** មានន័យ ទូលំទូលាយជាងនគរឬក្រុង សំដៅដល់ប្រទេសទាំងមូល ឬហៅតាមភាសាបាលីថា **រដ្ឋ**ៗនេះឯង។*

អាចារ្យទេវិន្ទៈ១។ រាត្រីមួយ ព្រះបាទវិទេហរាជទ្រង់យល់សុបិន[២]ក្នុងវេលាជិតភ្លឺ ជំណាលគ្នានឹងថ្ងៃដែលព្រះពោធិសត្វទ្រង់ប្រសូត៖

"មានគំនរភ្លើង ៤ ឆេះឡើងសន្ធោសន្ធៅ ប៉ុនមហាកំពែង ត្រង់ជ្រុងទាំង ៤ នៃព្រះរាជវាំង ស្រាប់តែមានភ្លើងមួយដុំប៉ុនអំពិលអំពែក លេចឡើងក្នុងកណ្តាលភ្លើងទាំង ៤ នោះ បញ្ចេញពន្លឺចិញ្ចែងចិញ្ចាចជាងភ្លើងទាំង ៤ មួយរំពេច រស្មីសាយឡើងទៅទល់នឹងព្រហ្មលោក គ្របដណ្តប់ទូទៅពេញសកលចក្រវាល[៣] លុះធ្លាក់មកលើផែនដីឃើញ ប្រាកដប៉ុនគ្រាប់ស្ពៃប៉ុណ្ណោះ។ រងើកភ្លើងតូចនោះ ត្រូវមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក បូជាដោយគ្រឿងក្រអូប និងផ្កាកម្រង

---

[២] មូលហេតុនៃសុបិន មាន ៦ យ៉ាងគឺ ធាតុដើរមិនស្មើ១ ប្រមាត់កម្រើក១ ស្លេស្មឡើងច្រើន១ ទេវតាបណ្តាលឲ្យឃើញ១ រឿងដែលធ្លាប់បានជួបប្រទះ១ រឿងរ៉ាវដែលនឹងកើតមានពិតប្រាកដ (បុព្វនិមិត្ត)១។ (មិលិន្ទបញ្ហា)។

[៣] ចក្រវាល ច័ក-ក្រៈវ៉ាល, សំ.(ន.) លោកធាតុ គឺភ្នំជាកំពែងពទ្ធជុំវិញនៃពិភពលោកទាំងមូល។ តាមសង្កេតឃើញប្រើប្រឡំដោយច្រើន ចំពោះការសរសេរ ចក្រវាឡ បែបនេះ ពីព្រោះសំស្រ្កឹតឥតមានតួអក្សរឡទេ បើយើងចង់សរសេរនឹងឡ ត្រូវសរសេរជាបែបបាលីថា **ចក្កវាឡ** ។

ជាដើមៗ រីឯមហាជនដែលដើរតាមចន្លោះភ្លើងនោះ ពុំបាន
របោកដោយកម្ដៅ សូម្បីបន្តិចឡើយ"ៗ

លុះទ្រង់សុបិនដូច្នេះ[៤]ហើយ ព្រះបាទវិទេហរាជ ទ្រង់មានព្រះ
ទ័យខ្លាចតក់ស្លុត ក៏តើនឡើង ហើយទ្រង់ព្រះតម្រិះថា៖

"តើនឹងមានរឿងអ្វីកើតឡើងចំពោះអញទេដឹង?"

ដោយព្រះតម្រិះដូច្នេះ ព្រះអង្គទ្រង់ផ្ទំពុំលក់ទៅវិញឡើយ ហើយ
ទ្រង់គង់ប្រថាប់ ត្រិះរិះរឿងសុបិននោះ រហូតដល់អរុណរះឡើងៗ

**នីប្រឹក្សាធស្សន៍ទាយសុបិន**

បណ្ឌិតទាំង ៤ មកពីព្រលឹម ក្រាបទូលសួរអំពីការផ្ទំជាសុខថា៖

"បពិត្រព្រះសម្មតិទេព តើព្រះអង្គទ្រង់ផ្ទំស្រួលទេ ក្រាបទូល?"
ព្រះបាទវិទេហរាជតបថា៖

"យើងផ្ទំពុំស្រួលទេ ព្រោះយើងបានឃើញសុបិនបែបនេះ"ៗ

បន្ទាប់ពីទ្រង់បានរៀបរាប់សុបិនទាំងអស់នោះ ដល់អាចារ្យជា
បណ្ឌិតទាំង ៤ ហើយ សេនកបណ្ឌិតក្រាបទូលព្រះរាជាថា៖

"មហាបពិត្រ សូមទ្រង់កុំខ្លាចឡើយ ទុំះជាសុបិននិមិត្តប្រកប

[៤] ដូច្នេះ ដូច-ច្នេះ (និ.) ដូចនេះ, យ៉ាងនេះ (ទោះបីសរសេរជា ដូចនេះ ក៏ត្រូវអានថា
ដូច-ច្នេះ ដែរ)ៗ

ដោយមង្គល សេចក្ដីចម្រើននឹងមានដល់ព្រះអង្គពុំខាន”។

ព្រះរាជាទ្រង់ត្រាស់សួរថា៖

“នឹងមានហេតុការណ៍អ្វីទៅ លោកអាចារ្យ?”

បណ្ឌិតសេនកៈ ក្រាបទូលថា៖

“បពិត្រមហារាជ អ្នកប្រាជ្ញបណ្ឌិតម្នាក់ទៀតជាគម្រប់ ៥ នឹងកើតឡើងគ្រប់សង្កត់ពួកទូលបង្គំ ដែលជាបណ្ឌិតទាំង ៤ ។ ទូលបង្គំទាំង ៤ នាក់ដូចជាគំនរភ្លើងទាំង ៤ ។ បណ្ឌិតម្នាក់ទៀតជាគម្រប់ ៥ ដែលនឹងកើតឡើងនោះ ដូចជាកូនដុំភ្លើងកើតឡើងនៅត្រង់កណ្ដាលភ្នក់ភ្លើងធំទាំង ៤ នោះអ៊ីចឹង។ បណ្ឌិតនោះពិតជាបុគ្គលពុំមាននរណាស្មើក្នុងលោក ព្រមទាំងទេវលោកឡើយ”។

ព្រះរាជាទ្រង់ត្រាស់សួរថា៖

“ចុះបណ្ឌិតនោះ ឥឡូវនេះគេនៅឯណា?”

សេនកបណ្ឌិត ក្រាបទូលដោយកម្លាំងប្រាជ្ញារបស់ខ្លួន ដូចមើលឃើញដោយភ្នែកទិព្វផ្ទាល់ថា៖

“បពិត្រមហារាជ ថ្ងៃនេះជាថ្ងៃដែលបណ្ឌិតនោះ ចាប់បដិសន្ធិ ឬប្រសូតចាកផ្ទៃម្ដាយ”។

ព្រះរាជាតែងតែរលឹកនូវទំនាយរបស់សេនកបណ្ឌិតតាំងពីគ្រានោះមក។

## ព្រះមហាសត្វច្យុតចាកឋានត្រៃត្រិង្ស

នៅត្រង់ទ្វារទាំង ៤ នៃក្រុងមិថិលានោះ មានស្រុក ៤ គឺបាចីនគ្រាម១ ទក្ខិណគ្រាម១ បច្ឆិមគ្រាម១ ឧត្តរគ្រាម១ ។ មានសេដ្ឋីម្នាក់ឈ្មោះថា **សិរីវឌ្ឍន៍** គាត់មានគេហដ្ឋាននៅក្នុងស្រុកបាចីនគ្រាមនោះដែរ។ ភរិយារបស់សិរីវឌ្ឍនសេដ្ឋីនោះ ឈ្មោះថា **សុមនទេវី**។ ក្នុងថ្ងៃនោះ ព្រះមហាសត្វទ្រង់ច្យុតចាកតាវត្តិង្ស ក្នុងវេលាដែលព្រះបាទវិទេហរាជទ្រង់យល់សុបិន ហើយចាប់បដិសន្ធិក្នុងផ្ទៃរបស់នាងសុមនទេវី។ ក្នុងវេលាជំណាលគ្នានោះ មានទេវបុត្រផ្សេងៗទៀតចំនួន ១.០០០ រូប ក៏បានច្យុតចាកតាវត្តិង្ស មកចាប់បដិសន្ធិក្នុងត្រកូលនៃសេដ្ឋីនិងអនុសេដ្ឋីជាលំដាប់ ក្នុងស្រុកជាមួយគ្នានោះដែរ។ ១០ ខែក្រោយមក នាងសុមនទេវីបានសម្រាលបុត្រមួយ ដែលមានសម្បុរដូចមាស[៥]។

## ព្រះមហាសត្វចេះនិយាយពេលប្រសូត

ក្នុងខណៈនោះ សក្កទេវរាជប្រមើលមើលមនុស្សលោក ជ្រាបដំណើរប្រសូតចាកផ្ទៃម្តាយរបស់ព្រះមហាសត្វហើយ ទ្រង់ព្រះតម្រិះថា៖

---

[៥] ស្ត្រីផ្សេងៗ ក្រៅពីម្តាយពោធិសត្វ តែងសម្រាលកូនមិនទាន់គ្រប់ ១០ ខែក៏មាន លើសពី ១០ ខែក៏មាន។ អបណ្ណកជាតកវណ្ណនា។

"គួរណាស់តែអញជួយជ្រោមជ្រែងពុទ្ធង្កុរនេះ ឲ្យល្បីរន្ទឺប្រាកដទូទៅក្នុងលោក ព្រមទាំងទេវលោក"។

ព្រះឥន្ទ្រត្រិះរិះដូច្នេះហើយ ទ្រង់បំបាំងកាយ យាងមកក្នុងខណៈដែលព្រះមហាសត្វកំពុងតែប្រសូតចាកផ្ទៃម្ដាយ ហើយទ្រង់ដាក់ឱសថមួយដុំទៅក្នុងបាតដៃរបស់ព្រះមហាសត្វ រួចក៏ទ្រង់យាងទៅកាន់ឋានរបស់ព្រះអង្គវិញ។

រីឯព្រះមហាសត្វ ទ្រង់កាន់ក្ដាប់ជាប់នូវឱសថនោះ។ ពេលព្រះមហាសត្វប្រសូតចាកផ្ទៃ ម្ដាយមិនមានការឈឺចុកចាប់បន្តិចបន្តួចឡើយ ទ្រង់ប្រសូតដោយស្រួល បីដូចទឹកហូរចេញអំពីធម្មក្រក[៦]។ ម្ដាយឃើញដុំឱសថក្នុងដៃរបស់ព្រះមហាសត្វ ទើបសួរថា៖

"នែកូន! កូនឯងបានអ្វីកាន់?"

"នេះជាឱសថអ្នកម្ដាយ!" ឆ្លើយដូច្នេះហើយ ព្រះមហាសត្វដាក់ឱសថទិព្វនោះទៅក្នុងដៃម្ដាយ ហើយប្រាប់ថា៖

---

[៦] គ្រឿងសមណបរិក្ខារមួយប្រភេទ រាងប៉ុនដបឬបំពង់ទឹកត្នោត ប្រើការដងទឹកកុំឲ្យដោយសត្វល្អិត បាតក្រោមដេរក្រណាត់ពាសបិទជុំវិញ កាលដាក់ចុះក្នុងទឹក ទឹកជ្រាប ចូលតាមក្រណាត់ពេញដប យកដៃចុកបិទរន្ធដបខាងលើ ហើយលើកឡើង ទឹកនឹងមិនធ្លាក់ លុះដកធ្នុកដៃចេញ ទឹកខាងក្នុងដបនឹងធ្លាក់ចុះ។

“បពិត្រអ្នកម្ដាយ សូមអ្នកម្ដាយយកឱសថនេះ ជូនដល់អ្នកជំងឺទាំងឡាយ ទោះពួកគេមានជំងឺអ្វីក៏ដោយ ក៏អាចព្យាបាលបានទាំងអស់”។

**ពិធីតាំងនាមព្រះមហាសត្ត**

ម្ដាយព្រះពោធិសត្វ មានអំណរក្នុងចិត្តឥតឧបមា បានជម្រាបសិរីវឌ្ឍនសេដ្ឋីឲ្យជ្រាបអំពីដំណឹងនោះ។ និយាយពីលោកសិរីវឌ្ឍនសេដ្ឋីវិញ គាត់មានជំងឺឈឺក្បាលត្រាំត្រែងមក ៧ ឆ្នាំហើយ ព្យាបាលពុំបានជាសះស្បើយសោះ។ គាត់ត្រេកអរណាស់ដោយនឹកថា “កូនដែលកើតចាកផ្ទៃម្ដាយ កាន់ថ្នាំនៅដៃ ថែមទាំងចេះនិយាយជាមួយនឹងម្ដាយក្នុងខណៈទើបតែកើតបែបនេះ គឺជាអ្នកមានបុណ្យដ៏អស្ចារ្យ។ ឱសថដែលអ្នកមានបុណ្យនាំមកបែបនេះ នឹងមានអានុភាពខ្លាំងពូកែជាមិនខាន”។ គិតដូច្នេះហើយ គាត់បានយកឱសថនោះដុសជាមួយនឹងថ្មសំលៀង[៧] លាបក្បាលបន្តិចលមើល។ ក្នុងខណៈនោះ រោគឈឺក្បាលរយៈពេល ៧ ឆ្នាំ របស់គាត់បែរជាមានសភាពធូរស្រាលឡះជាសះស្បើយរលីងធេងមួយរំពេច បីដូចទឹកធ្លាក់ពីស្លឹកឈូក។ គាត់មានសោមនស្សរីករាយណាស់ ហើយពោលថា៖

[៧] និសទាយំ ឃំសិត្វា។

“ឱ! ឱសថនេះមានអានុភាពពូកែខ្លាំងណាស់តើ”។

កាលល្បីអំពីដំណើរកើតមក យកឱសថជាប់មកជាមួយរបស់ព្រះមហាសត្តបានផ្សព្វផ្សាយជ្រួតជ្រាបទៅគ្រប់ទិសតំបន់។ មហាជនដែលមានជំងឺតម្កាត់ តែងនាំគ្នាទៅកាន់គេហដ្ឋានរបស់សិរីវឌ្ឍនសេដ្ឋី សូមនូវឱសថព្យាបាលជំងឺ។ មហាសេដ្ឋីសិរីវឌ្ឍនៈតែងតែដុសឱសថនឹងថ្មសំលៀងយកតែបន្តិច ហើយកូរលាយទឹកប្រគល់ឲ្យអ្នកជំងឺគ្រប់ៗគ្នា។

ពេលពួកគេយកឱសថទិព្វលាបខ្លួនប្រាណភ្លាម ជំងឺទាំងឡាយរមែងជាសះស្បើយ។ មហាជនទាំងឡាយដែលជាសះស្បើយ សុខស្រួលហើយ តែងតែពាំនាំសេចក្តីសរសើរទៅនិយាយប្រាប់អ្នកផងតៗគ្នាថា៖

“ឱសថក្នុងផ្ទះរបស់លោកសិរីវឌ្ឍនសេដ្ឋីមានអានុភាពពូកែសក្តិសិទ្ធិខ្លាំងណាស់”។

ក្នុងថ្ងៃតាំងនាមរបស់ព្រះមហាសត្ត មហាសេដ្ឋីបិតានិយាយថា៖

“ឈ្មោះរបស់កូនខ្ញុំ មិនចាំបាច់យកលំនាំតាមឈ្មោះជីតាឬឪពុកទេ សូមយកឱសថនេះជាឈ្មោះតែម្តង ពីព្រោះគេកើតមកកាន់ឱសថជាប់មកជាមួយ”

លុះសម្រេចដូច្នេះហើយ ទើបលោកសេដ្ឋីបានដាក់ឈ្មោះកូនគាត់ថា "**មហោសថ**" មានន័យថា អ្នកមានថ្នាំដ៏ពូកែសក្តិសិទ្ធិ។

**មហោសថកុមារនិងសម្លាញ់សាងមណ្ឌលកីឡា**

សិរីវឌ្ឍនសេដ្ឋី មានសេចក្តីត្រិះរិះដូច្នេះថា "កូនរបស់អញជាអ្នកមានបុណ្យច្រើន គេមិនមែនកើតតែម្នាក់ឯងទេ មុខតែមានទារកផ្សេងៗកើតរួមជាមួយនឹងកូនអញនេះពុំខាន"។ គិតដូច្នេះហើយ គាត់បានចាត់បម្រើឲ្យទៅស៊ើបដំណឹង អំពីអ្នកដែលមានកូនកើតនៅថ្ងៃដំណាលគ្នានឹងមហោសថ លុះដឹងពត៌មានថា មានក្មេង ១.០០០ នាក់កើតក្នុងថ្ងៃជាមួយនឹងមហោសថ គាត់បានផ្តល់នូវគ្រឿងប្រដាប់ជាច្រើនទៅឲ្យកុមារទាំងអស់នោះ និងផ្តល់មេដោះជាច្រើននាក់ទៅឲ្យផង សម្រាប់ជួយមើលការខុសត្រូវដល់កុមារទាំង ១.០០០ នាក់ដែលគាត់ស្រឡាញ់ដូចកូនបង្កើត។ សិរីវឌ្ឍនសេដ្ឋី បានរៀបចំធ្វើពិធីមង្គលបង្កក់កំណើតមហោសថកុមារព្រមទាំងកុមារទាំង ១.០០០ នាក់នោះផង។ សេដ្ឋីនិងអនុសេដ្ឋីទាំងឡាយបានតុបតែងកូនរៀងៗខ្លួន ហើយនាំមកឲ្យនៅបម្រើព្រះមហាសត្វ។ ព្រះពោធិសត្វតែងលេងកម្សាន្តជាមួយនឹងសម្លាញ់ទាំងឡាយនោះ លុះចម្រើនវ័យវឌ្ឍនាការឡើងដល់អាយុ ៧ ឆ្នាំ លោកមានរូបឆោមស្អាតផូរផង់ សម្បុរស្រស់សង្ហា បីដូចបដិមាមាស។

គ្រាមួយ ពេលដែលមហោសថកុមារ លេងកីឡាជាមួយនឹងមិត្តសម្លាញ់ទាំងឡាយនៅតាមវាលស្រែ ដីរនិងសេះជាដើម តែងតែមកអុកឡុក បណ្ដាលឲ្យពពួកក្មេងដែលលេងកីឡា ភ័យខ្លាច រត់ប្រសេចប្រសាចបែកគ្នាអស់។ ម្យ៉ាងទៀត ពួកក្មេងមានការលំបាកជាខ្លាំងក្នុងពេលដែលត្រូវខ្យល់និងកម្ដៅថ្ងៃ។ ក្នុងថ្ងៃមួយ ពួកគេកំពុងតែលេងកីឡា ស្រាប់តែមេឃក៏បង្អុរភ្លៀងចុះខុសរដូវ រំខានដល់ការលេងកីឡារបស់កុមារទាំងឡាយ។ ឃើញដូច្នោះ មហោសថកុមារពោធិសត្វមានកម្លាំងដូចនាគ ស្ទុះរត់ចូលទៅកាន់រោង។ ពួកកុមារផ្សេងៗទៀតដែលជាសម្លាញ់ បានស្ទុះរត់ទៅតាមពីក្រោយ ប្រទាក់ជើងគ្នាដួលត្រឡប់ត្រឡិនរបករលាត់បែកជង្គង់ បែកជើងបែកដៃជាដើម។ ចំណែកមហោសថកុមារគិតថា "យើងត្រូវសាងសង់មណ្ឌលកីឡាមួយខ្នងក្នុងទីនេះ ទើបគួរ ដើម្បីការពារខ្យល់ ភ្លៀង កម្ដៅថ្ងៃ កុំឲ្យរំខាន។ ធ្វើយ៉ាងនេះ ពួកយើងប្រាកដជាមិនលំបាកទៀតទេ"។ គិតដូច្នេះហើយ មហោសថបានប្រាប់ពួកមិត្រសម្លាញ់ទាំងអស់ថា "នែសម្លាញ់! ក្នុងទីនេះវាតែងមានខ្យល់ភ្លៀងនិងកម្ដៅថ្ងៃ រំខានដល់ការលេងរបស់ពួកយើង។ ដូច្នេះ ពួកយើងនឹងសាងសង់សាលាមួយខ្នងសម្រាប់សម្រាកផង ការពារខ្យល់ភ្លៀងនិងកម្ដៅថ្ងៃនោះផង។ សូមពួកអ្នកយកប្រាក់មួយកហាបណៈ

ម្នាក់ៗមកដើម្បីវិភាគទានក្នុងការសាងសង់មណ្ឌលកីឡា"។ ពួកសម្លាញ់របស់មហោសថ បានធ្វើតាមការណែនាំរបស់មហោសថ។

មហោសថកុមារ បានចាត់គេឲ្យទៅហៅជាងសំណង់ម្នាក់មកជួបរួចប្រគល់ប្រាក់ ១.០០០ កហាបណៈឲ្យហើយប្រាប់ថា "សូមលោកអ៊ំសង់សាលាមួយខ្នងក្នុងទីនេះឱ្យពួកខ្ញុំ"។ ជាងសំណង់យល់ព្រម ហើយទទួលប្រាក់ ១.០០០ កហាបណៈ រៀបចំដកជង្គត់បន្ទា ពង្រាបដីឲ្យស្មើ លាខ្សែវាស់តម្រឹមតម្រង់ខ្នាតសំណង់ដែលត្រូវសាងសង់។ មហោសថកុមារទាស់ចិត្តនឹងរបៀបវាស់វែងរបស់ជាងនោះណាស់ ក៏បន្តាប់ថា៖

"លោកមេជាងកុំវាស់ដូច្នេះ សូមវាស់ឲ្យល្អជាងនេះបន្តិច"។

មេជាងឆ្លើយថា៖

"លោកប្រុស ខ្ញុំវាស់ត្រឹមត្រូវតាមចំណេះវិជ្ជារបស់ខ្ញុំហើយ ការវាស់ប្លែកពីនេះទៀត ខ្ញុំមិនចេះទេ"។

មហោសថតបថា៖

"គ្រាន់តែប៉ុណ្ណឹងអត់ចេះទៅហើយ! តើលោកអ៊ំនឹងសាងសង់សាលាទាំងមូលដូចម្តេចកើត? សូមលោកអ៊ំយកខ្សែមកណោះ! ខ្ញុំនឹងវាស់បង្ហាញជូនលោកអ៊ំមើល"។

**សមិទ្ធផលរបស់មហោសថកុមារ**

មហោសថកុមារប្រើជាងឲ្យយកខ្សែមកហើយ ក៏ទាញវាស់តម្រង់ដោយខ្លួនឯងយ៉ាងស្ទាត់ជំនាញ ដូចជាការវាស់របស់ព្រះពិស្ណុការ[៨]។ មហោសថសួរថា៖

"តើលោកអ៊ំអាចវាស់បានយ៉ាងនេះទេ?"

"ខ្ញុំមិនអាចវាស់បានយ៉ាងនេះទេ?" ជាងឆ្លើយ។

មហោសថសួរ៖

"ចុះលោកអ៊ំអាចធ្វើតាមផែនការរបស់ខ្ញុំបានឬទេ?"

"ខ្ញុំអាច" ជាងឆ្លើយតប។

---

[៨] វិស្សកម្មទេវបុត្តស្ស បសារិតំ វិយ អហោសិ។ បាលីថា **វិស្សកម្ម** ខ្មែរយើងប្រើហៅឃ្លាតក្លាយទៅជា **ពិស្ណុការ** ដែលជានាមនៃទេវតាអ្នកមានចំណេះខាងការជាងជាអ្នកសម្រេចកិច្ចការថ្វាយព្រះឥន្ទ្រដែលធ្លាប់ហៅថា ព្រះវិស្សកម្មទេវបុត្រ។ ក្នុងប្រទេសខ្មែរយើងពួកជាងពីបុរាណច្រើនជឿថាទេវបុត្រនោះជាគ្រូធំលើជាងទាំងឡាយ ព្រោះហេតុនោះ បានជាក្នុងពេលសាងសង់ផ្ទះតែងរៀបរណ្ដាប់ជាទ្រនឹបជាង ឬ ទ្រនឹបគ្រូដោយប្រើពាក្យថា **រៀបព្រះពិស្ណុការ** គឺដើម្បីរលឹកដល់វិស្សកម្មទេវបុត្រដែលជាគ្រូជាងធំរបស់ព្រះឥន្ទ្រនោះឯង។

មហោសថកុមារបានឲ្យជាងសាងសង់មជ្ឈមណ្ឌលសង្គ្រោះមួយ ដែលមានសាលា ៥ ខ្នង គឺ

សាលាទី ១ សម្រាប់ជាលំនៅរបស់ជនអនាថា

សាលាទី ២ សម្រាប់ជាទីសម្រាលកូនរបស់ស្ត្រីអនាថា

សាលាទី ៣ សម្រាប់ជាលំនៅរបស់សមណព្រាហ្មណ៍អ្នកមកដល់ថ្មី

សាលាទី ៤ សម្រាប់ជាលំនៅរបស់មនុស្សអ្នកមកដល់ថ្មី

សាលាទី ៥ សម្រាប់ជាឃ្លាំងផ្ទុកផ្ញើទំនិញរបស់ពួកឈ្មួញអ្នកមកដល់ថ្មីៗ

បន្ទាប់មក មហោសថកុមារបានបញ្ជាឲ្យជាងសាងសង់សាលាធម្មសភាមួយខ្នង និងសាលាវិនិច្ឆ័យក្ដីមួយខ្នងៗ មហោសថកុមារចាត់ឲ្យហៅពួកជាងគំនូរមកជួប បញ្ជាដោយខ្លួនឯង ឲ្យពួកជាងគូររូបគំនូរដ៏ប្រណីតតាមជញ្ជាំង គួរជាទីពិតពិលរមិលមើល សាលានោះប្រៀបបាននឹង **សុធម្មាទេវសភា** នៅឋានត្រៃត្រិង្ស។

តពីនោះ មហោសថកុមារគិតថា "មិនមែនសាលាល្អដោយហេតុត្រឹមប៉ុណ្ណោះទេ គួរណាស់តែយើងជីកស្រះបោក្ខរណីមួយទៀត"។ គិតដូច្នេះហើយ មហោសថកុមារបានឲ្យគេទៅហៅជាងឥដ្ឋមកជួប រួចដាក់ផែនការឲ្យជាងជីកស្រះបោក្ខរណី ដែលមានកំពង់ចំនួន ១០០។ កំពង់

នីមួយៗ មានកាំជណ្ដើរចុះទៅ ១០ កាំ សរុប ១.០០០ កាំ[៩] សម្រាប់សាធារណជនប្រើប្រាស់ទឹកស្រះនោះ។ មហោសថកុមារបញ្ជាឲ្យពួកជាងដាំផ្កាបទុមទាំង ៥ ប្រភេទនៅក្នុងស្រះបោក្ខរណីនោះ។ លុះបញ្ចូលទឹកពេញហើយ ស្រះបោក្ខរណីនោះមានផ្ការីកស្គុះស្គាយដេរដាសហាក់ដូចជាស្រះបោក្ខរណីរបស់ទេពធីតាសុនន្ទានៅឋានត្រៃត្រិង្ស។ នៅតាមឆ្នេរស្រះនោះសោត មហោសថបានឲ្យដាំរុក្ខជាតិនានា ដែលមានផ្កាផ្លែ និងឲ្យសាងឧទ្យាន ដាំឈើផ្កាចម្រុះពណ៌ដ៏ស្រស់បំព្រង។ មហោសថកុមារបានរៀបចំចាត់ចែងការឲ្យទានជាប្រចាំ ដល់សមណព្រាហ្មណ៍អ្នកប្រកបដោយធម៌ និងដល់អ្នកដំណើរទៅមក ដែលចូលមកស្នាក់អាស្រ័យក្នុងសាលាថ្មីទាំងនោះ។ ការចាត់ចែងរបស់មហោសថនេះបានល្បីរន្ទឺទៅគ្រប់ទិសទី មនុស្សទាំងឡាយតែងមកជួបជុំគ្នាជាច្រើនចោមរោមមើល និងកោតសរសើរនូវស្នាដៃជាសមិទ្ធផលដ៏ចម្លែកនេះ។ ជារៀងរាល់ថ្ងៃ ព្រះមហាសត្វតែងអង្គុយក្នុងសាលា ណែនាំនូវការណ៍តូចការណ៍ធំ ការគួរនិងការមិនគួរដល់មនុស្សទាំងឡាយ ដែលមកដល់ថ្មីៗ និងតាំងការកាត់ក្ដីបីដូចសម័យព្រះពុទ្ធគង់នៅជាធរមានដូច្នោះដែរ។

[៩] សហស្សវង្កំ សតតិត្ថំ។

**ព្រះបាទវិទេហរាជស្វែងរកបណ្ឌិតទី ៥**

លុះពេលកន្លងទៅបាន ៧ ឆ្នាំ ព្រះបាទវិទេហរាជ ទ្រង់រលឹកឃើញថា "បណ្ឌិតទាំង ៤ បានប្រាប់អញថា នឹងមានបណ្ឌិតជាគម្រប់ ៥ កើតឡើងគ្របសង្កត់ពួកគេ តើបណ្ឌិតនោះ ឥឡូវនៅឯណាទៅហ្ន៎? លុះរលឹកដូច្នេះហើយ ព្រះអង្គចេញព្រះរាជបញ្ជាប្រើអាមាត្យ ៤ រូប ឲ្យទៅស្វែងរកលំនៅឋានរបស់បណ្ឌិតនោះ តាមទ្វារនគរទាំង ៤ ។

អាមាត្យទាំងឡាយ ដែលចេញទៅតាមទ្វារផ្សេងៗ រកមិនឃើញព្រះមហាសត្វទេ មានតែអាមាត្យដែលចេញទៅតាមទ្វារខាងកើតបាន រកឃើញលំនៅឋានរបស់ព្រះមហាសត្វ តាំងពីសាលាជាដើមឡើងទៅ ទើបគិតថា "អ្នកធ្វើសាលានេះ ទោះធ្វើដោយខ្លួនឯងក្តី ប្រើគេឲ្យធ្វើក្តី អ្នកនោះជាក់ជាបណ្ឌិតយ៉ាងពិតប្រាកដ"។ គិតដូច្នេះហើយ អាមាត្យក៏សួរមនុស្សទាំងឡាយថា៖

"សាលានេះជាងណាធ្វើ?"

មនុស្សទាំងឡាយប្រាប់ថា៖

"សាលានេះ ជាងធម្មតាមិនអាចធ្វើបានឡើយ អ្នកផ្តើមគំនិតធ្វើ គឺ មហោសថបណ្ឌិតកុមារ ជាកូនសិរីវឌ្ឍនសេដ្ឋីឯណោះទេ ដែលបញ្ជាឲ្យជាងធ្វើ ដោយដាក់ផែនការតាមកម្លាំងប្រាជ្ញារបស់ខ្លួនផ្ទាល់"។

"ចុះបណ្ឌិតនោះ មានអាយុប៉ុន្មានហើយ?" អាមាត្យសួរ។ មនុស្សទាំងឡាយប្រាប់ថា៖

"ឥឡូវ បណ្ឌិតកុមារមានអាយុគ្រប់ ៧ ឆ្នាំហើយ"។

អាមាត្យ បានរាប់ពេលដែលព្រះរាជាទ្រង់សុបិន មើលទៅយល់ឃើញថា "បណ្ឌិតនេះត្រូវគ្នានឹងសុបិននិមិត្តរបស់ព្រះរាជាមែន"។ ដូច្នេះគាត់ក៏បានបញ្ជូនទូតម្នាក់ឲ្យទៅក្រាបទូលព្រះរាជាថា៖

"បពិត្រព្រះសម្មតិទេព កូនប្រុសរបស់លោកសិរីវឌ្ឍនសេដ្ឋីក្នុងស្រុកបាចីនគ្រាម គឺពេញលក្ខណៈជាបណ្ឌិតពិតប្រាកដមែន។ កុមារនោះឈ្មោះ **មហោសថ** ឥឡូវអាយុ ៧ ឆ្នាំគត់ ប៉ុន្តែបើគេនៅក្មេង តែគេចេះចាត់ចែងការឲ្យជាងសាងសង់សាលាដ៏ប្រណីតព្រមទាំងស្រះបោក្ខរណី និងឧទ្យានដ៏ល្អវិចិត្របែបនេះ ទូលព្រះបង្គំជាខ្ញុំ នឹងនាំយកបណ្ឌិតកុមារនេះទៅគាល់ព្រះអង្គ"។

### សេនកបណ្ឌិតបដិសេធការនាំបណ្ឌិតទី ៥ ចូលព្រះរាជវាំង

ព្រះបាទវិទេហរាជ ទ្រង់ព្រះសណ្ដាប់នូវសេចក្ដីថ្លែងនោះហើយ មានព្រះហឫទ័យត្រេកអរណាស់ បង្គាប់ឲ្យគេទៅអញ្ជើញលោកបណ្ឌិតសេនកៈឲ្យមកគាល់ រួចព្រះអង្គទ្រង់ប្រាប់អំពីដំណើរនោះ ព្រមទាំងបានត្រាស់សាកសួរថា៖

"យើងនឹងនាំបណ្ឌិតនោះមកបានឬទេ?"

បណ្ឌិតសេនកៈហេតុតែជាមនុស្សកំណាញ់លោភ ក្រាបទូលជំទាស់ថា៖

“បពិត្រមហារាជ ដែលហៅថាបណ្ឌិតមិនមែនដោយហេតុត្រឹមតែជួលជាងឲ្យធ្វើសាលាជាដើមប៉ុណ្ណឹងទេ នរណាក៏អាចបញ្ជាឲ្យធ្វើសាលាជាដើមនោះបានដែរ ការនុ៎ះជារឿងតូចតាចណាស់”។

ព្រះបាទវិទេហរាជ ទ្រង់ព្រះសណ្ដាប់សម្ដីរបស់លោកបណ្ឌិតសេនកៈ រួចហើយទ្រង់គង់នៅស្ងៀម ដោយនឹកថា “ជាក់ជាមានហេតុការណ៍អ្វីក្នុងរឿងនេះពុំខាន”។ ដូច្នេះហើយទ្រង់បញ្ជូនទូតម្នាក់ត្រឡប់ទៅវិញ ឲ្យទៅជម្រាបអាមាត្យថា “ចូរអ្នកនៅទីនោះសិនចុះ ហើយត្រូវការសាកល្បងបណ្ឌិតនោះតទៅទៀត”។ រីឯអាមាត្យឮព្រះរាជបន្ទូលបង្គាប់ដូច្នោះ ក៏ស្នាក់នៅទីនោះ សាកល្បងបណ្ឌិតមហោសថកុមារតទៅទៀត។

# ជំពូកទី ២

## សត្តនារកបញ្ហា

### មហោសថកុមារអាយុ ៧ ឆ្នាំ ដោះប្រស្នា ៧ ខ

### ប្រស្នាទី ១ មំសបញ្ហា = ប្រស្នាខ្លែងពាំសាច់

*មានរឿងតំណាលថា ក្នុងថ្ងៃមួយ ពេលដែលមហោសថកុមារកំពុងតែធ្វើដំណើរទៅកាន់ទីលានកីឡា មានសត្វខ្លែងមួយលួចឆាបដុំសាច់អំពីជ្រញ់ ហើយពាំហើរយកទៅព្ធដ៏អាកាស។ សម្លាញ់មហោសថឃើញដូច្នោះហើយ ក៏នាំគ្នារត់ដេញតាមខ្លែង ដើម្បីឲ្យវាទម្លាក់ដុំសាច់នោះមកវិញ។ ចំណែកខ្លែងស្ទុះហើរទៅខាងនេះផង ទៅខាងនោះផង។ ក្មេងៗទាំងនោះ រត់ងើយទៅលើសម្លឹងមើលខ្លែង ដេញតាមពីក្រោមខ្លែងនោះ មិនបានមើលខាងក្រោម ក៏ជង់ទង្គិចចំថ្មនិងជន្ល់ត់ឈើជាដើម បណ្តាលឲ្យដួលក្រឡាប់ផ្កាប់ផ្ងារដួករណែលឈឺខ្លួនគ្រប់គ្នា។ គ្រានោះមហោសថកុមារប្រាប់ពួកមិត្តសម្លាញ់ថា៖*

*“ទុកឲ្យខ្ញុំដេញវាម្តង”។*

*“សូមដេញវាឲ្យទម្លាក់សាច់មក” ពួកសម្លាញ់និយាយ។*

*“បើអ៊ីចឹង ពួកអ្នកចាំតែមើលចុះ” មហោសថកុមារតប។*

និយាយដូច្នេះហើយ មហោសថកុមារពុំបានងើយមើលលើឡើយ ស្ទុះតាមពេញកម្លាំងជាន់ស្រមោលខ្លែង ទះដៃស្រែកយ៉ាងខ្លាំងៗ ដោយតេជះនៃមហោសថកុមារ សំឡេងនោះហាក់ដូចជាលាន់ទៅចាក់ត្រង់ពោះសត្វខ្លែង ខ្លែងនោះខ្លាចក៏ទម្លាក់ដុំសាច់ចុះមកៗ មហោសថកុមារក្រឡេកមើលស្រមោល ដឹងថាដុំសាច់ខ្លែងទម្លាក់ហើយ ក៏យកដៃទ្រទទួលដុំសាច់នោះពីអាកាស មិនឲ្យធ្លាក់ដល់ដីទាន់ឡើយៗ មនុស្សម្នាដែលមូលមីរគ្នាតាមមើល លុះឃើញដំណើរអស្ចារ្យដូច្នោះ ក៏នាំគ្នាស្រែកហ៊ោកញ្ជ្រៀវទះដៃឮកងរំពងទ្រហឹងអឹងអាប់ៗ អាមាត្យដែលនៅចាំឃ្លាំមើល ដឹងនូវពត៌មាននោះក៏បញ្ជូនទូតឲ្យទៅរាយការណ៍ថ្វាយចំពោះព្រះអង្គថា៖

"មហោសថកុមារជាបណ្ឌិត បានប្រើឧបាយនេះធ្វើឲ្យខ្លែងទម្លាក់ដុំសាច់ៗ សូមព្រះសម្មតិទេព មេត្តាទ្រង់ជ្រាបនូវរឿងនេះ"ៗ

រីឯព្រះបាទវិទេហៈ លុះទ្រង់ព្រះសណ្ដាប់នូវសេចក្ដីរាយការណ៍នោះហើយស្ដេចទ្រង់សួរទៅអាចារ្យសេនកៈថា៖

"បពិត្រអាចារ្យសេនកៈ សូមលោកមានប្រសាសន៍មកមើល តើពេលនេះល្មមយើងទៅនាំមហោសថកុមារ មកតាំងតំណែងជារាជបណ្ឌិតក្នុងរាជវាំងបានហើយឬយ៉ាងណា?"

អាចារ្យសេនកៈគិតថា "កាលបើ មហោសថនោះមកនៅទីនេះ ព្រះរាជានឹងលែងស្គាល់នូវអត្ថិភាពរបស់អញ ពួកអញនឹងលែងមានពន្លឺរស្មីតទៅទៀតហើយ ដូច្នេះមិនគួរទៅយកមហោសថមកទេ ព្រោះមហោសថនេះជាគ្រោះថ្នាក់ដ៏ធំរបស់អញ នឹងអាចបាត់លាភបាត់យសរបស់អញ"។ មានគំនិតដូច្នេះហើយ សេនកៈក៏ក្រាបទូលបដិសេធដោយមច្ឆរិយភាពដ៏ខ្លាំងក្នុងលាភ ចំពោះព្រះរាជាថា៖

"បពិត្រមហារាជ ដោយហេតុត្រឹមប៉ុណ្ណឹង នឹងហៅថាជាបណ្ឌិតមិនទាន់បានទេ ព្រោះគ្រាន់តែចេះបង្អើលសត្វខ្លែងឲ្យទម្លាក់ដុំសាច់នោះ ជាចំណេះកំប៉ិកកំប៉ុក តិចតួចស្តួចស្តើងណាស់"។

ព្រះរាជាទ្រង់នៅជាកណ្តាលមិនល្អៀងទៅខាងណា ហើយទ្រង់បញ្ជូនទូតទៅប្រាប់អាមាត្យថា "សូមលោករង់ចាំល្បងកុមារមហោសថក្នុងទីនោះតទៅទៀតសិនចុះ"។

**ប្រស្នាទី ២ គោណបញ្ហា = ប្រស្នាចោរលួចគោ**

មានរឿងតំណាលថា មានបុរសម្នាក់មានលំនៅឋានក្នុងស្រុកបាចីនគ្រាមជាមួយនឹងមហោសថនោះដែរ។ ក្នុងរដូវវស្សា មានភ្លៀងធ្លាក់ បុរសនោះ គិតថានឹងភ្ជួររាស់ស្រែ ក៏ទៅទិញគោមួយនឹមពីក្នុងស្រុកមួយនៅជិតនោះ ដឹកមកដល់ផ្ទះបានមួយយប់។ ដល់ព្រឹកឡើង បុរសនោះក៏

ដេញគោទៅឃ្វាលឯវាលដែលសម្បូរស្មៅបៃតងខ្ចី គាត់ឡើងជិះលើខ្នងគោ កាលអស់កម្លាំង ក៏ចុះមកដេកសម្រាកនៅក្បែរគល់ឈើមួយ។ ខណៈពេលគាត់កំពុងដេកលក់ស៊ប់ ស្រាប់តែមានចោរម្នាក់ លួចដឹកគោបំបោលយកទៅបាត់។ ម្ចាស់គោភ្ញាក់ឡើង រកមើលគោមិនឃើញ ក្រឡេកមើលនាយអាយ ស្រាប់តែប្រទះឃើញចោរកំពុងតែដេញគោបំបោលជើហុយទ្រលោមឯនាយ គាត់រត់ដេញតាមយ៉ាងពេញទំហឹង ស្រែកសួរបណ្ដើរថា៖

"អាឯងដេញគោអញទៅឯណាហ:?[10]"

លុះតាមទៅទាន់ ស្រាប់តែចោរប្រាប់បុរសនោះវិញថា៖

"អញដេញគោអញ ទៅកន្លែងដែលអញចង់ទៅទេវ៉ុយ[11]"។

ជនទាំងពីរនាក់ ឈ្លោះប្រកែកគ្នាប្រកាន់ថាជាម្ចាស់គោរៀងៗខ្លួន។ មហាជនឮទំនាស់នោះ ក៏នាំគ្នាមកចោមរោមមើល។

---

[10] ហ: ( និ. ) ឬ :ដូច្នោះទេហ: ?, ឯណោះទេហ: ?។ អេះ ?; (ព. សា. អ៊ីចេះ ? ; មាតាបិតាត្រូវសង្គ្រោះបុត្រធីតាដោយស្មានប៉ុន្មានយ៉ាងហ:អ្នក ? (ប្រើក្នុងការទេសនាបុច្ឆា-វិស្សជ្ជនា)។

[11] វ៉ឺយ ( និ. ) ពាក្យអាលបន:សម្រាប់និយាយទៅរកកូនក្មេងសាមញ្ញឬសម្រាប់មនុស្សដែលត្រូវប្រើពាក្យ អញ, ឯង ទៅរក : វ៉ឺយកនយើង !; នែវ៉ឺយ កុំលេងវ៉ឺយ !... (ប្រើពាក្យ វ៉ី ជាជំនួសក៏មាន)។

ម្ចាស់គោ និងចោរ ដើរបណ្ដើរប្រកែកគ្នាបណ្ដើររហូតបានចូលទៅដល់ទ្វារសាលាក្ដីរបស់មហោសថកុមារ។ គាប់ជួន មហោសថបានឮសំឡេងនោះ ក៏ហៅអ្នកទាំងពីរឲ្យចូលមកជួប។ គ្រាន់តែក្រឡេកមើលអាកប្បកិរិយារបស់អ្នកទាំងពីរភ្លាម មហោសថក៏ដឹងថា "អ្នកនេះ ជាចោរ អ្នកនេះ ជាម្ចាស់គោស្រេចទៅហើយ"។ ទោះបីដឹងយ៉ាងនេះក្ដី មហោសថកុមារធ្វើជាសួរថា៖

"តើពួកអ្នកឈ្លោះគ្នា ព្រោះរឿងអ្វី?"

ម្ចាស់គោនិយាយថា៖

"បពិត្រលោកប្រុស គោមួយនឹមនេះ ខ្ញុំបាទបានទិញអំពីដៃម្ចាស់គេនៅស្រុកឯណោះ ទើបតែនាំមកដល់ផ្ទះបានមួយយប់ ហើយក៏ដេញមកឃ្វាលនៅឯវាលសម្បូរស្មៅនោះ បុរសនេះឃើញការប្រហែស[១២]ធ្វេសរបស់ខ្ញុំនៅទីនោះ គេក៏លួចដេញបំបោលគោខ្ញុំយកទៅ ខ្ញុំក្រឡេកមើលឯណេះឯណោះ ប្រទះឃើញគេហើយ ក៏រត់ដេញតាមដើម្បីចាប់គោខ្ញុំយកមកវិញ ពួក

---

[១២] ប្រហែស (កិ.) ធ្វេសស្មារតី, មិនសូវប្រយ័ត្ន, បណ្ដែតបណ្ដោយ។ ប្រហែសធ្វេស ឬ ធ្វេសប្រហែស បណ្ដែតបណ្ដោយមិនសូវនឹកនា។ ពាក្យទំនឹម បុរាណបានថែងថា ប្រហែសបាត់ប្រយ័ត្នគង់ តែប្រហែស រមែងតែបាត់ បើប្រយ័ត្នតែងតែគង់។

អ្នកស្រុកឯណោះ អ្នកណាមួយក៏ជឿដឹងឮដែរថា ខ្ញុំបានទិញគោ
ទាំងនេះពិតប្រាកដមែន”

ចំណែកចោរនិយាយថា៖

“គោទាំងនេះ កើតនៅផ្ទះរបស់ខ្ញុំទេ បុរសនេះនិយាយកុហក!”

គ្រានោះ មហោសថបណ្ឌិតសួរទៅអ្នកទាំងពីរថា៖

“ខ្ញុំនឹងកាត់ក្ដីឲ្យពួកអ្នកដោយយុត្តិធម៌ តើពួកអ្នកយល់ព្រមឲ្យខ្ញុំ
កាត់ក្ដីនេះឬទេ?”

ជនទាំងពីរនាក់យល់ព្រមថា៖

“បាទ លោកប្រុស! ពួកយើងនឹងយល់ព្រមឲ្យលោកប្រុស
វិនិច្ឆ័យរឿងក្ដីនេះ”

មហោសថគិតថា “គួរណាស់តែឲ្យមហាជនជួយដឹងជួយឮផង”

ទើបសួរទៅចោរជាមុនថា៖

“តើអ្នកឲ្យគោទាំងនេះ ស៊ីអ្វី? ផឹកអ្វី?”

ចោរឆ្លើយថា៖

“ខ្ញុំឲ្យវាហុតបបរនិងឲ្យវាស៊ីម្សៅលាយគ្រាប់ល្ងនិងសណ្ដែក”

បន្ទាប់មក មហោសថសួរទៅបុរសជាម្ចាស់គោម្ដងៗ

បុរសម្ចាស់គោនោះឆ្លើយថា៖

“លោកប្រុសអើយ ខ្ញុំជាមនុស្សក្រមុ្សត់ទុគ៌ត នឹងបានបបរជាដើម ពីណាឲ្យគោស៊ី គោរបស់ខ្ញុំ ខ្ញុំឲ្យស៊ីតែស្មៅប៉ុណ្ណោះ”។

មហោសថបណ្ឌិត ប្រាប់មនុស្សម្នាជុំវិញនោះ ឲ្យជួយចាំសម្ដី របស់ជនទាំងពីរដោយយកចិត្តទុកដាក់។ បន្ទាប់មក មហោសថប្រើ សម្លាញ់ខ្លួនឲ្យទៅបេះបូតស្លឹកប្រយង្គុ[១៣] មកបុកឲ្យម៉ដ្ឋប្រេបាច់លាយទឹក ហើយប្រកឲ្យគោផឹកចូលទៅក្នុងពោះ។ មួយស្របក់ក្រោយមក គោ ទាំងពីរនោះក៏ក្អួតចេញមកសុទ្ធតែស្មៅ។ មហោសថបណ្ឌិតបង្ហាញ មហាជនថា៖

“ពួកអ្នកឃើញទេ នេះជាអ្វី?”

រួចមហោសថសួរទៅចោរថា៖

“តើអ្នកជាចោរ ឬមិនមែនចោរទេ?”

“បាទលោកប្រុស ខ្ញុំជាចោរលួចគោគេមែន” ចោរសារភាព។

មហោសថបណ្ឌិត ផ្ដល់ដំបូន្មានថា៖

“បើអ៊ីចឹង ពីពេលនេះទៅ ចូរអ្នកកុំធ្វើអំពើថោកទាបនេះទៀត”។

---

[១៣] ឈ្មោះឈើតូចពួកមួយ មានផ្កាជាចង្កោមកម្រងល្អិតៗ សម្បុរលឿងក្លិនក្រអូប ឆ្ងាញ់ ប៉ុន្តែក្រអូបស្បើយ មាន ២ ប្រភេទគឺ ប្រយង្គុធំ ស្លឹកស្រដៀងនឹងស្លឹកឈើ កែវ ប្រយង្គុតូច ស្លឹកតូចៗ។

ចំណែកឯមនុស្សម្នានៅជុំវិញមហោសថ ទ្រាំទប់កំហឹងមិនបាន ក៏វាយដំប្រចំធាក់ចោរនោះម្នាក់មួយដៃ មួយជើង មួយកែង បណ្ដាលឲ្យគេទ្រោមកម្លាំងជាខ្លាំង។ គ្រានោះមហោសថនិយាយនឹងចោរថា៖

"ក្នុងបច្ចុប្បន្ន អ្នកបានរងសេចក្ដីទុក្ខឈឺផ្សា[១៤]ប៉ុណ្ណេះ ចំណែកក្នុងបរលោក អ្នកនឹងសោយមហាទុក្ខធំធេងជាងនេះទៅទៀត មានទុក្ខក្នុងនរកជាដើម។ ម្នាលសម្លាញ់ពីថ្ងៃនេះតទៅ ចូរអ្នកលះបង់អំពើល្មួច[១៥]ចោរកម្មនេះចោលចុះ"។

ទូន្មានដូច្នេះហើយ មហោសថកុមារ ក៏ណែនាំឲ្យចោរនោះរក្សាសីល ៥ ដរាបរៀងទៅ ហើយដោះលែងឲ្យគេមានសេរីភាពវិញ។ និយាយពី លោកអាមាត្យដែលនៅចាំឃ្លាំមើលស្ថានការណ៍នៅទីនោះ បានបញ្ជូនទូតឲ្យទៅរាយការណ៍អំពីព្រឹត្តិការណ៍ថ្មីនេះ ថ្វាយចំពោះព្រះមហាក្សត្រវិទេហរាជ ដើម្បីទ្រង់ជ្រាបតាមការពិត។ រីឯព្រះបាទ

---

[១៤] សទិសសូរគឺផ្សារ ន័យខុសគ្នាគឺ ផ្សា ឈឺចុកពឹតរោលរាល។ ផ្សារ ជានាម សំដៅទីប្រជុំលក់ទំនិញ, ជាកិរិយា ភ្ជាប់ភ្ជិតដោយទឹកបន្សារ។

[១៥] **ល្មួច** មកពីពាក្យ លួច ផ្នត់ដែកទម្រង់ពចុះម ក្លាយរូបជា ល្មួច។ ពាក្យខ្មែរទម្រង់ពចុះមដូច្នេះ ច្រើនសម្គាល់ជាការកនាម គឺនាមរបស់មនុស្ស។ ឆ្មាំ អ្នកចាំ, ឈ្មួញ អ្នកជួញ, ខ្មាន់ អ្នកកាន់, ល្មោភ អ្នកលោភ, ល្មួច អ្នកលួច។ **អំពើល្មួច** គឺ អំពើរបស់អ្នកលួច ស្មើនឹងពាក្យ ចោរកម្ម អំពើរបស់ចោរអ្នកលួចដូចគ្នា។

វិទេហៈ លុះទ្រង់ព្រះសណ្ដាប់នូវសេចក្ដីរាយការណ៍នោះហើយ ទ្រង់ស្ដេចសួរទៅអាចារ្យសេនកៈថា៖

“បពិត្រអាចារ្យសេនកៈ សូមលោកមានប្រសាសន៍មកមើល តើយើងល្មមទៅនាំយកមហោសថកុមារ មកតែងតាំងតំណែងជារាជបណ្ឌិត ក្នុងវាំងបានហើយឬនៅ?”

អាចារ្យសេនកៈក្រាបទូលថា៖

“បពិត្រមហារាជ សត្វបើរឿងក្ដីគោ នរណាមួយក៏គេចេះវិនិច្ឆ័យដែរ សូមទ្រង់រង់ចាំមើលបន្តិចសិនក្រាបទូល”។

ព្រះរាជាព្រះអង្គ ទ្រង់ដាក់ព្រះទ័យជាកណ្ដាល ហើយបញ្ជូនដំណឹងទៅលោកអាមាត្យឲ្យរង់ចាំសម្គាល់មើលតទៅទៀត។

**កំណត់ចំណាំ**

អ្នកសិក្សា គប្បីជ្រាបយ៉ាងនេះ គ្រប់កន្លែងផង ដ្បិតថាពីនេះទៅមុខ យើងគ្រាន់តែលើកយកសាច់រឿងមួយៗ មកតំណាលតាមមាតិកាប៉ុណ្ណោះ ពុំមានអធិប្បាយលម្អិតអំពីការទាក់ទងរវាងអាមាត្យអ្នកស៊ើបអង្កេតនឹងព្រះបាទវិទេហរាជ ដូចរឿងមុនៗទៀតទេ។

**ប្រស្នាទី ៣ គន្លឹបញ្ញា = ស្ត្រីលួចសង្វារ**[១៦]

មានរឿងតំណាលថា ស្ត្រីទុគ៌តម្នាក់យកអំបោះ ដែលមានពណ៌ផ្សេងៗ មកចងធ្វើជាសង្វារពាក់ក។ វេលាមួយ នាងត្រូវការងូតទឹក ក៏ដោះសង្វារអំបោះនោះចេញ អំពីកដាក់ទុកលើសំពត់ រួចចុះទៅកាន់ស្រះបោក្ខរណីដែលសាងដោយមហោសថកុមារនោះឯង។ ពេលនោះ មានស្រីក្រមុំម្នាក់ទៀតឃើញសង្វារនោះ ហើយមានសេចក្តីលោភលន់ចង់បាន ក៏ចាប់លើកមើល ហើយធ្វើជានិយាយថា៖

"មីងអើយមីង សង្វារនេះល្អអ្វីម្ល៉េះទេ! មីងធ្វើដោយអ្វី? ខ្ញុំចង់ធ្វើសង្វារបែបហ្នឹងសម្រាប់ខ្លួនខ្ញុំដែរ។ ខ្ញុំសូមពាក់របស់មីង មើលបន្តិច តើវាល្មមសមកខ្ញុំឬទេ?"

ស្ត្រីម្ចាស់សង្វារ ហេតុតែខ្លួនមានចិត្តស្មោះត្រង់ ស្រែកប្រាប់ទៅថា៖

"ក្មួយអើយ លវាមើលចុះ មិនអីទេ"។

ស្ត្រីក្រមុំនោះ លុះតែបានពាក់ដល់កខ្លួនហើយ ទំដើរចេញយ៉ាងលឿនតែម្តង។ ស្ត្រីម្ចាស់សង្វារ លុះឃើញដូច្នោះ ក៏រលះរលាំងឡើងពីស្រះមកយ៉ាងរហ័ស ស្លៀកសំពត់ប្រញឹកប្រញាប់រត់ដេញតាម

---

[១៦] សង្វារ សង់វ៉ា ស. (ន.) (ស័ងវាល អ. ថ. --វ៉ាន) ខ្សែវិចិត្រមួយបែបសម្រាប់ពាក់ឆៀង ប្រើជាគ្រឿងប្រដាប់កាយ : ពាក់សង្វារ។

ស្រែកដង្ហោយហៅថា៖

"ហានឯងយកសង្វារអញរត់ទៅឯណា?"

លុះតាមទៅទាន់ហើយ ត្រូវនាងក្រមុំនោះនិយាយប្រកែកថា៖

"ខ្ញុំមិនបានយករបស់មីងទេ តែនៅនឹងកខ្ញុំ វាជារបស់ខ្ញុំ"។

មនុស្សម្នាឮដូច្នោះក៏មកចោមរោមមើល។ រីឯមហោសថកុមារ កំពុងតែលេងកីឡាជាមួយនឹងកុមារទាំងឡាយជាមិត្តសម្លាញ់ បានឮសំឡេងរបស់ស្ត្រីពីរនាក់ដែលដើរចូលទៅតាមទ្វារសាលាឈ្លោះគ្នា ក៏សួរថា "សំឡេងរបស់នរណាហ្នឹង?" លុះដឹងពីហេតុការណ៍ទំនាស់របស់ស្ត្រីពីរនាក់ ក៏ប្រើគេឲ្យទៅហៅស្ត្រីទាំងពីរនាក់នោះ ឲ្យចូលមកជួប គ្រាន់តែសង្កេតតាមអាការៈ មហោសថកុមារក៏ដឹងច្បាស់ថា ស្ត្រីណាជាចោរ ស្ត្រីណាមិនមែនចោរភ្លាមដោយឥតសង្ស័យ។ ទោះជាដឹងយ៉ាងនេះក្តី មហោសថនៅតែសួរបញ្ជាក់អំពីជំលោះរឿងឈ្លោះគ្នានោះដោយនិយាយថា៖

"ខ្ញុំនឹងវិនិច្ឆ័យឲ្យបងនិងមីង ដោយយុត្តិធម៌ តើបងនិងមីងយល់ព្រមឲ្យខ្ញុំវិនិច្ឆ័យឬទេ?"

ស្ត្រីទាំងពីរនាក់ក៏យល់ព្រមឲ្យមហោសថកុមារវិនិច្ឆ័យក្នុងរឿងក្តីនេះ។ មហោសថបណ្ឌិតសួរស្រីចោរជាមុនថា៖

"កាលដែលបងធ្វើនូវសង្វារនេះ តើបងបានអប់នូវក្លិនអ្វី?"

ស្ត្រីក្រមុំជាចោរឆ្លើយថា៖

"សង្វារនេះ ខ្ញុំបានអប់ដោយទឹកអប់ដែលធ្វើពីក្លិនផ្កាគ្រប់មុខ"។

តមក មហោសថសួរទៅមីងដែលត្រូវជាម្ចាស់សង្វារម្តង។ ស្ត្រីនោះប្រាប់ថា៖

"លោកប្រុសអើយ នាងខ្ញុំជាស្ត្រីក្រីក្រ តើនឹងបានទឹកអប់ចម្រុះក្លិនគ្រប់មុខមកពីណា? សង្វាររបស់ខ្ញុំនេះ គឺខ្ញុំអប់តែក្លិនផ្កាប្រយង្គុជានិច្ចកាលប៉ុណ្ណោះ"។

ឯមហោសថ ប្រើគេឲ្យទៅយកថាសទឹក រួចដាក់សង្វារនោះទៅក្នុងថាសទឹក ហើយឲ្យគេទៅអញ្ជើញជាងផលិតទឹកអប់មកប្រាប់ថា៖

"សូមពូជាងទឹកអប់ ជួយហិតក្លិននេះមើល តើវាជាក្លិនអ្វី?"

ជាងទឹកអប់ដាក់ប្រមុះស្រង[១៧]ក្លិនទៅ ដឹងថាក្លិនផ្កាប្រយង្គុក៏ជម្រាបមហោសថកុមារថា៖

"មិនមានក្លិនទឹកអប់ទេ ក្លិនដែលភាយចេញមកនេះ គឺជាក្លិនផ្កាប្រយង្គុសុទ្ធសាធ។ នាងក្រមុំនេះនិយាយមិនពិតទេ ឯស្ត្រីវ័យចំណាស់នោះ ទើបនិយាយការពិត"។

---

[១៧] ស្រងក្លិន គឺហិតរកក្លិន។ កុំប្រើឬនិយាយថា ស្រង់ក្លិន ពីព្រោះស្រង់ មានន័យថា លើកយកឲ្យផុតអំពីទឹកទេ ឧ. ស្រង់ក្មេងលង់ទឹក។

មហោសថកុមារ ធ្វើឲ្យមហាជនដឹងអំពីហេតុការណ៍នោះយ៉ាងនេះ ហើយសួរទៅស្ត្រីក្រមុំថា៖

"តើបងជាចោរ ឬមិនមែនជាចោរទេ?"

ស្ត្រីក្រមុំនោះ ក៏សារភាពចំពោះមុខមហាជនឲ្យដឹងថាខ្លួនជាចោរមែន។

តាំងពីគ្រានោះមក កិត្តិសព្ទនៃភាពជាបណ្ឌិតរបស់មហោសថ បានល្បីល្បាញខ្ចរខ្ចាយ លាន់ឮកាន់តែប្រាកដខ្លាំងឡើងៗគ្រប់ទិសទី។

**ប្រស្នាទី ៤ សុត្តំ = ស្ត្រីលួចអំបោះ**

មានរឿងតំណាលថា ស្ត្រីអ្នកចាំចម្ការកប្បាសម្នាក់ កាលកំពុងនៅយាមចម្ការ ក៏ជ្រើសរើសយកកប្បាសណាល្អៗ ដែលជ្រុះរោយរាយនៅទីនោះ មករវៃធ្វើជាអំបោះដ៏សុខុមបានមួយហុង។ កាលដែលនាងកណ្ដៀតកញ្ច្រែងអំបោះដើរមកផ្ទះ បានដើរកាត់មកតាមឆ្នេរស្រះបោក្ខរណីរបស់មហោសថកុមារ គិតថានឹងចុះងូតទឹកឲ្យត្រជាក់សិន ក៏ដោះសម្លៀកបំពាក់ចេញ ហើយដាក់ហុងអំបោះទុកលើមាត់ស្រះបោក្ខរណី ហើយចុះងូតទឹក។ មានស្ត្រីម្នាក់ទៀតដើរមក ឃើញហុងអំបោះនោះ ហេតុតែមានចិត្តល្មោភ ក៏កាន់យកហុងអំបោះមើល ហើយនិយាយថា៖

“ឱអំបោះនេះ ជាទីពេញចិត្តអ៊ីម្ល៉េះ! មីងអីយមីងអ្នកធ្វើអ៊្អី?[១៨]”

ស្ត្រីនោះធ្វើជាចាប់មើលចុះមើលឡើងស្រោប់តែកណ្ដៀតកញ្ច្រែង អំបោះ ដើរចេញទៅធ្វើព្រងើយៗ លុះស្ត្រីម្ចាស់ឃើញដូច្នោះ ក៏មាន ការឈ្លោះប្រកែកគ្នា រហូតនាំរឿងរ៉ាវដល់សាលាក្ដីរបស់មហោសថ កុមារ[១៩]ៗ មហោសថសួរស្ត្រីចោរមុនថា៖

“កាលនាងធ្វើហុងអំបោះ តើបានដាក់អ្វីនៅខាងក្នុង?”

“ខ្ញុំដាក់គ្រាប់កប្បាស លោកប្រុស” ស្ត្រីចោរឆ្លើយៗ

បន្ទាប់មក មហោសថសួរស្ត្រីដែលជាម្ចាស់ហុងអំបោះម្ដងៗ

“ខ្ញុំដាក់គ្រាប់ទន្ទាប់” ស្ត្រីម្ចាស់អំបោះឆ្លើយៗ

---

[១៨] ពាក្យ អ៊្អីនិងអ្ហ៎ះ ជានិបាតដូចគ្នា តែន័យខុសគ្នា អ៊្អីមានន័យថាឬ? ឧ. ម៉េច មិនទៅទេអ៊្អី? = ម៉េចមិនទៅទេឬ?, ក្រែងមានបម្រាមមិនឲ្យចូលតាមទ្វារហ្នឹងទេអ៊្អី?, មិនដឹងទេអ៊្អី? ក្រែងហ្នឹងហើយអ៊្អី? មីងអ្នកធ្វើអ៊្អី = មីងអ្នកធ្វើឬ? ។ រីឯពាក្យ អ្ហ៎ះ! (ទិ.សា.) ជាពាក្យឆ្លើយគ្នាឬឆ្លើយហើយសួរត្រឡប់ទៅវិញដោយសង្ស័យ ឧ. អ្ហ៎ះ! ថាម៉េច?, អ្ហ៎ះ! ថាអី?, សម្រាប់សរសេរក្នុងសេចក្ដីដែលមានទំនងត្រូវប្រើ សំឡេង សាមញ្ញៗ

[១៩] ត្រង់នេះយើងប្រែទុកជាសេចក្ដីដូច្នេះ ព្រោះមានបាលីថា សេសំ បុរិមនយេនេវ វិត្ថារេតព្វំ។ ប្រែថា ន័យផ្សេងៗ សូមអ្នកអានគប្បីជ្រាបពិស្ដារទៅតាមន័យមុនៗ

មហោសថ ប្រាប់មនុស្សម្នានៅជុំវិញឲ្យជួយចាំសម្ដីរបស់ស្ត្រីទាំងពីរ។ កាលដែលរុះហុងអំបោះមើលទៅ ស្រាប់តែឃើញគ្រាប់ទន្ទាប់ មហោសថកុមារ ក៏សួរសេង្កត់សង្កិនឲ្យស្ត្រីជាចោរនោះ ព្រមសារភាពថាខ្លួនជាចោរពិតប្រាកដមែន។ មហាជនដែលមកជួបជុំនោះសប្បាយត្រេកអរថា “រឿងក្ដីនេះវិនិច្ឆ័យបានល្អណាស់” ហើយនាំគ្នាទះដៃជូនពរសព្ទសាធុការដល់មហោសថកុមារ យ៉ាងកងរំពងគ្រប់ៗគ្នា។

**ប្រស្នាទី ៥ បុត្តោ = យក្ខិនីបន្លំលួចកូន**

មានរឿងតំណាលថា ថ្ងៃមួយ មានស្ត្រីម្នាក់បីកូនទៅកាន់ស្រះបោក្ខរណីរបស់មហោសថបណ្ឌិត ដើម្បីលុបលាងមុខ លុះផ្ងូតទឹកកូនហើយ នាងបានដាក់កូននោះឲ្យអង្គុយលើសំពត់សាដករបស់ខ្លួន ឯខ្លួនឯងដើរចុះទៅស្រះដើម្បីលុបលាងមុខមាត់។ ក្នុងខណៈនោះ យក្ខិនីមួយឃើញទារកនោះ ស្រក់ទឹកមាត់ប្រោកចង់ស៊ីសាច់មនុស្ស ក៏ប្រែកាឡាភេទជាស្រីម្នាក់មកសួរម្ដាយទារកថា៖

“អ្នកអើយអ្នក ទារកនេះល្អអ្វីម៉្លេះ! គាត់ជាកូនរបស់អ្នកមែនឬ?”

“ចាសអ្នក” ម្ដាយទារកឆ្លើយតបដោយសុភាពរាបសា។

“ខ្ញុំនឹងឲ្យគាត់ផឹកទឹក” យក្ខិនីនិយាយ។

“ឲ្យគាត់ផឹកចុះនាង” ម្ដាយទារកឆ្លើយតប។

យក្ខិនីនោះចាប់បីទារកនោះ បន្លំងលេងបានតែបន្តិច ក៏បីរត់ទៅយ៉ាងលឿនៗ ម្ដាយទារកឃើញដូច្នោះ ស្ទុះរត់ទៅចាប់ស្ដីឲ្យថា៖

"ហាងឯង នាំកូនរបស់អញទៅឯណា?"

យក្ខិនីនិយាយថា៖

"វានេះជាកូនហាងឯងពីអង្កាល់? នេះជាកូនរបស់អញទេតើ"ៗ

កាលដែលស្ត្រីទាំងពីរ ប្រឈ្លោះគ្នាយ៉ាងនេះ ក៏ដើរចូលទៅតាមទ្វារសាលាក្ដីៗ មហោសថបណ្ឌិត ឮសំឡេងឈ្លោះគ្នានោះ ក៏ប្រើគេឲ្យទៅហៅពួកនាងមកសួរថា "តើមានរឿងអ្វី?" ស្ត្រីទាំងពីរនាក់បានប្រាប់ដំណើរដើមទងនោះ ដល់មហោសថឲ្យលោកបានជ្រាបៗ មហោសថដឹងថា "ស្ត្រីមួយនេះជាយក្ខិនី" ព្រោះកត់សម្គាល់ឃើញ ភ្នែកនាងមិនប៉ប្រិច១ មានពណ៌ក្រហម១ មិនចេះខ្លាចរអែង១ មិនមានស្រមោល១ៗ ទោះបីជាលោកជ្រាបយ៉ាងនេះក្ដី ក៏លោកនៅតែសួរបញ្ជាក់ថា៖

"តើពួកនាងនឹងឋិតនៅក្នុងការវិនិច្ឆ័យរបស់ខ្ញុំឬទេ?"

ស្ត្រីទាំងពីរយល់ព្រមថា៖

"ចាស ពួកខ្ញុំនឹងតាំងនៅក្នុងការវិនិច្ឆ័យរបស់លោកម្ចាស់"ៗ

មហោសថបណ្ឌិតគូរវង្វង់លើផ្ទៃដី រួចដាក់ផ្ដេកទារកនៅកណ្ដាលវង្វង់នោះ ហើយបង្គាប់ស្ត្រីដែលជាយក្ខិនីឲ្យចាប់ជើង បង្គាប់ស្ត្រីដែលជាម្ដាយឲ្យចាប់ដៃ រួចនិយាយថា៖

"សូមមីងទាំងពីរ ទាញយកចុះ នរណាទាញឈ្នះ វាជាកូនរបស់
អ្នកនោះហើយ"។

ស្ត្រីទាំងពីរនាក់ ក៏ផ្តើមដណ្តើមគ្នាទាញទារក។ ទារកកាលត្រូវ
គេទាញ វាឈឺហើយក៏ស្រែកយំយ៉ាងខ្លាំង។ ស្ត្រីដែលជាម្តាយទារកពិត
ឮសូរកូនយំ ខ្លោចផ្សាក្នុងចិត្តអាណិតកូនស្ទើរតែបែកទ្រូង សុខចិត្ត
លែងទារកពីដៃហើយមកឈរយំវិញ។ មហោសថបណ្ឌិតសួរទៅ
មហាជនដែលមកជួបជុំក្នុងការកាត់ក្តីនោះថា៖

"ម្នាលអ្នកទាំងឡាយដ៏ប្រសើរ តាមធម្មតា តើម្តាយតែងមានចិត្ត
ទន់ភ្លន់ចំពោះកូនឬ ឬថាអ្នកដទៃ?"

មហាជនជាទូទៅនិយាយឡើងថា៖

"មានតែម្តាយទេ ដែលមានចិត្តទន់ចំពោះកូន"។

មហោសថបណ្ឌិតសួរបន្តថា៖

"ឥឡូវនេះ តើស្ត្រីដែលដណ្តើមយកកូនបាននេះ ជាម្តាយ ឬស្ត្រី
ដែលលែងកូន ហើយមកឈរយំនៅខាងនេះជាម្តាយ?"

មហាជននិយាយគ្រប់គ្នាថា៖

"ស្ត្រីដែលត្រូវជាម្តាយទារក គឺស្ត្រីដែលលែងទារកហើយឈរយំ
ហ្នឹងឯង"។

មហោសថសួរបន្តថា៖

"តើអ្នកទាំងអស់គ្នាស្គាល់ចោរលួចក្មេងនេះថាជាអ្វីទេ?"

មហាជនប្រាប់ថា៖

"បពិត្របណ្ឌិត ពួកយើងគ្មាននរណាមួយស្គាល់នាងជាអ្វីទេ"។

បណ្ឌិតមហោសថ ក៏ប្រាប់មនុស្សទាំងនោះថា៖

"ស្ត្រីនេះជាយក្ខិនី មានបំណងចង់ស៊ីសាច់ខ្ចីកូននេះ"។

មហាជនសួរលោកបណ្ឌិតថា៖

"បពិត្រលោកបណ្ឌិត ចុះលោកស្គាល់ដោយរបៀបណា?"

មហោសថបណ្ឌិតប្រាប់ថា៖

"ពួកអស់លោក មើលចុះភ្នែកនាងមិនប៉ប្រិចទេ ថែមទាំងក្រហមទៀតផង ទាំងនាងក៏ឥតចេះញញើត ស្រមោលរបស់នាងក៏មិនមាន ខ្ញុំស្គាល់នាងថា យក្ខិនីបានដោយលក្ខណៈបែបនេះឯង"។

គ្រានោះមហោសថសួរនាងនោះថា៖

"តើនាង ជាយក្ខិនីមែនឬ?"

"បពិត្រលោកប្រុស ខ្ញុំជាយក្ខិនីពិតមែន" ស្ត្រីនោះឆ្លើយ។

"ព្រោះហេតុអ្វីបានជានាងចាប់ទារកនេះ?" មហោសថសួរ។

"លោកប្រុស ខ្ញុំចាប់ព្រោះចង់ស៊ីសាច់វា" យក្ខិនីឆ្លើយ។

"ម្តេចក៏ល្ងង់អន្ធពាលម្ល៉េះ! នាងកាលដើមឡើយ ធ្វើបាបកម្ម ទើប បានកើតជាយក្ខិនី ឥឡូវនេះ នាងធ្វើបាបទៀត ឱ! នាងពេញជា អ្នកល្ងង់អន្ធពាលណាស់តើ"។

និយាយដូច្នេះហើយ មហោសថបណ្ឌិតបង្គាប់នាងឲ្យកាន់សីល៥ យ៉ាងខ្ជាប់ខ្ជួន រួចបញ្ជូនឲ្យទៅវិញដោយផ្តែផ្តាំថា៖

"តាំងអំពីឥឡូវនេះទៅ នាងកុំធ្វើបាបកម្មបែបនេះទៀត"។

ចំណែកម្តាយទារក មានចិត្តរីករាយយ៉ាងក្រៃលែង ដោយបានកូនមកវិញ ហើយនាងបានថ្លែងអំណរគុណមហោសថ និងជញ្ជក់មាត់ស្ញើចសរសើរមហោសថបណ្ឌិតដោយរំជួលទាំងទឹកភ្នែក ហើយជូនពរថា៖

"បពិត្រលោកប្រុស សូមលោកម្ចាស់មានអាយុយឺនយូរ"។

រួចសំពះលាដោយក្តីត្រេកអរឥតឧបមា ហើយក៏បីកូនចៀសចេញអំពីទីនោះទៅ។

**ប្រស្នាទី ៦ គោរគោ = ចោរលួចប្រពន្ធរបស់បុរសតឿ**

មានរឿងតំណាលថា បុរសម្នាក់ឈ្មោះគោតកាឡ ដែលគេហៅដូច្នោះព្រោះគាត់មានរាងទាបកន្ទិលផង ខ្មៅក្រេះផង គាត់ខំធ្វើកិច្ចការងារអស់ ៧ ឆ្នាំ ទើបចូលទៅស្តីដណ្តឹងកូនក្រមុំគេម្នាក់រៀបការជាប្រពន្ធ

ពេញសិទ្ធិបាន។ នាងជាប្រពន្ធឈ្មោះថា ទីឃតាលា[២០]។ ក្នុងថ្ងៃមួយ គោតកាឡបុរសស្វាមីនិយាយទៅកាន់ប្រពន្ធថា៖

"អូនសម្លាញ់! សូមអូនចម្អិននំចំណីអាហារឆ្ងាញ់ៗ ហើយយើងនឹងទៅលេងសួរសុខទុក្ខម្តាយឪពុករបស់បង"។

ប្រពន្ធបដិសេធថា៖

"ម្តាយឪពុករបស់បង មានប្រយោជន៍អ្វីទៅ?"

ទោះប្រពន្ធជំទាស់យ៉ាងនេះ ក៏គោតកាឡបុរសនៅតែទទូចប្រាប់នាងដរាបដល់ ៣ ដង ទើបបានប្រើនាងឲ្យចម្អិននំចំណីអាហារបានហើយ វេចខ្ចប់ស្បៀងខ្លះ គ្រឿងបណ្ណាការខ្លះ ចេញធ្វើដំណើរទៅជាមួយនឹងប្រពន្ធឆ្ពោះទៅផ្ទះឪពុកម្តាយ។ លុះទៅដល់ពាក់កណ្តាលផ្លូវ អ្នកទាំងពីរត្រូវឆ្លងស្ទឹងមួយឈ្មោះថា **ឧត្តានវាហិនី**។ ប៉ុន្តែប្តីប្រពន្ធទាំងពីរនាក់នោះ មានសារជាតិខ្លួនជាអ្នកខ្លាចទឹក។ ដូច្នោះពួកគេឈរស្ទាក់ស្ទើររេរាអល់អែកនៅលើច្រាំង មិនហ៊ានចុះទឹកឆ្លងស្ទឹងនោះទេ។

តាមការពិត ស្ទឹង**ឧត្តានវាហិនី** នោះជាស្ទឹងរាក់ តែផ្ទៃទឹកលាតសន្ធឹងធំធេងល្វឹងល្វើយ ល្មមតែអ្នកមិនធ្លាប់ដឹង ឃើញហើយខ្លាចមិនហ៊ានហែលឆ្លងមែន។

---

[២០] ត្រូវអានថា ទីឃៈដាឡា ព្រោះអក្សរតបាលីត្រូវអានចេញជាសូរអក្សរដខ្មែរ។

គ្រានោះ ក៏មានបុរសទុគ៌តម្នាក់ មានខ្នងវែងខ្ពស់ចង្រ្កាង ឈ្មោះ **ទីឃបិដ្ឋិ** ជាមនុស្សដើរសោត់អណ្តែត បានមកដល់ទីនោះដែរ។ ពេលនោះ ពីរនាក់ប្តីប្រពន្ធឃើញបុរសនោះ ហើយក៏សួរគេថា៖

"នែសម្លាញ់អើយ តើស្ទឹងនេះជ្រៅឬរាក់?"

ទីឃបិដ្ឋិបុរស ស្តាប់សម្តីរបស់ប្តីប្រពន្ធពីរនាក់នោះហើយ ដឹងថាពួកគេខ្លាចទឹក ក៏និយាយកុហកថា៖

"នែសម្លាញ់ ស្ទឹងនេះជ្រៅណាស់ ហើយសម្បូរត្រីកាចៗច្រើនទៀតផង"។

គោតកាឡបុរសសួរថា៖

"នែសម្លាញ់ ចុះលោកនឹងទៅដោយមធ្យោបាយដូចម្តេច?"

ទីឃបិដ្ឋិបុរសនិយាយថា៖

"ក្រពើ ឆ្លាម មករនឹងខ្ញុំ ពួកយើងស្គាល់គ្នាជិតដិតណាស់ ដូច្នោះ ពួកវាមិនបៀតបៀនខ្ញុំទេ"។

គោតកាឡបុរសនិយាយថា៖

"នែសម្លាញ់ បើដូច្នោះ ចូរអ្នកជួយចម្លងពួកខ្ញុំផង"។

ទីឃបិដ្ឋិបុរសទទួលព្រមថា៖

"មិនអ្វីទេសម្លាញ់"

ដូច្នេះពីរនាក់ប្តីប្រពន្ធក៏រៀបចំបាយទឹកនិងបង្អែមជូនទីឃបិដ្ឋិបរិភោគ។ លុះបរិភោគរួច ទីឃបិដ្ឋិបុរសសួរថា៖

"នែសម្លាញ់ ខ្ញុំត្រូវនាំនរណាទៅមុន?"

បុរសជាប្តីនិយាយថា៖

"សម្លាញ់ អ្នកចូរនាំប្រពន្ធខ្ញុំទៅមុនចុះ ហើយចាំមកយកខ្ញុំទៅតាមក្រោយ"។

ទីឃបិដ្ឋិបុរសយល់ព្រមថាល្អណាស់ ហើយក៏លើកនាងឲ្យជិះកដៃកាន់ស្បៀងផង កាន់បណ្ណាការផង ដើរចុះទៅកាន់ស្ទឹង ទៅបានតែបន្តិចដាក់គូទអង្គុយប្រហោងដើរទាក្នុងទឹកស្ទឹង ធ្វើហាក់ដូចជាទឹកជ្រៅពិតប្រាកដមែនអ៊ីចឹង។

គោតកាឡបុរស ដែលកំពុងតែឈរនៅលើច្រាំងទន្លេ មើលទៅឃើញទឹកស្មើក គេគិតក្នុងចិត្តថា "ស្ទឹងនេះជ្រៅណាស់ទេតើ សូម្បីគេខ្ពស់យ៉ាងនេះហើយ នៅតែទឹកស្មើត្រឹមក ចុះចំណង់បើអញច្បាស់ជាលិចលង់ដាច់ខ្យល់ស្លាប់ ធ្វងមិនដល់លើគោកទាន់ទេ"។

ចំណែកទីឃបិដ្ឋិបុរស ដែលនាំប្រពន្ធគេទៅនោះ លុះដល់ពាក់កណ្តាលស្ទឹង បាននិយាយល្បួងនាងថា៖

"នែអូនសម្លាញ់! បងនឹងចិញ្ចឹមអូនហើយទៅថ្ងៃក្រោយ អូនទៅណាមកណា នឹងមានខោអាវស្លៀកពាក់ស្រស់សង្ហា មានគ្រឿង

អលង្ការប្រដាប់ឆើតឆាយ មានទាសាទាសីហែហមចោមរោម
ឯអាកន្ទើខ្ទៅក្ងេះនុំះ មានប្រយោជន៍អ្វីដល់អូនទៅ។ សូមអូនធ្វើ
តាមពាក្យបងទៅ ពៅព្រលឹង!”។

នាងទីឃតាលាព្វាចាដ៏ផ្អែមដូចទឹកឃ្មុំ របស់ទីឃបិដ្ឋិបុរសក្លាម
នាងបានផ្តាច់សេចក្តីស្នេហាអំពីស្វាមីរបស់ខ្លួន ដាក់ចិត្តប្រតិពទ្ធមួយ
រំពេច ដោយយល់ព្រមហើយសាសងថា៖

“បពិត្រអ្នកប្រុសដ៏ចម្រើនបណ្តូលចិត្តអូន! ទៅថ្ងៃមុខប្រសិនបើ
បងមិនបោះបង់អូនចោលទេ អូននឹងធ្វើតាមពាក្យរបស់បង”។

ទីឃបិដ្ឋិតបថា៖

“ឱអូនសម្លាញ់បងអើយ និយាយអ្វីអ៊ីចឹង បងថាចិញ្ចឹមអូនគឺនឹង
ចិញ្ចឹមអូនរហូត ឥតកែប្រែលះបង់ពុំងាឲ្យរងាកាយ ក្លាយខ្លួនជា
ស្រីមេម៉ាយនោះឡើយ”។

លុះបានទៅដល់ត្រើយម្ខាងហើយអ្នកទាំងពីរលិចលង់ក្នុងសេចក្តី
ស្នេហាថ្មី ត្រេកត្រអាលចំពោះកាមាយ៉ាងរីករាយជាទីបំផុត ទីឃបិដ្ឋិ
បុរសនិយាយថ្នមៗថា៖

“សូមអូនលះបង់អាគោតកាឡនោះចោលទៅ”។

ចំណែកគោតកាឡបុរសវិញ ក៏កំពុងចោលភ្នែកទៅ មើលឃើញ
ច្បាស់ក្រឡែតជាក់នឹងភ្នែក នូវពួកគេទាំងពីរហូបបាយជាមួយគ្នា រួច

រលំហើយ គេបណ្ដើរគ្នាចៀសចេញទៅ។ គោតកាឡឃើញវិការភាពដូច្នោះ ហើយក៏ស្ទុះប្រាស់ប្រាល់នឹកថា "ច្បាស់ជាពួកនេះត្រូវរ៉ូវគ្នារត់ចោលអញហើយ" ស្ទុះចុះទៅទឹកបន្តិច[២១] ខ្លាចក៏រត់ឡើងមកវិញ ហេតុតែ កំហឹងខឹងនឹងអ្នកទាំងពីរនោះខ្លាំងពេក ក៏តាំងចិត្តថា "រស់ក៏រស់ ងាប់ ក៏ងាប់ទៅចុះ"។ ដូច្នេះ គាត់ក៏លោតប្លោងខ្លួនទៅក្នុងស្ទឹង ធ្លាក់អុកគូទនឹងដីបាតស្ទឹង ទើបដឹងថាស្ទឹងរាក់ ក៏ក្រោកស្ទុះរត់កាត់ទឹកយ៉ាងពេញទំហឹង តាមទៅទាន់ក៏និយាយថា៖

"នែអាចោរចង្រៃ! ឯងលួចនាំប្រពន្ធរបស់អញទៅឯណា?"

"នែអាកន្ទើគម្រក់! ភរិយារបស់ឯងពីអង្កាល់វ៉ី? នាងជាភរិយារបស់អញទេតើ" ទីឃបិដ្ឋិតប។

ស្ដីឲ្យដូច្នេះហើយ ក៏ចាប់ច្បាមករបស់គោតកាឡ គ្រវែងបោះទៅយ៉ាងឆ្ងាយ។

ទោះយ៉ាងណា គោតកាឡហេតុតែស្រឡាញ់ប្រពន្ធពេក ក៏រត់មកចាប់ដៃនាងទីឃតាលាជាប្រពន្ធ ហើយនិយាយថា៖

---

[២១] សោ ទិស្វា "ឥមេ ឯកតោ ហុត្វា មំ ឆឌ្ឌេត្វា បលាយន្តិ មញ្ញេ"តិ អបរាបរំ ធាវន្តោ ថោកំ ឱតរិត្វា ភយេន និវត្តិត្វា បុន តេសុ កោបេន "ជីវាមិ វា មរាមិ វា"តិ ឧល្លង្ឃិត្វា នទិយំ បតិតោ ឧត្តានភាវំ ញត្វា នទឹ ឧត្តរិត្វា វេគេន តំ បាបុណិត្វា "អម្ភោ ទុដ្ឋចោរ, កុហឹ មេ ភរិយំ នេសី"តិ អាហ។

“ឈប់សិន! អូននឹងទៅឯណា? បងខំធ្វើការអស់រយៈពេល ៧ ឆ្នាំ ទម្រាំតែ[២២]បានប្រាក់ស្ដីដណ្ដឹងអូនមកធ្វើជាប្រពន្ធស្របច្បាប់ បងស៊ូហាត់នឿយទ្រាំលំបាកណាស់”។

កាលឈ្មោះគ្នាជាមួយនឹងទីឃបិដ្ឋិទៅវិញទៅមក អ្នកទាំងបីក៏ដើរទៅដល់សាលាមហោសថកុមារ។ មហាជនបានមកប្រជុំគ្នាមើល និងរង់ចាំស្ដាប់ការកាត់ក្ដី។

មហោសថបណ្ឌិតសួរថា “សំឡេងអ្វីហ្នឹង” ហើយបានប្រើគេឲ្យទៅហៅមនុស្សទាំងពីរនាក់នោះ ឲ្យចូលមកជួប ស្ដាប់សម្ដីរបស់អ្នកទាំងពីរ ឃើញថាគេចោទគ្នាទៅវិញទៅមក។ ដូច្នេះលោកបានសួរថា

“តើអ្នកទាំងពីរ នឹងឋិតនៅក្នុងការកាត់ក្ដីរបស់ខ្ញុំឬ?”

បុរសទាំងពីរយល់ព្រមនឹងឋិតនៅក្នុងការកាត់ក្ដីរបស់មហោសថ។ លោកក៏ឲ្យគេហៅទីឃបិដ្ឋិឲ្យចូលមកជួបមុន រួចសួរថា៖

“អ្នកឈ្មោះអ្វី?”

[២២] **ទម្រាំ** (និ.) ទ្រាំតែ, ដរាបតែ, ដរាបដល់, ត្រាតែ,លុះតែ ទាល់តែ : ទម្រាំគេមកដល់; ទម្រាំបាយឆ្អិន; យើងធ្វើការបណ្ដើរទៅ ទម្រាំលោកអញ្ជើញមកដល់។ ទំនុកបំពេកូនសម័យបុរាណថា : កូនអើយដេកទៅ កូនពៅនាងកុំយំ ទម្រាំបាយឆ្អិនស៊ីរួចហើយដើរលេង។ ក្នុងសម័យយើងឥឡូវគួរថា : ...ស៊ីរួចហើយខំរៀន ឬ ...ទៅរៀន ដូច្នេះវិញ។

"ខ្ញុំឈ្មោះ ទីឃបិដ្ឋិ" ទីឃបិដ្ឋិឆ្លើយ។

"ចុះប្រពន្ធរបស់អ្នកឈ្មោះអ្វី?"

ទីឃបិដ្ឋិបុរស មិនទាន់ទាំងស្គាល់ឈ្មោះនាងទីឃតាលានោះផង ក៏ឆ្លើយឈ្មោះផ្សេង ថានេះ ថានោះ ឲ្យរួចតែពីមាត់ កុំឲ្យគេចាប់ថ្នាក់ថាខ្លួនមិនដឹងប៉ុណ្ណោះ។ មហោសថសួរថា៖

"ម្ដាយឪពុករបស់អ្នកឈ្មោះអ្វី?"

ទីឃបិដ្ឋិ ឆ្លើយឈ្មោះនេះឈ្មោះនោះ ពីព្រោះខ្លួនស្គាល់ច្បាស់ឈ្មោះម្ដាយឪពុកខ្លួន។ ប៉ុន្តែកាលត្រូវសួរអំពីឈ្មោះម្ដាយឪពុកខាងប្រពន្ធ គេមិនស្គាល់បន្តិចសោះ ចេះតែឆ្លើយផ្ដេសផ្ដាស ឈ្មោះនេះឈ្មោះនោះ ឲ្យបានរួចតែពីមាត់ប៉ុណ្ណោះ និងដើម្បីឲ្យមហាជនក្នុងសាលាសម្គាល់ថាខ្លួនជាប្ដីគេពិតមែន។

ក្រោយពេលឲ្យពួកមនុស្សអ្នកចូលរួម ចាប់សម្ដីរបស់ទីឃបិដ្ឋិបុរសបានហើយ មហោសថបណ្ឌិត បញ្ជាឲ្យគេនាំចេញទៅ។ បន្ទាប់មក លោកកោះហៅបុរសម្នាក់ទៀត ដែលមានឈ្មោះគោតកាឡនោះចូលមកជួបម្ដង រួចលោកសាកសួរឈ្មោះបុរសផ្ទាល់ ឈ្មោះភរិយានិងឪពុកម្ដាយទាំងសងខាង ដូចដែលសួរទៅទីឃបិដ្ឋិដែរ។

គោតកាឡបុរសនោះ ដឹងតាមពិតឥតសល់ចន្លោះ នូវឈ្មោះគ្រួសារប្រពន្ធទោះអ្នកណាមួយក៏ដោយ សួរភ្លាមឆ្លើយភ្លាមឥតក្លាត់

ខុស រួចហើយបណ្ឌិតមហោសថបញ្ជាឲ្យគេនាំចេញ។ បន្ទាប់មក លោកបានឲ្យគេអញ្ជើញនាងទីឃតាលាចូលមកជួបម្ដង។ លោកសាកសួរថា៖

"នាងឈ្មោះអ្វី?"

"លោកប្រុស ខ្ញុំឈ្មោះទីឃតាលា"។

កាលត្រូវសួរអំពីប្ដីរបស់នាងឈ្មោះអ្វី នាងក៏មិនដឹង ហើយថាឈ្មោះផ្សេងឲ្យរួចតែពីមាត់ដែរ។ កាលត្រូវសួរអំពីឈ្មោះម្ដាយឪពុកនាង នាងឆ្លើយបានទាំងអស់ថាឈ្មោះនេះឈ្មោះនោះ។ ប៉ុន្តែកាលសួរអំពីឈ្មោះម្ដាយឪពុកខាងប្ដីនាងឆ្លើយវេចវង្វេងថាឈ្មោះនេះឈ្មោះនោះឲ្យរួចតែពីមាត់។ ចុងក្រោយ លោកបណ្ឌិតមហោសថឲ្យគេហៅបុរសពីរនាក់ដែលសួររួចមុននោះ ឲ្យចូលមកទល់មុខគ្នាទាំង ៣ នាក់ រួចលោកសួរទៅមហាជនដែលមកចូលរួមនៅទីនោះថា៖

"សម្ដីរបស់ស្ត្រីនេះ ស៊ីន័យគ្នានឹងពាក្យរបស់ទីឃបិដ្ឋិបុរសឬ? ឬថាស៊ីន័យគ្នានឹងពាក្យរបស់គោតកាឡបុរស?"

មហាជនបញ្ចេញយោបល់គ្រប់គ្នាថា៖

"លោកបណ្ឌិត វាមិនត្រូវគ្នានឹងពាក្យរបស់ទីឃបិដ្ឋិទេ សម្ដីនាងគឺត្រូវគ្នានឹងពាក្យរបស់គោតកាឡបុរស"។

មហោសថកាត់ក្ដីសម្រេចថា៖

“គោតកាឡជាប្តីរបស់នាងទីយតាលាពិតប្រាកដមែន ឯទីយបិដ្ឋិនេះជាចោរ”។

ទើបលោកសួរថា៖

“អ្នកឯងជាចោរ ឬមិនមែនចោរទេ?”

“បាទលោកប្រុស ខ្ញុំបាទជាចោរមែន” ទីយបិដ្ឋិសារភាព។

ដោយវិនិច្ឆ័យរបស់លោកបណ្ឌិតមហោសថ គោតកាឡបាននូវភរិយារបស់ខ្លួនមកវិញ ហើយគេជញ្ជក់មាត់ស្ងើចសរសើរ ចំពោះព្រះមហាសត្វ រួចហើយបាននាំប្រពន្ធលាលោកបណ្ឌិតចៀសចេញទៅ។ ចំណែកបណ្ឌិតមហោសថ ផ្តល់នូវដំបូន្មានដល់ទីយបិដ្ឋិថា “អ្នកកុំធ្វើអំពើយ៉ាងនេះទៀតឲ្យសោះ”។

**ប្រស្នាទី ៧ រថេន = ព្រះឥន្ទ្រប្រណាំងរទេះ**

មានរឿងតំណាលថា ក្នុងថ្ងៃមួយបុរសម្នាក់ បររទេះចេញទៅរកទឹកលុបលាងមុខ។ ខណៈនោះ សក្កទេវរាជទ្រង់បានប្រមើលមើលទៅឃើញមហោសថបណ្ឌិត ទ្រង់ព្រះចិន្តាថា “អញនឹងជួយធ្វើឲ្យបញ្ញានុភាពរបស់មហោសថពុទ្ធង្កុរ រឹតតែល្បីរន្ទឺឡើងទៀត”។ ទើបទ្រង់ប្រែកាឡាកេទជាមនុស្សជំទង់ម្នាក់ ដើរតាមពីក្រោយរទេះនោះ។ ម្ចាស់រទេះសួរថា៖

"នែក្មួយ! ក្មួយឯងទៅណាមកណា? ម្ដេចក៏មកដើរតាមរទេះខ្ញុំ?"

"ខ្ញុំមកនេះដើម្បីបម្រើលោកអ៊ំ" យុវជននិយាយ។

ព្រដូច្នោះ ម្ចាស់រទេះយល់ព្រម ហើយគាត់បានបញ្ឈប់រទេះ រួចចុះទៅរកគុម្ពោត[២៣]ឈើបត់ជើង។ រំពេចនោះ អ្នកដំណើរឡើងជិះរទេះ ហើយបរបំបោលយ៉ាងលឿនចេញបាត់ទៅ។ ចំណែកម្ចាស់រទេះកាលឃើញ ក្មេងជំទង់នោះបររទេះបំបោលទៅលឿនដូច្នោះ គាត់ក៏រត់តាមពេញទំហឹង ស្រែកបន្ទកថា៖

"នែអាចង្រៃ! ឯងបររទេះអញទៅឯណា?"

យុវជននោះ ស្រែកតបថា៖

"រទេះរបស់ឯងផ្សេង នេះជារទេះរបស់អញទេ"។

អ្នកទាំងពីរឈ្លោះប្រកែកគ្នាបណ្ដើរ ទៅមុខបណ្ដើរ រហូតដល់ទ្វារសាលាកាត់ក្ដីរបស់មហោសថ។ មហោសថបណ្ឌិតសួរថា៖ "មានរឿងអ្វីហ្នឹង?" ហើយក៏ប្រើឲ្យគេទៅហៅអ្នកទាំងពីរនោះ ចូលមកជួប កាលឃើញពួកគេកំពុងតែដើរមក មហោសថក៏ស្គាល់ច្បាស់ថា "ម្នាក់នោះជាម្ចាស់រទេះ ម្នាក់នោះជាសក្កទេវរាជ ដ្បិតឥតញញើត១

[២៣] គុម្ពឈើតូចៗដែលដុះជុំគ្នាមួយដុំៗ ឧ. គុម្ពោតឈើ។

មិនប៉ប្រិចភ្នែក១" បើទោះជាស្គាល់ហើយក្ដី ក៏លោកសួរនាំហេតុនៃទំនាស់រួច លោកក៏បន្តសួរចិត្តអ្នកទាំងពីរថា៖

"តើអ្នកទាំងពីរ នឹងឋិតនៅក្នុងការកាត់ក្ដីរបស់ខ្ញុំឬ?"

ពួកគេយល់ព្រមឋិតនៅក្នុងការវិនិច្ឆ័យរបស់មហោសថ។ លោកបណ្ឌិតបាននិយាយថា៖

"ខ្ញុំនឹងប្រើមនុស្សឲ្យឡើងបររទេះ អ្នកទាំងពីរចូររត់តាមក្រោយរទេះ ម្ចាស់រទេះនឹងមិនលែងចោលរទេះទេ អ្នកមិនមែនម្ចាស់នឹងលែងចោលរទេះ ឥតប្រឹងរត់តាម"។

រួចលោកបង្គាប់បុរសម្នាក់ឲ្យឡើងបររទេះ។ បុរសនោះក៏បានធ្វើតាមបង្គាប់ ឡើងរទេះបរបំបោលយ៉ាងលឿនចេញទៅ។

ចំណែកបុរសពីរនាក់ ក៏រត់ដេញតាមពីក្រោយ។ បុរសម្ចាស់រទេះរត់តាមពីក្រោយតែមួយសន្ទុះ ហត់ទន់ដៃទន់ជើង ឈប់លែងរត់តាម។ ចំណែកយុវជននោះ រត់ទាន់ប្រកិតជំណាលគ្នានឹងរទេះ ដល់ពេលរទេះត្រឡប់មកដល់កន្លែងដើមវិញ គាត់ក៏មកដល់ជំណាលនឹងរទេះដែរ។ លោកមហោសថបណ្ឌិត ប្រាប់មនុស្សទាំងឡាយថា៖

"បុរសនេះ រត់តាមរទេះមួយសន្ទុះ ក៏ហត់ទន់ដៃទន់ជើង រត់លែងរួច ចំណែកបុរសក្មេងនេះវិញ រត់ទាន់ជំណាលគ្នានឹងរទេះ លុះត្រឡប់មកក៏ជំណាលគ្នានឹងរទេះដែរ ដោយគ្មានចេញញើស

*ពីខ្លួនសូម្បីមួយតំណក់ឡើយ ទាំងដង្ហើមហត់បន្តិចក៏គ្មាន*[២៤]

*ឥតញញើត និងមិនប៉ប្រិចភ្នែក នុះជាសក្កទេវរាជ"*ៗ

គ្រានោះ មហោសថសួរយុវជននោះថា៖

"តើលោកជាសក្កទេវរាជមែនឬទេ?"

"បាទលោកបណ្ឌិត ខ្ញុំជាសក្កទេវរាជពិតមែន" សក្កទេវរាជ ឆ្លើយៗ

"ហេតុអ្វីបានជាលោកមកធ្វើអីចឹង?" មហោសថសួរៗ

"លោកបណ្ឌិត ខ្ញុំមកនេះដើម្បីជួយប្រកាសប្រាជ្ញារបស់លោក តែម្យ៉ាងប៉ុណ្ណោះ" សក្កទេវរាជឆ្លើយៗ

"បើដូច្នោះសូមព្រះអង្គកុំធ្វើយ៉ាងនេះទៀតអី" មហោសថទូន្មានៗ

ចំណែកសក្កទេវរាជ សម្តែងអានុភាពនៃខ្លួន ជាស្តេចសក្កៈឲ្យមហាជនទាំងឡាយបានឃើញហើយ ទ្រង់ថ្លែងសេចក្តីសរសើរចំពោះបណ្ឌិតមហោសថថា "រឿងក្តីនេះ គឺលោកបណ្ឌិតបានវិនិច្ឆ័យល្អប្រពៃហើយ" រួចសក្កទេវរាជហោះទៅលំនៅឋានរបស់ព្រះអង្គវិញៗ

---

[២៤] អស្សាសបស្សាសោបិ នត្ថិៗ

គ្រានោះ អាមាត្យដែលរង់ចាំមើលប្រាជ្ញារបស់មហោសថ បាន ធ្វើដំណើរទៅកាន់រាជដំណាក់របស់ព្រះបាទវិទេហរាជ ដោយផ្ទាល់ ហើយរាយការណ៍ថ្វាយទ្រង់ថា៖

"បពិត្រមហារាជ មហោសថនុ៎ះ ហៅពេញជាបណ្ឌិតមែន
គេបានវិនិច្ឆ័យដោយប្រាជ្ញា គួរឲ្យស្ងើចសរសើរ និងស្ញប់ស្ញែង
ពន់ពេកៗ ចំណែកសក្កទេវរាជត្រូវបរាជ័យដោយបណ្ឌិតនោះៗ
បពិត្រព្រះសម្មតិទេព ទ្រង់មិនយល់ថា គេជាបុរសវិសេស
ព្រោះហេតុអ្វីទៅ?"

ព្រះបាទវិទេហរាជ សួរទៅអាចារ្យសេនកៈថា៖

"បពិត្រអាចារ្យសេនកៈ សូមលោកមានប្រសាសន៍មកមើល
តើយើងល្មមនឹងទៅនាំយកមហោសថកុមារ មកតាំងតំណែងជា
រាជបណ្ឌិត ក្នុងវាំងបានហើយឬនៅ?"

អាចារ្យសេនកៈ ហេតុតែខ្លាចបាត់បង់លាភ ក៏ក្រាបទូលព្រះរាជាថា៖

"បពិត្រមហារាជ នឹងហៅថាជាបណ្ឌិតដោយហេតុត្រឹមប៉ុណ្ណោះ
មិនទាន់បានទេ សូមព្រះអង្គរង់ចាំសិន ពួកយើងសាកល្បង
ហើយគង់តែនឹងដឹងទេ"ៗ

សត្តទារកបញ្ហា ចប់តែប៉ុណ្ណោះៗ

# ជំពូកទី ៣

## គន្ធកបញ្ហា

## ប្រស្នា ១២ ខ បន្ថែមទៀត

### ប្រស្នាទី ៨ ឧណ្ឌោ = ប្រស្នាដំបង

មានរឿងតំណាលថា ព្រះបាទវិទេហរាជ ទ្រង់ព្រះតម្រិះថា "អញនឹងសាកល្បងនូវបញ្ញាមហោសថបណ្ឌិតនោះ" ទើបទ្រង់បានប្រើគេឲ្យទៅយកឈើគគីរមួយដើមមកកាត់យកមួយកំណាត់ ប្រវែងមួយចំអាម រួចប្រើជាងមកដុសលញ់ខាត់ ធ្វាក់ក្បាច់យ៉ាងស្អាតស្រេចហើយ ទ្រង់ផ្ញើទៅស្រុកបាចីនគ្រាម ដោយមានព្រះបន្ទូលថា "យើងឮថាអ្នកស្រុកបាចីនគ្រាម សុទ្ធតែជាបណ្ឌិតៗ ឥឡូវនេះ ចូរពិនិត្យមើលថា តើឈើគគីរនេះ ខាងណាចុង ខាងណាគល់? ប្រសិនបើមិនដឹងទេ យើងនឹងពិន័យប្រាក់ ១.០០០ កហាបណៈ ក្នុងម្នាក់ៗ"។ មនុស្សអ្នកនៅក្នុងស្រុកមកជួបជុំនុំគ្នា ក៏មិនអាចដឹងថា ខាងណាចុង ខាងណាគល់ ទើបនាំគ្នាទៅជម្រាបសិរីវឌ្ឍនសេដ្ឋីថា៖

"បពិត្រមហាសេដ្ឋី ក្នុងពេលណាក៏ដោយ មហោសថបណ្ឌិតតែងតែដឹងទាំងអស់ សូមលោកមេត្តាឲ្យគេអញ្ជើញមហោសថ

បណ្ឌិត មកសួរមើល ក្រែងលោមហោសថដឹងឈើនេះ ខាងណាចុង ខាងណាគល់”

សេដ្ឋីបានប្រើគេឲ្យទៅហៅមហោសថ អំពីកីឡាមណ្ឌល[២៥] មកជួប ហើយប្រាប់ដំណើរដើមទងនោះ រួចសួរថា៖

“នែបាសម្លាញ់! អ្នកស្រុកនិងឪពុកអស់តម្រិះហើយ មិនអាចដឹងបានទេ តើបាឯងដឹងនូវចម្លើយក្នុងប្រស្នានេះឬទេ?”

ឮដូច្នោះ មហោសថបណ្ឌិតយល់ថា “បញ្ហាដែលព្រះរាជាដាក់ឲ្យរកខាងណាចុង ខាងណាគល់នៃឈើគគីរនេះ ពុំមានប្រយោជន៍អ្វីទាល់តែសោះ ប្រាកដជាព្រះអង្គទ្រង់បញ្ជូនមកនេះ ដើម្បីសាកល្បងប្រាជ្ញារបស់អញ”។ គិតដូច្នេះហើយមហាសត្តពោលថា៖

“លោកឪពុក! សូមយកឈើគគីរនោះមក ខ្ញុំប្រាកដជាដឹង”។

លុះគេយកមកដល់ មហោសថឈោងដៃទៅចាប់ក៏ដឹងភ្លាមថា “នេះខាងចុង នេះខាងគល់”។ ទោះបីដឹងយ៉ាងនេះហើយក៏ដោយ ដើម្បីឲ្យមហាជនមានទំនុកចិត្ត លោកបានប្រើគេឲ្យទៅយកទឹកមួយថាស ចងឈើគគីរនោះចំកណ្ដាលដោយអំបោះ ចាប់ចុងអំបោះហើយ ក៏ដាក់កំណាត់ឈើគគីរនោះទៅលើផ្ទៃទឹក។ ខាងគល់បានលិចទៅក្នុងទឹកមុន

---

[25] កីឡាមណ្ឌល --មន់-ឌល់ បា. (ន.) មណ្ឌលនៃកីឡា, វាលវង់សម្រាប់លេងកីឡា, ទីសម្រាប់លេងកីឡា ។

ព្រោះខាងគល់មានខ្លឹមចាស់ ជាសារធាតុធ្ងន់ជាងខាងចុង។ គ្រានោះ មហោសថ សួរមហាជនថា៖

“ធម្មតាឈើ តើខាងគល់ធ្ងន់ឬខាងចុងធ្ងន់?”

“ខាងគល់ធ្ងន់ លោកបណ្ឌិត” មហាជនឆ្លើយ។

មហោសថបានប្រាប់ខាងចុងខាងគល់ ដោយសញ្ញានេះថា៖

“បើដូច្នោះ ពួកលោកឃើញឈើនេះខាងណាលិចមុន នុ៎ះឯងជាខាងគល់”។

អ្នកស្រុកទាំងឡាយ បានបញ្ជូនឈើគគីរនោះទៅថ្វាយព្រះបាទវិទេហរាជ ដោយទូលថា “ខាងនេះចុង ខាងនេះគល់”។ ព្រះរាជាត្រាស់សួរថា “នរណាដឹងដូច្នេះ?” លុះទ្រង់ព្រះសណ្ដាប់ជ្រាបថា “មហោសថជាកូនសិរីវឌ្ឍនសេដ្ឋី” ទ្រង់ក៏ត្រាស់សួរទៅអាចារ្យសេនកៈថា៖

“នែអាចារ្យសេនកៈ! អញ្ជើញលោកមានប្រសាសន៍មកមើល តើយើងល្មមទៅនាំយកមហោសថ មកតែងតាំងជារាជបណ្ឌិតក្នុងរាជវាំងបានហើយឬនៅ?”

អាចារ្យសេនកៈក្រាបទូលថា៖

“សូមទ្រង់ពន្យាពេលបន្តិចសិន ព្រះសម្មតិទេព ទូលបង្គំនឹងសាកល្បងមហោសថនោះបន្ត ដោយឧបាយដទៃទៀត”។

**ប្រស្នាទី ៩ សីសំ = ប្រស្នាឧាយលលាដ៍ក្បាល**

មានរឿងតំណាលថា ព្រះរាជាប្រើគេឲ្យយកក្បាលខ្មោចពីរបញ្ជូនទៅអ្នកស្រុកបាចីនគ្រាមដោយប្រាប់ថា “ចូរពួកអ្នកពិនិត្យមើលថាតើក្បាលទាំងពីរនេះ មួយណារបស់មនុស្សស្រី មួយណារបស់មនុស្សប្រុស? បើមិនដឹងទេ យើងនឹងពិន័យប្រាក់ ១.០០០ កហាបណៈគ្រប់គ្នា”។ អ្នកស្រុកទាំងឡាយ កាលមិនដឹង ក៏នាំគ្នាសួរមហោសថបណ្ឌិត។ មហោសថឃើញភ្លាមក៏ដឹងច្បាស់។ ឯវិធីដែលមហោសថដឹងគឺធម្មតាលលាដ៍ក្បាលមនុស្សប្រុស មានថ្នេរត្រង់ភ្លឹង ក្បាលមនុស្សស្រីមានថ្នេរវៀចវិល។ ដោយការដឹងច្បាស់ដូច្នេះ មហោសថប្រាប់មនុស្សទាំងឡាយថា “នេះជាក្បាលមនុស្សស្រី នេះជាក្បាលមនុស្សប្រុស”។ ចំណែកអ្នកស្រុកទាំងឡាយ បានបញ្ជូនក្បាលទាំង ២ នោះ ទៅថ្វាយព្រះបាទវិទេហរាជ។ សេចក្ដីផ្សេងៗ មានន័យដូចមុន។

**ប្រស្នាទី ១០ អហិ = ប្រស្នាពស់ញីពស់ឈ្មោល**

មានរឿងតំណាលថា ថ្ងៃក្រោយមកទៀតព្រះបាទវិទេហរាជទ្រង់បញ្ជាគេឲ្យនាំយកនូវពស់ឈ្មោលមួយ ពស់ញីមួយ បញ្ជូនទៅអ្នកស្រុកបាចីនគ្រាមដោយព្រះតម្រាស់ថា “ចូរពួកអ្នកពិនិត្យមើលមួយណាពស់ឈ្មោល មួយណាពស់ញី។ ប្រសិនបើមិនដឹងទេ យើង

នឹងពិន័យជាប្រាក់ ១.០០០ កហាបណៈគ្រប់ៗគ្នា”។ អ្នកស្រុកទាំងឡាយកាលមិនដឹង ក៏នាំគ្នាមកសួរមហោសថបណ្ឌិត។ មហោសថបានឃើញភ្លាម ក៏ដឹងច្បាស់ ពីព្រោះថាកន្ទុយពស់ឈ្មោល រាងថ្លោស កន្ទុយពស់ញី រាងតូចវៀវ ក្បាលពស់ឈ្មោល រាងក្រាស់គ្រមឹប ឯក្បាលពស់ញី រាងតូចធ្ងឹម ភ្នែកពស់ឈ្មោលធំៗ ភ្នែកពស់ញីតូចៗ សន្ធារច្ឆតរបស់ពស់ឈ្មោលវែង សន្ធារច្ឆតពស់ញីខ្លី។ ដោយការដឹងច្បាស់យ៉ាងនេះ មហោសថបណ្ឌិតប្រាប់មហាជនថា “ពស់នេះ ជាពស់ឈ្មោល ពស់នេះ ជាពស់ញី”។ សេចក្ដីផ្សេងៗបានទូលថ្វាយព្រះរាជា មានន័យដូចតែងនៅខាងដើម។

**ប្រស្នាទី ១១ កុក្កុដោ = ប្រស្នាគោជុះស្លែងជើង**

មានរឿងតំណាលថា ក្នុងថ្ងៃមួយ ព្រះរាជាបានបញ្ជូននូវរាជសារទៅឲ្យអ្នកស្រុកបាចីនគ្រាមថា៖

“អ្នកស្រុកបាចីនគ្រាមទាំងឡាយ ចូរបញ្ជូននូវគោឧសភៈមួយមកថ្វាយយើង ដែលគោនោះមានសម្បុរសសុទ្ធ មានស្នែងនៅត្រង់ជើង បួរលើក្បាល ស្រែករោទ៍មិនរំលងកាល៣។ បើរកមិនបានទេ យើងនឹងពិន័យប្រាក់ ១.០០០ កហាបណៈគ្រប់ៗគ្នា”។

ពួកអ្នកស្រុក កាលមិនដឹង ក៏នាំគ្នាសួរមហោសថបណ្ឌិត។ មហោសថបណ្ឌិតប្រាប់ថា៖

"ព្រះរាជាឲ្យយើងនាំយកមាន់សសុទ្ធទៅថ្វាយ ដែលមាន់នោះមានស្នែងត្រង់ជើងគឺធ្នាល់[២៦]ជើងវានោះឯង ដែលថាមានបួរលើក្បាល គឺសិរលើក្បាលនោះឯង ដែលថាស្រែករោទ៍មិនរំលងកាល៣ គឺ វេលា ៣ ដងនោះឯងក្នុងរដូវភ្លៀង។ ព្រោះហេតុនោះពួកលោក ចូរបញ្ជូនមាន់បែបនេះទៅថ្វាយទ្រង់ចុះ"។

អ្នកស្រុកទាំងឡាយ ក៏បានបញ្ជូនមាន់ទៅថ្វាយទ្រង់។

**ប្រស្នាទី ១២ មណី = ប្រស្នាដោតអំបោះថ្មីចងកែវមណី**

មានរឿងតំណាលថា កែវមណីដែលសក្កទេវរាជថ្វាយចំពោះព្រះបាទកុសរាជ មានជ្រុង ៨ ជាគ្រឿងសម្គាល់។ ប៉ុន្តែអំបោះចាស់នៃកែវមណីនោះដាច់ ដោយគ្មាននរណាម្នាក់អាចហូតអំបោះចាស់នោះចេញបាន ហើយបញ្ចូលអំបោះថ្មីឲ្យចូលប្រហោងដដែលនោះបានទេ។

---

[២៦] ធ្នាល់ (ន.) គ្រឿងអាវុធរបស់សត្វទ្វេបាទពួកខ្លះ ដុះនៅជើង សម្រាប់ការពារខ្លួន : ធ្នាល់មាន់, ធ្នាល់ក្ងោក។ គួរឈប់ប្រើពាក្យ ខ្នាយមាន់ ព្រោះពាក្យ ខ្នាយ បាន ដល់ ចង្កូមស្រួចជាគ្រឿងការពាររបស់ជ្រូក ឧ. ខ្នាយជ្រូកព្រៃ។

ព្រោះហេតុដូច្នោះ ក្នុងថ្ងៃមួយ ព្រះបាទវិទេហរាជ បញ្ជូនកែវមណីនោះ ទៅឲ្យអ្នកស្រុកបាចីនគ្រាម ដោយប្រាប់ថា៖

"អ្នកស្រុកបាចីនគ្រាមត្រូវហូតអំបោះចាស់ចេញពីកែវមណីនេះ ហើយដោតអំបោះថ្មីបញ្ចូលវិញ"។

អ្នកស្រុកមិនហ៊ានហូតអំបោះចាស់នោះចេញទេ ក្រែងលោដោតអំបោះថ្មីទៅវិញមិនចូល ទើបនាំគ្នាប្រាប់មហោសថបណ្ឌិត។ មហោសថប្រាប់ថា៖

"កុំព្រួយបារម្ភអី ទៅយកទឹកឃ្មុំមកឲ្យខ្ញុំ"។

លុះប្រើគេឲ្យនាំយកទឹកឃ្មុំបានមកហើយ មហោសថលាបទឹកឃ្មុំត្រង់ប្រហោងទាំងពីរខាងនៃកែវមណីនោះ រួចយកទៅដាក់ក្នុងហ្វូងស្រមោច។ ពួកស្រមោចហេតុតែជុំក្លិនទឹកឃ្មុំ នាំគ្នាខាំពាំអំបោះចាស់ក្នុងកែវមណី ហើយស៊ីដេញដរាបអស់អំបោះចាស់ក្នុងកែវមណី។ មហោសថ វេញអំបោះកម្ពល[២៧]ថ្មី លាបទឹកឃ្មុំនៅត្រង់ចុង ហើយដោតបញ្ចូលក្នុងប្រហោងកែវមណីបន្តិច បន្ទាប់មកយកទៅដាក់ត្រង់ផ្លូវស្រមោចវារចេញចូល។ ពួកស្រមោចខាំបណ្ដើរ ទាញចូលបណ្ដើរ ដរាបចុងអំបោះថ្មី លៀនចេញមកផ្នែកម្ខាងទៀតនៃកែវមណី។

---

[២៧] ឈ្មោះសម្ពត់ពិសេសមួយប្រភេទ ដែលធ្វើដោយរោមសត្វ។

មហោសថបណ្ឌិតដឹងថា អំបោះនោះចេញទៅម្ខាងទៀត ហើយបាន យកមកឲ្យអ្នកស្រុកដោយប្រាប់ថា៖

"សូមពួកអ្នកយកកែវមណីទៅថ្វាយព្រះមហាក្សត្រវិញចុះ"។

អ្នកស្រុកបានបញ្ជូនទៅថ្វាយដល់ព្រះបាទវិទេហរាជ។ ព្រះរាជា ទ្រង់សណ្ដាប់នូវសេចក្ដីរាយការណ៍ អំពីឧបាយបញ្ចូលខ្សែអំបោះកម្ពល ថ្មី ទ្រង់មានព្រះរាជហឫទ័យត្រេកអររីករាយជាខ្លាំង។

**ប្រស្នាទី ១៣ ទិដាយនំ = ប្រស្នាគោឈ្មោលកើតកូន**

មានរឿងតំណាលថា រាជបុរសទាំងឡាយ បានឲ្យគោឧសភៈ មង្គលរបស់ព្រះបាទវិទេហរាជ ស៊ីនូវសណ្ដែកជាច្រើន ពោះធំកំពីង ពួកគេបានលាងសម្អាតស្នែង លាបស្រលាបដោយប្រេង ប្រោះព្រំដោយ ទឹកក្រអូបហើយបញ្ជូនទៅអ្នកស្រុកបាចីនគ្រាមដោយត្រាស់បញ្ជាថា៖

"ពួកអស់លោក សុទ្ធតែជាបណ្ឌិត ឥឡូវគោឧសភមង្គលរបស់ ព្រះរាជាមួយនេះ ផើមគ្រប់ខែហើយ។ ពួកអ្នកចូរជួយសម្រាល កូនឲ្យវាផង ហើយបញ្ជូនវាព្រមទាំងកូនមកឲ្យយើងវិញយ៉ាងឆាប់ បើមិនអាចទេ នឹងត្រូវពិន័យប្រាក់ ១.០០០ កហាបណៈ ក្នុង ម្នាក់ៗ"។

ពួកអ្នកស្រុកនាំគ្នាទៅសួរមហោសថបណ្ឌិតថា៖

"ពួកយើងមិនអាចធ្វើកិច្ចការនេះបានទេ យើងនឹងធ្វើដូចម្ដេច?" មហោសថគិតថា "ប្រស្នានេះ ជាប្រស្នាប្រៀបធៀប" រួចសួរមនុស្សទាំងឡាយថា៖

"ក្នុងចំណោមពួកយើង តើមាននរណាម្នាក់ក្លាហានទូលថ្វាយព្រះរាជាបានទេ?"

មហាជនប្រាប់ថា៖

"ការនុ៎ះមិនធ្ងន់ទេលោកបណ្ឌិត យើងមានអ្នកក្លាហានអាចទូលថ្វាយព្រះរាជាបាន"។

"បើដូច្នោះ ចូរហៅគេមកជួបខ្ញុំ" មហោសថបង្គាប់។

ពួកគេក៏ជ្រើសបុរសម្នាក់ ដែលទុកចិត្តថាល្មមនឹងអាចទូលថ្វាយព្រះរាជាបាន ឲ្យមកជួបមហោសថ។ គ្រានោះ មហោសថប្រាប់កលឧបាយថា៖

"មកណេះបងប្រុស! បងទម្លាក់សក់ឲ្យកន្ទ្រើងស៊ើងមមើងធ្លាក់លើខ្នង ទួញយំ ខ្សឹកខ្សួល អណ្ដឺតអណ្ដកវៀបរាប់ពីនេះពីនោះដើរទៅកាន់ទ្វារព្រះរាជវាំង។ បើទុកជាអ្នកដទៃសួរ កុំនិយាយអ្វីឲ្យសោះ គិតតែពីយំខ្សឹកខ្សួលទៅ ប៉ុន្ដែកាលបើព្រះរាជាបញ្ជាគេឲ្យហៅទៅសួរពីហេតុនៃការយំខ្សឹកខ្សួលនោះ បងប្រុសត្រូវក្រាបទូលព្រះអង្គថា បពិត្រព្រះសម្មតិទេព ឪពុករបស់ទូលព្រះ

បង្គំ មិនអាចសម្រាលកូនរួចទេ គិតមកដល់ថ្ងៃនេះ គឺ ៧ ថ្ងៃហើយ សូមព្រះអង្គទ្រង់ប្រោសធ្វើជាទីពឹងរបស់ទូលព្រះបង្គំយើងខ្ញុំ ជួយប្រាប់ឧបាយសម្រាលកូនស្រួលដល់ឪពុកពួកទូលបង្គំផង។ កាលបើព្រះរាជាត្រាស់ថា អ្នកឯងឃំធ្វើអ្វី មិនសក្តិសមហេតុផលសោះ បុរសណាដែលកើតកូនអ្ហះ! វាមិនដែលមាន។ ពេលនោះ អ្នកគប្បីនិយាយថា បពិត្រព្រះសម្មតិទេព ប្រសិនបើមិនដែលមានយ៉ាងនេះទេ ហេតុអ្វីបានជាទ្រង់បង្គាប់ពួកអ្នកស្រុកបាចីនគ្រាម ឲ្យធ្វើឲ្យគោឈ្មោល ជួយឲ្យគ្នាកើតកូនយ៉ាងម៉េច?”

បុរសនោះយល់ព្រមហើយ ក៏បានធ្វើតាមឧបាយដូច្នោះ។

“នរណាចេះគិតប្រស្នាប្រៀបធៀបនេះឃើញ?” ព្រះរាជាសួរ។ លុះស្តាប់គេក្រាបទូលថា “មហោសថបណ្ឌិត” ព្រះរាជាទ្រង់មានព្រះរាជហឫទ័យត្រេកអរយ៉ាងខ្លាំង។

## ប្រស្នាទី ១៤ ខ្ទិនឆំ = ប្រស្នាដាំបាយអត់អង្ករ

មានរឿងតំណាលថា ថ្ងៃមួយ រាជបុរសទាំងឡាយពិគ្រោះគ្នាថា ពួកយើងនឹងសាកល្បងមហោសថបណ្ឌិតទៀត ទើបបញ្ជូនព្រះរាជសារទៅអ្នកស្រុកបាចីនគ្រាម ដោយមានខ្លឹមសារថា៖

*"ចូរអ្នកស្រុកបាចីនគ្រាម ចម្អិនបាយជូរ[២៨] ប្រកបព្រមដោយអង្គ ៨ គឺ អត់អង្ករ១ អត់ទឹក១ អត់ឆ្នាំង១ អត់ចង្ក្រាន១ អត់ភ្លើង១ អត់ឧស១ អត់ស្ត្រី អត់បុរស១ យកមកកុំដើរតាមផ្លូវ១ ហើយបញ្ជូនមកថ្វាយយើង។ បើមិនអាចទេ យើងនឹងពិន័យជាប្រាក់ ១.០០០ កហាបណៈក្នុងម្នាក់ៗ"។*

អ្នកស្រុក កាលមិនដឹងប្រស្នានោះ ក៏នាំគ្នាទៅសួរមហោសថ។ មហោសថបណ្ឌិត លួងលោមមហាជនកុំឲ្យខ្វល់ រួចប្រាប់នូវដំណោះស្រាយថា៖

*"អត់អង្ករ យើងយកកញ្ចុំអង្ករ។ អត់ទឹក យើងយកទឹកសន្សើម។ អត់ឆ្នាំង យើងយកភាជន៍ដីថ្មីផ្សេង។ អត់ជើងក្រាន យើងយកជន្លត់ដោតទ្រ។ អត់ភ្លើង គឺកុំឲ្យយើងយកភ្លើងប្រក្រតី យើងត្រូវយកភ្លើងរន្ទះ[២៩]។ អត់ឧស យើងយកស្លឹកឈើងាប់ដុតចម្អិន។ បាយកាលដាក់ក្នុងភាជន៍ថ្មីហើយ កុំឲ្យមនុស្សស្រី*

---

[២៨] *អម្ពិលោទនំ ប្រែថា បាយជូរ។ ក្នុងសៀវភៅលោក* **ឈឹម ស៊ុម** *ឃើញប្រែត្រឹមតែ បាយ ងាយស្រួលស្តាប់។ ខ្ញុំប្រែទុកតាមសព្ទនេះ ដើម្បីឲ្យជួយពិភាក្សាតើជាបាយប្រភេទដូចម្តេច បានជាអដ្ឋកថាចារ្យប្រើពាក្យអ៊ីចឹង។*

[២៨] យំ កដ្ឋំ កដ្ឋន្តរេនា'គ្គិនិព្ពត្តនត្ថំ ឃំសតេ, តស្មិំ និម្មន្ថនទារុម្ហិ អរណី, អរ គមនេ, អណិ, ឡៀម្ហិ *អរណី។ ភ្លើងដែលព្រាយឡើងរវាងឈើនឹងឈើដែលកកិតគ្នា។*

ប្រសជាំ យើងឲ្យមនុស្សទ្រើយជាំៗ កុំឲ្យដើរតាមផ្លូវ គឺយើងកុំដើរលើផ្លូវធំ យើងដើរខាងៗផ្លូវ នាំយកទៅថ្វាយព្រះរាជាវិញ"ៗ មហាជនបាននាំគ្នាធ្វើតាមយ៉ាងនោះៗ

"នរណាអាចដឹងពីបញ្ហានោះបាន?" ព្រះរាជាសួរៗ

លុះស្តាប់គេក្រាបទូលថា "មហោសថបណ្ឌិត" ព្រះរាជាទ្រង់មានព្រះរាជហឫទ័យត្រេកអរយ៉ាងខ្លាំងៗ

**ប្រស្នាទី ១៥ ទាលុកំ = ប្រស្នាខ្សែដីខ្សាច់**

មានរឿងតំណាលថា ថ្ងៃមួយក្រោយមកទៀត ដើម្បីសាកល្បងមហោសថបណ្ឌិត រាជបុរសទាំងឡាយបានបញ្ជូនរាជសារទៅឲ្យអ្នកស្រុកបាចីនគ្រាមថា៖

"ព្រះរាជា ស្តេចទ្រង់មានព្រះបំណងចង់គង់ក្រសាលកម្សាន្តទោង ព្រោះទោងចាស់ក្នុងរាជត្រកូលដាច់អស់ហើយ ចូរពួកអ្នកវេញខ្សែដីខ្សាច់មួយ បញ្ជូនមកថ្វាយទ្រង់ៗ បើមិនអាចធ្វើបានទេ យើងនឹងពិន័យជាប្រាក់ ១.០០០ កហាបណៈក្នុងម្នាក់ៗ"ៗ

មនុស្សក្នុងស្រុក នាំគ្នាទៅសាកសួរមហោសថបណ្ឌិតៗ មហោសថគិតថា "សូម្បីប្រស្នានេះ ក៏ជាប្រស្នាប្រៀបធៀបដែរ" លោកបានលួងលោមអ្នកស្រុកឲ្យជកជង្ហើមធូរស្រួលកុំឲ្យបារម្ភ ហើយ

ប្រើគេឲ្យរកមនុស្សប្រុសពីរបីនាក់ ដែលមានវោហារ ពូកែនិយាយរួច ប្រាប់ថា៖

“អ្នកទាំងឡាយចូរទៅគាល់ព្រះរាជា ក្រាបទូលព្រះអង្គថា បពិត្រព្រះសម្មតិទេព អ្នកស្រុកទាំងឡាយ មិនដឹងទំហំខ្សែដីខ្សាច់នោះមានទំហំនិងប្រវែងប៉ុណ្ណាទេ ដូច្នេះមិនទាន់បានធ្វើនៅឡើយទេ។ លុះណាតែព្រះអង្គបញ្ជូនខ្នាតខ្សែដីខ្សាច់ចាស់ ទៅឲ្យពួកគេសិនទោះមួយចម្អាមក៏បាន ៤ ធ្នាប់ក៏បាន ទើបពួកគេធ្វើតម្រូវទៅតាមខ្នាតនោះ។ ប្រសិនបើព្រះរាជាត្រាស់នឹងពួកអ្នកថា ខ្សែពួរដីខ្សាច់ក្នុងវាំងព្រះអង្គ ព្រះអង្គមិនដែលឮថាមានទេ។ កាលបើដូច្នេះ អ្នកគប្បីក្រាបទូលព្រះអង្គតែម្តងថា “បពិត្រមហារាជប្រសិនបើព្រះអង្គមិនដែលមានខ្សែដីខ្សាច់បែបនេះ តើអ្នកស្រុកបាចីនគ្រាម នឹងធ្វើដូចម្តេចបាន?”

មនុស្សពីរបីនាក់នោះ បានធ្វើតាមដូច្នោះ។

ព្រះរាជាត្រាស់សួរថា៖

“នរណាគិតឃើញនូវបញ្ហាប្រៀបធៀបនេះបាន?”

លុះស្តាប់គេក្រាបទូលថា “មហោសថបណ្ឌិត” ព្រះរាជទ្រង់មានព្រះរាជហឫទ័យត្រេកអរខ្លាំងណាស់។

**ប្រស្នាទី ១៦ តន្សាក = ប្រស្នាសែងស្រះថ្វាយស្តេច**

មានរឿងតំណាលថា ក្នុងថ្ងៃមួយក្រោយមកទៀត ដើម្បីសាកល្បងមហោសថបណ្ឌិត រាជបុរសទាំងឡាយបញ្ជូនព្រះរាជសារទៅអ្នកស្រុកបាចីនគ្រាមថា៖

"ព្រះរាជាមានព្រះបំណងយាងស្រង់ទឹក ចូរពួកអ្នកបញ្ជូនស្រះបោក្ខរណី ដែលដេរដាសដោយផ្កាឈូក ៥ ពណ៌ មកថ្វាយព្រះអង្គ កាលបើពួកអ្នកមិនអាចទេ យើងនឹងពិន័យជាប្រាក់ ១.០០០ កហាបណៈ ក្នុងម្នាក់ៗ"។

មនុស្សក្នុងស្រុកបាចីនគ្រាម នាំគ្នាទៅប្រាប់មហោសថបណ្ឌិតឲ្យលោកជ្រាប។ មហោសថគិតថា "សូម្បីប្រស្នានេះ ក៏ជាប្រស្នាប្រៀបធៀបដែរ" លោកបានប្រើគេឲ្យរកមនុស្សប្រុសពីរបីនាក់ ដែលមានវោហារ ពូកែនិយាយស្តីមកជួប រួចប្រាប់ថា៖

"អ្នកទាំងឡាយ ចូរលេងទឹកឲ្យភ្នែកឡើងក្រហម សើមសក់សើមសំពត់ ប្រឡាក់កក់ខ្លួនប្រាណ ខ្លះកាន់ខ្សែ ខ្លះកាន់ដំបង កាន់ដុំដីដើរទៅកាន់ទ្វាររាជវាំង ឈរទៀបទ្វារប្រាប់គេឲ្យចូលទៅទូលព្រះរាជាអំពីដំណើរខ្លួនមកដល់។ ពួកអ្នកម្នាក់សក់ចូលទៅក្រាបទូលព្រះអង្គថា បពិត្រមហារាជ ឮថាព្រះអង្គបញ្ជូនរាជសារបញ្ជា អ្នកស្រុកបាចីនគ្រាម ឲ្យបញ្ជូនស្រះបោក្ខរណីមកថ្វាយ

ព្រះអង្គ។ ពួកទូលបង្គំនាំគ្នាសែងស្រះបោក្ខរណីដ៏ធំសក្តិសម ចំពោះព្រះអង្គមកហើយ ប៉ុន្តែស្រះនោះ ហេតុតែវាធ្លាប់នៅក្នុង ព្រៃ ដល់មកឃើញទីក្រុង មានទ្វារ កំពែង ស្នាមភ្លោះ និងប៉ម ជាដើម វាស្លន់ស្លោក្នុងចិត្ត កន្ត្រាងរើបម្រះដាច់ចំណងខ្សែ រត់ ចូលទៅព្រៃវិញបាត់។ ពួកទូលបង្គំទោះបីនាំគ្នាដេញគប់គ្រវែង ដោយដុំដី ដោយដំបងជាដើមយ៉ាងណា ក៏មិនអាចបំបែរវាឲ្យ ត្រឡប់មករករាជវាំងបានដែរ។ សូមទ្រង់ព្រះមេត្តាប្រោសប្រទាន ស្រះចាស់ ដែលព្រះអង្គធ្លាប់នាំយកពីព្រៃដល់ពួកទូលបង្គំជាខ្ញុំ សូមខ្ចីសិន ដើម្បីយកវាទៅធ្វើជាផ្ទាក់ទាក់ស្រះដែលរត់រួចនោះ ហើយពួកទូលបង្គំ នឹងបណ្តើរវាទាំងគូមកថ្វាយព្រះអង្គវិញ។ បើព្រះរាជាមានព្រះរាជឱង្ការថា ស្រះយើងធ្លាប់នាំមកពីព្រៃពី អន្លង់ ទាំងយើងក៏មិនដែលឲ្យស្រះទៅធ្វើជាផ្ទាក់ទាក់ស្រះ ណាមួយដែរ។ កាលបើព្រះរាជាត្រាស់ឆ្លើយដូច្នេះ ពួកអ្នកត្រូវ ក្រាបទូលថា បពិត្រព្រះសម្មតិទេព បើព្រះអង្គមិនអាចធ្វើយ៉ាង នេះទេ តើពួកអ្នកស្រុកបាចីនគ្រាមនឹងអាចបញ្ជូនស្រះមកថ្វាយ ព្រះអង្គដូចម្តេចកើត?”

បុរសពីរបីនាក់នោះ បានធ្វើតាមយ៉ាងនោះៗ ព្រះរាជាទ្រង់ជ្រាបដំណឹងថា ជាដំណោះស្រាយដែលកើតចេញអំពីប្រាជ្ញារបស់មហោសថ ព្រះរាជាទ្រង់មានព្រះរាជហឫទ័យរីករាយជាខ្លាំង។

**ប្រស្នាទី ១៧ ឧយ្យាន = ប្រស្នាសែងឧទ្យានថ្វាយស្តេច**

មានរឿងតំណាលថា ក្នុងថ្ងៃមួយបន្ទាប់មកទៀត រាជបុរសទាំងឡាយបានផ្ញើរាជសារទៅឲ្យអ្នកស្រុកបាចីនគ្រាមថា៖

"យើងមានបំណងដើរប្រពាតឧទ្យាន ឯដើមឈើក្នុងឧទ្យានចាស់របស់យើងបាក់បែកអស់ មានទេសភាពមិនស្រស់ឡើយ ចូរអ្នកស្រុកបាចីនគ្រាម បញ្ជូនឧទ្យានថ្មីដែលដេរដាសដោយរុក្ខជាតិស្រស់ខ្ចី មានផ្ការីកស្គុះស្គាយមកថ្វាយយើង"។

ពួកអ្នកស្រុក បាននាំគ្នាទៅជម្រាបមហោសថ។ មហោសថគិតថា "សូម្បីប្រស្នានេះ ក៏ជាប្រស្នាប្រៀបធៀបដែរ" រួចលោកបានលួងលោមមហាជននោះ កុំឲ្យព្រួយបារម្ភ ហើយបញ្ជូនមនុស្សឲ្យទៅក្រាបទូលដោយទំនងដូចរឿងស្រះអ៊ីចឹងដែរ។

**ប្រស្នាទី ១៨ អស្សតរ = ប្រស្នាសេះអស្សតរនិងសត្វលា**

ក្នុងគ្រានោះ ព្រះបាទវិទេហរាជ សប្បាយព្រះទ័យសួរទៅកាន់លោកអាចារ្យសេនកៈថា៖

"លោកអាចារ្យសេនកៈ សូមលោកមានប្រសាសន៍មកមើល

តើយើងល្មមទៅនាំយកមហោសថកុមារ មកតាំងតំណែងជារាជបណ្ឌិតក្នុងរាជវាំងបានហើយឬនៅ?"

អាចារ្យសេនកៈ ហេតុតែជាមនុស្សកំណាញ់ ចិត្តចង្អៀត ខ្លាចបាត់បង់លាភ ក្រាបទូលព្រះរាជាថា៖

"នឹងហៅថាជាបណ្ឌិតដោយហេតុត្រឹមប៉ុណ្ណោះ មិនទាន់បានទេ សូមព្រះអង្គរង់ចាំសិន ព្រះសម្មតិទេព"។

ឮសម្ដីក្រាបទូលជំទាស់ របស់អាចារ្យសេនកៈដូច្នោះ ព្រះរាជាមានព្រះតម្រិះថា "មហោសថបណ្ឌិត ជាក្មេងអាយុ ៧ ឆ្នាំ ដោះប្រស្នាសព្វព្រះទ័យអញ ទាំងប្រស្នាអាថ៌កំបាំង ទាំងប្រស្នាប្រៀបធៀប និងប្រស្នាបែបណាក៏ដោះបាន បីដូចការព្យាកររបស់ព្រះពុទ្ធច្បាស់ៗ ប៉ុណ្ណឹងហើយនៅតែអាចារ្យសេនកៈ មិនព្រមឲ្យអញនាំយកគេមកធ្វើជារាជបណ្ឌិត នៅក្នុងព្រះបរមរាជវាំងទៀត។ អាចារ្យសេនកៈមានប្រយោជន៍អ្វីដល់អញទៀត អញនឹងទៅនាំមហោសថបណ្ឌិតនោះមកដោយខ្លួនឯង"។ ព្រះតម្រិះដូច្នេះ ទ្រង់រៀបដំណើរចេញទៅកាន់ស្រុកបាចីនគ្រាមនោះ ដោយបរិវារហែហមជាច្រើន។ កាលស្ដេចកំពុងគង់លើសេះមង្គល ជើងសេះបានផុងទៅក្នុងចន្លោះដីប្រេះក្រហែងបណ្ដាលឲ្យបែកក្រចក គឺជាឧបសគ្គដល់រាជដំណើរ។ ព្រះរាជាទ្រង់ក៏

យានត្រឡប់ពីទីនោះ ហើយទ្រង់យានចូលទៅកាន់ព្រះនគរវិញ។ គ្រានោះ អាចារ្យសេនកៈ ចូលទៅរកព្រះរាជាសួរផ្ដើនថា៖

"បពិត្រមហារាជ ព្រះអង្គបានទ្រង់យាងទៅស្រុកបាចីនគ្រាម នាំមហោសថបណ្ឌិតនោះបានមកហើយឬ?"

"អើ បានហើយលោកបណ្ឌិត" ស្ដេចឆ្លើយ។

អាចារ្យសេនកៈចំអកថា៖

"បពិត្រមហារាជ ព្រះអង្គទតមើលទូលព្រះបង្គំជាខ្ញុំឃើញថា ជាមនុស្សឥតប្រយោជន៍ឬ? ទូលព្រះបង្គំនិយាយហើយថា សូមឲ្យទ្រង់រង់ចាំសិន ទ្រង់បែរជាទាន់ហន់ពេក។ គ្រាន់តែធ្វើដំណើរទៅដំបូងផង សេះមង្គលមានគ្រោះថ្នាក់ទៅហើយ"។

ព្រះបាទវិទេហរាជ ទ្រង់ព្រះសណ្ដាប់ពាក្យរបស់អាចារ្យសេនកៈ ហើយ ព្រះអង្គគង់នៅស្ងៀម។ ពេលព្រឹកឡើង ព្រះរាជាទ្រង់ប្រឹក្សាជាមួយនឹងអាចារ្យសេនកៈម្ដងទៀតថា៖

"លោកអាចារ្យសេនកៈ លោកនិយាយមកមើល តើយើងល្មមទៅយកមហោសថមកតែងតាំងជារាជបណ្ឌិត ក្នុងរាជវាំងយើងបានហើយឬនៅ?"

អាចារ្យសេនកៈក្រាបទូលថា៖

"បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំយាងទៅដោយផ្ទាល់ ក្រាបទូល សូមបញ្ជូនទូតទៅវិញប្រាប់ជាដំណឹងថា "នែបណ្ឌិត! កាលយើង ធ្វើដំណើរទៅកាន់សម្នាក់របស់អ្នក ជើងសេះមង្គល យើងផុងដី ប្រេះបែកក្រចកហើយ ចូរអ្នកបញ្ជូនសេះអស្សតរ ឬអ្វីដែល ប្រសើរជាងសេះអស្សតរមកថ្វាយយើង។ ប្រសិនបើ មហោសថ បញ្ជូនសេះអស្សតរមក មហោសថនឹងមកដោយ ខ្លួនឯង តែបើបញ្ជូនអ្វីដែលប្រសើរជាងសេះអស្សតរមក មហោសថប្រាកដជាបញ្ជូនឪពុកមកផង។ បពិត្រព្រះសម្មតិទេព នេះជាប្រស្នាមួយរបស់ពួកយើង"។

"ល្អណាស់លោកអាចារ្យ" ព្រះរាជាយល់ព្រម និងបានរៀបចំធ្វើ ដូច្នោះហើយ ទ្រង់បានបញ្ជូនទូតទៅប្រាប់មហោសថ។

មហោសថបណ្ឌិត ឮពាក្យទូតហើយ គិតថា "ព្រះរាជាមាន បំណងចង់ឃើញអញផង ឪពុកអញផង"។ លោកបានដើរទៅសម្នាក់ របស់ឪពុក ថ្វាយបង្គំហើយជម្រាបថា៖

"បពិត្រលោកឪពុក ព្រះបាទវិទេហរាជ មានព្រះបំណងចង់ជួប លោកឪពុកនិងខ្ញុំ សូមលោកឪពុកនាំសេដ្ឋីជាបរិវារ ១.០០០ នាក់ ទៅមុនៗ ពេលលោកឪពុកទៅ សូមពុកកុំទៅដោយដៃទទេ សូមអញ្ជើញយកទឹកដោះថ្លាថ្មីៗ ឲ្យបានគ្រប់គ្រាន់និងខ្លឹមចន្ទន៍

មួយហិបទៅជាមួយផង។ កាលព្រះរាជាធ្វើបដិសណ្ឋារកិច្ច ចំពោះលោកឪពុក ព្រះអង្គនឹងមានព្រះរាជឱង្ការថា ម្នាលគហ-បតី អ្នកចូរដើងអាសនៈសមគួរហើយអង្គុយចុះ។ កាលបើដូច្នេះ លោកឪពុក គប្បីយល់អាសនៈសមគួរ រួចសូមអញ្ជើញអង្គុយចុះ។ ពេលលោកឪពុកកំពុងអង្គុយ ខ្ញុំនឹងទៅដល់។ សូម្បីខ្ញុំក៏ព្រះរាជាធ្វើបដិសណ្ឋារកិច្ចដូចគ្នា ព្រះអង្គនឹងទ្រង់អញ្ជើញថា លោកបណ្ឌិត សូមលោកដឹងអាសនៈដ៏សមគួរ ហើយចូរអង្គុយចុះ។ នៅពេលនោះឯង ខ្ញុំនឹងក្រឡេកមើលលោកឪពុក។ សូមលោកឪពុក មេត្តាក្រោកចាកអាសនៈតាមសញ្ញានោះ ហើយមានប្រសាសន៍នឹងខ្ញុំថា នែមហោសថកូន! ចូរកូនមកអង្គុយលើអាសនៈពុកនេះចុះ។ ខណៈនោះ នឹងមានបញ្ហាចោទកើតឡើង"។

ឪពុកមហោសថយល់ព្រម ហើយបានធ្វើតាមដំណើរ ដែលមហោសថបានប្រាប់។ ដល់ទ្វាររាជវាំង គាត់បានប្រើគេឲ្យទៅក្រាបទូលព្រះរាជា អំពីការធ្វើដំណើររបស់ខ្លួនមកដល់ទ្វាររាជវាំង។

កាលបើព្រះរាជាអនុញ្ញាតឲ្យចូល សិរីវឌ្ឍនសេដ្ឋីក៏បានចូលទៅថ្វាយបង្គំព្រះរាជា រួចឈរក្នុងទីដ៏សមគួរ។ ព្រះរាជាបានធ្វើបដិសណ្ឋារៈចំពោះឪពុកមហោសថ ហើយទ្រង់សួរថា៖

“ម្នាលគហបតី តើមហោសថបណ្ឌិតកូនរបស់លោក គេនៅឯណា?”

“គេនឹងមកតាមក្រោយ ព្រះសម្មតិទេព” សិរីវឌ្ឍនសេដ្ឋីឆ្លើយ។

ព្រះរាជាទ្រង់ជ្រាបថា “មហោសថមកតាមក្រោយ” ទ្រង់មានព្រះ ហឫទ័យរីករាយ ហើយមានព្រះរាជឱង្ការថា៖

“នែមហាសេដ្ឋី! សូមលោករកអាសនៈដ៏សមគួរដល់ខ្លួន ហើយអញ្ជើញអង្គុយចុះ”។

ឪពុកមហោសថនោះ យល់អាសនៈដ៏សមគួរដល់ខ្លួនគាត់ហើយ គាត់ក៏បានអង្គុយចុះ។ ចំណែកមហោសថ រៀបចំខ្លួនយ៉ាងស្អាតបាត មានមិត្រសម្លាញ់ ១.០០០ នាក់ ជិះលើរថ ដែលតុបតែងយ៉ាងប្រណិត ធ្វើដំណើរចូលទៅកាន់ព្រះនគរ។ មហោសថ មើលណេះ មើលណោះ ប្រទះឃើញនូវសត្វលាមួយកំពុងតែដើរនៅលើភ្លឺនៃស្នាមក្លោះ ហើយក៏ប្រើមាណពកម្លាំងខ្លាំងពីរបីនាក់ ដោយប្រាប់ថា៖

“បងប្រុស! បងចូរទៅដេញចាប់សត្វលានុ៎ះមើល ពេលចាប់បាន ចូរបងចងឃ្លុំមាត់វា រុំនឹងកន្ទេលឲ្យជិត ដើម្បីកុំឲ្យវាស្រែកឮ រួចសែងយកមក”។

មាណពប៉ុន្មាននាក់នោះ បានធ្វើតាមដូច្នោះ ហើយសែងលាដើរតាមមហោសថ ដែលលោកធ្វើដំណើរចូលទៅកាន់នគរ ជាមួយនឹង

បរិវារជាច្រើនៗ មហាជនឮល្បីថា "កូនប្រុសរបស់សិរីវឌ្ឍនសេដ្ឋីនុ៎ះ ឈ្មោះមហោសថបណ្ឌិត ឮថា កាលគេកើតមក បានក្តាប់ឱសថមួយដុំមកជាមួយ និងឮថា មហោសថនេះជាក្មេងឈ្លាសវៃ ចេះដោះបញ្ហាសាកល្បងប៉ុណ្ណោះ បញ្ហាប្រៀបធៀបប៉ុណ្ណោះ"ៗ ដូច្នេះ ពួកអ្នកនគរម្នាក់ៗ ចោលភ្នែកមើលតាមមហោសថផង សរសើរផង ក្មេងដើរទៅកាន់កំពង់ចំណាតដំរីសេះ ក្មេងធ្វើការផាររអស់ៗ ចំណែកមហោសថដល់ទ្វាររាជវាំងហើយ បានឲ្យគេទៅក្រាបទូលព្រះរាជា ដើម្បីចូលទៅថ្វាយបង្គំៗ ព្រះរាជាគ្រាន់តែឮថា មហោសថមកដល់ភ្លាម ព្រះអង្គទ្រង់សប្បាយព្រះទ័យ ត្រេកអរយ៉ាងខ្លាំង ហើយមានព្រះរាជឱង្ការថា៖

"មហោសថបណ្ឌិតកូនយើង ចូរមកឲ្យឆាប់"ៗ

មហោសថ និងមិត្រសម្លាញ់ ១.០០០ នាក់ ដើរឡើងទៅប្រាសាទនាំគ្នាថ្វាយបង្គំព្រះរាជា រួចឈរនៅក្នុងទីសមគួរៗ ព្រះរាជាទតឃើញដូច្នោះ ព្រះរាជាមានព្រះទ័យសោមនស្សយ៉ាងខ្លាំងបានធ្វើបដិសណ្ឋារៈដោយព្រះរាជឱង្ការផ្អែមដូចទឹកឃ្មុំថា៖

"នែបណ្ឌិត ចូរអ្នកដឹងអាសនៈសមគួរ ហើយចូរអង្គុយចុះ"ៗ

គ្រានោះ ស្រាប់តែមហោសថក្រឡេកមើលឪពុករបស់ខ្លួនៗ ក្នុងពេលទន្ទឹមគ្នានោះ ឪពុករបស់មហោសថក្រោកឡើង ដោយដឹងសញ្ញាពីមហោសថ ហើយនិយាយថា៖

“លោកបណ្ឌិតកូន សូមអញ្ជើញមកអង្គុយលើអាសនៈនេះចុះ”។ មហោសថ ក៏មកអង្គុយលើអាសនៈនោះ តាមការអញ្ជើញរបស់ឪពុក។

គ្រាន់តែឃើញមហោសថអង្គុយ លើអាសនៈឪពុកភ្លាម ពពួកអាចារ្យសេនកៈ បុក្កុសៈ កាមិន្ទៈ និងទេវិន្ទៈ និងក្រុមជនអន្ធពាលដទៃទៀត ទះដៃសើចហ៊ោពោលចំអកឲ្យថា៖

“កោតតែមនុស្សម្នា ហៅក្មេងអន្ធពាលនេះថាជាបណ្ឌិតទៅកើត គេដេញឪពុកឲ្យក្រោកចេញអំពីអាសនៈ ហើយអង្គុយដោយខ្លួនឯង ការហៅក្មេងនេះជាបណ្ឌិត មិនត្រូវទាល់តែសោះ”។

ដោយឃើញអាកប្បកិរិយានេះ ព្រះបាទវិទេហរាជបាក់ទឹកចិត្ត មានព្រះកន្ត្រស្រពោនលែងញញឹម មិនសប្បាយក្នុងព្រះទ័យឡើយ។ គ្រានោះ មហោសថ ក្រាបទូលសួរព្រះរាជាថា៖

“បពិត្រមហារាជ ចី[៣០]ក៏ព្រះអង្គមានព្រះកន្ត្រស្រពោន?”

---

[៣០] ចី ? (និ.) ថ្វី?, អ្វី?, មានបើអ្វី?; ពាក្យសម្រាប់សួរគ្នាដោយសេចក្ដីឆ្ងល់, ទាំងចង់ដឹងហេតុ ដឹងដំណើរនោះឆាប់ភ្លាមៗផង; ប្រើបានតែអ្នកធំសួរទៅអ្នកតូច ឬអ្នកដែលស្និទ្ធស្នាល, ដែលមានសភាពស្មើគ្នា; អ្នកតូចសួរទៅអ្នកធំក៏បានខ្លះ ប៉ុន្តែត្រូវឲ្យមានពាក្យគោរពឱនលំទោនណាមួយដាក់ជាខាងដើមដូចយ៉ាងពាក្យទាន, ទានប្រោស ជាដើម : ទានចី ?, ទានប្រោសចី ?, ចុះវាចីបានជាយំ ? (ព. សា.)។

"អើបណ្ឌិត យើងមុខស្រពោនមែន កាលឮកិត្តិសព្ទរបស់អ្នក យើងគាប់ព្រះទ័យខ្លាំងណាស់ ប៉ុន្តែដល់មកឃើញអាកប្បកិរិយាអ្នកបែបនេះ យើងមិនគាប់ព្រះទ័យឡើយ" ព្រះរាជាត្រាស់តប។

"ព្រោះហេតុអ្វី មហាបពិត្រ?" មហោសថសួរ។

"ព្រោះអ្នកជេរឪពុក ឲ្យក្រោកចេញអំពីអាសនៈ ហើយអង្គុយដោយខ្លួនឯង" ព្រះរាជាត្រាស់តប។

មហោសថសួរព្រះរាជាបន្តថា៖

"មហាបពិត្រ ចុះព្រះអង្គសម្គាល់ថា ឲ្យតែឪពុកសុទ្ធតែខ្ពង់ខ្ពស់ជាងកូនៗ គ្រប់កាលៈទេសៈឬ?"

"អើអ៊ីចឹងមែនហើយ បណ្ឌិត" ព្រះរាជាត្រាស់តប។

គ្រានោះ មហោសថសួរព្រះរាជាបន្តថា៖

"បពិត្រមហារាជ ក្រែងព្រះអង្គបញ្ជូនរាជសារទៅឲ្យពួកទូលបង្គំយើងខ្ញុំរកសេះអស្សតរ ឬអ្វីដែលប្រសើរជាងសេះអស្សតរ ពិតមែនឬ ក្រាបទូល?"

និយាយបានត្រឹមតែប៉ុណ្ណេះ មហោសថក្រោកពីអាសនៈឲ្យសញ្ញាទៅពួកមាណព ដើម្បីឲ្យគេសែងលាចូលមកដាក់ឲ្យដេកទៀបព្រះបាទរបស់ព្រះបាទវិទេហរាជ រួចមហោសថ ក្រាបទូលសួរព្រះរាជាថា៖

"បពិត្រមហារាជ លានេះថ្លៃប៉ុន្មាន?"

"នៃបណ្ឌិត បើវាប្រើការបាន ថ្លៃ៨ កហាបណៈ" ព្រះរាជាតប។

"ចុះសេះអស្សតរដែលនៅក្នុងផ្ទៃមេសេះអាជានេយ្យ ត្រូវបង្កាត់ដោយបាលា មានតម្លៃប៉ុន្មាន?" មហោសថសួរព្រះរាជា។

"វាកាត់ថ្លៃមិនបានទេ បណ្ឌិត" ព្រះរាជាឆ្លើយ។

មហោសថក្រាបទូលថា៖

"បពិត្រព្រះសម្មតិទេព ព្រោះហេតុអ្វីបានជាព្រះអង្គទ្រង់ត្រាស់យ៉ាងនេះ? ក្រែងព្រះអង្គមានព្រះរាជឱង្ការអម្បាញ់មិញថា មានតែឪពុកទេ ទើបខ្ពង់ខ្ពស់ជាងកូនគ្រប់កាលៈទេសៈ។ ប្រសិនបើពាក្យព្រះអង្គនោះ ជាពាក្យសច្ចៈ សមតែលាខ្ពង់ខ្ពស់ជាងសេះអស្សតរ ទើបត្រូវតាមយោបល់របស់ព្រះអង្គ។ មហាបពិត្រ ចុះបណ្ឌិតទាំងឡាយរបស់ព្រះអង្គ ម្តេចក៏មិនអាចដឹងត្រឹមតែការណ៍ប៉ុណ្ណឹង កោតតែនាំគ្នាទះដៃសើចហ៊ោទៅកើតដែរ ឱះឱ! បញ្ញាសម្បត្តិរបស់ពួកបណ្ឌិតព្រះអង្គ តើបានមកពីណា?"

ធ្វើការបំអកឲ្យបណ្ឌិត ៤ នាក់វិញដូច្នេះហើយ មហោសថបានក្រាបទូលព្រះរាជាបញ្ជាក់សេចក្តីដូច្នេះថា៖

"បពិត្រព្រះរាជាដ៏ខ្ពង់ខ្ពស់លើជនទាំងឡាយនៃដែនវិទេហៈ ប្រសិនបើព្រះអង្គសម្គាល់ថា ឪពុកប្រសើរជាងកូនគ្រប់កាលៈ-ទេសៈ សូម្បីលានេះ វាក៏ប្រសើរជាងសេះអស្សតររបស់

ព្រះអង្គដែរ។ ព្រោះហេតុអ្វី? ពីព្រោះលាជាបារបស់សេះ
អស្សតរ”។

លុះពោលយ៉ាងនេះហើយ មហោសថក្រាបទូលព្រះរាជាទៀតថា៖

“បពិត្រមហារាជ ប្រសិនបើឪប្រសើរជាងកូន សូមព្រះអង្គយក
ឪពុករបស់ទូលបង្គំចុះ ប្រសិនបើកូនប្រសើរជាងឪពុក សូម
ទ្រង់យកទូលបង្គំជាខ្ញុំចុះ ដើម្បីបម្រើប្រយោជន៍ដល់ព្រះអង្គ”។

ព្រះបាទវិទេហរាជ ទ្រង់បែរជាមានសោមនស្សវិញ។ រាជបុរសទាំង
ពួងបន្លឺវាចាថា៖

“បណ្ឌិតដោះស្រាយបញ្ហាបានល្អណាស់”

ហើយនាំគ្នាឲ្យពរសព្ទសាធុការទះដៃ និងគ្រវីទង់យ៉ាងគគ្រឹកគគ្រេង
អបអរសាទរចំពោះប្រាជ្ញាមហោសថ។ ចំណែកបណ្ឌិតទាំង ៤ នាក់
មានទឹកមុខស្រពោនស្រពាប់ក្រៀមក្រំ ដោយក្តីប្រណែន និងក្តីអស់
សង្ឃឹម។

**កំណត់ចំណាំ**

សំណួរ៖

អ្នកដឹងគុណម្តាយឪពុក ស្មើនឹងពោធិសត្វមិនមានទេ អ៊ីចឹងមែន
ឬ? កាលបើដូច្នេះ ព្រោះហេតុអ្វីបានជាមហោសថធ្វើយ៉ាងនេះ?

ចម្លើយ៖

ទី ១- ដើម្បីបញ្ជាក់ឲ្យច្បាស់ ចំពោះបញ្ហាដែលព្រះរាជាទ្រង់ឲ្យបញ្ចូនសេះអស្សតរ ឬអ្វីដែលប្រសើរជាងសេះអស្សតរ

ទី ២- ដើម្បីឲ្យព្រះរាជាទ្រង់ដឹងនូវភាពជាបណ្ឌិតរបស់ខ្លួន

ទី ៣- ដើម្បីកុំឲ្យបណ្ឌិតទាំង ៤ មានកិច្ចកលសើចចំអកលេង

អាកប្បកិរិយាមហោសថយ៉ាងនេះ មិនមែនជាការមើលងាយ[៣១] ឪពុករបស់ខ្លួនទេ។

**មហោសថចូលវាំង**

ព្រះបាទវិទេហៈ ទ្រង់មានព្រះហឫទ័យរីករាយ ត្រេកអរជាខ្លាំង ព្រះអង្គចាប់យកនូវសុវណ្ណភិង្ការ[៣២] ដែលពេញដោយទឹកក្រអូប ចាក់ទៅលើបាតដៃរបស់សិរីវឌ្ឍនសេដ្ឋី ហើយប្រកាសប្រាប់ថា៖

---

[៣១] មើលងាយ (កិ.) មើលឃើញថាងាយ, មើលយល់ថាងាយ គឺមើលទៅឃើញថាងាយស្ដី ងាយថា ងាយធ្វើ ជាដើម (មាក់ងាយ) : មើលងាយគេ, មើលងាយការ។ មើលងាយមើលថោក មើលឃើញថាងាយឃើញថាថោក គឺឃើញថាមិនក្រមិនមានតម្លៃ (មាក់ងាយមាក់ថោក)។

មាក់ងាយ (កិ.) មើលងាយ។ ន. សេចក្ដីមើលងាយ។

[៣២] សុវណ្ណភិង្ការ - កំសៀវទឹកធ្វើពីមាស។

"សួយសាអាករទាំងប៉ុន្មានដែលមាននៅក្នុងស្រុកបាចីនគ្រាម សូមលោកសេដ្ឋីប្រើប្រាស់ដោយរាជកោគៈចុះ រីឯសេដ្ឋីផ្សេងៗ ចូរធ្វើជាឧបដ្ឋាករបស់សិរីវឌ្ឍនសេដ្ឋី"

ដូច្នេះហើយ ទ្រង់ក៏បញ្ជូននូវគ្រឿងអលង្ការជាច្រើនឲ្យទៅម្ដាយមហោសថ។ ព្រះអង្គមានព្រះទ័យជ្រះថ្លាក្នុងប្រស្នាលា ទ្រង់បានស្នើសូមមហាសេដ្ឋី ដើម្បីយកមហោសថធ្វើជាបុត្ររបស់ព្រះអង្គថា៖

"ម្នាលគហបតី សូមអ្នកប្រគល់មហោសថឲ្យធ្វើជាកូនរបស់យើង"។

មហាសេដ្ឋីក្រាបទូលថា៖

"បពិត្រព្រះសម្មតិទេព មហោសថនេះនៅក្មេងពេកណាស់ សូម្បីក្នុងថ្ងៃនេះ ក្លិនទឹកដោះស្រស់ មិនទាន់បាត់កាយចេញពីមាត់របស់គេទេ ចាំដល់ពេលគេធំសិន គេមុខតែនឹងមកនៅបម្រើក្នុងព្រះរាជដំណាក់របស់ព្រះអង្គម្ចាស់"។

ព្រះរាជាត្រាស់តបថា៖

"ម្នាលគហបតី ចាប់ពីថ្ងៃនេះតទៅ អ្នកកុំនឹកអាល័យមហោសថអី ព្រោះរាប់ពីថ្ងៃនេះរហូតទៅ គេជាកូនរបស់យើងហើយ។ យើងនឹងចិញ្ចឹមមហោសថ អ្នកចូរត្រឡប់ទៅវិញម្នាក់ឯងចុះ"។

ត្រាស់ដូច្នេះហើយ ទ្រង់ក៏ជូនដំណើរមហាសេដ្ឋី។

មហាសេដ្ឋីថ្វាយបង្គំលាព្រះរាជា រួចលើកបីមហោសថបណ្ឌិត ផ្ដេកផ្អឹបនឹងទ្រូង ថើបក្បាលកូនហើយផ្ដល់នូវឱវាទផ្ដែផ្ដាំថា៖

"នែមហោសថកូន! ចូរកូនកុំមានសេចក្ដីប្រហែសធ្វេសឲ្យសោះ"។ ចំណែកមហោសថ ថ្វាយបង្គំលើកទឹកចិត្តឪពុកថា៖

"បពិត្រលោកឪពុកជាទីគោរព សូមពុកកុំព្រួយបារម្ភអំពីខ្ញុំឡើយ" និយាយដូច្នេះហើយ ក៏ជូនដំណើរឪពុកចេញទៅ។ បន្ទាប់មក ព្រះរាជាសួរមហោសថបណ្ឌិតថា៖

"នែបា! អ្នកជាមនុស្សបរិភោគបាយខាងក្នុង ឬជាមនុស្សបរិភោគបាយខាងក្រៅ?"

មហោសថគិតថា "បរិវាររបស់អញ មានចំនួនច្រើន ការដែលអញជាមនុស្សបរិភោគបាយខាងក្រៅទើបគួរ" គិតរួច មហោសថបានក្រាបទូលព្រះរាជាថា "បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំមានចំណូលចិត្តបរិភោគបាយខាងក្រៅ"។ គ្រានោះ ព្រះរាជាបានបង្គាប់រាជបុរសឲ្យប្រទានគេហដ្ឋានមួយខ្នងដ៏សមគួរដល់មហោសថ និងសម្លាញ់របស់លោក ១.០០០ នាក់ទៀត ហើយចាត់អ្នកបម្រើឲ្យជួយផ្ដល់នូវស្បៀង និងគ្រឿងប្រើប្រាស់សព្វមុខតាមតម្រូវការ។ មហោសថ បានគាល់បម្រើព្រះរាជាតាំងពីពេលនោះមក។

**ប្រស្នាទី ១៩ កែវមណីក្នុងសំបុកក្អែក**

ចំណែកព្រះរាជា ទ្រង់មានបំណងចង់សាកល្បងមហោសថបណ្ឌិតថែមទៀត។ មានដំណើររឿងតំណាលដូចតទៅ៖

មហាជនបានមកគាល់ព្រះរាជា រាយការណ៍ថ្វាយព្រះអង្គថា៖

"បពិត្រព្រះសម្មតិទេព ក្នុងស្រះបោក្ខរណី មានកែវមណីមួយដ៏ប្រណីត"។

ព្រះរាជាហៅអាចារ្យសេនកៈមកសួរថា៖

"បានឮថា កែវមណីធ្លុះស្រមោលក្នុងស្រះបោក្ខរណី តើយើងនឹងឲ្យគេយកវាដោយវិធីដូចម្ដេច?"

"មហាបពិត្រ គួរតែឲ្យគេបាចទឹកចេញសិន សឹមយកកែវមណីនោះ" អាចារ្យសេនកៈ ក្រាបទូល។

ព្រះរាជាត្រាស់ថា៖

"បពិត្រលោកអាចារ្យ បើដូច្នោះ សូមធ្វើយ៉ាងហ្នឹងចុះ"។

អាចារ្យសេនកៈ បានកេណ្ឌមនុស្សជាច្រើននាក់ឲ្យមកប្រមូលផ្ដុំគ្នាបាចទាំងទឹក កើបទាំងភក់រកកែវមណី សូម្បីតែជីកដីបាតស្រះផង ក៏រកកែវមណីមិនឃើញ។ កាលបញ្ចូលទឹកពេញស្រះវិញ កែវមណីនៅតែធ្លុះស្រមោលមកលើស្រះបោក្ខរណីដដែល។ អាចារ្យសេនកៈធ្វើវិធីនោះ

ដដែលទៀតជាច្រើនដង នៅតែរកកែវមណីមិនឃើញ។ បន្ទាប់មក ព្រះរាជា ហៅមហោសថមកប្រាប់និងសួរថា៖

"នែបា! មានកែវមណីមួយប្រាកដនៅក្នុងស្រះបោក្ខរណី អាចារ្យសេនកៈឲ្យមនុស្សជាច្រើនបាចទឹក និងកើបភក់ចេញ ទោះបីជីកដីដល់បាតស្រះនោះ ក៏រកមិនឃើញ។ កាលបញ្ចូលទឹកពេញស្រះវិញ ស្រមោលកែវមណីនោះប្រាកដក្នុងស្រះដដែល តើអ្នកអាចឲ្យគេយកកែវមណីនោះបានឬទេ?"

មហោសថក្រាបទូលថា៖

"បពិត្រមហារាជ ការនុ៎ះមិនពិបាកពេកទេ សូមស្ដេចយាងទូលបង្គំនឹងបង្ហាញថ្វាយទ្រង់ទត ក្រាបទូល"។

ព្រះរាជាត្រេកអរនឹងពាក្យរបស់មហោសថបណ្ឌិត ទ្រង់បានយាងទៅកាន់ស្រះបោក្ខរណី ដោយមានមហាជនជាច្រើនចោមរោមជាបរិវារ ក្នុងព្រះបំណងថាទ្រង់នឹងបានទតឃើញនូវកម្លាំងប្រាជ្ញារបស់បណ្ឌិតមហោសថក្នុងថ្ងៃនេះ។

មហោសថ ឈរលើឆ្នេរស្រះ គយគន់រកកែវមណី ឃើញដើមត្នោតលើឆ្នេរស្រះ ក៏ដឹងច្បាស់ថា "កែវមណីមានពិត តែមិនមែនមាននៅក្នុងស្រះនេះទេ ប្រាកដជាក់ជានៅក្នុងសំបុកក្អែកលើដើមត្នោត" មហោសថ ក៏ក្រាបទូលព្រះរាជាថា៖

"បពិត្រព្រះសម្មតិទេព កែវមណីមិនមាននៅក្នុងស្រះទេ"។

"ចុះក្រែងស្រមោលវាប្រាកដនៅក្នុងស្រះនោះឬ?" ព្រះរាជាសួរ។

"បើដូច្នោះ សូមទ្រង់ឲ្យគេយកថាសទឹកមក" មហោសថពោល។ កាលអាមាត្យយកថាសទឹកមកដល់ មហោសថបង្ហាញថា៖

"សូមទតមើលចុះ ព្រះសម្មតិទេព! កែវមណីនេះ មិនត្រឹមតែធ្លុះស្រមោលនៅក្នុងស្រះប៉ុណ្ណោះទេ ថែមទាំងធ្លុះស្រមោលនៅក្នុងថាសនេះផងដែរ"។

"នែបណ្ឌិត! ចុះកែវមណីនៅកន្លែងណា?" ព្រះរាជាសួរ។

"បពិត្រព្រះសម្មតិទេព ស្រមោលដែលធ្លុះនៅក្នុងស្រះផង ក្នុងថាសផង មិនមែនជាកែវមណីពិតទេ គ្រាន់តែជាស្រមោលធ្លុះប៉ុណ្ណោះ ឯកែវមណីពិត មាននៅក្នុងសំបុកក្អែកនៅលើដើមត្នោតឯណោះ សូមព្រះអង្គទ្រង់បង្គាប់បុរសណាម្នាក់ឲ្យឡើងដើមត្នោតយកវាមក ក្រាបទូល" មហោសថក្រាបទូល។

ព្រះរាជាទ្រង់ប្រើបុរសម្នាក់ឲ្យឡើងទៅយក។ បុរសនោះ យកបានហើយ បានប្រគល់ឲ្យទៅមហោសថបណ្ឌិត។ មហោសថបណ្ឌិតទទួលកែវមណីនោះ ហើយក៏ថ្វាយដល់ព្រះរាជា។ មហាជន ឃើញការពិតដូច្នោះហើយ បានឲ្យពរសព្ទសាធុការដល់មហោសថ និងរិះគន់អាចារ្យសេនកៈថា៖

"កែវមណីនៅក្នុងសំបុកក្អែកលើដើមត្នោតឯនេះសោះ អាចារ្យសេនកៈប្រើមនុស្សជាច្រើននាក់ឲ្យបំផ្លាញស្រះបោក្ខរណី បែកទឹក បែកភក់អស់ ចំជាល្ងង់មែនៗ ឯមហោសថនេះ ទើបបានហៅពេញជាបណ្ឌិតពិតប្រាកដ"ៗ

ដូច្នេះហើយ ពួកគេបានស្ញើចសរសើរប្រាជ្ញានៃព្រះមហាសត្វៗ សូម្បីព្រះរាជា ក៏ទ្រង់សព្វព្រះរាជហឫទ័យនឹងមហោសថដែរ ព្រះអង្គទ្រង់បានប្រទានកែវមុក្តាហារ ជាគ្រឿងប្រដាប់ព្រះសូរងរបស់ព្រះអង្គផ្ទាល់ ដល់មហោសថ និងបង្គាប់ឲ្យគេប្រទានខ្សែរក្រងធ្វើពីកែវមុក្តាដល់ពួកសម្លាញ់នៃមហោសថផងៗ ព្រះរាជាទ្រង់អនុញ្ញាត សូមមហោសថនិងបរិវារបម្រើដោយការរក្សាបែបនេះៗ

គទ្រភបញ្ហា ចប់ៗ

# ជំពូកទី ៤

## មហោសថគាល់បម្រើព្រះបាទវិទេហរាជ

### កកណ្ឋកបញ្ហា

ប្រស្នាសត្វបង្កួយបានខ្សែកពាក់

**សត្វបង្កួយចេះគោរពព្រះរាជា**

តមកក្នុងថ្ងៃមួយ ព្រះរាជាស្តេចយាងទៅកាន់ឧទ្យានជាមួយនឹងបណ្ឌិតមហោសថ។ គ្រានោះ សត្វបង្កួយមួយដែលរស់នៅលើខ្លោងទ្វារ វាឃើញព្រះរាជាកំពុងតែយាងមក ក៏ចុះមកដេកលើដី។ ព្រះរាជាក្រឡេកឃើញនូវអាកប្បកិរិយារបស់សត្វបង្កួយនោះ ទ្រង់សួរមហោសថថា៖

"នែបណ្ឌិត! តើបង្កួយនេះកំពុងធ្វើអ្វី?"

"បពិត្រមហារាជ វាកំពុងតែគោរពព្រះអង្គ" មហោសថទូលពិត។

"ប្រសិនបើវាគោរពយើងយ៉ាងនេះ កុំឲ្យឥតប្រយោជន៍អី ប្រទានទ្រព្យឲ្យវាខ្លះទៅ" ព្រះរាជាទ្រង់ត្រាស់។

មហោសថ ក្រាបទូលថា៖

"បពិត្រមហារាជ សត្វបង្កួយនោះមិនត្រូវការប្រើប្រាស់ទ្រព្យអ្វីទេ ឲ្យត្រឹមតែចំណីវាស៊ី សមគួរណាស់ហើយ"

"ចុះវាស៊ីអ្វី?" ព្រះរាជាទ្រង់ត្រាស់សួរ។

"វាស៊ីសាច់ជាអាហារ ក្រាបទូល" មហោសថទូលថ្វាយ។

"គួរឲ្យសាច់តម្លៃប៉ុន្មាន" ព្រះរាជាត្រាស់សួរ។

"តម្លៃ ១ កាកណិកសមល្មមហើយ ព្រះអង្គ" មហោសថឆ្លើយ។

"រាជអំណោយ តម្លៃ ១ កាកណិក[៣៣] មិនសមរម្យទេ ចូរអ្នកយកសាច់តម្លៃពាក់កណ្តាលមាសកៈ[៣៤] ឲ្យដល់សត្វបង្កួយនេះឲ្យបានរៀងរាល់ថ្ងៃចុះ" ព្រះរាជាទ្រង់បង្គាប់រាជបុរសម្នាក់។

## សត្វបង្កួយមិនគោរពព្រះរាជា

រាជបុរសនោះបានធ្វើតាមរាជបញ្ជា តាំងពីគ្រានោះមក។ ក្នុងថ្ងៃមួយ រាជបុរសរកទិញសាច់មិនបាន ព្រោះថ្ងៃនោះជាថ្ងៃឧបោសថ ដែលច្បាប់មិនអនុញ្ញាតឲ្យសម្លាប់សត្វទេ គេក៏បានយកប្រាក់ពាក់កណ្តាលមាសកៈនោះ ដោតជាខ្សែកពាក់ឲ្យសត្វបង្កួយនោះ។ ក្រោយមក សត្វបង្កួយដំឡើងឫកក្រអឺតក្រទមកាច់រាង ដោយសារតែ

---

[៣៣] កាកណិក កាក:ណិក បា. (ន.) ឈ្មោះប្រាក់បុរាណដែលគេប្រើក្នុងមជ្ឈិមប្រទេស។

[៣៤] មាសក មាសក់ បា.; សំ. (ន.) (មាចក) ទម្ងន់ដែលស្មើគ្នានឹងសណ្តែករាជមាសមួយគ្រាប់; ឈ្មោះប្រាក់មួយប្រភេទ សម្រាប់ចាយក្នុងសម័យបុរាណ : ចំនួនប្រាំមាសក ជាមួយបាទ (ព. វ. ពុ.)។

បានពាក់ខ្សែកប្រាក់នោះៗ គាប់ចួនថ្ងៃមួយ ព្រះរាជាស្ដេចយាងមក ឧទ្យានជាមួយនឹងមហោសថម្ដងទៀតៗ សត្វបង្កួយនោះ ទោះបីឃើញស្ដេចកំពុងតែយាងមក វាដេកដំអក់ខ្លួនអង្រែន់ក្បាលធ្វើមិនដឹងនៅលើខ្លោងទ្វារនោះឯង មិនចុះមកគោរពព្រះរាជាដូចពីមុនទេ ថែមទាំងធ្វើឫកក្រអឺតក្រអោង ដោយអាងបានទ្រព្យបន្ដិចបន្តួច ក៏សម្ញែង[៣៥]ខ្លួនឯងប្រៀបស្មើនឹងស្ដេច ដោយមានគំនិតថា៖

"នៃវិទេហៈ! អ្នកមានទ្រព្យច្រើន ឬខ្ញុំនេះវិញទេ?"

ព្រះបាទវិទេហរាជទតឃើញអាកប្បកិរិយាវាដូច្នោះ ក៏សួរមហោសថថា៖

"នៃបណ្ឌិត! ហេតុអ្វីបង្កួយនុ៎ះមិនចុះមកក្រោមដូចថ្ងៃមុន? ថ្ងៃមុនវាមិនចំកោងខ្លួនកាច់រាងយ៉ាងនេះទេ តែឥឡូវវានៅលើខ្លោងទ្វារធ្វើឫកក្រអឺតក្រទមណាស់ៗ នៃមហោសថ! តើមានរឿងអ្វីទៅ?"

មហោសថបណ្ឌិត ឮព្រះបន្ទូលរបស់ព្រះរាជាហើយ ដឹងថា "ក្នុងថ្ងៃឧបោសថមានបម្រាមហាមសម្លាប់សត្វ រាជបុរសកាលរកទិញសាច់មិនបាន ក៏បំពាក់ប្រាក់អឌ្ឍមាសកៈនោះជាប់នឹងកបង្កួយ ព្រោះ

---

[៣៥] សម្ញែង សំ-ញ៉ែង (កិ.) ធ្វើឲ្យគេស្ញែង, បញ្ចេញឲ្យគេស្ញែង ខ្លាចគេមិនដឹងថាខ្លួនមាន : ដាក់របស់សម្ញែងឲ្យគេឃើញ, សម្ញែងខ្លួនៗ

ដូច្នេះ បានជាវាមានឫទ្ធិដឹងយ៉ាងនេះ” យល់ដូច្នេះ មហោសថក្រាប ទូលស្ដេចថា៖

“សត្វបង្កួយនេះ បានប្រាក់ពាក់កណ្ដាលមាសក: ដែលវាមិនធ្លាប់បានពីមុនមក ទើបវាមើលងាយព្រះបាទវិទេហរាជ អ្នកគ្រប់គ្រងក្រុងមិថិលា”។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យរបស់មហោសថបណ្ឌិតហើយ ក៏ប្រើគេ ឲ្យទៅហៅរាជបុរសអ្នកចិញ្ចឹមបង្កួយនោះមកចូលគាល់ ហើយទ្រង់ធ្វើការសាកសួរ។ រីឯបុរសនោះ បានក្រាបទូលឲ្យស្ដេចទ្រង់ជ្រាបតាមដំណើររឿងគ្រប់សព្វ។ ព្រះរាជាទ្រង់ស្ដាប់សម្ដីនោះហើយ ទ្រង់មានព្រះតម្រិះថា “មហោសថបណ្ឌិត មិនបានសួរនរណាម្នាក់សោះ ក៏ចេះមានប្រាជ្ញាដឹងអធ្យាស្រ័យរបស់សត្វបង្កួយ ហាក់បីដូចជាព្រះសព្វញ្ញុពុទ្ធ”។ គិតដូច្នេះហើយ ទ្រង់ជ្រះថ្លាក្រៃលែង បានឲ្យគេប្រទានសួយសាអាករ ៤ ស្រុក ដល់មហោសថបណ្ឌិត។ ប៉ុន្ដែស្ដេចទ្រង់ខ្ញាល់ចំពោះសត្វបង្កួយ បម្រុងនឹងបញ្ជាគេឲ្យដករាជអំណោយចេញ ប៉ុន្ដែមហោសថបណ្ឌិត ក្រាបទូលឃាត់ព្រះអង្គថា “បពិត្រមហារាជ កុំដកព្រះរាជអំណោយពីវាអី”។

ព្រះរាជាទ្រង់យល់ព្រម។

កកណ្ដកបញ្ហា ចប់។

# សិរិកាឡកណ្ណិបញ្ហា

## ស្រីបុណ្យខ្ពស់ ប្រុសឥតនិស្ស័យ

### ប្រពៃណីអាចារ្យទិសាបាមោក្ខ

*កាលកន្លងមក មាណពម្នាក់ឈ្មោះ* ***បិង្គុត្តរ*** *មានលំនៅក្នុងក្រុងមិថិលា គេបានធ្វើដំណើរទៅកាន់ក្រុងតក្កសីលា សិក្សានូវសិល្ប៍ក្នុងសម្នាក់របស់អាចារ្យទិសាបាមោក្ខ។ មាណពនោះ បានសិក្សាចេះចាំយ៉ាងរហ័ស។ បិង្គុត្តរមាណពនោះ បានជូនថ្ងៃសិក្សាហើយគោរពលាអាចារ្យត្រឡប់ទៅផ្ទះវិញ។ ប៉ុន្តែក្នុងត្រកូលអាចារ្យនោះមានប្រពៃណីដូច្នេះ ៖ "ប្រសិនបើមានកូនស្រីពេញវ័យក្រមុំ ត្រូវផ្សំផ្គុំជាមួយនឹងសិស្សជារៀមច្បង"។ ព្រោះហេតុដូច្នោះ លោកអាចារ្យ មានកូនស្រីម្នាក់ពេញវ័យក្រមុំ មានរូបឆោមស្រស់ល្អឆើត សម្បុរស្រស់ថ្លាប្រៀបបាននឹងស្រីទេពអប្សរ។*

*គ្រានោះ អាចារ្យប្រាប់បិង្គុត្តរមាណពថា៖*

*"នែមាណព! យើងនឹងផ្សំផ្គុំកូនស្រីយើងឲ្យជាភរិយារបស់អ្នក ចូរអ្នករៀបការជាមួយនឹងនាងហើយ សឹមចេញដំណើរទៅផ្ទះចុះ" រីឯមាណពនោះ ជាមនុស្សកាឡកណ្ណី ឥតកព្វសំណាងសាងពីព្រេង*

នាយ[៣៦] ចំណែកកូនក្រមុំអាចារ្យ ជាមនុស្សមានបុណ្យសំណាងខ្ពស់។ ចិត្តរបស់មាណព មិនបេតីលើនាងបន្តិចសោះ ទោះឃើញនាងស្អាតយ៉ាងណាក៏ដោយ ដោយហេតុតែខ្លួនជាសិស្សក៏យល់ព្រមឆ្លើយចំពោះមុខអាចារ្យថា "ខ្ញុំមិនជំទាស់ពាក្យលោកគ្រូទេ"។

**រៀបការរួចហើយឥតសំណាង**

លោកអាចារ្យទិសាបាមោក្ខ ក៏រៀបចំផ្សំផ្គុំកូនស្រីខ្លួននោះឲ្យជាប្រពន្ធរបស់មាណព។ ក្នុងវេលាយប់ផ្សំដំណេក បន្ទប់ត្រូវមាណពដេកលើគ្រែសិរីសួស្តី ដែលតុបតែងយ៉ាងស្អាត ក្នុងថ្ងៃមង្គលការ។ កូនក្រមុំក៏ឡើងគ្រែបម្រុងដេកក្បែរប្តី[៣៧] ស្រាប់តែមាណពជាប្តីមានចិត្តធុញទ្រាន់ជិនឆ្អន់ ដេកមិនសុខ ព្រោះមិនពេញចិត្ត ក៏ចុះពីលើគ្រែមកដេកនៅខាងក្រោម។ រីឯកូនក្រមុំចុះទៅតាមដេកក្បែរប្តីទៀត ប្តីក្រោកមកដេកលើគ្រែវិញ។ នាងក៏ឡើងតាមដេកក្បែរប្តីម្តងទៀត ប្តីនោះបែរជាចុះពីលើគ្រែ មកដេកនៅខាងក្រោមវិញ។ នេះឯង ដែលហៅថាមនុស្សកាឡកណ្ណី មិនសក្តិសមនឹងសិរីសួស្តីឡើយ។

[៣៦] ទុក្កគោ កាឡកណ្ណី។

[៣៧] តាយ អាគន្ត្វា សយនំ អភិរុឡ្ហមត្តាយ អឌ្ឍិយមានោ ហរាយមានោ ។

ចំណែកកូនក្រមុំ ផែងមានចិត្តតាម ក៏ដេកនៅលើគ្រែម្នាក់ឯងលង់លក់រហូតទល់ភ្លឺ ឯមាណពនោះក៏ដេកនៅខាងក្រោមម្នាក់ឯងទៅ។

**បិង្គុត្តរមាណពចោលប្រពន្ធលើដើមល្វា**

លុះរស់នៅរបៀបនេះអស់រយៈ ៧ ថ្ងៃហើយ បិង្គុត្តរមាណពក៏នាំកិរិយាថ្វាយបង្គំលាអាចារ្យចេញដំណើរទៅផ្ទះខ្លួន។ នៅតាមផ្លូវអ្នកទាំងពីរ ពុំមានសម្ដីចរចាគ្នាមួយម៉ាត់សោះ ពួកគេទាំងពីរចេះតែដើរៗទៅ ទាំងចិត្តមិនចង់នៅរួមគ្នាទាល់តែសោះ រហូតទៅជិតក្រុងមិថិលា។ គ្រានោះ បិង្គុត្តរមាណពឃើញដើមឧទុម្ពរ(ដើមល្វា)មួយដើមមានផ្លែច្រើនសន្ធឹក នៅមិនឆ្ងាយអំពីទីក្រុងប៉ុន្មាន មាណពឃ្លានខ្លាំងពេកក៏ឡើងដើមឧទុម្ពរនោះ បេះផ្លែបរិភោគ។ ចំណែកប្រពន្ធ ហេតុតែឃ្លានខ្លាំងដែរ ក៏ទៅឈរជិតគល់ឈើហើយស្រែកប្រាប់ប្ដីថា៖

"បងសម្លាញ់ អូនឃ្លានណាស់ សូមបងទម្លាក់ឲ្យខ្ញុំហូបផង"។ ប្ដីតបពីលើចុងឈើមកថា៖

"នាងមិនមានដៃជើងទេឬអី បានជាមិនចេះឡើងបេះធីខ្លួនឯង"។ ប្រពន្ធក៏ដាច់ចិត្តឡើងទៅបេះហូបដោយខ្លួនឯងដែរ។ បិង្គុត្តរមាណពដឹងថានាងឡើងហើយ គេចុះមកវិញយ៉ាងលឿន យកបន្លាស្រោស់ជុំវិញដើមល្វា ហើយរត់ចេញទៅទាំងស្រែកថា "អញលែងមេកាឡកណ្ណីស្រីចង្រៃឯងនេះហើយ!"។

**សំណាងស្រីប្ដីរត់ចោល**

ចំណែកធីតានោះ កាលមិនអាចចុះមកវិញរួច ក៏អង្គុយលើប្រគាបឈើ សញ្ជប់សញ្ជឹងឯកាតែម្នាក់ឯង។ គាប់ចួនគ្រានោះ ព្រះបាទវិទេហរាជ ស្ដេចទ្រង់ជិះដំរីយាងប្រពាតឧទ្យាន លុះដល់វេលារសៀល ស្ដេចយាងត្រឡប់ទៅនគរវិញ ដល់ក្បែរដើមល្វា ក៏ទតព្រះនេត្រឃើញធីតានោះនៅលើប្រគាបដើមល្វា អង្គុយត្រមោចត្រមង់តែម្នាក់ឯង ទ្រង់មានហឫទ័យប្រតិពទ្ធភ្លាម ហើយប្រើអាមាត្យឲ្យទៅសួរថា៖

"តើនាងមានគេហួងហែងហើយ ឬមិនទាន់មាននៅឡើយទេ?" ធីតានោះឆ្លើយថា៖

"អ្នកប្រុស នាងខ្ញុំមានប្ដីហើយដែលម្ដាយឪពុកផ្សំផ្គុំក្នុងត្រកូល ប៉ុន្តែប្ដីនាងខ្ញុំ ទុកឲ្យខ្ញុំអង្គុយនៅទីនេះ ហើយរត់ចោលខ្ញុំបាត់ទៅ"។ ចំណែកអាមាត្យ មកក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាបអំពីស្ថានការណ៍នោះ។ ព្រះរាជាមានព្រះតម្រិះថា "ធម្មតា ទ្រព្យឥតម្ចាស់ គឺជាទ្រព្យរបស់ស្ដេច" ហើយក៏ទ្រង់ដាក់នាងចុះឲ្យជិះដំរី នាំចូលទៅកាន់ព្រះរាជ-និវេសន៍ អភិសេកតាំងនាងក្នុងឋានៈជាអគ្គមហេសី។ នាងបានជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ព្រះបាទវិទេហរាជ។ អ្នកផង តែងហៅឈ្មោះនាងថា **ឧទុម្ពរទេវី** ព្រោះនាងជានារីដែលស្ដេចបានយកមកពីលើដើមល្វា។

**ឧទុម្ពរទេវីជួបប្ដីដើម**

តមកក្នុងថ្ងៃមួយ ពួកអ្នកស្រុកដែលនៅក្បែរទ្វារ នាំគ្នាជម្រះផ្លូវដើម្បីទទួលព្រះរាជដំណើររបស់ព្រះរាជាយាងទៅប្រពាតឧទ្យាន។ បិង្គុត្តរមាណព ក៏បានទៅស៊ីឈ្នួលក្នុងការងារនោះដែរ គាត់បានចងក្បិនកាន់ចបមួយ កាប់ជម្រះសម្អាតផ្លូវជាមួយនឹងអ្នកស្រុកផងទាំងឡាយ។ កាលផ្លូវមិនទាន់សម្រេចនៅឡើយ ព្រះរាជានឹងព្រះនាងឧទុម្ពរទេវី គង់ប្រថាប់លើរថទន្ទឹមគ្នា យាងតាមផ្លូវនោះ។ ឧទុម្ពរទេវី ចោលព្រះនេត្រាទៅប្រទះនឹងបិង្គុត្តរមាណព ដែលជាមនុស្សកាឡកណ្ណីកំពុងតែឈូសចាំងជម្រះផ្លូវ ទប់សំណើចមិនបាន នាងក៏នឹកហួសចិត្តថា "បុរសនេះជាកាឡកណ្ណី ទើបមិនអាចទ្រទ្រង់សិរីបែបនេះបាន"។ ព្រះរាជាឃើញនាងសើច ទ្រង់ពិរោធសួរព្រះនាងថា៖

"ហេតុអ្វីបានជានាងសើច? មានរឿងអ្វីឬ?"

"បពិត្រព្រះសម្មតិទេព បុរសអ្នកជម្រះផ្លូវនោះជាប្ដីដើមរបស់ខ្ញុំម្ចាស់ គេនេះឯងដែលទុកខ្ញុំម្ចាស់លើដើមល្វាស្រោសបន្ទាជុំវិញ ហើយរត់ចោលខ្ញុំម្ចាស់។ ខ្ញុំម្ចាស់មើលឃើញ នឹកហួសចិត្តថា គេនេះជាកាឡកណ្ណីទេតើ ទើបមិនអាចទ្រទ្រង់នូវសិរីបែបនេះបាន នឹកឃើញដូច្នេះ ទើបខ្ញុំម្ចាស់សើច" ព្រះនាងឆ្លើយ។

ព្រះរាជាឆាដាវឡើង មានព្រះរាជឱង្ការគំរាមថា៖

"នាងនិយាយកុហក នាងសើចព្រោះឃើញបុរសដទៃណាមួយ យើងនឹងសម្លាប់នាង"។

ឧទុម្ពរទេវីដល់នូវសភាពភ័យខ្លាច ក្រាបទូលព្រះរាជាថា៖

"បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់រកហេតុផលដោយសួរពួកបណ្ឌិតសិន កុំអាលខ្វល់ព្រះអង្គ!"។

ព្រះរាជាសួរអាចារ្យសេនកៈថា៖

"នែសេនកៈ លោកជឿពាក្យរបស់អគ្គមហេសីនេះឬទេ?"

អាចារ្យសេនកៈក្រាបទូលថា៖

"ទូលបង្គំមិនជឿទេ ក្រាបទូល បុរសណាក៏កំសាកញីម៉្លេះ ដាច់ចិត្តរត់ចោលស្ត្រីកែវបែបនេះ"។

**មហោសថជួយព្រះមហេសី**

ឧទុម្ពរទេវីឮសម្ដីរបស់អាចារ្យសេនកៈរឹតតែភ័យខ្លាចខ្លាំងឡើង។ គ្រានោះ ព្រះរាជាមានព្រះតម្រិះថា "អាចារ្យសេនកៈនេះ មិនចេះដឹងអ្វីទេ យើងនឹងសួរមហោសថបណ្ឌិតវិញ" រួចទ្រង់សួរមហោសថថា៖

"នែមហោសថ ស្ត្រីមានរូបល្អដូចកែវ ថែមទាំងមានមារយាទត្រឹមត្រូវ តើអ្នកជឿទេ មានមនុស្សប្រុសឯណាដែលមិនមានចិត្តប៉ងប្រាថ្នានាង?"

"ទូលព្រះបង្គំជាខ្ញុំជឿ ព្រះអង្គ! មនុស្សប្រុសឥតកព្វជាកាឡកណ្ណី និងមនុស្សស្ត្រីដែលមានសិរីសួស្តី គឺមិនស៊ីសង្វាក់គ្នាឡើយ[៣៨] ខុសគ្នាឆ្ងាយណាស់មិនត្រូវគ្នាទេ បីដូចត្រើយសមុទ្រ ខាងអាយ និងត្រើយសមុទ្រខាងនាយ ឬបីដូចផ្ទៃមេឃនិងផែនដី ឆ្ងាយគ្នាណាស់ ក្រាបទូល" មហោសថក្រាបទូល។

ព្រះរាជា ទ្រង់ព្រះសណ្តាប់នូវហេតុការណ៍នោះ តាមការពន្យល់របស់មហោសថបណ្ឌិត ហើយលែងមានសេចក្តីពិរោធចំពោះព្រះនាងឧទុម្ពរទេវី ស្រាកកំហឹងអស់ពីព្រះទ័យ។ ព្រះរាជាទ្រង់ត្រេកអរចំពោះមហោសថថា "បើកុំតែបានមហោសថបណ្ឌិត ម៉្លេះសមអញប្រាសនិរាសចាកស្ត្រីកែវបែបនេះពុំខាន ព្រោះសម្តីរបស់ពាលសេនកៈ អញបាននាងដោយសារមហោសថទេតើ"។ ទ្រង់ព្រះតម្រិះដូច្នេះហើយ ទ្រង់ចេញព្រះរាជបញ្ជា ឲ្យរៀបចំពិធីបូជាដោយចំណាយព្រះរាជទ្រព្យ ១០០.០០០ កហាបណៈ ដល់មហោសថបណ្ឌិត។

**ឧទុម្ពរទេវីសូមមហោសថធ្វើប្អូនធម៌**

ព្រះនាងឧទុម្ពរទេវី ថ្វាយបង្គំថ្លែងអំណរគុណព្រះរាជា និងសូមពរពីព្រះរាជាថា៖

[៣៨] ន សមេន្តិ កុទាចនំ។

“បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់បានជីវិតរស់ ព្រោះអាស្រ័យបណ្ឌិតមហោសថ ខ្ញុំម្ចាស់សូមពរពីព្រះអង្គ សូមព្រះអង្គតែងតាំងបណ្ឌិតរូបនេះ ជាប្អូនប្រុសរបស់ខ្ញុំម្ចាស់”។

ព្រះរាជាត្រាស់ថា៖

“ប្រពៃហើយ ព្រះនាងទេវី! សូមនាងទទួលយកចុះ យើងឲ្យពរនោះដល់នាង”

ឧទុម្ពរទេវីក្រាបទូលថា៖

“បពិត្រព្រះសម្មតិទេព ពីថ្ងៃនេះទៅ ខ្ញុំនឹងសោយក្រយាឆ្ងាញ់ៗដោយមិនមានប្អូនខ្ញុំពុំបានទេ ពីពេលនេះទៅ ខ្ញុំម្ចាស់សូមពរដើម្បីបានបញ្ជូនអាហារឆ្ងាញ់ៗនោះ[៣៩] ដល់មហោសថផងទោះក្នុងពេលត្រូវកាលក្តី ខុសកាលក្តី សូមព្រះអង្គឲ្យគេបើកទ្វារឲ្យ ក្រាបទូល”។

ព្រះរាជាត្រាស់ថា៖

“ប្រពៃហើយនាង! នាងទទួលយកពរនេះចុះ យើងប្រទានដល់នាងតាមសេចក្តីស្នើសូមគ្រប់យ៉ាង”។

សិរិកាឡកណ្ណិបញ្ហា ចប់។

---

[៣៩] មធុរសំ

## មេណ្ឌកបញ្ហា

ប្រស្នាអាថ៌កំបាំងនៃពពែនិងសុនខ

**សត្វពពែនិងសត្វសុនខយកគ្នាជាមិត្ត**

ថ្ងៃមួយក្រោយមកទៀត ព្រះបាទវិទេហរាជ ទ្រង់សោយក្រយាស្ងោយព្រឹក រួចទ្រង់យាងតាមចន្លោះល្វែងនៃប្រាសាទ[៤០] ទតតាមបង្អួចប្រទះឃើញពពែមួយនិងសុនខមួយ រស់នៅជាមួយគ្នាដោយសេចក្តីស្និទ្ធស្នាល។

តាមដំណើររឿងថា មានពពែមួយទៅរោងស្មៅដំរី[៤១] ដែលពួកអ្នកថែដំរី កំពុងបោះស្មៅនៅពីមុខដំរី។ គ្រានោះ អ្នកយាមដំរីក៏វាយសំពងដេញពពែនោះមួយដំបងឲ្យវាចេញ។ ពពែនោះឈឺស្រែករត់ចេញទៅ។ លំដាប់នោះ បុរសម្នាក់ទៀត រត់តាមយ៉ាងលឿន វាយមួយ

---

[៤០] បាសាទស្ស ទីយន្តរេ ចង្កមន្តោ វាតបានន្តរេន ឱលោកេន្តោ។ ល្វែង (ន.) ប៉ែកសង្កាត់ផ្ទះលំនៅត្រង់ចន្លោះជួរសសរ : ល្វែងផ្ទះ, ល្វែងសាលា, ល្វែងវិហារ, ផ្ទះប្រាំល្វែង។ ល្វែងរាសិចក្រ ឬ ល្វែងមេឃ ភាគរាសីឬប៉ែកសង្កាត់មេឃក្នុងរាសិចក្រ (ម. ព. រាសិចក្រ និង រាសី ផង)។

[៤១] អនាមដ្ឋតិណាំ។

ដំបងចំកណ្ដាលខ្នងថែមទៀត។ ពពែនោះ ទ្រោមខ្លួនឈឺចុកចាប់ទៅដេកផ្ងារ[៤២]ជើង ក្បែរមហាកំពែងនៃព្រះរាជវាំង។

ក្នុងថ្ងៃជាមួយគ្នានោះដែរ សុនខមួយដែលធំធាត់ ដោយសារស៊ីឆ្អឹងនិងស្បែកជាដើម ក្បែរមហារោងចុងភៅរបស់ព្រះរាជា[៤៣] វាធុំក្លិនត្រីនិងសាច់របស់ពួកចុងភៅដែលចម្អិនបាយ ហើយនាំគ្នាទៅឈរសំដិលខ្លួន សម្លួតញើសនៅឯក្រៅ សុនខនោះកាលមិនអាចអត់សង្កត់នូវគម្លាន[៤៤] បាន វាក៏រត់ចូលទៅក្នុងមហារោងចុងភៅ ខាំទាញទម្លាក់ភាជន៍សាច់ធ្លាក់ចុះមកក្រោម ហើយត្របាក់ខាំស៊ីសាច់នោះ។ គ្រានោះចុងភៅរត់ចូលទៅតាមស្នូរភាជន៍ ឃើញឆ្កែនោះកំពុងតែត្របាក់សាច់ស៊ីក៏នាំគ្នាបិទទ្វារ ហើយដេញវាយសំពងដោយដំបង និងគប់គ្រវែងដុំដីជាដើម។ ឆ្កែនោះ ចោលដុំសាច់ដែលខាំចេញពីមាត់ ស្រែកថ្ងូរង៉េកៗ

[៤២] ផ្ងារ (កិ. ឬ កិ. វិ.) ប្រែយកពោះមកខាងលើ យកខ្នងទៅខាងក្រោមឬយកមុខមកខាងលើយកក្រោយទៅខាងក្រោម: ផ្ងារប្រែអប់; ដាក់ផ្ងារ, ដេកផ្ងារ, ដួលផ្ងារ។ ផ្ងារស្រទាង ផ្ងារដូចគេត្រដាង។ ផ្ងារបង្រ្គាង ផ្ងារប្រងាង។ ព. ផ្ទុ. ផ្កាប់។
[៤៣] រញ្ញោ មហានសេ រោងធំសម្រាប់ចម្អិនក្រយាស្ងោយរបស់ព្រះរាជា។
[៤៤] គម្លាន (ន.) សេចក្ដីឃ្លាន: ស៊ូទ្រាំអត់សម្រេកគម្លាន។ ពុទ្ធសុភាសិតថា រោគអ្វីពុំស្មើនឹងគម្លាន, គ្មានអ្វីពុំស្មើគ្មានប្រាជ្ញា, ចំណាប់អ្វីពុំស្មើនឹងទោសា, ជាអ្វីពុំស្មើនឹងចិត្តជា។ (ម. ព. ឃ្លាន ទៀតផង)។

ចេញទៅក្រៅវិញ។ ចំណែកចុងភៅ ដេញតាមវាយសំពងមួយដំបង ចំកណ្តាលខ្នងយ៉ាងពេញទំហឹងថែមទៀត។ ក្តែនោះ ឈឺចុកទ្រោមខ្លួនជាខ្លាំង ដើរលើកជើងម្ខាងចូលទៅប៉ះចំកន្ទែងដេករបស់ពពែ។

គ្រានោះ ពពែសួរសុនខថា៖

"នែសម្លាញ់! ហេតុអ្វីបានជាអ្នកដើរធ្វើខ្លួនត្រូនៗយ៉ាងនេះ? តើអ្នកកើតរោគខ្យល់ឬ?[៤៥]"

ចំណែកសុនខមិនទាន់ឆ្លើយសំណួរពពែភ្លាមទេ សួរទៅពពែវិញថា៖

"ចុះអ្នកវិញ មកដេកធ្វើដូចជារហិរហៃយ៉ាងនេះ តើអ្នកកើតរោគខ្យល់ដែរឬ?"

សត្វទាំងពីរក៏បានប្រាប់រឿងផ្ទាល់ខ្លួនដល់គ្នាទៅវិញទៅមក។

"នែសម្លាញ់! ចុះឯងអាចទៅផ្ទះបាយទៀតឬទេ?" ពពែសួរ។

"មិនអាចទេសម្លាញ់! បើខ្ញុំទៅប្រាកដជាស្លាប់ជាមិនខាន ចុះឯងវិញអាចទៅកាន់រោងដំរីទៀតដែរឬទេ?" សុនខតប។

"ខ្ញុំក៏មិនអាចទៅទីនោះដែរ បើខ្ញុំទៅប្រាកដជាស្លាប់" ពពែឆ្លើយ។

---

[៤៥] កឹ តេ វតោ វិជ្ឈតិ។

ពួកវាទាំងពីរ នាំគ្នារកឧបាយថា "ឥឡូវនេះ ធ្វើដូចម្ដេចហ្ន៎ ទើបយើងរស់បានក្នុងស្ថានភាពបែបនេះ?" គ្រានោះពពែបានបញ្ចេញនូវយោបល់ប្រាប់ដល់សុនខជាមុនថា៖

"ប្រសិនបើយើងនៅរួមរស់ស្មោះត្រង់ជាមួយគ្នា ប្រាកដជាមានឧបាយមួយ"។

"បើដូច្នោះ អ្នកនិយាយមកមើល" សុនខតប។

"នែសម្លាញ់ ពីពេលនេះទៅ ចូរអ្នកទៅរោងដំរី អ្នកយាមដំរីគេមិនសង្ស័យចំពោះអ្នកទេ គេគិតថាអ្នកមិនចេះស៊ីស្មៅ ដូច្នេះអ្នកត្រូវទៅពាំស្មៅគេមកឲ្យខ្ញុំ។ ចំណែកខ្ញុំ នឹងចូលទៅផ្ទះបាយ គេក៏មិនសង្ស័យចំពោះខ្ញុំដែរ ព្រោះគេគិតថាខ្ញុំមិនចេះស៊ីសាច់ ដូច្នេះ ខ្ញុំនឹងពាំយកសាច់មកឲ្យអ្នក" ពពែនិយាយ។

សត្វទាំងពីរយល់ព្រមគ្នាថាឧបាយនេះល្អ។ ពីគ្រានោះមក សត្វសុនខទៅរោងដំរី ខាំពាំស្មៅមួយបាច់យកមកដាក់ក្បែរមហាកំពែង រីឯសត្វពពែទៅផ្ទះបាយ ពាំសាច់មួយដុំបៀមពេញមាត់ យកមកដាក់ក្នុងទីនោះដែរ សុនខស៊ីសាច់ ពពែស៊ីស្មៅ ពួកវារស់នៅក្បែរមហាកំពែងរីករាយ ព្រមព្រៀងគ្នាដោយឧបាយនេះ។

## ព្រះបាទវិទេហរាជចោទប្រស្នា

ព្រះរាជា ទ្រង់ទតឃើញសេចក្ដីស្និទ្ធស្នាលជាមិត្តភាពរបស់ពួកសត្វទាំងពីរ ទ្រង់ព្រះចិន្ដាថា "ឃើអើ មិនធ្លាប់ឃើញសោះ ហេតុចម្លែកនេះ អញទើបតែបានឃើញនៅពេលនេះទេតើ។ សត្វទាំងពីរនេះធ្លាប់ជាសត្រូវនឹងគ្នា តែបែរជាចេះរស់នៅយ៉ាងសុខសាន្តជាមួយគ្នា។ អញគួរយកការណ៍នេះ បង្កើតជាប្រស្នាសួរបណ្ឌិតទាំង ៥ នាក់ល្បងមើល។ បណ្ឌិតណាមិនចេះប្រស្នានេះទេ អញនឹងនិរទេសបណ្ឌិតនោះចេញចាកដែន តែបើបណ្ឌិតណាចេះដោះប្រស្នានេះ អញនឹងរៀបគ្រឿងសក្ការៈដ៏ធំជារង្វាន់ ជូនចំពោះបណ្ឌិតនោះ និងប្រកាសជាឧឡារិកថា "បណ្ឌិតបែបនេះ រកគ្មានទេ។ ថ្ងៃនេះមិនទាន់ដល់ពេលចោទប្រស្នានៅឡើយ រង់ចាំចោទប្រស្នាចំពោះពួកគេនៅថ្ងៃស្អែក ក្នុងពេលដែលពួកគេមកគាល់បម្រើយើង"។

ក្នុងថ្ងៃបន្ទាប់ បណ្ឌិតទាំង ៥ ក៏ធ្វើដំណើរមកកាន់ព្រះរាជវាំង ព្រះរាជាទ្រង់ផ្ដើមចោទប្រស្នាថា៖

"រឿងនោះមិនធ្លាប់មានក្នុងកាលណាឡើយ មានសម្លាញ់ពីរនាក់កើតក្នុងលោកនេះ មានតែជើង ៧ កន្ទះ ជាអមិត្រពីកំណើត

*ធម្មជាតិ តែក្លាយជាសម្លាញ់ ឬរផ្តាច់ស្លាប់រស់ជាមួយគ្នា តើដំណើរនោះព្រោះហេតុអ្វី?"*

*លុះទ្រង់ពោលយ៉ាងនេះហើយ ទ្រង់ត្រាស់យ៉ាងនេះបន្ថែមថា៖*

*"ប្រសិនបើក្នុងពេលអាហារព្រឹកថ្ងៃនេះ ពួកអ្នកមិនអាចដោះនូវប្រស្នានេះឲ្យយើងបានទេ យើងនឹងនិរទេសអ្នកទាំងអស់គ្នាចេញអំពីដែន ព្រោះថា អ្នកឥតប្រាជ្ញានឹងមិនមានប្រយោជន៍អ្វីដល់យើងឡើយ"។*

**បណ្ឌិតទាំង ៥ សូមពន្យារពេលដោះប្រស្នា**

*នៅគ្រានោះ អាចារ្យសេនកៈអង្គុយនៅដើមអាសនៈ ចំណែកបណ្ឌិតមហោសថ អង្គុយនៅចុងអាសនៈ។ មហោសថបណ្ឌិតគិតប្រស្នានោះមិនយល់ន័យទាល់តែសោះថា "ព្រះរាជាអង្គនេះ មានជាតុខ្លៅ ទ្រង់ពុំអាចគិតនិពន្ធនូវប្រស្នានេះបានទេ ច្បាស់ជាទ្រង់បានទតឃើញអ្វីម្យ៉ាងហើយ។ កាលបើបានឱកាសមួយថ្ងៃ អញនឹងអាចដោះប្រស្នានេះបាន សូមឲ្យអាចារ្យសេនកៈក្រាបទូល ព្រះរាជាអត់សង្កត់ព្រះទ័យត្រឹមតែមួយថ្ងៃនេះ ដោយឧបាយណាមួយសិនចុះ"។ ចំណែកបណ្ឌិតទាំង ៤ នាក់ ពុំយល់អ្វីបន្តិចសោះ ហាក់បីដូចចូលទៅក្នុងបន្ទប់*

ផងឹតស្ញុប[៤៦]។ អាចារ្យសេនកៈ ក្រឡេកមើលមហោសថ ក្រែងលោថា មហោសថមានមតិអ្វីខ្លះ។ ចំណែកឯមហោសថ ក៏មើលទៅមុខអាចារ្យសេនកៈវិញ។ អាចារ្យសេនកៈយល់ពីបំណងរបស់មហោសថ តាមអាការៈក្រឡេកមើលតបវិញនោះ គាត់គិតក្នុងចិត្តថា "មហោសថ មិនទាន់យល់ចម្លើយដូចពួកអញដែរ ទំនងជាមហោសថចង់បានឱកាសមួយថ្ងៃ អញគួរតម្រូវចិត្តរបស់គេ"។ គិតដូច្នេះហើយ អាចារ្យសេនកៈក៏ធ្វើជាលាន់សំណើចយ៉ាងខ្លាំង ដោយគាត់ជួបស្និទ្ធស្នាលនឹងព្រះរាជាហើយទូលព្រះរាជាថា៖

"បពិត្រមហារាជ បើពួកទូលបង្គំទាំងអស់គ្នាមិនអាចដោះប្រស្នាបាន ទ្រង់នឹងនិរទេសចាកដែនមែនឬ? ប្រស្នានុ៎ះ ប្រាកដជាទ្រង់យល់ថាជ្រាលជ្រៅណាស់ដែរហើយ[៤៧]។ មិនមែនពួកទូលបង្គំជាខ្ញុំ មិនអាចដោះប្រស្នានោះទេ។ ណ្ហើយចុះ សូមព្រះអង្គ ទ្រង់អត់សង្កត់ព្រះហឫទ័យសិន ព្រោះប្រស្នានេះស្មុគស្មាញណាស់ ពួកទូលបង្គំជាខ្ញុំ មិនអាចដោះនៅកណ្ដាលមហាជនបានទេ។

---

[៤៦] ស្ញុប (គុ.) យុរស្រុបប្រឡុប, យុរគ្របពីលើ : មែកឬសរ្សីយុរស្ញុប។ ផងឹតមុខ ឬវិលមុខជ្រប់ : វិលមុខស្ញុប។

[៤៧] ឯកោ គណ្ឋិបញ្ហោ ប្រស្នាដែលសាំញ៉ាំដូចព្រៃស្ដុក បណ្ឌិតល្មមៗក៏ពិបាកយល់។

ទាល់តែអង្គុយផ្ចង់គិតក្នុងទីដ៏សមគួរសិន ទើបអាចដោះប្រស្នាថ្វាយព្រះអង្គ ក្នុងកាលជាខាងក្រោយបាន សូមព្រះអង្គមេត្តាប្រោសប្រទានឱកាសដល់ពួកទូលបង្គំសិន ក្រាបទូល"។

ពោលដូច្នេះហើយ សេនកៈងាកមើលទៅមហោសថនិយាយបន្ថែមថា៖

"កាលបើនៅក្នុងទីប្រជុំជនមានគ្នាច្រើន គគ្រឹកគគ្រេង ជួបជុំគ្នាយ៉ាងអ៊ូអរបែបនេះ ពួកយើងខ្ញុំរវើរវាយ មានចិត្តមិននឹងនក្នុងអារម្មណ៍តែមួយ មិនអាចឆ្លើយប្រស្នានុ៎ះភ្លាមៗបានទេ។ បពិត្រព្រះជនិន្ទ្រាធិរាជ អ្នកប្រាជ្ញទាំងឡាយម្នាក់ៗ មានចិត្តតាំងនៅក្នុងអារម្មណ៍តែមួយ ទៅក្នុងទីស្ងាត់ ឋិតនៅក្នុងកាយវិវេក និងចិត្តវិវេក គិតនូវសេចក្ដីពិចារណានូវប្រស្នា ទើបក្រាបទូលសេចក្ដីនុ៎ះ ក្នុងកាលជាខាងក្រោយបាន ក្រាបទូល"។

**ព្រះបាទវិទេហរាជគំរាមបណ្ឌិតទាំង ៥**

ព្រះរាជា ទ្រង់ព្រះសណ្ដាប់នូវសម្ដីរបស់អាចារ្យសេនកៈហើយ ទ្រង់មានព្រះរាជហឫទ័យតុំរីករាយ។ តែទោះយ៉ាងនេះក្ដី ព្រះរាជាបានធ្វើការគំរាមថា៖

"ល្អហើយ អស់លោកគិតសិនចុះ សឹមឆ្លើយ។ បើដោះស្រាយមិនបានទេ យើងនឹងនិរទេសពួកអ្នកមិនខានឡើយ"។

បណ្ឌិតទាំង ៤ នាក់នោះ ដើរចុះចាកប្រាសាទ អាចារ្យសេនកៈនិយាយនឹងបណ្ឌិត ៣ នាក់គ្នាឯងនោះថា៖

“នែសម្លាញ់! ព្រះរាជាសួរប្រស្នាដ៏ល្អិតសុខុម បើពួកយើងដោះស្រាយមិនបានទេ អន្តរាយ[៤៨]ធំនឹងកើតឡើងដល់ពួកយើងហើយ ដូច្នោះ ពួកយើងត្រូវតែខំប្រឹងត្រិះរិះពិចារណាប្រស្នានោះឲ្យបានល្អិតល្អន់បន្តទៀត”។

ផ្ដែផ្ដាំគ្នាដូច្នេះហើយ អាចារ្យទាំង ៤ ក៏បែកគ្នាទៅផ្ទះរៀងៗខ្លួនដោយក្ដីព្រួយក្រៀមក្រំ។

**មហោសថស្វែងយល់ប្រស្នា**

ចំណែកមហោសថ ក្រោកឡើងដើរទៅព្រះរាជដំណាក់របស់ព្រះនាងឧទុម្ពរទេវី ក្រាបទូលសួរព្រះនាងថា៖

---

[៤៨] អន្តរាយ អន់-ត:រ៉ាយ សំ. បា. (ន.) (< អន្តរា “ក្នុងពាក់កណ្ដាល; ក្នុងរវាង ឬក្នុងចន្លោះ” + អាយ “មក”) ធម៌ដែលមកក្នុងរវាងនៃចុតិនិងបដិសន្ធិ (ព. ពុ.); ហេតុដែលមកជំទាស់ក្នុងចន្លោះឬក្នុងពាក់កណ្ដាល; សេចក្ដីទើសទាក់, ឧបសគ្គការណ៍; ភ័យ; ដំណើរខូចប្រយោជន៍, ការខូចបង់សៀត, សេចក្ដីវិនាស : ប្រទះលើអន្តរាយ; សូមកុំឲ្យមានអន្តរាយតាមផ្លូវ!។ ខ្មែរប្រើជា កិ. ផងក៏បាន សំដៅសេចក្ដីថា “ខូច, វិនាស” : លិចទូកទំនិញអន្តរាយអស់; អន្តរាយខ្លួន ឬ ខ្លួនត្រូវអន្តរាយ ។

"បពិត្រព្រះទេវី ថ្ងៃនេះឬថ្ងៃម្សិលមិញ តើព្រះរាជាទ្រង់ប្រថាប់គង់នៅកន្លែងណាយូរជាងគេ?"

ព្រះនាងទេវីប្រាប់ថា៖

"ប្អូនប្រុស កាលពីម្សិលមិញ បងឃើញព្រះរាជាយាងចង្រ្កមតាមថែវប្រាសាទ ហើយទ្រង់ទតតាមបង្អួចខ្ពោះទៅក្រៅ"។

លំដាប់នោះ បណ្ឌិតគិតថា "ព្រះរាជាជាក់ជាទតឃើញនូវហេតុអ្វីមួយនៅកន្លែងនោះមិនខាន" រួចមហោសថក៏ដើរទៅកន្លែងនោះ ចោលភ្នែកក្រឡេកមើលទៅខាងក្រៅ ឃើញនូវកិរិយារបស់ពពែ និងសុនខ ទើបមហោសថសន្និដ្ឋានតាមដំណើររឿងថា "ព្រះរាជាឃើញសត្វទាំងពីរនេះ ទើបប្រតិដ្ឋ[៤៩]នូវប្រស្នានេះបាន" យល់ដូច្នេះហើយ មហោសថក៏ត្រឡប់ទៅលំនៅឋានវិញ។

---

[៤៩] ប្រតិដ្ឋ អានថា ប្រដិត។ អក្សរ ត របស់បាលី ត្រូវអានជាអក្សរ ដ ខ្មែរ តែការសរសេរនៅតែអក្សរ ត ដដែល ដូច តារា, មាតា, បិតា, ធម្មតា, ប្រក្រតី, តន្ត្រី, តូរ្យតន្ត្រី, អតីត, ប្រតិដ្ឋ, ស្តូន, ស្តម្ភ។ បច្ចុប្បន្ន អ្នកខ្លះសរសេរ អតីត ជាអឌិត, ប្រតិដ្ឋ ជា ប្រឌិតឬប្រដិត ខុសក្បួនវេយ្យាករណ៍ខ្មែរ កុំសរសេរ ដឬឌ ក្នុងលក្ខណ្ឌបែបនេះឲ្យសោះ សូមសរសេរជាអក្សរ ត ដដែល គ្រាន់តែអានតាមក្បួនខ្មែរជាអក្សរ ដ ដូចយើងឧស្សាហ៍ឆាយឮនិងធ្លាប់អាន តារា ថា ដារា, មាតា ថា មាដា, ធម្មតា ថា ធម្មដា។ល។

ចំណែកអាចារ្យ ៣ នាក់ គិតហើយគិតទៀត មិនយល់អ្វីទាល់តែសោះ នាំគ្នាមកកាន់សម្នាក់អាចារ្យសេនកៈ ហើយត្រូវបានអាចារ្យសេនកៈសួរមុនថា៖

"ពួកលោក យល់ប្រស្នាហើយឬនៅ?"

"មិនយល់ទាល់តែសោះ លោកអាចារ្យ" អាចារ្យ ៣ នាក់ឆ្លើយ។

"ប្រសិនបើអីចឹង ព្រះរាជាមុខតែនឹងនិរទេសពួកអ្នកចេញពីនគរ តើពួកលោកធ្វើដូចម្ដេចទៅ?" សេនកៈនិយាយ។

"ចុះលោកយល់ហើយឬនៅ?" អាចារ្យទាំង ៣ សួរ។

"ខ្ញុំក៏អត់យល់ដូចគ្នា បើពួកអ្នកមិនយល់ទៅហើយ តើខ្ញុំនឹងយល់ដូចម្ដេច? ប៉ុន្តែយើងបានក្រាបទូលព្រះរាជាហើយថា យើងនឹងបកស្រាយប្រស្នាថ្វាយព្រះអង្គ ទើបបានជាយើងមកទីនេះ។ ពេលនេះ បើយើងដោះស្រាយមិនបានទេ ព្រះរាជានឹងខ្ញាល់ខ្លាំង តើយើងគួរធ្វើដូចម្ដេចទៅ? ថ្វីបើបញ្ហានេះពួកយើងមិនអាចយល់បាន ប៉ុន្តែមហោសថមុខតែគិតឃើញន័យ ១០០ ជង ១.០០០ ជង ១០០.០០០ជង ជាមិនខាន។ តោះយើងទៅកាន់សម្នាក់មហោសថវិញ" សេនកៈតប។

## មហោសថជួយបង្រៀនប្រស្នាដល់បណ្ឌិតទាំង ៤

បណ្ឌិតទាំង ៤ នាក់នាំគ្នាទៅកាន់គេហដ្ឋានមហោសថ ហើយបានប្រាប់អ្នកយាមឲ្យទៅជម្រាបមហោសថ អំពីការសូមចូលជួបរបស់បណ្ឌិតទាំង ៤ ។ កាលបើមហោសថប្រាប់ថា៖

"សូមបណ្ឌិតទាំងឡាយ អញ្ជើញចូលមកចុះ"។

បណ្ឌិតទាំង ៤ នាំគ្នាចូលទៅក្នុងគេហដ្ឋានមហោសថ ធ្វើបដិសណ្ឋារៈរួបអង្គុយក្នុងទីសមគួរ ហើយសួរមហោសថថា៖

"ចុះលោកបណ្ឌិត បានគិតអំពីប្រស្នានោះយល់ហើយឬ?"

"បាទ! ខ្ញុំគិតយល់ហើយ កាលបើខ្ញុំមិនយល់ តើអ្នកដទៃណាទៅអាចគិតយល់?" មហោសថតប។

"បពិត្របណ្ឌិត បើអ៊ីចឹង សូមលោកមេត្តាប្រាប់ពួកយើងផង" បណ្ឌិតទាំង ៤ ស្នើសូម។

មហោសថបណ្ឌិតគិតថា "ប្រសិនបើអញមិនប្រាប់ពួកគេទេ ព្រះរាជាមុខតែទ្រង់ក្រោធខ្ញាំងនឹងនិរទេសពួកគេចាកដែន។ រីឯអញនឹងត្រូវស្ដេចបូជាដោយរតនៈ ៧ ប្រការ។ សូមកុំឲ្យជនអន្ធពាលទាំងនេះវិនាសឡើយ។ អញសុខចិត្តប្រាប់ពួកគេទៅចុះ"។ គិតដូច្នេះ ហើយ

មហោសថប្រាប់ឲ្យបណ្ឌិតទាំង ៤ នាក់នោះ អង្គុយលើអាសនៈទាបហើយផ្គងអញ្ជលី មិនឲ្យពួកគេដឹងអំពីទិដ្ឋភាពដែលស្តេចឃើញទេ គ្រាន់តែប្រាប់ថា៖

"ពួកលោកសូមពោលយ៉ាងនេះ នៅពេលព្រះរាជាទ្រង់សួរ" ហើយចងកំណាព្យជាបាឡី ៤ គាថា ឲ្យបណ្ឌិតទាំង ៤ នាក់នោះរៀនៗ ក្នុងថ្ងៃទីពីរ បណ្ឌិតទាំងឡាយបាននាំគ្នាទៅកាន់ រាជុបដ្ឋាន[៥០]អង្គុយលើអាសនៈដែលគេក្រាលជូនៗ ព្រះរាជាត្រាស់សួរ អាចារ្យសេនកៈថា៖

"នែអាចារ្យសេនកៈ! តើលោកដឹងប្រស្នាហើយឬនៅ?"

អាចារ្យសេនកៈ ក្រាបទូល៖

"មហារាជ កាលបើទូលបង្គំមិនដឹង តើអ្នកដទៃណានឹងដឹង"ៗ

"បើដូច្នោះ ចូរអ្នកនិយាយមកមើល" ស្តេចបង្គាប់ៗ

" បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ព្រះសណ្តាប់" ហើយអាចារ្យសេនកៈពោលគាថា តាមដែលខ្លួនបានរៀនចេះចាំអំពីមហោសថដូច្នេះថា៖

[៥០] រាជ + ឧបដ្ឋាន = ទីដែលមន្ត្រីចូលគាល់បម្រើព្រះមហាក្សត្រៗ

"សាច់ពពែជាទីស្រឡាញ់ ជាទីពេញចិត្តរបស់កូនអាមាត្យ និង
បុត្ររបស់ស្តេច ពួកគេមិនបរិភោគសាច់សុនខទេ កាលបើ
ដូច្នេះ បានជាសុនខនិងពពែយកគ្នាជាសម្លាញ់"។

លុះពោលគាថាចប់ក៏ឈប់ស្ងៀម ដោយអាចារ្យសេនកៈខ្លួនឯង
ក៏មិនយល់អត្ថន័យនៃគាថានោះដែរ។

ចំណែកព្រះរាជា ទ្រង់ជ្រាបច្បាស់អំពីទិដ្ឋភាពដែលព្រះអង្គបាន
ទតឃើញ ព្រោះដូច្នោះទ្រង់លាន់ព្រះឱស្ឋថា៖

"សេនកៈយល់ប្រស្នា ហើយតើហ្ន៎!" រួចព្រះរាជាទ្រង់សួរអាចារ្យ
បុក្កុសៈម្តង។

ចំណែកអាចារ្យបុក្កុសៈ អួតនៅចំពោះព្រះភក្ត្រព្រះរាជាដែរថា៖

"ចុះទូលបង្គំវិញ មិនមែនជាបណ្ឌិតដែរឬទេព្រះអង្គ?"

បន្ទាប់មក គាត់ក៏ពោលគាថាតាមទំនងដែលខ្លួនបានរៀនចេះចាំអំពី
មហោសថដូច្នេះ៖

"ពួកជនតែងពន្ធះស្បែកពពែ ធ្វើជាកម្រាលក្រាលលើខ្នងសេះ
ដើម្បីបានអង្គុយស្រួល តែពួកជនទាំងនោះមិនក្រាលស្បែក
សុនខទេ ដូច្នេះ បានជាសុនខនិងពពែយកគ្នាជាសម្លាញ់"។

ការពិត អាចារ្យបុក្កុសៈក៏មិនបានយល់អត្ថន័យបន្ទិចសោះដូចសេនកៈដែរ។ ព្រះរាជា ហេតុតែព្រះអង្គទ្រង់យល់នូវប្រស្នាស្រាប់ ព្រះអង្គក៏ទ្រង់មានព្រះតម្រិះថា៖

"បុក្កុសៈ ក៏គេដឹងអត្ថន័យ នៃប្រស្នានេះដែរហ្ន៎!"

រួចព្រះរាជាទ្រង់សួរអាចារ្យកាមិន្ទុៈម្តង។

អាចារ្យកាមិន្ទុៈ ពោលគាថាតាមទំនងដែលខ្លួនបានរៀនចេះចាំអំពីមហោសថដូច្នេះថា៖

"ពពែមានស្នេងជារង្វង់[៩១] សុនខមិនមានស្នេងទេ ពពែស៊ីស្មៅ សុនខស៊ីសាច់ ដូច្នេះ បានជាសុនខនិងពពែយកគ្នាជាសម្លាញ់"។

និយាយចប់ អាចារ្យកាមិន្ទុៈក៏មិនយល់អត្ថន័យរបស់បញ្ហាបន្តិចសោះ ដូចជាអាចារ្យសេនកៈនិងបុក្កុសៈដែរ។

ព្រះរាជាព្រះទ្រង់តម្រិះថា "អាចារ្យកាមិន្ទុៈយល់អត្ថន័យនៃប្រស្នានេះដែរ" រួចទ្រង់សួរអាចារ្យទេវិន្ទុៈម្តង។ អាចារ្យទេវិន្ទុៈ បានពោលនូវគាថាតាមទំនង ដែលខ្លួនបានរៀនចេះចាំអំពីមហោសថដូច្នេះថា៖

---

[៩១] អាវេល្លិតសិង្គិកោ ហិ មេណ្ឌោ។

“ពពែស៊ីស្មៅនិងស៊ីស្លឹកឈើ ឯសុនខមិនស៊ីស្មៅ មិនស៊ីស្លឹកឈើទេ វាខាំតែទន្សាយនិងសំពោច កាលបើដូច្នេះ បានជាសុនខនិងពពែយកគ្នាជាសម្លាញ់”ឞ

និយាយចប់ អាចារ្យកាមិន្ទៈនោះក៏មិនបានយល់អត្ថន័យនៃគាថានោះបន្តិចសោះ ដូចអ្នកមុនៗដែរឞ

គ្រានោះព្រះរាជា ដោយហេតុតែព្រះអង្គយល់ ទ្រង់ព្រះតម្រិះថា “សូម្បីអាចារ្យទេវិន្ទៈ ក៏ចេះប្រស្នានេះដែរ”ឞ ដូច្នេះ ព្រះអង្គទ្រង់សួរមហោសថបណ្ឌិតម្តងថា៖

“នែបា! ចុះអ្នកចេះប្រស្នានេះទេ?”

មហោសថ ក្រាបទូលព្រះរាជាថា៖

“បពិត្រមហារាជ រាប់ពីអវិចីដល់ឋានព្រហ្ម លើកលែងទូលបង្គំចេញ តើអ្នកដទៃណានឹងចេះប្រស្នានោះ?”

“បើដូច្នោះ ចូរបានិយាយមកមើល” ព្រះរាជាទ្រង់ត្រាស់ឞ

“សូមទ្រង់ព្រះសណ្តាប់ចុះ មហារាជ” ហើយមហោសថក្រាបទូល តាមសេចក្តីយល់ច្បាស់របស់ខ្លួននូវប្រស្នានោះដូច្នេះថា៖

"សត្វជើង ៧ កន្ទុះ គឺឆ្កែមានជើងបីកន្ទុះ ពពែមានជើង ៤ ជើងមួយៗ មានក្រចក ២ រួមជា៨ ។ ឯឆ្កែនេះ លួចស្មៅឲ្យពពែនោះ ពពែនោះលួចសាច់ឲ្យឆ្កែនេះៗ ឮថាព្រះបាទវិទេហរាជ ជាស្ដេចដ៏ប្រសើរ ជាធំជាងជនក្នុងប្រទេស ស្ដេចគង់នៅលើប្រាសាទដ៏ស្កឹមស្កៃ ទ្រង់ទតឃើញយ៉ាងច្បាស់នូវសត្វទាំងពីរផ្លាស់ប្ដូរចំណីដែលលួចបានមកឲ្យគ្នាស៊ី"ៗ

## ព្រះរាជាប្រទានរាជអំណោយដល់បណ្ឌិតទាំង ៥

កាលព្រះរាជា មិនបានទ្រង់ជ្រាបថា "អាចារ្យផ្សេងៗ ចេះប្រស្នាដោយអាស្រ័យមហោសថ" ទ្រង់សម្គាល់ថា "បណ្ឌិតទាំង ៥ ចេះដោយកម្លាំងប្រាជ្ញារៀងៗខ្លួន"ៗ ព្រះរាជាទ្រង់សោមនស្សក្រៃលែង មានព្រះរាជឱង្ការដូច្នេះថា៖

"ពិតជាលាភរបស់យើងមែនទែន ដែលអស់លោកបណ្ឌិតទាំងឡាយ ឆ្លាតវាងវៃនៅក្នុងត្រកូលរបស់យើងៗ បណ្ឌិតទាំងនោះចេះដឹងអាថ៌ប្រស្នា ពោលនូវសុភាសិត ដោះនូវអាថ៌ប្រស្នាដែលមានអត្ថន័យជ្រាលជ្រៅល្អិតសុខុមបាន"ៗ

គ្រានោះ ព្រះរាជាទ្រង់ព្រះតម្រិះថា "តាមធម្មតាបុគ្គលអ្នកមានសេចក្តីត្រេកអរ ត្រូវតែធ្វើអាការៈនៃសេចក្តីត្រេកអរ"។ មុននឹងធ្វើនូវអាការៈត្រេកអរនោះ ព្រះរាជាទ្រង់មានព្រះបន្ទូលដូច្នេះថា៖

"យើងនឹងព្រះរាជទាន ដល់អស់លោកបណ្ឌិតនូវរទេះនិងសេះអស្សតរមួយៗម្នាក់ នូវស្រុកសួយដែលមានផ្ទៃដីធំៗ មួយៗម្នាក់ដែរ ពីព្រោះថា យើងមានចិត្តរីករាយយ៉ាងខ្លាំង ចំពោះសម្តីជាសុភាសិតរបស់អស់លោក"។

ត្រាស់ដូច្នេះហើយ ទ្រង់បញ្ជាឲ្យរាជបុរសព្រះរាជទាននូវរាជអំណោយទាំងពួងនោះ ដល់បណ្ឌិតទាំង ៥ រូប ដោយព្រះហឫទ័យរីករាយនិងក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់។

មេណ្ឌកបញ្ហា ចប់។

## សិរិមន្ទបញ្ហា

## ប្រស្នាអ្នកមានទ្រព្យនិងអ្នកមានប្រាជ្ញា

ចំណែកឯព្រះនាងឧទុម្ពរទេវី ដឹងថាអាចារ្យទាំង ៤ ចេះប្រស្នាដោយអាស្រ័យមហោសថបណ្ឌិត ព្រះនាងទ្រង់ព្រះតម្រិះថា “ព្រះរាជាទ្រង់ធ្វើសក្ការៈស្មើៗគ្នាដល់បណ្ឌិតទាំង ៥ ហាក់ដូចជាទ្រង់ធ្វើសណ្ដែកខៀវ មិនឲ្យប្លែកគ្នាអំពីសណ្ដែករាជមាស។ ព្រះរាជាគួរធ្វើនូវសក្ការៈវិសេសដល់ប្អូនប្រុសអញ ទើបត្រឹមត្រូវ”។ គិតដូច្នេះហើយ ព្រះនាងយាងទៅកាន់ដំណាក់របស់ព្រះរាជា ក្រាបទូលសួរថា៖

“បពិត្រព្រះសម្មតិទេព នរណាដោះប្រស្នាថ្វាយព្រះអង្គ?”

“បណ្ឌិតទាំង ៥ រូប មហេសីអូន” ព្រះរាជាឆ្លើយ។

“បពិត្រព្រះសម្មតិទេព តើព្រះអង្គជ្រាបទេថា អាចារ្យ ៤ នាក់នោះចេះដោះប្រស្នាដោយសារនរណា?” ឧទុម្ពរទេវីក្រាបទូល។

“យើងមិនដឹងទេ មហេសីអូន” ព្រះរាជាត្រាស់។

ព្រះទេវីក្រាបទូលថា៖

“បពិត្រមហារាជ អាចារ្យ ៤ នាក់មិនចេះដឹងអ្វីទេ។ មហោសថបណ្ឌិតទេតើ ជាអ្នកបង្រៀនអាថ៌ប្រស្នានោះ ដើម្បីកុំឲ្យពួកល្ងង់ទាំងនោះវិនាស។ ព្រះអង្គធ្វើសក្ការៈដល់ពួកគេទាំងអស់ស្មើៗ

គ្នាអ៊ីចឹង នុះពិតជាអយុត្តិធម៌ណាស់។ គួរណាស់តែព្រះអង្គធ្វើសក្ការៈវិសេសដល់មហោសថបណ្ឌិតទើបសម ក្រាបទូល"។

ព្រះរាជាមានព្រះតម្រិះថា "មហោសថបណ្ឌិត មិនប្រាប់អំពីចំណេះពួកអាចារ្យផ្សេងៗថាចេះមកអំពីខ្លួនសោះ"។ ដូច្នេះ ទ្រង់រឹតតែត្រេកអរចំពោះគុណធម៌មហោសថ។ ព្រះអង្គសព្វព្រះរាជហឫទ័យពេកណាស់ ចង់ធ្វើនូវសក្ការៈឲ្យក្រៃលែងឡើង ទ្រង់ព្រះតម្រិះថា "មិនអីទេ! ចាំដល់ពេលអញសួរ ប្រស្នាមួយចំពោះមហោសថកូនអញហើយ អញនឹងធ្វើសក្ការៈដល់គេយ៉ាងធំ"។ កាលកំពុងត្រិះរិះរកប្រស្នា ព្រះអង្គទ្រង់ព្រះតម្រិះឃើញនូវប្រស្នាមួយស្ដីអំពីអ្នកមានទ្រព្យ។

**ឆ្លើយឆ្លងគ្នារវាងសេនកៈនិងមហោសថ**

ថ្ងៃមួយ បណ្ឌិតទាំង ៥ រូប បានមកកាន់ទីឧបដ្ឋានរបស់ព្រះរាជាអង្គុយស្រួលបួលហើយ ស្ដេចត្រាស់នឹងអាចារ្យសេនកៈថា៖

"នែអាចារ្យសេនកៈ! យើងចង់សួរអ្នកនូវប្រស្នាមួយ"។

"ទ្រង់សួរមកចុះ ព្រះសម្មតិទេព" សេនកៈ ក្រាបទូល។

ព្រះរាជាត្រាស់សួរប្រស្នាសិរិមន្តដូច្នេះ ៖

"នែសេនកៈ! យើងសូមសួរសេចក្ដីមួយ គឺបុគ្គលមានប្រាជ្ញាតែខ្សត់ទ្រព្យសម្បត្តិ និងបុគ្គលមានយសនិងទ្រព្យសម្បត្តិ តែឥត

ប្រាជ្ញា បណ្តាបុគ្គលទាំងពីរនោះ អ្នកប្រាជ្ញទាំងឡាយពោលថា បុគ្គលណាប្រសើរជាង?"

ប្រស្នានេះ ត្រូវសង្វាក់គ្នានឹងតំណវង្សត្រកូលសារនៃអាចារ្យសេនកៈ ធ្វើឲ្យគាត់រីករាយណាស់ ហើយគាត់ដោះប្រស្នានោះយ៉ាងទាន់ហន់ថា៖

"បពិត្រព្រះជនិន្ទ[៥២] អ្នកប្រាជ្ញក្តី អ្នកល្ងង់ក្តី អ្នកមានចំណេះវិជ្ជាក្តី អ្នកមិនមានចំណេះវិជ្ជាក្តី ទោះបីជាមានជាតិខ្ពង់ខ្ពស់ អាចជាអ្នកធ្វើការបម្រើបុគ្គលអ្នកមានយស ដែលមានជាតិទាប ទូលព្រះបង្គំបានឃើញហេតុនេះ សូមទូលថ្វាយថា អ្នកមានប្រាជ្ញាជាបុគ្គលថោកទាប រីឯអ្នកមានយសធំ ទើបជាបុគ្គលប្រសើរ"។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ពាក្យរបស់អាចារ្យសេនកៈហើយ ទ្រង់មិនសួរអាចារ្យ ៣ នាក់ទេ ទ្រង់បែរទៅសួរមហោសថដែលជាអ្នកចំណូលថ្មីថា៖

"ម្នាលមហោសថ អ្នកមានប្រាជ្ញាមិនថោកថយ ជាអ្នកឃើញនូវហេតុដោយសព្វគ្រប់ យើងសូមសួរអ្នកម្តង អំពីបុគ្គលខ្លៅមាន

---

[៥២] ជនិន្ទ <ជន(ប្រជាជន) +ឥន្ទ(ស្តេច, អ្នកជាធំ)។ ពាក្យជ្រលិះគ្នានេះដូច ខេមរភូមិន្ទ <ខេមរ (ខ្មែរ) +ភូមិ (ដែនដី) + ឥន្ទ(ស្តេច, អ្នកជាធំ)។ ទេវានមិន្ទ <ទេវានំ (ទេវតាទាំងឡាយ) + ឥន្ទ(ស្តេច, អ្នកជាធំ) ផ្លាស់និគ្គហិតជា ម។

យស បណ្ឌិតគ្មានភោគៈ តើអ្នកប្រាជ្ញទាំងឡាយពោលថា បណ្ដាបុគ្គលទាំងពីរនោះ បុគ្គលណាប្រសើរជាង?”

គ្រានោះ មហោសថក្រាបទូលព្រះបាទវិទេហរាជថា៖

“ក្រាបទូលមហារាជ ពួកបុគ្គលខ្លៅ តែងធ្វើនូវអំពើអាក្រក់ទាំងឡាយ ហើយសម្គាល់ថា អំពើនេះឯងជាអំពើប្រសើរ គេឃើញត្រឹមតែលោកនេះថា មានតែឥស្សរិយៈទេ ដែលប្រសើរបំផុតសម្រាប់អញក្នុងលោកនេះ បុគ្គលខ្លៅ មើលមិនឃើញនូវលោកខាងមុខ ហ៊ានធ្វើនូវអំពើអាក្រក់ដោយអាងថា អញជាអ្នកធំ[៥៣] គេកាន់យកនូវទោសក្នុងលោកទាំងពីរ គឺកើតក្នុងនរកជាដើមក្នុងលោកខាងមុខ កាលរួចមកអំពីកំណើតនោះវិញ រមែងកើតក្នុងលោកយើងនេះ តែងកើតក្នុងត្រកូលទន់ទាបក្រីក្រហើយដល់នូវសេចក្ដីទុក្ខលំបាកលំបិន ត្រដាបត្រដួស គឺគេរមែងទទួលនូវបរាជ័យក្នុងលោកទាំងពីរ ដោយពិត។ ទូលព្រះបង្គំបានឃើញហេតុយ៉ាងនេះ ទើបទូលថ្វាយព្រះអង្គថា បុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរខ្ពង់ខ្ពស់ រីឯបុគ្គលខ្លៅ មានតែសក្តិយសធំនោះ មិនប្រសើរថ្លៃថ្លាទេ”។

---

[៥៣] ពាលោ ឥស្សរិយមានេន បាបកម្មំ កត្វា ...។

កាលបើមហោសថពោលយ៉ាងនេះ ព្រះរាជាទ្រង់ងាកមើលមុខអាចារ្យ សេនកៈ ហើយត្រាស់ថា៖

"មហោសថថា មានតែអ្នកមានប្រាជ្ញាទេ ជាបុគ្គលប្រសើរ អ៊ីចឹងឬ សេនកៈ?"

សេនកៈក្រាបទូលថា៖

"បពិត្រមហារាជ មហោសថនៅក្មេងនៅឡើយ សូម្បីថ្ងៃនេះ ក៏នៅមិនទាន់បាត់ក្លិនទឹកដោះពីមាត់ផង តើគេចេះដឹងអ្វី?"

រួចសេនកៈដោះប្រស្នាការពារគំនិតខ្លួនជាបន្តថា៖

"អ្នកមានចំណេះវិជ្ជាក្តី[៥៤] អ្នកមានផៅពង្សល្អក្តី ក៏មិនប្រសើរ ដូចអ្នកមានភោគសម្បត្តិឡើយ។ សូមព្រះអង្គទ្រង់ទតចុះ

[៥៤] ន សិប្បមេតំ វិទធាតិ ភោគំ។ ចំណេះ = ការចេះ, វិជ្ជាឬវិទ្យា = មុខសិល្បៈណាមួយដែលត្រូវរៀនឲ្យចេះ ដូច គណិតវិទ្យា, រូបវិទ្យា, ប្រវត្តិវិទ្យា។ល។ ដូច្នេះ បុរាណយើងប្រើពាក្យ ចំណេះវិជ្ជា ឧ.ចំណេះវិជ្ជា កណ្តុរមិនកាត់ ចោរលួចមិនបាន, ផ្ទុយពីសព្វថ្ងៃដែលគេប្រើពាក្យ ចំណេះដឹង ស្ទើរតែគ្រប់ទីកន្លែង ស្ទើងតែបាត់ពាក្យ ចំណេះវិជ្ជា។ ចំពោះមតិខ្ញុំ, ចំណេះដឹង គឺការចេះដឹងធម្មតា ពុំសំដៅដល់ការដឹងអ្វី ឬអ្នកខ្លះនិយាយថា គាត់នោះមានតែចំណេះដឹង អត់មានចំណេះធ្វើ, គេប្រៀប អ្នកចេះហើយអត់ធ្វើ និងអ្នកចេះហើយធ្វើវិញ, ឯពាក្យចំណេះវិជ្ជា គឺការចេះដោយសិក្សាតាមមេរៀនរបស់គ្រូដាក់ឲ្យ ឬ ក្រសួងរៀបចំឲ្យ ដោយមានកម្រិតពីទាបដល់ខ្ពស់។

ក្នុងនគរយើង មានសេដ្ឋីឈ្មោះ **គោវិន្ទៈ** មានសម្បត្តិ ៨០ កោដិ គាត់មានរូបចោមមិនគួរឲ្យមើលសោះៗ គាត់គ្មានកូនប្រុស គ្មានកូនស្រី ទាំងចំណេះវិជ្ជាអ្វីៗក៏គាត់មិនចេះដែរៗ ពេលគាត់ហាមាត់និយាយស្តីម្តងៗ ទឹកមាត់ហូរហៀរកក្លាក់តាមសងខាងចង្កា ស្ត្រីពីរនាក់ប្រដាប់ដោយអលង្ការគ្រប់បែប ស្អាតដូចទេពអប្សរ តែងនៅឈរអមសងខាងលោកគោវិន្ទសេដ្ឋី ដៃនាងកាន់ផ្កាឧប្បលខៀវដែលរីកស្រស់ល្អ កាលណាឃើញទឹកមាត់ហៀរ ក៏តែងយកផ្កាឧប្បលខៀវនោះជូត រួចបោះផ្កាឧប្បលខៀវនោះចោលទៅតាមបង្អួចៗ ពួកអ្នកប្រមឹកខ្លះ មុននឹងចូលទៅកន្លែងតៀមស្រា[៥៥] បើត្រូវការផ្កាឧប្បលខៀវប្រដាប់កាយ តែងតែនាំគ្នាទៅផ្ទះរបស់លោកគោវិន្ទសេដ្ឋី ស្រែកហៅថា "បពិត្រចៅហ្វាយគោវិន្ទសេដ្ឋីៗ"ៗ លោកគោវិន្ទសេដ្ឋីនោះ កាលឮសំឡេងពួកគេហៅ ក៏មកឈរក្បែរបង្អួចស្រែកថា "មានកិច្ចការអី ក្មួយៗអើយ?" គ្រានោះ ស្រាប់តែទឹកមាត់គាត់ហូរចេញមកតាមចង្កាទាំងសងខាងៗ ស្ត្រីពីរនាក់ដែលតាមបម្រើ ក៏ជូតទឹកមាត់នោះដោយផ្កាឧប្បលខៀវ រួចបោះចោលទៅលើផ្លូវៗ

[៥៥] បានាគារំៗ

ពួកអ្នកប្រមឹក រត់មករើសផ្កាទាំងនោះយកទៅលាងទឹកស្អាត ពាក់សៀតលើខ្លួនប្រាណឲ្យសង្ហា ដើរចូលទៅកាន់តៀមស្រា។ សេដ្ឋីនោះដល់នូវសេចក្ដីសុខ ដោយសារតែមានភោគសម្បត្តិ។ កាលទូលបង្គំបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប រីឯបុគ្គលមានភោគសម្បត្តិ ជាបុគ្គលប្រសើរ"។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់ដូច្នោះហើយទ្រង់ត្រាស់ថា៖

"យ៉ាងម៉េចទៅ បាមហោសថ?"

មហោសថបណ្ឌិតក្រាបទូលថា៖

"បពិត្រព្រះសម្មតិទេព អាចារ្យសេនកៈចេះដឹងស្អី គេឃើញតែយសទេ ដូចក្អែកនៅកន្ទែងជុំបាយ និងដូចសុនខប្រផងនឹងលិទ្ធទឹកដោះជូរ[៥៦]។ គេមិនឃើញដំបងជ្រុងធំធ្លាក់លើក្បាលទេ សូមទ្រង់ព្រះសណ្ដាប់ចុះ ព្រះសម្មតិទេព"។

ហើយមហោសថបានបញ្ចេញយោបល់ទៀតថា៖

"បុគ្គលអប្បប្រាជ្ញា បានសេចក្ដីសុខហើយរមែងស្រវឹង លុះត្រូវសេចក្ដីទុក្ខប៉ះពាល់វិញ ក៏ដល់នូវសេចក្ដីវង្វេង បុគ្គលអប្បប្រាជ្ញា

[៥៦] ទធឹ បាតុំ អារទ្ធសុនខោ វិយ។

កាលបើត្រូវសេចក្តីសុខនិងទុក្ខថ្មីមកប៉ះពាល់ ក៏រមែងញាប់ញ័រ ដូចត្រីចាប់ពីទឹក បោះទៅទីហាលក្តៅ ទូលបង្គំឃើញហេតុនេះ ទើបទូលថ្វាយថា បុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ រីឯបុគ្គលខ្លៅមានយស មិនប្រសើរឡើយ”។

ទ្រង់ស្តាប់ហើយ ព្រះរាជាមានព្រះរាជឱង្ការថា៖

“ដូចម្តេចវិញ សេនកៈ?”

សេនកៈក្រាបទូលថា៖

“បពិត្រព្រះសម្មតិទេព ក្មេងនេះចេះដឹងអ្វី កុំថាឡើយមនុស្ស សូម្បីហ្វូងបក្សីទាំងឡាយ ក៏តែងគប់រកនូវឈើណាដែលសម្បូរផ្កាផ្លែដែរ”។

អាចារ្យសេនកៈ ក្រាបទូលបន្តទៀតថា៖

“ពួកសត្វបក្សី តែងហើរសំដៅទៅទំអាស្រ័យនៅដើមឈើដែលមានផ្លែដ៏ឆ្ងាញ់ក្នុងព្រៃយ៉ាងណា ជនជាច្រើនតែងគប់រកបុគ្គលស្តុកស្តម្ភបរិបូណ៌ដោយទ្រព្យនិងភោគៈ ព្រោះហេតុតែប្រយោជន៍ ក៏យ៉ាងនោះដែរ។ ទូលបង្គំបានឃើញហេតុយ៉ាងនេះ ទើបទូលព្រះអង្គថា បុគ្គលមានប្រាជ្ញាជាបុគ្គលថោកទាប រីឯបុគ្គលមានសម្បត្តិ ជាបុគ្គលប្រសើរ”។

ព្ញដូច្នោះ ព្រះរាជាត្រាស់ថា៖

“យ៉ាងម៉េចវិញ បាមហោសថ?”

មហោសថក្រាបទូលថា៖

“តាពោះកំប៉ោងនុ៎ះ[៥៧]ចេះដឹងអ្វី សូមទ្រង់ព្រះសណ្ដាប់ចុះ”ៗ

ហើយមហោសថក្រាបទូលព្រះរាជាជាបន្តថា៖

“បុគ្គលខ្លៅ កាលណាមានអំណាច រមែងបាននូវទ្រព្យ ព្រោះតែធ្វើនូវកម្មដ៏ក្លៀវក្លា គឺការកៀបសង្កត់ប្រជារាស្ត្រ[៥៨] ដែលជាអំពើមិនល្អទេ ពួកនិរយបាល[៥៩] តែងទាញកន្ត្រាក់នូវបុគ្គលខ្លៅឥតប្រាជ្ញា ដែលកំពុងកន្ទក់កន្ទេញនោះ យកទៅកាន់នរកដែលមានទុក្ខវេទនាឈឺចាប់ខ្លោចផ្សាៗ ទូលបង្គំបានឃើញហេតុនេះទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ រីឯបុគ្គលខ្លៅមានយស មិនប្រសើរទេ”ៗ

ព្រះរាជាត្រាស់ថា៖

“តើមានយោបល់បន្ថែមទៀតទេ លោកសេនកៈ?”

អាចារ្យសេនកៈក្រាបទូលដូច្នេះថា៖

---

[៥៧] មហោទរោ <មហន្ត(ធំ) + ឧទរ (ពោះ) = ពោះធំ, ពោះកំប៉ោងៗ

[៥៨] ជន់ បីឡេត្វា ជន់ វិន្ទតិៗ

[៥៩] **និរយ**(នរក) + **បាល** (អ្នកត្រួត)= អ្នកត្រួតត្រាឋាននរក, អ្នកគ្រប់គ្រងឋាននរកៗ

"ទឹកស្ទឹងទាំងអស់ ទាំងស្ទឹងតូច ទាំងស្ទឹងធំ កាលហូរចាក់ទៅក្នុងទន្លេគង្គា រមែងលះបង់នូវនាមនិងគោត្រដើមរបស់ខ្លួន ដល់នូវការរាប់ថា ជាទឹកទន្លេគង្គាវិញ។ ទឹកទន្លេគង្គា បើហូរទៅដល់សមុទ្រ ក៏បាត់ឈ្មោះខ្លួនដែរ ហើយបានឈ្មោះថា ជាទឹកសមុទ្រវិញ យ៉ាងណាមិញ សូម្បីបុគ្គលមានប្រាជ្ញាច្រើន ជាគ្រឿងសម្រេច កាលបើមកដល់ក្នុងសម្នាក់របស់ ឥស្សរជនណាម្នាក់ គេក៏មិនប្រាកដ មិនល្បីក្នុងលោកទៀតទេ បីដូចទឹកទន្លេគង្គា ហូរចូលសមុទ្រដូច្នោះដែរ។ ទូលបង្គំបានឃើញហេតុយ៉ាងនេះ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប រីឯបុគ្គលមាន យសសម្បត្តិ ជាបុគ្គលប្រសើរ"។

ព្រះរាជាង៉ាកទៅសួរមហោសថម្តងថា៖

"យ៉ាងម៉េចដែរ បណ្ឌិត?"

មហោសថ ក្រាបទូលថា៖

"លោកសេនកៈ បានពោលថាសមុទ្រមានទំហំធំ ល្វឹងល្វើយ ដែលស្ទឹងទាំងឡាយ មានចំនួនរាប់មិនបាន តែងហូរចូលទៅអស់កាលទាំងពួង និងមានសន្ទុះរលកធំៗជានិច្ចកាល ដូច្នេះក៏ពិតមែនហើយ ប៉ុន្តែទឹកមហាសមុទ្រមិនអាចកន្លងហួសច្រាំងបានទេ កាលបើដល់ច្រាំងហើយ តែងបែកធ្លាយទៅមិនខាន។

ការប្រឹក្សាទាំងឡាយរបស់បុគ្គលខ្លៅក៏យ៉ាងនោះដែរ គឺមិនអាចកន្លងហួសពីអ្នកមានប្រាជ្ញាបានទេ កាលបើជ្រាបដល់អ្នកប្រាជ្ញហើយ ការប្រឹក្សានោះក៏រមែងមានដំណោះស្រាយល្អៗ អ្នកមានសម្បត្តិ មិនរំលងនូវអ្នកមានប្រាជ្ញាបានទេៗ ឧទាហរណ៍ថា មនុស្សម្នាក់កើតចម្ងល់ក្នុងការមានប្រយោជន៍ ឬឥតប្រយោជន៍ ដើម្បីកាត់នូវសេចក្ដីសង្ស័យនោះ ចាំបាច់ត្រូវតែសេពគប់នឹងអ្នកមានប្រាជ្ញា មិនត្រូវសសុលក្រោម បាទជើងអ្នកធំដែលខ្លៅនោះទេ[៦០] ដ្បិតថា ការវិនិច្ឆ័យបញ្ហាសំខាន់ៗនេះ គឺគេត្រូវឋិតនៅក្នុងទីជិតជើងដៃរបស់អ្នកមានប្រាជ្ញាហ្នឹងឯង ទូលបង្គំបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ រីឯបុគ្គលល្ងង់ខ្លៅ មានយសសក្តិ មិនប្រសើរទេ”ៗ

ព្រួដូច្នោះ ព្រះរាជាត្រាស់ថា៖

“យ៉ាងម៉េចវិញ លោកសេនកៈ?”

សេនកៈក្រាបទូលថា៖

“ក្រាបទូលព្រះអង្គ បុគ្គលដែលមានយស មានឥស្សរិយៈ មានបរិវារច្រើនចោមរោម ឋិតនៅក្នុងទីវិនិច្ឆ័យ បើទុកណាជា

---

[៦០] ន...ពាលស្ស ឥស្សរស្ស បាទមូលំ គច្ឆតិ ។

ខ្លួនគេទ្រុស្តសីល មិនសង្រួមដោយកាយជាដើម ក៏គេអាចបំភ្លៃសេចក្តី គឺនិយាយកុហកក្លែងសំដីពិត ធ្វើឲ្យអ្នកជាម្ចាស់មិនមែនម្ចាស់ សម្តីរបស់គេលូតលាស់ក្នុងកណ្តាលនៃពួកញាតិ។ មែនពិតអ្នកមានសម្បត្តិធ្វើអំពើដូច្នោះបាន តែអ្នកមានប្រាជ្ញាធ្វើមិនបានទេ ទូលបង្គំបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប រីឯបុគ្គលមានសម្បត្តិជាបុគ្គលប្រសើរ"។

ព្រះរាជា ត្រាស់សួរបន្តទៀតថា៖

"នែបាមហោសថ! ចុះអ្នកមានយោបល់អ្វីបន្ថែមទៀតទេ?"

មហោសថបណ្ឌិត ក្រាបទូលថា៖

"សូមទ្រង់ព្រះសណ្តាប់ ព្រះអង្គ! សេនកៈនេះល្ងង់ខ្លៅណាស់ មិនចេះដឹងអ្វីសោះ" ព្រោះថា៖

"បុគ្គលពាលអប្បប្រាជ្ញា និយាយកុហក ព្រោះហេតុនៃអ្នកដទៃឬខ្លួនឯង។ បុគ្គលពាលនោះរមែងត្រូវគេតិះដៀលក្នុងកណ្តាលទីប្រជុំ ក្នុងកាលខាងក្រោយ បុគ្គលពាលនោះរមែងទៅកាន់ទុគ្គតិ។ ទូលបង្គំបានឃើញហេតុនេះហើយ ទើបក្រាបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ រីឯបុគ្គលល្ងង់ខ្លៅមានយសមិនប្រសើរទេ"។

គ្រានោះ អាចារ្យសេនកៈ និយាយដូច្នេះថា៖

“បុគ្គលមានប្រាជ្ញាក្រាស់ដូចផែនដី តែមិនមានលំនៅ មិនមានទ្រព្យធន គឺជាបុគ្គលក្រីក្រ បើទុកជាពោលនូវសេចក្តីណាមួយដែលសមហេតុផល ក៏សម្តីរបស់បុគ្គលនោះមិនបានរីកចម្រើនក្នុងកណ្តាលនៃពួកញាតិ ទាំងសិរីសួស្តីក៏មិនមានដែរ។ ពេលទៅកាន់សម្នាក់អ្នកមានយសសក្តិ រមែងមានសភាពប្រាកដដូចអំពិលអំពែក ក្នុងពេលព្រះអាទិត្យរះឡើង។ ទូលបង្គំបានឃើញហេតុនេះ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប រីឯបុគ្គលល្ងង់ខ្លៅមានយសសម្បត្តិ ជាបុគ្គលប្រសើរ”។

ព្រះរាជាត្រាស់ទៀតថា៖

“មានយោបល់អ្វីបន្ថែមទេ បាមហោសថ”។

មហោសថបណ្ឌិតក្រាបទូលថា៖

“ចេះដឹងស្អី អាចារ្យសេនកៈហ្នឹង! គេមើលឃើញត្រឹមតែលោកនេះប៉ុណ្ណោះ។ លោកខាងមុខ គេមើលមិនឃើញទេ”។

ដូច្នេះហើយមហោសថពោលបន្តថា៖

“បុគ្គលអ្នកមានប្រាជ្ញាក្រាស់ដូចផែនដី មិននិយាយនូវពាក្យឡេះឡោះ ព្រោះហេតុនៃបុគ្គលដទៃឬខ្លួនឯងឡើយ។ បុគ្គលអ្នកមានប្រាជ្ញានោះតែងមានគេបូជាក្នុងកណ្តាលទីប្រជុំ លុះលះលោក

នេះទៅ អ្នកមានប្រាជ្ញានោះ រមែងទៅកាន់សុគតិភព។ ទូលបង្គំបានឃើញហេតុនេះហើយ ទើបក្រាបទូលថា បុគ្គលមានប្រាជ្ញាជាបុគ្គលប្រសើរ រីឯបុគ្គលខ្លៅមានយសមិនប្រសើរទេ”។

គ្រានោះ សេនកៈនិយាយថា៖

“ដីរី គោ សេះ កែវមណី កុណ្ឌល និងនារី តែងកើតមានក្នុងត្រកូលដ៏ស្តុកស្តម្ភ។ ដីរី គោ សេះជាដើម ទាំងអស់នោះជារបស់មិនមានឫទ្ធិ ទើបទៅជាគ្រឿងឧបភោគប្រើប្រាស់របស់បុគ្គលជាឥស្សរៈ។ មិនមែនត្រឹមតែនារីទាំងឡាយប៉ុណ្ណោះទេ សូម្បីសត្វទាំងឡាយអ្នកមិនមានឫទ្ធិទាំងអស់ ក៏គង់ក្លាយជាឧបភោគរបស់បុគ្គលជាឥស្សរៈនោះដែរ។ ទូលបង្គំបានឃើញហេតុនេះ ទើបទូលថ្វាយថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប រីឯបុគ្គលមានសម្បត្តិ ជាបុគ្គលប្រសើរ”។

លំដាប់នោះ មហោសថ និយាយថា៖

“អាចារ្យសេនកៈនុ៎ះ ចេះដឹងអ្វី?”

ហើយក៏ទាញយកហេតុផលមួយ មកពោលបង្ហាញដូច្នេះថា៖

“សិរី គឺឥស្សរិយយស តែងលះបង់បុគ្គលពាល ដែលមិនចេះចាត់ចែងការងារ ជាអ្នកមានគំនិតអាក្រក់ ឥតប្រាជ្ញា ដូចពស់សកសំណាកចាស់ចោល។ ទូលបង្គំបានឃើញហេតុនេះ ទើបទូល

ថ្វាយថា បុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ រីឯបុគ្គលល្ងង់ខ្លៅ មានយសសក្តិ មិនប្រសើរទេ"។

ព្រះរាជាសួរបន្តថា៖

"យ៉ាងម៉េចដែរ សេនកៈ?"

អាចារ្យសេនកៈនោះ ក្រាបទូលថា៖

"បពិត្រព្រះសម្មតិទេព គេនុំះក្មេងខ្ចីពេកណាស់គេចេះដឹងអ្វី សូមទ្រង់ព្រះសណ្តាប់"។

ហើយក៏ពោលក្នុងគំនិតផ្ចាញ់មហោសថឲ្យអស់តម្រិះលែងនិយាយត កើតដូច្នេះថា៖

"បពិត្រព្រះអង្គដ៏ចម្រើន ពួកទូលព្រះបង្គំជាខ្ញុំទាំង ៥ នាក់ សុទ្ធសឹងជាបណ្ឌិត ប្រណាម្យដែលបម្រើព្រះអង្គទាំងអស់គ្នា។ ព្រះអង្គជាធំលើសលុបលើពួកទូលព្រះបង្គំជាខ្ញុំ ដូចជាសក្កទេវរាជធំលើពួកទេវតា។ ទូលបង្គំបានឃើញហេតុនេះ ទើបទូលថ្វាយថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប រីឯបុគ្គលមានយសសម្បត្តិ ទើបជាបុគ្គលប្រសើរ"។

**មហោសថផ្ចាញ់សេនកៈដោយកម្លាំងបញ្ញា**

**កំណត់សម្គាល់**

*ព្រះបាទវិទេហរាជ ទ្រង់ព្រះសណ្ដាប់នូវសេចក្ដីអះអាងរបស់អាចារ្យសេនកៈប៉ុណ្ណោះ ទ្រង់មានព្រះតម្រិះថា "ហេតុផល ដែលអាចារ្យសេនកៈនាំមកពោលនេះ មានសភាពត្រឹមត្រូវ តើបុត្ររបស់យើងនឹងអាចទាញហេតុផលដទៃមកបំបែកទ្រឹស្ដីរបស់ អាចារ្យសេនកៈនេះបានឬទេ?" មានព្រះតម្រិះដូច្នេះហើយទ្រង់សួរមហោសថថា៖*

*"យ៉ាងម៉េច បណ្ឌិតកូន?"*

*ហេតុផលដែលអាចារ្យសេនកៈលើកមកពោលអះអាងនេះ វៀរលែងតែមហោសថចេញ គឺគ្មានបុគ្គលណាម្នាក់មានសមត្ថភាពអាចបំបែកទ្រឹស្ដីនោះបានឡើយ។ ព្រោះហេតុនោះ មហោសថមុននឹងបំបែកទ្រឹស្ដីរបស់អាចារ្យសេនកៈ ដោយកម្លាំងប្រាជ្ញារបស់ខ្លួន មហោសថបានក្រាបទូលព្រះរាជាថា៖*

*"បពិត្រមហារាជ មនុស្សខ្លៅទុំរចេះដឹងអ្វី គេឃើញតែយសទេ*

*គេមិនដឹងភាពពិសេសនៃប្រាជ្ញាទេ សូមទ្រង់ព្រះសណ្ដាប់"។*

*ហើយមហោសថក៏ពោលបន្តដូច្នេះទៀតថា៖*

*"បុគ្គលពាលដែលមានយស ទុកដូចជាទាសៈរបស់បុគ្គលអ្នក*

*មានប្រាជ្ញា។ កាលបើមានរឿងហេតុការណ៍អ្វីកើតឡើងដូច្នោះ*

អ្នកប្រាជ្ញបានទិពន្ធប្រស្នាដ៏ល្អិតសុខុម។ បុគ្គលពាល តែងវង្វេង វង្វាន់ទាល់ច្រកដោះប្រស្នាដ៏ល្អិតនោះមិនរួច។ ទូលបង្គំជាខ្ញុំបាន ឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ រីឯបុគ្គលខ្លៅមានយសសក្តិ មិនប្រសើរទេ"។

**សេនកៈទាល់តម្រិះ**

គ្រាន់តែមហោសថទាញយកហេតុផលដ៏ត្រូវទំនងនេះ មកសម្តែង ភ្លាម ហាក់បីដូចកើបខ្សាច់មាសអំពីជើងភ្នំព្រះសុមេរុ៍[៦១] ឬដូចបាច លម្អិតខ្ទឹមចន្ទន៍ពាសពេញផ្ទៃនភាល័យ។

នាកាលមហោសថថ្លែងបង្ហាញ អំពីអានុភាពនៃប្រាជ្ញាយ៉ាងនេះ ព្រះរាជាត្រាស់នឹងសេនកៈថា៖

"យ៉ាងម៉េចដែរ សេនកៈ! តើអ្នកអាចពោលបន្ថែមទៀតទេ?"

---

៦១ សុមេរុ --មេ-រុ ឬ--ម៉ែ សំ. បា. (ន.) (សុមេរុ "ភ្នំបៀតបៀននូវភ្នំទាំងពួង ដោយកម្ពស់របស់ខ្លួន គឺភ្នំខ្ពស់ជាងភ្នំទាំងអស់ក្នុងសាកលលោក") ឈ្មោះភ្នំមួយ ធំខ្ពស់ចម្បង ជាទីតាំងនៃត្រៃត្រិង្សសួគ៌ ដែលជាថានរបស់ព្រះឥន្ទ្រ។ ពាក្យថា នេរុ, មេរុ, សិនេរុ, តិទិវាធរ, សុរគិរី, សុរាទ្រិ, សុរាស្រ័យ សុទ្ធតែជាឈ្មោះរបស់ភ្នំនេះ ឯង ប៉ុន្តែខ្មែរប្រើពាក្យ សុមេរុ ឬ សុមេរុ៍ ជាង : ភពត្រៃត្រិង្ស ឋិតនៅលើភ្នំព្រះសុមេរុ៍ (ហៅ សុមេរុបពត៌ ឬ សុមេរុរាជ ក៏បាន)។

ចំណែកឯអាចារ្យសេនកៈ អស់តម្រិះទាល់ប្រាជ្ញា បង្អិនចំណេះវិជ្ជាខ្លួន ដែលខំរៀនទាំងអម្បាលម៉ាន ដូចធញ្ញជាតិប្រមូលដាក់ជង្រុក ហើយត្រូវខ្មួចខ្មីអស់ទៅវិញ គេអង្គុយខ្មាសសំយុងក ឱនមុខចុះៗ មែនពិត ប្រសិនបើសេនកៈនោះ គប្បីនាំមកនូវហេតុផលដទៃទៀត មកអាង ជាតកនេះនឹងមិនចប់ក្នុងគាថា ១.០០០[៦២]ៗ ប៉ុន្តែក្នុងពេល អាចារ្យសេនកៈអង្គុយអស់តម្រិះតតាំង មហោសថបានឆ្លៀតឱកាស ពោលសរសើរគុណនៃប្រាជ្ញាបន្ថែម បីដូចទឹកជំនន់ដ៏ធំដូច្នេះថា៖

"តាមពិត ពួកសប្បុរសតែងសរសើរប្រាជ្ញាតែម្យ៉ាងៗ បពិត្រ មហារាជ ព្រោះហេតុតែពួកមនុស្សអន្ធពាល តែងត្រេកអរ ចំពោះតែភោគៈ ដូច្នោះយសសក្តិ ទើបជាទីត្រេកអររបស់ពួក គេៗ ដែលហៅថា យសនេះ គឺបណ្ឌិតទាំងឡាយតែងតិះដៀល តែវាជាទីប្រាថ្នារបស់បុគ្គលពាលៗ មួយទៀត ញាណនៃអ្នក ប្រាជ្ញទាំងឡាយ មានតម្លៃរកអ្វីប្រៀបផ្ទឹមមិនបានទេៗ គ្រប់ សម័យកាលទាំងអស់ បុគ្គលអ្នកមានយសសក្តិ មិនអាច បោះបង់ចោលបុគ្គលអ្នកមានប្រាជ្ញាបានឡើយ ក្រាបទូល"ៗ

---

[៦២] ន គាថាសហស្សេនបិ ឥមំ ជាតកំ និដ្ឋាយេថៗ

ព្រះរាជាទ្រង់ព្រះសណ្ដាប់ដូច្នោះ ទ្រង់មានហឫទ័យត្រេកអរ ចំពោះការ ដោះស្រាយប្រស្នារបស់មហោសថ។ ព្រះអង្គ មុននឹងបូជាទ្រព្យចំពោះមហោសថឲ្យដូចជាភ្លៀងធ្លាក់មកទាំងដុំៗ ទ្រង់បានពោលដូច្នេះថា៖

"នែមហោសថ! អ្នកជាបុគ្គលឃើញធម៌សព្វគ្រប់ យើងបានសួរនូវប្រស្នាណា អ្នកអាចដោះនូវប្រស្នានោះ ថ្វាយយើងច្បាស់លាស់ណាស់ យើងសែនត្រេកអរជាទីបំផុតចំពោះការដោះប្រស្នារបស់អ្នក។ យើងព្រះរាជទានគោឧសភៈ ១.០០០ ដំរីរថដែលទឹមដោយសេះអាជានេយ្យ ១០ និងស្រុកសួយ ១៦ ដល់អ្នក"។

សិរិមន្ទបញ្ហា[៦៣] ចប់។

[៦៣] ក្នុងវីសតិនិបាត។

# ជំពូកទី ៥

## នាងអមរានិងមហោសថ

## ឆន្ទបថបញ្ហា

### មហោសថស្វែងរកភរិយា

ពីគ្រានោះមក មហោសថបានទទួលយសសក្តិទ្រព្យសម្បត្តិយ៉ាងច្រើន របស់របរទាំងអស់នោះ ព្រះនាងឧទុម្ពរទេវីបានរៀបចំទុកដាក់ឲ្យយ៉ាងគង់វង្ស[៦៤]។ ដល់មហោសថអាយុ ១៦ ឆ្នាំ ព្រះនាងគិតថា "ប្អូនអញធំពេញកំលោះហើយ យសរបស់គេក៏ខ្ពង់ខ្ពស់ដែរ គួរណាស់តែអញរៀបចំផ្សំផ្គុំគេឲ្យមានភរិយា[៦៥]"។ ហើយព្រះនាងទៅក្រាបទូលសេចក្តីនោះ ចំពោះព្រះរាជា។ ព្រះរាជាត្រាស់ថា "ប្រពៃណាស់ ចូរនាងប្រាប់មហោសថឲ្យដឹងផងចុះ"។ ព្រះនាងក៏បានប្រាប់មហោសថឲ្យដឹង។ កាលបើមហោសថយល់ព្រម ព្រះនាងប្រាប់ថា "ប្អូនប្រុសបើដូច្នោះ ខ្ញុំនឹងទៅស្តីដណ្តឹងកូនក្រមុំគេមកឲ្យប្អូនឯងផ្ទាល់"។ លំដាប់នោះ មហោសថគិតថា "ក្នុងកាលកន្លងមក កូនក្រមុំដែលអ្នកទាំងនោះ

---

[៦៤] តំ សព្វំ ឧទុម្ពរទេវីយេវ វិចារេសិ។

[៦៥] អាវាហមស្ស កាតុំ វដ្តតិ។

ស្តីដណ្តឹងមកឲ្យអញ មិនដែលត្រូវចិត្តអញសោះ អញត្រូវជ្រើសរើសប្រពន្ធដោយខ្លួនឯងវិញ សឹមទូលព្រះអង្គនិងព្រះនាងជាក្រោយ"

លុះគិតដូច្នេះហើយ មហោសថបានក្រាបទូលព្រះនាងយ៉ាងនេះថា៖

"បពិត្រព្រះទេវី សូមព្រះនាងកុំអាលប្រាប់អ្វីដល់ព្រះរាជា ចាំពីរបីថ្ងៃសិន ទូលបង្គំនឹងស្វែងរកនូវកូនក្រមុំគេម្នាក់ដោយខ្លួនឯង តាមការគាប់ចិត្តរបស់ទូលបង្គំ រួចនឹងទូលព្រះនាងជាក្រោយ"។

ព្រះនាងយល់ព្រមថា៖

"ប្អូនប្រុស ចូរប្អូនជ្រើសរើសតាមចិត្តប្អូនចុះ"។

មហោសថថ្វាយបង្គំលាព្រះទេវីហើយ ទៅកាន់ផ្ទះរបស់ខ្លួនឲ្យសញ្ញាដល់ពួកសម្លាញ់ រួចស្លៀកពាក់ក្លែងភេទដែលអ្នកផងមើលមិនស្គាល់ កាន់ដំបងនិងឧបករណ៍តម្បាញ ដើរចេញទៅតាមទ្វារខាងជើងតែម្នាក់ឯង ធ្វើដំណើរឆ្ពោះទៅកាន់ស្រុកឧត្តរគ្រាម ភូមិភាគខាងជើង។

**មហោសថជួបនាងអមរា**

នៅស្រុកនោះ មានត្រកូលមួយធ្លាប់ជាសេដ្ឋីពីជំនាន់ដើម តែក្រោយមកធ្លាក់ខ្លួនក្រ។ ត្រកូលនោះ មានកូនស្រីតែម្នាក់ ឈ្មោះ **អមរាទេវី** នាងមានរូបឆោមលោមល្អ គួរឲ្យពិតពិលរមិលមើល គួរជា

ទីស្រឡាញ់ ដល់ព្រមដោយលក្ខណៈសព្វគ្រប់ និងជាអ្នកមានបុណ្យ កព្វសំណាងពីព្រេងនាយ។ គាប់ចួនថ្ងៃនោះ នាងអមរា ចម្អិនបបរពីព្រលឹម ទូលយកទៅជូនឪពុកដែលកំពុងភ្ជួរស្រែ មហោសថ ក៏បានធ្វើដំណើរតាមផ្លូវនោះដែរ[៦៦]។ មហោសថលោតែ[៦៧]ប្រទះភ្នែកឃើញនាងកំពុងដើរមក គិតក្នុងចិត្តថា "នាងនេះមានលក្ខណៈល្អប្រពៃ សព្វគ្រប់អ្វីម្ល៉េះទេ! អញកម្របានជួបប្រទះណាស់ ប្រសិនបើនាងនៅលីវមិនទាន់មានគេគ្រប់គ្រងទេ[៦៨]នាងសមតែជាភរិយារបស់អញ"។ ចំណែកនាងអមរានោះវិញ ចោលភ្នែកឃើញមហោសថភ្លាម គិតក្នុងចិត្តថា "ប្រសិនបើអញគប្បីបាននៅក្នុងផ្ទះរបស់បុរសនោះ អញប្រាកដជាទុកដាក់ទ្រព្យសម្បត្តិបានយ៉ាងល្អ"។ គ្រានោះ មហោសថ គិតថា "ឥឡូវនេះ អញមិនទាន់ដឹងថាស្ត្រីនេះមានប្ដីឬអត់ប្ដីទេ អញនឹងសួរនាងដោយប្រស្នាក្ដាប់ដៃ ប្រសិនបើនាងនុ៎ះជាស្ត្រីឆ្លាត គង់តែនាងយល់ន័យពុំខាន តែបើនាងមិនឆ្លាត នាងនឹងមិនយល់ន័យឡើយ ហើយអញនឹងដើរហួសនាងទៅពីទីនេះតែម្ដង"។ លុះគិតដូច្នេះហើយ មហោសថ

---

[៦៦] តមេវ មគ្គំ បដិបជ្ជិ។

[៦៧] លោតែ (និ.) ស្រាប់តែ : លោតែមក, លោតែបាន, លោតែលេចប៉ឹមមកពីណា។

[៦៨] សចេ អបរិគ្គហា។

កំពុងឋិតនៅក្នុងទីឆ្ងាយនៅឡើយ ក៏ធ្វើអាការៈក្ដាប់ដៃឲ្យនាងអមរានោះមើលមកឃើញ។ ចំណែកនាងអមរាឃើញហើយ យល់ន័យភ្លាមថា "យីអើ! បុរសនេះសួរអញថា មានស្វាមីឬក៏អត់ទេតើ"។ ដូច្នេះ នាងក៏លាដៃឲ្យមហោសថឃើញវិញ។

**សំណួរឆ្លើយឆ្លងល្បងប្រាជ្ញា**

មហោសថកាលបានដឹងថា នាងនៅលីវ ក៏ដើរចូលទៅជិត រួចសួរថា៖

"ម្នាលប្អូនស្រី តើនាងឈ្មោះអ្វី?"

"បពិត្រអ្នកប្រុស ខ្ញុំមានឈ្មោះជារបស់ដែលមិនមានក្នុងអតីតៈ ឬអនាគត ឬក៏ក្នុងបច្ចុប្បន្ននេះ" អមរាឆ្លើយ។

"ម្នាលប្អូនស្រី ដែលហៅថាការមិនស្លាប់ មិនមានក្នុងលោកទេ នាងមានឈ្មោះ **អមរា** មែនទេ?" មហោសថនិយាយ។

"ពិតជាត្រឹមត្រូវមែន អ្នកប្រុស" អមរាឆ្លើយតប។

"នែប្អូនស្រី! តើនាងយកបបរទៅជូនទរណា?" មហោសថសួរ។

"ទៅជូនបុព្វទេវតា អ្នកប្រុស" អមរាឆ្លើយ។

"ដែលហៅថាបុព្វទេវតា គឺម្ដាយនិងឪពុក នាងទំនងជាយកបបរទៅជូនឪពុកនាងមែនឬទេ?" មហោសថនិយាយ។

"ពិតយ៉ាងនោះមែន អ្នកប្រុស" អមរាឆ្លើយ។

"ឪពុករបស់នាងកំពុងធ្វើអ្វី?" មហោសថសួរ។

"អ្នកប្រុស ឪពុកខ្ញុំកំពុងធ្វើរបស់មួយឲ្យទៅជាពីរ" អមរាឆ្លើយ។

"ធម្មតា ការធ្វើរបស់មួយឲ្យទៅជាពីរ មានតែការភ្ជួរ[៦៩]ស្រែ អ៊ីចឹងមានតែឪពុកនាងកំពុងតែភ្ជួរស្រែមែនឬទេ?" មហោសថនិយាយ។

"ពិតដូច្នោះមែនហើយ អ្នកប្រុស" អមរាឆ្លើយ។

"ចុះឪពុករបស់នាង ភ្ជួរស្រែនៅឯណា?" មហោសថសួរ។

"គាត់កំពុងភ្ជួរនៅកន្លែងដែលពួកគេទៅម្តងហើយមិនមកវិញទេ អ្នកប្រុស" អមរាឆ្លើយ។

"ដែលហៅថា កន្លែងមិនមកវិញរបស់ពួកមនុស្សអ្នកទៅម្តង មានតែព្រៃស្មសានកន្លែងចោលខ្មោច បើអ៊ីចឹងមានតែឪពុករបស់នាង ភ្ជួរស្រែជិតព្រៃស្មសានមែនឬទេ ប្អូនស្រី?" មហោសថនិយាយ។

"ពិតយ៉ាងនោះមែនហើយ អ្នកប្រុស" អមរាឆ្លើយ។

"តើនាងនឹងមកវិញក្នុងថ្ងៃនេះឬទេ?" មហោសថសួរ។

---

[៦៩] ភ្ជួរ (កិ.) រម្ងើងដីដោយនង្គ័លឲ្យរបើកជាអាចម៍បំណះ : ភ្ជួរស្រែ, ភ្ជួរដីចម្ការ។

"បពិត្រអ្នកប្រុស ប្រសិនបើគេមក ខ្ញុំនឹងមិនមកទេ តែបើគេមិនមក ខ្ញុំនឹងមកវិញ" អមរាឆ្លើយ។

"ឪពុកនាងទំនងជាភ្ជួរស្រែនៅឯត្រើយនាយនៃស្ទឹង កាលបើទឹកជន់មក នាងជាក់ជាមិនមកទេ តែកាលបើទឹកមិនជន់មកទេ នាងប្រាកដជាមកវិញមែនឬទេ?" មហោសថនិយាយ។

"ពិតមែនហើយ អ្នកប្រុស" អមរាឆ្លើយ។

មហោសថ បានធ្វើការនិយាយផ្ដោះផ្ដងសាសងឆ្លងឆ្លើយជាមួយនឹងនាងអមរាមានប្រមាណប៉ុណ្ណេះ។ គ្រានោះ អមរាទេវីសួរមហោសថថា៖

"តើអ្នកប្រុសចង់ទទួលទានបបរដែរឬទេ?"

មហោសថគិតថា "ធម្មតា ការបដិសេធដំបូង វាជាអពមង្គល" ហើយក៏ប្រាប់ថា៖

"បាទ ខ្ញុំចង់ហូបបន្តិចមើល"។

ចំណែកនាងអមរាដាក់បបរដែលនាងទូលចុះមក។ មហោសថគិតថា "ប្រសិនបើនាងមិនលាងចាន និងមិនឲ្យទឹកលាងដៃ អញនឹងចេញទៅចោលនាងតែម្ដង មិនទទួលទានបបរទេ"។ ប៉ុន្តែនាងអមរាលាងចាន រួចយកចានហ្នឹងដងទឹក ហុចឲ្យមហោសថលាងដៃ។

នាងអមរាដាក់បានលើដី រួចកូរបបរឲ្យពេញក្នុងឆ្នាំង[៧០] ព្រោះគ្រាប់បបរក្នុងឆ្នាំងនោះខាប់ដុំៗ។ គ្រានោះ មហោសថសួរនាងថា៖

"ម្នាលប្អូនស្រី ម្ដេចក៏បបរខាប់ម្ល៉េះ?"

"មកពីអត់មានទឹក អ្នកប្រុស" អមរាឆ្លើយ។

"ទំនងជានៅតាមភ្លឺស្រែ អត់មានទឹកឬ?" មហោសថនិយាយ។

"ពិតយ៉ាងនោះមែនហើយ អ្នកប្រុស" អមរាឆ្លើយ។

**ផ្លូវទៅផ្ទះនាងអមរា**

នាងអមរា ទុកបបរមួយចំណែកសម្រាប់ឪពុក ហើយបានឲ្យមហោសថមួយចំណែក មហោសថហុតបបររួចខ្ពុរមាត់ ហើយប្រាប់ថា៖

"នែប្អូនស្រី! ខ្ញុំនឹងទៅផ្ទះម្ដាយនាង សូមប្រាប់ផ្លូវខ្ញុំផងបានទេ"។

"មិនជាប្ដីទេ" អមរាឆ្លើយ។

ហើយនាងអមរាបានប្រាប់ផ្លូវដោយពាក្យដូច្នេះថា៖

"បពិត្រអ្នកប្រុស[៧១] សូមអ្នកអញ្ជើញចូលទៅខាងក្នុងស្រុក នឹងឃើញផ្សារសដូវមួយ បន្ទាប់ពីនោះ មានផ្សារម្ហូរ នៅខាងមុខនោះ

---

[៧០] យដំ អាលុឡេត្វា យាគុយា បូរេសិ។

[៧១] "សាមិ, អន្តោគាមំ បវិសិត្វា ឯកំ សត្តុអាបណំ បស្សិស្សសិ, តតោ កញ្ជិកាបណំ, តេសំ បុរតោ ឥគុណាបណ្ណោ កោវិឡារោ សុបុប្ផិតោ, តស្មា ត្វំ យេន សត្តុពិលង្គំ ច កោវិឡារោ ច បុប្ផិតោ, តេន គន្ត្វា កោវិឡារមូលេ ឋត្វា ឧក្ខិ

មានដើមល្ហុសស៊ីកពីរជាន់ កំពុងតែមានផ្ការីកស្គុសស្គាយ ដូច្នោះ អ្នកប្រុស ដើរតាមផ្សារលក់សដូវ ផ្សារលក់ម្ហូរ និងដើមល្ហុស ដែលមានផ្ការីកនោះចុះ ហើយឈរក្បែរគល់ល្ហុសបត់ទៅខាងស្តាំដៃ តាមដៃកាន់បបររបស់នាងខ្ញុំ កុំទៅខាងឆ្វេងតាមដៃ ដែលមិនបានកាន់បបរឲ្យសោះ ទិសនុ៎ះឯងហើយ ជាផ្លូវទៅចំផ្ទះរបស់យើង ដែលឋិតនៅក្នុងស្រុកយវមជ្ឈកគ្រាម នេះជាពាក្យដែលនាងខ្ញុំនិយាយបិទបាំងយ៉ាងនេះ សូមអ្នកប្រុសដឹងនូវផ្លូវកាត់ ឬផ្លូវកំបាំងនូវផ្លូវកាត់ ឬហេតុកំបាំងចុះ"។

ក្រោយពេលប្រាប់ផ្លូវទៅផ្ទះដល់មហោសថយ៉ាងនេះ នាងអមរាបានយកបបរបម្រុងជូនឪពុក ធ្វើដំណើរចៀសចេញទៅ។

## មហោសថឃ្លាំមើលចរិតនាងអមរា

ចំណែកមហោសថ ទៅផ្ទះនាងអមរាតាមផ្លូវដែលនាងប្រាប់។ គ្រានោះ ម្តាយរបស់អមរាទេវីឃើញមហោសថ គាត់ក៏រៀបចំកន្ទេលឲ្យអង្គុយ ហើយសួរថា៖

---

ឈំ គណ្ហ វាមំ មុញ្ច, ឯស មគ្គោ យវមជ្ឈកស្ស យវមជ្ឈកគាមេ ឋិតស្ស អម្ហាកំ គេហស្ស, ឯតំ ឯវំ បដិច្ឆាទេត្វា មយា វុត្តំ ឆន្នបថំ បដិច្ឆន្នបថំ ឆន្នបថំ វា បដិច្ឆន្នការណំ វិជានាហី"តិ។

"តើក្មួយចង់ហូបបបរឬទេ?"

មហោសថឆ្លើយថា៖

"បាទម៉ែ! អមរាទេវីប្អូនស្រីខ្ញុំ បានឲ្យបបរដល់ខ្ញុំបន្តិចហើយ"។

ឮដូច្នោះ ម្តាយអមរាដឹងច្បាស់ក្នុងចិត្តថា៖

"បុរសនេះប្រាកដជាមកដណ្តឹងកូនក្រមុំអញហើយ"។

មហោសថបើទុកណាជាដឹងភាពទុគ៌តរបស់ពួកគេ ក៏នៅតែសួរថា៖

"ម៉ែ! ខ្ញុំជាជាងដេរប៉ាក់ តើមានសំពត់អ្វីល្មមដេរបានឬទេ?"

ម្តាយអមរានិយាយថា៖

"មានដែរ ក្មួយអើយ ប៉ុន្តែមិនអត់មានប្រាក់ឈ្នួលទេ"។

"ខ្ញុំមិនគិតថ្លៃអ្វីទេ សូមម៉ែយកវាមកចុះ ខ្ញុំនឹងដេរជូន"។

ម្តាយនាងអមរា បានយកសំពត់ចាស់ៗជាច្រើនមកឲ្យដេរ។ មហោសថ គិតតែពីដេរ រហូតដល់អស់នូវសំពត់ដែលគាត់យកមកទាំងអម្បាលម៉ាន។ ពិតមែនហើយ ដែលហៅថាការងាររបស់អ្នកមានបុណ្យ តែងតែបានសម្រេច។ លំដាប់នោះ មហោសថប្រាប់ម្តាយនាងអមរាថា៖

"ម៉ែ! សូមម៉ែទៅជម្រាបអ្នកស្រុកឲ្យដឹងផងថា មានជាងប្រសប់ដេរខោអាវមកដល់ថ្មី"។

ម្តាយអមរាដើរជម្រាបគេឯង ឲ្យដឹងទូទាំងស្រុក។ មហោសថធ្វើការដេរប៉ាក់ត្រឹមតែមួយថ្ងៃបានចំណូល ១.០០០ កហាបណៈ។ ម្តាយនាងអមរា ចម្អិនអាហារពេលព្រឹកឲ្យមហោសថ រួចសួរថា៖

"កូន! តើម៉ែគួរចម្អិនអាហារល្ងាចនេះប៉ុនណា?"

"បាទម៉ែ! មនុស្សហូបចុកក្នុងផ្ទះនេះមានប៉ុន្មាននាក់? សូមដណ្តាំតាមចំនួនមនុស្សប៉ុណ្ណោះចុះ" មហោសថឆ្លើយ។

ម្តាយនាងអមរាបានចម្អិនម្ហូបទឹក និងម្ហូបគ្រៀមជាច្រើនមុខ និងដាំបាយយ៉ាងច្រើនផងដែរ។ ដល់វេលាល្ងាច នាងអមរាទៅទូលឧសមួយបាច់ ខ្ចប់បន្លែមួយថ្នក់ ដើរមកអំពីព្រៃ ដាក់បាច់ឧសជិតទ្វារខាងមុខផ្ទះ រួចចូលទៅផ្ទះតាមទ្វារខាងក្រោយ។ ចំណែកឪពុករបស់នាងដើរមកផ្ទះពេលល្ងាចជាងនាង។ មហោសថ បរិភោគនូវភោជនដែលមានឱជារសឆ្ងាញ់ពិសាផ្សេងៗ។ ចំណែកនាងអមរារៀបបាយម្ហូបជូនម្តាយឪពុកនិងមហោសថបរិភោគរួចមុនហើយ ទើបបាននាងហូបក្នុងកាលខាងក្រោយ។ បន្ទាប់មក នាងលាងជើងរបស់ម្តាយឪពុក រួចលាងជើងជូនភ្ញៀវមហោសថ។

មហោសថស្នាក់នៅទីនោះពីរបីថ្ងៃ ឃ្លាំមើលនាងអមរា។ កាលកំពុងសាកល្បងនាងអមរានោះ ក្នុងថ្ងៃមួយ មហោសថនិយាយថា "នែប្អូនស្រី! នាងយកអង្ករកន្ទះនាឡិទៅបែងចែកដាំបបរខ្លះ ធ្វើនំខ្លះ

ដាំបាយខ្លះ ឲ្យខ្ញុំទទួលទាន”។ នាងអមរាយល់ព្រមធ្វើតាម ក៏បុកអង្ករកន្ទះនាឡិនោះ អង្ករណាទៅគ្រាប់មូល ដាក់ដាំបាយ អង្ករណាបាក់ពាក់កណ្តាលដាក់ដាំបបរ ឯកុណ្ឌក[៧២]យកទៅចម្អិនធ្វើជានំ។ មិនតែប៉ុណ្ណោះ នាងបានចម្អិនម្ហូបទឹកនិងម្ហូបក្រៀមល្មមហូប ជាមួយនឹងបាយនោះផង បបរនោះក៏មានម្ហូបក្រៀម សម្រាប់ហូបជាមួយផងដែរ។ បបរនោះគ្រាន់តែដាក់ដល់មាត់ភ្លាម បានជ្រួតជ្រាបទៅតាមសរសៃទាំង ៧.០០០ ក្នុងសរីរាង្គកាយ។ ដើម្បីសាកល្បងនាងឲ្យបានជាក់លាក់ មហោសថធ្វើពុតជាខឹងថា៖

“នែប្អូនស្រី! នាងមិនចេះដាំបបរសោះ ហេតុអ្វីបានជាបង្ហិនអង្ករខ្ញុំយ៉ាងនេះ?”

ថាដូច្នេះហើយ ក៏ខាកទឹកមាត់ស្តោះទៅលើដី[៧៣]។ នាងអមរាឥតខឹងនឹងមហោសថទាល់តែសោះ នាងថែមទាំងហុចនំជូន ក៏និយាយថា៖

“បពិត្រអ្នកប្រុស បើបបរមិនឆ្ងាញ់ទេ សូមអញ្ជើញពិសានំវិញ”។ មហោសថក៏ធ្វើជាខឹង ស្តីបន្ទោសខាកស្តោះដូចមុនទៀត។ នាងអមរាហុចបាយទៅម្តង ហើយនិយាយថា៖

---

[៧២] កុណ្ឌក កុន-ឌក់ បា. (ន.) ផង់អង្ករ, ល្អងអង្ករ ។ ពាក្យនេះប្រើក្លាយមកជាកន្ទក់។

[៧៣] សហ ខេឡេន និដ្ឋុភិត្វា ភូមិយំ បាតេសិ។

"បពិត្រអ្នកប្រុស ប្រសិនបើទំមិនឆ្ងាញ់ទេ សូមអញ្ជើញបរិភោគបាយនេះម្តង"។

មហោសថធ្វើពុតជាខឹងទៀត បន្ទោសនាងដូច្នោះទៀតថា៖

"នាងមិនចេះចម្អិនអីសោះ ហេតុអ្វីបានជាបង្ខិនអង្ករខ្ញុំអស់យ៉ាងនេះ?"

លុះស្តីឲ្យហើយច្របល់របស់ទាំង ៣ លាយចូលគ្នា លាបទាំងក្បាលរហូតពេញរាងកាយរបស់នាងអមរា ហើយដេញថា៖

"ចេញទៅ ទៅអង្គុយនៅឯមាត់ទ្វារចុះ"។

"ចាស! អ្នកប្រុស" នាងអមរាឥតខឹងបន្តិចទាល់តែសោះ ក៏ដើរទៅអង្គុយនៅឯមាត់ទ្វារ។ មហោសថដឹងថា នាងអមរាចេះអត់ធ្មត់លះបង់នូវមានះ ក៏ស្រែកហៅនាងមកវិញថា៖

"មកណេះវិញមក ប្អូនស្រី" ។

នាងអមរាឥតខឹងដើរមកវិញ ដោយប្រាប់ត្រឹមតែមួយជង។ មុនចេញពីរាជធានីមក មហោសថបានរៀបចំជាស្រេចនូវសំពត់ថ្មីមួយគូព្រមទាំងប្រាក់ ១.០០០ កហាបណៈ ទុកក្នុងហិបម្លូ[៧៤]។ គ្រានោះ

---

[៧៤] តម្លូលបសិព្វកេ។ ម្លូ (ន.) វល្លិឡើងជន្ទន់ពួកមួយ មានឈ្មោះច្រើនយ៉ាង, ដើមនិងស្លឹកមានរសហាង ក្លិនប្រហើរឆ្ងួលបន្តិចៗ, គេដាំជារបរប្រើស្លឹកជាគ្រឿងផ្សំជាមួយនឹងកំបោរ, ស្លាជាដើម ទំពាបំបាត់ក្លិនមាត់មិនឲ្យធុំ អាក្រក់។

មហោសថទាញសំពត់ថ្មីនោះដាក់ទៅលើដៃរបស់នាងអមរា រួចប្រាប់ថា៖

"នែប្អូនស្រី! ចូរនាងទៅងូតទឹកជាមួយនឹងមិត្តសម្លាញ់ស្រីៗរបស់នាងរួច ហើយស្លៀកសំពត់ថ្មីនេះត្រឡប់មកវិញ"។

នាងអមរាបានធ្វើតាមការណែនាំរបស់មហោសថទាំងអស់។

**មហោសថស្ដីដណ្ដឹងនាងអមរា**

មហោសថបណ្ឌិត បានប្រគល់ទ្រព្យដែលរកបាន និងទ្រព្យខ្លួនដែលមានស្រាប់ ជូនដល់ម្ដាយឪពុករបស់នាងអមរា ដើម្បីសូមស្ដីដណ្ដឹងកូនស្រី ដោយនិយាយឲ្យពួកគាត់ទុកចិត្តនិងកុំឲ្យព្រួយបារម្ភ ហើយបានលាលោកឪពុកក្មេកម្ដាយក្មេក នាំបណ្ដើរនាងអមរាឆ្ពោះទៅកាន់រាជធានី។

ដើម្បីសាកល្បងនាងអមរានៅតាមផ្លូវ មហោសថហុចឆត្រ និងស្បែកជើងទៅឲ្យនាងអមរា ប្រាប់យ៉ាងនេះថា៖

"នែប្អូនស្រី! ចូរនាងដើរបាំងឆត្រ ពាក់ស្បែកជើងនេះចុះ"។

នាងអមរាទទួលយករបស់នោះ តែពុំបានធ្វើតាមយ៉ាងនោះទេ។ កាលនាងដើរនៅទីវាលហាលក្ដៅ នាងមិនបាំងឆត្រទេ តែដល់ក្នុងព្រៃដែលមានម្លប់ឈើ នាងបែរជាបាំងឆត្រទៅវិញ។ នៅលើគោកនាងដើរ

ដោះស្បែកជើង ដល់តែនៅក្នុងទឹក នាងបែរជាដើរពាក់ស្បែកជើងទៅវិញ។ មហោសថ ឃើញការណ៍ចម្លែកបែបនេះ ក៏សួរនាងថា៖

"តើហេតុដូចម្ដេចកាលនៅលើគោក នាងមិនពាក់ស្បែកជើង លុះមកដល់ក្នុងទឹកបែរជាពាក់ស្បែកជើងអ៊ីចឹង? នៅហាលក្ដៅម្ដេចមិនបាំងឆត្រ លុះមកដល់ព្រៃមានម្លប់ឈើ ទើបនាងបាំងឆត្រធ្វើអ្វី?"

នាងអមរាឆ្លើយថា៖

"បពិត្រអ្នកជាស្វាមី នៅកន្លែងគោកនាងខ្ញុំអាចមើលបន្លាជាដើមឃើញ រីឯនៅក្នុងទឹក ខ្ញុំមើលឆ្អឹងត្រីអណ្ដើកនិងបន្លាជាដើមមិនឃើញទេ។ កាលបើវាមុតជើង អាចបណ្ដាលឲ្យឈឺចាប់។ នៅទីវាល ឥតមានបន្លាឈើធ្លាប់ជាដើមទេ ប៉ុន្តែនៅក្នុងព្រៃគង់តែមានកំណាត់ឈើធ្លាប់ជាដើម ជ្រុះលើក្បាលក៏អាចបណ្ដាលឲ្យឈឺចាប់ដែរ។ ដោយហេតុនេះហើយ ទើបនាងខ្ញុំធ្វើយ៉ាងនេះជាប្រយោជន៍ដើម្បីការពារខ្លួន"។

## ផ្លែពុទ្រាក្ដៅនិងត្រជាក់

មហោសថ បានស្ដាប់សម្ដីនាងអមរា អំពីហេតុពីរយ៉ាងនេះហើយ លោកពេញចិត្តនឹងនាងអមរាជាខ្លាំង ក៏បន្តដំណើរទៅមុខទៀត។

ទៅដល់តំបន់មួយ មានដើមពុទ្រាមួយដើម មានមែកត្រឈឹងត្រឈៃ ទាំងមានផ្លែទុំដ៏ច្រើនៗ បន្ទាប់ពីបានឃើញហើយ អ្នកទាំងពីរដើរតម្រង់មកឈប់សម្រាកក្រោមម្លប់ដើមពុទ្រា។ នាងអមរាបានឃើញមហោសថអង្គុយក្បែរគល់ពុទ្រា ក៏បាននិយាយថា៖

"បង! សូមបងឡើងបេះផ្លែពុទ្រាពិសា ហើយទម្លាក់ឲ្យខ្ញុំហូបផង"

មហោសថតបថា៖

"អូន! បងហត់ណាស់មិនអាចឡើងទេ អូនឡើងបេះខ្លួនឯងចុះ"។

ឮពាក្យមហោសថពោលដូច្នោះ នាងអមរាក៏ឡើងដើមពុទ្រាដោយខ្លួនឯង រួចអង្គុយលើប្រគាបមែកបេះផ្លែពុទ្រា។ មហោសថនិយាយនឹងនាងថា៖

"អូន! ទម្លាក់ផ្លែឲ្យបងខ្លះផង"។

នាងអមរាគិតថា "បុរសនេះ ជាបណ្ឌិត ឬមិនមែនហ្ន៎? អញនឹងសាកល្បងមើលម្តងទៀតចុះ" រួចសួរមហោសថថា៖

"បង! តើបងចង់ពិសាផ្លែក្តៅឬផ្លែត្រជាក់?"

មហោសថតបធ្វើដូចជាមិនយល់ការណ៍យ៉ាងនេះថា៖

"បងត្រូវការផ្លែពុទ្រាក្តៅ"។

អមរាបោះផ្លែពុទ្រាជាច្រើនទៅលើផ្ទៃដីខ្សាច់ ទាំងនិយាយថា៖

"អញ្ជើញបងពិសាចុះ"។

មហោសថទៅរើសផ្លែពុទ្រាទាំងនោះ ផ្ទុំហើយបរិភោគ ហើយនិយាយសាកល្បងនាងអមរាវិញយ៉ាងនេះថា៖

"នែអូនអើយ! សូមអូនឲ្យផ្លែត្រជាក់បងម្តងមក"។

គ្រានោះ នាងអមរា បោះផ្លែពុទ្រាទៅលើស្មៅ។ មហោសថទៅរើសផ្លែទាំងនោះហូប គិតសប្បាយក្នុងចិត្តថា "ក្រមុំនេះឆ្លាតម៉្លេះ" ហើយប្រាប់ទៅនាងថា៖

"ប៉ុណ្ណឹងបានហើយ អូនចុះមកវិញមក"។

នាងអមរា ឮមហោសថប្រាប់ដូច្នោះ នាងក៏ចុះមក រួចកាន់ក្អមដើរទៅស្ទឹង ដងទឹកយកមកឲ្យមហោសថទទួលទាន។ មហោសថផឹកទឹក រួចខ្ពុរមាត់ ហើយក្រោកចាកទីនោះធ្វើដំណើរដរាបដល់រាជធានី។

**មហោសថពិសោធចិត្តនាងអមរា**

លំដាប់នោះ មហោសថ ផ្ញើនាងអមរាឲ្យនៅផ្ទះរបស់នាយឆ្មាំទ្វារដើម្បីសាកល្បងចិត្តនាងអមរាបន្ថែមទៀត។ មហោសថ ប្រាប់ប្រពន្ធនាយឆ្មាំទ្វារថា ខ្លួននឹងសាកល្បងនាងអមរា ហើយក៏លាគាត់ធ្វើដំណើរទៅលំនៅឋានរបស់ខ្លួន ហើយឲ្យប្រាក់ ១.០០០ កហាបណៈ ដល់ពួកប្រុសៗ ៤-៥ នាក់ ដោយប្រាប់ថា៖

"ខ្ញុំមកនេះ ដោយបានទុកស្ត្រីម្នាក់នៅឯផ្ទះនាយឆ្មាំទ្វារ ពួកអ្នកចូរយកប្រាក់ ១.០០០ កហាបណៈនេះ ទៅទិញទឹកចិត្តនាងមើល"។

ពួកប្រុសៗ បាននាំគ្នាធ្វើតាមបញ្ជាយ៉ាងនោះមែនៗ នាងអមរាបានបដិសេធយ៉ាងម៉ឺងម៉ាត់ចំពោះប្រុសៗទាំងនោះ ដោយនិយាយថា៖

"ប្រាក់ ១.០០០ កហាបណៈនេះ មានតម្លៃមិនស្មើនឹងធូលីដីដែលជាប់បាទជើងប្តីរបស់នាងខ្ញុំទេ ចូរពួកអ្នកទៅរកស្រីផ្សេងវិញទៅ"។

ពួកប្រុសៗ នាំគ្នាវិលត្រឡប់មកវិញ ជម្រាបមហោសថបណ្ឌិតឲ្យជ្រាបអំពីអាការៈនិងសម្តីរបស់នាងអមរា។ មហោសថបញ្ជូនអ្នកទាំងនោះ ឲ្យទៅសាកល្បងចិត្តនាងរហូតដល់ទៅ ៣ លើក ឯលើកទី ៤ មហោសថ ប្រាប់ពួកប្រុសៗថា៖

"បើដូច្នោះ ចូរពួកអ្នកទៅចាប់នាងយកមកផ្ទះខ្ញុំ"។

បុរសទាំងឡាយបានធ្វើតាមបទបញ្ជា ទៅទាញដៃនាងអមរាចេញពីផ្ទះនាយឆ្មាំទ្វារនាំទៅផ្ទះមហោសថ។ រាត្រីនោះមហោសថបានស្លៀកពាក់ឯកសណ្ឋានឥស្សរជនមានយសសម្បត្តិខ្ពង់ខ្ពស់ នាងអមរាមើលមហោសថមិនស្គាល់ថាជាស្វាមីរបស់នាងទេ គ្រាន់តែក្រឡេកឃើញឥស្សរជននោះភ្លាម នាងសើចផង យំផងៗ ឥស្សរជននោះសួរថា

ហេតុអ្វីបានជានាងសើចផងយំផងដូច្នេះ? គ្រានោះនាងប្រាប់ឥស្សរជននោះថា៖

"លោកប្រុសអើយ ខ្ញុំក្រឡេកឃើញសម្បត្តិរបស់លោកហើយខ្ញុំសើច គឺខ្ញុំសើចដោយគិតថា លោកប្រុសមិនមែនបានសម្បត្តិនេះដោយឥតហេតុទេ គឺបានដោយសារធ្វើកុសលកម្មទុកក្នុងភពមុនពិតប្រាកដណាស់ៗ ឱះឱ! នេះហើយដែលគួរឲ្យសរសើរហៅថាបុណ្យឲ្យផលមានយសសម្បត្តិស្តុកស្តម្ភអ៊ីចឹងទេតើៗ ខ្ញុំសើចដោយសរសើរជួយត្រេកអរលោក ប៉ុន្តែត្រង់ថាខ្ញុំយំ គឺយំដោយមានក្តីអាណិតអាសូរចំពោះលោកប្រុស ដោយគិតថាឥឡូវនេះលោកប្រុសនឹងប្រព្រឹត្តអំពើយង់ឃ្នងខុសចំពោះវត្ថុដែលមានអ្នកដទៃរក្សាគ្រប់គ្រង ហើយលោកប្រុសមុខតែនឹងធ្លាក់ខ្លួន ទៅឋាននរកពុំខានឡើយ"ៗ

### អាពាហ៍ពិពាហ៍មហោសថនិងនាងអមរា

មហោសថសាកល្បងនាងអមរា ដឹងថានាងមានភាពបរិសុទ្ធ ហើយស្មោះនឹងស្វាមីដូច្នេះ លោកបានបញ្ជាពួកទាំងនោះថា៖

"ពួកអ្នក ចូរនាំស្ត្រីនេះទៅទុកនៅកន្លែងដើមវិញទៅ"ៗ

លុះបានបញ្ជាពួកគេឲ្យនាំនាងអមរាទៅវិញដូច្នេះហើយ លោកក៏បានប្ដូរសម្លៀកបំពាក់ក្លែងខ្លួនជាជាងតម្បាញដូចមុនវិញ មកស្នាក់អាស្រ័យ នៅគេហដ្ឋាននាយឆ្មាំទ្វារជាមួយនឹងនាងអមរា។ លុះដល់ព្រឹកឡើង មហោសថបានធ្វើដំណើរទៅកាន់ព្រះបរមរាជវាំង ទូលព្រះនាងឧទុម្ពរទេវី អំពីដំណើរដើមទងរបស់ខ្លួននិងនាងអមរា។ ព្រះនាងឧទុម្ពរទេវី មានសេចក្ដីត្រេកអរជាខ្លាំង ក៏ក្រាបទូលព្រះរាជាឲ្យព្រះអង្គទ្រង់ជ្រាប បន្ទាប់មកព្រះនាងបាននាំនាងអមរា មកតុបតែងខ្លួន ប្រដាប់ដោយគ្រឿងអលង្ការ ហើយរៀបចំយានជំនិះដ៏ប្រណីត ដើម្បីនាំនាងមកកាន់គេហដ្ឋានរបស់មហោសថ ដោយមានក្បួនធ្វើសក្ការៈយ៉ាងធំ រៀបមង្គលការនាងអមរាជាមួយនឹងមហោសថបណ្ឌិត។ ព្រះរាជាបានបញ្ជូនគ្រឿងបណ្ណាការយ៉ាងអ៊ឹកអធិក[៧៥] ដែលមានតម្លៃជាប្រាក់ ១.០០០ កហាបណៈ ទៅជូនលោកបណ្ឌិតមហោសថ។ ប្រជាជនទូទាំងរាជធានីមាននាយឆ្មាំទ្វារជាដើម ក៏បានបញ្ជូនគ្រឿងបណ្ណាការមកជូនមហោសថផងដែរ។ ចំណែកនាងអមរាបានរំលែកបណ្ណាការ ដែលស្ដេចបញ្ជូនមកនោះ ជាពីរចំណែក ហើយបញ្ជូនមួយចំណែកថ្វាយព្រះរាជាវិញ។

[៧៥] អ៊ឹកធឹក ឬអ៊ុកអធិក  អ៊ុក-ក:ធឹក ឬ អ៊ឹក-អ: ធឹក (គុ.) ហ៊ឺកហ៊ាក់, គគ្រឹកគគ្រេង, រុងរឿង (ដោយមានមនុស្សច្រើននិងគ្រឿងតុបតែងដ៏ល្អព្រមទាំងភ្លេងតន្ត្រីផង): បុណ្យអ៊ឹកធឹក, មហោស្រពអ៊ឹកអធឹក (ម.ព. អធិក ផង)។ អ៊ឹកអធឹក

ឯមួយចំណែកទៀត នាងអមរាបានបញ្ជូនដល់ប្រជាជនទូទាំងក្រុង ដើម្បីសង្គ្រោះអ្នកនគរ។ តាំងពីគ្រានោះមក មហោសថបាននៅរួមសុខទុក្ខជាមួយនឹងនាងអមរា ហើយបានធ្វើជាទីប្រឹក្សា ផ្តល់នូវអនុសាសន៍ ដ៏មានហេតុផលត្រឹមត្រូវចំពោះព្រះមហាក្សត្រជរាបតទៅ។

អមរាទេវីបរិយេសនា ចប់។

## សព្វរតនថេនវណ្ណនា

### នាងអមរាវែកមុខជនទុច្ចរិត

**បណ្ឌិតទាំង ៤ ទម្លាក់កំហុសលើមហោសថ**

តមកក្នុងថ្ងៃមួយ សេនកៈពិភាក្សាជាមួយនឹងអាចារ្យទាំង ៣ រូប ដែលមកកាន់សម្នាក់របស់ខ្លួនថា៖

"នែអស់លោក! ពួកយើងមិនអាចតតាំងជាមួយនឹងមហោសថ សោះ ថែមទាំងឥឡូវនេះ គេបានប្រពន្ធឆ្លាតជាងគេទៅទៀត ធ្វើម្ដេចទៅទើបយើងកម្ចាត់មហោសថនោះចេញពីរាជវាំងបាន?[៧៦]"

អាចារ្យ ៣ រូប និយាយថា៖

"បពិត្រអាចារ្យ ពួកយើងធ្វើម៉េចនឹងដឹង ចុះលោកវិញដឹងឬទេ?"

សេនកៈតបថា៖

"មិនអីទេ កុំគិតច្រើនពេក។ ខ្ញុំមានល្បិចកលមួយ។ ខ្ញុំនឹងលួចស្មៀតសក់កែវមណីរបស់ព្រះរាជា។ បុក្កុសៈ អ្នកចូរលួចកម្រងមាស។ កាមិន្ទៈ អ្នកចូរលួចសំពត់កម្ពល។ ទេវិន្ទៈ អ្នកចូរលួចទ្រនាប់ជើងមាស។ កាលបើយើងទាំង ៤ នាក់ លួចរបស់ទាំង

---

[៧៦] កិន្តិ នំ រញ្ញោ អន្តរេ បរិភិន្ទេយ្យាម។

*នោះបានដោយឧបាយយ៉ាងនេះហើយ បន្ទាប់មក យើងកុំទុកក្នុងផ្ទះយើង យើងនឹងបញ្ជូនទៅផ្ទះមហោសថវិញ”។*

*គ្រានោះឯង ពួកគេទាំង ៤ នាក់ បានធ្វើតាមការមត់[៧៧]គ្នា ហើយលួចបានព្រះរាជទ្រព្យទាំង ៤ មុខ។ សេនកៈបានដាក់ស្នៀតសក់កែវមណីក្នុងក្អមទឹកដោះជូរ ឲ្យទៅក្នុងដៃទាសីរបស់ខ្លួនហើយបញ្ជាថា៖*

*“នាងកុំឲ្យក្អមទឹកដោះជូរនេះដល់ដៃអ្នកដទៃណាឲ្យសោះ បើទុកជាគេទិញក៏ដោយ ប៉ុន្តែបើមនុស្សក្នុងផ្ទះមហោសថទិញ នាងចូរឲ្យទាំងក្អមតែម្តងទៅ”។*

*ទាសីនោះដើរទៅទ្វារផ្ទះមហោសថ ដើរទៅដើរមក អំពាវនាវថា៖*

*“ទឹកដោះជូរៗ! សូមលោកអ្នកជួយទិញ”។*

*ចំណែកនាងអមរាទេវី ឈរក្បែរទ្វារផ្ទះឃើញកិរិយារបស់ទាសីរបស់អាចារ្យសេនកៈនោះ គិតថា “នាងនេះម្តេចមិនដើរទៅទីដទៃ រឿងនេះជាក់ជាមានហេតុការណ៍អ្វីមួយហើយ”។ បន្ទាប់មក នាងក៏បក់ដៃឲ្យពួកទាសីរបស់ខ្លួនថយចេញ ហើយហៅទាសីរបស់អាចារ្យសេនកៈដែលដើរទៅមកនោះ ដោយខ្លួនឯងថា៖*

---

[៧៧] **មត់** *(កិ.) បញ្ចេញឲ្យដឹងជាមុនដោយត្រូវគំនិតគ្នា, សន្មតគ្នាដោយប្តេជ្ញាយ៉ាងសម្ងាត់ ឱ. មត់គ្នា, និយាយមត់គ្នា។ ឯការមត់ ជាករណនាម។*

“នៃនាង! មកណេះ! ខ្ញុំនឹងទិញទឹកដោះជូររបស់នាង”។ ពេលនាងនោះដើរមក នាងអមរាបានហៅទាសីរបស់នាង ឲ្យត្រឡប់មកវិញ តែទាសីរបស់នាងមិនព្រម នាងអមរាក៏ប្រើទាសីលក់ទឹកដោះជូរនោះថា៖

“នាងអើយ ចូរនាងជួយទៅហៅពួកទាសីខ្ញុំឲ្យមកបន្តិច”។

កាលដែលទាសីនោះទៅផុត នាងអមរាក៏លូកដៃទៅក្នុងក្អមទឹកដោះជូរ រាវទៅឃើញយល់ដាក់កែវមណី។ ពេលទាសីម្ចាស់ក្អមមកវិញ នាងអមរាសួរថា៖

“នាងជាមនុស្សរបស់នរណា?”

“លោកស្រី នាងខ្ញុំជាទាសីរបស់សេនកបណ្ឌិត” ទាសីឆ្លើយ។ បន្ទាប់មក នាងអមរាសួរឈ្មោះរបស់ទាសីនោះ និងឈ្មោះម្ដាយនាង។ នាងទាសីប្រាប់តាមដំណើរថាខ្លួនឈ្មោះនេះ ម្ដាយខ្លួនឈ្មោះនោះ។

“នៃនាង ចុះទឹកដោះជូរនេះថ្លៃប៉ុន្មាន?” អមរាសួរ ។

“លោកស្រី ថ្លៃ ៤ នាឡិ[៧៨]” ទាសីឆ្លើយ។

បើដូច្នោះចូរលក់ទឹកដោះជូរនេះឲ្យខ្ញុំមក” អមរាថា។

---

[៧៨] អយេ្យ ចតុនាឡិកំ។ នាឡិ ជាឈ្មោះតម្លៃបុរាណមួយស្មើនឹង ១៦ តម៉ឹងផង ជារង្វាល់តូចរបស់បុរាណមួយប្រភេទសម្រាប់វាល់អង្ករ ឬវាល់គ្រាប់អ្វីៗ មានគ្រាប់សណ្ដែកបាយជាដើមផង ឧ.អង្ករមួយនាឡិៗ ក្នុងនេះ តម្លៃ៤នាឡិ = ៦៤ តម៉ឹង។

"លោកស្រី បើលោកស្រីទិញយក នាងខ្ញុំមិនយកថ្លៃអ្វីទេ សូមលោកស្រីទទួលយកទាំងក្អមតែម្តងទៅ"។

"បើអ៊ីចឹង ខ្ញុំអរគុណ! ហើយនាងចូរត្រឡប់ទៅវិញចុះ"

នាងអមរាបញ្ជូនទាសីនោះទៅវិញ ដូច្នេះហើយ នាងក៏យកទឹកដោះជូរទុក ថែមទាំងបានកត់ចុះក្នុងសៀវភៅកំណត់ហេតុ[៧៩] ខ្លួនថា "នៅខែនេះ ថ្ងៃនេះ អាចារ្យសេនកៈ បានបញ្ជូនស្បៀតសក់កែវមណីរបស់ព្រះរាជា តាមទាសីរបស់ខ្លួនឈ្មោះនេះ ម្តាយនាងឈ្មោះនេះ ដើម្បីជាជំនូនភ្ជាប់មេត្រីភាព[៨០]"។ ចំណែកបុក្កុសៈ បានដាក់កម្រងផ្កាមាសក្នុងប្រអប់ផ្កាម្លិះ បិទបាំងដោយផ្កាម្លិះជិតពីលើ ហើយក៏បានបញ្ជូនទៅផ្ទះមហោសថ តាមទំនងរបស់អាចារ្យសេនកៈដូច្នោះដែរ។ ចំណែកឯអាចារ្យកាមិន្ទៈ ដាក់សំពត់កម្ពលក្នុងកញ្ច្រែងបន្លែ យកបន្លែកប់ពីលើបិទបាំងហើយ បានបញ្ជូនទៅគេហដ្ឋានរបស់មហោសថអ៊ីចឹងដែរ។ ចំណែកអាចារ្យទេវិន្ទៈ ដាក់ទ្រនាប់ជើងមាសក្នុងចន្ទោះកណ្តាប់ស្រូវដំណើប[៨១] ហើយបញ្ជូនទៅគេហដ្ឋានរបស់មហោសថដែរ។

---

[៧៩] បណ្ណ លិខិត្វា។

[៨០] បហេនកត្ថាយ។

[៨១] យវកលាបន្តរេ ។

នាងអមរាទទួលយករបស់អស់ទាំងនោះ កត់ខែថ្ងៃឈ្មោះអ្នកយកមក និងឈ្មោះអ្នកបញ្ជូនមក ចុះទុកក្នុងបញ្ជី ហើយបានប្រាប់ដល់មហោសថជាប្ដី រួចយករបស់ទាំងនោះ ទៅរក្សានៅកន្លែងមានសុវត្ថិភាព។

**ព្រះបាទវិទេហៈជឿការញុះញង់**

បណ្ឌិតទាំង ៤ នាក់នោះ នាំគ្នាទៅកាន់ព្រះរាជវាំង ធ្វើជាក្រាបទូលព្រះរាជាថា៖

"បពិត្រព្រះសម្មតិទេព ម្ដេចឡើយព្រះអង្គមិនប្រដាប់ស្នៀតសក់កែវមណី"។

"មិនអីទេ ចាំយើងប្រដាប់" ព្រះរាជាតប។

ព្រះរាជាត្រាស់ដូច្នេះហើយ ទ្រង់ប្រើរាជបុរសឲ្យទៅយកស្នៀតសក់កែវមណីមក។ រាជបុរសទាំងឡាយ រកមើលស្នៀតសក់កែវមណីមិនឃើញ ករបស់ផ្សេងៗទៀតក៏មិនឃើញ ក៏នាំគ្នាទៅទូលព្រះរាជា។ គ្រានោះ បណ្ឌិតទាំង ៤ ទម្លាយការណ៍អាថ៌កំបាំងនោះថា៖

"បពិត្រព្រះសម្មតិទេព គ្រឿងអាភរណៈរបស់ព្រះអង្គ ទូលព្រះបង្គំឃើញនៅឯផ្ទះមហោសថ គេប្រើប្រាស់របស់ទាំងនោះសម្រាប់ខ្លួនគេ។ កូនគហបតីនេះ ពិតជាសត្រូវរបស់ព្រះអង្គហើយ មហារាជ"។

**មហោសថភៀសខ្លួន**

លំដាប់នោះអ្នកសង្កេតការណ៍[៨២]របស់មហោសថ បានធ្វើដំណើរយ៉ាងលឿន ទៅរាយការណ៍អំពីស្ថានភាពនោះដល់មហោសថភ្លាមៗ។ មហោសថ ក៏ធ្វើដំណើរទៅកាន់រាជដំណាក់ក្នុងគោលបំណងក្រាបទូលព្រះមហាក្សត្រ ពីមុខមាត់ជនទុច្ចរិតៗ ឯព្រះរាជា ទ្រង់ពិរោធយ៉ាងខ្លាំង ទើបព្រះអង្គដាក់បញ្ជាមិនអនុញ្ញាតឲ្យមហោសថមានឱកាស មកចូលគាល់ព្រះអង្គឡើយ ដោយទ្រង់ព្រះតម្រិះថា "នរណាដឹងថា នឹងមានអ្វីកើតឡើង? តើមហោសថនឹងធ្វើអ្វីចំពោះយើងទៀត?" មហោសថដឹងថា ព្រះរាជាខ្ញាល់ខ្លាំង ក៏បានវិលត្រឡប់ទៅលំនៅរបស់ខ្លួនវិញ។ ព្រះរាជា ទ្រង់ដាក់ព្រះអាជ្ញាឲ្យរាជបុរសទាំងឡាយ តាមចាប់ខ្លួនមហោសថ។ មហោសថឮអ្នកសង្កេតការណ៍ប្រាប់ថា ទ័ពស្ដេចកំពុងតាមចាប់ខ្លួន លោកក៏បានឲ្យដំណឹងដល់នាងអមរាថា ក្នុងស្ថានការណ៍បែបនេះ លោកចាំបាច់គេចខ្លួនមួយរយៈសិន។ មហោសថ បានស្លៀកពាក់ក្លែង[៨៣]រូប មិនឲ្យជនណាម្នាក់ស្គាល់ឡើយ ហើយធ្វើដំណើរចេញពីរាជធានី ភៀសខ្លួនទៅស្រុកទក្ខិណគ្រាម។ លោកបាន

---

[៨២] អត្តចរកា។

[៨៣] **ក្លែង** (កិ) ធ្វើឲ្យប្លែកចាករូបរាងដើមទៅយករូបរាងថ្មីដើម្បីកុំឲ្យគេស្គាល់ ឬពោលឲ្យខុសចាកសម្ដីដើមទៅពោលសម្ដីថ្មីដើម្បីកុំឲ្យគេដឹង ឧ. ក្លែងរូប, ក្លែងសម្ដី។

រស់នៅទីនោះ ប្រកបរបរជាកូនឈ្នួលរបស់នាយស្មូនឆ្នាំង។ ចំណែក នៅក្នុងក្រុងឯនេះវិញ កើតកោលាហល[៨៤] ពីមាត់មួយទៅមាត់មួយថា "មហោសថបណ្ឌិត រត់បាត់ហើយ"។

## បណ្ឌិតទាំង ៤ ធ្លាក់រណ្ដៅលាមក

បណ្ឌិតទាំង ៤ មានសេនកៈជាដើម ដឹងថាមហោសថរត់បាត់ ខ្លួនជំនុំគ្នាថា "កុំគិតខ្វល់អីទៀត ពួកយើងមិនមែនបណ្ឌិតទេឬអី?" ហើយម្នាក់ៗបញ្ជូនគ្រឿងបណ្ណាការទៅថែចង់នាងអមរាវៀងៗខ្លួន មិនឲ្យគ្នានឹងគ្នាដឹងឡើយ។ នាងអមរាទទួលទុកគ្រឿងបណ្ណាការ ទាំងឡាយដែលអាចារ្យទាំង ៤ នាក់ បញ្ជូនមក ហើយនិយាយណាត់ ឲ្យអាចារ្យទាំង ៤ មកក្នុងថ្ងៃតែមួយ តែពេលខុសគ្នាបន្តិចៗថា មក គេហដ្ឋាននាងនៅពេលនេះ ពេលនោះទៅ។ នាងអមរា បានឲ្យគេជីក រណ្ដៅមួយ ចាក់បំពេញដោយទឹក ព្រមទាំងលាមក បិទបន្ទះក្ដារយន្ត លើផ្ទៃខាងលើនៃរណ្ដៅលាមកនោះ ហើយដាក់កន្ទេលធំៗធ្វើជារបាំង មិនឲ្យមើលឃើញ។ នាងរៀបគ្រប់មធ្យោបាយដើម្បីចាប់ជនទុច្ចរិត។

---

[៨៤] កោលាហល កោឡា-ហល់ បា. (ន.) សេចក្ដីភ្ញាក់ផ្អើល, ជ្រួលជ្រើម : កើតកោលាហល។

លុះដល់វេលារសៀល សេនកៈតែងខ្លួនយ៉ាងស្រស់សង្ហា បរិភោគនូវភោជនមានរសឆ្ងាញ់ផ្សេងៗ ហើយចេញដំណើរទៅកាន់ផ្ទះមហោសថ។ លុះទៅដល់ គាត់បានឈរក្បែរទ្វារផ្ទះ ប្រាប់គេឲ្យទៅជម្រាបនាងអមរាថាខ្លួនបានមកដល់ហើយ។ នាងអមរាឲ្យគេទៅអញ្ជើញអាចារ្យសេនកៈឲ្យចូលមក។ កាលសេនកៈទៅឈរជិត នាងអមរាប្រាប់ថា៖

"លោកប្រុស ឥឡូវនេះ នាងខ្ញុំឋិតនៅក្នុងអំណាចរបស់លោកប្រុសហើយ លោកប្រុសធ្វើដំណើរមកពីឆ្ងាយមានអាការនឿយហត់ខ្លាំងណាស់ សូមអញ្ជើញលោកប្រុសងូតទឹកជម្រះខ្លួនប្រាណសិន មុននឹងចូលសម្រាន្ត"។ សេនកៈ កាលស្ដាប់ពាក្យនាងអមរា ហើយក៏ពោលថា "ល្អហើយ អ៊ីចឹង"។

នាងអមរាចេញទៅយកក្អមទឹក សម្ដែងអាការដូចជាចង់ចាក់ទឹកងូតជូនដល់សេនកៈ ថែមទាំងប្រើពាក្យសម្ដីលួងលោមថា៖

"មកណេះ លោកអាចារ្យ អញ្ជើញឡើងលើបន្ទះក្ដារងូតទឹក"។

ក្នុងពេលសេនកៈឈរលើបន្ទះក្ដារហើយ នាងអមរាចូលទៅក្នុងផ្ទះ ជាន់ចុងក្ដារបំបះទម្លាក់សេនកៈ ឲ្យធ្លាក់ចូលទៅក្នុងរណ្ដៅលាមកបាត់ទៅ។

ចំណែកបុក្កុសបណ្ឌិតវិញ ងូតទឹកវេលាល្ងាច តុបតែងខ្លួនយ៉ាងស្រស់សង្ហាពិសាភោជនរសឆ្ងាញ់ៗជាច្រើនមុខ ហើយទៅផ្ទះរបស់

មហោសថ ឈរក្បែរទ្វារផ្ទះប្រាប់គេឲ្យទៅជម្រាបនាងអមរាថាខ្លួនបាន មកដល់ហើយ។ ស្ត្រីបម្រើម្នាក់ទៅជម្រាបនាងអមរា។ ឮពាក្យស្ត្រី បម្រើប្រាប់ហើយ នាងអមរានិយាយថា៖

"សូមអញ្ជើញចូលមកលោកអាចារ្យ លោកអាចារ្យធ្វើដំណើរ មកពីឆ្ងាយមានអាការនឿយហត់ខ្លាំងណាស់ សូមអញ្ជើញលោក អាចារ្យងូតទឹកជម្រះខ្លួនប្រាណសិន មុននឹងចូលសម្រាន្ត"។

"ល្អណាស់" បុក្កុសៈថា។

នាងអមរាចេញទៅយកក្អមទឹក ធ្វើអាការដូចជាចង់ស្រោចជូន ហើយពោលថា៖

"មកណេះលោកអាចារ្យ អញ្ជើញឡើងលើបន្ទះក្តារងូតទឹក"។

ក្នុងពេលបុក្កុសៈឡើងលើក្តារឈរស្រួលបួលហើយ នាងអមរា ចូលក្នុងផ្ទះទាញហូតបន្ទះក្តារ ធ្វើឲ្យបុក្កុសៈ ទប់ជំហរខ្លួនមិនបាន ដួល ធ្លាក់ចុះទៅក្នុងរណ្តៅលាមកដែរ។ សេនកៈដែលនៅត្រាំអាចម៍ក្នុង ទីនោះមុន ស្រែកសួរថា៖

"អាណាគេ នុ៎ះវ៉ឺ?"

"អញ បុក្កុសៈ ចុះឯងជានរណាដែរ?" បុក្កុសៈសួរវិញ។

"អញ សេនកៈ" សេនកៈឆ្លើយ។

**នាងអមរាចាប់ចោរ ៤ នាក់ ទៅថ្វាយស្តេច**

ពួកគេឈរសួរគ្នាទៅវិញទៅមក។ សូម្បីអាចារ្យពីរនាក់ទៀត គឺអាចារ្យកាមិន្ទៈ និងទេវិន្ទៈ ក៏ត្រូវនាងអមរាបញ្ឆោតឲ្យធ្លាក់ក្នុងរណ្តៅលាមកនោះដែរ។ ពួកគេគ្រប់គ្នា បានឈរត្រាំនៅក្នុងរណ្តៅលាមកដែលគួរឲ្យខ្ពើមអស់មួយរាត្រី។ លុះដល់ព្រឹកឡើង នាងអមរាបានប្រើអ្នកបម្រើឲ្យលើកជនទាំង ៤ នាក់ ឡើងអំពីរណ្តៅ ហើយបង្គាប់ឲ្យកោរត្រងោលជនទាំង ៤ នាក់នោះ ក្រោយពីកោររួច យកអង្ករផ្សែមជាមួយនឹងទឹក បុកជាម្សៅ ដាំជាបបរឲ្យខាប់ មានសាច់ម៉ដ្ឋ ក្បួរហើយលាបស្រលាបពេញខ្លួនប្រាណ តាំងពីក្បាលដល់ចុងជើង ហើយផ្តិតគសក្បុសពាសពេញក្បាល ធ្វើឲ្យពួកគេរងសេចក្តីទុក្ខយ៉ាងខ្លាំង។ រួចដាក់ឲ្យដេកលើកន្ទេលផែងធំៗ[៩៥] មូររុំចងយ៉ាងជាប់ រួចឲ្យគេសែងទៅថ្វាយព្រះមហាក្សត្រ និងធ្វើសេចក្តីរាយការណ៍ទូលថ្វាយព្រះអង្គ។ នាងអមរាក៏បានប្រើគេឲ្យយករតនៈទាំង ៤ រួមជាមួយនឹងជនទាំង ៤ រូបនោះ ធ្វើដំណើរទៅកាន់ព្រះបរមរាជវាំង។ នាងអមរា ថ្វាយបង្គំព្រះរាជា ហើយអង្គុយក្នុងទីដ៏សមគួរ ក្រាបទូលថា៖

---

[៩៥] កន្ទេលផែង គឺកន្ទេលត្បាញដោយបន្ទោះឫស្សី។

"បពិត្រព្រះសម្មតិទេព សូមព្រះអង្គទទួលមហាបណ្ណាការ គឺស្វាសទាំង ៤ ក្បាលរបស់ខ្ញុំម្ចាស់"។

ជាដូច្នេះហើយ នាងក៏ប្រើអ្នកបម្រើឲ្យសែងកន្ទេលផែនទាំង ៤ មកតម្កល់ក្បែរព្រះបាទារបស់ព្រះមហាក្សត្រ។ គ្រានោះ ព្រះអង្គបញ្ជាគេឲ្យបើកកន្ទេល ស្រាប់តែឃើញអាចារ្យទាំង ៤ នាក់ ប្រាកដដូចស្វាស។ មនុស្សទាំងឡាយទាំងពួង ម្នាក់ៗលាន់មាត់ថា៖

"ឃើអើ! មិនធ្លាប់ឃើញសោះ ស្វាសធំៗបែបនេះ"។

ហើយក៏នាំគ្នាសើចយ៉ាងខ្លាំង។ រីឯបណ្ឌិតទាំង ៤ មានសេចក្ដីអាម៉ាស់មុខយ៉ាងខ្លាំង ចំពោះស្ដេច មន្ត្រី និងអាណាប្រជានុរាស្ត្រ។

**នាងអមរាជួយប្ដី**

គ្រានោះ អមរាទេវីក្រាបទូលព្រះរាជា អំពីភាពមិនមានទោសនៃប្ដីរបស់ខ្លួនដូច្នេះថា៖

"ព្រះសម្មតិទេព មហោសថបណ្ឌិតមិនមែនជាចោរទេ។ មនុស្ស ៤ នាក់នេះឯងជាចោរ ក្រាបទូល។ ក្នុងចំណោម ៤ នាក់នេះ សេនកៈជាអ្នកលួចស្នៀតសក់កែវមណី។ បុក្កុសៈជាអ្នកលួចកម្រងផ្កាមាស។ កាមិន្ទៈជាអ្នកលួចសំពត់កម្ពល។ ទេវិន្ទៈជាអ្នកលួចទ្រនាប់ជើងមាស។ ចោរទាំង ៤ នាក់នេះ បានប្រើ

ល្បិចដាក់រតនៈទាំងនេះក្នុងដៃទាសីរបស់ខ្លួនម្នាក់ៗ មានឈ្មោះនេះ ម៉ែនាងឈ្មោះនេះ ហើយបានបញ្ជូនមកផ្ទះខ្ញុំម្ចាស់ នៅខែនេះ ថ្ងៃនេះ សូមទ្រង់ទតនូវសៀវភៅកំណត់ហេតុនេះចុះ ក្រាបទូល ហើយសូមព្រះអង្គ ទទួលរតនវត្ថុរបស់ព្រះអង្គទាំងនេះវិញ និងសូមទទួលចោរទាំង ៤ នាក់នេះផង ក្រាបទូល”។

នាងអមរាធ្វើឲ្យជនទាំង ៤ នាក់ ទទួលនូវភាពអាម៉ាស់យ៉ាងខ្លាំង រួចថ្វាយបង្គំព្រះរាជា លាទៅកាន់គេហដ្ឋានរបស់ខ្លួនវិញ។ ព្រះរាជាហេតុតែសង្ស័យពេញបន្ទុកចំពោះមហោសថផង ដោយយល់ឃើញថា មហោសថរត់បាត់ខ្លួនផង និងហេតុមិនមានបណ្ឌិតដទៃសម្រាប់ប្រឹក្សាផង ដូច្នេះទ្រង់ក៏ពុំមានព្រះរាជឱង្ការចំពោះបណ្ឌិតទាំង៤ រូបនោះឡើយ បានត្រឹមតែត្រាស់ថា “នែពួកបណ្ឌិត! ចូរពួកអ្នកងូតទឹក ជម្រះខ្លួនប្រាណ ហើយត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញចុះ”។

អាចារ្យទាំង ៤ កើតក្តីអាម៉ាស់យ៉ាងខ្លាំង ហើយថ្វាយបង្គំលាព្រះរាជាទៅកាន់គេហដ្ឋានរៀងៗខ្លួន។

សព្វរតនថេនវណ្ណនា ចប់ ។

# ជំពូកទី ៦

## មហោសថដោះប្រស្នាទេវតារក្សាព្រះមហាស្វេតច្ឆត្រ

## ខជ្ជោបនកបញ្ហា

*ប្រស្នាបង្កាត់ភ្លើងដោយអំពិលអំពែក*

### ទេវតាសួរប្រស្នាព្រះរាជា

*ថ្ងៃមួយ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រមួយអង្គ មានការងឿងឆ្ងល់ថា ហេតុអ្វីបានជាពុំឃើញមហោសថសម្ដែងធម៌ទេសនា ដូចសព្វមួយដង។ ដូច្នេះហើយ ទេវតាអង្គនោះ ពិចារណារំពឹងមើលទៅយល់ពីហេតុដែលមហោសថរត់ចាកចេញពីព្រះរាជវាំង ទើបទេវតាគិតថា "អញនឹងប្រើឧបាយ ដើម្បីធ្វើឲ្យព្រះរាជានាំមហោសថមកវិញ"។ លុះវេលារាត្រីឈានចូលមកដល់ ទេវតាអង្គនោះបានតម្ងោះឆត្រឲ្យរបើក[៨៦] ហើយបានចោទសួរប្រស្នា ៤ ខ ចំពោះព្រះរាជា។*

**បញ្ហាទី ១ ៖**

"ហន្តិ ហត្ថេហិ បាទេហិ, មុខញ្ច បរិសុម្ភតិ;
ស វេ រាជ បិយោ ហោតិ, កំ តេន ត្វាភិបស្សសិ"។

---

[៨៦] *ឆត្តបិណ្ឌិកំ វិវរិត្វា។*

“បុគ្គលណា[៨៧] យកដៃទាំងពីរ ជើងទាំងពីរ វាយទាត់ធាក់ដល់បុគ្គលម្នាក់ទៀត បុគ្គលនោះបែរជាទីស្រឡាញ់របស់អ្នកដែលត្រូវបានទទួលការវាយទាត់ធាក់នោះទៅវិញ។ បពិត្រមហារាជ ព្រះអង្គយល់ថាបុគ្គលនោះជានរណា?”

**បញ្ហាទី ២ ៖**

“អក្កោសតិ យថាកាមំ, អាគមញ្ចស្ស ឥច្ឆតិ;
ស វេ រាជ បិយោ ហោតិ, កំ តេន ត្វាភិបស្សសិ”។

“បុគ្គលណាជេរប្រទេចបុគ្គលម្នាក់ទៀតតាមចិត្តចង់ ប៉ុន្តែក្នុងចិត្តនៅតែចង់ឃើញ ចង់ជួបបុគ្គលនោះ ដ្បិតគេជាទីស្រឡាញ់។ បពិត្រមហារាជ ព្រះអង្គយល់ថា បុគ្គលនោះជានរណា?”

**បញ្ហាទី ៣ ៖**

“អព្ភក្ខាតិ អភូតេន, អលិកេនាភិសារយេ;
ស វេ រាជ បិយោ ហោតិ, កំ តេន ត្វាភិបស្សសិ”។

“បុគ្គលណាពោលបង្កាច់បុគ្គលម្នាក់ទៀត ដោយពាក្យមិនពិតមួលបង្កាច់ ប៉ុន្តែបុគ្គលដែលត្រូវគេពោលបង្កាច់នោះបែរជាទីស្រឡាញ់របស់គេទៅវិញ។ បពិត្រមហារាជ តើព្រះអង្គយល់ថា បុគ្គលនោះ

---

[៨៧] ជា.ខុ. ៥៨/២៤០។

ជានរណា?"

**បញ្ហាទី ៤ ៖**

"ហារំ អន្នញ្ច ទានញ្ច, វត្ថសេនាសនានិ ច;
អញ្ញទត្ថុហរា សន្តា, តេ វេ រាជ បិយា ហោន្តិ;
កំ តេន ត្វាភិបស្សសិ"។

"បុគ្គលយកបាយ ទឹក សំពត់ និងសេនាសនៈជាដើម អំពីបុគ្គលម្នាក់ទៀត ប៉ុន្តែអ្នកយកនោះបែរជាទីស្រឡាញ់របស់គេទៅវិញ។ បពិត្រមហារាជ តើព្រះអង្គយល់ថា បុគ្គលនោះជានរណា?"

ព្រះរាជាមិនអាចឆ្លើយតបនឹងសំណួរទាំង ៤ ខ នោះបានឡើយ ព្រះអង្គក៏សូមឱកាសពីទេវតាមួយថ្ងៃថា៖

"ខ្ញុំមិនដឹងទេ ខ្ញុំសូមឱកាសមួយថ្ងៃដើម្បីសួរពួកបណ្ឌិតផ្សេងៗ"

លុះព្រឹកឡើង ព្រះរាជាបញ្ជូនព្រះរាជសារទៅអញ្ជើញបណ្ឌិតទាំង ៤ ឲ្យចូលមកគាល់ព្រះអង្គ។ អាចារ្យទាំង ៤ ឲ្យគេទៅក្រាបទូលព្រះរាជាថា៖

"ពួកទូលបង្គំ មានក្បាលត្រងោល កាលបើដើរតាមមហាវិថីទៅ ពួកទូលបង្គំ សែនខ្មាស់គេណាស់"

ព្រះរាជាបានបញ្ជូនមួក ៤ ទៅឲ្យពួកគេពាក់បិទបាំងក្បាលដើរមកកាន់ព្រះរាជវាំង។

**កំណត់ចំណាំ**

តាមការសន្និដ្ឋានរបស់បុរាណាចារ្យថា មួកដែលមានប្រើក្នុងសម័យសព្វថ្ងៃ គឺបានផ្ដើមកើតឡើងតាំងពីសម័យនោះ រៀងរាបដរាបតមក[៩៨] ដល់បច្ចុប្បន្ននេះ។

ក្រោយពេលពាក់មួកហើយ បណ្ឌិតទាំង ៤ ដើរមករាជវាំងថ្វាយបង្គំព្រះរាជា ហើយបណ្ឌិតទាំង ៤ ក៏នាំគ្នាអង្គុយលើអាសនៈដែលតាំងទុកដូចធម្មតា។ គ្រានោះ ព្រះរាជាត្រាស់ថា៖

"នែសេនកៈ! កាលពីយប់មិញ ទេវតាដែលនៅអាស្រ័យមហាស្វេតច្ឆត្រ បានសួរប្រស្នា ៤ ខ ចំពោះយើង ប៉ុន្តែយើងមិនដឹង ក៏ប្រាប់ថាចាំសួរអស់លោកជាបណ្ឌិតមើលសិន សូមអ្នកជួយដោះប្រស្នាទាំងនោះឲ្យយើងជាបន្ទាន់"។

ហើយព្រះអង្គទ្រង់បានប្រាប់ប្រស្នានោះដូច្នេះថា៖

"បុគ្គលណា[៩៩] យកដៃទាំងពីរផង ជើងទាំងពីរផង វាយទាត់ជាក់ដល់បុគ្គលម្នាក់ទៀត បុគ្គលនោះបែរជាទីស្រឡាញ់របស់អ្នកដែលត្រូវបានទទួលការវាយទាត់ជាក់នោះទៅវិញ។ តើបុគ្គល

---

[៩៨] តទា កិរ តេ នាឡិបដ្ដា ឧប្បន្នា។

[៩៩] ចិ.ខ. ៥៨/២៤០ ។

នោះ ជានរណា?”

សេនកៈមិនដឹងអត្ថន័យប្រស្នា បានត្រឹមតែនិយាយសាំដដែលៗថា៖

“ទាត់ធាក់វាយអ្វី ទាត់ធាក់វាយយ៉ាងម៉េចៗ”។

នឹករកចាប់ខាងដើមក៏មិនយល់ រកចាប់ខាងចុងក៏មិនយល់បន្តិចណាសោះ។ ចំណែកអាចារ្យ ៣ នាក់ផ្សេងទៀត ក៏ទាល់តម្រិះ មិនដឹងនូវចម្លើយថាម៉េចដូចគ្នា។

គ្រានោះ ព្រះរាជាទ្រង់មានវិប្បដិសារៈ[៩០]ជាខ្លាំង។ លុះរាត្រីមួយទៀតចូលមកដល់ ព្រះអង្គត្រូវទេវតាចេញមកសួរម្ដងទៀតថា៖

---

[៩០] វិប្បដិសារៈ វិប-ប៉ៈដិ-សារ៉ៈ បា. ឬ សំ. (ន.) (--សារ ឬ --សារ) សេចក្ដីក្ដៅក្រហាយចិត្ត, សេចក្ដីនឹកស្ដាយក្រោយ, សេចក្ដីនឹកតូចចិត្ត ព្រោះដឹងខ្លួនជាខុស : មានវិប្បដិសារៈ។ ជាទូទៅ យើងនិយាយថា មានវប្បដិសារី។ ជាបែបនេះមិនត្រឹមត្រូវទេ ព្រោះវិប្បដិសារី ជាការកនាម ប្រែថា អ្នកមានវិប្បដិសារ បើយើងនិយាយថា មានវិប្បដិសារី បានសេចក្ដីថា មានអ្នកដែលមានសេចក្ដីក្ដៅក្រហាយចិត្តនៅក្នុងចិត្ត ប៉ុន្តែយើងមិនចង់និយាយអ៊ីចឹង យើងចង់និយាយថា ខ្លួនមានសេចក្ដីក្ដៅក្រហាយក្នុងចិត្ត ដូច្នេះត្រូវប្រើ មានវិប្បដិសារ វិញ ត្រូវលែងប្រើ មានវិប្បសារី។ ពាក្យនេះនឹងប្រើផ្សំជាសមាសបានខ្លះដូច វិប្បដិសារកម្ម អំពើដែលនាំឲ្យមានវិប្បដិសារៈ (អំពើអាក្រក់)។ វិប្បដិសារចិត្ត ចិត្តដែលមានវិប្បដិសារៈ។ វិប្បដិសារភាព ភាពនៃវិប្បដិសារៈ, ដំណើរនឹកស្ដាយក្រោយ ព្រោះដឹងខ្លួនជាខុស ។ល។ វិប្រតិសារៈ

“តើព្រះអង្គដឹងប្រស្នាហើយឬនៅ?”

ព្រះរាជាទ្រង់ប្រាប់ថា៖

“យើងបានសួរបណ្ឌិតទាំង ៤ ហើយ ប៉ុន្តែពួកគេមិនដឹងចម្លើយទេ”។

**ទេវតាគំរាមព្រះរាជាឱ្យរកមហោសថ**

ទេវតាគំរាមព្រះរាជាថា៖

“បណ្ឌិតទាំង ៤ នាក់នោះចេះដឹងអ្វី លើកលែងតែមហោសថ គ្មានអ្នកដទៃណាមួយអាចដោះប្រស្នាទាំងនេះបានទេ ប្រសិនបើព្រះអង្គមិនឲ្យគេហៅមហោសថមកដោះប្រស្នាទាំងនេះទេ យើងនឹងបំបែកព្រះសិរសៈព្រះអង្គ ដោយដំបងដែកភ្លើងនេះ ជាក់ជាពុំខាន”

ហើយទេវតានោះ បាននិយាយពន្យល់ដូច្នេះទៀតថា៖

“បពិត្រមហារាជ កាលបើមានសេចក្ដីត្រូវការភ្លើង, ការដែលយកអំពិលអំពែកមកបង្កាត់មិនគួរទេ។ កាលមានសេចក្ដីត្រូវការទឹកដោះស្រស់, ការដែលរឹតស្នែងគោ ដើម្បីបានទឹកដោះមិនគួរទេ”

*រូបទេវតាបានពោលបន្ថែមក្នុងប្រស្នាអំពិលអំពែកដូច្នេះ*[៩១]*ថា៖*

“កោ នុ សន្តម្ហិ បជ្ជោតេ, អគ្គិបរិយេសនំ ចរំ;
អទ្ទក្ខិ រត្តិ ខជ្ជោតំ, ជាតវេទំ អមញ្ញថ។

“ស្វស្សុ គោមយចុណ្ណានិ, អភិមត្ថំ តិណានិ ច;
វិបរីតាយ សញ្ញាយ, នាសក្ខិ បជ្ជលេតវេ។

“ឯវម្បិ អនុបាយេន, អត្ថំ ន លភតេ មិគោ;
វិសាណតោ គវំ ទោហំ, យត្ថ ខីរំ ន វិន្ទតិ។

“វិវិធេហិ ឧបាយេហិ, អត្ថំ បប្បោន្តិ មាណវា;
និគ្គហេន អមិត្តានំ, មិត្តានំ បគ្គហេន ច។

“សេនាមោក្ខបលាភេន, វល្លភានំ នយេន ច;
ជគតិំ ជគតិបាលា, អាវសន្តិ វសុន្ធរំ”។

*“កាលបើភ្លើងមាន បុរសណាដែលដើរស្វែងរកភ្លើង បានប្រទះនឹងអំពិលអំពែកក្នុងវេលាយប់ហើយ សម្គាល់ថាភ្លើង បុរសនោះបានប្របាច់នូវលម្អិតអាចម៍គោនិងស្មៅជាដើម ឲ្យជាកម្ទេចរោយពីលើអំពិលអំពែកនោះ ហើយលុតជង្គង់បណ្ដើរដៃវែកបណ្ដើរ*

---

[៩១] *បិ.ខ. ៥៩/១៩៦*

ផ្ដុំបណ្ដើរ ក្នុងបំណងបង្កាត់ភ្លើងឲ្យឆេះ ទោះបីខំប្រឹងដោយសញ្ញា វិបរិតក៏ដោយ បុរសនោះមិនអាចញ៉ាំងភ្លើងឲ្យឆេះបានទេ។ គេឈ្មោះថាអន្ធពាល ខ្លៅដូចមនុស្សខ្វាក់ ប្រាកដដូចម្រឹគស្វែង រកខុសទំនងយ៉ាងនេះ មិនបានប្រយោជន៍ទេ។ មួយទៀត បុគ្គល កាលរឹតទឹកដោះមេគោអំពីស្នែងគោ រមែងមិនបានទឹកដោះទេ ពីព្រោះទឹកដោះមិននៅត្រង់ស្នែងទេ ដូចម្ដេចមិញ បុគ្គលអន្ធពាល មិនបានសម្រេចប្រយោជន៍ ដោយឧបាយខុសទំនង ដូចអ្នករឹត ទឹកដោះមេគោត្រង់ស្នែងអ៊ីចឹងឯង។ ជនទាំងឡាយតែងបាននូវ ប្រយោជន៍ ដោយឧបាយទាំងឡាយផ្សេងៗ គឺការផ្ដួញផ្ដាល់ សត្រូវទាំងឡាយផង ការទំនុកបម្រុងផ្គត់ផ្គង់ចំពោះមិត្រទាំង ឡាយផង។ ធម្មតាព្រះរាជាទាំងឡាយ ដែលអាចគ្រប់គ្រង ប្រទេសដ៏សម្បូររុងរឿងឲ្យគង់វង្សបានដោយសារមាន មហាសេនាឆ្នើមក្នុងការគ្រប់គ្រង់ទ័ពផង ដោយសារមានមន្ត្រីល្អ បុរោហិតពូកែៗ ជួយថ្វាយយោបល់ប្រកបដោយគតិបណ្ឌិតផង។ បពិត្រមហារាជ ព្រះអង្គសួរអាចារ្យសេនកៈជាដើម មិនខុសអី អំពីមនុស្សត្រូវការភ្លើង បែរជាទៅផ្ដុំអំពិលអំពែក មិនខុសអី អំពីមនុស្សដែលចោលជញ្ជីង បែរជាយកដៃថ្លឹង និងមិនខុសអី អំពីមនុស្សត្រូវការទឹកដោះ បែរជាទៅរឹតស្នែងគោ។ តើអាចារ្យ

ទាំង ៤ នោះចេះដឹងអ្វីទៅ ដ្បិតថា ពួកគេដូចអំពិលអំពែក ទៅហើយ ឯមហោសថបណ្ឌិតរុងរឿងដោយប្រាជ្ញា អាចប្រៀប ស្មើនឹងគំនរភ្លើង ម្ដេចក៏ព្រះអង្គមិនពឹងមហោសថទៅ។ សូម ព្រះអង្គមានព្រះរាជឱង្ការឲ្យគេទៅអញ្ជើញមហោសថមកសាក សួរចុះ កាលបើព្រះអង្គនៅតែមិនដឹងប្រស្នាទាំងនេះទេ ព្រះអង្គ មុខតែក្ស័យព្រះជន្មពុំខាន"។

ក្រោយពីបានគំរាមព្រះបាទវិទេហរាជដូច្នេះហើយ ទេវតាអង្គនោះ ក៏បំបាំងកាយបាត់ខ្លួនទៅវិញ។

ខជ្ជោបនកបញ្ហា ចប់។

# ត្រូវបញ្ហា

## ស្ដេចស្វែងរកមហោសថឱ្យចូលវាំងវិញ

គ្រានោះ ព្រះរាជាត្រូវមរណភ័យគំរាមហឫទ័យ ដល់ព្រឹកឡើង ហៅមន្ត្រី ៤ នាក់ចូលមកគាល់ ហើយទ្រង់បង្គាប់ឲ្យមន្ត្រី ៤ នាក់នោះ ជិះរទេះមួយម្នាក់ ចេញទៅតាមទ្វារនគរទាំង ៤ ថា បើជួបមហោសថ នៅកន្លែងណា ឲ្យធ្វើសក្ការៈដល់មហោសថនៅកន្លែងនោះ ហើយនាំ គេមកជួបយើងឲ្យឆាប់ៗ ចំណែកមន្ត្រីទាំង ៤ នាក់នោះ ម្នាក់ៗបាន ចេញដំណើរទៅតាមទ្វារក្រុងទាំង ៤ ទិសៗ បណ្ដាមន្ត្រីទាំង ៤ នាក់ នោះ មន្ត្រី ៣ នាក់ ដែលចេញទៅតាមទិសខាងកើត ខាងជើង និង ខាងលិច មិនបានជួបមហោសថទេៗ ចំណែកមន្ត្រីដែលបានចេញ ដំណើរទៅតាមទ្វារក្រុងទិសខាងត្បូង បានឃើញមហោសថនៅស្រុក ទក្ខិណគ្រាម ហើយក៏លបលាក់ខ្លួនចាំឃ្លាំមើលរាល់ទង្វើរបស់ មហោសថៗ ពេលនោះ មហោសថកំពុងដឹកដីស្អិត មកបង្វិលនឹង ម៉ាស៊ីននៅឡឥដ្ឋរបស់នាយស្មូនឆ្នាំង ទាំងនៅមានខ្លួនប្រាណប្រឡាក់ ប្រឡូសដោយដីស្អិតស្រមក ហើយមហោសថ ទៅអង្គុយលើគំនរដីកក់ ហូបបាយដំណើបនឹងម្រាមដៃ លើកចានហុតសម្លដែលមានតិចតួចៗ

**កំណត់សម្គាល់**

*ចុះហេតុអ្វីបានជាមហោសថ ធ្វើការងារនាយស្មូនឆ្នាំងដូច្នេះ? ព្រោះព្រះបាទវេទេហរាជកំពុងតែមានសេចក្តីសង្ស័យពេញបន្ទុកលើមហោសថថា គេនឹងដណ្តើមរាជ្យដោយមិនសង្ស័យ។ ហេតុនេះហើយ បានជាមហោសថធ្វើយ៉ាងនោះ ដោយគិតថា កាលព្រះរាជា ឮថាខ្លួនរស់នៅដោយបវរកស៊ីជាកូនឈ្នួលរបស់នាយស្មូនឆ្នាំង មុខជាទ្រង់អស់ក្តីសង្ស័យមកលើខ្លួនមិនខាន។*

*មហោសថក្រឡេកមើលទៅឃើញមន្ត្រីនោះ ដឹងថាប្រាកដជាគេមករកខ្លួនហើយ គិតក្នុងចិត្តថា "ក្នុងថ្ងៃនេះ យសនឹងកើតប្រាកដដល់អញ អញច្បាស់ជាបានហូបភោជនរសជាតិឆ្ងាញ់ៗ ដែលចម្អិនដោយដៃនាងអមរាភរិយាអញវិញហើយ"។ គិតដូច្នេះ មហោសថចោលដុំបាយដំណើបពីដៃ ក្រោកឡើងខ្ពុរមាត់ ហើយអង្គុយធម្មតា។ ខណៈនោះ មន្ត្រីដែលមកពីវាំងចូលទៅរកមហោសថ ហេតុតែគេជាមនុស្សក្នុងក្រុមរបស់អាចារ្យសេនកៈ គេបាននិយាយចំអកមហោសថថា៖*

*"បពិត្របណ្ឌិត ទ្រឹស្តីរបស់អាចារ្យសេនកៈ ត្រឹមត្រូវណាស់ យកជាការណ៍បាន មានប្រយោជន៍។ ឯប្រាជ្ញាបែបនោះរបស់លោកបណ្ឌិត កាលបើយសសាបសូន្យហើយ មិនអាចធ្វើជា*

ទីពឹងបានទេ? ឥឡូវនេះលោកមានខ្លួនប្រឡាក់ស៊ុទ្ធតែដីស្អិត អង្គុយលើកក់ហូបបាយយ៉ាងនេះ តើសមដែរទេ?"

ហើយបានស្ដីបញ្ឈឺឲ្យមហោសថជាបន្តដូច្នេះថា៖

"បពិត្រអ្នកមានប្រាជ្ញាក្រាស់ដូចផែនដី សម្បត្តិ សេចក្ដីព្យាយាម និងប្រាជ្ញាបែបនោះ មិនរក្សាបុគ្គលដែលធ្លាក់ចុះក្នុងសភាពក្រីក្របានទេ តួយ៉ាងដូចលោកកំពុងបរិភោគបាយដំណើបមានសម្បត្តិចឥឡូវនេះអ៊ីចឹង។ តើយោបល់នេះត្រឹមត្រូវឬទេ?"

គ្រានោះ មហោសថតបចំពោះមន្ត្រីនោះថា៖

"នែអន្ធពាល! ខ្ញុំមានបំណងធ្វើយសនោះឲ្យកើតប្រាកដម្ដងទៀត ដោយកម្លាំងប្រាជ្ញារបស់ខ្លួន ទើបបានជាខ្ញុំសុខចិត្តធ្វើយ៉ាងនេះ"។

ហើយមហោសថពោលបន្តទៀតថា៖

"ខ្ញុំកំពុងធ្វើសេចក្ដីសុខចាស់របស់ខ្ញុំឲ្យរីកចម្រើន ដោយយកសេចក្ដីទុក្ខជាមធ្យោបាយ។ ខ្ញុំពិនិត្យមើលនូវកាលគួរនិងកាលមិនគួរ ហើយសុខចិត្តលាក់ខ្លួនមកធ្វើជាកូនឈ្នួលរបស់នាយស្ទូនឆ្នាំង បើកទ្វារប្រយោជន៍សម្រាប់ខ្លួនឯង ហេតុនេះហើយបានជាខ្ញុំត្រេកអរហូបបាយដំណើប។ មួយទៀតខ្ញុំដឹងនូវកាលគួរ

ហើយធ្វើឲ្យប្រយោជន៍ចម្រើន ដោយប្រាជ្ញារបស់ខ្ញុំ ព្រោះសេចក្ដីព្យាយាមដ៏ខ្លាំងក្លា ដូចសត្វសីហៈក្លៀវក្លាលើមនោសិលា។ ខ្ញុំធ្វើសេចក្ដីព្យាយាមដ៏រឹងប៉ឹងនេះ អ្នកនឹងបានឃើញខ្ញុំមានអំណាចឡើងវិញជាក់ជាមិនខាន"។

គ្រានោះ មន្ត្រីប្រាប់មហោសថថា៖

"បពិត្របណ្ឌិត ទេវតាអាស្រ័យព្រះមហាស្វេតច្ឆត្រ បានសួរប្រស្នាចំពោះព្រះរាជា។ ព្រះរាជាបានសួរបណ្ឌិតទាំង ៤ រូប។ បណ្ដាបណ្ឌិតទាំង ៤ នាក់នោះ គ្មាននរណាម្នាក់អាចឆ្លើយប្រស្នានោះបានសោះ។ ព្រោះហេតុដូច្នោះ ទើបព្រះរាជាបញ្ជូនខ្ញុំឲ្យមកអញ្ជើញលោកឲ្យត្រឡប់ចូលរាជវាំងវិញ"។

មហោសថពណ៌នាអានុភាពនៃប្រាជ្ញាដូច្នេះថា៖

"កាលបើយ៉ាងនេះ ព្រោះហេតុអ្វីបានជាអ្នកមិនឃើញអានុភាពនៃប្រាជ្ញាផង។ ពិតណាស់ ក្នុងកាលៈទេសៈបែបនេះ ឥស្សរិយៈមិនបានជាទីពឹងអ្វីទេ។ បុគ្គលមានប្រាជ្ញា ទើបបានជាទីពឹង"។

ស្ដាប់រួច មន្ត្រីនោះបានតម្កល់ប្រាក់ ១.០០០ កហាបណៈក្នុងដៃរបស់

មហោសថ ដែលជាព្រះរាជអំណោយឲ្យមកធ្វើសក្ការៈដល់មហោសថបណ្ឌិត ក្នុងកន្លែងដែលបានជួបមហោសថ។ នាយស្នូនថ្នាំង ភ័យញ័រខ្លួន ពីព្រោះគាត់ទើបដឹងថា កូនឈ្នួលដែលគាត់ប្រើឲ្យធ្វើការយ៉ាងវក់វីនោះ គឺជាមហោសថបណ្ឌិត ដែលមានកេរ្តិ៍ឈ្មោះល្បីរន្ទឺទូទាំងនគរ។

គ្រានោះ មហោសថលួងលោមគាត់កុំឲ្យភ័យថា៖

"កុំខ្លាចអី លោកនាយស្នូនថ្នាំង! លោកមានឧបការៈដល់ខ្ញុំច្រើនណាស់"

ហើយមហោសថបានជូនប្រាក់ ១.០០០ កហាបណៈដល់នាយស្នូនថ្នាំងនោះ រួចឡើងអង្គុយលើរទេះ ទាំងមានខ្លួនប្រាណប្រឡាក់ដីស្អិតនៅឡើយ ធ្វើដំណើរចូលទៅកាន់ព្រះនគរ។ លុះមកដល់ព្រះរាជវាំង អាមាត្យចូលទៅក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាបពីការនិវត្តន៍របស់មហោសថ។

"តើអ្នកឃើញមហោសថនៅឯណា?" ព្រះរាជាត្រាស់សួរ។

អាមាត្យ ក្រាបទូលថា៖

"បពិត្រព្រះសម្មតិទេព មហោសថបាននៅធ្វើការងារឲ្យនាយស្នូនថ្នាំង រកកម្រៃមកចិញ្ចឹមជីវិត នៅក្នុងស្រុកទក្ខិណគ្រាម។

លោកបណ្ឌិតគ្រាន់តែឮព្រះអង្គត្រាស់ហៅភ្លាម លោកមិនបាន ផ្លូតទឹកទេ លោកមកទាំងខ្លួនប្រាណប្រឡាក់ប្រឡូសដីស្អិត ហ្នឹងឯង"។

ព្រះរាជាគិតថា "ប្រសិនបើមហោសថជាសត្រូវចំពោះអញ ម៉្លេះគេប្រព្រឹត្តអំពើតាមអំណាចឥស្សរិយៈរបស់គេ ប៉ុន្តែមហោសថនេះ មិនមែនជាសត្រូវរបស់អញទេ" ព្រះតម្រិះដូច្នេះហើយទ្រង់ត្រាស់ថា៖

"អ្នកទៅប្រាប់មហោសថឲ្យទៅផ្ទះផ្លូតទឹក តុបតែងខ្លួនហើយ ឲ្យចូលមកគាល់យើង"។

ឮដូច្នោះ មហោសថបណ្ឌិតទៅផ្ទះផ្លូតទឹក រៀបចំខ្លួនប្រាណ ហើយដើរមកកាន់ព្រះរាជវាំង កាលបើព្រះរាជាអនុញ្ញាតឲ្យចូលគាល់ លោកបានចូលទៅថ្វាយបង្គំព្រះរាជា ហើយឈរក្នុងទីដ៏សមគួរ។

**មហោសថផ្តល់អនុសាសន៍ថ្វាយព្រះរាជា**

ព្រះរាជាធ្វើបដិសណ្ឋារៈសួរសោកល្បងមហោសថដូច្នេះថា៖

"បពិត្របណ្ឌិត ជនពួកខ្លះ ជាអ្នកមានសេចក្តីសុខ បរិបូរដោយ ឥស្សរិយៈ ទើបមិនធ្វើនូវសេចក្តីបាប ព្រោះហេតុឥស្សរិយៈ ខ្ពង់ខ្ពស់នោះ ដោយគិតពី សុខនិងឥស្សរិយៈប៉ុណ្ណោះ គ្រប់គ្រាន់

សម្រាប់ពួកគេហើយ។ ជនពួកខ្លះទៀត មិនធ្វើបាប ព្រោះខ្លាចជាប់ពាក់ព័ន្ធនឹងពាក្យតិះដៀលពីអ្នកដទៃ គឺពួកគេខ្លាចក្រែងលោពាក្យតិះដៀលកើតឡើងដល់ពួកគេ កាលណាបើពួកគេបានប្រព្រឹត្តខុសចំពោះចៅហ្វាយ ដែលជាអ្នកផ្តល់នូវយសបែបនេះ។ បុគ្គលខ្លះមិនក្លាហាន បុគ្គលខ្លះខ្សោយប្រាជ្ញា ចំណែកអ្នកវិញជាបុគ្គលក្លាហានផង មានប្រាជ្ញាគិតនូវប្រយោជន៍ដ៏ទូលាយបានផង ហេតុអ្វីក៏អ្នកមិនដណ្តើមរាជ្យពីយើងទៅ?"

គ្រានោះ មហោសថក្រាបទូលព្រះរាជាថា៖

"បពិត្រមហារាជ បណ្ឌិតទាំងឡាយ រមែងមិនប្រព្រឹត្តនូវអំពើដ៏លាមក ព្រោះហេតុនៃសេចក្តីសុខផ្ទាល់ខ្លួនទេ ទោះបីជួបសេចក្តីទុក្ខបៀតបៀន ឬបាត់បង់វិនាសចាកសម្បត្តិ ឋិតនៅក្នុងវិបត្តិយ៉ាងណាក៏ដោយ ក៏មិនលះបង់នូវប្រពៃណីធម៌ គឺសុចរិតធម៌ព្រោះហេតុនៃសេចក្តីស្រឡាញ់ និងសេចក្តីស្អប់ឡើយ"។

ព្រះរាជាធ្វើពុតជាសួរសាកល្បងមហោសថទៀតថា៖

"បុគ្គលគប្បីលើកតម្កើងខ្លួនពីក្រខ្សត់ ឲ្យតាំងនៅក្នុងសម្បត្តិដោយពាក្យសរសើរ ឬដោយពាក្យទន់ភ្លន់ ឬក៏ដោយពាក្យ

ទ្រគោះណាទីមួយ រួចសឹមប្រព្រឹត្តធម៌ដោយប្រពៃក្នុងពេលក្រោយឬ?”

គ្រានោះ មហោសថក្រាបទូលប្រៀបធៀបអំពីឈើចំពោះព្រះរាជាថា៖

“បុគ្គលអង្គុយឬដេកក្នុងម្លប់ឈើណា មិនត្រូវកាច់មែកឈើនោះទេ ព្រោះថាបុគ្គលអ្នកទ្រុស្តមិត្រ ជាមនុស្សអាក្រក់លាមកដ៏ពន់ពេក។ បពិត្រមហារាជ បើទុកជាបំបែកមែកឈើដែលខ្លួនប្រើប្រាស់ហើយក៏ដោយ មនុស្សអ្នកធ្វើនូវអំពើបែបនេះ ឈ្មោះថាទ្រុស្តមិត្ត ដោយពិត។ ព្រះអង្គតែងតាំងឪពុកទូលបង្គំក្នុងឥស្សរិយៈដ៏ខ្ពង់ខ្ពស់ ទាំងទូលបង្គំក៏ព្រះអង្គទ្រង់អនុគ្រោះដ៏ក្រៃលែង។ កាលបើទូលបង្គំជាខ្ញុំប្រព្រឹត្តខុសចំពោះព្រះអង្គ នោះទូលបង្គំប្រាកដជាអ្នកទ្រុស្តមិត្រ”។

លុះបានសម្តែងអំពីភាពមិនទ្រុស្តមិត្ររបស់ខ្លួន ដោយសព្វគ្រប់ហើយ មហោសថយល់គំនិតរបស់ព្រះរាជា រួចលោកជាស់តឿនថា៖

“បពិត្រមហារាជ បុរសបានចេះដឹងនូវធម៌អំពីសម្នាក់អាចារ្យណាម្យ៉ាងទៀត សប្បុរសទាំងឡាយណា បានជួយបំបាត់នូវសេចក្តីសង្ស័យរបស់បុរសនោះបាន ការចេះដឹងនិងការបន្ទោបង់នោះឈ្មោះថា ជាទីពឹងផង ជាទីប្រព្រឹត្តទៅផង របស់បុរសនោះ។

បុគ្គលអ្នកមានប្រាជ្ញា មិនត្រូវញ៉ាំងមេត្តាចិត្តឲ្យសាបសូន្យអំពីអាចារ្យនោះទេ"។

បន្ទាប់មក មហោសថថ្វាយដំបូន្មានព្រះរាជាថា៖

"អលសោ គិហី កាមភោគី ន សាធុ,
អសញ្ញតោ បព្វជិតោ ន សាធុ;
រាជា ន សាធុ អនិសម្មការី,
យោ បណ្ឌិតោ កោធនោ តំ ន សាធុ"។

"និសម្ម ខត្តិយោ កយិរា, នានិសម្ម ទិសម្បតិ;
និសម្មការិនោ រាជ, យសោ កិត្តិ ច វឌ្ឍតិ"។

"គ្រហស្ថអ្នកបរិភោគកាមខ្ជិលច្រអូស មិនល្អ។ បព្វជិតមិនសង្រួម មិនល្អ។ ព្រះរាជាធ្វើការមិនពិចារណា មិនល្អ។ ជនជាបណ្ឌិតមានសេចក្តីក្រោធ មិនល្អ។ បពិត្រព្រះអង្គជាធំក្នុងទិសក្សត្រគប្បីពិចារណាសិនសឹមធ្វើ មិនគប្បីធ្វើដោយមិនបានពិចារណាជាមុនឡើយ។ បពិត្រព្រះរាជា យសបរិវារក្តី កេរ្តិ៍ឈ្មោះក្តី រមែងចម្រើនដល់ព្រះរាជាអ្នកពិចារណាហើយធ្វើយ៉ាងពិតប្រាកដ"។

ភូរិបញ្ហា ចប់។

## ទេវតាចោទប្រស្នា

### មហោសថឆ្លើយប្រស្នាទេវតា

កាលបើមហោសថពោលយ៉ាងនេះហើយ ព្រះរាជាបានអញ្ជើញមហោសថឲ្យឡើងអង្គុយលើរាជបល្ល័ង្ក ខាងក្រោមមហាស្វេតច្ឆត្រដែលបាំងស្រាប់ ព្រះអង្គឯងគង់លើអាសនៈទាបមានព្រះរាជឱង្ការថា៖

“បពិត្របណ្ឌិត ទេវតាអាស្រ័យនៅមហាស្វេតច្ឆត្រនេះ បានសួរប្រស្នា ៤ ខ ចំពោះយើងៗ យើងមិនចេះដោះប្រស្នាទាំងនោះ សូម្បីបណ្ឌិតទាំង ៤ ក៏មិនចេះដែរៗ នែបាជាទីស្រឡាញ់ សូមអ្នកដោះស្រាយប្រស្នាទាំងនោះ តាមបញ្ញារបស់បាផងចុះ”ៗ

មហោសថក្រាបទូលថា៖

“មហាបពិត្រ កុំថាឡើយទេវតាអាស្រ័យនៅនឹងមហាស្វេតច្ឆត្រ កុំថាឡើយស្តេចចតុលោកបាល[៩២] ប្រស្នាណាក៏ដោយ គឺទូល

---

[៩២] ចតុលោកបាល ច:តុលោក:បាល សំ.; បា. (ន.) (ចតុរ៑ + លោកបាល ចតុល្លោកបាល; ចតុ + លោកបាល > ចតុល្លោកបាល) ស្តេចទេវតា ៤ អង្គ ជា ជំនុំចាតុម្មហារាជិកាសួគ៌ ជាអ្នករក្សាលោក គឺព្រះបាទ ធតរដ្ឋ រក្សាទិសខាងកើត, ព្រះបាទវិរុឡ្ហក: រក្សាទិសខាងត្បូង, ព្រះបាទវិរូបក្ខ: រក្សាទិសខាងលិច, ព្រះបាទ កុ

ព្រះបន្ទំជាខ្ញុំអាចដោះស្រាយបានទាំងអស់ សូមព្រះអង្គ ទ្រង់ប្រាប់នូវប្រស្នាដែលទេវតាបានចោទសួរនោះមកចុះ មហារាជ”។

គ្រានោះ ព្រះរាជាទ្រង់ត្រាស់ប្រាប់ប្រស្នាតាមទំនងទេវតាសួរដូច្នេះថា៖

“បុគ្គលណា យកដៃទាំងពីរផង ជើងទាំងពីរផង ទាត់ធាក់ឬវាយមាត់ដល់បុគ្គលម្នាក់ទៀត បុគ្គលនោះបែរជាទីស្រឡាញ់របស់អ្នកដែលត្រូវបានទទួលការវាយទាត់ធាក់នោះទៅវិញ។
តើបុគ្គលនោះ ជានរណា?”

នៅពេលដែលមហោសថស្ដាប់ប្រស្នានោះភ្លាម លោកយល់អត្ថន័យបានយ៉ាងជាក់ច្បាស់ដូចព្រះចន្ទ[៩៣]ពេញវង់នៅឰដ៏នភាល័យ។

---

វេរៈ (វេស្សវ័ណ) រក្សាទិសខាងជើង ។សរសេរតាម សំ. បា. ក៏បាន, ប៉ុន្តែផ្ទុយពីទម្លាប់ប្រើរៀងមក។

[៩៣] តាមទម្លាប់យើងសរសេរ ច័ន្ទ បែបនេះដែលមានសំយោគសញ្ញា, ប៉ុន្តែតាមក្បួនវេយ្យាករណ៍ខ្មែរ ពុំតម្រូវឲ្យប្រើសំយោគសញ្ញា ចំពោះពាក្យដែលព្យញ្ជនៈខាងចុងត្រួតស្រាប់ទេ ឧទាហរណ៍ រាជបល្ល័ង្ក, ថ្ងៃចន្ទ, ខ្ទឹមចន្ទន៍, បណ្ណ, ឆត្រ, សញ្ញាបត្រ វិក្កយបត្រ, សត្វ, ទូរសព្ទ, ដែលសព្ទខាងចុងត្រួត គឺយើងអានឲ្យឮសូរសំយោគស្រេចទៅហើយ មិនចាំបាច់ដាក់សំយោគសញ្ញាទេ លើកលែងពាក្យពីរគឺ ប្រពន្ធ ន័យស្មើកិរិយា, ប្រព័ន្ធ ន័យស្មើដំណើរទាក់ទងគ្នា, យន្ត= ឡាន, យ័ន្ត=កន្ទែងដៃដែលចារបញ្ចុះមន្តអាគម។ ទាល់តែសព្ទខាងចុងឥតត្រួត ទើបយើងប្រើសំយោគ

មហោសថ បានដោះស្រាយប្រស្នាយ៉ាងច្បាស់ ដូចញាំងព្រះអាទិត្យឲ្យរះឡើងនៅពួដ៏កណ្ដាលនភាល័យយ៉ាងនេះថា៖

"មហារាជ! សូមទ្រង់ព្រះសណ្ដាប់ ជាការណ៍ពិតណាស់ កាលណាទារកតូច ដែលដេកលើភ្លៅម្ដាយ វាសប្បាយរីករាយ លេងវាយម្ដាយដោយដៃផង ជើងផង ច្បូតទាញសក់ផង ក្ដាប់ដៃ ទះមាត់ម្ដាយផង។ កាលនោះ ម្ដាយនិយាយនឹងកូនដោយសេចក្ដី ពេញចិត្តនិងស្រឡាញ់ថា "នែអាកូនកំហូច! ម៉េចបានជាកូនវាយ ម៉ែយ៉ាងនេះហ៎ះ?" គាត់ទប់ក្ដីស្រឡាញ់មិនបាន ក៏លើកទារកផ្ដេកលើទ្រូង ថើបជញ្ជក់ញក់ញីនូវមុខរបស់ទារកនោះ"។

ពួដូច្នោះ ទេវតាបើកឆត្រចេញមកឲ្យឃើញពាក់កណ្ដាលខ្លួនជូនពរសព្ទសាធុការ ដោយសំឡេងដ៏ពីរោះថា "ប្រស្នាដែលបណ្ឌិតឆ្លើយ ត្រឹមត្រូវល្អណាស់" ហើយទេវតាបូជាមហោសថដោយរតនៈមួយហិប និងផ្កាទិព្វ គ្រឿងក្រអូប គ្រឿងអប់ ហើយក៏បាត់ខ្លួនទៅវិញ។

---

សញ្ញាបានដើម្បីបង្ខើចស្នូរឲ្យខ្លី ដោយចំពោះ ឃើញច្រើនតែពាក្យក្លាយអំពីបាលីឬសំស្ក្រឹត សក>ស័ក, អធ្យាស្រយ> អធ្យាស្រ័យ, អាលយ>អាល័យ ។ល។

ចំណែកព្រះរាជាបូជាមហោសថបណ្ឌិត ដោយផ្កាជាដើម។ បន្ទាប់មក មហោសថ សូមព្រះអង្គទ្រង់ត្រាស់ប្រស្នាជទៃទៀត។ ព្រះរាជាបានប្រាប់ប្រស្នាទី ២ ជាបន្តថា៖

"បុគ្គលណាជេរប្រទេចបុគ្គលម្នាក់ទៀតតាមចិត្តចង់ ប៉ុន្តែក្នុងចិត្តនៅតែចង់ឃើញ ចង់ជួបបុគ្គលនោះ ដ្បិតគេជាទីស្រឡាញ់។ តើបុគ្គលនោះជានរណា?"

មហោសថដោះស្រាយប្រស្នាទី ២ ថ្វាយព្រះរាជាដូច្នេះថា៖

"បពិត្រមហារាជ កាលកូនអាយុ ៧ ឬ ៨ ឆ្នាំ ល្មមប្រើការបាន ម្តាយក៏ប្រើឲ្យទៅដេញចាបលលកតាមស្រែចម្ការ ឬថាគាត់ប្រើកូនឲ្យទៅផ្សារទិញនេះទិញនោះជាដើម។ កូនទារម្តាយថា លុះតែឲ្យចំណីចំណុកនេះនោះវាស៊ី ទើបវាព្រមទៅ។ ម្តាយក៏ព្រមឲ្យដោយប្រគល់ចំណី តាមដែលកូនសូម។ ក្មេងនោះបានស៊ីចំណីចំណុករួច វាដើរទៅក្រៅលេងជាមួយនឹងក្មេងៗគ្នីគ្នារបស់វាធ្វើព្រងើយ វាមិនទៅតាមពាក្យប្រើរបស់ម្តាយទេ។ ម្តាយឃើញអ៊ីចឹងតឿនឲ្យវាទៅធាប់ ប៉ុន្តែក្មេងនោះនិយាយថា "ម៉ែ! ម៉ែអង្គុយនៅមួប់ក្នុងផ្ទះត្រជាក់ ម្តេចម៉ែប្រើខ្ញុំឲ្យទៅខាងក្រៅ ខ្ញុំបញ្ឆោតម៉ែយកចំណីស៊ីទេតើ"។ ក្មេងនោះ ដើរទៅទាំងធ្វើការញាក់មុខ

ក្រឡេមក្រឡឹមគ្នាដៃវាសដៃចំអកឲ្យម្ដាយ។ ម្ដាយឃើញកូនធ្វើអាកប្បកិរិយាដូច្នោះ គាត់ខឹងខេវ ចាប់ដំបងគំរាមថា "យីវ៉ុ! ឯងស៊ីទំអញហើយ មិនចង់ទៅអ្ហែ" ហើយគាត់ដេញតាមកូនដែលកំពុងរត់យ៉ាងលឿនៗ កាលតាមមិនទាន់ ក៏ស្រែកជេរផ្ដាសាកូន តាមចិត្តចង់ថា "អាចោរគេកាប់" ដូច្នេះជាដើមៗ ទោះបីម្ដាយជេរកូនដោយប្រើពាក្យអ្វីក៏ដោយ ប៉ុន្តែទឹកចិត្តរបស់ម្ដាយគ្រប់រូបមិនចង់ឲ្យកូនជួបគ្រោះកាចបន្ដិចបន្តួចដូចមាត់គាត់ជេរឡើយៗ គាត់នៅតែចង់ឲ្យកូនមកវិញ ចង់ជួបមុខកូនដដែលៗ ក្មេងនោះលេងពេញមួយថ្ងៃ មិនហ៊ានចូលផ្ទះក្នុងពេលល្ងាចសោះ ក៏ដើរគេចទៅផ្ទះរបស់ញាតិណាមួយៗ ចំណែកម្ដាយរបស់គេវិញកាលទន្ទឹងមើលផ្លូវមិនឃើញកូនមក គាត់តែងសោកសៅ ក្ដុក-ក្ដួលក្នុងចិត្ត ទឹកភ្នែកហូររហាមច្រូចច្រាស រកមើលកូនតាមផ្ទះញាតិៗ កាលបើបានឃើញកូនហើយ ក៏ឱបរឹត បីត្រកង ថើបក្បាល ចាប់ដៃកូនទាំងពីរយ៉ាងជាប់ បង្កើននូវក្ដីស្រឡាញ់យ៉ាងខ្លាំង ដោយពោលពាក្យថា "នែកូនសម្លាញ់! កូនឯងនៅតែខឹងនឹងម្ដាយមែនឬ?" បពិត្រមហារាជ នេះឯងដែលហៅថា ពេលម្ដាយខឹង កូននៅតែជាទីស្រឡាញ់យ៉ាងវិសេសវិសាលដដែល"ៗ

ទេវតាបានធ្វើការបូជាដូចមុនៗ ចំណែកព្រះរាជាក៏បានបូជាដូចមុនដែរ ហើយមហោសថសូមឲ្យព្រះរាជាប្រាប់នូវប្រស្នាទី ៣ បន្តទៀតៗ ព្រះអង្គក៏ប្រាប់ប្រស្នាទី ៣ ដូច្នេះថា៖

"បុគ្គលណាពោលបង្កាច់បុគ្គលម្នាក់ទៀត ដោយពាក្យមិនពិតមូលបង្កាច់ ប៉ុន្តែបុគ្គលដែលត្រូវគេពោលបង្កាច់នោះបែរជាទីស្រឡាញ់របស់គេទៅវិញៗ តើបុគ្គលនោះ ជានរណា?"

គ្រានោះ មហោសថឆ្លើយថា៖

"បពិត្រមហារាជ ក្នុងពេលណា ប្ដីប្រពន្ធនៅក្នុងទីស្ងាត់តែពីរនាក់ប្រលែងគ្នាលេងតាមបែបនៃសេចក្ដីស្នេហាក្នុងលោក លេងបង្កាច់គ្នាទៅវិញទៅមក ដោយពាក្យមិនពិត រំលឹកពីរឿងនេះរឿងនោះដោយសម្ដីប៉ប៉ិលប៉ប៉ូច ចោទគ្នាយ៉ាងនេះជាដើមថា "នៃអូន សម្លាញ់! អូនមិនស្រឡាញ់បងទេ អូនបែកចិត្តពីបងទៅមានក្រៅហើយមែនទេ?" ក្នុងពេលនោះ អ្នកទាំងពីរស្រឡាញ់គ្នារឹងរឹតតែខ្លាំងឡើងៗ សូមមហាបពិត្រ ទ្រង់ជ្រាបអត្ថន័យប្រស្នានោះយ៉ាងនេះ ក្រាបទូល"ៗ

ទេវតាបានជូនពរសព្វសាធុការ និងបូជាគ្រឿងបណ្ណាការដូចមុនៗ ចំណែកព្រះរាជា ក៏បានបូជាដូចមុនដែរៗ មហោសថ ក៏ក្រាបទូលសូមឲ្យទ្រង់ប្រាប់នូវប្រស្នាមួយផ្សេងទៀតៗ ព្រះរាជាបានត្រាស់ដូច្នេះថា៖

"បុគ្គលណាមួយទទួលយកបាយ ទឹក សំពត់ និងសេនាសនៈជាដើម អំពីបុគ្គលម្នាក់ទៀត ប៉ុន្តែបុគ្គលអ្នកទទួលយកនោះបែរជាទីស្រឡាញ់របស់ម្ចាស់វត្ថុទៅវិញ។ តើបុគ្គលនោះជានរណា?"

គ្រានោះ មហោសថក្រាបទូលព្រះមហាក្សត្រថា៖

"បពិត្រមហារាជ ប្រស្នានេះសំដៅដល់ពួកសមណព្រាហ្មណ៍ប្រកបដោយធម៌។ ពិតណាស់ ត្រកូលទាំងឡាយណាដែលមានសទ្ធា ជឿថាលោកនេះមាន និងលោកខាងមុខមាន តែងឲ្យទានផង តែងចង់ឲ្យទានផង។ ត្រកូលទាំងនោះ បើទុកណាជាឃើញសមណព្រាហ្មណ៍បែបនោះ ទោះកំពុងបិណ្ឌបាតក៏ដោយ កំពុងឆាន់ក៏ដោយ ក៏បង្កើតនូវក្តីស្រឡាញ់រឹតតែខ្លាំង ចំពោះសមណ-ព្រាហ្មណ៍ទាំងនោះ ក្នុងគំនិតថា "ពួកលោកកំពុងឆាន់បាយនិងទឹក និងប្រើប្រាស់ទេយ្យទានជាដើម ដែលយើងបានប្រគេនផ្ទាល់"។ បពិត្រមហារាជ នេះឯងហើយដែលហៅថា ពួកអ្នកនាំយកទៅ គឺសំដៅដល់ស្មូមសប្បុរស មានអាជីពជាអ្នកសូមតែម្យ៉ាងផង នាំយកទៅនូវរបស់ដែលបានផង ហើយនៅតែជាទីស្រឡាញ់របស់ត្រកូលទាំងឡាយដែលមានសទ្ធា"។

## មហោសថទទួលតំណែងជាសេនាប្រមុខ

គ្រាន់តែមហោសថឆ្លើយចប់ ទេវតាបូជា និងឲ្យពរសព្ទសាធុការ ហើយដាក់ជូននូវរតនៈ ៧ ប្រការមួយហិប[៩៤] ក្បែរបាទជើងរបស់មហោសថ រួចនិយាយថា៖

"បពិត្រមហាបណ្ឌិត សូមអញ្ជើញទទួលយកសក្ការៈនេះចុះ"។

រីឯព្រះរាជា ទ្រង់ក៏ធ្វើការបូជាចំពោះមហោសថនូវគ្រឿងសក្ការៈដ៏ច្រើនថែមទៀត ដោយហេតុតែព្រះអង្គជ្រះថ្លាយ៉ាងក្រៃលែង ទ្រង់ក៏ប្រទានឋានៈ(តំណែង)[៩៥]ជាសេនាបតី ដល់មហោសថនៅពេលនោះតែម្តង។ តាំងពីគ្រានោះមក មហោសថ មានយសសក្តិកាន់តែខ្ពង់ខ្ពស់គួរឲ្យកោតសរសើរ។

---

[៩៤] សត្តរតនបូរំ រតនចង្កោជកំ។

[៩៥] តំណែង = មុខងារ, ឋានៈ, យសសក្តិដែលតែងតាំង។ អ្នកខ្លះសរសេរ ដំណែង នេះមិនត្រឹមត្រូវតាមក្បួនទេ ពីព្រោះពាក្យដើមគឺ តែង ដែលផ្តុំឡើងពីព្យញ្ជនៈ ត, កាលណាពាក្យដើមផ្តុំឡើងពីព្យញ្ជនៈតឬថ ដល់មកកម្លាយត្រូវសរសេរ ត ដូច តែង>តំណែង, ថ្លៃ>តម្លៃ, ត>តំណ, ថ្វា>តម្វា, តិះ>តំណិះ, តក់ >តំណក់, តូច> តំណូច, ថ្កល់>តម្កល់, ថ្កើង>តម្កើង។ គួរប្រយត្នប្រើពាក្យ តំណក់និងដំណក់ ន័យខុសគ្នា តំណក់ គឺការស្រក់របស់ទឹកធ្លាក់ចុះមួយតក់ៗ, ដំណក់ គឺទឹកដែលដក់ជាប់នៅកន្លែងណាមួយរួចស្រេចទៅហើយ។

# ជំពូកទី ៧

## ផ្ចាញ់សត្រូវដោយមេត្តាធម៌

## បញ្ចូបណ្ឌិតបញ្ហា

### បណ្ឌិតទាំង ៤ សួរប្រស្នាអាថ៌កំបាំង

បណ្ឌិតទាំង ៤ នាក់ បានពិភាក្សាគ្នាថា៖

"នែអស់លោកទាំងឡាយ! មហោសថកូនគហបតី កាន់តែឡើងឋានៈធំហើយៗ ឥឡូវនេះ តើយើងគួរធ្វើដូចម្ដេច?"

គ្រានោះ សេនកៈបញ្ចេញយោបល់ប្រាប់អាចារ្យទាំង ៣ ថា៖

"មិនជាអ្វីទេ ខ្ញុំមានឧបាយមួយ ពួកយើងនាំគ្នាចូលទៅរកមហោសថកូនគហបតី ក្លែងធ្វើជាសួរថា អាថ៌កំបាំងផ្ទាល់ខ្លួនរបស់យើងម្នាក់ៗគួរប្រាប់ដល់នរណា។ គេនឹងនិយាយថា មិនត្រូវប្រាប់ដល់នរណាទេ។ កាលយ៉ាងនេះ ពួកយើងប្រាកដជាបានលេស បង្កាច់បង្ខូចកេរ្តិ៍ឈ្មោះមហោសថ ចំពោះព្រះកក្ត្រ របស់ព្រះរាជាថា មហោសថក្លាយជាសត្រូវព្រះអង្គហើយ"។

បណ្ឌិតទាំង ៤ នាក់នោះ ពិភាក្សាស្រុះស្រួលគ្នាហើយ ក៏ធ្វើដំណើរទៅកាន់ផ្ទះរបស់មហោសថ ធ្វើបដិសណ្ឋារៈនិយាយថា៖

"បពិត្របណ្ឌិត ពួកយើងមកនេះប៉ងសួរប្រស្នាមួយ"។# មហោសថក៏តបថា "អញ្ជើញសួរមកចុះ"។

សេនកៈសួរថា៖

"បពិត្របណ្ឌិត ដែលហៅថាបុរស តើគួរតាំងខ្លួនក្នុងធម៌អ្វី?"

"គួរតាំងខ្លួនក្នុងសច្ចធម៌" មហោសថឆ្លើយ។

"តាំងខ្លួនក្នុងសច្ចធម៌ ត្រូវញុំាងអ្វីឲ្យកើតឡើង?" សេនកៈសួរ។

"គប្បីញុំាងទ្រព្យឲ្យកើតឡើង" មហោសថឆ្លើយ។

"ញុំាងទ្រព្យឲ្យកើតឡើងហើយ ត្រូវធ្វើដូចម្ដេច?" សេនកៈសួរ។

"ត្រូវរៀនយកចំណេះវិជ្ជា[៩៦]" មហោសថឆ្លើយ។

"លុះរៀនយកចំណេះវិជ្ជាហើយ តើត្រូវធ្វើអ្វី?" សេនកៈសួរ។

"មិនត្រូវប្រាប់អាថ៌កំបាំងខ្លួនដល់អ្នកដទៃ" មហោសថឆ្លើយ។

"ប្រពៃណាស់ លោកបណ្ឌិត" បណ្ឌិតទាំង ៤ នាក់ពោល។

## បណ្ឌិតទាំង ៤ ញុះញង់ព្រះរាជា

លុះសន្ទនារួច ពួកគេមានចិត្តក្រេកអរ លាមហោសថទៅកាន់សម្នាក់របស់ព្រះរាជា ក្នុបំណងថា "ពួកយើងគង់តែនឹងឃើញទោស

[៩៦] មន្ត្រា គហេតញ្ញេ។

កំហុសរបស់មហោសថ ដែលត្រូវស្ដេចដេញចេញអំពីរាជវាំងពុំខាន"។
លុះទៅដល់ព្រះរាជវាំង សេនកៈក្រាបទូលព្រះរាជាថា៖

"បពិត្រមហារាជ មហោសថក្លាយជាសត្រូវព្រះអង្គហើយ"។

ព្រះរាជាត្រាស់ថា៖

"យើងមិនជឿពាក្យអស់លោកទេ។ មហោសថនោះ មិនមែនជាសត្រូវយើងទេ"។

ពួកអាចារ្យក្រាបទូលថា៖

"ពិតណាស់មហារាជ! សូមព្រះអង្គទ្រង់ជឿចុះ បើទ្រង់មិនជឿ សូមព្រះអង្គទ្រង់សួរគេមើលថា តើអាថ៌កំបាំងរបស់ខ្លួន គួរប្រាប់ដល់នរណា។ បើគេមិនមែនជាសត្រូវ គេនឹងនិយាយថាគួរប្រាប់ដល់អ្នកនេះ ដល់អ្នកនោះ។ តែបើគេជាសត្រូវមែននោះ គេនឹងនិយាយថា មិនគួរប្រាប់ដល់នរណា គួរលាក់ទុកតែក្នុងចិត្តខ្លួនឯង។ ពេលនោះ ព្រះអង្គមុខតែនឹងជឿពាក្យរបស់ពួកទូលបង្គំ ហើយលែងមានសេចក្ដីសង្ស័យទៀត"។

"ល្អ ចាំយើងពិសោធមើល" ព្រះរាជាយល់ព្រម។

ក្នុងថ្ងៃមួយ កាលបើបណ្ឌិតទាំងអស់មកជួបជុំគ្នា ព្រះរាជាទ្រង់បានត្រាស់សួរប្រស្នាជាមុនថា៖

"អ្នកប្រាជ្ញទាំង ៥ នាក់មកជួបជុំគ្នាហើយ យើងមានចម្ងល់នូវប្រស្នាមួយ អ្នកទាំងឡាយចូរស្ដាប់ប្រស្នានោះៗ តើអ្នកផងគួរប្រាប់សេចក្ដីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាការណ៍អាថ៌កំបាំងដល់នរណា?"

កាលបើព្រះរាជាទ្រង់ត្រាស់យ៉ាងនេះ សេនកៈគិតថា "អញនឹងបញ្ចុះបញ្ចូលព្រះមហាក្សត្រឲ្យនៅក្នុងចំណោមពួកអញដែរ" ហើយក្រាបទូលព្រះរាជាថា៖

"បពិត្រព្រះភូមិបាល សូមព្រះអង្គទ្រង់ពិសោធឲ្យជាក់ច្បាស់ដល់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ព្រះអង្គជាអ្នកចិញ្ចឹម ជាម្ចាស់របស់ពួកទូលបង្គំផង ជាអ្នកអត់ធន់ចំពោះរាជកិច្ចដ៏ធ្ងន់ ដែលកើតឡើងហើយផង សូមព្រះអង្គទ្រង់ត្រាស់នូវប្រស្នាទុំះមុនៗ បពិត្រព្រះជនិន្ទដ៏មានអំណាចលើដែនដី អ្នកប្រាជ្ញទាំង ៥ នាក់នេះពិចារណានូវបំណងនិងរបស់ជាទីស្រឡាញ់ និងជាទីគាប់ព្រះទ័យរបស់ព្រះអង្គហើយ នឹងក្រាបទូលក្នុងកាលជាខាងក្រោយ"ៗ

គ្រានោះ ព្រះរាជាទ្រង់ត្រាស់ពាក្យទាក់ទងនឹងការលុះក្នុងអំណាចកិលេសរបស់ខ្លួនដូច្នេះថា៖

"ភរិយាណាមានសីលពិត ដែលបុរសដទៃល្មួចសម្លឹងមិនបានជាស្រីប្រព្រឹត្តតាមអំណាចនៃសេចក្ដីប្រាថ្នារបស់ព្រះភស្ដា ជាទី

ស្រឡាញ់ជាទីពេញចិត្តនៃព្រះភស្ដា តើបុគ្គលគួរប្រាប់អាថ៌កំបាំង ដែលគួរនិន្ទាឬគួរសរសើរ ដល់ភរិយានោះបានឬទេ?"

លំដាប់នោះ សេនកៈត្រេកអរណាស់ដោយគាត់គិតថា "ឥឡូវនេះ យើងបញ្ចុះបញ្ចូលព្រះរាជាបានចូលក្នុងចំណោមពួកយើងហើយ"។ កាលនឹងបំភ្លឺហេតុការណ៍ដែលជាកលឧបាយរបស់ខ្លួនឯងនោះ សេនកៈក៏បានពោលដូច្នេះថា៖

"សម្លាញ់ណាជាទីស្រឡាញ់ ជាទីរលឹក ជាទីស្និទ្ធស្នាល និងជាទីពឹងអាចទុកចិត្តបាន បុគ្គលអាចប្រាប់អាថ៌កំបាំងដែលគួរនិន្ទាឬគួរសរសើរដល់សម្លាញ់នោះបាន"។

បន្ទាប់មក ព្រះរាជាទ្រង់សួរបុក្កុសៈថា៖

"លោកបុក្កុសៈ តើលោកមានយោបល់ដូចម្ដេច សេចក្ដីគួរនិន្ទាឬគួរសរសើរដែលជាអាថ៌កំបាំង គប្បីប្រាប់ដល់នរណា?"

បុក្កុសៈ បានក្រាបទូលស្ដេចដូច្នេះថា៖

"បងប្អូនណាក៏ដោយ ទោះបីជាបងប្អូនស្រីក្ដី កណ្ដាលក្ដី ជាប្អូនពៅក្ដី បើបងប្អូននោះតម្កល់នៅស៊ប់ក្នុងសីល មានចិត្តនឹងនួន បុគ្គលគួរប្រាប់អាថ៌កំបាំងដែលគួរនិន្ទាឬគួរសរសើរដល់បងប្អូននោះបាន"។

បន្ទាប់មក ព្រះរាជាសួរកាមិន្ទៈថា៖

"នៃកាមិន្ទះ! តើលោកមានយោបល់ដូចម្តេច អាថ៌កំបាំងត្រូវប្រាប់ដល់នរណា?"

កាមិន្ទះ បានក្រាបទូលស្តេចដូច្នេះថា៖

"កូនប្រុសណា ជាអ្នកគោរពធ្វើតាមពាក្យប្រើរបស់ឪពុក លុះនៅក្នុងអំណាចនៃចិត្តរបស់ឪពុក និងចេះអត់ធន់ចំពោះដំបូន្មាន ជាអនុជាតបុត្រ[៩៧] គឺកូនដែលចេះរក្សាប្រពៃណីរបស់ត្រកូលឲ្យគង់វង្ស មានប្រាជ្ញាមិនអន់ជាងឪពុក ឪពុកគួរប្រាប់អាថ៌កំបាំងដែល គួរនិន្ទាឬគួរសរសើរ ដល់កូនប្រុសនោះបាន"។

បន្ទាប់មក ព្រះរាជាសួរទេវិន្ទះថា៖

"ម្នាលទេវិន្ទះ! តើលោកមានយោបល់ដូចម្តេច អាថ៌កំបាំងត្រូវប្រាប់ដល់នរណា?"

ទេវិន្ទះបានទូលព្រះរាជា តាមទំនងដែលខ្លួនរៀបរួចហើយដូច្នេះថា៖

"បពិត្រព្រះអង្គជាធំជាងជនដ៏ប្រសើរជាងមនុស្ស ម្តាយណាដែលចិញ្ចឹមកូនដោយសេចក្តីស្រឡាញ់ពេញចិត្ត បុគ្គលគួរប្រាប់អាថ៌កំបាំងដែលគួរនិន្ទាឬគួរសរសើរដល់ម្តាយនោះបាន"។

---

[៩៧] កូនមាន៣ គឺ **អតិជាតបុត្រ** កូនញុំាងយសដែលមិនមានឲ្យកើតឡើងបាន១ **អនុជាតបុត្រ** កូនអ្នករក្សាប្រពៃណីត្រកូលឲ្យគង់វង្ស១, **អវជាតបុត្រ** កូនទម្លន់ត្រកូល ឬកូននាំទុក្ខទោសដល់ត្រកូល១ ។

លុះសួរអាចារ្យទាំង ៤ នាក់យ៉ាងនេះហើយ ព្រះរាជាសួរមហោសថបណ្ឌិតម្តងថា៖

"លោកមានយោបល់ដូចម្តេចដែរ បណ្ឌិត! សេចក្តីអាថ៌កំបាំងត្រូវប្រាប់ដល់នរណា?"

មហោសថក្រាបទូល៖

"បពិត្រមហារាជ ដរាបណាសេចក្តីប្រាថ្នារបស់ខ្លួនមិនទាន់បានសម្រេច បុគ្គលអ្នកឆ្លាតគប្បីអត់សង្កត់ចិត្ត កុំអាលប្រាប់ដល់នរណាមួយដរាបនោះ"

និយាយដូច្នេះហើយ មហោសថពោលបញ្ជាក់ថា៖

"សេចក្តីពិតថា ការលាក់នូវអាថ៌កំបាំងជាការប្រពៃ។ ការប្រាប់នូវអាថ៌កំបាំង គេមិនសរសើរទេ។ អ្នកប្រាជ្ញ កាលបើសេចក្តីប្រាថ្នាមិនទាន់បានសម្រេចនៅឡើយ ត្រូវអត់សង្កត់ចិត្តទុកសិនមិនត្រូវប្រាប់ដល់នរណាម្នាក់ឡើយ លុះប្រយោជន៍បានសម្រេចហើយ ទើបគួរនិយាយតាមសេចក្តីសប្បាយចុះ"។

កាលបើមហោសថពោលយ៉ាងនេះ ព្រះរាជាមានព្រះទ័យពុំរីករាយទាល់តែសោះ។ សេនកៈអើតមើលព្រះភក្ត្រព្រះរាជា ព្រះរាជាក៏មើលទៅមុខរបស់សេនកៈវិញ។ មហោសថ គ្រាន់តែឃើញកិរិយារបស់ពួកគេដូច្នោះ ទើបដឹងថា "ជន ៤ នាក់នេះ បម្រុងកម្ចាត់កម្ចាយ

អញ កុំឲ្យនៅក្បែរព្រះមហាក្សត្រ អ៊ីចឹងតើបានជាពីថ្ងៃមុនពួកគេសួរប្រស្នា ដើម្បីពិសោធមតិរបស់អញ"។ កាលបើបណ្ឌិតទាំងនោះ កំពុងដោះស្រាយប្រស្នាតាមយោបល់រៀងៗខ្លួនដូច្នេះ ព្រះសូរិយាអស្ដង្គតប្រទីបទាំងឡាយបានភ្លឺឡើង។ មហោសថបណ្ឌិតគិតថា "ជាធម្មតាអំណាចរបស់ស្ដេចខ្លាំងក្លាណាស់ មិនអាចដឹងបានថានឹងមានរឿងអ្វីកើតឡើងទេ អញគួរតែចេញទៅជាប្រញាប់" ដូច្នេះ មហោសថ ក៏ថ្វាយបង្គំលាព្រះរាជាចេញទៅ។ មហោសថ ដើរបណ្ដើរគិតបណ្ដើរថា "បណ្ដាបណ្ឌិតទាំង ៤ នាក់ ម្នាក់និយាយថា គួរប្រាប់ដល់សម្លាញ់ ម្នាក់គួរប្រាប់ដល់បងប្អូន ម្នាក់និយាយថា គួរប្រាប់ដល់កូនប្រុស ម្នាក់ទៀតនិយាយថា គួរប្រាប់ដល់ម្ដាយ។ ពួកនេះប្រាកដជាបានរៀបចំផែនការទុំរួចស្រេចហើយ។ អញស្មានថា ពួកគេចេះបញ្ចេញយោបល់ទាន់សភាពការណ៍ភ្លាមៗ ប៉ុន្តែមិនថ្វីទេ អញនឹងស្វែងយល់អំពីបញ្ហាទុំនេះឲ្យជាក់ប្រាកដក្នុងថ្ងៃនេះ"។

**មហោសថរកឃើញរឿងអាថ៌កំបាំងរបស់បណ្ឌិតទាំង ៤**

បន្ទាប់ពីបានក្រាបទូលប្រស្នាថ្វាយព្រះរាជា តាមយោបល់រៀងៗខ្លួនរួចហើយ បណ្ឌិតទាំង ៤ នាក់ បានចេញពីព្រះរាជវាំងពីរបីថ្ងៃ[៩៨]

[៩៨] អញ្ញេសុ ទិវសេសុ។

ដើម្បីពិភាក្សានូវករណីយកិច្ចនៅតុអាហារ[៩៩]មួយ។ មហោសថដឹងពីទីកន្លែងដែលអាចារ្យទាំង ៤ នាក់ពិភាក្សាគ្នា រួចក៏គិតថា "អញគួរតែទៅដេកនៅខាងក្រោមតុ នឹងបានដឹងនូវអាថ៌កំបាំងរបស់អាចារ្យទាំង ៤ នាក់នុ៎ះ"។ គិតដូច្នេះ លោកក៏បានលាក់ខ្លួននៅក្រោមតុអាហារ រង់ចាំស្ដាប់ការពិភាក្សារឿងអាថ៌កំបាំងរបស់អាចារ្យទាំង ៤ នោះ។ ចំណែកឯសេនកៈ បានចូលទៅក្រាបទូលបំភ័យព្រះរាជាថា៖

"បពិត្រមហារាជ បើព្រះអង្គមិនជឿពាក្យរបស់ទូលបង្គំ តើព្រះអង្គគួរធ្វើដូចម្ដេច?"

ព្រះរាជាក៏ស្លុងចិត្តជឿពាក្យរបស់សេនកៈ ទ្រង់ពុំបានពិចារណាឲ្យគ្រប់ជ្រុងជ្រោយឬសង្កេតឲ្យបានល្អិតល្អន់សោះ គិតតែពីភ័យខ្លាចតក់ស្លុត។ ព្រះរាជាក៏សួរសេនកៈថា៖

"ដូច្នេះ តើយើងគួរធ្វើយ៉ាងណា?"

សេនកៈថ្វាយយោបល់ថា៖

"បពិត្រមហារាជ កុំបន្ទន់អល់អែករារែកចិត្តយូរឡើយ។ គួរតែសម្លាប់មហោសថកូនគហបតីនោះចោលទៅ ប៉ុន្តែត្រូវរកឧបាយធ្វើយ៉ាងណាកុំឲ្យនរណាម្នាក់ដឹងឲ្យសោះ"។

---

[៩៩] កត្តអម្ពណស្សរ។

"ម្នាលសេនកៈ លើកលែងតែលោកម្នាក់ចេញ គ្មាននរណាប្រាថ្នាប្រយោជន៍សម្រាប់យើងទេ។ ចូរអ្នកបបួលមិត្រពេះដូងស្មោះ[100] និងអ្នកជិតស្និទ្ធបំផុត ទៅឈរចាំនៅត្រង់ខ្លោងទ្វាររាជវាំង។ មហោសថកូនគហបតីចូលមកគាល់យើងក្នុងកាលណា ចូរលោកកាត់ក្បាលមហោសថដោយព្រះខាន់នេះចុះ" ព្រះរាជាត្រាស់។

ប្រាប់ដូច្នេះហើយ ទ្រង់បានប្រទានព្រះខាន់កែវរបស់ព្រះអង្គផ្ទាល់ដល់អាចារ្យសេនកៈ។ សេនកៈធានាថា៖

"ព្រះករុណាថ្លៃវិសេស សូមព្រះអង្គទុកហឫទ័យលើទូលបង្គំចុះ ទូលបង្គំនឹងសម្លាប់មហោសថនោះឲ្យខាងតែបាន"។

សេនកៈនិយាយធានាដូច្នេះហើយ ក៏ក្រាបបង្គំលាព្រះរាជា។ សេនកៈ មានសេចក្តីរីករាយជាខ្លាំងបន្ទាប់ពីបានទទួលព្រះខាន់កែវពីព្រះរាជា ក៏បាននាំអាចារ្យ ៣ នាក់ទៀត ទៅពិភាក្សានៅឯតុអាហារដែលមហោសថពួននៅខាងក្រោមនោះ។ សេនកៈបង្ហើបប្រាប់មិត្រទាំង ៣ នាក់ថា៖

"ពួកយើងបានឱកាសសម្លាប់បច្ចាមិត្រហើយ។ នែវ៉ឺយកនយើង! នរណា ហ៊ានសម្លាប់មហោសថកូនគហបតី?"

---

[100] អត្តនោ សុហទេ គហេត្វា។

អាចារ្យ ៣ នាក់ និយាយក្នុងន័យប្រគល់ការៈជូនសេនកៈវិញថា៖

“បពិត្រអាចារ្យ មានតែលោកទេ ទើបមានសមត្ថភាពអាចសម្លាប់មហោសថបាន”។

**រឿងអាថ៌កំបាំងរបស់សេនកៈ**

បន្ទាប់មក សេនកៈសួរអាចារ្យជាគូកនថា៖

“ពួកអ្នក ម្នាក់ៗបានទូលថ្វាយព្រះរាជាហើយថា រឿងអាថ៌កំបាំងត្រូវប្រាប់ដល់អ្នកនេះដល់អ្នកនោះៗ តើរឿងនោះ ពួកលោកបានធ្វើហើយមែនទេ? ឬគ្រាន់តែបានឃើញ? ឬក៏បានត្រឹមតែឮ?”

“ពួកខ្ញុំបានធ្វើរួចហើយ លោកអាចារ្យ” អាចារ្យទាំង ៣ ឆ្លើយរួចពួកគេ សួរទៅសេនកៈវិញភ្លាមថា៖

“លោកក៏បញ្ចេញយោបល់ដែរថា រឿងអាថ៌កំបាំងគួរប្រាប់ដល់សម្លាញ់ តើរឿងនោះលោកបានធ្វើហើយមែនទេ? ឬគ្រាន់តែបានឃើញ? ឬបានត្រឹមតែឮ?”។

“រឿងនុ៎ះ គឺខ្ញុំបានធ្វើរួចហើយដែរ” សេនកៈតបៗ

“សូមប្រាប់មកមើល លោកអាចារ្យ” ទាំង ៣ នាក់ទទូចសួរៗ

“កាលបើរឿងអាថ៌កំបាំងនេះ ត្រូវព្រះរាជាដឹង ខ្ញុំមុខតែលែងមានជីវិតរស់ហើយ”ៗ

សេនកៈបង្អើបប៉ុណ្ណោះរួច ក៏យកក្រចកដៃគោះតុ ហើយនិយាយថា៖

“តិចលោនៅក្រោមនេះ មានមហោសថកូនគហបតីទេដឹង?”

អាចារ្យទាំង ៣ នាក់ និយាយថា៖

“បពិត្រអាចារ្យ មហោសថកូនគហបតី ជាមនុស្សមានយសសក្តិខ្ពង់ខ្ពស់ គេមិនឲ្យខ្លួនគេថោកទាបចូលនៅក្រោមតុបែបនេះទេ។ ឥឡូវនេះ មហោសថមានត្រឹមតែយសទេ សូមលោកនិយាយមកចុះ”។

សេនកៈបានបង្អើបប្រាប់រឿងអាថ៌កំបាំងរបស់ខ្លួនជាមុនដូច្នេះថា៖

“ពួកលោកស្គាល់ស្រីពេស្យា[១០១] ឈ្មោះនេះ នៅនគរនេះឬទេ?”

“ថីមិនស្គាល់ លោកអាចារ្យ” ៣ នាក់ឆ្លើយ។

“ឥឡូវនេះ មានដែលឃើញនាងទៀតដែរឬទេ?” សេនកៈសួរ។

“មិនដែលឃើញនាងទាល់តែសោះ លោកអាចារ្យ។ តើមានរឿងហេតុដូចម្ដេចជាមួយនឹងនាង?” អាចារ្យ ៣ នាក់សួរទៅវិញ។

សេនកៈក៏រៀបរាប់ថា៖

“ខ្ញុំបានរួមដំណេកជាមួយនឹងនាងក្នុងឧទ្យានសាលវ័នរួចហើយ ហេតុតែលោភចង់បានគ្រឿងប្រដាប់របស់នាង ខ្ញុំបានសម្លាប់

---

[១០១]ស្រីពេស្យាឬស្រីផ្កាមាស ជាស្រីលក់កាយចំណាយប្រាណចំពោះបុរសមិនរើសមុខនិងជាសំបុកនៃកាមរោគ។

នាងចោល ហើយយកសំពត់របស់នាងខ្ចប់ជាបង្វិចនូវគ្រឿងប្រដាប់ទាំងនោះ ទៅព្យួរទុកនៅទីងងុកងឹក្នុងបន្ទប់ឯណោះកូមិឯណោះ ក្នុងផ្ទះរបស់ខ្ញុំ។ ខ្ញុំមិនហ៊ានប្រើប្រាស់គ្រឿងប្រដាប់ទាំងនោះទេ នឹកឃើញតែអំពើនោះជាប់ក្នុងចិត្ត ខ្ញុំបានធ្វើនូវកំហុសបែបនេះ ហើយបានប្រាប់ដល់សម្លាញ់ម្នាក់ សម្លាញ់នោះមិនធ្លាប់ប្រាប់ដល់នរណាម្នាក់ឡើយ។ នេះឯងជាហេតុដែលធ្វើឲ្យខ្ញុំនិយាយថា អាថ៌កំបាំងគួរប្រាប់ដល់សម្លាញ់”។

មហោសថ ដែលពួនចាំស្តាប់ ក៏បានកំណត់រឿងអាថ៌កំបាំងរបស់សេនកៈនោះទុកយ៉ាងល្អ និងចងចាំទុកក្នុងចិត្ត។

**រឿងអាថ៌កំបាំងរបស់បុក្កុសៈ**

ចំណែកបុក្កុសៈវិញ បានប្រាប់រឿងអាថ៌កំបាំងរបស់ខ្លួនដែរថា៖ “ខ្ញុំមានរោគឃ្លង់នៅត្រង់ភ្លៅ។ ខ្ញុំមិនដែលប្រាប់ឲ្យនរណាម្នាក់ដឹងទេ ក្រៅពីប្អូនពៅរបស់ខ្ញុំ។ តាំងពីដើមមក វាបានលាងរោគលាបថ្នាំ និងរុំចងក្រណាត់ពីលើ។ ព្រះរាជាសព្វព្រះហឫទ័យនឹងខ្ញុំ ច្រើនតែហៅខ្ញុំឲ្យមកក្បែរ ហើយទ្រង់ផ្ទំកើយលើភ្លៅឃ្លង់របស់ខ្ញុំទៀតផង។ ប្រសិនបើព្រះរាជាដឹងរឿងនោះ ទ្រង់ប្រាកដជាសម្លាប់ខ្ញុំពុំខាន។ រឿងនោះ លើកលែងតែប្អូនពៅរបស់ខ្ញុំចេញ

គ្មានអ្នកដទៃណាដឹងឡើយ។ នុ៎ះឯងជាហេតុធ្វើឲ្យខ្ញុំនិយាយថា រឿងអាថ៌កំបាំងគួរប្រាប់ដល់បងប្អូនប្រុស"។

**រឿងអាថ៌កំបាំងរបស់កាមិន្ទះ**

ចំណែកឯកាមិន្ទះ បានប្រាប់រឿងអាថ៌កំបាំងរបស់ខ្លួនដូច្នេះថា៖

"ខ្ញុំត្រូវយក្ខមួយឈ្មោះថា **នរទេព** ចូលក្នុងថ្ងៃឧបោសថខាងរនោច ពេលនោះ ខ្ញុំស្រែកហាក់បីដូចឆ្កែឆ្កួត ខ្ញុំបានប្រាប់ព្រឹត្តិការណ៍នោះ ដល់កូនប្រុស  កូនប្រុសខ្ញុំដឹងថាយក្ខចូលខ្លួនខ្ញុំ វាបានផ្តេកខ្ញុំក្នុងបន្ទប់ខាងក្នុងផ្ទះបិទទ្វារជិត ហើយទៅប្រាប់ឲ្យពួកអ្នកមហោស្រព មកលេងក្បែរទ្វារ ដើម្បីបិទបាំងសំឡេងខ្ញុំស្រែកកុំឲ្យឮទៅខាងក្រៅ។ នេះឯងជាហេតុធ្វើឲ្យខ្ញុំនិយាយថា អាថ៌កំបាំងគួរប្រាប់ដល់កូនប្រុស"។

**រឿងអាថ៌កំបាំងរបស់ទេវិន្ទះ**

បន្ទាប់មក អាចារ្យទាំង ៣ សួរទេវិន្ទះម្តង។ ទេវិន្ទះ បានប្រាប់រឿងអាថ៌កំបាំងរបស់ខ្លួនថា៖

"ខ្ញុំបានលួចយកនូវកែវមណីមង្គល ជាកែវនាំមកនូវសិរីសួស្តីដែលជាព្រះរាជទ្រព្យតមកពីព្រះរាជវង្សនៃព្រះបាទ **កុសរាជ** ដែលស្តេចសក្កទេវរាជថ្វាយព្រះអង្គ។ ខ្ញុំបានលួចកែវមណីនោះ

ជូនម្ដាយខ្ញុំ។ ម្ដាយខ្ញុំមិនដែលប្រាប់នរណាឲ្យដឹងទេ លុះដល់ពេលខ្ញុំចូលមកបម្រើការក្នុងរាជវាំង គាត់បានឲ្យកែវមណីនោះដល់ខ្ញុំវិញ។ ខ្ញុំចូលបម្រើការក្នុងរាជវាំងមានរាសីខ្ពស់ត្រដែតដោយសារកែវមណីនោះ ទើបព្រះរាជាមិននិយាយរកពួកអ្នក ហើយទ្រង់ចរចាជាមួយនឹងខ្ញុំមុនពួកអ្នក និងទ្រង់តែងប្រទានប្រាក់ ៨, ១៦, ៣២, ៦៤ កហាបណៈ ប្រយោជន៍ដើម្បីជាស្បៀងដល់ខ្ញុំជារៀងរាល់ថ្ងៃ។ បើព្រះរាជាទ្រង់ជ្រាបនូវអំពើលួចកែវមណីនោះ ខ្ញុំមុខតែលែងមានជីវិតរស់ទៀតឡើយ។ នេះឯងជាហេតុដែលធ្វើឲ្យខ្ញុំនិយាយថា អាថ៌កំបាំងគួរប្រាប់ដល់ម្ដាយ”។

**ឧទុម្ពរទេវីបញ្ជូនសារទៅមហោសថ**

ចំណែកមហោសថបានចាំយ៉ាងជាក់ច្បាស់នូវរឿងអាថ៌កំបាំងរបស់អាចារ្យទាំងអស់។ អាចារ្យទាំងនោះ បានប្រាប់រឿងអាថ៌កំបាំងដល់គ្នានឹងគ្នា ហាក់ដូចជាគេហែកពោះខ្លួនឯងបញ្ចេញពោះវៀនមកក្រៅរួចផ្ដែផ្ដាំគ្នាថា៖

“ពួកលោកកុំធ្វេសប្រហែសឲ្យសោះ ចូរមកពីព្រលឹម ចាំសម្លាប់មហោសថកូនគហបតី”។

រួចហើយអាចារ្យទាំង ៤ នាក់ បំបែកផ្លូវគ្នាចេញទៅ។

បន្ទាប់ពីអាចារ្យទាំង ៤ ទៅបាត់មួយសន្ទុះ មហោសថ ក៏ក្រោកចេញពីក្រោមតុអាហារជាខាងក្រោយៗ មហោសថ ត្រឡប់ទៅផ្ទះងូតទឹករួច ប្រដាប់ខ្លួនស្អាតបាត បរិភោគនូវភោជនដ៏ឆ្ងាញ់ពិសា ហើយសន្និដ្ឋានស្មានការណ៍ជាមុនថា "ក្នុងថ្ងៃនេះ ឧទុម្ពរទេវីបងស្រីរបស់អញ នឹងផ្ដល់ដំណឹងមកពុំខាន"ៗ ដូច្នេះហើយ លោកបានប្រើបុរសដែលគួរទុកចិត្តម្នាក់ ឲ្យទៅឈរនៅក្បែរទ្វារគេហដ្ឋាន ដោយប្រាប់ថា៖

"បើមានដំណឹងអ្វីមកអំពីរាជដំណាក់ អ្នកគប្បីបញ្ជូនមកឲ្យខ្ញុំជាបន្ទាន់"ៗ

និយាយយ៉ាងនេះរួច មហោសថបានទៅសម្រាន្តនៅក្នុងបន្ទប់ៗ

ក្នុងខណៈនោះដែរ ព្រះរាជាទ្រង់កំពុងផ្ទំលើទីក្រឡាព្រះបន្ទំពិចារណារលឹកគុណមហោសថបណ្ឌិតដូច្នេះថា "មហោសថបណ្ឌិតបានបម្រើអញតាំងពីក្មេងអាយុ ៧ ឆ្នាំមកម៉េះ មិនដែលធ្វើអំពើណាដែលឥតប្រយោជន៍តិចតួចចំពោះអញទេ ទាំងប្រស្នាដែលទេវតាសួរបើកុំតែមានមហោសថបណ្ឌិត ម៉េះអាត្មាអញអស់ជីវិតទៅបាត់ហើយៗ អំពើដែលអញជឿពាក្យអាចារ្យទាំង ៤ ដែលជាអ្នកតាមចងពៀរនឹងមហោសថ ហើយអញបានប្រគល់ព្រះខាន់ដល់ពួកគេ ដើម្បីសម្លាប់មហោសថបណ្ឌិត ជាអ្នកមានគុណដ៏ធ្ងន់រកអ្វីប្រៀបពុំបាន ពុំសមគួរទាល់តែសោះៗ ពីថ្ងៃស្អែកនេះទៅ អញនឹងលែងបានឃើញមហោសថ

ទៀតហើយ”។ ទ្រង់ព្រះតម្រិះដូច្នេះហើយ ទ្រង់មានសេចក្ដីសោកស្ដាយជាពន់ពេក ធ្វើឲ្យព្រះរាជាបែកញើសហូរចេញពីព្រះសរីរកាយ។ ព្រះអង្គមានសេចក្ដីសោកសៅជាខ្លាំង និងពុំមានសេចក្ដីសុខក្នុងព្រះហឫទ័យឡើយ។ ចំណែកព្រះនាងឧទុម្ពរទេវី ដែលផ្ទំនៅលើក្រឡាបន្ទំរួមជាមួយនឹងព្រះរាជា ព្រះនាងបានទតឃើញនូវអាការៈខុសប្លែកពីធម្មតា នឹកឆ្ងល់ថា “អញមានកំហុសអ្វីខ្លះទេដឹង ឬព្រះអង្គមានហេតុនៃក្ដីសោកសៅផ្ទាល់ព្រះអង្គឯង អញគួរតែទូលសួរព្រះអង្គ”។ ទើបព្រះនាងមានព្រះសវនីយ៍សួរថា៖

“បពិត្រព្រះរាជាដ៏ប្រសើរ ព្រះអង្គទ្រង់មានបញ្ហាអ្វី បានជាព្រះអង្គមានអាការៈខុសប្លែកពីធម្មតាដូច្នេះ? បពិត្រព្រះអង្គជាធំជាងមនុស្សក្នុងដែនវិទេហៈ ខ្ញុំម្ចាស់ចង់ស្ដាប់ព្រះតម្រាស់របស់ព្រះអង្គ តើព្រះអង្គទ្រង់ព្រះចិន្ដាយ៉ាងដូចម្ដេច បានជាទ្រង់ខ្វល់ខ្វាយព្រះហឫទ័យម៉្លេះ? ព្រះសម្មតិទេព ឬមួយក៏ខ្ញុំម្ចាស់បានប្រព្រឹត្តកំហុសធ្ងន់ធ្ងរចំពោះព្រះអង្គ?”

គ្រានោះ ព្រះរាជាត្រាស់ថា៖

“មហេសីអូន! បណ្ឌិត ៤ នាក់ បានប្រាប់ម្ចាស់បងថា មហោសថជាសត្រូវនឹងម្ចាស់បង។ បងមិនបានពិចារណាឲ្យល្អិតល្អន់ តាមសភាពពិតសោះ ក៏ជ្រុលជ្រួសជ្រលួសមាត់បញ្ជាឲ្យគេសម្លាប់

មហោសថ។ មហោសថនឹងត្រូវគេសម្លាប់ជាក់ជាមិនខាន។ មហោសថ ជាអ្នកមានប្រាជ្ញាដូចផែនដី ត្រូវបងបង្គាប់គេឲ្យចាំសម្លាប់ បងគិតដល់រឿងនោះហើយ បានជាមានហឫទ័យទោមនស្សខ្លាំងយ៉ាងនេះ។ ទេវីអូន! អូនគ្មានកំហុសអ្វីទេ"។

គ្រាន់តែឮព្រះរាជឱង្ការរបស់ព្រះរាជាភ្លាម សេចក្ដីទុក្ខប៉ុនភ្នំបានកើតឡើងដល់ព្រះនាងឧទុម្ពរទេវី ព្រោះសេចក្ដីស្រឡាញ់ចំពោះមហោសថជាប្អូនធម៌។ គ្រានោះ ព្រះនាងគិតថា "អញនឹងប្រើឧបាយមួយ លួងលោមព្រះរាជាធ្វើឲ្យព្រះអង្គផ្ទំលក់ស៊ប់ អញនឹងបញ្ជូនសារទៅប្អូនរបស់អញ"។ គ្រានោះព្រះនាងលួងលោមស្ដេចថា៖

"បពិត្រមហារាជ មហោសថកូនគហបតី គឺព្រះអង្គទេតើ ជាអ្នកតែងតាំងក្នុងឥស្សរិយយសដ៏ខ្ពង់ខ្ពស់ គឺព្រះអង្គបានតែងតាំងគេក្នុងឋានៈជាមហាសេនាបតី។ ឮថាឥឡូវ គេត្រឡប់ទៅជាសត្រូវចំពោះព្រះអង្គទៅវិញ។ សត្រូវនេះ មិនមែនជម្មតាទេ។ គេសមតែស្លាប់អ៊ីចឹងហើយ។ សូមព្រះអង្គកុំគិតខ្វល់ព្រះហឫទ័យច្រើនពេក ក្រាបទូល"។

ព្រះរាជា ទ្រង់បានជួរក្តីសោកសៅ ហើយទ្រង់ឈានចូលកាន់និទ្រា[១០២]លង់លក់ស៊ប់ទៅ។ រីឯព្រះនាងឧទុម្ពរទេវី ក្រោកចេញទៅក្នុងបន្ទប់របស់ព្រះនាង សរសេរលិខិតមួយមានអត្ថន័យថា "មហោសថប្អូន! បណ្ឌិត ៤ នាក់ បំបែកបំបាក់ប្អូនហើយ។ ព្រះរាជាទ្រង់ខ្ញាល់ខ្លាំងណាស់ បានបង្គាប់គេឲ្យរង់ចាំសម្លាប់ប្អូននៅក្បែរប្រចកទ្វារព្រះរាជវាំង។ ថ្ងៃស្អែក ប្អូនមិនត្រូវមករាជវាំងទេ។ ប៉ុន្តែបើប្អូនមក ប្អូនត្រូវធ្វើរាជធានីឲ្យស្ថិតនៅក្នុងកណ្តាប់ដៃ និងពង្រឹងសមត្ថភាពជាមុនសិន"។ សរសេរដូច្នេះហើយ ព្រះនាងបានដាក់លិខិតខាងក្នុងស្រោម[១០៣] រុំដោយអំបោះដាក់ក្នុងកាជន៍គ្របជិត ហើយព្រះនាងប្រថាប់ត្រាជាគ្រឿងសម្គាល់ប្រគល់ទៅឲ្យទាសីជំនិតម្នាក់ រួចប្រាប់ថា "នាងចូរយកលិខិតនេះទៅឲ្យប្អូនខ្ញុំជាបន្ទាន់"។ ទាសីនោះ ក៏បានធ្វើតាមបញ្ជារបស់ព្រះនាងភ្លាម។

---

[១០២] ការដែលសរសេរ និទ្រា មិនត្រឹមត្រូវទេ។

[១០៣] បណ្ណំ លិខិត្វា មោទកស្ស អន្តោ បក្ខិបិត្វា មោទកំ សុត្តេន វេឋេត្វា នវភាជនេ កត្វា ធាទេត្វា លញ្ឆេត្វា អត្តចារិកាយ ទាសិយា អទាសិ។

**កំណត់សម្គាល់**

អ្នកសិក្សាមិនគប្បីគិតថា "នាងទាសីចេញទៅយ៉ាងម៉េចក្នុងពេលយប់"។ ដ្បិតថា ព្រះរាជាបានប្រទានពរដល់ព្រះនាងឧទុម្ពរទេវី តាំងពីគ្រាជំបូងរួចហើយ។ ហេតុនោះ ទាសីដែលចេញចូលតាមទ្វាររាំង គ្មានទាហានណាម្នាក់ ហ៊ានហាមឃាត់ឡើយ
ព្រោះប្រើផ្កាកសញ្ញាជាគ្រឿង
សម្គាល់។

**មហោសថផ្ដោលទោសស្ដេច**

មហោសថ ទទួលលិខិតហើយ បានបញ្ជូនទាសីនោះឲ្យត្រឡប់ទៅវិញ។ ទាសីបានមកទូលថ្វាយព្រះនាងទេវីឲ្យទ្រង់ជ្រាបអំពីដំណើរដែលខ្ញុំបានជូនភាជន៍នោះ ដល់មហោសថរួចហើយ។ ក្នុងខណៈនោះ ព្រះនាងឧទុម្ពរទេវីក៏យាងមកផ្ទុំជាមួយនឹងព្រះរាជាវិញ។ ចំណែកមហោសថ ហែកស្រោមសំបុត្រទាញមកអាន ក៏ដឹងរឿងរ៉ាវនោះ ហើយដេកលើគ្រែពិចារណារំពឹងរកមធ្យោបាយដោះស្រាយ។

និយាយពីអាចារ្យទាំង ៤ រូបវិញ ព្រឹកព្រហាមឡើង បានកាន់ព្រះខាន់មកឈរនៅក្បែរប្រេកទ្វារ តែមិនឃើញមហោសថមកសោះ

ម្នាក់ៗខកចិត្តជាខ្លាំង នាំគ្នាទៅកាន់សម្នាក់ព្រះរាជាវិញ។ ព្រះរាជាទ្រង់ត្រាស់សួរថា៖

"ពួកលោក បានសម្លាប់មហោសថកូនគហបតីហើយឬនៅ?"

"មិនឃើញមហោសថមកទេ ព្រះអង្គ" ពួកគេបានក្រាបទូល។

រីឯមហោសថវិញ កាលបើអរុណរះឡើង លោកបានធ្វើនគរឲ្យនៅក្នុងកណ្ដាប់ដៃរបស់ខ្លួន[១០៤] ដាក់ទាហានយាមរក្សាសន្តិសុខយ៉ាងហ្មត់ចត់ នៅកន្លែងនេះកន្លែងនោះគ្រប់ច្រកល្ហកក្នុងរាជធានី។ លោកបានឡើងជិះរថដោយមានមហាជនចោមរោមជាបរិវារ ធ្វើដំណើរត្ពោះទៅទ្វារព្រះរាជវាំង។ ព្រះរាជាបើកសីហបញ្ជរ ឈរទតមើលទៅខាងក្រៅ។ លំដាប់នោះ មហោសថចុះពីរថឈរប្រណម្យដៃសំពះត្ពោះទៅរកព្រះរាជា។ ព្រះរាជាបានទតឃើញដូច្នោះ ទ្រង់ព្រះតម្រិះថា "ប្រសិនបើ មហោសថនេះជាសត្រូវរបស់អញ ម៉្លេះគេមិនសំពះអញទេ" ទើបទ្រង់គង់លើអាសនៈវិញ ប្រើអាមាត្យឲ្យទៅហៅមហោសថចូលគាល់។ មហោសថ ចូលមកអង្គុយក្នុងទីសមគួរ។ ចំណែកបណ្ឌិត ៤ រូបនោះក៏អង្គុយនៅទីនោះដែរ។ គ្រានោះ ព្រះរាជាសួរមហោសថ ធ្វើហាក់ដូចជាមិនដឹងការណ៍អ្វីសោះថា៖

---

[១០៤] នគរំ អត្តនោ ហត្ថគតំ កត្វា។

"នៃបុត្រ! ម្សិលមិញអ្នកទៅផ្ទះ ថ្ងៃនេះហេតុអ្វីបានជាមកយឺតយូរ យ៉ាងនេះ? តើអ្នកចង់ បោះបង់យើងចោលមែនទេ?"

រួចទ្រង់ត្រាស់បន្តថា៖

អ្នកទទួលជំណឺងអ្វី? ចិត្តរបស់អ្នកសង្ស័យដូចម្ដេច? ម្នាលអ្នក មានប្រាជ្ញាក្រាស់ដូចផែនដី តើនរណាបានប្រាប់អ្នកមិនឲ្យមកកាន់ សម្នាក់របស់យើងកាលពីព្រឹកព្រលឹមដូចសព្វដង? យើងចង់ ដឹង អ្នកចូរប្រាប់យើងមើល"។

"បពិត្រមហារាជ ព្រះអង្គជឿពាក្យញុះញង់របស់បណ្ឌិតទាំង ៤ នាក់ ទ្រង់បានបង្គាប់ពួកគេឲ្យរង់ចាំសម្លាប់ទូលព្រះបង្គំនៅច្រក ទ្វារព្រះរាជវាំង ទូលបង្គំយល់ហេតុនោះ ទើបទូលបង្គំមិនមក តាមពេលធម្មតា" មហោសថក្រាលទោសស្ដេច។

ហើយមហោសថពោលតទៅដូច្នេះថា៖

"បពិត្រព្រះអង្គជាធំជាងជន ព្រះអង្គទ្រង់នៅក្នុងទីស្ងាត់ បាន ប្រាប់រឿងអាថ៌កំបាំងដែលព្រះអង្គប្រឹក្សាជាមួយនឹងបណ្ឌិតទាំង ៤ នាក់ ក្នុងពេលព្រលប់ ដល់ព្រះអគ្គមហេសីក្នុងវេលាយប់ថា ទូលបង្គំនឹងត្រូវគេសម្លាប់ ព្រោះប្រស្នាអាថ៌កំបាំងសម្លាប់ទូល បង្គំនោះ ឈ្មោះថា ព្រះអង្គបានធ្វើឲ្យបែកធ្លាយដល់អគ្គមហេសី

ក្នុងកាលនោះៗ រឿងអាថ៌កំបាំងនុ៎ះ ទូលព្រះបង្គំបានដឹងក្នុងខណៈនោះ ភ្លាមៗដែរ"ៗ

ព្រះរាជាទ្រង់ព្រះសណ្ដាប់ដូច្នោះភ្លាម ទ្រង់សម្លឹងទៅមុខព្រះនាងឧទុម្ពរទេវីទ្រង់ត្រាស់ថា៖

"នាងនេះ! ប្រាកដជាលួចបញ្ជូនដំណឹងប្រាប់មហោសថក្នុងខណៈនោះមិនខាន"ៗ

មហោសថ ដឹងថាស្ដេចទ្រង់ខ្ញាល់នឹងអគ្គមហេសី លោកបានក្រាបទូលព្រះរាជាថា៖

"បពិត្រព្រះសម្មតិទេព ព្រះអង្គខ្ញាល់នឹងព្រះទេវីឬ? ទូលបង្គំជាខ្ញុំដឹងទាំងអស់ ទាំងរឿងអតីតៈ រឿងអនាគត និងរឿងបច្ចុប្បន្នៗ បពិត្រព្រះសម្មតិទេព កុំថាឡើយអាថ៌កំបាំងព្រះអង្គដែលប្រាប់ដល់ព្រះអគ្គមហេសី សូម្បីអាថ៌កំបាំងរបស់សេនកៈ បុក្កុសៈ កាមិន្ទៈ និងទេវិន្ទៈ តើមាននរណាប្រាប់ដល់ទូលបង្គំទៅ? ទូលបង្គំក៏បានដឹងអាថ៌កំបាំងរបស់ពួកគេទាំងអស់ដែរ"ៗ

**មហោសថឧទ្ធាយរឿងអាថ៌កំបាំងរបស់អាចារ្យទាំង ៤**

បន្ទាប់មក មហោសថក្រាបទូលបន្តនូវរឿងអាថ៌កំបាំងរបស់អាចារ្យសេនកៈដូច្នេះថា៖

"អាចារ្យសេនកៈបានធ្វើអំពើអាក្រក់ ជាអំពើមានសភាពមិនល្អ ជាអំពើលាមក ជាអកុសលកម្ម ក្នុងឧទ្យានដ៏ជេរជាសរដោយដើមសាលព្រឹក្សគឺថា គេបានសេពសន្ថវៈជាមួយនឹងស្រីពេស្យាឈ្មោះនេះ ក្នុងឧទ្យានសាលព្រឹក្ស ក្នុងនគរនេះ រួចសម្លាប់នាងបូន់យកគ្រឿងអលង្ការ ហើយយកសំពត់របស់នាងខ្ចប់វេចនូវគ្រឿងអលង្ការទៅព្យួរនៅចុងស្នែងដំរីនៅក្នុងផ្ទះរបស់ខ្លួននៅទីនេះ នៅទីនោះៗ បពិត្រមហារាជសេនកៈនេះ ទៅក្នុងទីស្ងាត់ប្រាប់ដល់សម្លាញ់គេម្នាក់ៗ រឿងអាថ៌កំបាំង ដែលអាចារ្យសេនកៈបានធ្វើរួចហើយ គឺទូលបង្គំបានដឹងច្បាស់ណាស់ៗ ទូលបង្គំមិនមែនជាសត្រូវរបស់ព្រះអង្គទេ សេនកៈទេតើជាសត្រូវ ក្រាបទូលៗ បើព្រះអង្គចង់ចាប់ឬសម្លាប់សត្រូវ សូមព្រះអង្គបញ្ជាទាហានឲ្យ ចាប់សេនកៈចុះ ក្រាបទូល"ៗ

ព្រះរាជាទតសម្លឹងមុខសេនកៈរួចត្រាស់សួរថា៖

"ពិតមែនឬ សេនកៈ?"

"ពិតមែន ព្រះសម្មតិទេព" សេនកៈឆ្លើយៗ

ឮពាក្យសារភាពរបស់សេនកៈដូច្នេះ ព្រះរាជាក៏បានបញ្ជាទាហានឲ្យចាប់សេនកៈបញ្ជូនទៅដាក់ក្នុងពន្ធនាគារៗ

មហោសថបានក្រាបទូលស្ដេចជាបន្ត អំពីរឿងអាថ៌កំបាំងរបស់បុក្កុសៈដូច្នេះថា៖

“បពិត្រព្រះអង្គជាធំជាងជន បុក្កុសៈជាមនុស្សកើតរោគឃ្លង់។ រោគនោះមិនសមគួរដល់ព្រះរាជាយកព្រះសិរសៈផ្ទុំកើយទេ ដែលជារឿយៗ ព្រះអង្គបានផ្ទុំកើយលើភ្លៅគម្លង់របស់បុក្កុសៈ ដោយព្រះតម្រិះថាភ្លៅគេទន់ស្រួល ប៉ុន្តែសម្ផស្សទន់ៗ ទន់ស្រួល ដោយសារក្រណាត់សំពត់រុំឃ្លង់ត្រង់ភ្លៅ។ បុក្កុសៈត្រូវបានប្អូនប្រុសជួយមើលថែ ដោយដាក់ថ្នាំលាង និងរុំរបួសដោយក្រណាត់សំពត់ ក្រាបទូល។ រឿងអាថ៌កំបាំងណា ដែលអាចារ្យបុក្កុសៈបានធ្វើ គឺទូលបង្គំបានដឹងយ៉ាងនេះ ក្រាបទូល។

ព្រះរាជា សម្លឹងមើលមុខបុក្កុសៈនោះ ហើយទ្រង់សួរថា៖

“ពិតមែនឬ បុក្កុសៈ?”

“ពិតមែន ព្រះសម្មតិទេព” បុក្កុសៈសារភាព។

ឮពាក្យសារភាពរបស់បុក្កុសៈដូច្នេះ ព្រះរាជាក៏បានបញ្ជាទាហានឲ្យចាប់អាចារ្យបុក្កុសៈបញ្ជូនទៅដាក់ក្នុងពន្ធនាគារ។

មហោសថបានក្រាបទូលនូវរឿងអាថ៌កំបាំងរបស់កាមិន្ទៈម្ដងថា៖

“អាចារ្យកាមិន្ទៈនេះ មានជំងឺដ៏អាក្រក់ ស្រែកដូចឆ្កែឆ្កួត ពេលត្រូវខ្មោចយក្ខចូលម្ដងៗ។ គេជាមនុស្សអសប្បុរស ចោកទាប

កើតរោគអ៊ីចឹងហើយ គេមិនគួរថ្លើមធំ ហ៊ានបន្ទំចូលមកបម្រើ

ការក្នុងព្រះរាជវាំងសោះ។ ជំងឺឆ្កួតនេះ មានតែកូនប្រុសគេម្នាក់

គត់ ដែលដឹងពីរឿងអាថ៌កំបាំងនេះ ក្រាបទូល។ រឿងអាថ៌កំបាំង

ដែលអាចារ្យកាមិន្ទៈបានធ្វើ ទូលបង្គំបានដឹងយ៉ាងនេះ ព្រះអង្គ។

ព្រះរាជា សម្លឹងមើលមុខកាមិន្ទៈនោះ ហើយទ្រង់ក៏សួរថា៖

"ពិតមែនឬ កាមិន្ទៈ?"

"ពិតមែន ព្រះសម្មតិទេព" កាមិន្ទៈសារភាព។

ព្រះរាជាក៏បានបញ្ជាទាហាន ឲ្យចាប់អាចារ្យកាមិន្ទៈបញ្ជូនទៅដាក់

ក្នុងពន្ធនាគារ បន្ទាប់ពីបានឮពាក្យសារភាពរបស់អាចារ្យនោះ។

មហោសថ ក៏បន្តទូលនូវរឿងអាថ៌កំបាំងរបស់ទេវិន្ទៈ ដូច្នេះថា៖

"ព្រះឥន្ទ្របានថ្វាយមណីរត្នមានជ្រុង ៨ ដ៏ប្រណិត ដល់ព្រះបាទ

**កុសរាជ** ជាព្រះអយ្យកោរបស់ព្រះអង្គ។ អាចារ្យទេវិន្ទៈជាចោរ

បានលួចយកមណីរត្ន ដែលសន្មតថាជាកែវមណីមង្គលនោះ

ក្រាបទូល។ ក្រៅអំពីម្ដាយរបស់គេ គឺពុំមាននរណាដឹងរឿង

អាថ៌កំបាំងនេះទេ។ រឿងអាថ៌កំបាំងដែលអាចារ្យទេវិន្ទៈបានធ្វើ

គឺទូលបង្គំបានដឹងយ៉ាងនេះ មហារាជ។

ព្រះរាជា សម្លឹងមើលមុខទេវិន្ទៈនោះ ហើយទ្រង់ត្រាស់សួរថា៖

"ពិតមែនឬ ទេវិន្ទៈ?"

"ពិតមែន ព្រះសម្មតិទេព" ទេវិន្ទះសារភាព។ ព្រះរាជាទ្រង់ក៏បញ្ជាឲ្យទាហានចាប់ទេវិន្ទះដាក់ក្នុងពន្ធនាគារ។

ដោយប្រការដូចថែងមកនេះ នឹងឃើញយ៉ាងច្បាស់ថា អាចារ្យ ៤ នាក់ ប៉ុនប៉ងនឹងសម្លាប់មហោសថបណ្ឌិត តែបែរជាត្រូវជាប់គុកខ្លួនឯងទៅវិញ។

**រឿងអាថ៌កំបាំងគួរប្រាប់អ្នកដទៃពេលណា?**

ចំណែកមហោសថ ក្រាបទូលព្រះរាជាថា៖

"បពិត្រមហារាជ ដោយហេតុនេះហើយ ទើបទូលបង្គំក្រាបទូលព្រះអង្គថា អាថ៌កំបាំងរបស់ខ្លួនមិនត្រូវប្រាប់ដល់អ្នកដទៃឡើយ។ ប៉ុន្តែពួកគេម្នាក់ៗសោតសឹងតែ[១០៥]បញ្ចេញយោបល់ថាគួរប្រាប់ ទើបបានជាដល់សេចក្តីវិនាសដ៏ធំយ៉ាងនេះ"។

លុះពោលដូច្នេះហើយ មហោសថពោលធម៌ជាគាថាបន្ថែមថា៖

"គុយ្ហស្ស ហិ គុយ្ហមេវ សាធុ, ន គុយ្ហស្ស បសត្ថមាវិកម្មំ;
អនិប្ផន្នតា សហេយ្យ ធីរោ, និប្ផន្នោវ យថាសុខំ ភណេយ្យ។

"ន គុយ្ហមត្ថំ វិវរេយ្យ, រក្ខេយ្យ នំ យថា និធឹ;
ន ហិ បាតុកតោ សាធុ, គុយ្ហោ អត្ថោ បជានតា។

[១០៥] សោតសឹង = សុទ្ធសឹង។ សោតសឹងតែ = សុទ្ធសឹងតែ។

"ជិយា គុយ្ហំ ន សំសេយ្យ, អមិត្តស្ស ច បណ្ឌិតោ;
យោ ចាមិសេន សំហីរេ, ហទយត្ថេនោ ច យោ នរោ។

"គុយ្ហមត្ថំ អសម្ពុទ្ធំ, សម្ពោធយតិ យោ នរោ;
មន្តភេទភយា តស្ស, ទាសភូតោ តិតិក្ខតិ។

"យាវន្តោ បុរិសស្សត្ថំ, គុយ្ហំ ជានន្តិ មន្តិនំ;
តាវន្តោ តស្ស ឧព្វេគា, តស្មា គុយ្ហំ ន វិស្សជេ។

"វិវិច្ច ភាសេយ្យ ទិវា រហស្សំ, រត្តិំ គិរំ នាតិវេលំ បមុញ្ចេ;
ឧបស្សុតិកា ហិ សុណន្តិ មន្តំ, តស្មា មន្តោ ខិប្បមុបេតិ ភេទំ"។

*"ការលាក់អាថ៌កំបាំង ជាការប្រពៃ។ ការប្រាប់អាថ៌កំបាំងឲ្យអ្នកដទៃដឹងមិនប្រពៃឡើយ។ អ្នកប្រាជ្ញកាលបើសេចក្តីប្រាថ្នាមិនទាន់សម្រេច ត្រូវអត់សង្កត់ទុក លុះសម្រេចប្រយោជន៍ហើយ ទើបគួរនិយាយតាមសប្បាយចុះ។ បុគ្គលមិនគប្បីបើកនូវអាថ៌កំបាំង គប្បីលាក់នូវអាថ៌កំបាំងនោះ ដូចជារក្សានូវកំណប់ ដ្បិតថា (កំណប់ជារបស់មានតម្លៃច្រើន) បុគ្គលមិនត្រូវប្រាប់ដល់អ្នកដទៃទើបជាការប្រពៃ។ អ្នកប្រាជ្ញមិនគប្បីនិយាយប្រាប់នូវអាថ៌កំបាំងដល់ស្ត្រី ដល់ជនជាសត្រូវ ដល់ជនរឡិបរឡប់*

ដោយអាមិស[១០៦] ដល់ជនលួចគំនិតគ្នា។ ជនណា តែងញ៉ាំង អាថ៌កំបាំងដែលមិនទាន់មានគេដឹង ឲ្យគេដឹង។ អ្នកប្រាជ្ញតែង អត់សង្កត់មិនប្រាប់ដល់ជននោះ ព្រោះខ្លាចបែកការដែលគិតទុក ដូចជាមនុស្សខ្ញុំគេ ដែលទ្រាំនឹងការជេរ ការផ្ដាសា និងការវាយ ដំអំពីចៅហ្វាយនាយដោយមិនតបត។ បុរសចេះនូវមន្តអាថ៌កំបាំង កាលបើមានអ្នកដទៃដឹងច្រើន សេចក្ដីតក់ស្លុតរបស់បុរសនោះ ក៏កើនច្រើនដែរ។ ក្នុងពេលថ្ងៃ អ្នកប្រាជ្ញគប្បីនិយាយអាថ៌កំបាំង ក្នុងទីស្ងាត់ មិនគប្បីនិយាយក្នុងពេលយប់ទេ ព្រោះថាពួក អ្នកឈ្លបតែងលួចស្ដាប់ឮរឿងអាថ៌កំបាំងដែលបានប្រឹក្សាគ្នា។ ហេតុនោះ រឿងអាថ៌កំបាំងមិនត្រូវនិយាយនៅពេលយប់ទេ”។

---

[១០៦] អាមិស  បា.; សំ. (ន.) (អាមិស; អាមិម) សាច់ (ដែលប្រើជាអាហារ); នុយ; របស់ជាគ្រឿងទាក់ចិត្តឬជាគ្រឿងជន្លជន្លេញចិត្ត; លាភ:, សក្ការ: ឬលាភសក្ការ:; ទាន, ទេយ្យទាន ឬទេយ្យវត្ថុ; ចតុប្បច្ច័យ; អាហារ ។ល។: ខំប្រឹងសម្លឹងឃើញអាមិស: ។ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃ សរសេរជា អាមិស (អ. ថ. --មិស:), ដូចជា អាមិសទាន ការឲ្យអាមិស:; ការឲ្យចតុប្បច្ច័យ (ជាគូគ្នានឹង ធម្មទាន)។ អាមិសទាយក (--យក់) អ្នកឲ្យអាមិស: (បើស្ត្រីជា អាមិសទាយិកា)។ អាមិសបូជា បូជាដោយអាមិស: ។ អាមិសសន្និច័យ ការសន្សំអាមិស:, ការលាក់សុំអាមិស:។ អាមិសហេតុ ព្រោះហេតុតែអាមិស:; ដោយសារតែអាមិស: គឺដោយសារសម្លឹងឃើញលាភឬផលប្រយោជន៍នៅមុខ ។ល។  អាមិស:។

**មហោសថលើកលែងទោសបណ្ឌិតទាំង ៤**

*ព្រះរាជា ទ្រង់ព្រះសណ្ដាប់សម្ដីរបស់មហោសថហើយ ព្រះអង្គទ្រង់ព្រះពិរោធថា៖*

*"ពួកនោះ មានពៀរនឹងស្ដេចដោយខ្លួនឯង បែរជាធ្វើឲ្យមហោសថមានពៀរចំពោះយើងទៅវិញ"។*

*ដូច្នេះ ទ្រង់បានដាក់អាជ្ញាថា៖*

*"សេនា! ពួកអ្នកចូរនាំអាប៉ុន្មាននាក់នោះចេញពីនគរ ដោតសូលឡើងលើ បើពុំនោះទេ កាត់ក្បាលពួកវាឲ្យអស់"។*

*អាចារ្យទាំង ៤ នាក់ ត្រូវរាជបុរសចងក្រពាត់ស្លាបសេកបណ្ដើរនាំទៅតាមផ្លូវបែកជា ៤ វាយវាត់ដោយខ្សែតីរប់ពាន់ខ្វាប់។ មហោសថបណ្ឌិត ក្រាបទូលសូមព្រះរាជាឲ្យទ្រង់អត់ទោសដល់ពួកគេថា៖*

*"បពិត្រព្រះសម្មតិទេព អាចារ្យទាំង ៤ នេះ សុទ្ធតែជាមន្ត្រីចាស់របស់ព្រះអង្គ។ សូមទ្រង់ព្រះមេត្តាប្រោសអត់ទោសកំហុសដល់ពួកគេដោយក្ដីអនុគ្រោះផងចុះ"។*

ព្រះរាជា ក្រោយពីទទួលការស្នើសុំរបស់មហោសថ ទ្រង់ក៏យល់ព្រមតាមសេចក្ដីស្នើ ហើយចាត់គេឲ្យទៅហៅអាចារ្យទាំង ៤ នាក់ចូលមកគាល់ព្រះអង្គ រួចទ្រង់ប្រទានអាចារ្យទាំងនោះធ្វើជាទាសៈរបស់មហោសថតែម្ដង។ ប៉ុន្ដែមហោសថ ថែមទាំងបានស្នើសូម ព្រះរាជាដោះលែងពួកគេឲ្យមានសេរីភាពរួចពីទាសភាព។ ដោយព្រះរាជាមានហឫទ័យចង់ដាក់អាជ្ញាចំពោះអាចារ្យទាំង ៤ នោះ ទើបត្រាស់និរទេសថា៖

"បើដូច្នោះ មិនត្រូវឲ្យអាចារ្យទាំង ៤ នេះនៅក្នុងដែនរបស់យើងតទៅទៀតទេ"។

មហោសថបណ្ឌិត បានក្រាបទូលសូមព្រះរាជាឲ្យទ្រង់អត់ទោសដល់ពួកគេម្ដងទៀតថា៖

"បពិត្រព្រះសម្មតិទេព សូមទ្រង់អត់ទោសដល់ជនអន្ធពាលទាំងនេះផង កុំបណ្ដេញពួកគេអី។ សូមទ្រង់ទុកឋានន្តរសក្តិរបស់ពួកគេតាមប្រក្រតីដើមវិញម្ដងទៀតចុះ ក្រាបទូល"។

ព្រះរាជាមានព្រះតម្រិះថា "មហោសថ មានសេចក្ដីមេត្តាបែបនេះចំពោះសត្រូវទៅកើតដែរ មិនចាំបាច់និយាយទៅថ្វីដល់ពួកជនដទៃ" ដូច្នេះហើយ ព្រះរាជាទ្រង់ជ្រះថ្លាយ៉ាងខ្លាំងចំពោះមហោសថបណ្ឌិត។

តាំងពីគ្រានោះមក បណ្ឌិត ៤ នាក់ លែងហ៊ាននិយាយអ្វី ពួកគេអស់ពិសដូចពស់ដកចង្កូមៗ

បញ្ចបណ្ឌិតបញ្ហា ចប់ៗ

# ជំពូកទី ៨

## យុទ្ធសាស្ត្រទប់ទល់នឹងសង្គ្រាមវាតទីរបស់កបិលរដ្ឋ

## យុទ្ធបរាជយគណ្ឋ

*បរាជ័យក្នុងសមរភូមិ*

**មហោសថអភិវឌ្ឍប្រទេសជាតិ**

*តាំងពីគ្រានោះមក មានតែមហោសថបណ្ឌិតប៉ុណ្ណោះ ដែលជាអ្នកថ្វាយទស្សនៈហេតុផលដ៏ត្រឹមត្រូវចំពោះព្រះរាជា។ មហោសថបានគិតថា "សេតច្ឆត្រមានចំពោះតែព្រះរាជាប៉ុណ្ណោះ ប៉ុន្តែមានតែរូបអញម្នាក់គត់ ដែលមានសមត្ថភាពធ្វើឲ្យរាជាណាចក្រនេះ គង់វង្សរីកចម្រើនតទៅមុខបាន។ អាត្មាអញមិនត្រូវមានសេចក្តីធ្វេសប្រហែសឡើយ"។ មហោសថគិតដូច្នេះហើយ បានឲ្យជាងសាងមហាកំពែងដ៏ធំមួយព័ទ្ធជុំវិញក្រុង និងកំពែងតូចព័ទ្ធជុំវិញមួយជាន់ទៀត ប៉មធំនៅតាមទ្វារធំៗ និងប៉មតូចៗនៅចន្លោះៗ ថែមទៀត និងជីកស្នាមភ្លោះ ៣ ជាន់ គឺស្នាមភ្លោះទឹក១ ស្នាមភ្លោះភក់១ ស្នាមភ្លោះស្ងួត១។ អគារចាស់ៗ ដែលនៅខាងក្នុងនគរ មហោសថ បានចាត់ឲ្យជាងជួសជុលតុបតែងលម្អយ៉ាងស្អាតទាំងអស់ និងឲ្យជាងជីកស្រះបោក្ខរណីធំៗ តម្កល់ទឹកទុកពេញៗ*

មិនឲ្យខ្វះ ជម្រកនៅក្នុងក្រុងទាំងអស់ គឺមានស្រូវតម្កល់ទុកពេញៗ ជានិច្ចៗ មហោសថ បានសូមឲ្យពួកតាបសជាជីតុន[១០៧] នាំពូជស្មៅនិងផ្កាឈូកស[១០៨] ល្អៗជាច្រើន អំពីព្រៃហេមពាន្តមកផ្សាំបណ្តុះដាំឲ្យមានសោភណភាព នៅក្នុងទីក្រុងៗ សូម្បីនៅខាងក្រៅក្រុង ក៏លោកចាត់ឲ្យមានការជួសជុលសាលាចាស់ៗ ឲ្យបានល្អសម្រាប់ប្រើការឡើងវិញៗ មហោសថ បានរៀបចំធ្វើយ៉ាងនេះ ដើម្បីនឹងការពារនូវភយន្តរាយក្នុងពេលអនាគតៗ

**ទំនាក់ទំនងអន្តរជាតិ**

មានពួកឈ្នួញ[១០៩]ជាច្រើន តែងមកពីប្រទេសផ្សេងៗចូលកាត់តាមទឹកដីនៃព្រះរាជាណាចក្រមិថិលាៗ រីឯមហោសថ តែងតែស្និទ្ធស្នាល

---

[១០៧] ពាក្យសម្រាប់គ្រហស្ថហៅអ្នកបួស ដែលជាញាតិ ឬដែលខ្លួនស្និទ្ធស្នាល ហើយបានទំនុកបម្រុងបច្ច័យ ៤ ផងៗ

[១០៨] កុម្រុទស កុមុទពីជានិ

[១០៩] ឈ្នួញ ជាការកនាម គឺនាមសព្ទប្រើកំណត់សម្គាល់ទៅលើមនុស្ស មានន័យថា អ្នកជួញឬអ្នកធ្វើជំនួញៗ ពាក្យនេះកើតឡើងដោយផ្សំមូលបទ ជាមួយនឹងបទដែរ ទម្រង់ព ចុះម, ពាក្យដទៃទៀតមានដូចជា៖ ឆ្មាំ <ចាំ +ម (អ្នកចាំយាម, អ្នកធ្វើការចាំយាម ឧ. ឆ្មាំទ្វារ)ៗ ខ្មាន់ <កាន់ +ម (អ្នកកាន់, អ្នកធ្វើការកាន់ ឧ. ខ្មាន់កាំភ្លើង, ខ្មាន់ព្រះកេស)ៗ ល្មួច <លួច +ម (អ្នកលួច, អ្នកធ្វើការលួច ឧ. ឯងជាមនុស្ស

សាកសួរអំពីស្រុកទេសរបស់ពួកគេៗ ក្រោយពេលពួកគេប្រាប់ថា មកអំពីប្រទេសនេះប្រទេសនោះ លោកក៏សួរអំពីចំណង់ចំណូលចិត្ត របស់ស្ដេចនៃពួកឈ្មួញទាំងនោះៗ កាលបើពួកឈ្មួញប្រាប់ថា ស្ដេច ពួកគេចូលចិត្តរបស់នេះរបស់នោះ មហោសថ រឹតតែបន្ថែមសេចក្ដី រាប់អានរាក់ទាក់ ចំពោះពួកឈ្មួញទាំងនោះៗ កាលពួកគេត្រូវធ្វើដំណើរ ត្រឡប់ទៅវិញ មហោសថក៏តែងជូនដំណើរ សម្ដែងអំពីការគួរសមៗ បន្ទាប់មក មហោសថបានហៅនាយទាហានរបស់ខ្លួនចំនួន ១០១ នាក់ មកជួប ហើយបានប្រាប់ថា៖

"នែសម្លាញ់ ពួកអ្នកចូរយកគ្រឿងបណ្ណាការទាំងឡាយដែលខ្ញុំ ឲ្យនេះ ធ្វើដំណើរឆ្ពោះទៅកាន់រាជធានីទាំង ១០១ ក្រុង ហើយ ថ្វាយបណ្ណាការទាំងនេះ ចំពោះស្ដេចនៃប្រទេសទាំងនោះ តាម សេចក្ដីស្រឡាញ់និងចំណូលចិត្តរបស់ស្ដេចនៃប្រទេសនីមួយៗ។ អ្នកទាំងឡាយចូរនៅគាល់បម្រើស្ដេចទាំងនោះកុំខាន និងសង្កេត ឲ្យដឹងអំពីកិរិយា ឬមន្ត ចំណេះវិជ្ជាការរបស់ស្ដេចទាំងនោះផង

---

ល្មួច = ឯងជាចោរ)ៗ ស្មេរ <សរសេរ +ម (អ្នកសរសេរ, អ្នកធ្វើការសរសេរកត់ត្រា លុប សរ ខាងដើម)ៗ ស្មូម<សូម +ម (អ្នកសូម, អ្នកធ្វើការសូម ឱ)ៗល។ ជួនប្រើពាក្យ អ្នក នាំមុខមូលបទឬកិរិយាសព្ទ ក៏ហៅថា ការកនាម ដែរ ដូច ធ្វើ អ្នកធ្វើ, លួច អ្នកលួច, ប្លន់ អ្នកប្លន់ៗ

ហើយបញ្ជូនពត៌មានមកឲ្យខ្ញុំ។ ចូរអ្នករស់នៅទីនោះចុះ ចំណែកកូនប្រពន្ធរបស់ពួកអ្នក គឺខ្ញុំធានាប៉ាច់ផងចិញ្ចឹមថែរក្សារហូតអ្នកចប់បេសកកម្ម"។

និយាយដូច្នេះហើយ លោកបានឆ្លាក់អក្សរឲ្យជាប់នៅលើកុណ្ឌល[១១០]ខ្លះ ទ្រនាប់ជើងខ្លះ ព្រះខាន់ខ្លះ សុវណ្ណមាលា[១១១]ខ្លះ ប្រគល់ឲ្យពួកទាហាននាំយកទៅដោយអធិដ្ឋានក្នុងចិត្តថា "ពេលណាខ្ញុំមានរឿងហេតុអ្វីកើតឡើង សូមឲ្យខ្ញុំដឹងរឿងហេតុទាំងនោះ យ៉ាងជាក់ច្បាស់ ដោយសារវត្ថុទាំងនេះ"។

ពួកទាហានបានធ្វើដំណើរទៅតាមស្រុកទេសតាមទិសដៅរៀងៗខ្លួន ហើយបានថ្វាយបណ្ណាការដល់ស្តេចនៃប្រទេសទាំងនោះ។ កាលបើស្តេចភូមិភាគទាំងនោះ សួរថាអ្នកមកដើម្បីអ្វី? ពួកទូតទាំងនោះបានក្រាបទូលស្តេចថា ពួកទូលបង្គំមកដើម្បីបម្រើព្រះអង្គ តែប៉ុណ្ណោះ។ កាលបើស្តេចសួរថាមកពីណា? ពួកគេមិនក្រាបទូលពីទីកន្លែងដែលខ្លួនមកតាមត្រង់ទេ ពួកគេក្រាបទូលស្តេចថា មកពី

---

១១០ កុណ្ឌល កុន-ឌល់ សំ.បា. (ន.) ប្រដាប់សម្រាប់ពាក់ត្រចៀក មានទំហូ, ការ ជាដើម។

១១១ សុវណ្ណមាលា កម្រងផ្កាមាស; ខ្សែមាស។

កន្លែងនេះកន្លែងនោះផ្សេងវិញ។ កាលបើស្ដេចយល់ព្រមឲ្យនៅ ពួកគេក៏នៅគាល់បម្រើព្រះអង្គ ធ្វើជាជនឈ្លបការណ៍បង្កប់ខ្លួនក្នុងព្រះរាជវាំងរបស់ស្ដេចទាំងនោះ។

**សេកនរំសារ**

គ្រានោះ នៅដែនកបិលរដ្ឋ មានស្ដេចមួយអង្គនាមថា **សង្ខពល** បានឲ្យរាជបុរសត្រៀមអាវុធជាច្រើន និងកេណ្ឌប្រមូលទាហានឲ្យមកជួបជុំគ្នាយ៉ាងច្រើនកុះករ។ បុរសឈ្លបការណ៍របស់មហោសថ ដែលបានបង្កប់ខ្លួនក្នុងសម្នាក់ស្ដេចនោះ បានបញ្ជូនសារទៅលោកសេនាប្រមុខ[១១២]មហោសថថា៖

"បពិត្រលោកសេនាបតី ខ្ញុំមិនដឹងព្រឹត្តិការណ៍នៅទីនេះថា នឹងប្រព្រឹត្តទៅយ៉ាងណាទេ ស្ដេចនៅនគរនេះ បានឲ្យទាហានត្រៀមអាវុធជាច្រើន ហើយនិងកេណ្ឌ[១១៣]កម្លាំងទ័ពយ៉ាងច្រើន

[១១២] **សេនាប្រមុខ ឬសេនាបតី** មានន័យថា មេទ័ព ដូចគ្នា។

[១១៣] កេណ្ឌ ( កិ. ) បង្គាប់, ប្រមូលហៅរកដោយអាជ្ញា : កេណ្ឌពល, កេណ្ឌរទេះ។ ធ្លាប់ប្រើជា កែន ក៏មាន។

សូមលោក បញ្ជូនពួកឈ្លបពិសេសមក ទើបអាចដឹងនូវតថភាព[១១៤]នៃព្រឹត្តិការណ៍នេះ"។

លំដាប់នោះ មហោសថហៅសត្វសេកមួយរបស់លោកមកប្រាប់ថា៖

"នែសម្លាញ់អើយ ស្តេចព្រះនាមសង្ខពល នៅដែនកបិលរដ្ឋបានឲ្យពួកទាហានត្រៀមអាវុធជាច្រើន។ ឯងចូរទៅទីនោះ ស្វែងយល់[១១៥]អំពីការណ៍ពិត ថាតើស្តេចអង្គនោះបម្រុងនឹងធ្វើអ្វីរួចហើយ ហើរមើលតាមសកលជម្ពូទ្វីបនាំពត៌មាន[១១៦]ឲ្យខ្ញុំ"។

---

[១១៤] **តថភាព** សេចក្តីពិត, ភាពជាក់ស្តែង, ការណ៍មិនកុហក, ថា **តថតា** ក៏បាន។

[១១៥] **ស្វែងយល់** ស្វែងរកឲ្យយល់នូវអ្វីដែលខ្លួនមិនដឹង ឲ្យដឹងឡើង។ សូមប្រយត្ន ប្រើពាក្យនេះកុំឲ្យច្រឡំទៅនឹងពាក្យ **ឈ្វេងយល់** ព្រោះន័យខុសគ្នាស្រឡះដូចមេឃនិងដី **ឈ្វេងយល់** គឺយល់ដោយប្រាជ្ញាថ្លៃថ្លាខ្ពង់ខ្ពស់ បីដូចទឹកថ្លាឈ្វេងធ្លុះរូបភាពអ្វីច្បាស់ ប្រាកដល្អ ប្រើចំពោះតែពុទ្ធាទិបណ្ឌិតប៉ុណ្ណោះ។

[១១៦] ខ្ទះសរសេរ ព័ត៌មាន។ ចំពោះពាក្យខ្មែរព្យាង្គមួយ ប្រើវណ្ណយុត្តិបានតែមួយប៉ុណ្ណោះ ទោះក្លាយពីប្រភពអ្វីក៏ដោយ នឹងដាក់វណ្ណយុត្តិពីរមិនត្រូវ នាំឲ្យតែស្មុគស្មាញទទេ ដូច ធម្ម ជាខ្មែរថា ធម៌, គត្ត ថា គត៌, វណ្ណ ថា ពណ៌, យើងមិនប្រើ ធ័ម៌, គ័ត៌, ព័ណ៌ ទេ ។ ទោះបីយើងមិនដាក់ " ័ " ក៏វាមានលក្ខណៈស្មរគ្រប់គ្រាន់ដោយអំណាច " ៌ " មួយនេះស្មើនឹង " ័ + រ " ស្រាប់ហើយ ខុសគ្នាត្រង់ថាយើងប្រើ " ៌ " ជាមួយនឹងពាក្យក្លាយពីបាលី ឯពាក្យខ្មែរមួយចំនួនដែលមានស្មរដូច " ៌ " នេះ ហើយមានអក្សរ "រ" នៅខាងចុង គឺយើងប្រើ " ័ " នេះវិញ ដូច ទំព័រ, ញ័រ, ខ្ញ័រ,

បានបញ្ហាដូច្នេះហើយ លោកសេនាប្រមុខមហោសថ ឲ្យសេក ស៊ីលាជលាយទឹកឃ្មុំ ផឹកទឹកលាយទឹកឃ្មុំ លាបប្រេងដែលគេ ចម្អិន ១០០ដង ១.០០០ដង ត្រង់ចន្លោះស្លាប ហើយលោកដើរ ទៅឈរត្រង់សីហបញ្ជរ[១១៧]ទិសខាងកើត រួចព្រលែង[១១៨]សេក នោះឲ្យហើរទៅៗ រីឯសត្វសេកហើរទៅទីនោះ យល់ការណ៍ពិត នៃព្រឹត្តិការណ៍របស់ព្រះរាជាអង្គនោះអំពីសម្នាក់ចារបុរសនោះ ហើយ ក៏បានហើរឃ្លាំមើលស្ថានការណ៍ទូទាំងជម្ពូទ្វីបរហូតដល់

---

សង្ស័រឃលឃ ដូច្នេះនឹងឃើញថា ដាក់វណ្ណយុត្តិបានតែមួយប៉ុណ្ណោះឃ ពត៑មាន < វត្ត + មាន, វ ជា ព, ដើង ត ផ្លាស់ជា “ ៑ ” = ពត៑ + មាន = ពត៑មានឃ ចំពោះ ពាក្យ ព្យាង្គមួយ អក្សរនៅក្រោម “ ៑ ” ជាព្យញ្ជនៈអ្វីក៏ដោយ មិនជាសំខាន់ មិនបាច់ គិតអានវាទេ គិតតែអក្សរដើមបូកនឹង “ ៑ = ័ + រ ” ឧ. ធម៑ = ធ័រ, គក៑ = គ័រ, ពណ៑ = ព័រឃ ម, ក, ណ នៅក្រោម “ ៑ ” ស្លាប់ស្ងួរ យើងមិនគិតឃ ប៉ុន្តែបើមាន ព្យាង្គណានៅបន្ទាប់ ចាំបាច់ត្រូវតែអាន ដូច ទុព៑ល (ទុរពល់), ទុគ៑ត (ទុរគត់)ឃលឃ ដូច្នេះ ពាក្យ ពត៑មាន នេះ អក្សរ ត នៅក្រោម “ ៑ ” ត្រូវអានថា **ព័រដមាន** ព្រោះ **ត** របស់បាលីអានជាសំនៀងដខ្មែរជាដរាបដូចពន្យល់ខាងដើមរួចហើយ ហាមអាន ព័ររមាន ព្រោះ “ ៑ ” នោះ ក្តោបស្នូរជាមួយនឹងអក្សរខាងដើមអស់សិទ្ធិស្នូរជាអ្វី ទៀតហើយឃ

[១១៧] បន្ទួចដែលមានរង្វង់ស្រដៀងនឹងជំហរនៃសត្វសីហៈឃ

[១១៨] បណ្តោយឲ្យទៅតាមការ, បើកអំណាចឲ្យចេញឃ

រាជធានីមួយឈ្មោះថា **បញ្ចាលនគរ** ឋិតនៅភូមិភាគខាងជើងក្នុងដែនកបិលវត្ថុ។

**ចូឡនីព្រហ្មទត្តស្តេចបញ្ចាលនគរ**

ក្នុងនគរបញ្ចាល មានព្រះរាជាមួយអង្គ ព្រះនាមថា **ចូឡនីព្រហ្មទត្ត** កំពុងសោយរាជ្យ។ ស្តេចអង្គនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះថា **កេវដ្ដៈ** ជាទីប្រឹក្សាអ្នកថ្វាយទស្សនៈហេតុផលចំពោះព្រះរាជា និងជាបណ្ឌិតឈ្លាសវៃក្នុងនយោបាយនិងយុទ្ធសាស្ត្រផងដែរ។

ក្នុងថ្ងៃមួយកេវដ្ដព្រាហ្មណ៍បានភ្ញាក់ឡើងពីព្រលឹមស្រាងៗ គាត់គយគន់ក្នុងបន្ទប់ដែលតុបតែងស្អាតបាត គាត់បានឃើញយសដ៏ធំរបស់ខ្លួន ហើយគិតថា "យសនេះអញបានដោយខ្លួនឯង ឬបានដោយសារនរណា?" ស្រាប់តែគិតឃើញថា "យសដ៏ធំរបស់អញនេះ មិនមែនបានដោយខ្លួនឯងទេ គឺព្រះបាទចូឡនីព្រហ្មទត្ត ទ្រង់ព្រះរាជទានឲ្យដូច្នេះគួរតែអញជួយជ្រោមជ្រែងលើកតម្កើងស្តេចអង្គនេះ ឲ្យបានឡើងឋានៈជាអគ្គរាជ រីឯអញក៏នឹងបានឡើងតំណែងជាអគ្គបុរោហិតដែរ"។ លុះគិតឃើញដូច្នេះហើយ កេវដ្ដព្រាហ្មណ៍នោះបានងូតទឹកពីព្រលឹមពិសាភោជន៍ និងតុបតែងខ្លួនរួចធ្វើដំណើរទៅកាន់សម្នាក់របស់ព្រះរាជាក្រាបទូលសួរអំពីការផ្ទំរបស់ព្រះរាជាដូច្នេះថា៖

"បពិត្រព្រះសម្មតិទេព ព្រះអង្គផ្ទំសុខព្រះកាយឬទេ?"

"អើបណ្ឌិត! យើងផ្ទំស្រួល" ស្តេចត្រាស់តប។

"បពិត្រព្រះសម្មតិទេព ទូលបង្គំមានយោបល់ដែលត្រូវពិភាក្សា ក្រាបទូល" កេវដ្តព្រាហ្មណ៍ក្រាបទូលស្តេច។

"មានប្រសាសន៍មកចុះ លោកអាចារ្យ" ស្តេចទ្រង់ត្រាស់។

"បពិត្រព្រះសម្មតិទេព រឿងអាថ៌កំបាំងមិនអាចពិភាក្សាខាងក្នុងនគរបានទេ គួរតែយាងទៅឧទ្យានវិញ ក្រាបទូល" កេវដ្តៈទូល។

"ល្អណាស់ លោកអាចារ្យ" ព្រះរាជាទ្រង់តប។

ថាដូច្នេះហើយ ព្រះរាជាបានយាងទៅកាន់ឧទ្យានជាមួយនឹងកេវដ្តព្រាហ្មណ៍ រៀបចំកម្លាំងកងទ័ពឲ្យនៅយាមពីខាងក្រៅយ៉ាងហ្មត់ចត់ ស្តេចទ្រង់គង់ប្រថាប់លើសិលាមង្គលមួយផ្ទាំង។

គ្រានោះ សេកមើលឃើញកិរិយានោះ គិតថា "ជាក់ជាមានហេតុការណ៍អ្វីក្នុងទីនុ៎ះមិនខាន។ ថ្ងៃនេះ អញពិតជាបានឮពត៌មានខ្លះដែលបណ្ឌិតកេវដ្តៈក្រាបទូលថ្វាយស្តេចពុំខាន"។ គិតដូច្នេះរួច ក៏ហើរចូល

ទៅកាន់ឧទ្យាន ទំពួនសំងំ[១១៩]ក្នុងចន្លោះស្លឹកឈើសាលព្រឹក្សមង្គល។

**នយោបាយកាន់កាប់ទឹកដី**

ព្រះរាជាទ្រង់ត្រាស់ថា៖

"ចូរមានប្រសាសន៍មកចុះ លោកអាចារ្យ"។

កេវដ្តព្រាហ្មណ៍ក្រាបទូលស្តេចថា៖

"បពិត្រមហារាជ សូមទ្រង់ផ្ទៀងសោតាព្រះអង្គឲ្យនៅទីនេះតែម្យ៉ាង ព្រោះនឹងមានមន្តចតុក្កណ្ណ[១២០]គឺមន្តកលល្បិចដែលមានតែត្រចៀក ៤ ប៉ុណ្ណោះដឹងឮ គឺជាព្រះកាណ៌[១២១]របស់ព្រះអង្គពីរនិងត្រចៀករបស់ទូលបង្គំពីរ ក្រៅពីនេះ ពុំចាំបាច់ឲ្យមានបុគ្គលណាមួយដឹងឮឡើយ។ មហាបពិត្រ ប្រសិនបើព្រះអង្គទ្រង់សព្វព្រះហឫទ័យធ្វើតាមអនុសាសន៍របស់ទូលបង្គំ ព្រះអង្គ

---

[១១៩] កុំសរសេរ សម្ងំ បែបនេះឡើយ ព្រោះពាក្យនេះក្លាយពីឫសពាក្យ ងំ ជាព្យាង្គរាយទេ ដូច្នេះ កម្លាយរបស់វា ក៏ត្រូវសរសេររាយដែរ ឧ. ងំ>សំងំ។ ងាប់>រំងាប់។ ពាក្យណាក្លាយពីឫសពាក្យព្យាង្គតម្រួត ដូច ស្ងាត់ ស្ងាប់ ស្គាល់ ។ល។ កម្លាយរបស់វាក៏ត្រូវសរសេរត្រួតដែរ ស្ងាត់>សម្ងាត់។ ស្ងាប់>សម្ងាប់។ ស្គាល់>សម្គាល់។

[១២០] ចតុក្កណ្ណោ មន្តោ ភិជ្ជតិ។ ចតុក្កណ្ណ ត្រូវអានថា ចៈ-តុក-កាន់។

[១២១] ត្រចៀក។ ពាក្យ កាណ៌ នេះ ប្រើជារាជសព្ទ។

នឹងអាចក្លាយទៅជាស្ដេចអគ្គរាជ ធំលើស្ដេចផែនដីទាំងឡាយ ក្នុងសកលជម្ពូទ្វីបយើងនេះបាន"។

ព្រះបាទចូឡនីព្រហ្មទត្ត ហេតុតែទ្រង់ល្មោភខ្លាំងគ្រាន់តែឮពាក្យរបស់អាចារ្យនោះភ្លាម ទ្រង់មានក្ដីសោមនស្សត្រាស់ថា៖

"អញ្ជើញនិយាយមកចុះ លោកអាចារ្យ យើងប្រាកដជាធ្វើតាមពាក្យរបស់លោក"។

កេវដ្តព្រាហ្មណ៍ក្រាបទូលថា៖

"បពិត្រព្រះសម្មតិទេព ជាដំបូងយើងត្រូវកេណ្ឌទាហានទៅឡោមព័ទ្ធនគរតូចៗជុំវិញរាជ្យ រីឯខ្ញុំមានតួនាទីជាអ្នកបញ្ចុះបញ្ចូល នឹងចូលទៅនគរតាមទ្វារតូចហើយក្រាបទូលស្ដេចក្នុងនគរផ្សេងៗថា 'បពិត្រមហារាជ ព្រះអង្គមិនចាំបាច់ធ្វើចម្បាំងទេ សូមព្រះអង្គចុះចូលជាចំណុះរបស់ស្ដេចនៃទូលបង្គំចុះ។ រាជសម្បត្តិនៅតែជារាជ្យរបស់ព្រះអង្គដដែលទេ ប៉ុន្តែបើព្រះអង្គច្បាំងវិញ ប្រាកដជាបរាជ័យចាញ់ពួកទូលបង្គំពុំខាន ពីព្រោះកងទ័ពនិងពាហនៈរបស់ពួកទូលបង្គំមានចំនួនច្រើនលើសលប់ ថាបើ ព្រះអង្គធ្វើតាមពាក្យទូលបង្គំ យើងនឹងអនុគ្រោះព្រះអង្គ តែបើច្បាំងគ្នា មិនធ្វើតាមវិញនោះ ព្រះអង្គប្រាកដជាក្ស័យជន្មា។

ធ្វើដូច្នេះ យើងនឹងយកកងទ័ពរបស់ស្ដេចនគរទាំងនោះ រួមបញ្ចូលគ្នាជាមួយនឹងកងទ័ពរបស់យើង បានជាកម្លាំងពីរនគរទៅដណ្ដើមយកនគរដទៃទៀត លុះបាននគរមួយ ទៅដណ្ដើមយកនគរមួយទៀតៗ ដោយឧបាយនេះ ពួកយើងនឹងដណ្ដើមរាជសម្បត្តិបានទូទៅទាំងសកលជម្ពូទ្វីប ក្រាបទូលៗ ចំណែកព្រះអង្គ ផ្ទាល់ត្រូវប្រកាសប្រាប់ស្ដេចទាំងអស់ឲ្យទ្រង់ជ្រាបថា ពួកយើងនឹងផឹកទឹកជយបាន[១២២]រួមគ្នា ហើយនាំស្ដេច ១០១ អង្គ មកកាន់នគរយើង បង្គាប់ជាងឲ្យធ្វើមណ្ឌបស្រាក្នុងឧទ្យានៗ កាលបើ ស្ដេចទាំងអស់គង់ប្រថាប់ក្នុងទីនោះគ្រប់ព្រះអង្គហើយ យើងនឹងអញ្ជើញស្ដេចទាំងនោះឲ្យផឹកស្រាដែលលាយថ្នាំពិស ធ្វើឲ្យស្ដេចទាំងអស់នោះក្ស័យព្រះជន្មសង្ខារ ហើយយើងនឹងយករាជ្យក្នុងនគរទាំង ១០១ មកក្ដាប់ក្នុងអំណាចរបស់យើងទាំងអស់ៗ កាលបើធ្វើបានតាមគម្រោងដូចដែលបានពោលមកនេះ ព្រះអង្គនឹងបានឡើងព្រះឋានៈ ព្រះនាមថា **អគ្គរាជ** ក្នុងសកលជម្ពូទ្វីបជាពុំខាន"ៗ

"ប្រពៃណាស់អាចារ្យ ខ្ញុំនឹងធ្វើតាមយ៉ាងនេះ" ស្ដេចចូឡនីតបៗ

---

[១២២] ទឹកជប់លៀងផឹកពេលឈ្នះសង្គ្រាមៗ

កេវដ្តព្រាហ្មណ៍ទូលបន្តថា៖

"បពិត្រមហារាជ ដែលហៅថា មន្តចតុក្កណ្ណ អ៊ីចឹងឯង គឺមាន តែត្រចៀក ៤ ប៉ុណ្ណោះដែលដឹងឮ គឺព្រះកាណ៌របស់ព្រះអង្គពីរ និងត្រចៀករបស់ទូលបង្គំពីរ។ មន្តនេះឯង គឺអ្នកដទៃមិនអាច ដឹងឮបានឡើយ។ ដូច្នោះ សូមព្រះអង្គកុំបង្អង់នៅទីនេះយូរ សូមទ្រង់ធាប់យានចេញទៅចុះ ក្រាបទូល"។

ព្រះរាជាសព្វព្រះទ័យត្រេកអរជាខ្លាំងហើយទ្រង់ទទួលធ្វើតាមដូច្នោះ។

## សេកផ្ដល់ដំណឹង

សត្វសេក ស្ដាប់ឮដូច្នោះ ក៏ហោតចុះពីលើមែក ជុះអាចម៍មួយ ដុំ ដាក់លើក្បាល[១២៣]កេវដ្តព្រាហ្មណ៍។ កេវដ្តព្រាហ្មណ៍ងើយមើល ធ្វល់ថា ស្អីវាធ្លាក់។ សេកនោះ ក៏បានជុះអាចម៍មួយដុំទៀតឲ្យជ្រុះចំ មាត់កេវដ្តៈ ហើយស្រែកធ្វើសូរក្រិកៗ ហោតហើរពីមែកឈើ ស្រែក ចំអកថា៖

---

[១២៣] ក្បាល ក្លាយអំពីបាលីថា **កបាល** គឺក្បួនខ្មែរឲ្យយកព្យញ្ជនៈទីពីរធ្វើជាជើង ព្យញ្ជនៈទីមួយ ចំពោះពាក្យបាលីមួយចំនួន, មានពាក្យដទៃទៀត ដូច គរុឌ ទៅជា គ្រុឌ, គរុ ទៅជា គ្រូ, ធនុ ទៅជា ធ្នូ ។ល។

“នែកេវដ្ដៈអើយ[១២៤] អ្នកសម្គាល់ថា មន្តរបស់អ្នកជាចតុក្កណ្ណ ឥឡូវវាឡើងដល់ឆក្កណ្ណហើយ បន្តិចទៀត នឹងឡើងដល់អដ្ឋកក្កណ្ណ ហើយនឹងឡើងដល់អនេកសតក្កណ្ណទៀតផង”។

ស្ដេចនិងកេវដ្ដៈស្រែកជំណាលគ្នាថា៖

“ទាហានៗ! ចាប់ៗ!”។

សត្វសេកនោះក៏ហើរដោយសន្ទុះយ៉ាងលឿនដូចខ្យល់ ទៅកាន់ក្រុងមិថិលា រួចចូលទៅកាន់សំណាក់របស់លោកសេនាប្រមុខមហោសថ។ ប៉ុន្តែសត្វសេកនោះ មានទម្លាប់ដូច្នេះ បើដំណឹងណាត្រូវប្រាប់មហោសថតែម្នាក់ វាតែងចុះទំលើចង្កួយស្មា[១២៥]របស់មហោសថ។ បើដំណឹងណាគួរនាងអមរាទេវីឮផង វាទំនៅលើភ្លៅ។ បើដំណឹងណាគួរមហាជនឮផង វាចុះទៅដីនិយាយ។ ពេលនោះ សត្វសេកនោះទៅទំលើចង្កួយស្មារបស់មហោសថ។ ដោយសញ្ញានោះ មហាជនក៏នាំគ្នា

---

[១២៤] “កេវដ្ដ, ត្វំ ចតុក្កណ្ណមន្តោតិ មញ្ញសិ, ឥទានេវ ឆក្កណ្ណោ ជាតោ, បុន អដ្ឋកណ្ណោ ភវិត្វា អនេកសតកណ្ណោបិ ភវិស្សតិ”។

[១២៥] ពាក្យ ចង្កួយ មានន័យថា លំពាស់ឬចុង ដូចយ៉ាងលំពាស់ធ្នូ ឬចុងស្មា ចុងកែងដៃជាដើម ឧ. ចង្កួយធ្នូ ចង្កួយស្មា ចង្កួយដៃ។

ចៀសចេញ ដោយគិតថា "ជាក់ជាមានរឿងអាថ៌កំបាំងអ្វីហើយ"។ មហោសថ ចាប់សេកដើរឡើងទៅជាន់លើបន្ទស់ ហើយសួរថា៖

"តើឯងបានឃើញបានឮស្ថានការណ៍អ្វីខ្លះ?"

"បពិត្រលោកសេនាប្រមុខ ខ្ញុំបាទហើរមើលទូទៅពេញជម្ពូទ្វីប ហើយ ពុំឃើញមានរឿងអាថ៌កំបាំងអ្វីក្នុងសម្នាក់ព្រះរាជាដទៃទេ ប៉ុន្តែកាលមកដល់បញ្ចាលនគរ មានព្រាហ្មណ៍ម្នាក់ឈ្មោះ កេវដ្ដៈ គាត់ឋានៈជាបុរោហិត របស់ព្រះបាទចូឡនីព្រហ្មទត្ត។ គេបាននាំស្ដេចទៅក្នុងឧទ្យាន ហើយបង្រៀនព្រះអង្គអំពីមន្ត ចតុក្កណ្ណ។ កាលបើដូច្នេះ ខ្ញុំទំនៅចន្ទោះមែកឈើមួយក្នុងសួន ព្រះរាជា ឮនស្ដាប់មន្តរបស់ពួកគេ ដរាបដល់ពេលចប់មន្ត ខ្ញុំក៏ជុះអាចម៍ដាក់ ក្បាលដាក់មាត់របស់កេវដ្ដព្រាហ្មណ៍" សេករាយការណ៍។

ប្រាប់ដូច្នេះហើយ សត្វសេកបានបន្តប្រាប់រាល់សម្ដីទាំងអស់ ដែលកេវដ្ដព្រាហ្មណ៍និងស្ដេចជជែកគ្នា។

"តើព្រះបាទចូឡនីយល់ព្រមទេ?" មហោសថសួរ។

"ស្ដេចយល់ព្រម លោកសេនាប្រមុខ" សេកប្រាប់។

## ផែនការការពារប្រទេសជាតិរបស់មហោសថ

គ្រានោះ មហោសថឲ្យចំណីដ៏ល្អមសមគួរឲ្យដល់សត្វសេក ហើយដាក់ឲ្យដេកយ៉ាងស្រួលក្នុងទ្រុងមាសដែលមានទ្រនំក្រាលដោយក្រណាត់សូត្រដ៏ទន់ៗ មហោសថគិតថា "កេវដ្ដៈ មិនដឹងទេឬ? ថាមហោសថអញនេះ ជាបណ្ឌិត? មន្ត្របស់ឯងឥឡូវនេះ អញនឹងមិនឲ្យសម្រេចដល់ទីបំផុតបានឡើយ"ៗ លុះគិតដូច្នេះរួច មហោសថបានចាត់ផែនការណ៍ជម្លៀស[១២៦]គ្រួសារទុគ៌តក្រីក្រទាំងឡាយ ដែលរស់នៅក្នុងក្រុងឲ្យចេញទៅសង់លំនៅឋានខាងក្រៅក្រុងទាំងអស់ និងនាំយកត្រកូល ដែលមានយសសក្តិធំៗអាចសម្រេចកិច្ចការស្រុកទេសបានឲ្យមកតាំងគេហដ្ឋាននៅខាងក្នុងក្រុង ដើម្បីបង្កបង្កើតទ្រព្យធន និងធញ្ញជាតិឲ្យបានកាន់តែច្រើនៗ

## ស្តេចចូឡនីវាតនីកាន់កាប់សកលជម្ពូទ្វីប

ព្រះបាទចូឡនីព្រហ្មទត្ត ជឿតាមពាក្យរបស់កេវដ្ដព្រាហ្មណ៍ ទ្រង់កេណ្ឌអង្គសេនាកងទ័ពទាហានមកជាបរិវារជាច្រើន ហើយចេញ

---

[១២៦] ជម្លៀស ក្លាយពីពាក្យ ឈ្លៀស (កិ.) ដែលមានន័យថា ស្កាត់កែនយកពាហនៈឬយកមនុស្សមកប្រើជារាជការបណ្ដើរសិន ដោយបន្ទាន់ការប្រញឹក ប្រញាប់ : ឈ្លៀសរទេះ, ឈ្លៀសគោ, ឈ្លៀសមនុស្សៗ

ដំណើរទៅឡោមព័ទ្ធនគរតូចមួយៗ ចំណែកកេវដ្ដៈ ចូលទៅក្នុងនគរ តាមវិធីសាស្ត្រដែលគេនិយាយ ដើម្បីបញ្ចុះបញ្ចូលស្ដេចក្នុងប្រទេស នោះ ឲ្យមកជាចំណុះស្ដេចប្រទេសខ្លួន ទទួលបានជោគជ័យមែនៗ ព្រះបាទចូឡនី បានប្រមូលបង្រួបបង្រួមទ័ពទាំងពីរប្រទេសចូលគ្នា ពួត[១២៧]ដៃទៅហ៊ុមព័ទ្ធនគរដទៃមួយទៀត បន្ទាប់ពីនគរនោះៗ ដោយសារតែនយោបាយទុំះឯង ព្រះបាទចូឡនី បានក្ដោបក្ដាប់នគរ ទាំងអស់នោះ តាមលំដាប់ដូចផែនការណ៍របស់កេវដ្ដព្រាហ្មណ៍មែនៗ

នេះសបញ្ជាក់ឲ្យឃើញថា ព្រះបាទចូឡនីព្រហ្មទត្ត ឋិតក្នុងឱវាទ របស់អាចារ្យកេវដ្ដព្រាហ្មណ៍ ហើយបានធ្វើឲ្យស្ដេចផ្សេងៗចូលជា ចំណុះរបស់ខ្លួនបានទូទាំងសកលជម្ពូទ្វីប លើកលែងតែព្រះបាទវិទេហ រាជដែលជាស្ដេចរបស់សេនាប្រមុខមហោសថមួយព្រះអង្គគត់ៗ

---

[១២៧] ពួត (កិ.) ចាប់ក្ដួត, ដុសក្ដួតក្រឡឹងជុំវិញ: ពួតដំបង, ដុសក្អែលពួតៗ ពួតភ្លើង យកកូនពំនួតដាក់ផ្ទប់ពីលើមេពំនួតរុញទាញៗ ដោយប្រឹងសង្កត់ពេញកម្លាំង ដើម្បីឲ្យក្ដៅកើតភ្លើង; (ហៅថា ក្ដួតភ្លើង ក៏មាន តាមទម្លាប់ដោយស្រុក; ប៉ុន្តែបើហៅ ក្ដួត គួរប្រើ ន. ជា កំនួត)ៗ ពួតដៃស្មុះចូល យកបាតដៃម្ខាងចាប់រឹតក្រឡឹងកដៃឬកំភួនដៃ ស្មុះចូលដោយបម្រុងនឹងដាល់ឬទះ, តប់ៗ ព. ប្រ. ពួតដៃគ្នា ចូលគំនិតស្រុះគ្នាធ្វើការប្រណាំងប្រជែងយកឈ្នះៗល។

ចំណែកឯពួកចារបុរសរបស់មហោសថ តែងបញ្ជូនដំណឹងទៅឲ្យលោកសេនាប្រមុខជានិច្ចថា៖

"ព្រះបាទចូឡនីព្រហ្មទត្ត បានកាន់កាប់នគរប៉ុណ្ណេះៗហើយ សូមលោកសេនាប្រមុខ កុំធ្វេសប្រហែសឲ្យសោះ"។

រីឯសេនាប្រមុខមហោសថវិញ តែងបញ្ជូនដំណឹងតបទៅពួកគេវិញថា៖

"ខ្ញុំនៅទីនេះ បានរៀបចំផែនការណ៍មិនមានសេចក្ដីធ្វេសប្រហែសទេ។ សូមពួកលោកកុំបារម្ភ ចូរនៅកុំធ្វេសប្រហែសឲ្យសោះ"។

រាជាណាចក្រក្នុងសកលជម្ពូទ្វីបទាំងអម្បាលម៉ាន គឺសុទ្ធសឹងតែត្រូវព្រះបាទចូឡនីព្រហ្មទត្ត ដណ្ដើមកាន់កាប់បានទាំងអស់ ដោយចំណាយពេលត្រឹមតែ ៧ឆ្នាំ ៧ខែ ៧ថ្ងៃប៉ុណ្ណោះ លើកលែងតែនគរវិទេហៈមួយគត់ ដែលដណ្ដើមមិនទាន់បាន។

## គម្រោងលុកលុយក្រុងមិថិលា

ថ្ងៃមួយ ព្រះបាទចូឡនីព្រហ្មទត្តបានត្រាស់នឹងកេវដ្តព្រាហ្មណ៍ថា៖

"លោកអាចារ្យ ដល់ពេលដែលយើងត្រូវវាយដណ្ដើមកាន់កាប់រាជាណាចក្រវិទេហៈនៅក្រុងមិថិលាហើយ"។

កេវដ្តព្រាហ្មណ៍ បានក្រាបទូលព្រះមហាក្សត្រចូឡនី អំពីគុណសម្បត្តិរបស់លោកសេនាប្រមុខមហោសថ ឲ្យទ្រង់ជ្រាបច្បាស់ ដូចជាព្រះចន្ទដែលបញ្ចេញពន្លឺ ភ្លឺត្រចះត្រចង់ពួងដ៏មេឃា ដោយបរិយាយយ៉ាងពិស្តារដូច្នេះជាដើមថា៖

"បពិត្រមហារាជ ពួកយើងមិនអាចដណ្តើមកាន់កាប់រាជាណាចក្រក្នុងនគរ ដែលមានមហោសថបណ្ឌិតរស់នៅបានទេ ពីព្រោះគេជាមនុស្សបរិបូរដោយបញ្ញាយ៉ាងនេះ ឈ្លាសវៃក្នុងឧបាយកលយ៉ាងនេះ"។

ការពិត អាចារ្យកេវដ្តព្រាហ្មណ៍នេះ ក៏ជាមនុស្សឈ្លាសក្នុងកិច្ចកលឧបាយមិនធម្មតាដែរ។ ដូច្នេះបានជាគេមានសមត្ថភាពអាច ធ្វើឲ្យព្រះរាជាជឿសម្តីរបស់គេដូច្នេះថា៖

"បពិត្រព្រះសម្មតិទេព មិថិលានគរនុ៎ះ ជារដ្ឋតូចតាច រីឯនគរក្នុងសកលជម្ពូទ្វីបដែលយើងកាន់កាប់បានប៉ុណ្ណោះ វាល្មមគ្រប់គ្រាន់សម្រាប់យើងហើយ។ យើងចង់បាននគរកំប៉ិកកំប៉ុក តូចតាចមួយនុ៎ះ មកធ្វើអ្វីទៀត? ចូរយើងទាំងអស់គ្នា ធ្វើពិធីជប់លៀងសោយទឹកជយ ចំពោះការចុះចូលរបស់ស្តេចនគរផ្សេងៗនេះ"។

ចំណែកស្តេចផ្សេងៗ ដែលបានដាក់រាជ្យជាចំណុះនោះទាមទារថា៖

"យើងដណ្ដើមរាជ្យមិថិលានគរឲ្យបានសិន សឹមធ្វើពិធីជប់លៀង សោយទឹកជយបាន សប្បាយឲ្យអស់ដៃ"។

ប៉ុន្ដែការទាមទាររបស់ពួកស្ដេចទាំងនោះ ត្រូវបានលោកកេវដ្ដៈនិយាយជំទាស់ ដោយឧបាយដូច្នេះថា៖

"យើងទៅដណ្ដើមនគរវិទេហៈធ្វើអ្វី សូម្បីស្ដេចវិទេហៈនោះ ក៏ជាចំណុះយើងដែរ ព្រោះហេតុនោះ សូមយាងស្ដេចគ្រប់ៗអង្គត្រឡប់ទៅវិញចុះ"។

ស្ដេចទាំងឡាយនោះ ជឿពាក្យកេវដ្ដៈ ហើយនាំគ្នាត្រឡប់ទៅវិញ។

ពួកចារបុរសបានបញ្ជូនដំណឹងទៅលោកសេនាប្រមុខមហោសថថា៖

"ស្ដេចចូឡនីព្រហ្មទត្ត ដែលមានស្ដេច១០១អង្គជាបរិវារ ប្រុងនឹងធ្វើដំណើរមកកាន់នគរមិថិលា ប៉ុន្ដែឥឡូវទ្រង់ត្រឡប់ទៅនគរព្រះអង្គវិញអស់ហើយ"។

មហោសថបញ្ជូនដំណឹងតបទៅវិញថា ៖

"តាំងពីពេលនេះទៅ សូមពួកលោកសង្កេតឲ្យដឹងអំពីទង្វើរបស់ស្ដេចអង្គនោះ កុំប្រហែសឲ្យសោះ"។

## ផែនការធ្វើគុតស្តេច ១០១ អង្គ ដោយថ្នាំពិស

ព្រះបាទចូឡនីព្រហ្មទត្ត បានប្រឹក្សាជាមួយនឹងកេវដ្ដៈព្រាហ្មណ៍ថា៖

“តើឥឡូវនេះ យើងត្រូវធ្វើដូចម្ដេចទៀត?”

“យើងនឹងរៀបចំពិធីជប់លៀងជយបាន” កេវដ្ដៈទូលថ្វាយ។

ព្រះរាជាទ្រង់បង្គាប់សេវកាមាត្យ[១២៨]ថា៖

“ចូរពួកអ្នកតុបតែងឧទ្យាន រៀបចំស្រា ១០០ ពាង ១.០០០ ពាង និងធ្វើម្ហូបចំណីត្រីសាច់សម្រាប់ក្មេង ត្រៀមឲ្យបានច្រើនមុខ”។

បុរសឈ្លបការណ៍បានបញ្ជូនដំណឹងនោះ ទៅជម្រាបដល់លោកសេនាប្រមុខមហោសថ។ ប៉ុន្តែពួកគេមិនដឹងថាព្រះបាទចូឡនីព្រហ្មទត្ត

---

[១២៨] សេវក : --វ៉ៈក : សំ. បា. (ន.) (សេវក) អ្នកបម្រើ, អ្នកចាំទទួលការបម្រើ, អ្នកគាល់បម្រើ; បរិវារ : ពួកសេវក។ ប្រើស្ត្រីជា សេវិកា។ សេវកជន មនុស្សអ្នកបម្រើ។ សេវកបុរស បុរសអ្នកចាំទទួលការបម្រើ (ក្នុងក្រសួងឬក្រុមរាជការនីមួយ)។ សេវកយោសិត ឬ សេវិកា ស្ត្រីអ្នកចាំទទួលការបម្រើ, ស្ត្រីអ្នកបម្រើ។ សេវកាមាត្យ (--ម៉ាត; សំ. សេវក + អមាត្យ) មន្ត្រីអ្នកគាល់បម្រើព្រះរាជា, មន្ត្រីក្នុងព្រះរាជសំណាក់, ខ្ញុំរាជការជិតព្រះអង្គ (ហៅ រាជសេវក ឬ រាជសេវកាមាត្យ ក៏បាន) ។ល។ (ព. កា.) : រាជសេវក យកចិត្តទុកដាក់បម្រើក្សត្រិយ៍ក្សាន្ត រមែងមានយស ខ្ពង់ខ្ពស់ពុំខាន ព្រោះហេតុទ្រង់បាន សង្កេតចរិយា។

រៀបចំស្រាថ្នាំពិសបង្ក៉ផ្ចើគុត[១២៩]ស្តេចទាំងនោះទេ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ មហោសថ ហេតុតែបានដឹងតថភាពនៃព្រឹត្តិការណ៍នោះ ដោយសារបានស្តាប់ពត៌មានពីសត្វសេក លោកក៏បានបញ្ជូនដំណឹងតបទៅថា៖

"ពិធីជប់លៀងនោះ គឺជាថ្ងៃដែលគេត្រូវឲ្យស្តេចចំណុះទាំងអស់សោយសុរាថ្នាំពិស ពួកអ្នកចូរដឹងកាលបរិច្ឆេទនៃពិធីជប់លៀងនោះ ហើយបញ្ជូនដំណឹងមកឲ្យខ្ញុំ"។

បុរសឈ្លបការណ៍ទាំងឡាយនោះ បាននាំគ្នាធ្វើតាមយ៉ាងដូច្នោះ។

---

[១២៩] កុំច្រឡំពាក្យ គត់ និង គុត។ គត់ មានន័យ ២ យ៉ាងគឺទី១ ដែលត្រឹមស្មើមិនលើសមិនខ្វះ ឧ. ១០ គត់។ ទី២ រាំងមិនឲ្យចូលបាន មិនឲ្យជ្រាបលេចបាន ឧ. វាយគាត់ជាច្រើនដៃ មិនចូលត្រូវគាត់ទាល់តែសោះ គាត់គត់បានរហូត។ ធត្រនេះគត់ភ្លៀងល្អណាស់។ ចំណែកពាក្យ គុត វិញ ថ្នាក់ជាកិរិយា មានន័យថា ប្រហារកាប់ ពិឃាត ធ្វើឃាត សម្លាប់។ ថ្នាក់ជានាម ការប្រហារ -កាប់ -ពិឃាត -ធ្វើឃាត -សម្លាប់។ អ្នកខ្លះប្រើច្រឡំទាំងនិយាយទាំងសរសេរថា ធ្វើគត់ៗ រត់មាត់ ថ្នឹកដៃស្ទើរពេញប្រទេសអស់ទៅហើយ អាចនឹងអស់សំណើចពាក្យ ធ្វើគុត នេះផងក៏មិនដឹង។ យើងខ្ញុំសម្រេចសរសេរបែបនេះ ដោយឃើញនិយមន័យពាក្យគត់និងគុតផ្សេងគ្នា មួយទៀត ក្នុងសាស្ត្រាបុរាណឈ្មោះលក្ខណវង្សមានកាព្យមួយឃ្លាថា "លុះដល់ទីធ្វើគុត ឲ្យនាងលុតព្រះជង្ឃា..."។ ដូច្នេះ គប្បីឈប់ប្រើពាក្យធ្វើគត់នេះតទៅទៀត ត្រូវប្រើ ធ្វើគុត វិញ។

មហោសថបណ្ឌិតគិតថា "កាលបើបុគ្គលដូចជារូបអញនេះ នៅមានជីវិតនៅឡើយ មានគេធ្វើគុតស្តេចទាំង ១០១អង្គនោះ បាន សម្រេច ជារឿងមិនសក្តិសមចំពោះរូបអញទាល់តែសោះ។ អញត្រូវ តែជាទីពឹងរបស់ស្តេចទាំងនោះឲ្យខាងតែបាន"។ លុះគិតដូច្នេះហើយ មហោសថបានបញ្ជាឲ្យហៅមិត្ត ១.០០០ នាក់ ដែលកើតជំណាលគ្នា នឹងខ្លួនឲ្យមកជួបជុំគ្នា ហើយដាក់បទបញ្ជាដូច្នេះថា៖

"នែសម្លាញ់ ឮដំណឹងថា ព្រះបាទចូឡនីព្រហ្មទត្ត ឲ្យអ្នកបម្រើ តុបតែងឧទ្យាន គ្រោងជប់លៀងសោយសុរា ដែលមានស្តេច ចំណុះ ១០១ អង្គជាបរិវារ។ ចូរពួកលោកទៅទីនោះ នៅពេល ក្រាលអាសនៈសម្រាប់ស្តេច ពួកលោកត្រូវបង្គាប់ឲ្យពួកអ្នក បម្រើ ក្រាលអាសនៈសម្រាប់ស្តេចយើងបន្ទាប់ពីស្តេចចូឡនី។ មិនត្រូវឲ្យស្តេចអង្គដទៃ គង់បន្ទាប់ពីស្តេចចូឡនីក្រៅពីស្តេច យើងឡើយ។ បើរាជបុរសទាំងនោះដេញដោលសួរថា តើពួក អ្នកជារាជបុរសស្តេចអង្គណា? ពួកលោកគប្បីប្រាប់គេថា ពួកលោកជារាជបុរសរបស់ព្រះបាទវិទេហរាជ។ បើពួកលោក ប្រាប់យ៉ាងនេះ ពួកគេមុខតែឈ្លោះជាមួយនឹងពួកលោកពុំខាន។ ពួកគេនឹងនិយាយថា "កាលដែលពួកគេដណ្តើមរាជ្យអស់

រយៈពេល ៧ឆ្នាំ ៧ខែ ៧ថ្ងៃ មិនឃើញព្រះបាទវិទេហៈមួយថ្ងៃណាសោះ នុ៎ះជាស្ដេចអ្វី?" ហើយពួកគេនឹងប្រាប់ពួកលោកឲ្យទៅរៀបចំអាសនៈរបស់ស្ដេចយើងនៅឯចុងគេ។ កាលបើពួកគេប្រាប់ឲ្យធ្វើដូច្នេះ ពួកលោកត្រូវតែបន្លឺជម្លោះឲ្យខ្លាំងឡើងថា លើកលែងតែព្រះបាទព្រហ្មទត្ត គ្មានស្ដេចដទៃណានៅទីនេះលើស្ដេចយើងបានទេ។ ពួកលោកបន្លឺជម្លោះហើយ កុំយកឈ្នះពួកគេអី ពួកលោកត្រូវធ្វើជាចាញ់ សុខចិត្តអត់បានអាសនៈសម្រាប់ស្ដេចយើងចុះ តែត្រូវនាំគ្នា ស្រែកឡូឡាទ្រហឹងអឹងកងម្ដងវិញថា ឥឡូវនេះ យើងមិន ឲ្យពួកគេបានផឹកស្រាស៊ីត្រីសាច់ក្លែមទេ។ ហើយចូរបន្ទាចបំភ័យពួកគេឲ្យតក់ស្លុត រួចនាំគ្នាចាប់ដុំដី ដំបងធំៗ វាយបំបែកពាងស្រាចោលឲ្យអស់ ធ្វើឲ្យត្រីសាច់គ្រឿងក្លែមឲ្យរាយប៉ាយ ដើម្បីកុំឲ្យគេស៊ីផឹកកើត។ បន្ទាប់មកពួកអ្នកត្រូវរត់ចូលទៅក្នុងកងទាហាន លោតផ្លោងផ្លោះបោះខ្លួនមកវិញ ឲ្យដូចអសុរវាយលុកចូលទេវនគរព្រះឥន្ទ្រ។ ចូរអ្នកទាំងឡាយស្រែកប្រាប់ពួកគេឲ្យ បានស្គាល់ខ្លួនពួកអ្នកគ្រប់គ្នាផងថា "ពួកអញជាកងទ័ពរបស់ លោកសេនាប្រមុខមហោសថបណ្ឌិត នៅឯនគរមិថិលា បើពួកឯងក្លាហានដេញតាមពួកអញមកចុះ"។

មិត្តទាំង ១.០០០ នាក់ បានទទួលការណែនាំរបស់មហោសថរួច លើកដៃសំពះជម្រាបលា ហើយបំពាក់អាវុធទាំង៥[១៣០]នាំគ្នាចេញដំណើរទៅកាន់ប្រទេសរបស់ព្រះបាទចូឡនីព្រហ្មទត្ត ចូលទៅក្នុងឧទ្យានដែលតុបតែងស្អាតដូចទន្ទនវនឧទ្យាននៅឯត្រៃត្រិង្ស ឃើញនូវសិរីសម្បត្តិ

---

[១៣០] អាវុធ --វុត បា.; សំ. (ន.) (អាយុធ) គ្រឿងប្រហារឬគ្រឿងចម្បាំងផ្សេងៗដែលទីទៃពីសស្ត្រា : ធ្នូ, ស្នា, កាំភ្លើង,... ហៅថា អាវុធ; ដាវ, លំពែង, ផ្គាក់,... ហៅថា សស្ត្រា។ (ព. កា.) : ទាហានមោះមុត ដែលមានអាវុធ ជាប់នៅក្នុងដៃ កាលបើបានជួប ចោរកាចចង្រៃ មិនសូវសំចៃ ច្រើនតែគំរាម។ ព្រោះមានអាវុធ សម្រាប់ប្រយុទ្ធ ពុំដែលទីមទាម ប្រទះសត្រូវ ច្រើនតទល់ក្លាម ស៊ូប្តូរសាច់ឈាម ពុំដែលរុញរា។ ការពារប្រទេស ពុំដែលមានធ្វេស គួររាស្ត្រប្រជា ជួយឧបត្ថម្ភ គាំទ្រយោធា ដោយក្តីស្នេហា ស្រឡាញ់ទាហាន។ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃ អ. ថ. --ធ :, ដូចជា អាវុធករ អ្នកធ្វើអាវុធ, ជាងធ្វើអាវុធ។ អាវុធកោដ្ឋាគារ, អាវុធាគារ ឬ អាយុធគ្រឹះ, អាយុធាគារ ឃ្លាំងអាវុធ ឬ ឃ្លាំងដាក់គ្រឿងសស្ត្រាវុធ។ អាវុធយុទ្ធភណ្ឌ (--វុត-យុត-ធ :ភាន់) គ្រឿងអាវុធនិងភណ្ឌៈសម្រាប់ចម្បាំង។ អាវុធសន្និច្ច័យ ការសន្សំអាវុធទុកឬការសាងគ្រឿងសស្ត្រាវុធទុក (បម្រុងការពារប្រទេស) : ធ្វើអាវុធសន្និច្ច័យ។ អាវុធសាលា សាលារៀនធ្វើអាវុធឬរោងធ្វើគ្រឿងសស្ត្រាវុធ។ អាវុធហត្ថ (--ធ :--) អ្នកកាន់អាវុធ; ទាហានដែលមានអាវុធក្នុងដៃ គឺសេនាទាហានពួកមួយដែលប្រដាប់ដោយអាវុធ ជាអ្នកដើរត្រួតត្រាការពារនិងរក្សាសេចក្តីសុខសាន្តក្នុងស្រុក : ពួកអាវុធហត្ថបានប្រតិបត្តិការយ៉ាងម៉ឺងម៉ាត់ (ហៅ ខ្លាន់អាវុធ ក៏បាន) ។ល។ (ម. ព. សស្ត្រ ផង)។

ដែលតុបតែងយ៉ាងស្អាត មានតាំងពីការលើកឡើងនៃស្វេតច្ឆត្រ និង តម្រៀបរាជបល្ល័ង្កសម្រាប់ស្តេចទាំង ១០១ អង្គជាដើម ហើយពួកគេ បានធ្វើនូវកាតព្វកិច្ចទាំងពួង តាមគម្រោងការណ៍របស់មហោសថ។ មិត្តទាំង ១.០០០ នាក់ បានពញាក់បំភ័យបន្ទាចមហាជនឲ្យតក់ស្លុត ហើយក៏នាំគ្នាកៀសខ្លួនគេចចេញពីតំបន់នោះ ឆ្ពោះមុខឈមទៅកាន់ ក្រុងមិថិលាវិញ។ ចំណែករាជបុរសទាំងឡាយ បាននាំយកព្រឹត្តិការណ៍ នោះ ទៅធ្វើសេចក្តីរាយការណ៍ថ្វាយស្តេចរៀងៗខ្លួន។

ព្រះបាទចូឡនីព្រហ្មទត្ត ទ្រង់ពិរោធថា៖

> "មិនគួរណាអន្តរាយកើតឡើងដូច្នេះសោះ ធ្វើឲ្យខូចគម្រោងការ ស្រាថ្នាំពិសរបស់អញបែបនេះអស់ទេ"។

រីឯស្តេចចំណុះផ្សេងៗ ដែលមិនដឹងថាខ្លួននឹងត្រូវស្លាប់ ដោយសារផឹក ស្រាថ្នាំពិស ក៏ខឹងក្រេវក្រោធជេរប្រទេចថា៖

> "អាចង្រៃយក្ស មិនគួរណាធ្វើឲ្យពួកអញ ខានជប់លៀងសោយ ជយបាន ខានផឹកស្រាស៊ីត្រីសាច់ក្លែមធ្ងាញ់អឺចឹងសោះ"។

ចំណែកមេទាហាននិងកូនទាហានទាំងឡាយតូចចិត្តនឹកស្តាយថា៖

"មិនគួរណាយើងខានផឹកស្រា ដែលមិនគិតថ្លៃយ៉ាងនេះសោះ ពិតជាស៊ិយមែន"។

**សង្គ្រាមនៅក្រុងមិថិលា**

ព្រះបាទចូឡនីព្រហ្មទត្ត ហៅព្រះរាជាទាំងឡាយមកប្រាប់ថា៖

"នែកនយើង តោះទៅក្រុងមិថិលាកាត់ក្បាលព្រះបាទវិទេហរាជដោយព្រះខាន់ រួចយកជើងជាន់ឈ្លី ហើយយកក្បាលមកទ្រាប់អង្គុយសោយទឹកជយបាន។ ហ៍ សូមព្រះអង្គគ្រប់អង្គកេណ្ឌកងទាហានត្រៀមដំណើរចេញ"។

លុះព្រះបាទចូឡនី ទ្រង់បង្គាប់ស្តេចទាំងឡាយយ៉ាងនេះហើយ ព្រះអង្គទ្រង់យាងទៅក្នុងទីស្ងាត់ បញ្ជាក់ប្រាប់កេវដ្ដៈម្ដងទៀតថា៖

"នែលោកអាចារ្យ យើងនឹងចាប់សត្រូវដែលបំផ្លាញផែនការរបស់យើងឲ្យបាន។ យើងមានទាហាន ១៨ អក្ខោភិនី[១៣១]

[១៣១] ពាក្យ អក្ខោភិនី ជាឈ្មោះមហាចតុរង្គសេនា គឺក្បួនកងទ័ពជើងគោកធំៗ ៤ ប្រភេទក្នុងបុរាណសម័យគឺ ១-ទ័ពដំរីចំនួន ២១.៨៧០, ២-ទ័ពសេះចំនួន ៦៥.៦១០, ៣-ទ័ពរថប្បរទេះ ចំនួន ២១.៨៧០, ៤-ទ័ពថ្មើរជើងចំនួន ១០៩.៣៥០ រួមទាំងគ្រឿងអាវុធយុទ្ធភណ្ឌគ្រប់បែបយ៉ាង។ ចំនួនកងទ័ពទាំង៤កងធំៗនេះ ហៅថា ១ អក្ខោភិនី

របស់ស្តេចទាំង ១០១ អង្គទៅជាមួយផង។ តោះយើងទៅ លោកអាចារ្យ”។

បណ្ឌិតកេវដ្តព្រាហ្មណ៍ គិតថា “មិនអាចយកជ័យជម្នះលើ មហោសថបណ្ឌិតបានទេ មុខតែពួកយើងខ្មាសគេជាក់ជាពុំខាន អញត្រូវតែពន្យល់ព្រះអង្គឲ្យប្តូរព្រះទ័យវិញ”។ គិតដូច្នេះហើយ ទើបកេវដ្ត: ក្រាបទូលស្តេចថា៖

“បពិត្រមហារាជ អ្នកបំផ្លាញផែនការនោះ មិនមែនជាស្តេច វិទេហៈទេ គឺមហោសថជាអ្នកបំផ្លាញផែនការរបស់យើង ក្រាបទូល។ មហោសថនុ៎ះ មានអំណាចខ្លាំងណាស់ គេមាន ឋានៈជាសេនាបតី មានមុខងារគ្រប់គ្រងរក្សានគរមិថិលា បីដូច រាជសីហ៍រក្សាគុហា[១៣២] គ្មាននរណាម្នាក់អាចចាប់គេបានទេ។ បើយើងហ៊ានទៅ មុខតែខ្មាសគេមិនខាន, កុំទៅទីនោះអី ក្រាបទូល”។

---

បូកសរុបទៅស្មើនឹង ២១៨.៧០០។ ដូច្នេះកងទ័ព១៨អក្ខោភិនី យកចំនួន ២១៨.៧០០ × ១៨ = ៣.៩៣៦.៦០០។ ម្យ៉ាងទៀត អក្ខោភិនី ជាចំនួនមួយរយសែនទិន្នហុត។

[១៣២] គុហា (គុហ៑ា) សំ. បា. (ន.) រូងធំដែលកើតឯងក្នុងភ្នំ : យោគីធ្វើសមណធម៌ក្នុងគុហា។

រីឯព្រះបាទចូឡនី ដោយហេតុតែទ្រង់ស្រវឹងនឹងអំណាច ហើយអួតក្អេងក្អាងថា អញជាអគ្គរាជ អញធំជាងគេក្នុងលោក ទ្រង់បានត្រាស់ថា៖

"មហោសថនោះ នឹងធ្វើអ្វីអញកើតទៅ?"

ហើយទ្រង់ដឹកនាំស្តេច ១០១ អង្គជាបរិវារ ចេញដំណើរទៅជាមួយនឹងទាហានចំនួន ១៨ អក្ខោភិនី។

ចំណែកឯកេវដ្ដៈ កាលមិនអាចពន្យល់ព្រះរាជា ឲ្យយល់សម្ដីរបស់ខ្លួនបាន ក៏សម្រេចចិត្តតាមដង្ហែព្រះរាជាដែរ ដោយគិតថា "ការមានទស្សនៈផ្ទុយពីស្តេចរបស់ខ្លួន ព្រោះហេតុតែព្រះអង្គមិនយកយោបល់ខ្លួន មិនសមទេ"។

ទាហានទាំងឡាយរបស់ព្រះបាទចូឡនីអង្គនោះ បានធ្វើដំណើរទៅដល់ក្រុងមិថិលា ដោយចំណាយរយៈពេលត្រឹមតែមួយរាត្រីប៉ុណ្ណោះ ហើយព្រះបាទចូឡនីព្រហ្មទត្ត បានឲ្យអ្នកនាំសារអំពីការប្រកាសសង្គ្រាមដែលព្រះអង្គបម្រុងនឹងធ្វើ ដល់មហោសថបណ្ឌិតជាមុន។ តាមពិតមហោសថបានជ្រាបដំណឹងនេះជាមុនរួចស្រេចទៅហើយ តាមរយៈពួកចារបុរសរបស់លោក។ ដ្បិតចារបុរសទាំងឡាយតែងបញ្ជូនដំណឹងទៅមហោសថជាប់ៗមិនដាច់ថា៖

"ព្រះបាទចូឡនីព្រហ្មទត្ត មកជាមួយនឹងស្ដេច ១០១ អង្គជាបរិវារ ក្នុងគោលបំណងចាប់ព្រះបាទវិទេហរាជ។ សូមលោកបណ្ឌិត កុំធ្វេសប្រហែស។ ថ្ងៃនេះ ស្ដេចយាងដល់កន្លែងនោះ ថ្ងៃនេះ ស្ដេចយាងដល់កន្លែងនេះ ថ្ងៃនេះស្ដេចនឹងយាងដល់នគរហើយ"។

ក្រោយពីឮដំណឹងដូច្នោះ លោកសេនាប្រមុខមហោសថបាន ប្រុងជើងការ មិនមានការធ្វេសប្រហែសឡើយ។ ចំណែកឯព្រះបាទ វិទេហរាជវិញ គ្រាន់តែបានឮដំណឹងតៗគ្នាថា៖

"ព្រះបាទចូឡនីព្រហ្មទត្ត កំពុងមកលុកលុយកាន់កាប់នគរ មិថិលាហើយ"។

គ្រានោះ ព្រះបាទចូឡនី ហេតុតែកើតកំហឹងក្រពុលមុខខ្លាំង ទ្រង់យាងដោយទ្រោលប្រទីប១០០.០០០ បញ្ជាទាហានឲ្យនៅព័ទ្ធជុំវិញ នគរទាំងមូល ដាក់ទាហានមួយកងៗ នៅកន្លែងនេះ កន្លែងនោះ មាន កងដំរី កងរថជាដើម រៀបទាហានធ្វើជាកំពែងឡោមព័ទ្ធជុំវិញនគរ នោះ។ ពួកទាហាន ដែលឈរឡោមព័ទ្ធទាំងនោះ បាននាំគ្នាទះដៃ ស្រែកហ៊ោកញ្ជ្រៀវ ទ្រហឹងអឺងកងរំពង លោតកញ្ជ្រោល ស្រែកគំរាម សន្ធាប់ដោយសម្រែកខ្លាំងៗ។ ដោយសារតែពន្លឺនៃប្រទីប និងដោយ សារឱភាសនៃគ្រឿងអលង្ការ ក្រុងមិថិលាដែលមានទំហំដី ៧ យោជន៍

បានទទួលពន្លឺ ចាំងចូលគ្នាតែមួយ ភ្លឺសាយទូទៅ។ ដោយសារស្នូរដើរ សេះ រថ និង តូរ្យតន្ត្រីប្រឡប់ចូលគ្នា វាហាក់ដូចជាផែនដីរញ្ជួយស្ទើរ តែប្រេះបែក។

បណ្ឌិត ៤ នាក់ មានបុក្កុសៈជាដើម បានឮសំឡេងទ្រហឹងអឹង កងរំពង មិនយល់ថាមានហេតុការណ៍អ្វីកើតឡើង ក៏នាំគ្នាទៅកាន់ សម្នាក់របស់ព្រះមហាក្សត្រ ក្រាបទូលថា៖

“បពិត្រមហារាជ ពួកទូលបង្គំយើងខ្ញុំមិនដឹងថាមានហេតុការណ៍ អ្វីកើតឡើងទេ សូមព្រះអង្គទ្រង់ពិចារណា ក្រាបទូល”។

ព្រះបាទវិទេហៈ ទ្រង់ព្រះសណ្ដាប់ដូច្នោះ ព្រះអង្គបើកសីហបញ្ជរ នឹកក្រែងលោថា ស្ដេចចូឡនីព្រហ្មទត្តយាងមកពិតប្រាកដមែនឬយ៉ាង ណា? ពេលនោះ ទ្រង់ចោលព្រះនេត្រាសម្លឹងមើលទៅឯក្រៅ ក៏យល់ ជាក់ប្រាកដថា ស្ដេចចូឡនីលើកទ័ពមកមែន ទ្រង់មានព្រះទ័យភ័យ តក់ស្លុត ក៏មានរាជតម្រាស់ជាមួយនឹងអាចារ្យទាំង ៤ នាក់នោះថា៖

“ពួកយើងមុខតែស្លាប់ ពួកយើងមុខតែអស់ជីវិតមិនខាន”។

**ព្រះបាទវិទេហៈខ្លាចចម្បាំងស្ដេចចូឡនី**

ចំណែកលោកសេនាប្រមុខមហោសថវិញ ដឹងថាស្ដេចចូឡនី លើកទ័ពមកដល់ក្រុងមិថិលាហើយ លោកមិនខ្វាចញញើត ស្លុតចិត្ត ព្រឺរោម ញាប់ញ័រអ្វីបន្តិចឡើយ។ លោកមានសេចក្ដីអង់អាចក្លាហាន បីដូចរាជសីហ៍ ព្រោះលោកបានរៀបចំផែនការយាមរក្សាយ៉ាងហ្មត់ចត់ ទូទៅទាំងរាជធានីរួចរាល់ហើយ។ លោកទៅកាន់ព្រះបរមរាជវាំង ឡើងទៅព្រះរាជនិវេសន៍ ក្នុងគោលបំណងទូលព្រះរាជា កុំឲ្យទ្រង់ស្លុតព្រះទ័យ ហើយលោកឈរក្នុងទីដ៏សមគួរ។

ព្រះរាជា គ្រាន់តែឃើញលោកសេនាប្រមុខមកក្លាម ទ្រង់បានធូរព្រះទ័យបន្តិច ព្រះអង្គទ្រង់ព្រះតម្រិះថា "ក្រៅពីមហោសថបណ្ឌិតកូនអញ គ្មានអ្នកណាមានសមត្ថភាពអាចជួយអញឲ្យរួចចាកទុក្ខ បែបនេះបានទេ"។ ហើយព្រះអង្គ ទ្រង់ពិភាក្សាជាមួយនឹងលោកសេនាប្រមុខមហោសថ ដូច្នេះថា៖

"ម្នាលមហោសថ ស្ដេចចូឡនីព្រហ្មទត្តនៃក្រុងបញ្ចាល ទ្រង់កេណ្ឌទ័ពដ៏ច្រើនរាប់មិនអស់ មកធ្វើចម្បាំងជាមួយនគរយើងហើយ។ ទ័ពទាំងនោះ មានពលដាំងឈើ និងពលថ្មើរជើង សុទ្ធតែជាអ្នកឈ្លាសក្នុងសង្គ្រាម អាចវាយលុក សម្រុកចូល

ទៅកាត់ក្បាលពួកទាហានរបស់សត្រូវ មិនឲ្យសត្រូវដឹងខ្លួនជាមុនឡើយ ជាទ័ពមានសំឡេងសន្ធាប់លាន់ព្ទចូលទៅក្នុងសង្គ្រាម ធ្វើឲ្យទ័ពសត្រូវភ័យតក់ស្លុត ម្យ៉ាងទៀត អាចញ៉ាំងគ្នានឹងគ្នាឲ្យដឹងដោយសំឡេងស្គរនិងសង្ខ។ ទ័ពទាំងនោះ មានវិជ្ជាផ្នែកចម្រាញ់លោហៈ មានគ្រឿងប្រដាប់ មានទង់ជ័យ មានមនុស្សអ្នកឡើងកាន់ពាហនៈខាងឆ្វេង សុទ្ធតែជាអ្នកស្ទាត់ជំនាញក្នុងការធ្វើសង្គ្រាម។ ចំណែកពួកសេនាដ៏ក្លៀវក្លាអង់អាចទាំងនោះ មានភាពតស៊ូខ្លាំងស្មើនឹងសត្វសីហៈ។ ក្នុងនោះ មាននាយពល ១០ នាក់ ជាអ្នកឈ្លាស មានប្រាជ្ញាទូលំទូលាយ តែងតែទៅប្រឹក្សាជាមួយនឹងមាតារបស់ស្តេចចូឡនី ក្នុងទីស្ងាត់។ ព្រះរាជ-មាតានេះ ត្រូវបានចាត់ជាអ្នកប្រាជ្ញទី ១១។ ព្រះនាងតែងប្រៀនប្រដៅពួកសេនាក្នុងក្រុងបញ្ចាល។ សេនាទាំង ១០ នាក់នោះ ត្រូវបានពួកទាហានហៅថាបណ្ឌិត ព្រោះពួកគេមានប្រាជ្ញាទូលំទូលាយស្មើនឹងផែនដី។ បណ្ឌិតទាំងនោះ តែងណាត់ជួបពិភាក្សាគ្នាក្នុងទីស្ងាត់។ កាលពួកគេគិតជំនុំគ្នាតែមួយថ្ងៃឬពីរថ្ងៃ អាចធ្វើឲ្យផែនដីប្រែប្រួលបាន អាចចាប់អាកាសបាន។ អ្នកប្រាជ្ញទី ១១ គឺព្រះមាតារបស់ស្តេចចូឡនីព្រហ្មទត្ត ព្រះនាងមានប្រាជ្ញាវាងវៃ ជាងអ្នកទាំង ១០ នាក់ហ្នឹងទៅទៀត។

ព្រះនាងតែងបណ្ណែ[១៣៣]ផ្តល់អនុសាសន៍ ដល់ពួកសេនាក្នុងក្រុងបញ្ចាល។ មានរឿងតំណាលថា ក្នុងថ្ងៃមួយ បុរសម្នាក់កាន់អង្ករមួយនាឡិ បាយមួយកញ្ចប់ និងប្រាក់ ១.០០០ កហាបណៈ ចុះស្ទឹងហែលឆ្លងទៅត្រើយម្ខាង បានពាក់កណ្តាលស្ទឹង ហែលទៅមុខលែងរួច ក៏បានស្រែករកមនុស្សដែលឈរនៅត្រើយម្ខាងទៀតឲ្យជួយថា 'នែអ្នកអើយ នៅដៃខ្ញុំមានអង្ករមួយនាឡិ បាយមួយកញ្ចប់និងប្រាក់ ១.០០០ កហាបណៈ បណ្តារបស់ទាំង ៣ នេះ ខ្ញុំនឹងឲ្យរបស់ណាមួយដែលជាទីគាប់ចិត្តនៃខ្ញុំ ឲ្យតែអ្នកណាមួយហ៊ានមកជួយចម្លងខ្ញុំឲ្យឆ្លងផុតពីស្ទឹង'។ គ្រានោះ មានបុរសម្នាក់ មានកម្លាំងខ្លាំង ចងក្បិនយ៉ាងមាំ ចុះក្នុងស្ទឹង ហែលទៅចាប់ដៃបុរសនោះ ជួយចម្លងឲ្យដល់ត្រើយម្ខាង រួចពោលថា 'ចូរឲ្យរបស់ដែលត្រូវឲ្យដល់ខ្ញុំ'។ បុរសម្ចាស់របស់និយាយថា 'អ្នកចូរយកចុះ អង្ករមួយនាឡិក៏បាន បាយមួយកញ្ចប់ក៏បាន'។ បុរសអ្នកជួយថា 'ទេសម្លាញ់ ខ្ញុំមិនគិតដល់ជីវិតរបស់ខ្ញុំផង ហើយខំហែលទៅជួយចម្លងអ្នកឲ្យឆ្លងផុតគ្រោះថ្នាក់ ខ្ញុំមិនត្រូវការអង្ករ ឬបាយនេះទេ ចូរអ្នក

---

[១៣៣] និយាយណែឲ្យយល់ គឺនិយាយជាតម្រុយជាទំនងលំអានឲ្យល្មមយល់បាន ឧ.កុំ តែបានបងបណ្ណែការហ្នឹង ប្រហែលជាឥតកើតទេ។

ឲ្យប្រាក់ដល់ខ្ញុំវិញ’។ ម្ចាស់របស់តបថា ‘ខ្ញុំបាននិយាយថា ខ្ញុំនឹងឲ្យរបស់ណាដែលជាទីគាប់ចិត្តខ្ញុំ បណ្តា របស់ទាំង ៣ នេះ។ ឥឡូវ ខ្ញុំឲ្យរបស់ជាទីគាប់ចិត្តខ្ញុំហើយតើ បើអ្នកត្រូវការ ចូរអ្នកយកចុះ’។ អ្នកជួយមិនសុខចិត្ត ក៏បានប្រាប់មនុស្សម្នាក់ដែលឈរនៅក្បែរនោះ។ សូម្បីមនុស្សឈរក្បែរនោះ ក៏និយាយថា ‘គេឲ្យឯងនូវរបស់ជាទីគាប់ចិត្តខ្លួនគេហើយ ឯងចូរយកចុះ’។ អ្នកជួយនៅមិនសុខចិត្តដដែល ក៏នាំម្ចាស់របស់ទៅកាន់ទីវិនិច្ឆ័យដើម្បីជម្រាបរឿងក្តីដល់វិនិច្ឆយាមាត្យ។ សូម្បីវិនិច្ឆយាមាត្យស្តាប់រឿងក្តីអស់ហើយ ក៏កាត់ក្តីអ៊ីចឹងដដែល។ អ្នកជួយមិនសុខចិត្តនឹងការកាត់ក្តីនោះ ក៏បាននាំម្ចាស់របស់នោះ ទៅកាន់សម្នាក់របស់ព្រះរាជា ក្រាបទូលរឿងរ៉ាវនោះឲ្យទ្រង់ជ្រាប។ ព្រះរាជាក៏បានឲ្យគេទៅអញ្ជើញពួកវិនិច្ឆយាមាត្យ លុះទ្រង់ព្រះសណ្តាប់រឿងអ្នកទាំងពីរហើយ ទ្រង់មិនដឹងកាត់ក្តីយ៉ាងម៉េច ក៏កាត់ក្តីឲ្យបុរសអ្នកលះបង់ជីវិតខ្លួន ហែលទៅជួយចម្ពងនោះឲ្យបាញ់ ដូចពួកវិនិច្ឆយាមាត្យដែរ។ ក្នុងខណៈនោះ ព្រះមាតារបស់ស្តេចចូឡនីព្រះនាម **ចលាកទេវី** គង់នៅក្បែរនោះ បានឮការកាត់ក្តីមិនយុត្តិធម៌របស់ស្តេច ក៏មានព្រះសវនីយ៍ថា ‘នែបុត្ររឿងក្តីនេះ លុះត្រាតែដឹងច្បាស់លាស់ជាមុនសិន ទើប

អាចវិនិច្ឆ័យបានល្អ'។ ព្រះបាទចូឡនីត្រាស់ថា 'បពិត្រព្រះមាតា បុត្រចេះដឹងតែប៉ុណ្ណោះឯង សូមព្រះមាតាជួយវិនិច្ឆ័យ'។ ព្រះនាង ទ្រង់ព្រះសវនីយ៍ថា យើងនឹងវិនិច្ឆ័យឲ្យបានល្អ ក៏ឲ្យគេហៅម្ចាស់របស់នោះចូលគាល់។ គ្រានោះ ព្រះនាងប្រាប់ឲ្យរៀបរបស់ទាំង ៣ មុខ តាមលំដាប់នៅលើដី រួចសួរម្ចាស់របស់នោះថា 'នែអ្នក កាលអ្នកកំពុងហែលទឹក អ្នកនិយាយថាម៉េចនឹងបុរសអ្នកជួយនេះ?' គេបានក្រាបទូលព្រះនាងតាមដំណើររឿងថា 'ទូលបង្គំ នឹងឲ្យរបស់ណាមួយដែលជាទីគាប់ចិត្តរបស់ទូលបង្គំ'។ ព្រះនាងបានបង្គាប់ថា 'បើដូច្នោះ ចូរអ្នកចាប់យករបស់ណាដែលគាប់ចិត្តអ្នកចុះ'។ ម្ចាស់របស់ចាប់យកស្បោងប្រាក់ ១.០០០ កហាបណៈ។ ពេលគេដើរទៅបានបន្តិច ព្រះនាងបញ្ជាគេឲ្យហៅម្ចាស់របស់នោះមកវិញ រួចសួរថា 'នែអ្នកប្រាក់ ១.០០០ កហាបណៈនេះ គាប់ចិត្តអ្នកឬទេ?' 'ព្រះករុណាថ្លៃវិសេសព្រះម៉ែម្ចាស់' ម្ចាស់របស់ទូលតប។ ព្រះនាងសួរបន្តទៀតថា 'តើអ្នក ពិតជាបានពោលនឹងបុរសនេះថា អ្នកនឹងឲ្យរបស់ជាទីគាប់ចិត្ត អ្នកមែនឬមិនមែន?' 'អ៊ីចឹងមែនព្រះម៉ែម្ចាស់' ម្ចាស់របស់ទូល តបវិញ។ ព្រះនាងសម្រេចកាត់ក្ដីថា 'បើអ៊ីចឹងអ្នកចូរឲ្យប្រាក់ ១.០០០ កហាបណៈ

នេះដល់បុរសដែលជួយអ្នកនោះទៅវាជា ការត្រឹមត្រូវហើយ"។ ស្រាប់តែម្ចាស់របស់ស្រែកយំខ្សឹកខ្សួល ប្រគល់ប្រាក់ឲ្យទៅអ្នកជួយ។ ខណៈនោះ ព្រះរាជានិងអាមាត្យត្រេកអរសរសើរប្រាជ្ញាដ៏ប្រសើររបស់ព្រះរាជមាតា។ តាំងពីគ្រានោះមក ភាពជាបណ្ឌិតរបស់ព្រះនាងបានល្បីល្បាញខ្ចរខ្ចារ សាយព្រះកិត្តិនាមទៅគ្រប់ទិសតំបន់។ បណ្ដាមហាជនព្រមទាំងក្សត្រិយ៍ ១០១ អង្គជាចំណុះព្រះបាទចូឡនីព្រហ្មទត្ត ដែលទ្រង់ដណ្ដើមដែនបាន។ ស្ដេចទាំងនោះខ្លាចស្លាប់ ក៏ព្រមនៅក្រោម អំណាចនៃព្រះបាទចូឡនីព្រហ្មទត្ត។ ស្ដេចទាំង ១០១ អង្គនោះ ឋិតក្រោមបញ្ជារបស់ស្ដេចចូឡនីព្រហ្មទត្ត ទោះបីពួកទ្រង់មិនគាប់ព្រះទ័យក៏ដោយ ក៏ព្រមធ្វើតាមព្រះបាទចូឡនីព្រហ្មទត្តគ្រប់យ៉ាង ដោយហេតុតែពួកទ្រង់ធ្លាក់ក្នុងអំណាចនៃព្រះបាទព្រហ្មទត្តនោះទៅហើយ។ ឥឡូវនេះ មិថិលានគររបស់ពួកអ្នកវិទេហៈត្រូវពួកសេនារបស់ស្ដេចចូឡនីឡោមព័ទ្ធជា ៣ ជាន់ ជុំវិញយ៉ាងមាំ។ មានសាស្ត្រាវុធព្រោងព្រាតដូចជាផ្កាយ។ ម្នាលមហោសថបាសម្លាញ់ តាំងពីអវិចីដល់ព្រហ្មលោក គ្មានបណ្ឌិតណាឈ្លាសក្នុងឧបាយកលប្រាកដស្មើអ្នកទេ។ ភាពជាបណ្ឌិតរបស់អ្នក តែងល្បីរន្ទឺក្នុងគ្រាមានអាសន្ន។ ហើយយើងជឿជាក់

ថា អ្នកនឹងមានមធ្យោបាយដោះសោចក្ដីទុក្ខនេះបាន តើអ្នកមាន
មធ្យោបាយដូចម្ដេច?”

**មហោសថបន្ធើលសត្រូវ**

មហោសថឮព្រះរាជបន្ទូលដ៏ទន់របស់ព្រះរាជាហើយ លោកគិតថា “ស្ដេចអង្គនេះខ្លាចចំពោះមរណភ័យខ្លាំងណាស់ៗ ពិតណាស់ពេទ្យជាទីពឹងរបស់អ្នកជំងឺ ភោជនជាទីពឹងរបស់មនុស្សអ្នកឃ្លានៗ ទឹកជាទីពឹងរបស់មនុស្សអ្នកស្រេកៗ លើកលែងរូបអញចេញ គ្មានអ្នកណាជាទីពឹងដល់ព្រះរាជាអង្គនេះទេៗ អញត្រូវតែទូលព្រះអង្គ អំពីផែនការដែលអញបានរៀបចំទុកជាស្រេច ដើម្បីឲ្យព្រះអង្គបានធូរព្រះទ័យ” គិតដូច្នេះហើយ មហោសថបានក្រាបទូលស្ដេច បីដូចរាជសីហ៍បន្លឺសីហនាទនៅលើផ្ទាំងមនោសិលាថា៖

> “កុំខ្លាចអី មហាបពិត្រ សូមព្រះអង្គសោយរាជ្យជាសុខចុះ
> ក្រាបទូល ទាហានចំនួន ១៨ អក្ខោភិនីរបស់ស្ដេចចូឡនីទ៌ុះ
> ប្រៀបបីដូចក្អែកពាំដុំដី និងដូចស្វាកាន់ដួ គឺទូលបង្គំជាខ្ញុំនឹង
> បង្អើលឲ្យរត់ រប៉ាត់រប៉ាយ បាត់មេ បាត់កោយ អាចបាត់ទាំង
> ខោស្លៀកជាប់នឹងចង្កេះផងក៏ថាបាន”ៗ

ហើយលោកបានពោលបញ្ជាក់ថា៖

"បពិត្រព្រះទេវៈ សូមព្រះអង្គទ្រង់សណ្ដូកព្រះបាទឲ្យស្រួលចុះ សូមព្រះអង្គទ្រង់ក្រសាលរីករាយក្នុងកាមចុះៗ ស្ដេចចូឡនី ព្រហ្មទត្ត មុខជានឹងរត់ចោលទាហានរបស់ខ្លួនមិនខាន"ៗ

លោកសេនាប្រមុខមហោសថ ក្រាបទូលលួងលោមព្រះរាជា កុំឲ្យភ័យព្រួយបារម្ភយ៉ាងនេះហើយ លោកថ្វាយបង្គំលាចុះពីរាជនិវេសន៍ បញ្ជាឲ្យពួកទាហានដើរទូងស្គរទូទាំងនគរ ប្រកាសសេចក្ដីជូនដំណឹងចំពោះអ្នកនគរថា៖

"បពិត្រម៉ែឪបងប្អូនទាំងឡាយ សូមលោកទាំងឡាយកុំគិតព្រួយខ្លាចអ្វី សូមរៀបចំកម្រងផ្កា និងគ្រឿងក្រអូប គ្រឿងលាប បាយទឹកជាដើម លេងមហោស្រព ៧ ថ្ងៃចុះៗ សូមមនុស្សទាំងឡាយគ្រប់តំបន់ នាំគ្នាផឹកស៊ីតាមសប្បាយ សូមលេងរបាំរាំច្រៀងទះដៃស្រែកហ៊ោកញ្ជ្រៀវទ្រហឹងអឺងកងចុះៗ ឯប្រាក់ចំណាយក្នុងពិធីសប្បាយនេះ ទុកឲ្យខ្ញុំមហោសថ ធានារ៉ាប់រងចំណាយចុះ អស់លោកនឹងឃើញនូវអានុភាពខ្ញុំពុំខាននៅពេលនោះ"ៗ

អ្នកក្រុងទាំងឡាយ បាននាំគ្នាធ្វើបាយទឹក នំចំណីចំណុកជាដើម លេងមហោស្រពទូទាំងក្រុងយ៉ាងគគ្រឹកគគ្រេងៗ គ្រានោះមនុស្សទាំងឡាយ ដែលនៅខាងក្រៅក្រុង កាលដែលបានឮសំនៀងចម្រៀង ការ

ដេញជំប្រគំកូតជាដើម បាននាំគ្នាចូលទៅកាន់នគរតាមទ្វារតូចៗ ដើម្បីលេងកម្សាន្តសប្បាយ។ ទាហានរបស់មហោសថ មិនចាប់ប្រជាជនទូទៅ ដែលចូលទៅលេងកម្សាន្តនោះទេ លើកលែងតែសត្រូវ។ ព្រោះហេតុនោះ ដំណើរទៅមករបស់មនុស្ស ជាប់ៗគ្នាមិនដាច់ក្រសែឡើយ។ មនុស្សដែលចូល ទៅកាន់នគរ តែងបានមើលឃើញអ្នករបាំស្រីប្រុសដែលលេងនៅលើឆាកមហោស្រពគ្រប់ៗគ្នា។

ចំណែកស្ដេចចូឡនីព្រហ្មទត្ត ទ្រង់ឮសំឡេងមហោស្រពហើយ ព្រះអង្គត្រាស់នឹងអាមាត្យយ៉ាងនេះថា៖

"នែអស់លោក កាលបើយើងមកបោះទីតាំងនៅឡោមព័ទ្ធនគរដោយទាហាន ១៨ អក្ខោភិនី ពួកអ្នកនគរមិនមានសេចក្ដីភ័យខ្លាច មិនមានសេចក្ដីអៀនខ្មាស[១៣៤]បន្តិចសោះ។ ពួកគេបែរជាអរសប្បាយរីករាយក្អាកក្អាយ ទះដៃស្រែកហ៊ោកញ្ជ្រៀវរាំច្រៀងទៅវិញ។ ព្រោះហេតុអ្វីបានជាពួកគេធ្វើដូច្នេះ?"

គ្រានោះ អ្នកឈ្លបការណ៍ទាំងឡាយរបស់មហោសថ បានក្រាបទូលបង្វែងជានស្ដេចចូឡនី ដោយមុសាវាទយ៉ាងនេះថា៖

---

១៣៤ សារជ្ជំ។

“បពិត្រព្រះសម្មតិទេព ពួកទូលបង្គំជាខ្ញុំ បានចូលទៅកាន់នគរតាមទ្វារតូចដោយមានការងារខ្លះៗ ហើយឃើញមនុស្សប្រុសស្រីកំពុងនាំគ្នាលេងសប្បាយក្នុងពិធីមហោស្រព បានសួរពួកគេដែរថា នែអស់លោក ស្តេចជាធំក្នុងសកលជម្ពូទ្វីបទ្រង់លើកទ័ពមកឡោមព័ទ្ធនគររបស់អស់លោកអស់អ្នក ជុំវិញអស់ហើយប៉ុន្តែពួកអ្នកវិញ ហេតុអ្វីពួកអ្នកធ្វេសប្រហែសខ្លាំងម្ល៉េះ នាំគ្នាលេងសប្បាយទៅវិញ? បពិត្រព្រះសម្មតិទេព ពួកអ្នកនគរទាំងនោះ គេបានប្រាប់ពួកទូលបង្គំយ៉ាងនេះថា ព្រះរាជារបស់ពួកគេ មានសេចក្តីប្រាថ្នាតាំងអំពីកុមារវ័យថា បើនគររបស់ព្រះអង្គត្រូវស្តេចសកលជម្ពូទ្វីបយកធ្វើជាចំណុះ ព្រះអង្គនឹងឲ្យពួកអ្នកនគរលេងមហោស្រព ក្នុងថ្ងៃនេះ សេចក្តីប្រាថ្នារបស់ស្តេចពួកគេបានសម្រេចតាមគោលបំណងហើយ។ ហេតុនោះស្តេចពួកគេបានចេញរាជបញ្ញា ឲ្យទូងស្គរប្រកាសជាដំណឹងឲ្យអ្នកនគរនាំគ្នាលេងមហោស្រព។ រីឯស្តេចវិទេហរាជវិញ ក៏ទ្រង់កំពុងប្រារព្ធពិធីជប់លៀងកម្សាន្តយ៉ាងសប្បាយជាមួយនឹងពួកមន្ត្រីក្នុងប្រាសាទទេវាវិនិច្ឆ័យ[១៣៥]ផងដែរ”។

---

[១៣៥] បាលីត្រង់នេះ **មហាតលដ្ឋាន** បានដល់បន្ទប់ប្រជុំធំទូលាយរបស់ព្រះមហាក្សត្រ

ព្រះបាទចូឡនីព្រហ្មទត្ត ឮសម្ដីពួកអ្នករាយការណ៍ដូច្នោះ ទ្រង់ខ្វាល់ទៅ ហើយបញ្ជាសេនាទាហានថា៖

"ទាហាន ទៅបិទនគរនេះឲ្យជិតគ្រប់ច្រកទាំងអស់ឲ្យធាប់ ទម្លាយស្នាមភ្លោះ ទម្លាយកំពែង បំបែកទ្វារនិងប៉ម សម្រុកចូលក្នុងនគរ កាត់ក្បាលមហាជនដឹកដោយរទេះមកដូចក្អមទឹកចុះ កាត់ក្បាលស្ដេចវិទេហរាជយកមកឲ្យយើងឲ្យបានផង"។

ព្រះរាជបញ្ជាដូច្នោះហើយ ពួកទាហានក្លៀវក្លា មានអាវុធគ្រប់ដៃ ស្ទុះទៅបានដល់ត្រឹមតែជិតទ្វារ ក៏ត្រូវទទួលគ្រោះថ្នាក់ ដោយពួកទាហានរបស់លោកសេនាប្រមុខមហោសថចាក់ក្រួស ខ្សាច់ និងភក់ពីលើមក និងប្រានជណ្ដើរឲ្យជ្រួលរលំត្រឡប់ទៅវិញ មិនឲ្យពួកខ្មាំងទាំងនោះឡើងមកលើកំពែងបានឡើយ។ ទាហានទាំងនោះក៏នាំគ្នារត់ត្រឡប់ក្រោយវិញ។ ពួកទាហានណា ដែលកំពុងចុះស្នាមភ្លោះថានឹងទៅទម្លាយកំពែង ក៏ត្រូវទាហានខាងមហោសថដែលឈរយាមល្បាត

---

ឬរបស់ឧត្តមមន្ត្រី ដែលមានកន្លែងមួយផ្នែកសម្រាប់នរណាម្នាក់ឡើងឈរថ្លែងសុន្ទរកថាផ្សេងៗ ក្នុងពិធីប្រជុំ។ ដូច្នេះយើងសម្រេចប្រែពាក្យនេះថា ប្រាសាទទេវា-វិនិច្ឆ័យឬព្រះរាជមន្ទីរ គឺបានដល់ប្រាសាទជាទីប្រជុំធំដែលមានព្រះសម្មតិទេព គង់ជាប្រធាន។ អង់. (dias)។

តាមប៉មចន្លោះៗនោះ បាញ់ព្រួញ បាញ់ធ្នូ បោះពួយលំពែង ពួយច្បូក ជាដើម ធ្វើឲ្យស្លាប់និងរបួសជាច្រើននាក់ៗ ទាហានទាំងឡាយរបស់លោកសេនាប្រមុខមហោសថ ធ្វើកាយវិការឌឺដងដាក់ទាហានរបស់ស្តេចចូឡនីព្រហ្មទត្ត ថែមទាំងជេរផ្តាសាគំរាម ដោយប្រការផ្សេងៗ។ ខ្លះក៏លើកស្រា ខ្លះក៏លើកត្រីសាច់អាំងជន្ទប់ញែមថា "ពួកឯងលំបាកហើយ មិនបានបាយស៊ី ហ៏ផឹកបន្តិចទៅ ហ៏ស៊ីត្រីអាំងសាច់អាំងទៅ" ថាដូច្នេះហើយ ក៏ផឹកស៊ីដោយខ្លួនឯងទៅវិញ ហើយដើរទៅដើរមកលើកំពែងតូចៗនោះ។

ពួកទាហានរបស់ព្រះបាទចូឡនីព្រហ្មទត្ត កាលមិនអាចធ្វើអ្វីទៅលើទាហានមហោសថកើត ក៏នាំគ្នាត្រឡប់ទៅកាន់សម្នាក់របស់ស្តេចចូឡនីព្រហ្មទត្តវិញ ក្រាបទូលស្តេចឲ្យទ្រង់ជ្រាបថា៖

"បពិត្រព្រះសម្មតិទេព លើកលែងតែអ្នកមានឫទ្ធិ គឺគ្មានបុគ្គលណាអាចកម្ចាត់កម្ចាយពួកនោះបានទេ ក្រាបទូល"។

ព្រះបាទចូឡនីចូលមកដល់ទឹកដីវិទេហរដ្ឋ អស់រយៈពេលពីរបីថ្ងៃហើយ ប៉ុន្តែមិនអាចរកឱកាសចូលទៅចាប់ព្រះបាទវិទេហរាជបានសោះ ដូច្នេះទ្រង់ក៏សួរកេវដ្តព្រាហ្មណ៍ថា៖

"លោកអាចារ្យ អស់រយៈពេលពីរបីថ្ងៃហើយ យើងនៅតែមិនអាចវាយលុកដណ្ដើមយកនគរនេះបាន សូម្បីតែទាហានម្នាក់ក៏គ្មានសមត្ថភាពចូលទៅរួច តើយើងត្រូវធ្វើដូចម្ដេចវិញ?"

"មិនជាអ្វីទេ មហាបពិត្រ ដែលហៅថាទីក្រុង គឺតែងមានទឹកនៅខាងក្រៅ ចាំពេលនគរនោះអស់ទឹកសិន សឹមយើងច្បាំងដណ្ដើមយក។ មនុស្សទាំងឡាយ កាលលំបាកដោយទឹកប្រាកដជាបើកទ្វារក្រុងពុំខាន" កេវដ្ដៈឆ្លើយ។

"អើអើ! មានឧបាយល្អហើយតើ" ស្ដេចសព្វព្រះរាជហឫទ័យ។

តាំងពីគ្រានោះមក ព្រះបាទចូឡនីព្រហ្មទត្តទ្រង់បានឲ្យគេផ្ដាច់ប្រព័ន្ធទឹកទាំងអស់លែងឲ្យមានចូលទៅខាងក្នុងទីក្រុង។

បុរសឈ្លបការណ៍របស់មហោសថ សរសេរសំបុត្រមួយច្បាប់ចងជាប់នឹងចុងសរ(ព្រួញ) ហើយបាញ់បញ្ជូនពត៌មាននោះទៅ។ ចំណែកឯមហោសថ ក៏បានបញ្ជាទាហានរបស់ខ្លួនទុករួចជាស្រេចហើយថា៖

"ជនណាក៏ដោយឲ្យតែឃើញសំបុត្រជាប់ព្រួញ ត្រូវយកមកឲ្យខ្ញុំជាបន្ទាន់"។

គ្រានោះ បុរសម្នាក់ឃើញសំបុត្រជាប់ព្រួញ ក៏យកទៅជូនមហោសថ។ មហោសថអានដឹងពត៌មាននោះ គិតថា "ពួកនេះមិនដឹងថាអញជាបណ្ឌិតទេដឹង?" ហើយបានបញ្ជាឲ្យគេពុះឫស្សីជាពីរចំហៀង ប្រវែង ៦០ ហត្ថ ចាំងលួសថ្នាំងស្អាត បានផ្គុំបវាជាមួយគ្នាវិញ យកស្បែកចង រួចលាបកក់ពីលើ និងឲ្យអ្នកជំនាញកសិកម្មយកពូជស្នៅ ផ្កាឈូកស ដែលឥសីអ្នកមានឫទ្ធិនាំមកអំពីព្រៃហិមពាន្តមកដាំ នៅលើកក់ក្បែរស្រះបោក្ខរណី ហើយបង្គាប់ឲ្យដាក់ឫស្សីពីលើ ចាក់ទឹកឲ្យពេញ។ ក្នុងរយៈពេលត្រឹមតែមួយរាត្រី ផ្កាឈូកសដុះឡើងទៅលើខ្ពស់ផុតពីចុងឫស្សីប្រវែងមួយហត្ថ។

គ្រានោះ មហោសថប្រាប់ទាហានខ្លួនឲ្យលើកយកឫស្សីនោះទៅថ្វាយដល់ព្រះបាទចូឡនីព្រហ្មទត្ត។ ពួកទាហានបានសែងឫស្សីនោះបោះពីលើកំពែងទៅ ដោយនិយាយថា៖

> "នែវ៉ៃយ ពួកអាខ្ញុំព្រះបាទរបស់ស្តេចព្រហ្មទត្ត កុំស្លាប់ដោយសេចក្តីឃ្លាន ចូរយកផ្កាឈូកសនេះទៅតែងខ្លួនចុះ ហើយចូរស៊ីឫស្សីនេះឲ្យពេញពោះផងទៅ"។

ឫស្សីនោះ គឺបុរសឈ្លបការណ៍របស់មហោសថម្នាក់ បានយកទៅថ្វាយស្តេចចូឡនី ហើយក្រាបទូលថា៖

"បពិត្រព្រះសម្មតិទេព សូមទ្រង់ទតឫស្សីនេះ ពីដើមមក ពួកទូលបង្គំមិនធ្លាប់ឃើញឫស្សីវែងអ៊ីចឹងសោះ"។

"ពួកអ្នកចូរវាស់វាមើល" ស្ដេចចូឡនីត្រាស់បញ្ជា។

ពួកបុរសឈ្លបការណ៍របស់មហោសថ បានវាស់ឫស្សី ប្រវែង ៦០ ហត្ថនោះ បន្ទំបន្ថិតឲ្យវែងដល់ទៅ ៨០ ហត្ថ។

ស្ដេចចូឡនីសួរថា៖

"ឫស្សីនោះដុះនៅឯណា?"

បុរសឈ្លបម្នាក់ ក្រាបទូលកុហកថា៖

"បពិត្រព្រះសម្មតិទេព ទូលបង្គំជាខ្ញុំចង់ផឹកសុរា បានចូលទៅនគរតាមទ្វារតូច ដើម្បីរកសុរាផឹក ក៏បានប្រទះឃើញស្រះបោក្ខរណីដ៏ធំ ដែលធ្វើដើម្បីយកទឹកប្រើប្រាស់ ងូត និងហែលលេងកម្សាន្ត សម្រាប់អ្នកក្រុងទាំងមូល។ មនុស្សម្នាជិះទូកកាច់ ផ្កាជាច្រើនក្នុងស្រះនោះ។ ឈូកនេះដុះនៅក្នុងតំបន់មាត់ស្រះនោះឯង ក្រាបទូល។ តែប្រសិនបើវាដុះនៅទឹកជ្រៅវិញនោះ វានឹងអាចលូតវែងជាងនេះដល់ទៅ ១០០ ហត្ថ ក៏ថាបាន"។

ទ្រង់ព្រះសណ្ដាប់ដូច្នោះ ព្រះបាទចូឡនីត្រាស់នឹងកេវដ្ដៈថា៖

"លោកអាចារ្យ ពួកយើងមិនអាចវាយដណ្តើមយកនគរនេះ ដោយរង់ចាំឲ្យនគរនេះអស់ទឹកបានទេ ចូរលោកនឹករកឧបាយផ្សេងទៀតមើល"។

"បពិត្រព្រះសម្មតិទេព បើអ៊ីចឹង យើងនឹងប្លាំងពេលនគរនេះអស់ស្រូវ ពីជង្រុកដែលស្តុក[១៣៦]ទុកក្នុងនគរ ធម្មតានគរតែងមានស្រូវនៅខាងក្រៅ" កេវដ្តៈឆ្លើយ។

"ចាំដល់អ៊ីចឹង ក៏អ៊ីចឹងទៅចុះអាចារ្យ" ស្តេចចូឡនីយល់ព្រម។

មហោសថ ជ្រាបពត៌មាននោះ តាមមធ្យោបាយមុនៗ លោកគិតថា "កេវដ្តព្រាហ្មណ៍មិនស្គាល់ថា អញជាបណ្ឌិតទេដឹង? "ហើយក៏បានបញ្ជាឲ្យពួកទាហានសែងភក់ដាក់លើកំពែង និងឲ្យដាំស្រូវនៅលើភក់នោះ។ ជាធម្មតាបំណងរបស់ពោធិសត្វទាំងឡាយ តែងតែបានសម្រេចដូច្នោះ ស្រូវដែលដាំបានដុះឡើង ក្នុងរយៈពេលត្រឹមតែមួយរាត្រី មានពណ៌ខៀវស្រងាត់ប្រាកដនៅលើខ្នងកំពែង។

ឃើញដូច្នោះស្តេចចូឡនីព្រហ្មទត្តសួរថា៖

---

[១៣៦] ស្តុក ដើង ត (ន.) សន្និធិ; ចំនួនទំនិញដែលតម្កល់ទុកបម្រុងលក់, គំនរទំនិញផ្សេងៗដែលនៅសល់តម្កល់ទុកក្នុងឃ្លាំង, ក្នុងផ្សារ : ពិនិត្យស្តុកទំនិញ ។

"ពួកលោកមើលហ្ន៎ អ្វីខៀវៗនៅលើកំពែង?"

បុរសឈ្លបការណ៍របស់មហោសថ និយាយកាត់បន្ទូលរបស់ស្តេចចូឡនី ទាំងទ្រង់មិនទាន់បញ្ចប់ព្រះរាជបន្ទូលថា៖

"បពិត្រមហារាជ មហោសថបណ្ឌិតកូនគហបតី ឃើញភ័យក្នុងអនាគត ដោយខ្លាចមានគ្រោះទុរ្ភិក្សកើតឡើង ទើបបានជាលោកណែនាំឲ្យប្រជាជនធ្វើស្រែទូទាំងប្រទេស ប្រមូលស្រូវទុកពេញៗក្នុងជង្រុកជាដើម និងដាក់ស្រូវដែលនៅសល់តាមខាងៗកំពែង។ ពូជស្រូវទាំងនោះ ពេលត្រូវកម្តៅថ្ងៃ ក៏ស្ងួត កាលបើត្រូវទឹកភ្លៀងឬសន្សើម ក៏ដុះចេញជាម្លូរ (ស្រូវដែលដុះចេញឯងៗ) នៅទីនោះតែម្តង។ ថ្ងៃមួយ ទូលបង្គំបានចូលទៅតាមទ្វារតូច ដោយមានកិច្ចការខ្វះ ក៏ប្រទះឃើញនូវអ្នកនគរកំពុងប្រូតស្រូវនៅតាមកំពែង ដាក់កណ្តាប់ចោលនៅតាមវិថី។ គ្រានោះ ពួកអ្នកប្រូតនិយាយលេងនឹងទូលបង្គំថា 'ពូប្រហែលជាឃ្លានហើយ សូមពូយកស្រូវមួយបង្វេចទៅផ្ទះ ដើម្បីឲ្យប្រពន្ធកូនកិនបុកជាអង្ករចម្អិនជាបាយពិសាចុះ'"។

ទ្រង់សណ្តាប់នូវពាក្យនោះហើយ ព្រះបាទចូឡនីក៏ត្រាស់នឹងកេវដ្ដៈថា៖

"ម្នាលលោកអាចារ្យ យើងមិនអាចវាយលុកដណ្ដើមនគរនេះដោយចាំពេលអស់ស្រូវនោះបានទេ ព្រោះនេះមិនមែនជាឧបាយល្អឡើយ"។

"ព្រះសម្មតិទេព បើដូច្នោះ សូមព្រះអង្គរង់ចាំនៅពេលដែលនគរនេះអស់ឧសសិន ធម្មតានគរតែងមានឧសនៅខាងក្រៅ" កេវដ្ដៈទូលថ្វាយ។

"ចាំអ៊ីចឹង ក៏អ៊ីចឹងទៅចុះ លោកអាចារ្យ" ស្ដេចត្រាស់។

មហោសថ ជ្រាបពត៌មាននោះដោយមធ្យោបាយដូចមុន បានបញ្ជាឲ្យគរឧសជាគំនរយ៉ាងខ្ពស់ផុតពីស្រូវលើកំពែង។ រីមនុស្សទាំងឡាយរបស់មហោសថបណ្ឌិត បានពោលចំអកឲ្យពួកទ័ពរបស់ព្រះបាទចូឡនីព្រហ្មទត្តថា៖

"បើពួកឯងឃ្លាន ចូរយកឧសនេះទៅចម្អិនបបរបាយហូបចុះ" ហើយក៏បោះឧសធំៗទៅឲ្យ។

ព្រះបាទចូឡនីសួរថា៖

"ឧសធំៗ នៅលើកំពូលកំពែង បានមកពីណា?"

បុរសឈ្លបការណ៍ទូលតបថា៖

"បពិត្រព្រះសម្មតិទេព បានឮថា មហោសថកូនគហបតីបាន យល់ឃើញពីភ័យអន្តរាយដែលអាចកើតមានឡើងនាពេល អនាគត ទើបបញ្ជាគេឲ្យដឹកឧសមកគរទុកជាច្រើន នៅខាង ក្រោយគេហដ្ឋានគ្រប់ៗគ្រួសារ។ ដោយឧសទាំងនុ៎ះមានច្រើន ពេក ទើបគេយកមកទុកក្បែរកំពែងនោះ"។

## សង្គ្រាមធម៌

ព្រះបាទចូឡនីឮដូច្នោះ ទើបទ្រង់ពិគ្រោះនឹងកេវដ្ដៈថា៖

"លោកអាចារ្យ ចម្បាំងរបស់យើង មិនអាចរង់ចាំរហូតដល់ ពេលពួកសត្រូវអស់ឧសបានទេ ចូរលោកនឹករកឧបាយផ្សេង ទៀតមើល"។

កេវដ្ដៈទូលតបថា៖

"មហាបពិត្រ សូមទ្រង់កុំមានកង្វល់ក្នុងព្រះទ័យឡើយ ក្រាប ទូល។ ទូលព្រះបង្គំបាននឹកឃើញនូវឧបាយកលដ៏ពិសេស មួយទៀត ក្រាបទូល"។

ព្រះរាជាទ្រង់ត្រាស់សួរថា៖

"លោកអាចារ្យ ឧបាយនុះយ៉ាងម៉េចទៅ? កន្លងមកឧបាយកល ជាច្រើន ដែលលោកអាចារ្យបានទូលដល់យើង តែគ្មានឧបាយ ណាមួយ ដែលធ្វើឲ្យយើងបានទទួលជោគជ័យទាល់តែសោះ។ បើយ៉ាងនេះ យើងនឹងមិនអាចដណ្ដើមយកនគរវិទេហៈបានទេ ប្រាកដជានាំនូវបរាជ័យ ត្រឡប់ទៅនគរយើងវិញមិនខាន"។

កេវដ្ដៈទូលព្រះរាជាថា៖

"បពិត្រព្រះសម្មតិទេព កាលបើយើងដកទ័ពថយទៅវិញ ពិតជានឹងទទួលភាពអាម៉ាស់ ដោយមានពាក្យតំណិះដំណៀល[១៣៧] នឹងលេចឮថា ទ្រង់ព្រមទាំងស្ដេច ១០១អង្គ គ្មានសមត្ថភាពច្បាំង

---

[១៣៧] ពាក្យរិះគន់ និន្ទា ឬពេបជ្រាយ ដែលគេនិយាយនៅទីកំបាំងមិនចំពោះមុខ។ តំណិះដំណៀល ក្លាយពីពាក្យ តិះដៀល។ តិះ ទៅជា តំណិះ ដូច តក់ ទៅជា តំណក់។ ដៀល ទៅជា ដំណៀល ដូច ដើរ ទៅជា ដំណើរ។ ហេតុនេះ តិះដៀល ទៅជា តំណិះដំណៀល។ យើងក៏គិតឃើញដែរថា ពាក្យនេះមិនធ្លាប់ប្រើ ច្រើនប្រើតែពាក្យ តិះដៀល យើងសម្រេចសរសេរ ព្រោះន័យក្នុងអត្ថបទនេះតម្រូវឲ្យប្រើស្របតាមខ្លឹមសារ មួយទៀត តំណិះដំណៀល មិនជាពាក្យបុរាណចាស់ហួសសម័យពេកទេ ទាស់តែយើងមិនប្រើឲ្យវាទំនើបប៉ុណ្ណោះ ទើបអានទៅមិនសូវស្រួលមាត់ដូចពាក្យ តិះដៀល ប៉ុន្តែអានយូរៗទៅ គង់តែថ្នឹកមាត់ ហើយមិនច្រឡំន័យនឹងពាក្យតិះដៀល ដែលប្រើចំពោះមុខក៏បានកំបាំងមុខក៏បាននោះឡើយ។

ដណ្ដើមយកនគរវិទេហៈទេ។ មហោសថ ជាបណ្ឌិត រីឯទូលបង្គំក៏ជាបណ្ឌិតដែរ ទូលបង្គំនឹងធ្វើកលឧបាយ[១៣៨] មួយតទៅទៀត”។

“ឧបាយកលអ្វីទៅ លោកអាចារ្យ?” ព្រះរាជាទ្រង់ត្រាស់សួរ។

“បពិត្រមហារាជ ឧបាយកលសង្គ្រាមធម៌ ក្រាបទូល” កេវដ្ដៈទូលតបថ្វាយ។

“សង្គ្រាមធម៌ហ្នឹង យ៉ាងម៉េច?” ព្រះរាជាត្រាស់សួរ។

កេវដ្ដៈទូលថ្វាយថា៖

“បពិត្រមហារាជ សង្គ្រាមធម៌ គឺទាហានទាំងពីរខាង មិនចាំបាច់ច្បាំងគ្នាទេ តែបណ្ឌិតពីរនាក់របស់ស្ដេចទាំងពីរប្រទេស នឹងត្រូវប្រឈមមុខគ្នា។ បណ្ដាបណ្ឌិតទាំងពីរនោះ បណ្ឌិតណាមួយ

[១៣៨] សូមអ្នកអានកុំឆ្ងល់ថា ម្ដេចក្នុងសៀវភៅនេះ ម្ដងសរសេរឧបាយកល ម្ដងកលឧបាយអ៊ីចឹង ព្រោះពាក្យណាដែលប្រើប្រាសត្រឡប់គ្នាបាន យើងបានសរសេរក្នុងសៀវភៅនេះដើម្បីឲ្យឃើញឲ្យយល់ថាប្រើដូច្នោះបានឥតទាស់អ្វីទេ ឧ. ឧបាយកល នឹងប្រើ កលឧបាយ ក៏បាន។ ប្រហែសធ្វេស នឹងប្រើ ធ្វេសប្រហែស ក៏បាន។ ផ្កាញ់ផ្កាល នឹងប្រើ ផ្កាលផ្កាញ់ ក៏បាន។ ទូលពិត នឹងប្រើ ពិតទូល ក៏បាន។ លោកអ្នកទម្លាប់ប្រើមួយណាស្រួលមាត់ ក៏ប្រើចុះ មិនទាស់ខុសអ្វីទេ តែបើពេញចិត្តជួយប្រើឲ្យបានសម្បូរបែប កាន់តែល្អរឹតតែប្រសើរ។

លើកដៃសំពះមុន បណ្ឌិតនោះឈ្មោះថា ជាអ្នកចាញ់សង្គ្រាមធម៌ ខណៈនោះ មហោសថ នឹងមិនដឹងនូវកលឧបាយនេះទេ។ ទូលបង្គំចាស់ ឯគេក្មេង ពេលគេជួបទូលបង្គំ គេមុខតែសំពះ ជម្រាបសួរ ទូលបង្គំមុនមិនខាន។ គ្រានោះ ស្តេចវិទេហៈ ឈ្មោះ ថាបរាជ័យដោយខ្លួនឯង។ កាលបើដូច្នេះ យើងឈ្មោះ ថាបានផ្ចាញ់[១៣៩] ស្តេចវិទេហៈឲ្យបរាជ័យ ហើយយើងនឹងអាច ទៅនគរវិញបាន ដោយគ្មានការអាម៉ាស់ ព្រោះពាក្យតំណិះ ដំណៀល។ សង្គ្រាមធម៌គឺយ៉ាងនេះឯង ក្រាបទូល”។

ចំណែកមហោសថដឹងអាថ៌កំបាំងនោះ ដោយឧបាយដូចមុនៗដែរ លោកគិតថា “ប្រសិនបើអញចាញ់កេវដ្តព្រាហ្មណ៍ អញមិនមែនជា បណ្ឌិតទេ”។

រីឯព្រះបាទចូឡនីព្រហ្មទត្តត្រាស់នឹងកេវដ្តៈថា៖

“ពិតជាល្អណាស់ លោកអាចារ្យ ល្បិចនេះ”

---

[១៣៩] ផ្ចាញ់ (កិ.) ធ្វើឲ្យចាញ់។ ផ្ចាញ់ផ្ចាល ឬ ផ្ចាលផ្ចាញ់ ធ្វើឲ្យចាញ់ឲ្យរាង ចាលលែងហ៊ានតទៅទៀត ឬ ផ្តន្ទាបង្អាប់បង្អោនឲ្យមានអៀនអន់រាងចាល។

គ្រានោះ ព្រះបាទចូឡនីបានឡាយព្រះហស្តលេខាលើសំបុត្រមួយច្បាប់ រួចឲ្យអ្នកនាំសារបញ្ជូនទៅថ្វាយព្រះបាទវិទេហរាជតាមទ្វារតូច ដែលមានខ្លឹមសារដូច្នេះថា៖

"ថ្ងៃស្អែក យើងនឹងធ្វើសង្គ្រាមធម៌ជាមួយនឹងនគររបស់ព្រះអង្គ។ ជោគជ័យឬបរាជ័យ វាអាស្រ័យទៅលើធម៌របស់បណ្ឌិត ២ នាក់។ ប្រសិនបើព្រះអង្គបដិសេធមិនធ្វើសង្គ្រាមធម៌នោះ ព្រះអង្គឈ្មោះ ថាជាអ្នកបរាជ័យ"។

ព្រះបាទវិទេហៈ កាលបើទ្រង់បានទទួលសារលិខិតនោះហើយ ព្រះអង្គបានបញ្ជាគេឲ្យទៅអញ្ជើញលោកសេនាប្រមុខមហោសថ មកចូលគាល់។ ព្រះបាទវិទេហៈ ទ្រង់ត្រាស់ប្រាប់នូវសេចក្តីក្នុងសារលិខិតនោះ ដល់មហោសថ។ មហោសថបណ្ឌិត កាលបើបានជ្រាបនូវសេចក្តីទាំងនោះហើយ លោកក៏ក្រាបទូលដល់ព្រះរាជាថា៖

"ប្រពៃណាស់ ព្រះសម្មតិទេព យើងនឹងរៀបចំមណ្ឌលសង្គ្រាមធម៌ នៅក្បែរទ្វារនគរខាងលិច ក្នុងវេលាព្រឹកថ្ងៃស្អែក។ សូមព្រះអង្គ ទ្រង់បញ្ជូនលិខិតបញ្ជាក់ប្រាប់ពីទីតាំងដែល ត្រូវធ្វើសង្គ្រាមធម៌ ហើយគោរពយាងនិងអញ្ជើញស្តេច និងមន្ត្រីទាំង

អស់ ឲ្យមកកាន់មណ្ឌលសង្គ្រាមធម៌ដើម្បីទត និងទស្សនាចុះ ក្រាបទូល”។

ព្រួដូច្នោះ ព្រះបាទវិទេហរាជ បានឡាយព្រះហស្តលេខាលើសារលិខិតមួយច្បាប់ ប្រគល់ឲ្យទូតអ្នកនាំសាររបស់ព្រះបាទចូឡនី យកលិខិតឆ្លើយតបទៅថ្វាយស្តេចរបស់ខ្លួនវិញ។

នៅថ្ងៃបន្ទាប់ មហោសថបានបញ្ជាកងទ័ពឲ្យរៀបចំមណ្ឌលសង្គ្រាមធម៌នៅក្បែរទ្វារនគរខាងលិច ដោយពោលក្នុងចិត្តថា “សូមឲ្យបរាជ័យ ធ្លាក់ទៅលើកេវដ្តព្រាហ្មណ៍ចុះ”។

និយាយពីបុរសឈ្លបទាំង ១០១ នាក់ របស់បណ្ឌិតមហោសថ តែងដើរហែហាមជុំវិញកេវដ្តព្រាហ្មណ៍ ប្រយោជន៍ដើម្បីយកពត៌មានជូនមហោសថបណ្ឌិត បើមិនធ្វើដូច្នេះ នឹងមិនអាចដឹងថាមានរឿងអ្វីកើតឡើងទេ។ ចំណែកឯស្តេចចំណុះទាំង ១០១ អង្គ បានយាងទៅកាន់មណ្ឌលសង្គ្រាមធម៌ ឈរបែរព្រះភក្ត្រទៅទិសខាងកើត រង់ចាំមើលការធ្វើសង្គ្រាមធម៌រវាងមហោសថបណ្ឌិត និងកេវដ្តព្រាហ្មណ៍។

ចំណែកលោកសេនាប្រមុខមហោសថ ផ្លូតទឹកក្រអូបពីព្រលឹមស្លៀកសំពត់ថ្មីទិញពីដែនកាសី ដែលមានតម្លៃ ១០០.០០០កហាបណៈ ប្រដាប់ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង បរិភោគនូវភោជនមាន

ឱជារសេធ្វាញ់ៗ ហើយបានធ្វើដំណើរទៅកាន់ព្រះរាជវាំង ហែហម ដោយបរិវារជាច្រើន ដើម្បីថ្វាយបង្គំលាព្រះរាជា ទៅធ្វើសង្គ្រាមធម៌ៗ លោកសេនាប្រមុខមហោសថបណ្ឌិត បានឈរក្នុងទីសមគួរៗ

គ្រានោះ ព្រះរាជាទ្រង់សួរថា៖

"អ្នកនឹងទៅណា បាសម្លាញ់?"

មហោសថ បានក្រាបទូលថា៖

"ទូលបង្គំជាខ្ញុំ នឹងទៅកាន់មណ្ឌលសង្គ្រាមធម៌ ក្រាបទូល"ៗ

"តើបណ្ឌិតកូន នឹងត្រូវយកអ្វីទៅជាមួយ?" ស្តេចត្រាស់សួរៗ

មហោសថក្រាបទូលថា៖

"បពិត្រព្រះសម្មតិទេព ទូលបង្គំសូមខ្ចីកែវមណីយកទៅបញ្ឆោតកេវដ្តព្រាហ្មណ៍ៗ សូមព្រះអង្គទ្រង់រាជានុញ្ញាតឲ្យទូលបង្គំយកកែវមណីជ្រុង ៨[១៤០] ទៅជាមួយផង ក្រាបទូល"

ព្រះរាជាអនុញ្ញាតឲ្យមហោសថយកកែវមណីនោះទៅ មហោសថក៏ថ្វាយបង្គំលាព្រះបាទវិទេហរាជ ចុះពីព្រះរាជនិវេសន៍ មាននាយទាហាន ១.០០០ នាក់ ដែលជាមិត្រកើតក្នុងថ្ងៃជំណាលគ្នា ហែហមជា

---

[១៤០] អដ្ឋវង្កំ មណិរតនំ លទ្ធុំ វដ្តតិ។

បរិវារ ប្រដាប់ដោយសម្លៀកបំពាក់តុបតែងដ៏ល្អប្រណីតគ្រប់ៗគ្នា ឡើងជិះរថដ៏បវរទឹមដោយសេះសិន្ធពសសុទ្ធ ដែលមានតម្លៃ ៩០.០០០ កហាបណៈ ចេញដំណើរទៅទ្វារនគរខាងលិច។

ចំណែកឯបណ្ឌិតកេវដ្ដៈ បានឈរទន្ទឹងរង់ចាំមើលផ្លូវមហោសថបណ្ឌិត ដោយគិតថា "មហោសថនឹងមកដល់ឥឡូវនេះ"។ ការដេកកសម្លឹងរកមើលមហោសថញឹកញាប់ពេក លោកស្ទើរតែក្លាយជាមនុស្សកវែងទៅហើយ ញើសហូរចេញសស្រាក់ ដោយត្រូវកម្ដៅព្រះអាទិត្យដែលរះកាន់តែខ្ពស់ពីទិសខាងកើត។

រីឯលោកសេនាប្រមុខមហោសថ លោកមានភាពអង់អាចក្លាហានប្រៀបបីដូចទឹកមហាសមុទ្រ មិនខ្លាចញញើតតក់ស្លុត ព្រឺរោមបន្តិចបន្តួចឡើយ លោកប្រដាប់សង្វារគ្រង់ក បានបញ្ជាច្មាំទ្វារឲ្យបើកទ្វារ ហើយចុះពីលើរថចេញដំណើរទៅ បង្ហាញពីភាពអង់អាចក្លាហានបីដូចរាជសីហ៍។ ស្ដេចទាំង ១០១ អង្គទតឃើញរូបសម្បត្តិរបស់មហោសថ មួយអង្គៗមានព្រះចិន្ដាថា "ទុំះ មហោសថបណ្ឌិតកូនសិរីវឌ្ឍនសេដ្ឋី គេជាអ្នកប្រាជ្ញគ្មានពីរ ក្នុងសកលជម្ពូទ្វីប" ហើយក៏បានក្ងាក់ផ្អើលក្រោកមើលឈូចរ[១៤១]។

---

[១៤១] ឧក្កុដ្ឋិសហស្សានិ បវត្តយិំសុ។

**បណ្ឌិតមហោសថយកកែវមណីបញ្ឆោតបណ្ឌិតកេវដ្ដៈ**

មហោសថបណ្ឌិត ដើរតម្រង់ទៅរកកេវដ្ដបណ្ឌិតទាំងដៃកាន់កែវមណីនោះ ដោយសិរីសម្បត្តិឥតមានអ្វីប្រៀប ហាក់បីដូចសក្កទេវរាជ មានទេវតាចោមរោមជុំជិតៗ កេវដ្ដបណ្ឌិត គ្រាន់តែក្រឡេកឃើញមហោសថបណ្ឌិតដើរតម្រង់មក គាត់ពុំអាចទប់ជំហរខ្លួនបាន ដោយបានក្រោកទទួលស្វាគមន៍យ៉ាងរីករាយ ហើយពោលដូច្នេះថា៖

"នែមហោសថបណ្ឌិត យើងទាំងពីរនាក់សុទ្ធតែជាបណ្ឌិតដូចគ្នា យើងនៅអស់កាលប៉ុណ្ណេះក្បែរលោកហើយ លោកពុំដែលផ្ញើគ្រឿងបណ្ណាការអ្វីបន្តិចមកឲ្យខ្ញុំសោះៗ ហេតុអ្វីបានជាលោកធ្វើយ៉ាងនេះ?"

បណ្ឌិតមហោសថតបចំពោះកេវដ្ដៈថា៖

"បពិត្រលោកបណ្ឌិត មួយរយៈកាលនេះ ខ្ញុំបាទមានកិច្ចរវល់ លៃលកមើលថា តើគ្រឿងបណ្ណាការណាសក្តិសមចំពោះលោក? ទើបតែថ្ងៃនេះ ខ្ញុំរកបានកែវមណីនេះសម្រាប់ជូនលោកបណ្ឌិត សូមលោកមេត្តាទទួលយក ដ្បិតថា កែវមណីដទៃដែលមានលម្អបែបនេះរកពុំមានទេ"ៗ

កេវដ្តព្រាហ្មណ៍ ឃើញកែវមណីដ៏រុងរឿងនៅលើដៃមហោសថភ្លាម គិតថា មហោសថមានបំណងជូនមែន ក៏លាដៃទទួលយក ព្រមទាំងនិយាយថា៖

"បើអ៊ីចឹង សូមឲ្យមកខ្ញុំៗ លោកបណ្ឌិត"។

មហោសថទម្លាក់ទៅលើចុងម្រាមដៃកេវដ្ដៈ ព្រមទាំងនិយាយបន្ថែមថា៖

"សូមទទួលយកចុះ លោកអាចារ្យ"។

កេវដ្តព្រាហ្មណ៍ឈោងទប់កែវមណីដ៏ធ្ងន់ដោយម្រាមដៃមិនបាន ក៏បណ្ដាលឲ្យកែវមណីជ្រុះពីដៃ រមៀលទៅរកជើងរបស់លោកសេនាប្រមុខមហោសថ ។ កេវដ្តព្រាហ្មណ៍ ហេតុតែជាមនុស្សល្មោភ ក៏បន្ទាបខ្លួនឱនក្បាលដេញតាមចាប់កែវមណី ឱនទៅៗ ក្បាលគាត់រុលទៅជិតជើងមហោសថ ប៉ងថានឹងរើសកែវមណីឲ្យបាន នៅពេលនោះស្រាប់តែលោកសេនាប្រមុខមហោសថ ចាប់ជ្រមុជកេវដ្តៈសង្កត់មិនឲ្យងើបរួច ដៃម្ខាងចាប់កញ្ចឹងក ដៃម្ខាងចាប់ធ្នុកក្បិន សង្កត់ជាប់រូសមុខគាត់ទៅនឹងដីជាច្រើនដង បណ្ដាលឲ្យរបកស្បែកប្រឡាក់ឈាមដាបមុខ ហើយមហោសថស្រែកបន្លឺមហាជននៅជុំវិញទីនោះថា៖

“លោកអាចារ្យ អញ្ជើញក្រោកឡើង ក្រោកឡើង លោកអាចារ្យ ខ្ញុំបាទក្មេងខ្ចីពេកណាស់ ស្មើនឹងចៅលោកទៅហើយ សូមលោកមេត្តាកុំថ្វាយបង្គំខ្ញុំបាទអី ធ្វើយ៉ាងនេះមិនសមទេណាលោក”។

រួចក៏ចាប់ក្រឡុកបោះពេញទំហឹង ទាំងស្តីបន្ទោសថា៖

“នែចាស់អន្ធពាល ល្ងង់ដូចមនុស្សខ្វាក់ ម្តេចក៏មកថ្វាយបង្គំយើងជាមនុស្សក្មេងអ៊ីចឹង?”

កេវដ្តព្រាហ្មណ៍នោះ ខ្លួតធ្លាក់ទៅទីចម្ងាយ១ឧសភៈ[១៤២]ក្រោកឡើង រត់រកតែព្រះអាយុសៗ ចំណែកកែវមណី ត្រូវបានមិត្តសម្លាញ់របស់មហោសថ រើសទុកជូនលោកសេនាប្រមុខវិញ។

រីឯសំឡេងរបស់លោកសេនាប្រមុខមហោសថ ដែលស្រែកថា “លោកអាចារ្យ អញ្ជើញក្រោកឡើង ក្រោកឡើង លោកអាចារ្យ លោកកុំថ្វាយបង្គំខ្ញុំ” បានឮជ្រួតជ្រាបទូទៅដល់ស្តេច មន្ត្រី កងប្រជាប់

---

[១៤២] ពាក្យ ឧសភៈ នេះប្រែថា គោឈ្មោល គោឡើងក ឬគោបា ប៉ុន្តែក្នុងសម័យបុរាណ គេយកសម្រែករបស់គោឧសភៈនេះប្រើជាមាត្រាវាស់ប្រវែងមួយ ដែលចម្ងាយវាស្រែកបានដល់ទៅ ១៤០ ហត្ថ។ ដូច្នេះ ១ឧសភៈ គឺប្រវែងឬចម្ងាយ ១៤០ ហត្ថ។ ៨០ ឧសភៈ ហៅថា ១គាវុត។ ៤ គាវុត ហៅថា ១យោជន៍។ ១គាវុត = ១៤០ × ៨០ = ១១.២០០ ហត្ថ។ ១យោជន៍ = ១១.២០០ × ៤ = ៤៤.៨០០ ហត្ថ។

អាវុធគ្រប់រូបៗ សូម្បីពួកទាហានរបស់សេនាប្រមុខមហោសថ ក៏បាន
ស្រែកព្រមគ្នាថា "កេវដ្តព្រាហ្មណ៍ថ្វាយបង្គំមហោសថៗ"។ ស្តេចទាំង
អស់ រួមទាំងស្តេចចូឡនីព្រហ្មទត្តផងដែរ ព្រះអង្គបានទតមើលទៅ
ឃើញអាការកេវដ្តៈកំពុងតែឱនខ្លួនទៀបបាទជើងមហោសថមែន ក៏
ស្រែកប្រាប់គ្នីគ្នាថា "បណ្ឌិតរបស់ពួកយើងថ្វាយបង្គំមហោសថហើយ
ឥឡូវយើងបរាជ័យហើយ មហោសថនឹងមិនទុកជីវិតឲ្យយើងទេ" រួច
បាននាំគ្នារត់ឡើងសេះរៀងៗខ្លួន បំផាយសេះយ៉ាងលឿន ឆ្ពោះមុខទៅ
ក្រុងបញ្ចាល ឯទិសខាងជើងវិញ។ កងទ័ពរបស់មហោសថឃើញពួក
គេកំពុងរត់ដូច្នោះ នាំគ្នាស្រែកសន្ធាប់បន្ថែមថា "ស្តេចចូឡនីព្រហ្មទត្ត
នាំស្តេច១០១ រត់កៀសខ្លួនហើយ"។ គ្រាន់តែឮដូច្នោះ ស្តេចទាំងឡាយ
នោះខ្លាចស្លាប់ ក៏កាន់តែតក់ស្លុតខ្លាំងឡើង រឹតតែខំបំបោលសេះរត់
បែកបាក់ពីកងទាហាន លែងបានជុំជំណើរគ្នា។ ចំណែកទាហានរបស់
មហោសថ នាំគ្នាស្រែកហ៊ោកញ្ជ្រៀវសន្ធាប់ ឮទ្រហឹងអឺងកង បង្កើត
ការជ្រួលជ្រើម ការផ្អើលឈូឆរ ប្របូកប្របល់គ្នាកាន់តែខ្លាំងឡើងៗ
សេនាប្រមុខមហោសថ មានអង្គសេនាអមចោមរោម ដើរចូលទៅកាន់
នគរវិញ។ រីឯពួកទាហានរបស់ព្រះបាទចូឡនីព្រហ្មទត្ត នាំគ្នារត់ទៅ
យ៉ាងឆ្ងាយ ប្រវែងដី ៣ យោជន៍ពីទីលានសង្គ្រាមធម៌។

ចំណែកកេវដ្តព្រាហ្មណ៍ ក៏ជិះសេះបំបោលតាមគេដែរ ទាំងដៃជូតឈាមលើថ្ងាសបណ្តើរ កាលទៅជិតទាន់ពួកទាហាន ក៏ស្រែកពីលើខ្នងសេះថា "នែពួកប្រស្នែងអើយ កុំរត់ៗ! ខ្ញុំមិនមែនថ្វាយបង្គំមហោសថកូនគហបតីទេ ឈប់ៗ"។ ពួកទាហានមិនជឿ ហើយក៏មិនឈប់ចាំ និយាយគ្នាឲ្យយល់ការណ៍ឡើយ កេវដ្តៈកាន់តែមកជិត ពួកគេកាន់តែខំបំផាយសេះបង្កើនល្បឿនឲ្យកាន់តែលឿនទៅៗ ធ្វើដូចជាមិនឮសម្តីកេវដ្តៈស្រែកហៅសោះ មានតែជេរផ្តាសាកេវដ្តៈវិញថា "នែ! អាព្រាហ្មណ៍កញ្ចាស់ចង្រៃ អាក្រក់លាមក ឯងនិយាយថា ឯងនឹងធ្វើសង្គ្រាមធម៌ តែឯងបែរជាថ្វាយបង្គំមនុស្សក្មេងមានអាយុប្រហែលចៅរបស់ខ្លួនទៅវិញ" ជេរបណ្តើររត់បណ្តើរ។ កេវដ្តៈក៏ខំបំបោលសេះយ៉ាងលឿន រហូតទៅទាន់ពួកទាហាន ក៏ប្រាប់ពួកគេថា "នែអស់លោកសូមជឿពាក្យខ្ញុំចុះ ខ្ញុំមិនថ្វាយបង្គំគេទេ គេយកកែវមណីមកបញ្ឆោតខ្ញុំទេតើ!" ហើយក៏ទៅក្រាបទូលស្តេចទាំងអស់ឲ្យទ្រង់ជ្រាបដោយហេតុផលផ្សេងៗ។ កាលដឹងថា ស្តេចទាំងអស់ជឿសម្តីរបស់ខ្លួនហើយ ក៏បានបញ្ជាកងទ័ពដែលបែកបាក់គ្នា ឲ្យត្រឡប់ក្រោយវិញ។

## កំណត់សម្គាល់

ពិតណាស់ កងទាហានរបស់ស្ដេចចូឡនីនោះ ច្រើនសែនច្រើនមហិមា ប្រសិនបើពួកគេចាប់អាចម៍ដីម្នាក់មួយក្ដាប់ ឬដុំដីម្នាក់មួយដុំបោះតម្រង់ទៅនគរមិថិលា គំនរដីនឹងអាចពេញស្នាមភ្លោះខ្ពស់ស្មើកំពែងបាន។ ប៉ុន្តែជាធម្មតា បំណងរបស់ពោធិសត្វទាំងឡាយ តែងតែបានសម្រេចសមតាមប្រាថ្នា ព្រោះហេតុនោះ ឥតមានទាហានណាម្នាក់នឹកឃើញឧបាយនោះ ហើយគ្មានអ្នកណាម្នាក់បោះអាចម៍ដីមួយក្ដាប់ឬដុំដីមួយដុំទៅលើនគររបស់ព្រះបាទវិទេហរាជឡើយ។ នេះគឺអាស្រ័យដោយគុណធម៌ គឺបារមីដ៏ឧត្តុង្គឧត្តមរបស់ព្រះពោធិសត្វ។

ទាហានទាំងអស់នោះ លុះត្រឡប់ក្រោយវិញហើយ បានបែកគ្នាជាកង១ ហើយវិលទៅទីតាំងបន្ទាយតាមក្រុមរៀង១ខ្លួនដូចដើមវិញ។ ព្រះបាទចូឡនីព្រហ្មទត្តសួរកេវដ្ដៈថា៖

"យើងនឹងធ្វើដូចម្ដេច លោកអាចារ្យ?"

កេវដ្ដៈ ក្រាបទូលថា៖

"បពិត្រព្រះសម្មតិទេព យើងនឹងបិទច្រកចេញចូលទាំងអស់នៃនគរមិថិលា មិនអនុញ្ញាតឲ្យនរណាម្នាក់ចេញតាមទ្វារតូចបាន។

មនុស្សទាំងឡាយ ដែលមិនបានចេញគង់តែកើតក្ដីអផ្សុក ពួកគេ មុខតែបើកទ្វារចេញ កាលបើធ្វើដូច្នេះ យើងនឹងចាប់សត្រូវបាន ទាំងអស់"។

**អនុកេវដ្ដព្រាហ្មណ៍បំពេញបេសកកម្មពិសេស**

លោកសេនាប្រមុខមហោសថជ្រាបពត៌មាននោះ ដោយប្រការដូចមុន ទើបត្រិះរិះថា "កាលបើពួកសត្រូវទាំងនេះ នៅទីនេះយូរ នាំឲ្យយើងកើតក្ដីលំបាក គួរតែអញប្រើឧបាយកលបណ្ដេញពួកសត្រូវទាំងនោះឲ្យរត់បែកខ្ញែកចេញអស់ ទើបជាការល្អ។ អញនឹងប្រើមន្តពិធីដូចម្ដេច ដើម្បីដេញពួកសត្រូវទាំងនេះ?" រំពឹងរកមន្តពិធីដោយប្រាជ្ញាដ៏ឈ្លាសវៃ ក៏នឹកឃើញដល់ព្រាហ្មណ៍ម្នាក់ឈ្មោះ**អនុកេវដ្ដៈ** ហើយបង្គាប់អ្នកបម្រើឲ្យទៅហៅអនុកេវដ្ដៈមកជួប ហើយប្រាប់ថា៖

"បពិត្រលោកអាចារ្យ យើងមានកិច្ចការរួមមួយ ដែលគួរធ្វើជាមួយនឹងលោក"។

អនុកេវដ្ដៈសួរថា៖

"តើយើងនឹងធ្វើអ្វី លោកបណ្ឌិត? សូមមានប្រសាសន៍មកចុះ"។

មហោសថប្រាប់ថា៖

“បពិត្រលោកអាចារ្យ ពេលពួកទាហានរបស់យើងធ្វេសប្រហែស សូមលោកលបលួចបោះស្បៀងមានទំ ត្រី និងសាច់ជាដើម ទៅឲ្យពួកទាហានរបស់ស្ដេចចូឡនីព្រហ្មទត្ត តាមចន្លោះ កំពែងនោះ ហើយគប្បីប្រាប់ពួកគេថា នែអស់លោក ចូរបរិភោគរបស់ទាំងនេះចុះ កុំព្រួយបារម្ភអ្វីឡើយ សូមពួកលោកតស៊ូនៅទីនេះ ឲ្យបានពីរបីថ្ងៃទៀត ពួកអ្នកនៅក្នុងនគរនេះនឹងកើតក្ដីអផ្សុក បីដូចមាន់ជាប់ទ្រុង មិនយូរប៉ុន្មាន ពួកគេនឹងបើកទ្វារសម្រាប់ពួកលោកហើយៗ កាលបើដូច្នេះ ពួកអស់លោកនឹងអាចចាប់ព្រះបាទវិទេហរាជ និងមហោសថកូនគហបតី បានជាពុំខានៗ បពិត្រលោកអាចារ្យ ពួកទាហានរបស់យើង ឮសម្ដីលោកថា ដូច្នោះ មុខតែជេរគំរាមលោក ពួកទាហានរបស់ស្ដេចចូឡនីព្រហ្មទត្ត ក៏បានឃើញជាក់ច្បាស់នឹងភ្នែក ហើយទាហានយើងនឹងនាំគ្នាចាប់លោក វាយវាត់ដោយបន្ទះឫស្សីជាដើម កោរសក់លោកចេញ ឲ្យលោកកាន់ត្រួយ ៥ ឲ្យពួកគេរោយរាយដោយលម្អិតក្បឿង ទាត់ធាក់ពីរបីជើងបង្ហាញការឈ្លោះគ្នាកំបាំងខ្នង កុំឲ្យពួកសត្រូវដឹងៗ ពួកទាហាននឹងដាក់លោកចូលក្នុងសង្រែក ទំលាក់ចុះ ប្រគល់ឲ្យពួកទាហានរបស់ស្ដេចចូឡនីទាំងជេរថា “នែអាចោរក្បត់ជាតិ ឯងទៅឲ្យស្លាប់ទៅចុះ

ឈប់មកជាន់ដីពួកអញ”។ ពួកទាហានរបស់សត្រូវទាំងនោះ នឹងនាំលោកទៅកាន់សម្នាក់របស់ស្ដេចចូឡនី។ ស្ដេចចូឡនី ព្រហ្មទត្តទតឃើញលោកហើយ នឹងសួរលោកថា តើលោកមាន កំហុសអ្វី? កាលដូច្នេះ លោកគប្បីក្រាបទូល ស្ដេចចូឡនីយ៉ាង នេះថា “បពិត្រមហារាជ ដើមឡើយទូលបង្គំជាខ្ញុំ មានយសសក្ដិ ធំដុំណាស់ តែអាកូនគហបតីវិឹងនឹងទូលបង្គំថា ទូលបង្គំក្បត់ ជាតិ វាទៅទូលស្ដេចវិទេហៈ ឲ្យដកហូតយសសក្ដិ និងបំផ្លិច បំផ្លាញសិរីសម្បត្តិរបស់ទូលបង្គំទាំងអស់។ ទូលបង្គំបានឲ្យ បាយ ទឹក នំចំណី ត្រីសាច់ដល់ពួកកងទ័ពរបស់ព្រះអង្គ ដែល កំពុងឈរនៅទីនោះ ឲ្យពួកគេបានបរិភោគបាត់ក្ដីស្រេកឃ្លាន ដោយបំណងឲ្យ ពួកគេជួយកាត់យកក្បាលរបស់មហោសថ គហបតីបុត្រ ដែលជាខ្មាំងបំផ្លាញយសសក្ដិរបស់ទូលបង្គំ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ មហោសថបានទុកទូលបង្គំ ដែលជា សត្រូវចាស់របស់គេនៅក្នុងចិត្ត ហើយធ្វើឲ្យទូលបង្គំដល់នូវ សេចក្ដីវិនាសបែបនេះតែម្ដង។ រឿងរ៉ាវ ដែលគេធ្វើមកលើ ទូលបង្គំយ៉ាងណានោះ គឺពួកទ័ពរបស់ព្រះអង្គ បានឃើញដឹង គ្រប់គ្នាហើយ មហារាជ។ សូមព្រះអង្គ ទ្រង់ពន្យល់ឲ្យពួកទាហាន ជឿរឿងរ៉ាវនេះ និងសូមទ្រង់ជួយប្រាប់ដល់មនុស្សជំនិតព្រះអង្គ

ផង ក្រាបទូល។ បពិត្រមហារាជ នៅពេលដែលទូលបង្គំបាន នៅបម្រើព្រះអង្គហើយ សូមព្រះអង្គ កុំគិតព្រួយព្រះទ័យឡើយ។ ឥឡូវនេះ ជីវិតរបស់ស្តេចវិទេហរាជ និងមហោសថ នឹងមិន អាចទប់ទល់បានទៀតទេ ព្រោះថាទូលបង្គំ ដឹងទីតាំងកំពែងនេះ កន្លែងណាមាំ កន្លែងណាខ្សោយ និងស្នាមភ្លោះ កន្លែងណាមាន ក្រពើ កន្លែងណាឥតក្រពើជាដើមហើយ។ មិនយូរប៉ុន្មានទេ ទូលបង្គំនឹងច្បាំងដណ្តើមយកនគរនេះ ថ្វាយព្រះអង្គឲ្យទាល់ តែបាន"។ កាលស្តេចចូឡនីបានព្រះសណ្តាប់ដូច្នេះ ព្រះអង្គនឹង ជឿសម្តីលោក ផ្តល់រង្វាន់ដល់លោក ហើយនឹងឲ្យលោកគ្រប់ គ្រងពលទាហាន និងពាហនៈ។ ដល់ពេលនោះ លោកចូរនាំទ័ព ព្រះអង្គចុះស្នាមភ្លោះ ត្រង់កន្លែងណាមានក្រពើច្រើន។ ពួក ទាហានច្បាស់ជាមិនហ៊ានចុះ ព្រោះខ្លាចក្រពើ។ ពេលនោះ ចូរលោកចូលគាល់ស្តេចចូឡនី ក្រាបទូលព្រះអង្គថា "បពិត្រ ព្រះសម្មតិទេព មហោសថបានឲ្យគ្រោងដល់ពួកទាហានរបស់ ព្រះអង្គហើយ។ ស្តេចទាំងអស់ រួមនឹងកេវដ្តព្រាហ្មណ៍ជាដើម គ្មាននរណាមួយដែលមិនកាន់គ្រោះទេ។ ពួកគេទាំងនោះ ដើរចោម រោមព្រះអង្គមែន ប៉ុន្តែពួកគេសុទ្ធតែជាមនុស្សរបស់មហោសថ។ មានតែទូលបង្គំម្នាក់គត់ ជាមនុស្សរបស់ព្រះអង្គ។ ប្រសិនបើ

ព្រះអង្គមិនជឿទូលបង្គំ សូមព្រះអង្គអញ្ជើញស្ដេច ទាំងអស់ គុបតែងខ្លួនមកចូលគាល់ព្រះអង្គទតចុះ ក្រាបទូល”។
កាលបើដូច្នេះ លោកគប្បីពោលថា “ព្រះអង្គនឹងឃើញអក្សរ លើសម្លៀកបំពាក់ អលង្ការ និងព្រះខាន់ជាដើម ដែលមហោសថ បានចារឈ្មោះរបស់គេប្រគល់ឲ្យអ្នកទាំងនោះ ព្រះអង្គនឹងអស់ ក្ដីសង្ស័យ[១៤៣] ”។ ស្ដេចអង្គនោះ មុខតែធ្វើតាម ហើយនឹងឃើញ ដូច្នោះមែន ទ្រង់នឹងអស់ក្ដីសង្ស័យ ក៏កើតភ័យតក់ស្លុតក្នុងចិត្ត នឹងបញ្ជូនស្ដេចទាំងនោះឲ្យត្រឡប់ទៅវិញ ហើយនឹងសួរលោក ថា “តើយើងនឹងធ្វើដូចម្ដេចឥឡូវនេះ លោកបណ្ឌិត?” លោក គប្បីក្រាបទូលស្ដេចអង្គនោះថា “បពិត្រមហារាជ មហោសថ មានមាយាពុតត្បុតច្រើន ប្រសិនបើព្រះអង្គនៅជំអក់តែពីរបីថ្ងៃ ទៀត ប្រាកដជាមហោសថក្ដោបក្ដាប់ទាហានទាំងអស់របស់ ព្រះអង្គ ឲ្យធ្វើជាទាហានរបស់គេវិញពុំខាន។ គេមុខតែនឹងចាប់ ព្រះអង្គទៀតផង។ ដូច្នោះ កុំបង្អង់យូរឡើយ ចន្លោះមជ្ឈិមយាម យប់នេះ យើងនឹងជិះសេះរត់កុំឲ្យស្លាប់ក្នុងដៃរបស់សត្រូវទាន់”។ ស្ដេចចូឡនី លុះទ្រង់ព្រះសណ្ដាប់ពាក្យលោកហើយ ទ្រង់មុខ

---

[១៤៣] និដ្ឋំ គច្ឆេយ្យ។

ជាធ្វើតាមយ៉ាងនោះមិនខានៗ ក្នុងវេលាស្តេចរត់ហើយ ចូរលោកត្រឡប់ក្រោយវិញ ប្រាប់ឲ្យពួកទាហានរបស់យើងបានដឹងផង"ៗ

ពួកលល្បិចដូច្នោះ អនុកេវដ្តព្រាហ្មណ៍ពោលតបថា៖

"ប្រពៃណាស់លោកបណ្ឌិត ខ្ញុំនឹងធ្វើតាមពាក្យរបស់លោក"ៗ

មហោសថបញ្ជាក់ថា៖

"បើអ៊ីចឹង លុះតែអ្នកសុខចិត្តទ្រាំនឹងទារុណកម្មដ៏សាហាវ ដែលទាហានរបស់យើងធ្វើដល់លោក ទើបកិច្ចការរបស់យើងបានសម្រេច"ៗ

អនុកេវដ្តៈតបថា៖

"លោកបណ្ឌិត លើកលែងតែជីវិតនិងដៃជើងខ្ញុំ អ្វីផ្សេងៗ សូមលោកធ្វើតាមគាប់ចិត្តលោកចុះ"ៗ

មហោសថបានផ្តល់គ្រឿងសក្ការៈឧបត្ថម្ភដល់ក្រុមគ្រួសាររបស់អនុកេវដ្តៈ មិនឲ្យមានការខ្វះខាតឡើយ ធ្វើឲ្យអនុកេវដ្តៈនោះ មានសេចក្តីពេញចិត្តធ្វើតាមកលល្បិចដែលមហោសថប្រាប់ទាំងអស់ ត្រូវទាហានរបស់មហោសថចាប់បាន ធ្វើទារុណកម្មផ្សេងៗ មានវាយ

ទាត់ធាក់ជាដើម រួចដាក់ក្នុងសម្រែកទម្លាក់ចុះ ប្រគល់ដល់ពួកទាហានរបស់ស្តេចចូឡនីព្រហ្មទត្ត។ លំដាប់នោះ ពួកទាហានទាំងនោះចាប់អនុកេវដ្ដៈនាំទៅថ្វាយស្តេចចូឡនី។ ស្តេចចូឡនី ធ្វើការពិសោធមើលទៅ ទ្រង់ក៏ជឿ ហើយផ្តល់រង្វាន់ឲ្យលោកអនុកេវដ្ដៈ និងបានតែងតាំងក្នុងឋានៈជាអ្នកគ្រប់គ្រងពួកកងទ័ព។ ចំណែកលោកអនុកេវដ្ដៈនោះតែងដឹកនាំកងទ័ពឲ្យចុះត្រង់ស្នាមភក់ ដែលមានក្រពើច្រើន។ ទាហានទាំងនោះក៏ត្រូវក្រពើទាំងឡាយត្របាក់ស៊ី ខ្លះត្រូវពួកទាហានរបស់មហោសថ ដែលឈរនៅតាមប៉ម បាញ់សរ ពួយលំពែង និងច្បូកបណ្ដាលឲ្យស្លាប់ជាច្រើន។ តាំងពីពេលនោះមក គ្មានទាហានណាអាចចូលទៅជិតតំបន់នោះបានទេ ព្រោះខ្លាចក្រពើ គ្រាប់សរ ច្បូក និងលំពែង។ លោកអនុកេវដ្ដៈចូលទៅគាល់ព្រះរាជាចូឡនី ក្រាបទូលថា៖

"ចម្បាំងនេះ គ្មានប្រយោជន៍អ្វីដល់ព្រះអង្គទាល់តែសោះ ទាហានទាំងអស់ ទទួលត្រារបស់មហោសថគ្រប់ៗគ្នា។ បើទ្រង់ពុំជឿ សូមទ្រង់ហៅពួកគេមក ហើយទ្រង់ទតមើលអក្សរលើសម្លៀកបំពាក់ និងសម្ភារៈសឹករបស់ពួកគេចុះ ក្រាបទូល"។

សូមបញ្ជាក់ថា ដោយមានឋានៈជាមេទ័ព អនុកេវដ្ដៈ បានបញ្ជាកូនទាហានទាំងអស់ឲ្យពាក់នូវត្រា ដែលជាស្លាកសញ្ញារបស់ខ្លួន ជា

គ្រឿងសម្គាល់ថា ជាកូនទាហានរបស់មហោសថ តែកូនទាហានទាំង នោះមិនដឹងថាត្រានោះ ជាសញ្ញាអ្វីឡើយ។

ព្រះរាជាធ្វើតាម ក៏បានទតឃើញអក្សរលើសម្លៀកបំពាក់ និង សម្ភារៈសឹករបស់កងទ័ពទាំងនោះ ទ្រង់អស់ក្តីសង្ស័យថា ពួកនេះ ប្រាកដជាទទួលត្រាមហោសថគ្រប់គ្នាមែន ទ្រង់ក៏ត្រាស់សួរអនុកេវដ្ដៈ ថា៖

"បពិត្រលោកអាចារ្យ ឥឡូវនេះ ត្រូវធ្វើដូចម្ដេច?"

អនុកេវដ្ដៈក្រាបទូលថា៖

"ប្រសិនបើព្រះអង្គយឺតយូរ មហោសថនឹងចាប់ព្រះអង្គបាន។ សូម្បីអាចារ្យកេវដ្ដព្រាហ្មណ៍ ដែលមានស្លាកស្នាមលើលលាដ៍ ក្បាល[១៤៤] ក៏ព្រោះតែទទួលត្រារបស់មហោសថដែរ ដូចព្រះអង្គ ទ្រង់ជ្រាបស្រាប់ កេវដ្ដព្រាហ្មណ៍នេះបានយកកែវមណី ហើយ ប្រើល្បិចធ្វើឲ្យព្រះអង្គរត់ចម្ងាយដី ៣ យោជន៍ ថែមទាំងបញ្ចុះ បញ្ចូលព្រះអង្គ ឲ្យជឿសម្ដីគេ ហើយនាំព្រះអង្គត្រឡប់មកទីនេះ វិញ មួយសាទៀត។ កេវដ្ដៈ នេះក្រឡិចក្រឡុចណាស់[១៤៥]

[១៤៤] អាចរិយកេវដ្ដោបិ កេវលំ នលាដេ វណំ កត្វា ចរតិ ។

[១៤៥] អយម្បិ បរិភិន្នកោវ។

ក្រាបទូល។ ការស្នាក់នៅទីនេះមួយយប់ទៀតរបស់ព្រះអង្គ មិនគាប់ចិត្តទូលបង្គំសោះ យើងគួរតែរត់គេចខ្លួនក្នុងចន្លោះមជ្ឈិមយាមថ្ងៃនេះឲ្យហើយ។ លើកលែងទូលបង្គំចេញ ដូចជាគ្មាននរណាមានចិត្ត ស្វាមីភក្តិស្មោះត្រង់ចំពោះព្រះអង្គឡើយក្រាបទូល"។

ស្ដេចចូឡនីតបថា៖

"នែអាចារ្យ បើអ៊ីចឹង ចូរលោកជ្រើសរើសសេះ រៀបចំត្រៀមយានជំនិះសម្រាប់យើង"។

អនុកេវដ្ដព្រាហ្មណ៍ ដឹងដំណើររត់គេចខ្លួនរបស់ស្ដេចដោយឥតសង្ស័យ ហើយបានពោលសម្រួលព្រះទ័យព្រះអង្គថា៖

"បពិត្រមហារាជ កុំព្រួយបារម្ភអ្វី ក្រាបទូល"។

ពោលដូច្នេះហើយ អនុកេវដ្ដៈ លាព្រះអង្គចេញទៅខាងក្រៅផ្ដល់ដំណឹងដល់ពួកចារបុរសឈ្លបការណ៍ថា៖

"ស្ដេចចូឡនីនឹងគេចខ្លួនក្នុងមជ្ឈិមយាមយប់នេះ ពួកអ្នកកុំដេកលក់ឲ្យសោះ"។

រួចអនុកេវដ្ដៈ បានជ្រើសរើសសេះល្អ សម្រាប់ស្ដេចរត់គេចខ្លួន។ ដល់ពេលកណ្ដាលអធ្រាត អនុកេវដ្ដៈបានក្រាបទូលស្ដេចថា៖

"បពិត្រព្រះសម្មតិទេព សេះល្អទូលបង្គំបានត្រៀមរួចរាល់ហើយ សូមស្ដេចយាងក្រាបទូល"។

ព្រះរាជា ទ្រង់ឡើងគង់លើសេះ ហើយក៏បំផាយសេះឲ្យរត់ទៅមុខយ៉ាងលឿន។ ចំណែកអនុកេវដ្ដៈ ក៏ឡើងជិះសេះបំបោលតាម ធ្វើដូចជាទៅតាមស្ដេចមែនទែន ប៉ុន្ដែទៅបានបន្ដិចក៏ត្រឡប់ក្រោយវិញ។ រីឯសេះដែលអនុកេវដ្ដៈជ្រើសសម្រាប់ស្ដេចចូឡនីនោះ ទោះបីជាស្ដេចខំបញ្ឈប់យ៉ាងណាក៏ដោយ ក៏វានៅតែមិនឈប់ គិតតែពីបោលនាំស្ដេចទៅខាងមុខប៉ុណ្ណោះ។ ចំណែកអនុកេវដ្ដៈ លុះត្រឡប់មកក្រោយវិញ ក៏បានចូលទៅក្នុងបន្ទាយកងទ័ព ស្រែកឆោឡោឡើងថា៖

"ស្ដេចចូឡនីព្រហ្មទត្តរត់ហើយៗ"។

ពួកចារបុរសទាំងអស់ ដែលបង្កប់ខ្លួនក្នុងនោះ ក៏បានស្រែករួមជាមួយនឹងពលទាហានទាំងអស់ដែរ។ ស្ដេចផ្សេងៗ ឮដូច្នោះគិតថា "មហោសថ ប្រាកដជាលើទ័ពចេញមកសម្លាប់ពួកយើងជាមិនខាន"។ ស្ដេចគ្រប់អង្គ ទ្រង់មានការភ័យតក់ស្លុត មិនខ្វល់នឹងមើលគ្រឿង

ឧបភោគ និងគ្រឿងបរិភោគអ្វីឡើយ ហើយក៏រត់បែកផ្លូវគ្នាទៅតាមទិសរៀងៗខ្លួន តាមដែលអាចរត់ទៅបានៗ

ពួកទាហានបានស្រែកយ៉ាងខ្លាំងៗទៀតថា៖

"ស្តេចទាំងឡាយ ទ្រង់រត់អស់ហើយៗ"ៗ

ពួកទាហានដែលឈរជើងតាមទ្វារ និងប៉មជាដើម ឮដូច្នោះក៏ស្រែកផងទះដៃផងៗ និយាយរួមមក នគរទាំងមូលកក្រើករំពើកភ្លូកភ្លឹក ឮតែសូរស្រែកអ៊ូរអរតែម្យ៉ាង ទាំងខាងក្នុងទាំងខាងក្រៅ បីដូចការរញ្ជួយស្រុតបាក់នៃប្រឹថពី និងដូចរលកធំៗ នៃមហាសមុទ្រៗ ទ័ពចំនួន ១៨ អក្ខោភិនីរបស់ស្តេចចូឡនី ឮដំណឹងថា ស្តេចរបស់ខ្លួន និងស្តេចផ្សេងៗទៀត ត្រូវមហោសថចាប់បានៗ ម្នាក់ៗភ័យខ្លាចស្លាប់ នាំគ្នារត់យកតែព្រះអាយុស ខ្លះមិនទាន់បានស្លៀកពាក់ខោអាវស្រួលបួលផង ខ្លះទៀតចោលសម្ភារៈទ័ព រាយប៉ាយពេញទូទាំងបន្ទាយៗ ទីតាំងបន្ទាយទ័ពរបស់ស្តេចចូឡនីមើលទៅឃើញទទេស្ងាត់ជ្រងំ រកមនុស្សម្នាក់គ្មានៗ ស្តេចចូឡនីព្រហ្មទត្ត បាននាំស្តេច ១០១ អង្គធ្វើដំណើរទៅកាន់នគររបស់ខ្លួនវិញៗ

**ជ័យភណ្ឌក្រោយសង្គ្រាម**

ព្រឹកថ្ងៃបន្ទាប់ ពួកពលរបស់សេនាប្រមុខមហោសថ បានបើកទ្វារនគរទាំង ៤ នាំគ្នាចេញពីក្រុង ឃើញរបស់របរជយភណ្ឌច្រើនដេរដាសដូច្នោះ បានទៅជម្រាបលោកសេនាប្រមុខឲ្យជ្រាបនិងសួរថា៖

"តើពួកខ្ញុំនឹងធ្វើដូចម្ដេច លោកបណ្ឌិត?"

មហោសថប្រាប់ថា៖

"ទ្រព្យដែលពួកទាហានទាំងនោះ បោះបង់ចោល នឹងក្លាយជារបស់ពួកយើងហើយ។ ទ្រព្យណាជារបស់ស្ដេច ពួកលោកចូរយកទៅថ្វាយស្ដេចយើង។ រីឯរបស់ណាជារបស់សេដ្ឋី និងកេវដ្តព្រាហ្មណ៍ ពួកលោកចូរយកមកសម្រាប់ពួកយើង។ វត្ថុក្រៅពីនោះ ចូរឲ្យពួកអ្នកនគររបស់យើងយកប្រើប្រាស់ផងចុះ"។

ពួកទាហានដឹកជញ្ជូនជយភណ្ឌ ដែលជារតនៈមានតម្លៃច្រើនអស់រយៈពេលកន្លះខែ។ របស់របរនិងសម្ភារៈផ្សេងៗក្រៅពីនោះពួកគេជញ្ជូន ៤ ខែ ទើបអស់។ សេនាប្រមុខមហោសថ បានផ្ដល់រង្វាន់ដ៏ច្រើនបន្ថែមទៀតដល់លោកអនុកេវដ្តៈ។ ម្យ៉ាងទៀត អ្នកនគរមិថិលា មានមាស ប្រាក់ច្រើនរហូតដល់សព្វថ្ងៃនេះ ក៏ដោយសារទទួលបាននូវជយភណ្ឌក្នុងសមរភូមិ ដែលស្ដេចចូឡនីព្រហ្មទត្តចាញ់

សង្គ្រាម តាំងពីគ្រានោះមកៗ រីឯស្តេចចូឡនីព្រហ្មទត្តវិញ បានគង់នៅឯនគរបញ្ចាល ភាគខាងជើងជាមួយនឹងស្តេច ១០១ អង្គ មិនមានព្រះហឫទ័យបង្កើតសង្គ្រាមក្នុងរយៈពេល ១ ឆ្នាំៗ

យុទ្ធបរាជយកណ្ឌ ចប់

# ជំពូកទី ៩

## ល្បិចទល់ល្បិច

## សុវកណ្ឌ

## សេកមាធុរៈប្រលោមស្ដេចសារិកា

### ល្បិចនាក់ស្ដេចវិទេហៈ

*តមកក្នុងថ្ងៃមួយ កេវដ្តព្រាហ្មណ៍ ចុះកញ្ចក់មើលមុខខ្លួនឯង បានឃើញស្លាកស្នាមនៅជាប់លលាដ៍ក្បាល គិតថា "នេះជាទង្វើរបស់មហោសថធ្វើមកលើអញ វាធ្វើឲ្យអញអាម៉ាស់មុខក្នុងកណ្ដាលជំនុំពួកស្ដេច ១០១ អង្គ"។ លុះគិតដូច្នេះហើយ គាត់ក៏ចងគំនុំក្នុងចិត្តថា "តើដល់កាលណាទៅហ្ន៎ ទើបអញមានសមត្ថភាពអាចឃើញភាពទាល់ច្រករបស់មហោសថនោះបាន?" កេវដ្តព្រាហ្មណ៍បានរិះរកគ្រប់មធ្យោបាយដើម្បីឈ្នះមហោសថ គាត់មានឧបាយកលពិសេសមួយទៀតគឺ នឹងយករាជធីតារបស់ព្រះមហាក្សត្រខ្លួន មាននាមថា* ***បញ្ចាលចន្ទី*** *ព្រះនាងមានរូបឆោមលោមពណ៌សម្បុរស្រស់ឆើតឆាយ ស្អាតបីដូចទេពអប្សរ ធ្វើជានុយប្រលោមស្ដេចវិទេហរាជដោយកាមគុណ នឹងថ្វាយព្រះនាងដល់ព្រះបាទវិទេហរាជ ហើយនឹងក្របួចកស្ដេច*

វិទេហរាជ ព្រមទាំងមហោសថ យកមកសម្លាប់ទាំងពីរនាក់ឲ្យដូចត្រី លេបនុយ រួចហើយនឹងធ្វើពិធីជប់លៀងសោយទឹកជយបាន។ ធ្វើសេចក្តីសន្និដ្ឋានតែម្នាក់ឯងដូច្នេះហើយ ក៏បានចូលទៅគាល់ព្រះបាទចូឡនីព្រហ្មទត្ត ក្រាបទូលព្រះអង្គថា៖

"បពិត្រព្រះសម្មតិទេព ទូលបង្គំ មានកិច្ចដ៏ធំមួយដែលនឹងត្រូវពិភាក្សាជាមួយនឹងព្រះអង្គ"។

ស្តេចត្រាស់តបថា៖

"ដោយសារតែការពិភាក្សារបស់អ្នកហ្នឹងហើយ ទើបពួកយើងរត់បាត់មេបាត់កោយបោលទាំងខោពីចង្កេះ។ ឥឡូវ តើលោកនឹងធ្វើអ្វីទៀត? បើយកល្អ សូមលោកស្ងាត់ស្ងៀមវិញទៅប្រសើរជាង"។

កេវដ្ដៈទូលតបថា៖

"បពិត្រមហារាជ ឧបាយមុនៗ ពុំស្មើនឹងឧបាយនេះទេ ក្រាបទូល"។

"បើអ៊ីចឹង លោកចូរនិយាយមកចុះ" ស្តេចត្រាស់តប។

កេវដ្ដៈទូលតបថា៖

"បពិត្រមហារាជ ការពិភាក្សានៅកន្លែងមួយដែលមានតែព្រះអង្គ និងទូលព្រះបង្គំ ទើបបាន ក្រាបទូល"។

"បើអ៊ីចឹងក៏បាន តោះយើង" ស្ដេចទ្រង់ត្រាស់។

គ្រានោះ កេវដ្តព្រាហ្មណ៍សូមយាងព្រះរាជាឲ្យឡើងទៅលើប្រាសាទជាន់លើ ហើយក្រាបទូលថា៖

"បពិត្រមហារាជ យើងនឹងប្រលោមស្ដេចវិទេហរាជ ដោយកាមគុណ។ យើងនឹងបញ្ឆោតស្ដេចអង្គនោះ ឲ្យមកនគរយើងនេះ បន្ទាប់មក យើងនឹងសម្លាប់ស្ដេចអង្គនោះចោល ជាមួយនឹងទីប្រឹក្សារបស់ព្រះអង្គគឺ មហោសថតែម្ដង"។

ស្ដេចទ្រង់ត្រាស់ថា៖

"ល្អណាស់លោកអាចារ្យ ឧបាយនេះ ប៉ុន្តែយើងប្រលោមស្ដេចនោះ ឲ្យមកទីនេះបានដោយឧបាយកលដូចម្ដេចទៅ?"

កេវដ្តៈទូលតបថា៖

"បពិត្រមហារាជ **បញ្ចាលចន្ទី** រាជធីតារបស់ព្រះអង្គ ព្រះនាងមានរូបឆោមលោមពណ៌សម្បុរស្រស់ឆើតឆាយ លើសស្រីនានាក្នុងលោក យើងនឹងឲ្យពួកកវីតែងនូវបទចម្រៀង ពិពណ៌នាអំពី

រូបសម្បត្តិរបស់ព្រះនាង ជាមួយនឹងទំនុកបទតន្ត្រីដ៏ពីរោះ ហើយឲ្យអ្នកចម្រៀង ច្រៀងនូវបទទាំងនោះក្នុងក្រុងមិថិលា និងមានលាយឃ្លាបញ្ជាក់ថា ស្ដេចវិទេហៈទ្រង់មានតែរាជសម្បត្តិ បើមិនបានស្ត្រីកែវបែបនេះ មិនមានប្រយោជន៍សោះឡើយ។ លុះដឹងថា ស្ដេចវិទេហៈ ចាប់ចិត្តប្រតិព័ទ្ធដោយការជាប់ជំពាក់នឹងការស្ដាប់ចម្រៀងនោះហើយ ទូលព្រះបង្គំជាខ្ញុំនឹងទៅទីនោះ ដេញពេលារកថ្ងៃកំណត់រៀបអភិសេក។ កាលកំណត់ពេលាអភិសេកបានហើយ ទូលបង្គំជាខ្ញុំនឹងត្រឡប់មកវិញ។ ព្រះបាទវិទេហរាជនឹងយាងមកដែរ ព្រះអង្គនឹងនាំមហោសថមកជាមួយផង។ កាលបើធ្វើយ៉ាងនេះ យើងមុខតែសម្លាប់អ្នកទាំងពីរនោះបានយ៉ាងងាយ ដូចត្រីលេបនុយមានផ្លែសន្ទូចដូច្នោះឯង”។

ព្រះបាទចូឡនី ទ្រង់ព្រះសណ្ដាប់ឧបាយកល របស់កេវដ្តព្រាហ្មណ៍ ហើយ ទ្រង់សព្វព្រះហឫទ័យជាពន់ពេកថា៖

“ឧបាយកលនេះល្អណាស់ លោកអាចារ្យ យើងនឹងធ្វើតាម”។

សូមបញ្ជាក់ថា ការប្រឹក្សាវាងព្រះរាជានឹងកេវដ្តព្រាហ្មណ៍ ត្រូវបានសត្វសារិកា ដែលចិញ្ចឹមនៅក្បែរក្រឡាព្រះបន្ទំរបស់ព្រះបាទចូឡនីស្ដាប់ឮ ហើយចាំបានទាំងអស់។

## ចម្រៀងមន្តស្នេហ៍

ព្រះបាទចូឡនីបានត្រាស់បញ្ជាឲ្យអញ្ជើញពួកបណ្ឌិតកវីកំណាព្យមកចូលគាល់ ទ្រង់ព្រះរាជទាននូវទ្រព្យជាច្រើន ហើយបង្ហាញឲ្យពួកគេ បានឃើញព្រះរាជធីតារបស់ព្រះអង្គ និងបានប្រាប់ពួកកវីទាំងនោះឲ្យតែងកំណាព្យ កាព្យឃ្លោង ពិពណ៌នាអំពីរូបសម្បត្តិរបស់ព្រះរាជធីតាអង្គនោះៗ កវីកំណាព្យទាំងនោះ បាននិពន្ធកំណាព្យជាបទចម្រៀង បង្កប់ដោយមន្តស្នេហ៍ជាច្រើន ហើយបានអានថ្វាយព្រះរាជាទ្រង់ព្រះសណ្តាប់ៗ ព្រះរាជាទ្រង់សព្វព្រះហឫទ័យជាពន់ពេក ហើយបានព្រះរាជទាន នូវព្រះរាជអំណោយដ៏ច្រើន ដល់ពួកកវីទាំងនោះថែមទៀតៗ អ្នកចម្រៀងទាំងឡាយបានហាត់ច្រៀងនូវកំណាព្យទាំងនោះ អំពីសម្នាក់របស់ពួកកវីហើយ បាននាំគ្នាច្រៀងនៅលើឆាកមហោស្រពនានាៗ មិនយូរប៉ុន្មាន បទចម្រៀងទាំងនោះបានផ្សព្វផ្សាយទៅយ៉ាងទូលំទូលាយ ហើយក៏បានជ្រួតជ្រាបដល់មនុស្សជាច្រើនៗ ព្រះរាជាបានឲ្យហៅពួកអ្នកចម្រៀងមកចូលគាល់ រួចទ្រង់ត្រាស់ថា៖

"នែអ្នកទាំងឡាយ ចូរអ្នកចាប់សត្វស្លាបធំៗមកចងទុកៗ លុះដល់ពេលយប់ ចូរពួកអ្នកយកសត្វស្លាបឡើងទៅលើដើមឈើធំៗ ខ្ពស់ៗ ហើយច្រៀងលើដើមឈើនោះៗ ដល់ពេលអរុណរះ

ឡើង ពួកអ្នកចូរចងថាសសរិទ្ធិឲ្យជាប់ត្រង់កសត្វស្វាបទាំងនោះ ហើយបង្ហើរពួកវាទៅ រួចពួកអ្នកចុះមកវិញចុះ”។

ព្រះរាជាធ្វើបែបនេះ ប្រយោជន៍ដើម្បីប្រកាសកាពល្បីល្បាញ ឲ្យប្រជាជនភ្ញាក់ផ្អើលថា “សូម្បីតែទេវតា ក៏ច្រៀងសរសើរពីរូបសម្បត្តិ របស់ព្រះរាជធីតានៃស្តេចក្រុងបញ្ចាលដែរ”។ ក្រោយមកទៀត ព្រះរាជា បានឲ្យអាមាត្យអញ្ជើញពួកកវីមកគាល់ជាថ្មីម្តងទៀត ហើយទ្រង់ត្រាស់បង្គាប់ថា៖

“នែអ្នកទាំងឡាយ ឥឡូវនេះ ពួកអ្នកចូរនិពន្ធបទចម្រៀងសរសើរពីឥស្សរិយៈយើងផង ពីរូបសម្បត្តិនៃបុត្រីរបស់យើងផង ថា ព្រះរាជធីតាបែបនេះ មិនសក្តិសមដល់ស្តេចដទៃណាក្នុងសកលជម្ពូទ្វីបទេ សក្តិសមចំពោះតែព្រះបាទវិទេហរាជ ស្តេចក្រុង មិថិលាតែមួយអង្គប៉ុណ្ណោះ”។

ពួកកវីបាននាំគ្នានិពន្ធដូច្នោះហើយ ក្រាបទូលព្រះបាទចូឡនីឲ្យទ្រង់ជ្រាប។ ព្រះរាជា ក៏បានប្រទានរង្វាន់ជាច្រើនដល់ពួកគេ រួចទ្រង់ត្រាស់បង្គាប់ពួកអ្នកចម្រៀងថា៖

“នែអ្នកទាំងឡាយ ចូរពួកអ្នកចូលទៅក្រុងមិថិលាច្រៀងឲ្យបានពីរោះ ដូចអ្នកច្រៀងនៅទីនេះ កុំឲ្យល្បៀងក្នុងទីប្រជុំជនឲ្យសោះ”។

អ្នកចម្រៀងទាំងនោះ បានច្រៀងបទចម្រៀងទាំងនោះតាមលំដាប់ ចេញពីស្រុកមួយ ចូលទៅស្រុកមួយ រហូតបានទៅដល់ក្រុងមិថិលា ក៏បានច្រៀងនៅលើឆាកមហោស្រពមួយ។ មហាជនដែលបានស្ដាប់បទចម្រៀងទាំងនោះហើយ បាននាំគ្នាទះដៃអបអរសាទរគាំទ្រនិងជូនរង្វាន់ជាច្រើនដល់ពួកសិល្បករ។ ក្នុងពេលរាត្រី[១៤៦] អ្នកចម្រៀងទាំងនោះនាំគ្នាឡើងលើដើមឈើ ច្រៀងថតដាក់ក្នុងថាសសំរិទ្ធិ រួចចងជាប់នឹងកបក្សីទាំងឡាយ ហើយព្រលែងពួកវាឲ្យហើរក្នុងពេលជិតភ្លឺ ទើបនាំគ្នាចុះមកវិញ។ សូរសព្ទនៃបទចម្រៀង បានលាន់ឮនៅឮដ៏អាកាស ធ្វើឲ្យអ្នកនគរទូទៅមានការភ្ញាក់ផ្អើលថា "សូម្បីតែពួកទេវតាក៏បានច្រៀងសរសើរអំពីរូបសម្បត្តិ របស់ព្រះរាជធីតានៃស្ដេចក្រុងបញ្ចាលដែរ"។

**កេវដ្ដព្រាហ្មណ៍នៅដេញពេលារៀបអភិសេក**

ព្រះបាទវិទេហរាជ ទ្រង់បានឮការផ្សាយបទចម្រៀងមន្តស្នេហ៍ហើយ ក៏បានបង្គាប់អាមាត្យឲ្យទៅអញ្ជើញពួកអ្នកចម្រៀង រៀបចំឆាកមហោស្រពលេងក្នុងព្រះបរមរាជវាំង ទ្រង់ត្រេកអរដោយបានឮ

---

[១៤៦] តេ រត្តិសមយេ រុក្ខេសុបិ គាយិត្វា បច្ចូសកាលេ សកុណានំ គីវាសុ កំសតាលេ ពន្ធិត្វា ឱតរន្តិ។ អាកាសេ កំសតាលសទ្ទំ សុត្វា "បញ្ចាលរាជធីតុ សរីរវណ្ណំ ទេវតាបិ គាយន្តី"តិ សកលនគរេ ឯកកោលាហលំ អហោសិ។

ចម្រៀងច្រៀងថា ស្ដេចចូឡនី មានបំណងប្រទានរាជធីតា ដែលមានរូបស្អាតដូចទេពអប្សរដល់ព្រះអង្គ។ ហើយព្រះអង្គក៏បានប្រទាន រាជទ្រព្យជាច្រើនដល់ពួកអ្នកចម្រៀងទាំងនោះ។ អ្នកចម្រៀងទាំងឡាយនោះបានមករាយការណ៍ថ្វាយដំណើរនោះ ចំពោះព្រះបាទចូឡនី។ គ្រានោះ កេវដ្ដព្រាហ្មណ៍ប្រឹក្សានឹងព្រះបាទចូឡនីថា៖

"បពិត្រមហារាជ ឥឡូវនេះ ទូលបង្គំជាខ្ញុំនឹងទៅជេញពេលាកំណត់ថ្ងៃអភិសេក"។

"ល្អហើយលោកអាចារ្យ តើលោកគួរយកអ្វីទៅជាមួយផងទេ?" ស្ដេចទ្រង់ត្រាស់សួរ។

កេវដ្ដៈទូលតបថា៖

"យកតែគ្រឿងបណ្ណាការទៅបន្តិចបន្តួច គួរណាស់ទៅហើយ"។

"បើអ៊ីចឹង ចូរអ្នកអញ្ជើញយកចុះ" ព្រះរាជាចូឡនីទ្រង់ត្រាស់។

បន្ទាប់មក កេវដ្ដព្រាហ្មណ៍ ជាមួយនឹងបរិវារជាច្រើន បានយកគ្រឿងបណ្ណាការធ្វើដំណើរទៅ រៀងរាបដរាបដល់ដែនដីវិទេហរដ្ឋ។ ការធ្វើដំណើរចូលមកដែនដីវិទេហរដ្ឋរបស់កេវដ្ដព្រាហ្មណ៍ម្ដងនេះ បានធ្វើឲ្យអ្នកនគរទូទៅភ្ញាក់ផ្អើលថា៖

"ព្រះបាទចូឡនីនិងព្រះបាទវិទេហៈនឹងចងសម្ពន្ធមិត្រជាមួយគ្នា។ ព្រះបាទចូឡនី នឹងប្រទានព្រះរាជធីតារបស់ព្រះអង្គ ចំពោះព្រះរាជារបស់ពួកយើង។ ឥឡូវនេះ កេវដ្តព្រាហ្មណ៍មកជ្រើសរើសពេលាកំណត់ថ្ងៃរៀបអភិសេកហើយ"។

ព្រះបាទវិទេហរាជ និងលោកសេនាប្រមុខមហោសថ ក៏បានទទួលដំណឹងនេះដែរ។ ប៉ុន្តែលោកសេនាប្រមុខមានសេចក្តីត្រិះរិះដូច្នេះថា៖

"កេវដ្តព្រាហ្មណ៍មកទីនេះ មិនគាប់ចិត្តអញសោះ ប្រាកដជាមានកលល្បិចអ្វីមិនខាន អញនឹងស៊ើបអង្កេតឲ្យបានដឹងរឿងនេះ តាមភាពជាក់ស្តែង" ហើយលោកក៏បានបញ្ជូនសារទៅឲ្យពួកចារបុរស ដែលកំពុងបង្កប់ខ្លួននៅក្នុងសម្នាក់របស់ព្រះបាទចូឡនី ដោយសេចក្តីថា៖

"សូមអ្នកស៊ើបអង្កេតរកការណ៍ពិតនៃរឿងនេះ ហើយត្រូវបញ្ជូនដំណឹងមកវិញជាប្រញាប់"។

ពួកចារបុរសបានទទួលសារលិខិតហើយ ក៏បានឆ្លើយតបទៅវិញថា៖

"ពួកខ្ញុំមិនអាចដឹងអាថ៌កំបាំងនៃរឿងនេះបានទេ។ ស្តេច និងកេវដ្តៈ បានអង្គុយប្រឹក្សាគ្នា ក្នុងបន្ទប់ក្រឡាបន្ទំនៅប្រាសាទជាន់លើ ប៉ុន្តែមានសត្វសារិការបស់ស្តេចចូឡនីតែមួយគត់

ដែលបានដឹងពីរឿងរ៉ាវនុ៎ះ ព្រោះសត្វសារិកានោះ ព្រះរាជាទ្រង់បានចិញ្ចឹមទុកក្នុងទ្រុងមាស ក្បែរក្រឡាព្រះបន្ទំរបស់ព្រះអង្គ"។

ព្វដូច្នោះហើយ លោកសេនាប្រមុខមហោសថគិតថា "អញមិនត្រូវឲ្យកេវដ្តព្រាហ្មណ៍ ដែលជាបច្ចាមិត្រយល់ដឹងពីការរៀបចំល្អ និងការរីកចម្រើនរបស់នគរអញបានទេ"។ គិតដូច្នេះហើយ មហោសថបញ្ជាពួកទាហានឲ្យយកកន្ទេលផែនធំៗ បិទបាំងសងខាងផ្លូវដើរតាំងអំពីទ្វារនគររហូតដល់ព្រះរាជវាំង តាំងអំពីព្រះរាជវាំងរហូតដល់លំនៅឋានរបស់ខ្លួន សូម្បីតែកំពូលអគារ ក៏លោកឲ្យយកកន្ទេលផែនបិទបាំងដែរ រួចឲ្យធ្វើវិចិត្រកម្ម លម្អដោយរោយរាយផ្កាឈើផ្សេងៗលើដី តម្កល់ក្អមដែលមានទឹកពេញ តាំងដើមចេក លើកទង់ជាតិ និងចងបដា ដើម្បីស្វាគមន៍រាជទូតកេវដ្តព្រាហ្មណ៍។ កេវដ្ដៈចូលទៅនគរមិនបានឃើញសោភណភាពនគរដោយសព្វគ្រប់សោះ ក៏គិតថា ស្ដេចឲ្យគេតុបតែងផ្លូវដើម្បីខ្លួន មិនដឹងថា មហោសថធ្វើមិនឲ្យខ្លួនបានទស្សនានគរនោះទេ។ បណ្ឌិតកេវដ្ដៈបានបន្តដំណើរត្រោះទៅគាល់ព្រះបាទវិទេហរាជ ហើយក្រាបទូលថ្វាយគ្រឿងបណ្ណាការដោយគោរពរួចអង្គុយក្នុងទីដ៏សមគួរ។ បន្ទាប់អំពីព្រះរាជាទ្រង់ធ្វើបដិសណ្ឋារៈ

ដោយសេចក្តីរាប់អានយ៉ាងរាក់ទាក់ហើយ គាត់ក៏បានក្រាបទូលព្រះរាជាអំពីគោលបំណងរបស់ខ្លួនថា៖

"ព្រះបាទចូឡនី ស្តេចរបស់ពួកទូលបង្គំយើងខ្ញុំ មានបំណងចងសម្ពន្ធមិត្រជាមួយនឹងព្រះអង្គ ទាំងមានរាជបំណងទ្រង់ថ្វាយកែវទាំងឡាយ មានស្រីកែវជារាជធីតារបស់ព្រះអង្គផ្ទាល់ជាដើម ចំពោះព្រះអង្គ។ ចាប់ដើមពីថ្ងៃនេះទៅ សូមឲ្យពួករាជទូតទាំងឡាយនៃនគរយើងទាំងពីរ នាំយកគ្រឿងបណ្ណាការអំពីឧត្តរបញ្ចាលនគរ មកនគរមិថិលានេះ និងពីនគរមិថិលានេះទៅនគរឧត្តរបញ្ចាលនោះវិញ។ សូមឲ្យពួករាជទូតទាំងពីរប្រទេសពោលវាចាដ៏ទន់ភ្លន់ ជាវាចាគួរត្រេកអរ សូមស្តេចក្រុងបញ្ចាលនិងស្តេចក្រុងមិថិលាទាំងពីរអង្គនោះ បានសន្ទនាគ្នា រួបរួមគ្នាជាធ្លុងមួយ ឲ្យដូចជាទឹកទន្លេគង្គានិងទន្លេយមុនា ទៅមករកគ្នាដូច្នោះឯង"។

បន្ទាប់មក កេវដ្តព្រាហ្មណ៍ពោលបន្តថា៖

"បពិត្រមហារាជ ស្តេចរបស់ពួកទូលបង្គំយើងខ្ញុំ ប្រុងនឹងបញ្ជូនលោកមហាមន្ត្រីមកទេ តែព្រះអង្គបញ្ជូនទូលបង្គំមកវិញ ដោយសារតែព្រះអង្គទ្រង់មានព្រះតម្រិះថា បុគ្គលដទៃមិនអាចធ្វើ

សេចក្ដីភយ ការណ៍រាជសារថ្វាយព្រះអង្គឲ្យជាទីសព្វព្រះហឫទ័យបានឡើយ ក្រាបទូល។ ព្រះបាទចូឡនីទ្រង់មានរាជបណ្ដាំថា កាលណាទូលបង្គំក្រាបទូលថ្វាយព្រះអង្គឲ្យទ្រង់ជ្រាបច្បាស់ហើយ សូមឲ្យទូលបង្គំយាងព្រះអង្គទៅជាមួយកុំខាន។ សូមមហារាជស្ដេចយាងទៅ ក្រាបទូល។ ព្រះអង្គប្រាកដជាបាននូវរាជធីតាវ័យក្មេង ដែលមានរូបស្អាតគ្មានពីរ យ៉ាងពិតប្រាកដ។ មិត្តភាពរវាងព្រះអង្គនិងស្ដេចរបស់ពួកទូលបង្គំ នឹងឋិតថេរចីរកាល មិនមានប្រេះឆាឡើយ"។

## កេវដ្ដព្រាហ្មណ៍នៅផ្ទះមហោសថ

ព្រះបាទវិទេហរាជ ទ្រង់ព្រះសណ្ដាប់ពាក្យពេចន៍នៃកេវដ្ដៈរួចព្រះអង្គទ្រង់មានព្រះហឫទ័យត្រេកអរឥតឧបមា ហើយទ្រង់មានព្រះតម្រិះថា "យើងនឹងបានស្រីក្រមុំដែលមានរូបឆោមដ៏ឧត្ដមហើយពេលនេះ"។ ព្រះបាទវិទេហៈទ្រង់រំភើបខ្លាំងណាស់ ព្រោះទ្រង់បានទទួលនូវរាជសារពិសេសនេះ ព្រះអង្គទ្រង់មានព្រះតម្រាស់ថា៖

"នែលោកអាចារ្យ យើងដឹងថា លោកនិងមហោសថមានវិវាទគ្នាក្នុងសង្គ្រាមធម៌។ សូមអញ្ជើញលោកទៅជួបកូនយើងសិន។

បណ្ឌិតទាំងពីរនាក់ សូមអត់ទោសឲ្យគ្នានឹងគ្នាទៅវិញទៅមក ប្រឹក្សាគ្នាហើយចាំអញ្ជើញត្រឡប់មកជួបយើងវិញចុះ"។

ឮព្រះរាជតម្រាស់ដូច្នោះ កេវដ្ដៈបានថ្វាយបង្គំលាព្រះរាជា ធ្វើដំណើរទៅជួបមហោសថ។

ក្នុងថ្ងៃនោះ មហោសថគិតថា អញមិនចង់ចរចាជាមួយនឹងកេវដ្ដព្រាហ្មណ៍ ជាមនុស្សថោកទាបនោះឡើយ ដូច្នេះ លោកបានផឹកសប្បិ(ទឹកដោះថ្លា)បន្តិច ពីព្រលឹមយកអាចម៍គោស្រស់ លាបបូកគេហដ្ឋានយ៉ាងក្រាស់ យកប្រេងលាបតាមសសរផ្ទះ ទុកតែគ្រែសម្រាន្តមួយសម្រាប់ទទួលកេវដ្ដៈ។ មហោសថ ឲ្យគេជញ្ជូន តុ តាំង កៅអីនិងគ្រែជាដើម ទៅទុកនៅឯក្រៅផ្ទះអស់។

លោកបានផ្ដាំនឹងមនុស្សជំនិតៗរបស់ខ្លួនថា៖

"នែអស់លោក កាលបើកេវដ្ដព្រាហ្មណ៍ចាប់ផ្ដើមនិយាយ ពួកលោកគប្បីនិយាយស្កាត់យ៉ាងនេះថា 'នែតាព្រាហ្មណ៍ កុំមានប្រសាសន៍ជាមួយនឹងលោកបណ្ឌិត ព្រោះថ្ងៃនេះ គាត់ទើបតែពិសាថ្នាំងងុយ។ ម្យ៉ាងទៀត កាលដែលខ្ញុំធ្វើអាការរកនិយាយនឹងកេវដ្ដៈនោះ ពួកលោកគប្បីឃាត់ខ្ញុំថា 'សូមលោកបណ្ឌិតកុំមានប្រសាសន៍អី ព្រោះលោកទើបតែពិសាថ្នាំងងុយ"។

លុះបានផ្តាំយ៉ាងនេះរួចហើយ មហោសថស្លៀកសំពត់ពណ៌ក្រហម ដើរបង្គាប់ពួកទាហានឲ្យឈរយាម នៅតាមខ្លោងទ្វារទាំង ៧ ហើយលោកទៅសម្រាន្តនៅក្នុងបន្ទប់សម្ងាត់របស់លោក ដែលស្ថិតនៅខាងខ្លោងទ្វារទី ៧ ។ ចំណែកកេវដ្តៈមកដល់គេហដ្ឋានរបស់លោកសេនាប្រមុខមហោសថ នៅខ្លោងទ្វារទីមួយ ក៏សួរពួកអ្នកយាមថា៖

"លោកបណ្ឌិតមហោសថនៅឯណា?"

ពួកអ្នកយាមបានប្រាប់កេវដ្តៈថា៖

"បពិត្រលោកអាចារ្យ សូមលោកកុំមានប្រសាសន៍ខ្លាំងពេក ប្រសិនបើលោកមានបំណងចូលមក សូមលោកចូលមកដោយភាពស្ងាត់ស្ងៀមៗ ដ្បិតអីថ្ងៃនេះ លោកបណ្ឌិតគាត់បានពិសាថ្នាំងងុយ មិនគួរណាលោកមានប្រសាសន៍ខ្លាំងរំខានគាត់ទេ"។

សូម្បីពួកអ្នកយាមតាមខ្លោងទ្វារផ្សេងៗ ក៏បានជម្រាបអាចារ្យកេវដ្តៈ ដូច្នោះដែរ។ កេវដ្តព្រាហ្មណ៍ ដើរហួសខ្លោងទ្វារទី៧ ក៏សំដៅត្រោះទៅកាន់សម្ងាត់របស់លោកសេនាប្រមុខមហោសថ។ បណ្ឌិតមហោសថ លុះឃើញកេវដ្តព្រាហ្មណ៍ដើរមក លោកសម្តែងអាការៈដូចជារកនិយាយជាមួយ ស្រាប់តែពួកអ្នកបម្រើរបស់លោកឃាត់ថា៖

"បពិត្រលោកបណ្ឌិត សូមកុំមានប្រសាសន៍អី លោកទើបតែពិសាថ្នាំផ្សុយថ្មីៗផង ការមានប្រសាសន៍ជាមួយនឹងព្រាហ្មណ៍អាក្រក់នេះ មានប្រយោជន៍អ្វីដល់លោកបណ្ឌិត"។

កេវដ្តព្រាហ្មណ៍នោះ ទោះបីគាត់បានចូលទៅដល់សម្នាក់របស់លោកសេនាប្រមុខក៏ពិតមែន ប៉ុន្តែគាត់រកកន្លែងអង្គុយមិនបាន រកទីឈរក្បែរអាសនៈក៏មិនបាន ដើរងាកទៅកន្លែងណា ក៏ជាន់តែអាចម៍គោស្រស់ ថែមទាំងត្រូវពួកមនុស្សរបស់មហោសថបណ្ឌិតគំរាម ដោយអ្នកខ្លះបញ្ចេញអាការៈ បើកភ្នែកធំ សម្លឹងសម្លក់ដាក់ អ្នកខ្លះញាក់ចិញ្ចើមដាក់ ខ្លះលើកកែងដៃ បង្ហាញសាច់ដុំៗ កេវដ្តព្រាហ្មណ៍ ឃើញកិរិយារបស់ពួកគេដូច្នោះ ក៏កើតសេចក្តីខ្មាសអៀន ហើយនិយាយថា៖

"ខ្ញុំសូមលាហើយ លោកបណ្ឌិត"។

ស្រាប់តែអ្នកបម្រើម្នាក់និយាយថា៖

"នែអាព្រាហ្មណ៍ចង្រៃ អញហាមហើយថា កុំឲ្យនិយាយព្ធខ្លាំង ម្តេចក៏ឯងមិនស្តាប់ ប្រយ័ត្នអញវាយឯងបាក់ឆ្អឹងអស់"។

កេវដ្តះភ័យតក់ស្លុតដើរត្រឡប់មកវិញ ដើរបណ្តើរងាកមើលក្រោយបណ្តើរ ព្រោះខ្លាចគេលបលួចវាយធ្នក់ៗ គ្រានោះ ទាហានម្នាក់ធ្នក់វាយខ្នងកេវដ្តព្រាហ្មណ៍ ដោយបន្ទះឫស្សីមួយខ្ទាប់ ម្នាក់ទៀត ចាប់

ក្របួចកកេវដ្ដៈ រុញច្រាន ម្នាក់ទៀតវាយខ្នងកេវដ្ដៈមួយបាតដៃ។ កេវដ្ដព្រាហ្មណ៍ ខ្វាចតក់ស្លុត ចេញទម្រាំតែផុតពីខ្លោងទ្វារទាំង ៧ បាន ទៅដល់ព្រះរាជវាំងវិញ ហាក់បីដូចជាម្រឹគមានសំណាងរបូតផុតពីមាត់ ខ្លាធំ។

ចំណែកព្រះបាទវិទេហរាជវិញ ទ្រង់ព្រះតម្រិះថា "ក្នុងថ្ងៃនេះ មហោសថ កូនអញ ឮដំណឹងនេះហើយ ជាក់ជាត្រេកអរពុំខាន។ បណ្ឌិតពីរនាក់ ប្រាកដជាមានធម្មសាកច្ឆាធំមិនខាន។ ថ្ងៃនេះ បណ្ឌិត ទាំងពីរនោះ ប្រាកដជាសូមខមាទោសចំពោះគ្នាទៅវិញទៅមក នេះពិត ជាមហាលាភរបស់អញមែនហ្ន៎" លុះឃើញកេវដ្ដៈត្រឡប់មកវិញ ទ្រង់សួរសំណេះសំណាលថា៖

"នែកេវដ្ដៈ អ្នកបានជួបនឹងមហោសថដែរឬ? អ្នកចូរប្រាប់សេចក្ដី នោះមកមើល ថាតើមហោសថរម្ងាប់កំហឹង ហើយអត់ទោស ឲ្យអ្នក ក្នុងរឿងជម្លោះដែលបានកើតឡើងនៅឯមណ្ឌលសង្គ្រាម ធម៌ហើយឬនៅ? ដោយមហោសថទទួលដំណឹងថា ស្ដេចរបស់ អ្នកបានបញ្ជូនអ្នកមកដូច្នេះ តើគេសប្បាយចិត្តឬទេ?"

កេវដ្ដៈឮដូច្នោះ ក្រាបទូលថា៖

“បពិត្រមហារាជ កោតតែព្រះអង្គចាត់ទុកមហោសថនោះថា ជាបណ្ឌិតទៅកើត។ បុគ្គលអសប្បុរស អាក្រក់ជួជាតិ ឲ្យដូចជាមហោសថនោះ រកមិនមានទេក្នុងលោកនេះ ក្រាបទូល”។

បន្ទាប់មក កេវដ្ដៈពោលទោសរបស់មហោសថតទៅទៀតថា៖

“បពិត្រព្រះអង្គជាធំជាងជន មហោសថហៅពេញជាបុរសថោកទាប មិនមែនជាតិជាបណ្ឌិតទេ ពុំមានសេចក្ដីស្មោះ ជាមនុស្សរឹងរូស ជាអសប្បុរស គេពុំបានពោលពាក្យអ្វីមួយមាត់សោះជាមួយនឹងទូលបង្គំឡើយ ដូចជាមនុស្សគ ឬមនុស្សថ្លង់”។

ព្រះរាជា មិនត្រេកអរចំពោះសម្ដីរបស់កេវដ្ដៈនោះទេ ហើយក៏មិនបដិសេធដែរ។ ទ្រង់បានឲ្យអាមាត្យប្រទានស្បៀងនិងលំនៅដល់កេវដ្ដៈ និងគណៈប្រតិភូដែលរួមដំណើរមកជាមួយ។ ទ្រង់ព្រះតម្រិះមួយព្រះអង្គឯងថា “មហោសថបណ្ឌិតកូនអញ ជាមនុស្សឈ្លាសក្នុងបដិសណ្ឋារៈណាស់ ព្រថាគេមិនធ្វើបដិសណ្ឋារៈចំពោះកេវដ្ដព្រាហ្មណ៍ មិនមានសេចក្ដីត្រេកអរចំពោះ កេវដ្ដព្រាហ្មណ៍ ប្រាកដជាគេមានហេតុផលរបស់គេ” រួចទ្រង់មានព្រះរាជឱង្ការមួយព្រះអង្គឯងថា៖

“កាយរបស់អញញាប់ញ័រ បើអញជឿពាក្យញុះញង់របស់កេវដ្ដៈនោះមានន័យថា អញលះបង់មហោសថចោល ម្យ៉ាងទៀត

បើអញលះបង់មហោសថ គឺបីដូចជាអញលះបង់អំណាច និងដែនរបស់ខ្លួន ហើយទៅជ្រកក្រោមអំណាចនៃការគ្រប់គ្រងរបស់អ្នកដទៃក៏ដូច្នោះដែរ។ មហោសថកូនអញគេយល់ច្បាស់ហើយ អ្នកដទៃក្រៅពីកូនអញ កម្រនឹងដឹងការពិតណាស់។ មហោសថ ជាមនុស្សបរិសុទ្ធ មានសេចក្ដីព្យាយាម ប្រាកដជាឃើញហេតុ និងកលល្បិចរបស់កេវដ្ដព្រាហ្មណ៍ ដែលមកទីនេះគឺមិនមែនមកដើម្បីប្រយោជន៍ក្នុងការចងសម្ពន្ធមិត្រទេ គឺប្រាកដជាគេមកដោយប្រើល្បិចល្បួងអញដោយកាម នាំអញទៅកាន់នគរគេហើយ នឹងចាប់អញពុំខាន មហោសថបណ្ឌិតកូនអញប្រាកដជាឃើញភ័យក្នុងរឿងនោះជាក់ច្បាស់ ទើបកូនអញធ្វើដូច្នេះ"។

ក្នុងកាលស្ដេចកំពុងគន់ពិចារណានូវហេតុការណ៍នោះ ស្រាប់តែបណ្ឌិតទាំង ៤ នាក់បានចូលមកដល់។ ព្រះរាជាទ្រង់សួរសេនកៈថា៖

"ម្នាលសេនកៈ ការធ្វើដំណើរទៅក្រុងឧត្តរបញ្ចាល ដណ្ដឹងព្រះរាជធីតារបស់ស្ដេចចូឡនីព្រហ្មទត្តគាប់ចិត្តអ្នកឬទេ?"

សេនកៈទូលតបថា៖

"មានព្រះរាជឱង្ការថាម៉េច? មហារាជ ជាការពិតណាស់ ការដែលសិរីមកដល់ហើយ យកដំបងវាយបណ្តេញវាឲ្យចេញ មិនជាការត្រឹមត្រូវឡើយ ប្រសិនបើព្រះអង្គទៅទីនោះ ស្តីដណ្តឹងព្រះរាជធីតាបានមកធ្វើជាមហេសី ព្រះអង្គនឹងពុំមានស្តេចដទៃណាស្មើនឹងព្រះអង្គបានទេក្នុងសកលជម្ពូទ្វីប លើកលែងតែស្តេចចូឡនីព្រហ្មទត្តចេញ។ ព្រោះហេតុអ្វី? ព្រោះថាព្រះអង្គបានរាជធីតានៃស្តេចកំពូលមកធ្វើជាអគ្គមហេសី។ ពិតណាស់ព្រះបាទចូឡនីអង្គនោះ ទ្រង់បានគិតថា ស្តេចផ្សេងៗជាចំណុះរបស់ទ្រង់ហើយ មានតែព្រះអង្គមួយអង្គទេ ដែលស្មើនឹងព្រះបាទចូឡនី ដូច្នេះហើយ បានជាស្តេចចូឡនី ថ្វាយព្រះរាជធីតាដែលមានរូបឆោមឧត្តមល្អជាច់គេក្នុងសកលជម្ពូទ្វីបចំពោះព្រះអង្គ។ សូមព្រះអង្គ ទ្រង់ស្តេចយាងទៅក្រុងឧត្តរបញ្ចាលដណ្តឹងព្រះរាជធីតា ក្រាបទូល។ សូម្បីពួកទូលបង្គំដែលនៅអាស្រ័យនឹងព្រះអង្គ ក៏នឹងបានសំពត់ និងគ្រឿងអលង្ការដែរ"។

ព្រះរាជាសួរបណ្ឌិត ៣ នាក់ទៀត។ ពួកគេក៏ឆ្លើយដូចលោកបណ្ឌិតសេនកៈដែរ។ កាលព្រះរាជាកំពុងតែប្រឹក្សាជាមួយនឹងបណ្ឌិត ៤ នាក់នោះ មិនទាន់ចប់សេចក្តីផង ស្រាប់តែកេវដ្តព្រាហ្មណ៍បានចេញ

ពីអាគារសំណាក់របស់ខ្លួន ប៉ុន្តែមកថ្វាយបង្គំលាព្រះរាជាត្រឡប់ទៅនគរវិញ ហើយក្រាបទូលព្រះបាទវិទេហរាជថា៖

"បពិត្រព្រះករុណា ពួកទូលបង្គំមិនអាចយឺតយូរបានទេ ទូលបង្គំសូមក្រាបថ្វាយបង្គំលាព្រះអង្គត្រឡប់ទៅវិញឥឡូវនេះ"។

## មហោសថជំទាស់នឹងការរៀបអភិសេក

ព្រះរាជាបានប្រទានរង្វាន់ដល់កេវដ្ដៈ ហើយក៏ជូនដំណើរលោកត្រឡប់ទៅវិញយ៉ាងសមរម្យ។ ចំណែកលោកសេនាប្រមុខមហោសថដឹងថា កេវដ្ដព្រាហ្មណ៍ចេញដំណើរត្រឡប់ទៅវិញហើយ លោកងូតទឹកតុបតែងខ្លួន មកកាន់រាជុបដ្ឋាន ថ្វាយបង្គំព្រះមហាក្សត្រ ហើយអង្គុយក្នុងទីសមគួរ។ ព្រះរាជា ទ្រង់ព្រះតម្រិះថា "មហោសថបណ្ឌិតកូនអញជាអ្នកមានចំណេះវិជ្ជាច្រើន ចេះចប់មន្ដវិជ្ជាទាំងអស់ អាចយល់ដឹងរឿងរ៉ាវទាំងក្នុងអតីតៈ អនាគតនិងបច្ចុប្បន្ន គេប្រាកដជាដឹងថា ដំណើរយាងទៅទីនោះរបស់យើង គួរឬមិនគួរ"។ លុះព្រះតម្រិះដូច្នេះហើយ ព្រះអង្គមិនមានព្រះបន្ទូល តាមព្រះតម្រិះដែលទ្រង់ត្រិះរិះជាដំបូងនោះទេ ទ្រង់បែរជាត្រេកអរដោយរាគៈ វង្វេងដោយមោហៈ ហើយត្រាស់សួរមហោសថនោះដូច្នេះថា៖

"គំនិតរបស់យើងទាំង ៦ នាក់ គឺកេវដ្តព្រាហ្មណ៍ផង អាចារ្យ ៤ នាក់ផង ហើយនិងយើងម្នាក់ផង ដែលជាអ្នកឈ្លាស មានប្រាជ្ញាដ៏ខ្ពង់ខ្ពស់ផុតដូចផែនដីស្មើគ្នាជាឯកច្ឆន្ទថា ការទៅនាំយកព្រះរាជធីតារបស់ព្រះបាទចូឡនី គាប់ចិត្តយើងទាំង ៦ នាក់នេះហើយ បីដូចទឹកទន្លេគង្គាហូរចូលគ្នា ស្មើនឹងទឹកទន្លេយមុនា។ សេចក្តីគាប់ចិត្តរបស់យើងទាំង ៦ នាក់ ប្រមាណមិនបានសោះ។ ម្នាល មហោសថ អ្នកចូរគិតមើលថា តើការយាងទៅរៀបអភិសេក របស់យើងនៅទីនោះ គាប់ចិត្តអ្នកដែរឬទេ ឬក៏កុំយាងទៅ?"។

មហោសថបណ្ឌិតឮដូច្នោះហើយគិតថា "ព្រះរាជាអង្គនេះ ល្មោភកាមខ្លាំងណាស់ ទ្រង់ជឿពាក្យរបស់អាចារ្យ ៤ រូបដោយភាពល្ងង់ខ្លៅ។ អញនឹងនិយាយពីទោសក្នុងការទៅទីនោះ ដើម្បីធ្វើឲ្យព្រះអង្គដកព្រះហឫទ័យវិញ" ហើយក៏បានក្រាបទូលព្រះអង្គដូច្នេះថា៖

"បពិត្រព្រះមហារាជ សូមព្រះអង្គទ្រង់ជ្រាបថា ស្តេចចូឡនីជាអ្នកមានអានុភាពធំ មានយសធំ មានពលច្រើនដល់ទៅ ១៨ អក្ខោភិនី ឥឡូវប្រាថ្នាដើម្បីនឹងសម្លាប់ព្រះអង្គ ដូចនាយព្រានដែលសម្លាប់ម្រឹគដោយផ្លាក់។ ពិតណាស់ នាយព្រានបង្រៀន

ម្រឹគញីមួយ ហើយចងខ្សែនាំយកទៅដាក់ក្នុងព្រៃ ដែលជាកន្លែងរកចំណីរបស់សត្វម្រឹគទាំងឡាយ។ ម្រឹគញីនោះចង់ល្បួងម្រឹគល្ងង់ឲ្យលុះក្នុងអំណាចរបស់ខ្លួន ក៏ស្រែកសូរសៀងដ៏ពីរោះបង្កើតតម្រេក ដោយមាយារបស់ខ្លួន។ ម្រឹគល្ងង់ឮសូរចម្រៀងមន្តស្នេហ៍ដ៏ពីរោះរបស់ម្រឹគញីនោះហើយ ទោះបីកំពុងតែដេកក្នុងព្រៃ ដែលមានហ្វូងម្រឹគញីផ្សេងៗ ចោមរោមជុំជិតក៏ដោយក៏ពុំមានចំណាប់អារម្មណ៍ចំពោះម្រឹគញីផ្សេងៗនោះឡើយ ព្រោះតែវល់ ជាប់ជំពាក់នឹងសំនៀងនៃម្រឹគញីជាផ្លាក់គេនោះ។ ម្រឹគល្ងង់ក្រោកដើរចេញ និងអើតកទៅរកម្រឹគញីនោះ តាមអំណាចនៃកិលេស ឈរបែរខ្នងឲ្យនាយព្រាន។ នាយព្រានក៏បាញ់សរដ៏មុត តម្រង់ទៅម្រឹគឈ្មោលនោះ បណ្តាលឲ្យវាស្លាប់បាត់បង់ជីវិតទៅ។ ក្នុងឧទាហរណ៍នេះ ព្រះបាទចូឡនីប្រៀបដូចនាយព្រាន ព្រះរាជធីតាប្រៀបដូចម្រឹគញីជាផ្លាក់ កេវដ្តព្រាហ្មណ៍ប្រៀបដូចអាវុធក្នុងដៃរបស់នាយព្រាន គឺស្តេចចូឡនីព្រហ្មទត្ត។ សរុបសេចក្តីមកថា នាយព្រានប្រាថ្នាដើម្បីសម្លាប់ម្រឹគដោយផ្លាក់យ៉ាងណា ស្តេចចូឡនីក៏ប្រាថ្នាធ្វើគុតព្រះអង្គយ៉ាងនោះដែរ។ បពិត្រមហារាជ ត្រីទោះបីរស់នៅក្នុងទឹកជ្រៅ ១០០ ព្យាម ក៏នៅតែជាសត្វជាប់ចិត្តនឹងនុយស្រស់ ដែលគេបិទត្រង់ផ្លែ

សន្ទូចនោះ ហើយបានលេបផ្លែសន្ទូច ដែលគេបិទបាំងដោយសាច់ មិនដឹងសេចក្ដីស្លាប់របស់ខ្លួន យ៉ាងណាមិញ ព្រះរាជ-ធីតានោះ មិនខុសអ្វីអំពីនុយ ដែលគេបិទជាប់ត្រង់ផ្លែសន្ទូច គឺជាសម្ដីរបស់កេវដ្ដ ព្រាហ្មណ៍នៃម្ចាស់សន្ទូច គឺព្រះបាទចូឡនីព្រហ្មទត្តទេ។ រីឯព្រះអង្គជាអ្នកជាប់ព្រះទ័យក្នុងកាម ទ្រង់មិនជ្រាបថា រាជធីតារបស់ស្ដេចចូឡនីនោះគឺជានុយទេ ទាំងមិនជ្រាបថា មរណៈរបស់ ព្រះអង្គ ដែលប្រៀបដូចជាត្រីនោះក៏អ៊ីចឹងឯង។ បើព្រះអង្គស្ដេចយាងទៅកាន់ក្រុងឧត្ដរបញ្ចាល ព្រះអង្គមុខជានឹងបាត់បង់ព្រះជន្ម ព្រះអង្គឯងយ៉ាងឆាប់ ភ័យធំនឹងមកដល់ព្រះអង្គ ដូចភ័យធំមកដល់ម្រឹគដែលដើរតាមផ្លូវក្បែរផ្ទះនៃអ្នកស្រុកដែរ។ ពិតមែន ពួកព្រានកាន់អាវុធចេញពីស្រុក ដើម្បីនឹងសម្លាប់ម្រឹគ បានជួបម្រឹគណា ក៏តែងសម្លាប់ម្រឹគនោះ។ ដូច្នេះភ័យធំនឹងកើតដល់ម្រឹគណា ដែលបានដើរតាមផ្លូវក្បែរទ្វារស្រុក។ សេចក្ដីក្នុង ឧទាហរណ៍នេះយ៉ាងណា មរណភ័យដ៏ធំនឹងមកដល់ព្រះអង្គ កាលបើព្រះអង្គទ្រង់យាងទៅកាន់ក្រុងឧត្ដរបញ្ចាលនោះ មានសេចក្ដីដូចដែលទូលបង្គំលើកមកប្រៀបដូច្នោះដែរ”។

លោកសេនាប្រមុខមហោសថបាននិយាយផ្ទួញផ្ទាល់ព្រះបាទវិទេហរាជ ដោយពាក្យទាំងនេះ។

## ព្រះបាទវិទេហៈមើលងាយមហោសថ

ព្រះរាជាអង្គនោះ កាលត្រូវមហោសថក្រាបទូលពន្យល់ ដោយពាក្យបែបផ្ទួញផ្ទាល់ដូច្នេះ ទ្រង់ព្រះពិរោធក្នុងព្រះទ័យថា៖

"មហោសថនេះចាត់ទុកអញដូចខ្ញុំបម្រើរបស់ខ្លួនហើយតើ វាមិនចាត់ទុកថាអញជាស្តេចឯណា។ ស្តេចអគ្គរាជបានបញ្ជូនដំណឹងមកសម្អាក់យើងថា ព្រះអង្គនឹងថ្វាយរាជធីតា គេដឹងហើយ មិននិយាយសម្តីប្រកបដោយមង្គលមួយម៉ាត់សោះ ថាយើងដូចម្រឹគល្ងង់ ដូចត្រីលេបផ្លែសន្ទូច ដូចម្រឹគដែលគេដេញតាមផ្លូវ ហើយនឹងដល់នូវសេចក្តីស្លាប់"។

ព្រះរាជាទ្រង់មានព្រះរាជឱង្ការតបវិញថា៖

"ពួកយើង ខំតែប្រាប់អ្នកអំពីលាភពិសេសដែលត្រូវបាន គឺស្រីកែវដ៏ឧត្តម។ ការប្រាប់របស់យើង អ្នកគួរតែត្រេកអរ ប៉ុន្តែអ្នកបែរជាថាឲ្យយើង ជាមនុស្សល្ងង់ល្ងីល្ងើទៅវិញ។ អ្នកឯងជាមនុស្សបម្រើនវ័យដោយចុងនង្គ័ល ធំពេញវ័យក្នុងការងារស្រែ

ចម្ការៗ អ្នកឯងចេះតែការងារស្រែចម្ការទេ[១៤៧] មិនចេះការងារមន្តលរបស់ពួកស្តេចឡើយៗ អ្នកឯងមិនចេះការងារមន្តលរបស់ពួកស្តេច ដូចបណ្ឌិតផ្សេងៗ មានកេវដ្តព្រាហ្មណ៍ ឬសេនកៈជាដើមនោះ ម្តេចនឹងបានទៅ? ចំណោះរបស់ឯងសមតែទៅធ្វើស្រែចម្ការវិញទេ ទើបបានសក្តិសមនឹងមុខឯង"ៗ

បន្ទាប់ពីជេរផ្តាសាមហោសថដូច្នេះហើយ ព្រះរាជាទ្រង់ពិរោធក្នុងព្រះទ័យថា "មហោសថនេះ កំពុងធ្វើអន្តរាយចំពោះអញហើយទេតើ" ហើយក៏ទ្រង់ស្រែកបញ្ជាថា៖

"នែទាហាន ចូរចាប់កអាមួយនេះ អូសយកទៅប្រហារជីវិតបោលភ្លាម កុំឲ្យវាមានមុខមាត់នៅលើដែនដីរបស់អញទៀត ព្រោះវាហ៊ាននិយាយឲ្យអញអន្តរាយពុំបានស្រីកែវ"ៗ

**សេកធ្វើជាឈ្លបពិសេសស៊ើបមូលហេតុនៃការអភិសេក**

លោកសេនាប្រមុខមហោសថ ដឹងថាស្តេចពិរោធខ្លាំង លោកគិតថា "ប្រសិនបើអញត្រូវនរណាម្នាក់ដែលស្តាប់បញ្ជាស្តេច ចាប់ដៃឬចាប់កអញ មុខតែអញខ្មាសអ្នកនោះអស់មួយជីវិត ចៀសវាងរឿង

[១៤៧] គុំ គហបតិកម្មមេវ ជានាសិៗ

បែបនេះកើតឡើង អញត្រូវចេញទៅដោយខ្លួនឯងវិញ”។ ដូច្នេះ មហោសថបានថ្វាយបង្គំព្រះរាជាម្ដីម្នាទៅកាន់លំនៅរបស់ខ្លួនវិញ។ ចំណែកឯព្រះរាជាវិញ ព្រះអង្គទ្រង់មានព្រះរាជឱង្ការដូច្នោះ ក៏ដោយអំណាចក្ដីក្រោធ ដូចភ្លើងចំបើងតែប៉ុណ្ណោះ តែទ្រង់មិនហាព្រះឱស្ឋបង្គាប់ឲ្យនរណាធ្វើតាមសម្ដីទ្រង់ឡើយ ពីព្រោះព្រះអង្គទ្រង់មានចិត្តធ្ងន់ចំពោះលោកសេនាប្រមុខមហោសថ។ គ្រានោះ លោកសេនាប្រមុខមហោសថទៅផ្ទះ ជញ្ជឹងគិតថា “ព្រះរាជាអង្គនេះ វង្វេងវង្វាន់លែងដឹងអ្វីជាប្រយោជន៍ ឬមិនជាប្រយោជន៍សម្រាប់ខ្លួនព្រះអង្គ ហើយទ្រង់ងប់ងុលក្នុងកាមរាគ គិតតែពីរឿងធ្វើម៉េចឲ្យបានរាជធីតារបស់ស្ដេចចូឡនីនោះ។ កាលបើព្រះអង្គយាងទៅនគរឧត្តរបញ្ចាល មុខតែនឹងដល់នូវមហាវិនាស។ ការដែលអញប្រកាន់ទឹងនឹងសម្ដីរបស់ព្រះអង្គក្នុងចិត្តមិនសមគួរសោះឡើយ ព្រោះថា ព្រះរាជាអង្គនុ៎ះ មានឧបការច្រើនចំពោះអាត្មាអញ ព្រះអង្គបានប្រទានតំណែង យសសក្តិខ្ពស់ផុតលេខដល់អញ មានតែអញជួយជ្រោមជ្រែងចំពោះព្រះអង្គវិញទើបសម។ ប៉ុន្តែជាដំបូង អញត្រូវបញ្ជូនសត្វសេកឲ្យទៅស៊ើបការណ៍ជាមុនសិន លុះដឹងការណ៍ពិតជាក់ស្ដែងហើយ អញរកវិធីការពារព្រះរាជានិងនគរ ហើយសឹមយាងស្ដេចទៅក្នុងកាលខាងក្រោយ”។ លុះគិតដូច្នេះហើយ មហោសថ ហៅសេកសុវបណ្ឌិតមាធុរៈជាទូតមកប្រាប់ថា៖

“នៃសម្លាញ់ស្វាបខៀវ មកណេះ ចូរជួយធ្វើកិច្ចការពិសេសមួយឲ្យអញ។ អ្នកដទៃជាតិជាមនុស្សពុំអាចនឹងធ្វើបានដូចឯងទេ”។

“តើខ្ញុំនឹងត្រូវធ្វើអ្វី លោកនាយ?” សេកសួរ។

“នៃសេកសម្លាញ់ លើកលែងតែស្តេចចូឡនីនិងកេវដ្តៈចេញ ពុំមានបុគ្គលដទៃណាដឹងនូវហេតុការណ៍នៃដំណើរមកកាន់នគរយើងរបស់រាជទូតឈ្មោះកេវដ្តព្រាហ្មណ៍ទេ។ អ្នកទាំងពីរបានអង្គុយប្រឹក្សាគ្នាក្នុងបន្ទប់ក្រឡាបន្ទំរបស់ព្រះបាទចូឡនីព្រហ្មទត្ត។ ប៉ុន្តែមានដំណឹងថាស្តេចក្រុងបញ្ចាលអង្គនោះ មានសារិកាញីមួយ ដែលទ្រង់ចិញ្ចឹមទុកនៅជិតក្រឡាបន្ទំព្រះអង្គ។ សារិកាញីនោះ ប្រាកដជាដឹងនូវរឿងអាថ៌កំបាំងរបស់ពួកគេ។ ចូរឯងទៅទីនោះ ធ្វើសេចក្តីស្និទ្ធស្នាលដោយការរួមមេត្រីជាមួយនឹងសារិកាញីនោះ ហើយសួររឿងអាថ៌កំបាំងរបស់ពួកគេ ត្រូវសួរសារិកាញីនោះក្នុងកន្លែងស្ងាត់ កុំឲ្យអ្នកណាម្នាក់ដឹងរឿងរ៉ាវនោះឲ្យសោះ ព្រោះបើនរណាម្នាក់ឮសំឡេងរបស់ឯង ឯងមុខតែលែងមានជីវិតត្រឡប់មកវិញហើយ ដូច្នេះចូរឯងសួរដោយប្រុងប្រយត្នបំផុត ក្នុងកន្លែងកំបាំងពីភ្នែកត្រចៀកអ្នកដទៃ។ ពិតមែនហើយ សារិកាញីនោះជាសត្វឈ្លាសវៃក្នុងកិច្ចការ

ទាំងពួង នាងជឹងការណ៍អាចកំបាំងទាំងអស់របស់ជនទាំងពីរនាក់ គឺព្រះរាជានិងកេវដ្តព្រាហ្មណ៍ជាកោសិយគោត្រ" មហោសថប្រាប់។

សេកសុវបណ្ឌិតឈ្មោះ**មាធុរៈ** ជាសត្វស្លាបខៀវនោះ លុះបានទទួលនូវការណែនាំនិងការទំនុកបម្រុង ដូចកាលមុនពីលោកសេនាប្រមុខ ហើយវាបានទទួលបេសិតកម្មពិសេសនេះ[១៤៨]។ បន្ទាប់មក សេកមាធុរៈក៏លាមហោសថ ធ្វើប្រទក្សិណ ហើយហើរចេញតាមបង្អួចដែលបើកស្រាប់ បោះពួយលឿនស្មេរដូចខ្យល់ ទៅកាន់បុរីមួយឈ្មោះថា **អរិដ្ឋបុរី** នៅក្នុងដែនសិវិរដ្ឋ ធ្វើការកំណត់សម្គាល់នូវព្រឹត្តិការណ៍ក្នុងទីនោះហើយ ក៏ហើរទៅកាន់សម្នាក់នៃនាងសារិកា។ ឧបាយដែលប្រើបន្ទាប់ពីការចូលទៅដល់ទីនោះ គឺគ្រាដំបូង មាធុរៈបាន

---

[១៤៨] បេសិតកម្ម មានន័យថា "អំពើរបស់ជនដែលត្រូវគេប្រើ ឬកិច្ចការរបស់ជនអ្នកទទួលបម្រើ"។ កន្លងមក យើងធ្លាប់ប្រើពាក្យ «បេសកកម្ម» ជាយូរដែរហើយ, តែបើគិតដល់ន័យត្រង់ៗរបស់ពាក្យ ឃើញថា ដូចជាមិនសូវសម ទើបក្នុងសៀវភៅនេះ សម្រេចសរសេរពាក្យ បេសិតកម្ម ប្រើសំដៅយកអំណាចឬសិទ្ធិដែលប្រគល់ឲ្យដល់ប្រតិភូ ដើម្បីទៅបំពេញកិច្ចការអ្វីមួយនៅទីដទៃ; មុខការងារមានកំណត់ជាក់ប្រាកដធ្វើយ៉ាងនេះ ឬយ៉ាងនោះដែលរដ្ឋាភិបាលបានប្រគល់ឲ្យដល់ភ្នាក់ងាររាជការពិសេស ដើម្បីធ្វើឲ្យបានសម្រេចមួយដងមួយគ្រា។

ទំនៅលើដំបូលមាសនៃព្រះរាជនិវេសន៍ ហើយបានបញ្ចេញសូរសៀង ដ៏ពីរោះផ្អែមដូចទឹកឃ្មុំ ជាហេតុនាំឲ្យកើតតម្រេកៗ ដើម្បីអ្វីទៅ? ដើម្បីឲ្យសារិកាញីឮសូរ ហើយស្រែកធ្វើសូរតបវិញ ហើយគេនឹងទៅជិតនាងសារិកាតាមស្នូរនោះៗ ចំណែកសារិកាញីទំនៅក្នុងទ្រុងមាស ក្បែរទីក្រឡាបន្ទំរបស់ស្តេចចូឡនី គ្រាន់តែឮសូរសំឡេងរបស់សេកមាធុរៈ នាងមានចិត្តទទឹកជោកដោយសេចក្តីត្រេកត្រអាល បានស្រែកធ្វើសូរតបវិញភ្លាម ដល់ទៅ ៣ លើកៗ សេកមាធុរៈហើរចូលទៅជិតបន្តិច ធ្វើសូរម្តងទៀត ទៅមុខបន្តិចធ្វើសូរទៀត រហូតដល់បានឈរចំពីមុខនៃសីហបញ្ជរ តាមក្រសែសូរសំឡេង ដែលនាងសារិកាធ្វើតបៗ ដោយពិនិត្យមើលស្ថានការណ៍ដឹងថា ពុំមានគ្រោះថ្នាក់ សេកមាធុរៈក៏ហើរទៅឲ្យដល់សម្នាក់នៃសារិកាញីនោះតែម្តងៗ

**សេកប្រើល្បិចមន្តស្នេហ៍ទាក់ចិត្តសារិកា**

គ្រានោះ សារិកាញីនិយាយនឹងសេកមាធុរៈថា៖

“មកណេះអ្នកអើយ សូមទំលើទ្រុងមាសខ្ញុំចុះ”ៗ

ព្ទដូច្នោះ សេកក៏ទៅទំនៅទីនោះៗ កាលបានចូលកៀកយ៉ាងនេះហើយ សេកមានបំណងធ្វើសេចក្តីស្និទ្ធស្នាលទាក់ទងនឹងរឿងស្នេហា ទើបបានហៅនាងសារិកាដោយពាក្យដ៏ពីរោះថា៖

"នៃនាងមានទ្រុងល្អ នាងសុខសប្បាយជាទេ? នៃនាងជាវេស្ស
ជាតិ នាងមិនមានជំងឺតម្កាត់អ្វីទេឬ? នៃនាងមានទ្រុងល្អ
នាងបានលាជលាយទឹកឃ្មុំដែរឬ?"

បណ្ដាសត្វស្វាបទាំងឡាយ សារិកាឈ្មោះថា ជាវេស្សជាតិ
ហេតុនោះ បានជាសេកមាធុរៈហៅនាងថា វេស្សជាតិ។

សារិកាញតបថា៖

"ម្នាលអ្នកអើយ ខ្ញុំមានសេចក្ដីសុខស្រួល ពុំមានជំងឺតម្កាត់
អ្វីទេ។ បពិត្រសុវបណ្ឌិត ទាំងលាជលាយទឹកឃ្មុំខ្ញុំក៏បានដែរ។
ឱអ្នកអើយ តើអ្នកមកអំពីណាហ្ន៎? ឬអ្នកណាប្រើអ្នកមក?
មួយវិញទៀត អ្នកជាសត្វដែលខ្ញុំមិនធ្លាប់ឃើញ មិនធ្លាប់ស្គាល់
ពីមុនមកទេ"។

សេកមាធុរៈ ឮពាក្យនាងសារិកាសួរដូច្នោះ គិតថា "ប្រសិនបើ
អញប្រាប់ថា អញមកអំពីក្រុងមិថិលា នាងសារិកានេះ ទោះបីស្លាប់
ក៏មិនព្រមធ្វើសេចក្ដីស្និទ្ធស្នាលជាមួយនឹងអញដែរ ក៏ប៉ុន្តែអញបាន
កំណត់ចំណាំអរិដ្ឋបុរីក្នុងដែនសិវិរដ្ឋរួចហើយ ទើបអញមកទីនេះ ព្រោះ
ហេតុដូច្នោះ អញនឹងនិយាយកុហកថាមកពីដែនសិវិរដ្ឋ ប្រាប់ថាស្ដេច
សិវិរាជបញ្ជូនមកទៅចុះ" រួចបានប្រាប់សារិកាថា៖

"គេចិញ្ចឹមខ្ញុំទុកនៅទីក្រឡាបន្ទំ ក្នុងប្រាសាទនៃព្រះបាទសិវិ ព្រះរាជាអង្គនោះ ទ្រង់ឋិតនៅក្នុងធម៌ ទ្រង់តែងដោះលែងសត្វទាំងឡាយដែលជាប់ចំណង ឲ្យរួចចាកចំណងអំពីទីនោះៗ ពេលព្រះអង្គ កំពុងតែដោះលែងសត្វទាំងនោះ ទ្រង់ក៏បានដោះលែងខ្ញុំដែរ ដោយសារតែព្រះអង្គទុកព្រះទ័យលើខ្ញុំ។ ពេលខ្ញុំបានចេញពីទ្រុងមាសនោះហើយ ខ្ញុំក៏ចេញទៅខាងក្រៅប្រាសាទ ស្វែងរកចំណីបរិភោគតាមប្រាថ្នា ទើបវិលត្រឡប់ចូលទៅក្នុងទ្រង់មាសនោះវិញ។ ខ្ញុំមិនបាននៅក្នុងទ្រុងជានិច្ចកាលដូចនាងទេ"។

គ្រានោះ សារិកាបានឲ្យលាជលាយទឹកឃ្មុំផង ទឹកដែលលាយទឹកឃ្មុំផង ដែលតម្កល់ទុកក្នុងចានមាសសម្រាប់ខ្លួនជូនទៅសេករួចសួរថា៖

"នែសម្លាញ់ អ្នកធ្វើដំណើរអំពីទីឆ្ងាយមកដល់ទីនេះ ព្រោះហេតុអ្វីទៅ?"

សេកឮពាក្យនាងសារិកាសួរដូច្នោះ មានបំណងស្តាប់រឿងអាថ៌កំបាំងក៏ឆ្លើយតបកុហកថា៖

"ខ្ញុំមានកិរិយាមួយជាសារិកាសម្ដីពីរោះដូចនាង។ ម្នាលនាងមាន ទ្រង់ល្អ កាលដែលខ្ញុំកំពុងតែសម្ងំងកិរិយាខ្ញុំយ៉ាងជាប់ចិត្ត ស្រាប់តែមានសត្វខ្លែងមួយក្បាល ឆាបយកកិរិយាខ្ញុំទៅ"។

គ្រានោះ សារិកាសួរសេកថា៖

"ចុះហេតុអ្វី បានជាសត្វខ្លែងឆាបឆក់យកកិរិយាសំណព្វចិត្ត របស់លោកទៅបាត់?"

សេកបានរៀបរាប់ឲ្យសារិកាស្ដាប់ថា៖

"សូមស្ដាប់ចុះ អូនសម្លាញ់ ក្នុងថ្ងៃមួយ ព្រះរាជារបស់ខ្ញុំ បាន យាងទៅក្រសាលទឹក ព្រះអង្គទ្រង់ហៅខ្ញុំទៅជាមួយទ្រង់។ កាលបើយ៉ាងនេះ ខ្ញុំនាំកិរិយាខ្ញុំទៅលេងជាមួយដែរ លុះដល់ វេលារសៀល ខ្ញុំក៏ត្រឡប់មកជាមួយនឹងព្រះរាជាវិញ ឡើងទៅ កាន់ប្រាសាទជាមួយនឹងព្រះអង្គ ខ្ញុំបាននាំកិរិយារបស់ខ្ញុំ ចេញ ទៅតាមសីហបញ្ជរ ទំនៅកំពូលអាគារ ដើម្បីនឹងសំងិលខ្លួនឲ្យ ស្ងួត។ ក្នុងខណៈនោះ សត្វខ្លែងមួយក្បាល ហើរចេញអំពីកំពូល អាគារ ស្ទុះមកសង្គ្រុបយើងទាំងពីរនាក់ ខ្ញុំភ័យខ្លាចស្លាប់ ក៏ស្ទុះ ហើរទៅយ៉ាងពេញទំហឹង។ ចំណែកកិរិយាខ្ញុំ ហេតុតែនាងមាន គភ៌ចាស់ខែពេលនោះផង ដូច្នោះហើយ នាងពុំអាចស្ទុះហើរ

ពេញកម្លាំងបាន ក៏ត្រូវសត្វខ្វែងឆាបឆក់ពាំយកទៅ នៅនឹងមុខ ខ្ញុំតែម្ដង។ គ្រានោះ ខ្ញុំយំសោក ហោកខ្លួន ស្ដាយកិរិយាខ្ញុំណាស់ ព្រះរាជាកាលបើ ឃើញខ្ញុំមានសភាពទុក្ខព្រួយ សោកសៅ ដូច្នោះ ទ្រង់ក៏ត្រាស់សួរ។ លុះព្រះអង្គទ្រង់ព្រះសណ្ដាប់រឿងដ៏ អកុសលរបស់ខ្ញុំហើយ ព្រះអង្គទ្រង់ត្រាស់ថា "នែសេកសម្លាញ់ អ្នកកុំយំសោកស្ដាយខ្លាំងពេកអី ចូរអ្នកស្វែងរកកិរិយាថ្មីមួយ ទៀតចុះ"។ ខ្ញុំទូលថា "បពិត្រព្រះសម្មតិទេព បើខ្ញុំយកកិរិយា មួយទៀត ប៉ះចំស្រីអនាចារទ្រុស្ដសីល មារយាទថោកទាប មិនមានប្រយោជន៍ទេ ក្រាបទូល។ ពីពេលនេះតទៅ ការរស់នៅ ម្នាក់ឯងប្រសើរជាង"។ ព្រះរាជាក៏ទ្រង់ត្រាស់ថា "នែសេក សម្លាញ់ ខ្ញុំបានឮដំណឹងថា មានបក្សីមួយជាបក្សីបរិបូរដោយ សីល និងមារយាទថ្លៃថ្នូរ ប្រហែលនឹងកិរិយារបស់អ្នក ជា សារិកាមានសភាពបែបនេះៗ ដែលស្ដេចចូឡនីចិញ្ចឹមទុកនៅ ក្នុងក្រឡាបន្ទំ។ អ្នកឯងចូរទៅទីនោះ សាកសួរចិត្តនាង សូម ឱកាសពីនាង បើនាងពេញចិត្តអ្នក អ្នកចូរមកប្រាប់យើង យើងនឹងរៀបការឲ្យអ្នក ហើយនឹងឲ្យបរិវារជាច្រើនទៅដង្ហែ អ្នកមក។ ព្រះរាជារបស់ខ្ញុំ ទ្រង់ត្រាស់ដូច្នេះ រួចក៏បញ្ជូនខ្ញុំមក ទីនេះដើម្បីរឿងនេះឯង"។

សេកមាធុរៈបាននិយាយបន្តទៅទៀតថា៖

"ខ្ញុំមានសេចក្តីប្រាថ្នាយ៉ាងខ្លាំងចំពោះភរិយានោះ បានជាមកក្នុងសម្នាក់នៃនាង ប្រសិនបើនាងផ្តល់ឱកាសឲ្យខ្ញុំ យើងទាំងពីរនាក់នឹងរស់នៅជាមួយគ្នាជាសុខ ដរាបដល់អស់ជីវិត"។

សារិកាស្តាប់សម្តីរៀបរាប់របស់សេក នាងមានសោមនស្សយ៉ាងខ្លាំង។ បើទុកជាយ៉ាងនេះក៏ដោយ សារិកាញីនៅតែលាក់សេចក្តីស្នេហារបស់ខ្លួនទុកក្នុងចិត្តមិនឲ្យដឹងឡើយ ហើយនិយាយធ្វើឫកពា ដូចជាមិនចង់សោះថា៖

"ជាធម្មតា សេកឈ្មោលគួរតែប្រាថ្នារកសេកញី សារិកាឈ្មោលគួរតែប្រាថ្នារកសារិកាញី ចុះការនៅរួមដោយសេកឈ្មោលនិងសារិកាញីដូចម្តេចកើត។ នៅថ្ងៃណាមួយ សេកឈ្មោលបានជួបនឹងសេកញី ដែលមានជាតិស្មើគ្នា នឹងលះបង់ចោលសារិកាទោះបីបានរួមរស់ជាមួយគ្នាយូរក៏ដោយ។ ការព្រាត់ប្រាសចាកអ្នកជាទីស្រឡាញ់នោះ នឹងនាំមកនូវសេចក្តីទុក្ខសង្រេងសង្រែយ៉ាងខ្លាំង។ ដូច្នេះ ការរួមរស់ជាមួយគ្នា ដែលមានជាតិខុសគ្នាមិនជាការត្រឹមត្រូវឡើយ"។

សេកមាធុរៈឮដូច្នោះ គិតថា "នាងនេះមិនបដិសេធអញហើយទេតើ សម្ដីរបស់នាងប្រកបដោយការប្រុងប្រយត្ន ខ្លាចក្រែងអញលែងបោះបង់នាងចោលទៅថ្ងៃក្រោយ។ នាងប្រាកដជាប្រាថ្នាអញដោយពិត អញនឹងធ្វើឲ្យនាងជឿ ដោយលើកយកឧបមាផ្សេងៗសិន"។

សេកក៏បន្តថា ៖

"បុគ្គលណាប្រាថ្នាស្ត្រីណាក្នុងកាម បុគ្គលនោះមិនគួរគិតថា ស្ត្រីនោះមានជាតិត្រកូលជាចណ្ឌាលនោះទេ ព្រោះថា ការរួមដំណេកគ្រប់ប្រភេទទាំងអស់ គឺដូចគ្នា គ្មានរឿងអ្វីដែលខុសគ្នានោះឡើយ"។

លុះពោលយ៉ាងនេះហើយ សេកមាធុរបណ្ឌិតទាញយកអតីតនិទានមកបរិយាយជាបន្តបន្ទាប់ ដើម្បីសឲ្យឃើញសមានភាពនៃបុគ្គលអ្នកមានជាតិខុសៗគ្នា ក្នុងឋានមនុស្សលោក ដូចតទៅ៖

"នៃអូនសម្លាញ់ ព្រះមាតានៃព្រះបាទសិវិរាជ ព្រះនាមថា ជម្ពាវតី មានជាតិជាចណ្ឌាលសោះ តែបានធ្វើជាអគ្គមហេសី ជាទីគាប់ព្រះរាជហឫទ័យរបស់ព្រះបាទវាសុទេពកណ្ហាយនគោត្រ ដែលជារាជបុត្រច្បង ក្នុងបណ្ដាបងប្អូនប្រុស ១០ នាក់។ មានរឿងតំណាលមកថា ក្នុងថ្ងៃមួយ ព្រះរាជាវាសុទេពយាងចេញអំពី

ក្រុងទ្វារវតី ទៅកាន់ឧទ្យានដើម្បីយាងប្រពាតកម្សាន្ត ក៏បាន
ឃើញស្រីក្រមុំជាតិចណ្ឌាលម្នាក់ មានរូបស្អាត ពណ៌សម្បុរ
ធោមលោមស្រស់ នាងមានកិច្ចចូលទៅទីក្រុង បានឃើញ
ព្រះអង្គ ហើយក៏ឈរគោរពនៅទីនោះ។ ព្រះរាជាទ្រង់មាន
ហឫទ័យប្រតិព័ទ្ធមួយរំពេច ប្រើអាមាត្យឲ្យទៅសួរថា តើនាង
មានអម្បូរអ្វី? ទោះបីទ្រង់ជ្រាបថា នាងមានអម្បូរចណ្ឌាលក្ដី
ហេតុតែទ្រង់មានព្រះទ័យប្រតិព័ទ្ធ ទ្រង់ក៏ឲ្យគេទៅសួរម្ដងទៀត
ថា តើនាងនៅលីវឬទេ? លុះទ្រង់ជ្រាបថា នាងនៅមិនទាន់មាន
ប្ដីទេ ព្រះអង្គក៏បាននាំនាងមកកាន់ព្រះបរមរាជវាំង ហើយ
អភិសេកតែងតាំងនាងក្នុងតំណែងជាអគ្គមហេសី។ ព្រះនាង
មានព្រះនាម **ជម្ពាវតី** ប្រសូតបានរាជបុត្រមួយអង្គ គឺព្រះបាទ
សិវិរាជ ដែលគ្រងរាជ្យសព្វថ្ងៃនេះឯង”។

លុះនាំឧទាហរណ៍នេះមកតំណាលដូច្នេះហើយ សេកមាធុរៈពន្យល់នាង
សារិកាថា៖

“ព្រះអង្គជាក្សត្របែបនេះ គង់សម្រេចការរួមសំវាសជាមួយ
នឹងនារីចណ្ឌាលបាន ចុះពួកយើងមានជាតិជាសត្វតិរច្ឆានដូចគ្នា

ម្ដេចរួមសំវាសជាមួយគ្នាមិនបាន។ ពិតណាស់ តម្រេកក្នុងការរួមសំវាស ដូចគ្នាតែទាំងអស់ហ្នឹង”។

បន្ទាប់មក សេកមាធុរៈ នាំមកនូវឧទាហរណ៍ផ្សេងៗទៀត មកតំណាលបន្ថែមថា៖

“សូម្បីនាងកិន្នរីឈ្មោះថា **វដ្ឋវតី** ក៏បានធ្វើឲ្យតាបសឈ្មោះវច្ឆៈប្រាថ្នាដែរ។ មនុស្សរួមសំវាសជាមួយនឹងមេម្រឹគក៏មាន។ ការនៅរួមក្នុងកាម មិនខុសគ្នាទេ។ តើវច្ឆតាបសត្រូវវដ្ឋវតីកិន្នរីញ៉ាំងឲ្យលុះក្នុងកាមដោយប្រការដូចម្ដេច? មានរឿងតំណាលថា កាលពីអតីតកាល ព្រាហ្មណ៍ម្នាក់បានយល់ឃើញថា កាមទាំងឡាយ មានទោសច្រើន ក៏បានលះបង់នូវសក្ដិយសដ៏ធំ ចេញទៅសាងផ្នួសជាឥសី គាត់បានសាងបណ្ណសាលាមួយខ្នងក្នុងព្រៃហិមពាន្ត។ មានកិន្នរជាច្រើន រស់នៅក្នុងគុហាមួយជិតបណ្ណសាលារបស់វច្ឆតាបសនោះ។ ក្នុងទីនោះ មានសត្វពីងពាងមួយ[១៤៩]តែងរស់នៅជិតទ្វារគុហា វាជាសត្វដែលចេះបញ្ចេញសរសៃពីគូទព័ទ្ធត្រដាង ប្រទាក់ក្រឡាជាសំណាញ់ ឬមង[១៥០]

---

[១៤៩] តត្ថេវ ឯកោ មក្កដកោ ទ្វារេ វសតិ។ មក្កដោ=ស្វា។ មក្កដកោ=ពីងពាង។

[១៥០] សោ ជាលំ វិនេត្វា តេសំ សីសំ ភិន្ទិត្វា លោហិតំ បិវតិ។

ដើម្បីទាក់ពួកកិន្នរ និងចោះទម្លុះក្បាលកិន្នរជាច្រើន បឺតជញ្ជក់ឈាមៗ ជាធម្មតា កិន្នរទាំងឡាយ មានកម្លាំងខ្សោយ ភ័យខ្លាចច្រើនពីកំណើតៗ ចំណែកឯពីងពាង ជាសត្វមានមាឌធំសម្បើមណាស់[១៥១]ៗ កិន្នរទាំងឡាយនោះ កាលបើមិនអាចទប់ទល់ចំពោះពីងពាងនោះបាន ក៏នាំគ្នាចូលទៅរកវច្ឆតាបសៗ ពេលនោះ តាបសធ្វើបដិសណ្ឋារៈទទួល និងសាកសួរៗ ពួកកិន្នរបានប្រាប់ថា "បពិត្រលោកម្ចាស់ ពីងពាងមួយក្បាលតែងសម្លាប់ពួកយើងខ្ញុំ យើងខ្ញុំមិនដឹងជាត្រូវទៅពឹងនរណាឲ្យជួយទេ ក្រៅពីលោកៗ សូមលោកជួយសម្លាប់ពីងពាងនោះ ដើម្បីសុវត្ថិភាពដល់យើងខ្ញុំផងចុះ"ៗ ព្រះពុទ្ធជ្រោះវច្ឆតាបសបដិសេធថា "ចូរចៀសចេញឲ្យឆាប់ មនុស្សដូចយើង មិនធ្វើបាណាតិបាតទេ"ៗ បណ្តាកិន្នរទាំងនោះ មានកិន្នរញីមួយឈ្មោះ **រដ្ឋវតី** មានរូបស្អាតគួរជាទីស្រឡាញ់ នាងមិនទាន់មានប្តីនៅឡើយៗ ពួកកិន្នរទាំងឡាយ បានតុបតែងខ្លួនឲ្យនាងកិន្នរីរដ្ឋវតីនោះហើយ នាំទៅកាន់សម្នាក់វច្ឆតាបស និយាយថា "បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលយករដ្ឋវតីនេះ ជា

---

[១៥១] សោបិ មក្កដកោ អតិវិសាលោៗ

កិរិយាចុះ សូមលោកម្ចាស់ជួយសម្លាប់ពីងពាងនោះចោល ដើម្បីសន្តិសុខដល់ពួកយើងខ្ញុំផង"។ គ្រាន់តែបានឃើញកិន្នរីវដ្ដវតីនោះភ្លាម តាបសក៏មានចិត្តប្រតិព័ទ្ធយ៉ាងខ្លាំង លុះបាននៅរួមមេត្រីជាមួយនឹងកិន្នរីវដ្ដវតីនោះហើយ ក៏បានទៅឈរលាក់ខ្លួនក្បែរទ្វារគុហា សំពងពីងពាងដែលកំពុងវារចេញមករកចំណីមួយដំបងជ្រុងងាប់បាត់ទៅ។ វច្ឆតាបសនោះ បាននៅរួមសមគ្គសំវាស[១៥២] ជាមួយនឹងកិន្នរីនោះ បានកូនប្រុសស្រីជាច្រើន។ លុះក្រោយមក តាបសក៏អស់ជីវិតនៅទីនោះឯង។ សរុបសេចក្ដីមកថា កិន្នរីវដ្ដវតីនោះ បានញ៉ាំងវច្ឆតាបសឲ្យលុះនៅក្នុងអំណាចនៃកាមគុណដែរ"។

សេកមាតុរ: នាំឧទាហរណ៍នេះមកហើយ ក៏បញ្ជាក់សេចក្ដីថា៖

"វច្ឆតាបស ជាតិជាមនុស្សសោះ សម្រេចការនៅរួមសំវាស ជាមួយនឹងកិន្នរី ដែលជាជាតិតិរច្ឆាន ចុះយើងទាំងពីរនាក់ ជាបក្សីដូចគ្នា មានកំណើតតិរច្ឆានដូចគ្នាសោះ ម្ដេចមិនអាចរួមសំវាសជាមួយគ្នាកើត? សូម្បីជាតិជាមនុស្ស ក៏អាចរួមសំវាសជាមួយ

[១៥២] ការនៅរួមព្រមចិត្តគំនិតគ្នាជាប្ដីប្រពន្ធ, ការនៅរួមសុខរួមទុក្ខរបស់ស្វាមីភរិយា។

នឹងម្រឹគញីបាន នេះជាសក្ខីភាពបញ្ជាក់ថា ការរួមសំវាស មាន
ភាពដូចៗគ្នា ភាពខុសគ្នាក្នុងការរួមសំវាសមិនមានទេ ចិត្តទេតើ
ដែលជាគ្រឿងកំណត់នូវកម្រិតនៃសេចក្តីស្នេហានោះ”។

នាងសារិកា ឮពាក្យបកស្រាយរបស់សេកមាធុរៈហើយ ក៏ពោលថា៖

“បពិត្រអ្នកជាម្ចាស់បណ្តូលចិត្ត ធម្មតាចិត្តជាធម្មជាតមិនស្ថិត
ស្ថេរ បងមិនអាចស្រឡាញ់អូនតែម្នាក់ជារៀងរហូតបានទេ អូន
ខ្លាចណាស់ចំពោះការព្រាត់ប្រាសអ្នកជាទីស្រឡាញ់ទៅថ្ងៃមុខ”។

សេកមាធុរៈ ជាសត្វឈ្លាសក្នុងមាយាស្រី ដូច្នោះគេបាននិយាយសាក
ល្បងចិត្តនាងតទៅទៀតថា៖

“នែនាងសារិកា សម្តីពីរោះអើយ បើដូច្នោះ ខ្ញុំនឹងទៅវិញ ព្រោះ
នាងបានប្រកែកមិនព្រម សម្តីរបស់នាង ជាសម្តីមើលងាយខ្ញុំ
យ៉ាងពិតប្រាកដ។ នាងមើលរំលងខ្ញុំហើយ នាងមិនជឿជាក់លើ
ខ្ញុំទេ។ ព្រះមហាក្សត្រទ្រង់យកព្រះទ័យទុកដាក់លើរូបខ្ញុំខ្លាំង
ណាស់។ ករិយា ខ្ញុំមិនលំបាករកទេ ខ្ញុំនឹងទៅស្វែងរកករិយានៅ
កន្លែងផ្សេងវិញចុះ”។

សារិកាញី គ្រាន់តែស្តាប់សម្តីរបស់សេកមាធុរៈប៉ុណ្ណោះក្តាម ស្ទើរតែ
បែកទ្រូង ទោះបីជាត្រូវពេលវាលដោយតម្រេកក្នុងកាមជំណាលគ្នា

នឹងការឃើញសេកមាធុរៈក៏ដោយ នាងធ្វើឫកពាហាក់ដូចជាមិនប្រាថ្នា ដោយមាយាស្ត្រីរបស់ខ្លួន ហើយបាននិយាយតបនឹងសេកមាធុរៈថា៖

"នែមាធុរសុវបណ្ឌិត សិរីរមែងមិនមានដល់អ្នកប្រញាប់ពេកទេ ការដែលអ្នកប្រញាប់ទៅ មិនល្អទេ ជាធម្មតា ការនៅរួមរស់ជាមួយគ្នាជាគូគ្រង គឺត្រូវគិតថា វាមានការកិច្ចធ្ងន់ណាស់ ដូច្នេះថ្លឹងថ្លែងរួចសិន សឹមធ្វើ អ្នកចូរឈប់នៅទីនេះ ដរាបបានឃើញព្រះរាជារបស់ខ្ញុំ ដែលទ្រង់ប្រកបដោយយសធំៗ អ្នកនឹងបានស្តាប់នូវសំឡេងសម្ភោរ និងស្នូរសព្ទចម្រៀង ការដេញដំប្រគំកូតផ្សេងៗទៀត ដែលពួកនារីស្អាតៗ ដំណើរល្ហោសល្ហទ់ទន់ភ្លន់ ញ៉ែងញ៉ង ដូចជាកិន្នរី នាំគ្នាលេងក្នុងវេលាល្ងាចៗ អ្នកនឹងបានឃើញអានុភាព និងសិរីសម្បត្តិដ៏លើសលប់នៃព្រះរាជារបស់ខ្ញុំៗ នែសម្លាញ់ អ្នកប្រញាប់ធ្វើអ្វី អ្នកមិនដឹងសូម្បីតែលេស[១៥៣]ឬ? សូមអ្នករង់ចាំសិន ចាំយើងដឹងគ្នាតាមក្រោយ"ៗ

---

[១៥៣] លេស=ហេតុបន្តិចបន្តួច, ការណ៍បន្តិចបន្តួច, កិច្ចកល, ឧបាយ, ពុតៗ

## សារិកាប្រាប់មូលហេតុនៃការរៀបអភិសេក

ដល់ពេលរសៀលជ្រៀលជ្រេកាលណាហើយ សារិកាញីនិងសេកមាឈ្មោល បានទៅរួមបវេណីជាមួយគ្នា ព្រមព្រៀងគ្នានៅរួមសំវាសដោយសេចក្ដីរីករាយសប្បាយ[១៥៤]។ គ្រានោះ សេកមាឈ្មោលគិតថា "តែប៉ុណ្ណេះ នាងសារិកាឈប់លាក់រឿងអាថ៌កំបាំងចំពោះអញហើយ អញត្រូវតែសួរនាងឥឡូវនេះ ហើយនឹងចេញដំណើរ" គិតដូច្នេះរួចក៏និយាយទៅកាន់សារិកាថា៖

"នែអូនសារិកា"។

"ចា៎ះបង ហៅខ្ញុំមានការអ្វី?" សារិកាឆ្លើយ។

"បងមានរឿងចង់និយាយជាមួយនឹងអូនបន្តិច" សេកតប។

"និយាយមកចុះ បងសម្លាញ់" សារិកាឆ្លើយ។

"មិនអីទេអូន ថ្ងៃនេះជាថ្ងៃមង្គលរបស់យើង ចាំយើងដឹងនៅថ្ងៃក្រោយវិញ" សេកនិយាយ។

---

[១៥៤] សមគ្គា សម្មោទមានា បិយសំវាសំ វសីសុ។

"ប្រសិនបើរឿងនោះជារឿងមង្គល សូមបងនិយាយមកចុះ តែបើមិនជារឿងមង្គលទេ សូមកុំនិយាយចេញមកអីបង" សារិកាតប។

"រឿងនោះ ជារឿងមង្គល ណាអូនសម្លាញ់" សេកនិយាយ។

"បើអ៊ីចឹង និយាយមកចុះ" សារិកាតប។

"បើដូច្នេះ ចូរអូនចាំស្ដាប់" សេកនិយាយ។

សេកមាធុរៈ ក៏និយាយដើម្បីធ្វើរឿងអាថ៌កំបាំងឲ្យលេចឡើងថា៖

"ដំណឹងពិសេសនេះ បានឮល្បីទៅដល់ជនបទខាងក្រៅ និងរដ្ឋផ្សេងៗថា ព្រះរាជធីតានៃព្រះបាទបញ្ចាល ដែលមានសម្បុរដូចជាផ្កាយព្រឹក ព្រះអង្គនឹងប្រទានព្រះរាជធីតានោះ ដល់ព្រះបាទវិទេហៈ ដើម្បីរៀបអភិសេក តើពិតឬទេអូនសម្លាញ់មាសបង? បងបានឮភាពល្បីរន្ទឺប្រាកដទៅយ៉ាងនេះ ក៏នឹកឆ្ងល់ថា រាជធីតានេះ មានរូបស្អាតពន់ពេក ព្រះបាទវិទេហរាជធ្លាប់ជាសត្រូវរបស់ព្រះបាទចូឡនី ស្ដេចទាំងឡាយផ្សេងៗ ក្នុងសកលជម្ពូទ្វីបស្ថិតនៅក្នុងអំណាចរបស់ព្រះបាទចូឡនីអស់ហើយ ម្ដេចក៏ព្រះអង្គមិនថ្វាយដល់ស្ដេចអង្គណាមួយក្នុងចំណោមស្ដេចទាំងនោះ ព្រះអង្គបែរជាថ្វាយដល់ស្ដេចវិទេហៈ ដែលជាសត្រូវទៅវិញ?"

សារិកាស្តាប់នូវពាក្យសេកមាធុរៈហើយតបថា៖

"បពិត្រស្វាមី ហេតុអ្វីបានជាបងនិយាយពាក្យអពមង្គល ក្នុងថ្ងៃមង្គលរបស់យើងអ៊ីចឹង?"

"នែអូនសម្លាញ់ បងគិតថាវាជាមង្គល ហេតុអ្វីបានជាអូនថាអពមង្គលទៅវិញ?" សេកសួរ។

"សូមកុំឲ្យមានពិធីមង្គលបែបនេះ ដល់ជនទាំងឡាយនោះ ដែលជាសត្រូវនឹងគ្នា" សារិកាតប។

"បងមិនយល់សម្តីអូនទេ ចូរអូនបញ្ជាក់ឲ្យបានច្បាស់ជាងនេះ" សេកទទូចសួរ។

"ខ្ញុំនិយាយមិនបានទេបង" សារិកាប្រកែក។

"នែអូនសម្លាញ់ អូនមិនប្រាប់រឿងអាថ៌កំបាំងឲ្យបងបានដឹងផងទេហ៊ឺះ តាំងពីពេលនេះទៅ ការនៅរួមរស់ជាមួយគ្នារបស់យើងទាំងពីរក៏ពុំអាចមានតទៅទៀតដែរ ព្រោះអូនមិនមានការទុកចិត្តបង" សេកនិយាយ។

សារិកា កាលបើត្រូវសេកមាធុរៈនិយាយបំភ័យយ៉ាងនោះ នាងទ្រាំមិនបានក៏និយាយថា "បពិត្របងសម្លាញ់ សូមកុំឲ្យមានការរៀបចំ

វិវាហមង្គលរបស់ពួកសត្រូវ ដូចជាព្រះនាងបញ្ចាលចន្ទីជាមួយនឹង ស្ដេចវិទេហៈដែលនឹងប្រព្រឹត្តទៅនេះឡើយ”។

“នែអូនសម្លាញ់មាសបង ព្រោះហេតុអ្វីទៅ ទើបអូននិយាយសម្ដីបែបនេះ?” សេកសួរ។

នាងសារិកាក៏បន្តប្រាប់ថា៖

“ព្រះរាជាដ៏ធំលើដែនកាសីនិងជម្ពូទ្វីប បញ្ឆោតស្ដេចវិទេហៈមកដល់ពេលណា នឹងសម្លាប់ចោលនៅពេលនោះ។ ព្រះបាទចូឡនី មិនមែនជាសម្លាញ់របស់ស្ដេចវិទេហៈនោះទេ គឺព្រះអង្គទ្រង់មិនធ្វើមិត្តធម៌ ឬភាពជាសម្លាញ់ជាមួយនឹងស្ដេចវិទេហៈនោះឡើយ។ សូម្បីសេនាប្រមុខមហោសថ ក៏ត្រូវស្ដេចចូឡនីគ្រោងនឹងសម្លាប់ចោលដែរ។ កេវដ្តព្រាហ្មណ៍ បានប្រឹក្សាជាមួយនឹងព្រះរាជាដូច្នេះថា លុះសម្លាប់ជនទាំងពីរនោះបានហើយ ពួកគេនឹងជប់លៀងទឹកជយបាន។ អ៊ីចឹងហើយ បានជាកេវដ្តព្រាហ្មណ៍ធ្វើដំណើរទៅក្រុងមិថិលានោះ គឺដើម្បីបញ្ឆោតស្ដេចវិទេហៈនោះ នាំមកសម្លាប់តែប៉ុណ្ណោះ”។

នាងសារិកា បានប្រាប់ការណ៍អាថ៌កំបាំងទាំងអស់ ដល់សេក មាធុរៈយ៉ាងនេះៗ រីឯសេកមាធុរៈ លុះស្ដាប់ការណ៍អាថ៌កំបាំងនោះ បានហើយ ធ្វើជាបញ្ចើចបញ្ចើសរសើរកេវដ្ដព្រាហ្មណ៍ថា៖

"អាចារ្យកេវដ្ដៈ ជាអ្នកឈ្លាសក្នុងឧបាយណាស់ហ្ន៎ អស្ចារ្យ គម្រោងការសម្លាប់ដោយល្បិចបែបនេះ គួរឲ្យកោតសរសើរ"

សេកពោលបន្ថែមទៀតថា៖

"និយាយរឿងអពមង្គលបែបនេះ មិនមានប្រយោជន៍អ្វីសម្រាប់ យើងទេណាអូន ពួកយើងគួរដេកស្ងាត់ស្ងៀមវិញល្អជាង"ៗ

**សេកមាធុរៈរាយការណ៍ដល់មហោសថ**

លុះបានសម្រេចកិច្ចការរបស់ខ្លួនហើយ សេកមាធុរៈមិនមាន បំណងចង់ដឹងអ្វីទៀតទេ ហើយបន្តនៅរួមដំណេកជាមួយនឹងនាង សារិកាញីក្នុងរាត្រីនោះៗ លុះព្រលឹមស្រាងៗ សេកមាធុរៈប្រាប់នាង សារិកាថា៖

"នែពៅព្រលឹង បងនឹងទៅដែនសិវិរដ្ឋ ដើម្បីក្រាបទូលឲ្យព្រះ បាទសិវិនិងព្រះទេវីទ្រង់បានជ្រាប អំពីបងដែលរកប្រពន្ធជាទី ពេញចិត្តដូចជារូបអូននេះបានហើយ"ៗ

ដើម្បីឲ្យសារិកាអនុញ្ញាតឲ្យខ្លួនទៅដោយស្រួល សេកពោលបន្តថា៖

"សូមអូនអនុញ្ញាតឲ្យបងទៅត្រឹម ៧ រាត្រី ទម្រាំបងទូលព្រះបាទសិរិនិងព្រះមហេសីថា បងបាននៅរួមជាមួយនឹងអូនហើយ។ ធ្វើយ៉ាងនេះ ដើម្បីឲ្យព្រះអង្គ រៀបចំបណ្ណាការមកកាន់សម្នាក់របស់អូននៅទីនេះ ក្នុងថ្ងៃទី៨ បងនឹងយកអូនទៅដោយមានបរិវារជាច្រើនហែហម ដូច្នេះសូមអូនកុំអផ្សុក កុំលំបាកចិត្តអី"។

ឮដូច្នោះ សារិកាទោះបីមិនប្រាថ្នាការនៅបែកគ្នាពីសេកមាធុរៈក៏ដោយ ក៏មិនហ៊ានពោលជំទាស់នឹងពាក្យស្នើរបស់សេកមាធុរៈនោះដែរ គ្រាន់តែផ្ដែផ្ដាំកុំឲ្យភ្លេចពាក្យសន្យាថា៖

"ចាសបង ខ្ញុំអនុញ្ញាតឲ្យបងទៅត្រឹម ៧ រាត្រី បើបងមិនត្រឡប់មករកអូនវិញក្នុងថ្ងៃទី ៨ ទេ អូននឹងក្សិណក្សយជីវិតមិនខាន ពេលនោះបងនឹងឃើញត្រឹមតែសាកសពអូនប៉ុណ្ណោះ។ ព្រោះហេតុនោះ សូមបងកុំនៅយូរពេក ធ្វើឲ្យអូនកើតទុក្ខចំបែងចិត្តនឹកបងខ្លាំងឡើយ"។

"នៃអូនសម្លាញ់ ម្ដេចបាននិយាយអ៊ីចឹង ចំណែករូបបងវិញ បើមិនបានឃើញប្រិយមិត្តក្នុងថ្ងៃទី ៨ ទេ បងក៏មិនអាចរស់នៅបានដែរ[១៥៥]" សេកមាធុរៈតប។

សេកមាធុរៈនិយាយដូច្នេះក៏ពិត តែក្នុងចិត្តគិតថា៖

"ទោះបាងរស់ឬស្លាប់ក៏ដោយ តើបាងមានប្រយោជន៍អ្វីដល់រូបអញទៅ[១៥៦]?"

សេកមាធុរៈស្ទុះហើរតម្រង់ទៅដែនសិវិរដ្ឋ បានតែ មួយស្របក់ល្មមផុតពីកន្ទុយភ្នែកសារិកា ក៏បែរក្បាលហើរតម្រង់ត្រោះ ទៅក្រុងមិថិលា ដល់ហើយ ចុះទំលើចង្កូយស្មារបស់លោកសេនាប្រមុខមហោសថ។ ដោយសញ្ញានោះ លោកសេនាប្រមុខក៏ឡើងទៅប្រាសាទជាន់លើ សាកសួរសេកមាធុរៈជាសម្ងាត់។ ចំណែកសេកមាធុរៈ បានរាយការណ៍ជូនលោកសេនាប្រមុខមហោសថ ឲ្យជ្រាបពត៌មានទាំងអស់ ដែលខ្លួនបានដឹងឮ និងបញ្ជាក់ថា "ពាក្យនេះជាពាក្យរបស់នាងសារិកាប្រាប់ខ្ញុំ"។ មហោសថក៏បានទំនុកបម្រុងសេកមាធុរៈគ្រប់បែបយ៉ាងដូចគ្រាមុនៗ។

សុវិកណ្ឌ ចប់។

---

[១៥៥] កទ្ទេ កឹ វទេសិ, មយ្ហម្បិ អដ្ឋមេ ទិវសេ តំ អបស្សន្តស្ស កុតោ ជីវិតំ ។

[១៥៦] ជីវ វា ត្វំ មរ វា, កឹ តយា មយ្ហំ ។

# ជំពូកទី ១០

## សត្រូវក្លាយជាមិត្រ

## មហាឧម្មង្គកណ្ឌ

### មហោសថជួយរៀបចំផែនការអភិសេក

*បន្ទាប់ពីបានទទួលរបាយការណ៍ពីសេកមាធុរៈរួចហើយ លោកសេនាប្រមុខមហោសថគិតថា "ទោះបីអញមិនព្រមទៅនគរឧត្តរបញ្ចាលក៏ព្រះរាជាប្រាកដជាយាងទៅមួយព្រះអង្គឯងពុំខានៗ លុះស្ដេចយាងទៅហើយ ព្រះអង្គប្រាកដជាដល់នូវសេចក្ដីវិនាសយ៉ាងធំៗ កាលបើស្ដេចវិនាស ខ្លួនអញមុខតែត្រូវអ្នកនគរតិះដៀលថា 'មហោសថបានគុំទុកក្នុងចិត្តនូវពាក្យជេរប្រមាថរបស់ស្ដេចដែលទ្រង់ប្រទានយសសក្ដិដ៏ធំបែបនេះឲ្យដល់គេ ហើយគេព្រងើយកន្តើយ មិនព្រមជួយធ្វើការជ្រោមជ្រែងសង្គ្រោះដល់ព្រះមហាក្សត្រ បណ្ដោយឲ្យទ្រង់ស្លាប់ក្រោមកណ្ដាប់ដៃស្ដេចចូឡនី'ៗ ដូច្នេះ កាលបើបណ្ឌិតដូចអាត្មាអញមានជីវិតរស់នៅឡើយ អញនឹងមិនត្រូវបណ្ដោយឲ្យព្រះមហាក្សត្ររបស់អញវិនាសដោយឧបាយកលរបស់ស្ដេចចូឡនីទេៗ អាត្មាអញត្រូវតែធ្វើដំណើរទៅឲ្យបានមុនស្ដេចរបស់អញយាងទៅដល់ អញនឹង*

ចូលគាល់ព្រះបាទចូឡនី សូមរាជានុញ្ញាតរៀបចំទីក្រុង ធ្វើព្រះរាជដំណាក់សម្រាប់ព្រះបាទវិទេហរាជប្រថាប់គង់នៅ។ រីឯអញក៏នឹងធ្វៀតឱកាសធ្វើឧម្មង្គ(រូងក្នុងដី) ថ្មើរជើងប្រវែងមួយគាវុត និងធ្វើឧម្មង្គក្រោមដីមួយទៀតឲ្យធំជាងនោះ មានប្រវែងកន្លះយោជន៍ ធ្វើជាស្ថានទីរៀបអភិសេកព្រះរាជធីតា របស់ព្រះបាទចូឡនី ឲ្យជាអគ្គមហេសីរបស់ស្តេចអញ។ ជាការពិតណាស់ ស្តេច ១០១ អង្គ ព្រមទាំងទាហានចំនួន ១៨ អក្ខោភិនី នឹងមកឡោមព័ទ្ធទីតាំងនុ៎ះ ដើម្បីនឹងចាប់ស្តេចរបស់អញនិងខ្លួនអញទៅសម្លាប់ចោល។ ដូច្នេះ ភារកិច្ចរបស់អញ គឺត្រូវត្រៀមផ្លូវសម្ងាត់ដើម្បីរំដោះព្រះមហាក្សត្រឲ្យគេចផុតពីគម្រោងការសម្លាប់របស់បច្ចាមិត្រ រួចយាងព្រះអង្គ មកនគរមិថិលាវិញដោយសុវត្ថិភាព បីដូចដួងចន្ទរួចពីមាត់រាហូ”។

កាលដែលសេនាប្រមុខមហោសថកំពុងតែជញ្ជឹងនឹកគិត ដោយកតញ្ញុតាធម៌ដ៏ជ្រាលជ្រៅយ៉ាងនេះ ស្រាប់តែបីតិសេចក្តីផ្អែតចិត្ត កើតឡើងធ្វើឲ្យលោកព្រឺសម្បុរ។ ដោយសន្ទុះបីតិនោះ លោកសេនាប្រមុខមហោសថ បានបន្លឺវាចាតែម្នាក់ឯងថា៖

“បុរសដែលបានយសសក្តិដ៏ធំអំពីព្រះមហាក្សត្រអង្គណាហើយ ប្រើប្រាស់ភោគសម្បត្តិតាមរយៈយសសក្តិដ៏ធំនោះ បើទោះបី

ព្រះមហាក្សត្រអង្គនោះជេរប្រមាថក៏ដោយ វាយប្រហារក៏ដោយ ចាប់កទាញអូសចេញក៏ដោយ បុគ្គលជាបណ្ឌិត មានឧត្តមគតិគប្បីធ្វើសេចក្ដីសុខ សេចក្ដីចម្រើន និងប្រយោជន៍ថ្វាយព្រះមហាក្សត្រអង្គនោះវិញ ដោយកាយទ្វារ វចីទ្វារ និងមនោទ្វារ។ អំពើទ្រុស្ដមិត្រ គឺបណ្ឌិតទាំងឡាយមិនគប្បី ប្រព្រឹត្តឡើយ"។

លុះគិតដោយប្រការដូច្នេះហើយ មហោសថងូតទឹក តុបតែងខ្លួនប្រកបដោយយស រួចធ្វើដំណើរចេញទៅព្រះបរមរាជវាំង ព្រមទាំងមានបរិវារជាច្រើន ក្រាបថ្វាយទូលព្រះរាជាថា៖

"បពិត្រព្រះសម្មតិទេព ព្រះអង្គនឹងយាងទៅកាន់ឧត្តរបញ្ចាលនគរ ពិតមែនឬ?"

ស្ដេចត្រាស់ថា៖

"ពិតប្រាកដហើយបុត្រ កាលបើយើងមិនបានរាជធីតាបញ្ចាលចន្ទីទេ រាជសម្បត្តិគ្មានប្រយោជន៍អ្វីសម្រាប់យើងទេ។ សូមអ្នកកុំលះបង់យើង សូមអញ្ជើញទៅជាមួយនឹងយើងកុំខាន។ ដ្បិតថា គម្រោងការណ៍ទៅទីនុ៎ះរបស់យើងជាក់ជាបានសម្រេចប្រយោជន៍ពីរ គឺ ទី១ យើងផ្ទាល់នឹងបានស្ត្រីកែវ ទី២ មេត្រី

កាលណាស្ដេចចូឡនីនិងយើង នឹងមានសម្ពន្ធភាពជាមួយគ្នា កាន់តែជិតស្និទ្ធនិងយូរអង្វែង"។

មហោសថក្រាបទូលស្ដេចថា៖

"បពិត្រព្រះជនិន្ទ បើអ៊ីចឹង ទូលបង្គំជាខ្ញុំ សូមទៅកាន់នគររបស់ព្រះបាទចូឡនីជាមុន ដើម្បីសាងរាជនិវេសន៍បម្រុងព្រះអង្គដ៏មានយសធំក្នុងដែនវិទេហៈ។ បពិត្រក្សត្រិយ៍ កាលខ្ញុំព្រះអង្គសាងរាជនិវេសន៍នៅទីនោះរួចហើយ ទូលបង្គំជាខ្ញុំ នឹងបញ្ជូនទូតមកក្រាបទូលយាងព្រះអង្គទៅក្នុងវេលានោះ"។

**មហោសថយកអ្នកទោស ៤ គុកធ្វើធាហារ**

ទ្រង់ព្រះសណ្ដាប់ដូច្នោះ ព្រះបាទវិទេហៈមានហឫទ័យត្រេកអររីករាយដោយព្វថា មហោសថមិនលះបង់ព្រះអង្គចោលទេ ទ្រង់ត្រាស់ថា៖

"ម្នាលបាសម្លាញ់ កាលបើអ្នកទៅមុន អ្នកត្រូវយកអ្វីទៅខ្លះ?"

"ទូលព្រះបង្គំត្រូវការទាហាននិងពាហនៈ ក្រាបទូល" មហោសថតបព្រះរាជា។

"អ្នកត្រូវការទ័ពទៅប៉ុណ្ណា យកប៉ុណ្ណោះទៅចុះបា" ព្រះរាជាទ្រង់អនុញ្ញាត។

មហោសថទូលតបថា៖

"បពិត្រព្រះសម្មតិទេព សូមព្រះអង្គឲ្យគេបើកពន្ធនាគារទាំង ៤ ដោះឡែងលែងអ្នកទោសទាំងនោះ ដើម្បីឲ្យពួកគេទៅជាមួយនឹងទូលព្រះបង្គំជាខ្ញុំ ក្រាបទូល"។

ស្តេចទ្រង់ត្រាស់តបថា៖

"ចូរអ្នកធ្វើតាមសេចក្តីពេញចិត្តរបស់អ្នកចុះបា"។

សេនាប្រមុខមហោសថ បានបញ្ជាឲ្យឆ្មាំគុកបើកទ្វារពន្ធនាគារ ដោះលែងអ្នកទោស ៤ គុក ហើយជ្រើសរើសរកពួកទណ្ឌិតណា ដែលក្លាហានអង់អាច មកបំពាក់អាវុធនិងផ្តល់យសសក្តិឲ្យ ដើម្បីលើកទឹកចិត្តពួកគេ ឲ្យជួយសម្រេចផែនការសម្ងាត់របស់ខ្លួន។ មហោសថ បានផ្តល់អនុសាសន៍ឲ្យពួកគេយកចិត្តទុកដាក់ធ្វើតាមផែនការណ៍របស់ខ្លួន។ បន្ទាប់មក លោកបានផ្តល់នូវសក្ការៈចំពោះកងប្រដាប់អាវុធថ្មីៗទាំងអស់នោះ។ មិនតែប៉ុណ្ណោះ មហោសថ បានជ្រើសយកមេទាហានជាង ១៨ នាក់ ដែលជំនាញខាងសិល្បៈផ្សេងៗបន្ថែមទៀត មានជាងឈើ ជាងសំណង់ ជាងស្បែក ជាងឥដ្ឋ ជាងថ្មនិងជាងគំនូរជាដើម និងបញ្ជាឲ្យពួកគេជីកឧបករណ៍ទាំងឡាយជាច្រើន

មានកាំបិត ប៉ូវថៅ[១៥៧] ចបកាប់ ចបជីក ពន្លាកជាដើម ចេញដំណើរអំពីនគរមិថិលា ដោយមានពួកទ័ពជាច្រើនដើរហែហមជាបរិវារឆ្ពោះទៅកាន់បញ្ចាលនគរដ៏ជាទីរីករាយរបស់ព្រះបាទចូឡនី ដើម្បីសាងនិវេសន៍សម្រាប់ព្រះបាទវិទេហៈ។

មុននឹងប្រកាសសេចក្តីនោះឲ្យបានជាក់ច្បាស់ ព្រះបរមគ្រូសាស្តាចារ្យនៃយើង ទ្រង់ត្រាស់ថា៖

"លំដាប់នោះឯង មហោសថក៏បានទៅកាន់នគរបញ្ចាលរបស់ព្រះបាទចូឡនីជាមុន ដើម្បីសាងនិវេសន៍សម្រាប់ព្រះបាទវិទេហៈ ដ៏មានយសធំ ជាស្តេចរបស់ខ្លួន"។

## មហោសថត្រៀមការពារសុវត្ថិភាពព្រះរាជាតាមផ្លូវ

កាលធ្វើដំណើរទៅតាមផ្លូវ សេនាប្រមុខមហោសថបានបង្កើតស្រុកជាច្រើនដែលមានចម្ងាយពីគ្នាមួយយោជន៍ៗ និងដាក់មន្ត្រីឲ្យគ្រប់គ្រងក្នុងមួយស្រុកម្នាក់ៗ ទាំងផ្តល់អនុសាសន៍ថា៖

---

[១៥៧] ប៉ូវថៅ ក្លាយពីពាក្យចិន ថា ប៉ូវថាវ គឺបានដល់ប្រដាប់ធ្វើដោយដែក មានលៅបញ្ចុះដងឈើ សម្រាប់ប្រើការ កាប់ ពុះ ច្រាស ជាដើម។

“ក្នុងពេលព្រះរាជារបស់យើង យកព្រះរាជធីតាបញ្ចាលចន្ទីបាន ហើយ ពួកលោកគប្បីរៀបចំត្រៀមដំរី សេះ និងរថ ជាទីនាំង សម្រាប់យាងព្រះអង្គរត់ ទៅក្រុងមិថិលាឲ្យលឿន និងត្រូវការពារសុវត្ថិភាពព្រះអង្គតាមផ្លូវនោះ ឲ្យបានហ្មត់ចត់ជាទីបំផុត”។

លុះធ្វើដំណើរទៅដល់ឆ្នេរទន្លេគង្គា លោកសេនាប្រមុខឲ្យគេហៅជនម្នាក់ឈ្មោះអានន្ទ ឲ្យចូលមកជួប រួចលោកដាក់ផែនការណ៍ឲ្យធ្វើថា៖

“នែអានន្ទ ចូរលោកយកជាងឈើ ៣០០ នាក់ ឡើងទៅខាងលើក្បែរទន្លេគង្គា បង្គាប់ឲ្យពួកគេកាប់យកឈើខ្លឹមៗ ធ្វើជានាវាចំនួន ៣០០ ហើយឈូសចាំងឈើនៅទីនោះ ដើម្បីស្ថាបនាទីក្រុងមួយ និងដឹកឈើស្រាលៗឲ្យពេញនាវាមកវិញឲ្យឆាប់ផង”។

## មហោសថត្រួតពិនិត្យដែនដីស្ដេចចូឡនី

ចំណែកលោកសេនាប្រមុខផ្ទាល់ បានជិះនាវាឆ្លងទន្លេគង្គា ជិះបណ្ដើរ វាស់ប្រវែងទន្លេគង្គាបណ្ដើរ ដោយប៉ាន់ប្រមាណទៅនឹងជំហានជើង តាំងពីកំពង់ចម្លងរហូតទៅ។ លោកកំណត់នូវទីតាំងដែលត្រូវសាងសង់ដូច្នេះ “កន្លែងកន្លះយោជន៍នេះនឹងត្រូវកសាងមហាឧម្មង្គ ត្រង់នេះ នឹងត្រូវកសាងទីក្រុងជានិវេសន៍របស់ព្រះមហាក្សត្រ ពីកន្លែងនេះរហូតទៅដល់ព្រះបរមរាជវាំងរបស់ព្រះបាទចូឡនី នឹងត្រូវកសាងឧម្មង្គ

ដើរជើងក្នុងទីប្រវែង១គាវុត[១៥៨]”។ លុះកំណត់យ៉ាងនេះហើយ សេនាប្រមុខ បានចូលទៅកាន់នគររបស់ព្រះបាទចូឡនីព្រហ្មទត្ត។ ព្រះបាទចូឡនី ឮដំណឹងថាមហោសថធ្វើដំណើរមកដល់នគរទ្រង់ ព្រះអង្គមានសេចក្ដីត្រេកអរយ៉ាងខ្លាំងថា “គោលបំណងអញ ឥឡូវនេះ នឹងបានសម្រេច អញនឹងបានឃើញភាពបរាជ័យរបស់ពួកសត្រូវ។ កាលបើមហោសថមកហើយ មិនយូរប៉ុន្មានទេ ស្ដេចវិទេហៈនឹងយាងមកដែរ។ កាលបើដូច្នេះ អញនឹងសម្លាប់ពួកគេទាំងពីរនាក់ រួចសោយរាជ្យតែម្នាក់ឯង លើផ្ទៃដីជម្ពូទ្វីបទាំងមូល”។ ពួកអ្នកនគរទូទៅ មានការភ្ញាក់ផ្អើលថា “ឮថាគេនុ៎ះជាមហោសថបណ្ឌិត ដែលបានដេញស្ដេច ១០១ អង្គ ឲ្យរត់យ៉ាងឆាយ ដូចបង្អើលសត្វក្អែកដោយគប់នឹងដុំដី”។

## ស្ដេចចូឡនីទទួលមហោសថ

កាលដែលពួកអ្នកនគរកំពុងតែប្រជ្រៀតគ្នាមើលនូវរូបសម្បត្តិរបស់មហោសថយ៉ាងឈូឆរ មហោសថក៏ចេះតែធ្វើដំណើរទៅកាន់ព្រះបរមរាជវាំង រួចឲ្យគេទៅក្រាបទូលព្រះបាទចូឡនីឲ្យទ្រង់ជ្រាបមុនអំពីដំណើរមកដល់របស់ខ្លួន កាលបើស្ដេចអនុញ្ញាតឲ្យចូល លោកក៏បាន

---

[១៥៨] គាវុត  បា.; សំ. (ន.) (គ្វយូតិ) មាត្រាវាស់ ឬ រង្វាស់ ចំនួនពីរពាន់ព្យាម គឺមួយរយសិន (ប្រើតែពីក្នុងសម័យបុរាណ)។

ចូលទៅថ្វាយបង្គំព្រះរាជា រួចអង្គុយក្នុងទីដ៏សមគួរ។ គ្រានោះ ស្តេចចូឡនីធ្វើបដិសណ្ឋារៈចំពោះលោកសេនាប្រមុខមហោសថ ដោយទ្រង់សាកសួរថា៖

"នែមហោសថ តើព្រះរាជារបស់អ្នកនឹងស្តេចយាងមកក្នុងពេលណា?"

"ព្រះរាជារបស់ទូលបង្គំនឹងយាងមក ក្នុងពេលណាដែលទូលបង្គំជាខ្ញុំបញ្ជូនដំណឹងទៅថ្វាយ ក្រាបទូល" មហោសថក្រាបទូល។

"ចុះអ្នកវិញមកដើម្បីអ្វី?" ស្តេចចូឡនីត្រាស់សួរ។

មហោសថឆ្លើយថា៖

"ទូលបង្គំមកនេះ ដើម្បីសាងនិវេសន៍សម្រាប់ស្តេចទូលបង្គំ ក្រាបទូល"។

"ប្រពៃណាស់ មហោសថ" ស្តេចចូឡនីត្រាស់។

គ្រានោះ ព្រះរាជាបានឲ្យគេប្រទានស្បៀងដល់ពួកកងទ័ពរបស់មហោសថ និងឲ្យគេធ្វើសក្ការៈជាច្រើន ចំពោះសេនាប្រមុខមហោសថផ្ទាល់ផង រួចទ្រង់ព្រះរាជទានទូវលំនៅឋានមួយខ្នងសម្រាប់មហោសថ និងប្រាប់មហោសថថា៖

"នែមហោសថ ដរាបណាព្រះរាជារបស់អ្នកមិនទាន់យាងមក ដល់ទេ អ្នកចូរនៅទីនេះ ធ្វើអ្វីដែលគួរធ្វើចំពោះយើងសិន ដើម្បី កុំឲ្យកើតក្តីអផ្សុក"។

**មហោសថធ្វើទ្វារឧមង្គ**

តាមដំណើររឿងថា កាលដែលមហោសថដើរឡើងជណ្តើរព្រះរាជនិវេសន៍របស់ស្តេចចូឡនី លោកបានឈរនៅក្បែរជើងជណ្តើរធំ គិតកំណត់ក្នុងចិត្តថា "កន្លែងនេះ នឹងត្រូវកសាងទ្វារឧមង្គរបើរជើង"។ គ្រានោះ មហោសថមានសេចក្តីត្រិះរិះថា "ព្រះរាជាប្រាប់អញឲ្យធ្វើកិច្ចដែលគួរធ្វើចំពោះព្រះអង្គ កាលបើអញជីកឧមង្គ គួរណាស់តែអញធ្វើយ៉ាងណាកុំឲ្យជណ្តើរនេះស្រុតចុះ"។ គិតដូច្នេះរួច ទើបលោកក្រាបទូលព្រះរាជាយ៉ាងនេះថា៖

"បពិត្រព្រះសម្មតិទេព កាលទូលបង្គំដើរចូលមកទីនេះ បាន ឈរក្បែរជើងជណ្តើរ សម្លឹងមើលនូវសំណង់ ឃើញការមិន ទំនងនៅត្រង់ជណ្តើរ បើព្រះអង្គឥតយល់ទាស់ទេ ទូលបង្គំនឹង យកឈើ មកក្រាលជាក្តារឲ្យសព្វព្រះរាជហឫទ័យ ក្រាបទូល"។

ស្តេចចូឡនីថា៖

"ប្រពៃណាស់បណ្ឌិត អញ្ជើញលោកក្រាលក្តារចុះ"។

មហោសថ កំណត់ទីតាំងដែលនឹងត្រូវធ្វើទ្វារឧម្មង្គហើយ បាន លើកជណ្ដើរនោះចេញ រួចឲ្យគេក្រាលបន្ទះក្ដារ ប្រយោជន៍ដើម្បីកុំឲ្យ អាចម៍ដីធ្លាក់ចូលទៅក្នុងកន្លែងដែលនឹងត្រូវធ្វើទ្វារឧម្មង្គ។ បន្ទាប់មក លើកជណ្ដើរយកមកដាក់ដូចដើមវិញ ប្រិតប្រៀងមិនឲ្យករញ្ជើកឲ្យនៅ នឹងថ្កល់ មិនឲ្យជណ្ដើរស្រុតចុះបាន។ ព្រះរាជាកាលមិនយល់ស្ថាន-ការណ៍នោះ សម្គាល់ថា មហោសថធ្វើអ្វីចឹង ព្រះហេតុតែស្រឡាញ់ ព្រះអង្គ។

**មហោសថជ្រើសរើសទីតាំងសាងសង់រាជដំណាក់**

បន្ទាប់ពីបានចំណាយពេលមួយថ្ងៃ ក្នុងការងារសំណង់ជណ្ដើរ នោះហើយ មកដល់ថ្ងៃបន្ទាប់ មហោសថបានក្រាបទូលព្រះរាជាថា៖

> “បពិត្រព្រះសម្មតិទេព ប្រសិនបើពួកទូលបង្គំសូមជ្រើសព្រះ រាជនិវេសន៍ សម្រាប់ស្ដេចរបស់ពួកទូលបង្គំដោយខ្លួនឯង ពួកទូលបង្គំនឹងអាចជួសជុលធ្វើឲ្យជាទីសព្វព្រះរាជហឫទ័យ របស់ព្រះបាទវិទេហៈ ក្រាបទូល”។

ស្ដេចចូឡនីមានព្រះរាជឱង្ការថា៖

"ល្អណាស់លោកបណ្ឌិត លើកលែងតែនិវេសន៍របស់យើង ចេញ លោកត្រូវការនិវេសន៍ណា ក្នុងនគរទាំងមូលនេះ ចូរយក មួយនោះចុះ"។

មហោសថក្រាបទូលថា ៖

"បពិត្រមហារាជ ពួកទូលបង្គំជាអ្នកដំណើរ ទើបតែមកដល់ថ្មីៗ ទាហានជាច្រើនក្នុងវាំង សោតសឹងតែជាមនុស្សសំណព្វព្រះទ័យ របស់ព្រះអង្គ កាលបើពួកទូលបង្គំជ្រើសប៉ះចំផ្ទះរបស់ពួកគេ ពួកគេនឹងឈ្លោះប្រកែកជាមួយនឹងពួកទូលបង្គំ។ បពិត្រព្រះអង្គ ក្នុងពេលនោះ ពួកទូលបង្គំនឹងធ្វើដូចម្ដេច ជាមួយនឹងពួកគេ?"

ស្ដេចចូឡនីត្រាស់ថា ៖

"សូមលោកកុំខ្វល់ទៅនឹងពាក្យរបស់ពួកគេអី សូមលោកឲ្យគេ ជ្រើសរកកន្លែងស្នាក់នៅតាមសេចក្ដីពេញចិត្តលោកចុះ"។

មហោសថថា៖

"បពិត្រព្រះសម្មតិទេព ពួកគេនឹងមកម្ដងហើយម្ដងទៀត ពិតទូលចំពោះព្រះអង្គ ធ្វើឲ្យព្រះអង្គ មិនបានសុខព្រះទ័យ ប៉ុន្តែបើព្រះអង្គសព្វព្រះរាជហឫទ័យឥតយល់ទាស់ទេ សូមឲ្យ

ទ័ពទាំងឡាយរបស់ពួកទូលបង្គំធ្វើជាឆ្មាំទ្វារ ចាំយាមជំនួសទ័ពព្រះអង្គវិញ ទម្រាំតែពួកទូលបង្គំជ្រើសរកនិវេសន៍បាន ពេលនោះ ពួកគេនឹងមិនហ៊ានចេញចូលវាំងព្រះទ័យរបស់ព្រះអង្គឡើយ ក្រាបទូល"។

ព្រះរាជាចូឡនី ទ្រង់យល់ព្រមតាមសេចក្ដីស្នើរបស់លោកសេនាប្រមុខមហោសថ។

សេនាប្រមុខមហោសថ បានចាត់តាំងពួកទាហានខ្លួន ឲ្យនៅយាមគ្រប់ទីកន្លែង គឺនៅជើងជណ្ដើរ នៅក្បាលជណ្ដើរនិងនៅទ្វារធំ ព្រមទាំងបញ្ជាពួកគេថា "ពួកលោកកុំឲ្យនរណាម្នាក់ចូលទៅបានឲ្យសោះ" ក្រោយមក លោកដើរទៅកាន់និវេសន៍របស់ព្រះមាតានៃស្ដេចចូឡនី រួចបង្គាប់ពួកមនុស្សខ្លួន ឲ្យសម្ដែងអាការធ្វើដូចជាចង់វាយបំបែកដំណាក់របស់ព្រះរាជមាតា។ ពួកទាហានរបស់មហោសថ បានចាប់ផ្ដើមរើឥដ្ឋនិងដីស្អិតចេញ តាំងពីរបៀងទ្វារនិវេសន៍ទៅ។ ព្រះរាជមាតាបានឃើញដូច្នេះ ទ្រង់ត្រាស់សួរផ្ទាល់ថា៖

"នែអស់លោក ហេតុអ្វីអស់លោកវាយបំបែកដំណាក់របស់ខ្ញុំ"។

ទាហានទាំងនោះទូលថា៖

"លោកសេនាប្រមុខមហោសថ បញ្ជាពួកទូលបង្គំឲ្យវាយបំបែក ហើយមានបំណងនឹងសាងសង់ព្រះរាជនិវេសន៍ថ្មី សម្រាប់ព្រះបាទវិទេហៈ"។

ព្រះរាជមាតា មានព្រះសវនីយ៍ថា៖

"បើអ៊ីចឹង សូមពួកលោកឈប់សកម្មភាពវាយរំលុះទាំងនេះប៉ុណ្ណឹងចុះ"។

ពួកទាហានក្រាបទូលថា៖

"ពួកពលនិងពាហនៈរបស់ព្រះរាជានៃពួកទូលបង្គំមានចំនួនច្រើន ទីនេះមិនល្មមដាក់បានទេ ពួកទូលបង្គំនឹងសង់គេហដ្ឋានមួយទៀត ឲ្យធំទូលាយជាងនេះ"។

ព្រះរាជមាតាគំរាមពួកទាហានថា៖

"ពួកលោកមិនស្គាល់ខ្ញុំទេឬ? ខ្ញុំនេះជាព្រះមាតាបង្កើតរបស់ស្ដេចចូឡនី ខ្ញុំនឹងទៅកាន់សម្នាក់របស់បុត្រខ្ញុំ ដល់ពេលនោះពួកលោកគង់តែនឹងដឹង"។

ពួកទាហានក្រាបទូលតបថា៖

“ពួកទូលបង្គំ វាយបំបែកតាមព្រះរាជបញ្ជារបស់ព្រះរាជាទេតើ តែបើព្រះនាងអាចជំទាស់បាន សូមស្តេចយាងទៅចុះ”។

ព្រះរាជមាតាអង្គនោះ ទ្រង់ពិរោធខ្លាំងបានយាងទៅកាន់ទ្វារព្រះបរមរាជវាំង ក្នុងគោលបំណងចង់យល់អំពីទង្វើដែលពួកទាហានទាំងនោះធ្វើដូច្នេះ។

គ្រានោះ ពួកទាហានឆ្មាំទ្វាររបស់សេនាប្រមុខមហោសថ ដែលនៅយាមតាមព្រះបរមរាជវាំងនោះ ឃាត់ព្រះរាជមាតាមិនឲ្យចូលទៅយ៉ាងដាច់អហង្ការ។

គ្រានោះ ព្រះរាជមាតាត្រាស់គំរាមថា៖

“យើងនេះជាព្រះមាតារបស់ស្តេចផែនដី”។

ពួកទាហានទូលតបថា៖

“ពួកទូលបង្គំមិនស្គាល់ព្រះនាងជាអ្វីទេ ព្រះរាជាបញ្ជាពួកទូលបង្គំឲ្យយាមនៅទីនេះ មិនអនុញ្ញាតឲ្យនរណាម្នាក់ចូលទៅជាដាច់ខាត សូមព្រះនាងយាងត្រឡប់ទៅវិញចុះ ក្រាបទូល”។

ព្រះរាជមាតា កាលរកតម្រិះតវ៉ាមិនបាន[១៥៩]ក៏ត្រឡប់ក្រោយវិញ មកឈរសម្លឹងមើល ស្ពាយនិវេសន៍របស់ព្រះនាង។ គ្រានោះ ទាហាន របស់មហោសថម្នាក់ មកចាប់កព្រះរាជមាតាបណ្ដេញថា "នាងធ្វើអ្វី នៅទីនេះ? ទៅទៅ ម៉េចនាងមិនទៅទៅអ៊្ហែ?" ហើយក៏បោកផ្ដួលព្រះរាជ មាតាឲ្យដួលទៅលើដី។

ព្រះរាជមាតា ទ្រង់ព្រះតម្រិះថា "ទាហានទាំងអស់នេះ ប្រាកដជា ត្រូវស្ដេចបង្គាប់មែនហើយ បើពុំនោះទេ គេមិនអាចនឹងធ្វើយ៉ាងនេះ បានទេ អញនឹងទៅកាន់សម្នាក់របស់មហោសថបណ្ឌិតម្ដង"។ ព្រះរាជ មាតាយាងទៅសួរសេនាប្រមុខមហោសថថា៖

"នៃមហោសថ ហេតុអ្វីក៏លោកប្រើកងទ័ពវាយកម្ទេចលំនៅឋាន របស់យើងអ៊ីចឹង?"

មហោសថមិននិយាយអ្វីជាមួយនឹងព្រះរាជមាតាទេ។ ខណៈនោះ ទាហានម្នាក់ដែលឈរក្បែរមហោសថ ទូលសួរថា៖

"បពិត្រព្រះមហាក្សត្រិយានី ព្រះនាងមានព្រះបន្ទូលពីរឿងអ្វី?" ព្រះរាជមាតាត្រាស់សួរវិញថា៖

---

[១៥៩] គហេតព្វគហណំ អបស្សន្តិ។

"នែអ្នក មហោសថបណ្ឌិតចៅហ្វាយអ្នកឯង ឲ្យគេវាយកម្ទេចលំនៅឋានរបស់យើង តើព្រោះហេតុអ្វី?"

ទាហានទូលតបវិញថា៖

"ដើម្បីសាងសង់ព្រះរាជដំណាក់សម្រាប់ព្រះបាទវិទេហៈ"។

ព្រះរាជមាតាត្រាស់ថា៖

"ហេតុអ្វីបានជាធ្វើអីចឹង? ក្នុងទីក្រុងធំធេងយ៉ាងនេះ មហោសថរកកន្លែងដទៃសាងសង់រាជដំណាក់មិនបានទេឬ? ហ៏ណេះ ប្រាក់ ១.០០០ កហាបណៈនេះ[១៦០]ជាសំណូករបស់ខ្ញុំ សូមឲ្យលោកមហោសថទទួល ហើយទៅសាងសង់រាជដំណាក់ នៅកន្លែងផ្សេងចុះ"។

ទាហានក្រាបទូលថា៖

"ក្រាបទូលព្រះនាងទេវី ខ្ញុំនឹងបញ្ឈប់នូវគម្រោងការសាងសង់ត្រង់ព្រះរាជដំណាក់របស់ព្រះនាង សូមព្រះនាងកុំប្រាប់នរណាម្នាក់ឲ្យដឹងអំពីការទទួលសំណូកនេះឡើយ បើមិនដូច្នេះទេ អ្នកដទៃនឹងធ្វើតាមព្រះនាង ដើម្បីរក្សាដំណាក់របស់ខ្លួនដែរ"។

---

[១៦០] ឥមំ សតសហស្សំ លញ្ជំ គហេត្វា អញ្ញត្ថ គេហំ ការេតុ។

ព្រះរាជមាតាត្រាស់ថា៖

"ប្រពៃហើយអ្នក ប៉ុន្តែនៅពេលលេចឮដំណឹងថា ព្រះមាតាស្ដេចឲ្យសំណូកដល់គេ ពេលនោះ យើងនឹងអាម៉ាស់មុខខ្លាំងណាស់ ដោយហេតុនោះ យើងនឹងមិនប្រាប់នរណាម្នាក់ទេ"។

បន្ទាប់ពីទទួលសំណូក ១.០០០ កហាបណៈ ពីព្រះមាតាមក ទាហាននោះក៏យកប្រាក់ ហើយទៅជម្រាបដល់លោកសេនាប្រមុខមហោសថ។ គ្រានោះមហោសថនិយាយថា៖

"ល្អណាស់ លោកទទួលប្រាក់សំណូកចំនួន ១.០០០ កហាបណៈ ហើយបញ្ឈប់នូវគម្រោងការសាងសង់ត្រង់រាជដំណាក់របស់ព្រះនាង ហើយចូរអ្នកទៅផ្ទះរបស់កេវដ្តព្រាហ្មណ៍ម្តង"។

ចំណែកកេវដ្តព្រាហ្មណ៍ បានទៅព្រះបរមរាជវាំង ដើម្បីទូលប្ដឹងព្រះបាទចូឡនីដូចគ្នា លទ្ធផលបានត្រឹមតែកន្ទួលស្បែកខ្នង ដោយបទុះឫស្សី[១៦១] ពីពួកឆ្មាំវាំង គាត់រកវិធីតវ៉ាមិនបាន ក៏វិលមកលំនៅឋានខ្លួនវិញ សូកប្រាក់ ១.០០០ កហាបណៈដែរ។ ដោយឧបាយនោះ ប្រាក់ ៩ កោដិកហាបណៈបានកើតឡើង ដោយទទួលសំណូក ក្នុងអំឡុងពេលជ្រើសរើសទីតាំងសំណង់រាជដំណាក់ ក្នុងទីក្រុងទាំងមូល។

---

[១៦១] វេឡុបេសិកាហិ បិដ្ឋិចម្មុប្បាជនំ លភិត្វា។

**មហោសថស្នើសាងសង់រាជដំណាក់ខាងក្រៅទីក្រុង**

*លោកសេនាប្រមុខមហោសថ លុះបានដើរសព្វប្រកល្អកទូទាំងនគរហើយ លោកបានមកកាន់ព្រះបរមរាជវាំងនៃព្រះបាទចូឡនីវិញ។ លំដាប់នោះ ព្រះរាជាសួរមហោសថថា៖*

*"យ៉ាងម៉េចហើយ លោកបណ្ឌិត? តើលោកជ្រើសរកបាននូវទីឋានសម្រាប់សាងសង់ព្រះរាជដំណាក់ថ្មីហើយឬនៅ?[១៦២]"*

*មហោសថក្រាបទូលថា៖*

*"បពិត្រមហារាជ កាលបើពួកទូលបង្គំជ្រើសចំកូមិគ្រឹះ ឬដំណាក់របស់ពួកគេ នេះជាការប៉ះពាល់ខ្លាំងណាស់ អាចធ្វើឲ្យប្រជារាស្ត្ររបស់ព្រះអង្គមិនសប្បាយចិត្តចំពោះព្រះអង្គ និងពួកទូលបង្គំឡើយ ដូច្នេះ ទូលព្រះបង្គំជាខ្ញុំនឹងសាងទីក្រុងជារាជដំណាក់សម្រាប់ព្រះមហាក្សត្រនៃពួកទូលបង្គំ នៅទីឯណោះ ចន្លោះទន្លេគង្គានិងទីក្រុងនេះ ក្នុងទំហំដីមួយគាវុត ខាងក្រៅទីក្រុងព្រះអង្គនេះវិញ ក្រាបទូល"។*

[១៦២] គឺ បណ្ឌិត លទ្ធំ តេ វសនដ្ឋានំ។

ទ្រង់ព្រះសណ្ដាប់ដូច្នោះ ព្រះរាជាសព្វព្រះទ័យដោយនឹកថា "ប្រពៃណាស់ បើបានគេសង់ព្រះរាជដំណាក់នោះ នៅក្រៅទីក្រុង អញងាយស្រួលនឹងធ្វើសង្គ្រាម ព្រោះទ័ពគេនៅក្រៅដោយឡែក ទ័ពអញនៅក្នុងក្រុងដោយឡែក មិនច្របូកច្របល់គ្នា អញនឹងសម្លាប់សត្រូវ មិនឲ្យសេសសល់ឡើយ។

បន្ទាប់មកព្រះអង្គត្រាស់ប្រាប់មហោសថភ្លាមថា៖

"ល្អណាស់ លោកបណ្ឌិត ចូរលោកសាងសង់ត្រង់ចន្លោះទន្លេគង្គានិងទីក្រុងនេះចុះ"។

មហោសថទូលព្រះរាជាថា៖

"បពិត្រមហារាជ ទូលបង្គំនឹងសាងសង់នៅទីនោះ ប៉ុន្តែសូមកុំឲ្យប្រជារាស្ត្ររបស់ព្រះអង្គ ចូលទៅរកឧសនិងបន្លែផ្លែឈើជាដើមក្នុងការដ្ឋានឬទីតាំងសំណង់[១៦៣]របស់ពួកទូលបង្គំឡើយ ក្រាបទូល ជាការពិតណាស់ កន្លែងការដ្ឋាន បើមានមនុស្សទៅមកអ៊ូអរ នាំឲ្យមានការរំខាន និងអាចបង្កជម្លោះក៏ថាបាន ធ្វើឲ្យពួកជាងរបស់ទូលបង្គំមានចិត្តមិនស្ងប់ ធ្វើការមិនបានសម្រេច"។

---

[១៦៣] អម្ហាកំ នវកម្មដ្ឋានំ នាគន្តព្វំ។

ព្រះរាជាទ្រង់ត្រាស់តបថា៖

“អ៊ីចឹងល្អហើយ លោកបណ្ឌិត បិទផ្លូវចរាចរណ៍ចុះ កុំឲ្យពួកគេដើរទៅមកចូលកាត់ការដ្ឋានរបស់លោក[១៦៤]”។

មហោសថក្រាបទូលថា៖

“បពិត្រព្រះសម្មតិទេព ដំរីទាំងឡាយរបស់ពួកទូលបង្គំ ត្រូវការចុះលេងទឹក គង់តែពួកវាលេងទឹកក្នុងទន្លេនិងស្ទឹងនៅតំបន់នោះពុំខានៗ ទឹកថ្លានឹងក្លាយជាល្អក់ ពួកអ្នកនគរនឹងរអ៊ូរទាំថាចាប់តាំងពីមហោសថចូលមកទីនេះ ពួកយើងរកទឹកថ្លាផឹកមិនបានទាល់តែសោះ ដូច្នេះ កិច្ចការសំណង់នោះ ទូលបង្គំសូមព្រះអង្គសហការក្នុងរឿងនេះផងដែរ ក្រាបទូល[១៦៥]”។

ព្រះរាជាត្រាស់តបថា៖

“មិនអីទេ ចូរឲ្យហ្វូងដំរីរបស់លោក ចុះលេងតាមចិត្តចុះ”។

មានព្រះរាជឱង្ការដូច្នេះរួច ទ្រង់ក៏បញ្ជាអ្នកបម្រើឲ្យដើរវាយស្គរប្រកាសជូនដំណឹងដល់ប្រជាជនទូទាំងនគរថា៖

---

១៦៤ តេន បវេសនំ និសេធេហិ ការេហិ។

១៦៥ តម្បិ សហិតព្វំ។

"ជនណាមួយចេញពីក្រុងនេះ ទៅកាន់តំបន់ការដ្ឋានរបស់លោកសេនាប្រមុខមហោសថ ជននោះនឹងត្រូវផាកពិន័យជាប្រាក់ចំនួន ១.០០០ កហាបណៈ"។

## ការរៀបចំមហាឧមង្គ

សេនាប្រមុខមហោសថ បានថ្វាយបង្គំលាព្រះបាទចូឡនីព្រហ្មទត្ត ដឹកនាំកងប្រដាប់អាវុធរបស់ខ្លួន ចេញទៅទៅកាន់ទីការដ្ឋាន បានចាប់ផ្តើមសាងសង់ទីក្រុងថ្មី ក្នុងភូមិភាគតាមដែលបានកំណត់ជាផែនការហើយស្រាប់។ នៅត្រើយម្ខាងនៃទន្លេគង្គា សេនាប្រមុខបានបង្កើតស្រុកមួយឈ្មោះថា វគ្គុលី សម្រាប់ថែរក្សាដំរី សេះ រថ ពាហនៈ និងគោជំៗនៅក្នុងស្រុកនោះ។ បន្ទាប់មក លោកចាត់ផែនការកសាងទីក្រុងឧមង្គដោយបែងចែកការងារទាំងពួងថា មនុស្សប៉ុណ្ណោះធ្វើការងារនេះ មនុស្សប៉ុណ្ណោះធ្វើការងារនោះ។ ទ្វារមហាឧមង្គ ត្រូវបានកសាងនៅត្រង់កំពង់ទន្លេគង្គា។ ពួកទាហាន ដែលធ្វើមហាឧមង្គនោះ មានចំនួន ៦.០០០នាក់។ បំណះដីខ្សាច់ត្រូវទាហានទាំងនោះសែងទាំងការុងធំៗ[១៦៦] យកទៅចាក់ក្នុងទន្លេគង្គា។ អាចម៍ដីដែលធ្លាក់ទៅទាំងអម្បាលម៉ានពពួកដំរីតែងជាន់ពន្លិចទៅក្នុងទឹកអស់។ ក្រសែទឹកទន្លេគង្គា បានហូរ

[១៦៦] មហន្តេហិ ចម្មបសិព្វកេហិ វាលុកបំសុំ ហរិត្វា គង្គាយ បាតេន្តិ។

ក្ដួចនាំនូវភោគពកខ្វក់[១៦៧]ទៅជាមួយផង[១៦៨]។ ពួកប្រជាជន ដែលរស់នៅក្នុងក្រុងបញ្ចាល នាំគ្នាស្ដីបន្ទោសមហោសថថា “តាំងពីមហោសថមកយើងមិនមានទឹកថ្លាផឹកសោះ ទឹកទន្លេគង្គាប្រែជាកករល្អក់ ដំណើរនោះព្រោះហេតុអ្វី?” ក្នុងកាលនោះ ពួកទាហានបន្ទប់របស់មហោសថ បានប្រាប់ប្រជាជនទាំងឡាយនោះឲ្យជ្រាបថា “ហ្វូងដំរីរបស់លោកសេនាប្រមុខមហោសថ កំពុងលេងទឹក ទើបបានធ្វើឲ្យភក់ក្នុងទន្លេគង្គាផុរខ្សុលឡើង ជាហេតុបណ្ដាលឲ្យទឹកទន្លេហូរកករល្អក់”។

ជាធម្មតា គោលបំណងរបស់ព្រះពោធិសត្វទាំងឡាយ តែងតែបានសម្រេចសមតាមប្រាថ្នា។ ព្រោះដូច្នោះ ទោះគល់ឈើក្ដី ដង្គត់ឈើ

[១៦៧] គង្គា អាឡ្ហុលា សន្ទូតិ។

[១៦៨] ជាមួយ=ដែរ, ផងដែរ, រួមគ្នា, រួមផង, រួមផងដែរ។ ជាមួយនឹង=ព្រមដោយ, ព្រមទាំង, មានទាំង, ថែមទាំង, មួយអន្លើដោយ។ ចំពោះពាក្យពីរនេះ មានការប្រើប្រទ្បំគ្នាច្រើនដោយយល់ថាន័យដូចគ្នា។ ប៉ុន្តែភាពពិត គឺខុសគ្នាឆ្ងាយណាស់ដូចត្រើយអាយនិងត្រើយនាយនៃមហាសមុទ្រ សូមសង្កេតទម្រង់និងឧទាហរណ៍៖ **ជាមួយ** មានទម្រង់គឺ កិរិយា+ជាមួយ, ឧ.ទៅជាមួយ, បរិភោគជាមួយ។ ជួនណានឹងប្រើពាក្យ គ្នា នៅខាងចុងជាមួយ ក៏បាន ឧ. ទៅជាមួយគ្នា បរិភោគជាមួយគ្នា។ ចំណែក**ជាមួយនឹង** មានទម្រង់គឺ ជាមួយនឹង+នាម, ឧ. បងនិយាយជាមួយនឹងប្អូន, គ្រូកំពុងនិយាយជាមួយនឹងនិស្សិតច្រើននាក់, អ្នកទៅជាមួយនឹងខ្ញុំឬទេ?, អ្នកណាខ្លះមកជាមួយនឹងអ្នក?

ក្តី ជុំជីក្តី ថ្មក្តី ទាំងអស់នោះដែលមាននៅក្នុងការដ្ឋានឧមង្គ បានលិចចូលទៅក្នុងផែនដី។ ទ្វារនៃឧមង្គថ្មើរជើងត្រូវបានធ្វើក្នុងទីក្រុងថ្មីនោះឯង។ ពួកទាហានដែលជីកឧមង្គថ្មើរជើងនោះ មានចំនួន ៣០០ នាក់។ ពួកគេបានប្រកអាចម៍ដីក្នុងការុង សែងយកមកទម្លាក់ក្នុងការដ្ឋានសំណង់ទីក្រុងថ្មីនោះ។ ពួកទាហានសំណង់ បានឲ្យជីរជាន់អាចម៍ដី ដែលគេយកមកទម្លាក់ហើយនោះ ប្របល់លាយជាមួយនឹងទឹក ផ្សំជាមួយនឹងវត្ថុធាតុដទៃទៀត ដើម្បីកសាងកំពែង។ ការសាងសង់មហាឧមង្គមហោសថ បានបញ្ជាទាហានឲ្យធ្វើទ្វារយន្ត បើកបិទដោយម៉ាស៊ីនមានកម្ពស់ ១៨ ហត្ថ។ ទ្វារយន្តនោះ បើគេជាន់គន្លឹះមួយ[១៦៩] វានឹងបិទ បើគេជាន់គន្លឹះមួយទៀត វានឹងរបើក។ ជញ្ជាំងទាំងពីរខាងនៃមហាឧមង្គបានសាងពីឥដ្ឋ លាបថ្នាំស រូបគូរគំនូរផ្សេងៗ យ៉ាងល្អប្រណីត[១៧០]។ នៅផ្នែកខាងលើ ប្រក់ក្តារជាដំបូល គួរឲ្យចង់គយគន់[១៧១]។ មហាឧមង្គនោះ មានទ្វារធំ ៨០ ទ្វារតូច ៦៤ រួមទាំងអស់ ១៤៤ ទ្វារ សុទ្ធតែបើកបិទដោយគ្រឿងយន្តទាំងអស់។ កាលបើជាន់គន្លឹះមួយ ទ្វារទាំងអស់

---

[១៦៩] តញ្ហិ ឯកាយ អាណិយា អក្កន្តាយ បិធីយតិ, ឯកាយ អាណិយា អក្កន្តាយ វិវរីយតិ។

[១៧០] សុធាកម្មំ ការេសិ។

[១៧១] ឧល្លោកំ។

នឹងបិទ កាលបើជាន់គន្លឹះមួយទៀត ទ្វារទាំងអស់នឹងបើក។ នៅក្នុងឧម្មង្គ មានប្រទីបជាច្រើន បើកបិទដោយគ្រឿងយន្តស្វ័យប្រវត្តិដែរ។ កាលបើបើកមួយ វាភ្លឺទាំងអស់ កាលបើបិទមួយ វាងងឹតទាំងអស់។ នៅសងខាងឧម្មង្គ មានបន្ទប់ក្រឡាបន្ទំ មានកម្រាលពណ៌ផ្សេងៗ សម្រាប់ក្សត្រ ១០១ អង្គ ដែលគេរៀបចំរួចបំរុងជាស្រេច។ លើក្រឡាបន្ទំនីមួយៗ មានស្វេតច្ឆត្រ ដោតបញ្ឈរស្រាប់ លើសពីនោះទៅទៀត ពួកជាងគំនូរបានឆ្លាក់រូបស្ត្រីស្អាតៗ មានពណ៌ចោមស្រស់ល្អ ភ្ជាប់ទៅនឹងក្រឡាបន្ទំនីមួយៗ បើមិនយកដៃស្ទាបទេ មិនអាចដឹងថាជារូបមនុស្ស ដែលជាងឆ្លាក់នោះឡើយ។ ប្រការមួយវិញទៀត ពួកវិចិត្រករដ៏មានទេពកោសល្យប៉ិនប្រសប់ខាងគំនូរ បានគូររូបទេសភាពយ៉ាងវិចិត្រមានប្រការផ្សេងៗ តាំងនៅតាមជញ្ជាំងឧម្មង្គ ពិពណ៌នាអំពីដំណើរយាងយាសរបស់សក្កទេវរាជ ភ្នំព្រះសុមេរុ ភ្នំសត្តបរិភណ្ឌ ចក្រវាលមហាសាគរ ស្រះធំទាំង៧ មហាទ្វីបទាំង ៤ ព្រៃហិមពាន្ត អនោតត្តស្រះផ្ទាំងមនោសិលា ព្រះឥន្ទ្រ ព្រះចន្ទ ព្រះអាទិត្យ រួមនឹងសម្បត្តិសួគ៌ ៦ ជាន់ ពណ៌នាតាំងពីឋាន ចាតុម្មហារាជិកា ជាដើម។ នៅលើផែនដីពួកគេបានរោយរាយគ្រាប់ ខ្សាច់ដែលមានពណ៌ដូចផ្ទាំងប្រាក់ នៅខាងលើមានផ្កាឈូកគួរឲ្យគយគន់។ តាមសងខាង មានផ្សារលក់ទំនិញផ្សេងៗ។ នៅគ្រប់កន្លែង សុទ្ធតែមានសំណុំ ឬបាច់នៃគ្រឿងក្រអូប

បាច់ផ្កាជាដើម ព្យួរសំយ៉ុងចុះត្រៀបត្រា ជាការតុបតែងមួយ ប្រៀប បានទៅនឹង *សុធម្មាទេវសភា* នៅឯឋានត្រៃត្រិង្សសួគ៌ទេវលោក។

**ព្រះបាទវិទេហៈយាងមករាជដំណាក់ថ្មី**

និយាយអំពីមេជាងឈើ ៣០០ នាក់ ដែលមហោសថបានប្រើ ទៅនោះ ពួកគេបានអារឈើ ឈូសចាំង វាយពត់ធ្វើជាសំពៅបាន ចំនួន ៣០០ សំពៅ ហើយផ្ទុកដោយទព្វសម្ភារៈ[១៧២] ដែលលាបពណ៌ ហើយស្រេចពេញសំពៅ ដឹកទៅតាមទន្លេគង្គា រួចទៅជម្រាបមហោសថ បណ្ឌិតឲ្យលោកជ្រាប។ ទព្វសម្ភារៈទាំងឡាយនោះ មហោសថបាននាំ យកមកប្រើប្រាស់ក្នុងទីក្រុងថ្មីនោះ ឯសំពៅឲ្យយកទៅលាក់ទុកក្នុងទី កន្លែងស្ងាត់កំបាំង សម្រាប់ប្រើប្រាស់ក្នុងពេលដែលត្រូវការ។ មហោសថ បានបញ្ជាឲ្យជាងជីកស្នាមភ្លោះ[១៧៣] ៣ ក្នុងទីក្រុងថ្មីនោះ

---

[១៧២] គ្រឿងប្រុង គឺគ្រឿងប្រដាប់សម្រាប់ផ្ទុំ, សម្រាប់ផ្សំ, ដំឡើង ដូចយ៉ាងគ្រឿង គេហដ្ឋាននិងគ្រឿងរទេះជាដើម ឧ. មុននឹងសង់គេហដ្ឋាន គប្បីរកទព្វសម្ភារៈឲ្យបាន សព្វគ្រប់សិន។

[១៧៣] គូតូចឬប្រឡាយធំជ្រៅដែលជីកពទ្ធជុំវិញកំពែងជាដើម ខ្លះមានបញ្ចូលទឹក ខ្លះ បញ្ចូលភក់ ខ្លះស្នសំណាចាក់ឲ្យដក់នៅជានិច្ច ខ្លះទុកឲ្យស្ងួតមិនបញ្ចូលអ្វីទៅទេ, ទាំង នេះ សម្រាប់ការពារមិនឲ្យបច្ចាមិត្រពីខាងក្រៅចូលមកបានដោយងាយ។

គឺស្នាមភ្លោះទឹក១ ស្នាមភ្លោះភក់១ ស្នាមភ្លោះស្ងួត១ និងបានកសាងនូវសមិទ្ធផលផ្សេងទៀត គឺកំពែងកំពស់ ១៨ ហត្ថ ប៉មទីក្រុង រាជនិវេសន៍ រោងដំរីជាដើម និងស្រះបោក្ខរណី ជាច្រើនកន្លែង។ ចំណាយពេលត្រឹមតែ ៤ ខែប៉ុណ្ណោះ មហោសថបានសាងសង់មហាឧមង្គ ឧមង្គថ្មើរជើង និងនគរទាំងអស់នោះ រួចស្រេចជាស្ថាពរ។ លុះចប់កិច្ចការប៉ុណ្ណោះហើយ លោកសេនាប្រមុខមហោសថ បានបញ្ជូនទូតឲ្យទៅក្រាបទូលព្រះបាទវិទេហរាជថា "មហាបពិត្រ ព្រះរាជនិវេសន៍ បានសាងសង់រួចរាល់ហើយ សូមព្រះអង្គស្ដេចយាងមកក្នុងកាលឥឡូវនេះចុះ"។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់ពាក្យរបស់ទូតហើយ ព្រះអង្គមានព្រះហឫទ័យត្រេកអរជាខ្លាំង ហើយទ្រង់កេណ្ឌចតុរង្គសេនា គឺពលដំរី ពលសេះ ពលរថ និងពលថ្មើរជើង ធ្វើដំណើរចេញអំពីនគរជាក្បួនព្យុហយាត្រា ព្រមទាំងបរិវារជាច្រើនទៀត និងពាហនៈ មានចំនួនច្រើនរាប់មិនអស់ ដើម្បីទៅកាន់ទីក្រុងថ្មីដ៏ធំទូលាយ ដែលមហោសថសាងនៅឯកបិលរដ្ឋ។

## ព្រះបាទវិទេហៈបញ្ជូនរាជទូតទៅសម្លាក់ព្រះបាទចូឡនី

ព្រះបាទវិទេហៈ ទ្រង់យាងតាមលំដាប់រហូតទៅដល់ទន្លេគង្គា ដែនកបិលរដ្ឋ។ គ្រានោះ លោកសេនាប្រមុខមហោសថ មកទទួលស្វាគមន៍ចំពោះព្រះអង្គ រួចយាងព្រះអង្គចូលទៅខាងក្នុងនគរដែលខ្លួនបានរៀបចំទុកបម្រុងស្រេច។ ព្រះរាជាយាងឡើងប្រាសាទដ៏បវរ។ ក្នុងទីនោះ ព្រះរាជាសោយព្រះក្រយាស្ងោយ មានឱជារសឆ្ងាញ់ៗ ហើយសម្រាកព្រះកាយព្រះអង្គមួយស្របក់ លុះដល់វេលារសៀល ទ្រង់បញ្ជូនរាជទូតឲ្យនាំរាជសារទៅថ្វាយស្ដេចចូឡនី ដើម្បីក្រាបទូលអំពីដំណឹងនៃការយាងមកដល់របស់ព្រះអង្គថា៖

"បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំយាងមកដល់ហើយ ទូលបង្គំសូមថ្វាយបង្គំនូវព្រះបាទទាំងគូរបស់ព្រះអង្គ។ ទូលព្រះបង្គំជាខ្ញុំយាងមកទីនេះ ដើម្បីរៀបអភិសេកជាមួយនឹងព្រះរាជធីតា ដែលជាព្រះរាជទានរបស់ព្រះអង្គ ហេតុដូច្នេះ សូមព្រះអង្គទ្រង់ព្រះមេត្តា ព្រះរាជទាននូវព្រះរាជធីតា ដែលមានសព៌ាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការមាស ដែលមានពួកទាសីជាបរិវារឲ្យមកជាមហេសីរបស់ទូលបង្គំជាខ្ញុំ ក្នុងកាលឥឡូវនេះចុះ"។

## កំណត់សម្គាល់

ព្រះបាទចូឡនី មានវ័យក្មេងជាងព្រះបាទវិទេហៈ ព្រោះហេតុតែព្រះបាទវិទេហៈ វង្វេងកាន់កាំងដោយអំណាចកិលេស ទ្រង់បែរជាព្រះតម្រិះថា ធម្មតាកូនកំលោះរបស់កូនក្រមុំ គួរថ្វាយបង្គំឪពុកក្មេក ទ្រង់ចិន្តាដូច្នេះ ទើបព្រះបាទវិទេហៈអង្គនោះ បញ្ជូនរាជសារទៅថ្វាយបង្គំព្រះយុគលបាទរបស់ព្រះបាទចូឡនីយ៉ាងនេះ។ ព្រះអង្គមិនបានដឹងអំពីល្បិចកិច្ចកលរបស់ព្រះបាទចូឡនីអង្គនោះទេ។

ព្រះបាទចូឡនី ទ្រង់ព្រះសណ្ដាប់សេចក្ដីរាយការណ៍របស់ទូតហើយ ទ្រង់មានសោមនស្សក្នុងព្រះទ័យថា "ឥឡូវនេះ បច្ចាមិត្ររបស់អញ មិនអាចគេចខ្លួនទៅទីណាបានទេ អញនឹងកាត់ក្បាលពួកគេទាំងពីរនាក់ ហើយជប់លៀងសោយទឹកជយបាន"។ មិនត្រឹមតែសប្បាយព្រះទ័យប៉ុណ្ណឹងទេ ស្ដេចចូឡនីថែមទាំងផ្ដល់រង្វាន់ដល់រាជទូតដែលមកនោះថែមទៀតផង រួចទ្រង់មានព្រះរាជឱង្ការ ហាក់ដូចព្រះបាទវិទេហៈនៅចំពោះព្រះភក្ត្រព្រះអង្គថា៖

"បពិត្រព្រះបាទវិទេហៈ ព្រះអង្គស្ដេចយាងមកល្អណាស់ សូមព្រះអង្គរើសរកថ្ងៃនក្ខត្តឫក្សចុះ យើងមុខតែនឹងថ្វាយរាជធីតា

ដែលប្រដាប់ដោយគ្រឿងអលង្ការមាស មានពួកទាសីជាបរិវារ ដល់ព្រះអង្គពុំខាន"។

ចំណែកទូត ឮព្រះរាជតម្រាស់ដូច្នោះ បានត្រឡប់ទៅកាន់សម្នាក់របស់ព្រះបាទវិទេហៈវិញ ក្រាបទូលថា៖

"បពិត្រព្រះសម្មតិទេព ព្រះបាទចូឡនី សូមឲ្យព្រះអង្គជ្រើសរកពេលានក្ខត្តឫក្សដ៏សមគួរ ដើម្បីរៀបចំនូវពិធីអភិសេកឲ្យហើយសិន ទើបព្រះបាទចូឡនីនោះ បញ្ជូនរាជធីតា មកថ្វាយព្រះអង្គ ក្រាបទូល"។

បន្ទាប់ពីព្រះបាទវិទេហៈ បានទទួលដំណឹង ទ្រង់ក៏ជ្រើសពេលាហើយដឹងថា "ថ្ងៃនេះ ជាថ្ងៃមាននក្ខត្តឫក្សល្អហើយ" ទ្រង់ក៏បញ្ជូនទូតនាំរាជសារទៅម្តងទៀតថ្វាយព្រះបាទចូឡនី ព្រហ្មទត្តថា៖

"សូមព្រះអង្គទ្រង់ប្រទានរាជធីតាដែលមានសព៌ាង្គកាយដ៏ល្អប្រដាប់ដោយគ្រឿងអលង្ការមាស មានពួកទាសីជាបរិវារឲ្យជាមហេសីរបស់ទូលព្រះបង្គំ ក្នុងកាលឥឡូវនេះមកចុះ"។

ចំណែកស្តេចចូឡនីតបដំណឹងទៅវិញថា៖

"ទូលបង្គំ នឹងថ្វាយរាជធីតា តាមពាក្យដែលទូលបង្គំបានសន្យាហើយដល់ព្រះអង្គ"។

ព្រះបាទចូឡនីមានព្រះបន្ទូលតបទៅថា នឹងថ្វាយព្រះរាជធីតាដល់ព្រះបាទវិទេហៈក្នុងកាលឥឡូវនេះ នោះសុទ្ធតែជាពាក្យកុហកបោកប្រាស់ ព្រោះដើម្បីពន្យាពេលក្នុងការរៀបចំល្បិចប៉ុណ្ណោះ។

ហើយព្រះបាទចូឡនីក៏បានឲ្យសញ្ញាដល់ស្តេច ១០១ អង្គថា៖

"សូមព្រះអង្គទាំងអស់ ព្រមទាំងកងប្រដាប់អាវុធចំនួន ១៨ អក្ខោភិនី ត្រៀមសព្វាវុធយុទ្ធភណ្ឌចេញទៅសមរភូមិ។ ថ្ងៃនេះដល់ពេលដែលយើងអាចកាត់ក្បាលសត្រូវដល់ទៅពីរនាក់ រួចយើងនឹងជួបជុំគ្នាជប់លៀងសោយទឹកជយបាននៅថ្ងៃស្អែក"។

## ស្តេចចូឡនីឡោមព័ទ្ធរាជដំណាក់ថ្មី

មុននឹងចេញទៅសមរភូមិ ស្តេចចូឡនី ទ្រង់បានរៀបចំឲ្យក្សត្រ ៤ អង្គ គឺ ព្រះរាជមាតាព្រះនាម **ចលាកទេវី**១ អគ្គមហេសីព្រះនាម **នន្ទាទេវី**១ ព្រះរាជបុត្រព្រះនាម **បញ្ចាលចន្ទ**១ ព្រះរាជធីតាព្រះនាម **បញ្ចាលចន្ទី**១ នៅលើប្រាសាទយ៉ាងសមរម្យជាមួយនឹងពួកស្រីស្នំ។ លុះរៀបចំរួចហើយ ព្រះបាទចូឡនីនាំស្តេចទាំង ១០១ អង្គ ព្រមទាំងរេហ៍ពលទាំងអស់ ចេញដំណើរទៅសមរភូមិ។

ចំណែកសេនាប្រមុខមហោសថ បានធ្វើសក្ការៈដ៏ធំដល់ព្រះបាទវិទេហៈ និងធ្វើពិធីជប់លៀងដល់ពួកទាហានដែលមកជាមួយនឹងព្រះអង្គ។ ទាហាន ខ្លះផឹកស្រា ខ្លះបរិភោគគ្រឿងក្លែមមានត្រីសាច់ជាដើម ខ្លះហត់នឿយខ្លាំងពេកក៏សំងំដេកលក់ទៅ ព្រោះដើរផ្លូវឆ្ងាយអស់ពេលជាច្រើនថ្ងៃ។ ចំណែកឯព្រះបាទវិទេហៈ យកបណ្ឌិតទាំង ៤ នាក់មានសេនកៈជាដើម ទៅប្រថាប់គង់នៅក្នុងប្រាសាទទេវវិនិច្ឆ័យ ដែលតុបតែងយ៉ាងស្អាត មានគណៈមន្ត្រីធំៗ[១៧៤]អង្គុយជុំវិញជាបរិវារ។

ចំណែកស្តេចចូឡនី បានពង្រាយខ្សែត្រៀមកងទ័ព១៨អក្ខោភិនីនោះជា៤ក្រុមឲ្យរត់ទៅតាមជ្រុងនីមួយៗនៃនគរ[១៧៥]ឡោមព័ទ្ធជុំវិញនគរទាំងអស់ ដួលគប់ភ្លើងរប់សែន ឈរជើងត្រៀមចាំចាប់ស្តេចវិទេហៈ និងសេនាប្រមុខមហោសថនៅពេលអរុណរះឡើង។

## មហោសថចាប់រាជវង្សស្តេចចូឡនី

សេនាប្រមុខមហោសថដឹងស្ថានការណ៍ដូច្នោះ បានបញ្ជាទាហានរបស់ខ្លួនចំនួន ៣០០ នាក់ថា៖

[១៧៤] អមច្ចគណបរិវុតោ។

[១៧៥] សព្វំ តំ នគរំ តិសន្តំ ចតុសង្ខេបំ បរិក្ខិបិត្វា។

"ចូរអ្នកទាំងឡាយចូលទៅតាមឧមង្គជើងជើង ទៅយាងព្រះមាតា អគ្គមហេសី រាជបុត្រ និងរាជធីតារបស់ស្តេចចូឡនីមក តាមឧមង្គជើងជើង រួចចូលតាមមហាឧមង្គ កុំឲ្យពួកគេចេញក្រៅទ្វារឧមង្គបានឲ្យសោះ ឲ្យនៅតែខាងក្នុងឧមង្គបានហើយ នៅទីនោះចូរមើលរក្សាឲ្យបានហ្មត់ចត់រហូតដល់យើងមកទីនេះវិញ។ ក្នុងពេលយើងមកដល់ អ្នកទាំងឡាយចូរយាងពួកទ្រង់អំពីឧមង្គទៅឃុំទុកក្នុងបន្ទប់ដ៏ធំមួយក្បែរទ្វារឧមង្គចុះ"។

ទាហានទាំង ៣០០ នាក់នោះទទួលបញ្ជាពីលោកសេនាប្រមុខមហោសថ ហើយបាននាំគ្នាធ្វើដំណើរតាមឧមង្គជើងជើង គាស់ក្តារក្រាលត្រង់ជើងជណ្តើរ រួចឡើងទៅចាប់ពួកអង្គរក្សដែលនៅយាមតាមជើងជណ្តើរ និងក្បាលជណ្តើរនៃប្រាសាទទេវវិនិច្ឆ័យរបស់ព្រះបាទចូឡនី និងពួកអ្នកបម្រើទាំងអស់ មានមនុស្សគមជាដើម ចងដៃ ចងជើង និងបិទមាត់មិនឲ្យនិយាយអ្វីកើត ហើយនាំមនុស្សទាំងនោះទៅឃុំទុកក្នុងកន្លែងផ្សេងៗគ្នា រួចនាំគ្នាបរិភោគក្រយាស្ងោយដែលគេត្រៀមដើម្បីស្តេចចូឡនី រួចបោកបំបែកថាស ចាន ភាជន៍ ផ្តិល រាត់រាយខ្ទេចខ្ទីអស់ ហើយនាំគ្នាឡើងទៅប្រាសាទជាន់ខាងលើ។ គ្រានោះ ព្រះមាតាចលាកទេវីនៃស្តេចចូឡនី បានយកព្រះមហេសីនន្ទាទេវី ព្រះរាជបុត្រ

និងរាជធីតា ទៅផុំលើក្រឡាបន្ទំរបស់ខ្លួន ព្រោះមិនបានដឹងថា នឹងមានរឿងរ៉ាវអ្វីកើតឡើងសោះ។ ពួកទាហាន របស់មហោសថ បន្លំខ្លួនធ្វើជាទាហានរបស់ស្ដេចចូឡនី ទៅឈរក្បែរទ្វារបន្ទប់ហៅព្រះនាងឲ្យយាងចេញមក។

"មានរឿងអ្វីកើតឡើង អ្នក?" ព្រះនាងចេញមកសួរ។

"បពិត្រព្រះទេវី ព្រះរាជារបស់យើង សម្លាប់ស្ដេចវិទេហៈ និងសេនាប្រមុខមហោសថបានហើយ ទ្រង់នឹងសោយរាជ្យតែមួយព្រះអង្គឯង ក្នុងសកលជម្ពូទ្វីបមានស្ដេច ១០១ អង្គ ចោមរោមជាបរិវារ ឥឡូវនេះ ព្រះអង្គកំពុងគង់សោយទឹកជយបាន ក្នុងពិធីជប់លៀងដ៏ធំ។ ក្នុងថ្ងៃនេះព្រះអង្គដ៏ទ្រង់យស បានបញ្ជាឲ្យពួកទូលបង្គំមកយាងព្រះនាង ព្រមទាំងព្រះរាជសុណិសា បុត្រាបុត្រី ទៅចូលរួមក្នុងពិធីជប់លៀងនោះ" ពួកទាហានក្រាបទូល។

ក្សត្រិយ៍ទាំង ៤ អង្គ ជឿពាក្យរបស់ពួកទាហាននោះ ដោយនឹកស្មានថាជាទាហានរបស់ស្ដេចចូឡនី ក៏បានយាងចុះអំពីប្រាសាទ ពេលទៅដល់ជើងជណ្ដើរ ស្រាប់តែទាហានទាំងនោះនាំគ្នាចាប់ក្សត្រិយ៍ទាំង ៤ ឲ្យចូលទៅក្នុងឧមង្គច្រើរជើង។ ក្សត្រិយ៍ទាំង ៤ អង្គមានព្រះបន្ទូលសួរថា៖

"យើងរស់នៅកន្លែងនេះជាយូរណាស់មកហើយ មិនធ្លាប់ចុះដើរតាមមហាវិថីក្នុងវូងដីបែបនេះសោះ"។

ពួកទាហានទាំងនោះក្រាបទូលថា៖

"បពិត្រព្រះទេវី មហាវិថីនេះ មនុស្សមិនអាចដើរបានគ្រប់ពេលតាមចិត្តចង់នោះទេ ព្រោះជាវិថីមង្គល តែដោយថ្ងៃនេះជាថ្ងៃមង្គល ទើបព្រះរាជាបង្គាប់ឲ្យពួកទូលបង្គំនាំព្រះទេវីយាងតាមផ្លូវនេះ" ។

ក្សត្រិយ៍ទាំង ៤ អង្គនោះជឿសម្តីរបស់ពួកទាហានទាំងនោះដោយឥតសង្ស័យអ្វីឡើយ។ លំដាប់នោះ ទាហានមួយពួកនាំក្សត្រិយ៍ទាំង ៤ អង្គបន្តដំណើរទៅមុខ។ រីឯមួយពួកទៀត ត្រឡប់ក្រោយទៅបើកទ្វារឃ្លាំងមាសប្រាក់រតនៈកែវកង ក្នុងព្រះរាជនិវេសន៍នៃស្តេចចូឡនី ប្បាមយកតែរតនៈណាថ្លៃៗ តាមតម្រូវការ ហើយក៏បកក្រោយមកវិញ។ ចំណែកក្សត្រិយ៍ ៤ អង្គ បានទៅដល់មហាឧមង្គខាងមុខ បានមើលឃើញមហាឧមង្គដែលរចនាវិចិត្រដោយក្បាច់ដ៏ស្អាត ប្រៀបបានទៅនឹងទេវសភា មួយអង្គៗសម្គាល់ថា "គេរៀបចំត្រៀមដើម្បីព្រះមហាក្សត្រ"។ គ្រានោះ ពួកទាហាននាំក្សត្រិយ៍ទាំង ៤ អង្គ ទៅកាន់កន្លែងជិតទន្លេគង្គា ឲ្យប្រថាប់គង់ក្នុងបន្ទប់មួយដែលតុបតែងយ៉ាង

ស្អាតបាតនៅខាងក្នុងឧម្មង្គហ្នឹងដែរ។ ពួកទាហានឈរជើងល្បាតយាមមើលយាមរក្សាការពារយ៉ាងហ្មត់ចត់។ ទាហានមួយពួកទៀត នាំគ្នាទៅជម្រាបលោកសេនាប្រមុខមហោសថ ឲ្យជ្រាបអំពីកិច្ចការនាំខ្លួនក្សត្រិយ៍ទាំង ៤ អង្គនោះមកបានសម្រេចហើយ។ លោកសេនាប្រមុខមហោសថស្ដាប់សេចក្ដីរាយការណ៍របស់ពួកទាហានភ្លាម នឹកសប្បាយក្នុងចិត្តថា "គោលបំណងរបស់អញ ជិតបានសម្រេចហើយ" រួចក៏ធ្វើដំណើរទៅថ្វាយបង្គំគាល់ព្រះរាជា។

## ព្រះបាទវិទេហៈដឹងខ្លួនថាជាប់អន្ទាក់គេ

ចំណែកព្រះបាទវិទេហៈវិញ ហេតុតែព្រះអង្គមានព្រះទ័យប្រតិព័ទ្ធខ្លាំងជាមួយនឹងព្រះរាជធីតាបញ្ចាលចន្ទី ម៉្លោះហើយ ក៏ចេះតែរំពឹងថា "ស្ដេចចូឡនីនឹងបញ្ជូនរាជធីតាដល់អញក្នុងកាលឥឡូវនេះ ស្ដេចចូឡនីនឹងបញ្ជូនរាជធីតាដល់អញ ក្នុងកាលឥឡូវនេះ" គង់ពុំសុខ ក្រោកអំពីរាជបល្ល័ង្ក ចោលព្រះនេត្រទតមើលទៅតាមបង្អួច ឃើញគប់ភ្លើងរាប់សែនក្លីប្រាលរន្ទាលពេញទីក្រុង និងមានពួកទាហានណែនណាន់តាន់តាប់ ឡោមព័ទ្ធជុំជិតអស់។ ទតឃើញដូច្នោះ ព្រះអង្គទ្រង់កើត

ពិកាល់[១៧៦] ថា តើមានរឿងអ្វីកើតឡើង ទើបបានប្រឹក្សាជាមួយនឹងបណ្ឌិតទាំង ៤ ថា៖

"ពលដំរី ពលសេះ ពលរថ ពលថ្មើរជើង និងសេនាកាន់ខែលឈរនៅត្រៀបត្រា និងមានគប់ភ្លើងឆេះសន្ធោសន្ធៅ។ នៃបណ្ឌិតស្តេចចូឡនីទ្រង់ធ្វើពីធីស្វាគមន៍យើង ឬក៏ត្រៀមធ្វើសង្គ្រាមជាមួយយើង?"

អាចារ្យសេនកៈឮដូច្នោះ ក្រាបទូលថា៖

"កុំព្រួយបារម្ភ[១៧៧]អ្វីឡើយ មហាបពិត្រ គប់ភ្លើងភ្លឺប្រាលរន្ទាលច្រើនក្រៃលែងដូច្នោះ ទំនងជាព្រះបាទចូឡនីព្រហ្មទត្តកំពុងតែនាំយកព្រះរាជធីតាមកដើម្បីថ្វាយដល់ព្រះអង្គហើយ"។

បុក្កុសៈទូលថា៖

"ប្រាកដជាគេឈរយាមរក្សាការពារ ដើម្បីធ្វើកិច្ចស្វាគមន៍ចំពោះការយាងមកដល់របស់ព្រះអង្គហើយ ក្រាបទូល"។

---

[១៧៦] ពិកាល់ (កិ.) ចាប់មន្ទិល, ភ្នកគិតព្រួយដោយចាប់មន្ទិល ឧ. ពិកាល់ក្នុងចិត្ត។ ប្រើជា ន. ក៏បាន ឧ.មានពិកាល់, កើតពិកាល់។

[១៧៧] បារម្ភ (កិ.) ដំណើរនឹកថប់ឬនឹកព្រួយជាមុន។

សរុបមកថា អាចារ្យទាំងនោះ ចេះតែនិយាយតាមតែចិត្តនឹកឃើញរបស់ខ្លួនៗ ប៉ុន្តែព្រះរាជាឮសម្រែករបស់ពួកគេ ស្រែកថា "ទាហានចូរឈរយាមនៅតាមគោលដៅ ដែលបានកំណត់ដាក់ឲ្យរៀងៗខ្លួន ចូរពួកឯងកុំធ្វេសប្រហែសឲ្យសោះ" ឮដូច្នោះ ព្រះអង្គក្រឡេកមើលទៅខាងក្រៅកំពែងនគរ ឃើញពួកកងទ័ពសុទ្ធសឹងតែប្រដាប់ដោយអាវុធគ្រប់ប្រភេទ មានដាវ លំពែង ធ្នូ ស្នាទិងខែលគ្រប់ដៃ ព្រះអង្គក៏ខ្លាចមរណៈ ទ្រង់មានរាជបំណងស្ដាប់យោបល់របស់លោកសេនាប្រមុខមហោសថវិញ ទើបមានព្រះរាជឱង្ការសួរថា៖

"ពលដំរី ពលសេះ ពលរថ ពលថ្មើរជើង និងសេនាកាន់ខែលឈរនៅត្រៀបត្រា គប់ភ្លើងឆេះសន្ធោសន្ធៅ នែបណ្ឌិត តើអ្នកគិតដូចម្ដេច? តើពួកសេនាទាំងនោះ នឹងធ្វើអ្វីចំពោះពួកយើង?"

**មហោសថពង្រាង[១៧៨]ស្ដេច**

ឮព្រះរាជឱង្ការដូច្នោះ មហោសថគិតថា “អញនឹងបំភ័យស្ដេចល្ងង់អន្ធពាលនេះឲ្យស្លុតព្រះទ័យបន្តិចមើល ហើយអញនឹងបង្ហាញកម្លាំងបញ្ញារបស់អញលួងលោមព្រះអង្គ ក្នុងកាលជាខាងក្រោយ” គិតរួច មហោសថ បានក្រាបទូលព្រះរាជាថា៖

“បពិត្រមហារាជ ស្ដេចចូឡនីលើកទ័ពជាច្រើនមកធ្វើសង្គ្រាមជាមួយព្រះអង្គ ហ៊ុំព័ទ្ធព្រះអង្គទុកធ្វើគុតក្នុងពេលព្រឹកស្អែកនេះ”។

ឮសម្ដីមហោសថថាដូច្នោះ ទាំងស្ដេច ទាំងមន្ត្រី និងអ្នកនៅជុំវិញនោះ មានសេចក្ដីខ្លាចចំពោះមរណៈទាំងអស់គ្នា។ ព្រះបាទវិទេហរាជស្លុតក ខ្សោះទឹកមាត់ ក្ដៅព្រះវរកាយ[១៧៩] ទ្រង់ខ្លាចមរណៈ បានខ្សឹកខ្សួលយ៉ាងនេះថា៖

---

[១៧៨] ពង្រាង (កិ.) ធ្វើឲ្យរាងចាល, ឲ្យរអា លែងចង់ លែងត្រូវការទៀត។ កុំប្រើពាក្យ ពង្រាងច្បាប់ ពង្រាងសេចក្ដី ព្រោះពាក្យនេះមិនមែនក្លាយពីពាក្យ ព្រាង ទេ។ ឧទាហរណ៍ ពង្រីក មកពីពាក្យ រីក មានបុព្វបទទម្រង់ ពសព ចុះ ពង់ ទៅជាពង្រីក មិនមែនមកពីពាក្យ ព្រីក ដែលជាគុណនាមនោះទេ។ ពង្រឹង មកពីពាក្យ រឹង។ ពង្រត់ មកពីពាក្យ រត់។ ត្រូវប្រើ សេចក្ដីព្រាង សេចក្ដីព្រាងច្បាប់វិញ។
[១៧៩] វណ្ណោ កណ្ឋោ សុស្សិ មុខេ ខេឡោ បរិធិជ្ជិ, សរីរេ ទាហោ ឧប្បជ្ជិ។

*"នៃមហោសថបណ្ឌិតបាសម្លាញ់ ហឫទ័យរបស់យើងញាប់ញ័រ រន្ធត់ កក្រើកឃ្លេងឃ្លោងបីដូចត្រូវខ្យល់ព្យុះបក់ ទាំងមាត់របស់យើងក៏ស្ងោះស្ងួត យើងមិនបានសេចក្តីស្ងប់ ដូចជាឈើត្រូវភ្លើងឆេះក្នុងកណ្តាលកម្តៅថ្ងៃៗ ចង្ក្រានរបស់ជាងមាសឆេះតែខាងក្នុង មិនឆេះខាងក្រៅ យ៉ាងណាមិញ ហឫទ័យរបស់យើងក៏ឆេះតែខាងក្នុង មិនឆេះខាងក្រៅ ក៏យ៉ាងនោះដែរ"ៗ*

លោកសេនាប្រមុខមហោសថ បានឮសំឡេងខ្សឹកខ្សួលរបស់ព្រះរាជា ហើយគិតថា "ស្តេចអន្ធពាលនេះមិនព្រមជឿពាក្យរបស់អញដែលប្រាប់ពីថ្ងៃមុនទេ[១៨០] អញនឹងផ្ចាលផ្ចាញ់[១៨១]ព្រះអង្គឲ្យកាន់តែខ្លាំង" គិតរួច លោកសេនាប្រមុខក្រាបទូលព្រះរាជាថា៖

*"បពិត្រក្សត្រ ព្រះអង្គស្រវឹងនុបនុលក្នុងកាម ទើបប្រព្រឹត្តកន្លងការប្រឹក្សាជាមួយនឹងទូលបង្គំ ដែលជាអ្នកឃើញគ្រោះភ័យក្នុងអនាគត ជាអ្នកប្រឹក្សាកំណត់ជាក់លាក់ដោយបញ្ញាៗ ព្រះអង្គបោះបង់ចោលយោបល់របស់ទូលបង្គំ ទៅជឿយោបល់របស់*

---

[១៨០] *អយំ អន្ធពាលោ អញ្ញេសុ ទិវសេសុ មម វចនំ ន អកាសិៗ*

[១៨១] *ផ្ចាញ់ផ្ចាល ឬនឹងប្រើថា ផ្ចាលផ្ចាញ់ ក៏បាន គឺមានន័យតែមួយថា ធ្វើឲ្យចាញ់ឲ្យរាងចាលលែងហ៊ានតទៅទៀត ឬផ្តន្ទាបន្ទាប់បង្អោនឲ្យមានការអៀនអន់រាងចាលៗ*

សេនកៈ ជាដើមវិញ។ ឥឡូវនេះសូមឲ្យបណ្ឌិតទាំង ៤ នាក់ មាន សេនកៈជាដើម ដែលជាអ្នកមានប្រាជ្ញា រក្សាព្រះអង្គចុះ។ ទូលបង្គំ នឹងរង់ចាំមើលកម្លាំងពួកគេវិញ។ បពិត្រព្រះរាជា ព្រះអង្គមិនធ្វើ តាមយោបល់របស់ទូលបង្គំជាឧត្តមមន្ត្រី[១៨២] ដែលជាអ្នកប្រាជ្ញា សេចក្ដីចម្រើន និងស្វែងរកប្រយោជន៍ដល់ប្រទេសជាតិ ទ្រង់ត្រេកអរដោយបីតិដ៏សៅហ្មងរបស់ព្រះអង្គ ដូចម្រឹគមកជាប់អន្ទាក់ ព្រោះតែល្មោភចំណី ព្រះអង្គមិនជឿពាក្យរបស់ទូលបង្គំ ទ្រង់យាងមកដោយហេតុតែល្មោភកិលេសថា ខ្លួនព្រះអង្គនឹងបាននៃបនិត្យ[១៨៣]នឹងព្រះរាជធីតាបញ្ចាលចន្ទី។ ឥឡូវនេះ ព្រះអង្គធ្លាក់ខ្លួនបីដូចជាម្រឹគជាប់ក្នុងអន្ទាក់គេទៅហើយ។ ទូលបង្គំ បានទូលរួចហើយថា ត្រីជាសត្វល្មោភក្នុងនុយស្រស់ លេបនូវផ្លែសន្ទូចមានផ្លៀន មិនដឹងសេចក្ដីស្លាប់របស់ខ្លួនយ៉ាងណា បពិត្រព្រះរាជា ព្រះអង្គជាអ្នកល្មោភក្នុងកាម ចង់បានធីតារបស់ស្ដេចចូឡនី ទ្រង់មិនជ្រាបនូវមរណៈរបស់ព្រះអង្គ ដូចត្រីយ៉ាងនោះដែរ។ បើស្ដេចយាងទៅក្រុងបញ្ចាល ទ្រង់មុខតែស្លាប់ គ្រោះភ័យដ៏ធំនឹងកើតដល់ព្រះអង្គ ដូចគ្រោះ

---

[១៨២] ឧត្តមអមច្ចស្ស វចនំ អកត្វា។

[១៨៣] នៃបនិត្យ (កិ.) អែបជិត, ផ្ដេកផ្ដិត, កៀកឱប, អែបជិតមិនដាច់។

ភ័យកើតដល់ម្រឹគ ដែលដើរទៅតាមផ្លូវក្បែរស្រុក។ បពិត្រព្រះជនិន្ទ មិនតែប៉ុណ្ណោះ ទូលបង្គំ សូមនាំឧទាហរណ៍មួយទៀត បុរសមានសភាពមិនថ្លៃថ្នូរ ដូចសត្វពស់នៅក្នុងថ្នក់ វាគប្បីចឹកយើងបាន បុរសមានប្រាជ្ញាមិនគប្បីធ្វើនូវមេត្រីភាពជាមួយនឹងបុរសនោះទេ ព្រោះថាការសេពគប់ជាមួយនឹងបុរសអាក្រក់ រមែងនាំមកនូវសេចក្ដីទុក្ខដោយពិត។ ព្រាហ្មណ៍ប្រាកដដូចកេវដ្ដព្រាហ្មណ៍ គឺគេមានជាតិជាមនុស្សអសប្បុរស ជាមនុស្សមិនចេះខ្មាស។ បពិត្រព្រះជនិន្ទ បុរសជាបណ្ឌិតស្គាល់បុគ្គលណាថា អ្នកនេះមានសីល មានការចេះដឹងច្រើន ដូច្នេះបុរសជាបណ្ឌិតនោះ គួរធ្វើនូវមេត្រីភាពជាមួយនឹងបុគ្គលនោះ ព្រោះថាការសេពគប់សប្បុរសទាំងឡាយ រមែងនាំមកនូវសេចក្ដីសុខពិត។ ព្រះអង្គមិនធ្វើមិត្តធម៌ជាមួយនឹងបុរស ជាបណ្ឌិតបែបនោះទេ ព្រះអង្គបែរជាធ្វើមិត្តធម៌ជាមួយនឹងកេវដ្ដព្រាហ្មណ៍ ជឿពាក្យសម្ដីរបស់គេ។ ការសេពគប់ជាមួយនឹងមនុស្សបែបនោះ អស់ពេលតែមួយគ្រាក៏ដោយ មុខតែជួបទុក្ខធំក្នុងលោកនេះផង ក្នុងលោកខាងមុខផង។ ផ្ទុយទៅវិញ បើព្រះអង្គបានធ្វើមិត្តធម៌ជាមួយនឹងបុរសជាបណ្ឌិត ប្រាកដជាបានសុខយ៉ាងទៀងទាត់ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង”។

បន្ទាប់មក លោកសេនាប្រមុខមហោសថផ្ចាញ់ផ្ចាលព្រះរាជា កាន់តែខ្លាំងលើសមុនដោយគិតថា "ស្ដេចអង្គនេះនឹងធ្វើបែបនេះទៀត" ហើយលោកបានរំលឹក ពីព្រះរាជឱង្ការស្ដេចស្ដីតិះដៀលមើលងាយខ្ញុំកាលពីពេលមុនថា៖

"បពិត្រព្រះរាជា ព្រះអង្គជាមនុស្សល្ងង់ បានពោលពាក្យបន្ទុះបន្អាប់មើលងាយខ្ញុំព្រះអង្គដែលជាអ្នកមានប្រាជ្ញាដ៏ឧត្ដមថា ខ្ញុំព្រះអង្គជាអ្នកចម្រើនវ័យដោយចុងនង្គ័ល ធ្វើម្ដេចនឹងដឹងសេចក្ដីចម្រើនដូចអ្នកដទៃ ទាំងទ្រង់បញ្ជាថា អ្នកទាំងឡាយចូរចាប់មហោសថនេះត្រង់ក ហើយនិរទេសឲ្យផុតពីដែនដីអញ ព្រោះវាហ៊ាននិយាយឲ្យអញអន្តរាយមិនបានស្រីកែវ"។

លុះលោកនិយាយរំលឹកដោយពាក្យប៉ុណ្ណោះហើយ លោកសេនាប្រមុខនិយាយផ្ចាញ់យ៉ាងនេះទៀតថា៖

"បពិត្រមហារាជ ទូលបង្គំជាខ្ញុំជាកូនអ្នកស្រែចម្ការ នឹងចេះដឹងអ្វីឲ្យដូចបណ្ឌិតផ្សេងៗ មានសេនកៈជាដើម ដែលពួកគេមានចំណេះដឹង អាចធ្វើប្រយោជន៍យ៉ាងច្រើនសម្រាប់ព្រះអង្គ។ ការងារនុ៎ះ ហួសវិស័យពីចំណេះរបស់ទូលបង្គំ[១៨៤] ចំណេះ

---

[១៨៤] អគោចរោ ឯស មយ្ហំ។

របស់ទូលបង្គំជាខ្ញុំ បានតែខាងការងារស្រេចម្ការ។ ដំណោះស្រាយនេះ សេនកបណ្ឌិតជាដើម ពួកគេចេះដឹងច្បាស់ណាស់។ ក្នុងថ្ងៃនេះ ទាហាន ១៨ អក្ខោភិនី កំពុងតែឡោមព័ទ្ធយ៉ាងកកកុញ មានតែសេនកៈជាដើមទេជាទីពឹង អាចជួយរកដំណោះស្រាយថ្វាយព្រះអង្គបាន។ ចំណែកទូលបង្គំវិញ សូមព្រះអង្គចេញព្រះរាជបញ្ជា ឲ្យគេចាប់កទាញអូសចេញចុះ។ ហេតុអ្វីឥឡូវព្រះអង្គ ទ្រង់សួរទូលបង្គំដូច្នេះវិញអ៊ីចឹង?"

ព្រះរាជា ទ្រង់ឮពាក្យលោកសេនាប្រមុខមហោសថដូច្នោះ ទ្រង់ព្រះតម្រិះថា "លោកបណ្ឌិតនិយាយរំលឹកកំហុសសម្ដីអញទេតើ គេប្រាកដជាដឹងនូវគ្រោះភ័យក្នុងអនាគតនេះ តាំងពីដើមមកម៉្លេះ ហេតុនោះហើយ បានជាគេខំផ្ចាញ់ផ្ចាលអញខ្លាំងៗ។ មួយរយៈកាលនេះ មហោសថមិនទៅទំនេរទេ គេរវល់មមាញឹកណាស់។ មហោសថនេះ ជាក់ជាបានធ្វើផែនការការពារសុវត្ថិភាពសម្រាប់អញ ប្រាកដណាស់" ទើបទ្រង់ត្រាស់ នឹងមហោសថដូច្នេះថា៖

"ម្នាលមហោសថ បណ្ឌិតទាំងឡាយ រមែងមិនចាក់ដោតអ្នកដទៃ ដោយទោសដែលកន្លងទៅហើយទេ អ្នកចាក់ដោតយើង បីដូចគេយកជន្ទញចាក់សេះ ដែលចងទុកហើយធ្វើអ្វី ប្រសិនបើអ្នក

មានមធ្យោបាយរំដោះខ្លួនសម្រាប់យើង ឬឃើញសេចក្ដីក្សេម សម្រាប់យើង អ្នកចូរពន្យល់យើងពីមធ្យោបាយសុវត្ថិភាព[១៩៥] នោះ ដើម្បីឲ្យយើងបានដកដង្ហើមធូរស្រាលផង អ្នកចាំបាច់ចាក់ដោតយើង ដោយការលើកយកទោសដែលកន្លងហួសទៅហើយ ធ្វើអ្វី? ដ្បិតថា ក្រៅពីអ្នក យើងពុំមានទីពឹងដទៃឡើយ"។

គ្រានោះ មហោសថគិតថា "ស្ដេចអង្គនេះ ចំជាល្ងង់អន្ធពាលខ្លាំងណាស់ មិនដឹងសេចក្ដីវិសេសរបស់បុរសទេ អញធ្វើឲ្យព្រះអង្គលំបាកបន្តិចសិន ចាំធ្វើជាទីពឹងរបស់ព្រះអង្គ ក្នុងកាលជាខាងក្រោយ" ទើបក្រាបទូលស្ដេចថា៖

"មនុស្សប្រព្រឹត្តអំពើធ្វើឲ្យកន្លងហួសទៅហើយ អំពើនោះ ជាអំពើគេកែបានដោយលំបាក សម្រួលវិញបានដោយលំបាក ខ្ញុំព្រះអង្គមិនអាចរំដោះព្រះអង្គបានទេ។ បពិត្រក្សត្រិយ៍ សូមព្រះអង្គទ្រង់ជ្រាបចុះ សូមឲ្យដំរីទាំងឡាយមានឫទ្ធិ មានយសដែលអាចហោះ ទៅតាមអាកាសបាន នាំស្ដេចយាងទៅចុះ។

[១៩៥] សុវត្ថិ (សួស្ដី) + ភាព (ការមាន) = សុវត្ថិភាព ការមានសួស្ដី, ការប្រកបដោយសេចក្ដីសុខ ឧ. បានត្រឡប់មកដល់ស្រុកវិញដោយសុវត្ថិភាព, ធ្វើដំណើរដោយសុវត្ថិភាព ។ល។

សូមឲ្យសេះទាំងឡាយមានឫទ្ធិ មានយស ដែលអាចហោះទៅតាមអាកាសបាន នាំស្ដេចយាងទៅចុះៗ សូមឲ្យបក្សីទាំងឡាយមានឫទ្ធិ មានយស ដែលអាចហោះហើរទៅតាមអាកាសបាន នាំស្ដេចយាងទៅចុះៗ សូមឲ្យយក្សទាំងឡាយ មានឫទ្ធិ មានយស អាចហោះទៅតាមអាកាសបាន នាំស្ដេចយាងទៅចុះៗ អំពើជារបស់នៃមនុស្សដែលកន្លងហួសទៅហើយ ជាអំពើគេកែបានដោយកម្រ សម្រួលវិញបានដោយកម្រ បពិត្រក្សត្រិយ៍ទូលបង្គំមិនអាចរំដោះព្រះអង្គទៅក្រុងមិថិលាតាមផ្លូវអាកាសបានទេ"ៗ

ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវសម្ដីរបស់សេនាប្រមុខមហោសថដូច្នោះ ទ្រង់គង់ស្ងៀមឈឹងឥតមានព្រះបន្ទូលមួយម៉ាត់ នឹករកតម្រិះអ្វីតបក៏ពុំបានៗ គ្រានោះ សេនកៈបានគិតថា "ឥឡូវនេះ លើកលែងតែមហោសថបណ្ឌិតចេញ ពុំមានអ្វីដទៃណាជាទីពឹងសម្រាប់ ព្រះរាជានិងពួកយើងឡើយ ប៉ុន្តែព្រះរាជាស្ដាប់នូវសម្ដីមហោសថហើយ ទ្រង់មានហឫទ័យភ័យខ្លាចចំពោះសេចក្ដីស្លាប់ណាស់ ទើបរកហាព្រះឱស្ឋបន្ទូលអ្វីទៅមិនរួច អញនឹងអង្វរមហោសថដោយខ្លួនឯងមើល" គិតដូច្នេះហើយ អាចារ្យសេនកៈ និយាយថា៖

"បុរសដែលហែលក្នុងមហាសមុទ្រឥតឃើញត្រើយ កាលបើបានដល់ទីពំនាក់នៅកន្លែងណាហើយ គេក៏បានសេចក្ដីសុខក្នុងកន្លែងនោះ យ៉ាងណាមិញ បពិត្រមហោសថ អ្នកជាទីពឹងរបស់ពួកយើងនិងព្រះរាជា ក៏យ៉ាងនោះដែរ ព្រោះអ្នកជាបុគ្គលប្រសើរជាងពួកយើងនិងពួកមន្ត្រី សូមអ្នករំដោះពួកយើងឲ្យផុតទុក្ខផង"។

គ្រានោះ លោកសេនាប្រមុខមហោសថ បានផ្ចាញ់សេនកៈដោយពាក្យថា៖

"អំពើជារបស់នៃមនុស្សដែលកន្លងហួសទៅហើយ ជាអំពើគេកែបានដោយកម្រ សម្រួលវិញបានដោយកម្រ ខ្ញុំមិនអាចរំដោះព្រះរាជាបានទេ ចំណែកអ្នកចូររំដោះព្រះអង្គទៅក្រុងមិថិលាចុះនៃសេនកៈ អ្នកចូរដឹងដូច្នេះចុះ"។

ចំណែកព្រះរាជាវិញ កាលរកអ្វីមកនិយាយឲ្យមហោសថជឿមិនបាន ទ្រង់គិតតែព្រួយបារម្ភចំពោះសេចក្ដីស្លាប់តែម្យ៉ាង រកនិយាយអ្វីជាមួយនឹងមហោសថក៏ពុំរួច ទ្រង់ងាកទៅសួរសេនកៈនោះថា "គ្រប់កាលៈទេសៈទាំងអស់ សេនកៈគង់ចេះដឹងពីឧបាយខ្លះ យើងសូមសួរអ្នកមើល" រួចទ្រង់មានព្រះរាជបន្ទូលសួរថា៖

"អ្នកចូរស្ដាប់ពាក្យរបស់យើង អ្នកឃើញភ័យធំនុ៎ះស្រាប់ហើយ ម្នាលអាចារ្យសេនកៈ ឥឡូវនេះអញសួរអ្នក តើអ្នកអាចរកវិធីសាស្ត្រដូចម្ដេច ដើម្បីរំដោះខ្លួនចេញពីស្ថានភាពបែបនេះ?"

ពួដូច្នោះ អាចារ្យសេនកៈគិតថា "ព្រះរាជាសួរឧបាយចំពោះខ្លួនអញហើយ ទោះល្អក៏ដោយ មិនល្អក៏ដោយ អញនឹងនិយាយឧបាយឲ្យបានមួយទៅចុះ" រួចបានបញ្ចេញយោបល់ថា៖

"ពួកយើងគួរដុតភ្លើងត្រង់ទ្វារ ឬកាន់កាំបិតកាប់សម្លាប់គ្នាទៅវិញទៅមក ដើម្បីឲ្យឆាប់ស្លាប់ កុំឲ្យស្ដេចចូឡនីសម្លាប់ពួកយើងទាន់ នាំឲ្យលំបាកយូរឡើយ"។

ពួដូច្នោះ ព្រះរាជាមិនសប្បាយព្រះរាជហឫទ័យសោះ ទ្រង់តបថា៖

"ចូរលោកធ្វើជើងថ្ករ[១៨៦] សម្រាប់កូនប្រពន្ធរបស់លោក និងខ្លួនលោកចុះ"

រួចទ្រង់ត្រាស់សួរអាចារ្យបុក្កុសៈជាដើមៗ អាចារ្យទាំង ៣ នាក់នោះបានទូលថ្វាយដំណោះស្រាយដ៏ល្ងង់ខ្លៅរៀងៗខ្លួនៗ

[១៨៦] ជើងថ្ករ (ន. បា.សំ.ថា ចិតក, ចិត្យា) បង្គោល៤បោះអមទប់គ្នារមឈូស ដែលតម្កល់ក្នុងទីធ្វើឈាបនកិច្ច ឧ.បោះជើងថ្ករៗ សូម្បីទីដីនិងឧសដែលរៀបចំធ្វើឈាបនកិច្ចនោះ ក៏ហៅថា ជើងថ្ករដែរ, ឧ. លត់ជើងថ្ករៗ

បុក្កុសៈថា៖

“ពួកយើងគួរផឹកថ្នាំពិសសម្លាប់ខ្លួន ដើម្បីឲ្យឆាប់ស្លាប់ កុំឲ្យស្តេចចូឡនីសម្លាប់ពួកយើងទាន់ នាំឲ្យលំបាកយូរឡើយ”។

ស្តេចត្រាស់សួរកាមិន្ទៈម្តងថា៖

“នែកាមិន្ទៈ អ្នកចូរស្តាប់ពាក្យរបស់យើង អ្នកឃើញភ័យជំនុំៈស្រាប់ហើយ ឥឡូវនេះយើងសួរ តើអ្នករកវិធីសាស្ត្រដូចម្តេចដើម្បីដោះស្រាយក្នុងស្ថានភាពបែបនេះ?”

កាមិន្ទៈទូលថា៖

“ពួកយើងត្រូវយកខ្សែចងរឹតកឲ្យស្លាប់ ឬលោតទៅក្នុងអណ្តូងឲ្យស្លាប់ក៏បាន កុំឲ្យស្តេចចូឡនីសម្លាប់ពួកយើងទាន់ នាំឲ្យលំបាកយូរឡើយ”។

ស្តេចត្រាស់សួរទេវិន្ទៈម្តងថា៖

“នែទេវិន្ទៈ អ្នកចូរស្តាប់ពាក្យរបស់យើង អ្នកឃើញភ័យជំនុំៈស្រាប់ហើយ ឥឡូវនេះយើងសួរ តើអ្នករកវិធីសាស្ត្រដូចម្តេចដើម្បីដោះស្រាយក្នុងស្ថានភាពបែបនេះ?”

ទេវិន្ទៈទូលថា៖

"ពួកយើងបិទទ្វារដុតភ្លើង ហើយកាន់កាំបិតកាប់សម្លាប់គ្នាទៅវិញទៅមក យើងនឹងស្លាប់យ៉ាងឆាប់ ថាបើមហោសថមិនអាចនឹងរំដោះពួកយើងឲ្យរួចដោយងាយទេ"ៗ

ប្រការមួយវិញទៀត បណ្ដាអាចារ្យ ៤ នាក់នោះ អាចារ្យទេវិន្ទៈគិតថា "ព្រះរាជាអង្គនេះកំពុងធ្វើអ្វី ភ្លើងមានស្រាប់ហើយ ម្ដេចឡើយទ្រង់បែរជាផ្លុំ អំពិលអំពែក[១៨៧]បន្ដាត់ភ្លើងទៅវិញ? លើកលែងតែមហោសថបណ្ឌិតចេញ ពុំមានបុគ្គលដទៃណាមានសមត្ថភាពអាចការពារសុវត្ថិភាពរបស់ព្រះអង្គបានទេ នៅក្នុងទីនេះៗ ស្ដេចអង្គនេះមិនសួរមហោសថទេ សួរតែពួកអញ ពួកអញចេះដឹងអ្វីទៅ" កាលរកឧបាយដទៃនិយាយមិនឃើញ ក៏និយាយ តាមពាក្យអាចារ្យសេនកៈពីរឃ្លាខាងដើម និងពីរឃ្លាខាងចុងថា៖

"បពិត្រមហារាជ ពួកយើងទាំងអស់គ្នា សុទ្ធតែបានអង្វរលោកសេនាប្រមុខមហោសថបណ្ឌិតរួចហើយ ប៉ុន្ដែមហោសថមិនព្រមទទួលយកពាក្យអង្វររបស់ពួកយើងឡើយ គាត់នៅតែ

---

[១៨៧] អំពិលអំពែក (ន.) សុខុមសត្វពួកជន្លេវ មានពន្លឺព្រាកៗ នៅក្រោមពោះត្រង់ចុងកន្ទុយ ភ្លឺតែក្នុងវេលាយប់ងងឹត, ឈ្មោលមានស្លាបហើរបាន ញីឥតស្លាប, ជាពួកសត្វរត្តិចរៗ

មិនអាចរំដោះពួកយើងឲ្យមានសុវត្ថិភាពបានដោយស្រួលទេ។ កាលបើដូច្នេះ មានតែពួកយើងធ្វើតាមយោបល់របស់លោកសេនកៈចុះ ក្រាបទូល"។

ឮយោបល់នោះ ព្រះរាជានឹកឃើញនូវកំហុសទ្រង់ដែលស្តីថាឲ្យសេនាប្រមុខមហោសថ ហើយមិនហ៊ាននិយាយអ្វីជាមួយនឹងលោកសេនាប្រមុខមហោសថទាល់តែសោះ។ កាលមហោសថកំពុងតែផ្ចង់ចិត្តស្តាប់ ព្រះរាជាទ្រង់ខ្សឹកខ្សួលថា៖

"បុគ្គលស្វែងរកខ្លឹមរបស់ដើមចេក រមែងមិនបាន យ៉ាងណាមិញ យើងស្វែងរកឧបាយជាគ្រឿងរួចចាកទុក្ខក៏មិនបាន ប្រស្នាន៎ុះក៏យ៉ាងនោះដែរ។ បុគ្គលស្វែងរកខ្លឹមនៃដើមរកាមិនបាន យ៉ាងណាមិញ យើងស្វែងរកឧបាយជាគ្រឿងរួចចាកទុក្ខក៏មិនបាន ប្រស្នាន៎ុះក៏យ៉ាងនោះដែរ។ ការនៅនៃដំរីទាំងឡាយក្នុងទីមិនមានទឹក ឈ្មោះថានៅក្នុងទីមិនសមគួរនឹងនៅ យ៉ាងណាមិញ កាលបើយើងនៅក្នុងទីជិតនៃពួកមនុស្សអាក្រក់ល្ងង់ខ្លៅ មិនចេះ មិនដឹង ឈ្មោះថា នៅក្នុងទីមិនគួរនឹងនៅ ក៏ដូច្នោះដែរ។ ហឫទ័យរបស់យើងមិនត្រជាក់ ញ័ររន្ធត់ ទាំងមាត់របស់យើងក៏សោះស្ងួត ដូចឈើត្រូវភ្លើងឆេះក្នុងកណ្តាលកម្តៅថ្ងៃ។ ចង្ក្រានរបស់ជាង

មាសឆេះតែខាងក្នុង មិនឆេះខាងក្រៅយ៉ាងណាមិញ ហឫទ័យរបស់យើងឆេះតែខាងក្នុង មិនឆេះខាងក្រៅ ក៏យ៉ាងនោះដែរ"។

**មហោសថជួយរំដោះព្រះរាជានិងពួកមន្ត្រីចេញពីសត្រូវ**

ក្នុងវេលានោះ លោកសេនាប្រមុខមហោសថ ជាអ្នកមានប្រាជ្ញា ជាអ្នកឃើញនូវប្រយោជន៍គ្រប់កាលទាំងពួង បានឮព្រះរាជឱង្ការ លាយឡំដោយអាការៈខ្សឹកខ្សួលដូច្នោះ លោកគិតថា "ព្រះរាជាអង្គនេះលំបាកព្រះទ័យខ្លាំងមែនទែនហើយ ប្រសិនបើអញមិនលួងលោមព្រះអង្គទេ ព្រះអង្គនឹងបែកព្រះឱរាក្សយ៍ព្រះជន្មពុំខាន" គិតដូច្នេះហើយក៏ក្រាបបង្គំទូលលួងលោមព្រះរាជាវិញថា៖

"បពិត្រមហារាជ សូមព្រះអង្គកុំព្រួយព្រះទ័យខ្លាំពេក ទូលបង្គំនឹងជួយរំដោះព្រះអង្គ ដូចគេរំដោះព្រះចន្ទត្រូវរាហូចាប់។ ទូលបង្គំនឹងជួយរំដោះព្រះអង្គ ដូចគេរំដោះព្រះអាទិត្យត្រូវរាហូចាប់។ ទូលបង្គំនឹងជួយរំដោះព្រះអង្គ ដូចគេរំដោះដំរីផុងក្នុងភក់។ ទូលបង្គំនឹងជួយរំដោះព្រះអង្គ ដូចគេរំដោះពស់ដែលជាប់នៅក្នុងកំប្រោង។ ទូលបង្គំនឹងជួយរំដោះព្រះអង្គ ដូចគេរំដោះបក្សីដែលជាប់នៅក្នុងទ្រុង។ ទូលបង្គំនឹងជួយរំដោះព្រះអង្គ ដូចគេរំដោះត្រីទាំងឡាយ ដែលជាប់នៅក្នុងសំណាញ់។ ទូលបង្គំនឹងជួយរំដោះ

ព្រះអង្គ ព្រមទាំងរេហ៍ពល និងពាហនៈទាំងអស់ឲ្យចេញផុតពីគ្រោះថ្នាក់។ បពិត្រមហារាជ សូមព្រះអង្គកុំព្រួយព្រះទ័យតក់ស្លុតពេកឡើយ ទូលបង្គំនឹងដេញស្តេចចូឡនីឲ្យរត់ បីដូចគេដេញក្អែកនិងខ្វែងដោយគប់ដុំដី។ បុគ្គលណាមិនជួយរំដោះព្រះអង្គដែលកំពុងតែបិតក្នុងសេចក្តីស្លាប់បែបនេះ តើប្រាជ្ញារបស់បុគ្គលនោះ នឹងមានប្រយោជន៍អ្វី? ឬមន្ត្រីបែបនោះ នឹងមានប្រយោជន៍អ្វី?"

ព្រះបាទវិទេហៈ ទ្រង់ព្រះសណ្តាប់នូវពាក្យលោកសេនាប្រមុខហើយ ទ្រង់បានដកដង្ហើមធូរស្រាល ដោយទ្រង់ព្រះតម្រិះថា "ឥឡូវនេះអញលែងស្លាប់ហើយ"។ ចំណែកពួកនាហ្មឺនសព្វមុខមន្ត្រីទាំងអស់ និងជននៅជុំវិញនោះ កាលបានឮលោកសេនាប្រមុខមហោសថបន្លឺសីហនាទ យ៉ាងអង់អាចដូច្នេះ ម្នាក់ៗត្រេកអរខ្លាំងណាស់។ ខណៈនោះសេនកៈសួរលោកសេនាប្រមុខថា "បពិត្រមហោសថ ចុះលោកនឹងនាំយើងទាំងអស់គ្នាឲ្យចេញពីកណ្តាប់ដៃសត្រូវបាន ដោយកលឧបាយដូចម្តេច?"

មហោសថប្រាប់ថា "ខ្ញុំនឹងយាងព្រះអង្គ និងអ្នកទាំងឡាយទៅតាមឧម្មង្គក្នុងដី ដែលបានជីកនិងតុបតែងយ៉ាងស្អាតត្រៀមរួចជាស្រេច

សូមពួកលោកអញ្ជើញរៀបចំចេញដំណើរឥឡូវនេះចុះ”។ លោកសេនាប្រមុខមហោសថ បានចេញបញ្ជាឲ្យកងទ័ពបើកទ្វារឧម្មង្គ ដោយមានប្រសាសន៍ដូច្នេះ៖

“នែទាហានទាំងឡាយ អ្នកទាំងឡាយចូរក្រោកឡើង ហើយទៅបើកគន្លឹះយន្ត យានព្រះរាជារបស់យើង ព្រមទាំងពួកមន្ត្រីចេញដំណើរតាមឧម្មង្គឥឡូវនេះ”។

ទាហានទាំងឡាយទទួលបញ្ជាលោកសេនាប្រមុខហើយ នាំគ្នាបើកទ្វារឧម្មង្គនិងគន្លឹះទ្វារយន្ត។ ពន្លឺថ្ងៃបានបាញ់ចូលទៅក្នុងឧម្មង្គទាំងមូល ធ្វើឲ្យមានឱភាសពន្លឺ ភ្លឺរុងរឿង ចិញ្ចែងចិញ្ចាច បីដូចទេវសភានៅឋានត្រៃត្រិង្ស។ ក្រោយពេលដែលបើកទ្វារឧម្មង្គរួចហើយ ទាហានទាំងនោះបានមកជម្រាបលោកសេនាប្រមុខឲ្យជ្រាប។ មហោសថបានទូលថ្វាយព្រះមហាក្សត្រថា៖

“បពិត្រព្រះសម្មតិទេព ដល់ពេលដែលព្រះអង្គត្រូវយាងចុះចាកប្រាសាទនេះហើយ”។

រំពេចនោះ ព្រះបាទវិទេហរាជទ្រង់ក៏យាងចុះចាកប្រាសាទនោះតាមការទូលយាងរបស់លោកសេនាប្រមុខ។ គ្រានោះ បណ្ឌិតសេនកៈដោះមួកចេញអំពីក្បាល ដោះអាវហើយចងក្បិនយ៉ាងមាំ។

"នៃសេនកៈ លោកធ្វើអ្វីហ្នឹង?" មហោសថសួរ។

"បពិត្របណ្ឌិត បើពួកយើងធ្វើដំណើរទៅតាមឧម្មង្គអ៊ីចឹង ត្រូវតែដោះឈ្នួតក្បាលចង់ក្បិនឲ្យមាំទើបទៅបាន បើពុំដូច្នោះទេ យើងច្បាស់ជាលំបាកលូនហើយ" សេនកៈឆ្លើយ។

"នៃសេនកៈ អ្នកកុំស្មានថា ពេលអ្នកចូលទៅក្នុងឧម្មង្គ ត្រូវឱនក្បាល ឬវារដោយជង្គង់លូនចូលទៅឲ្យសោះ។ ប្រសិនបើអ្នកចង់ជិះដំរីទៅ ក៏អាចជិះចូលទៅបាន។ ប្រសិនបើអ្នកចង់ជិះសេះទៅ ក៏អាចជិះចូលទៅបាន។ ឧម្មង្គខ្ពស់ ១៨ ហត្ថ មានទ្វារធំទូលំទូលាយស្រឡះល្អណាស់ អ្នកតុបតែងខ្លួនតាមសប្បាយ ហើយអញ្ជើញដើរទៅខាងមុខព្រះមហាក្សត្រទៅ" មហោសថប្រាប់។

សេនាប្រមុខមហោសថ បានចាត់ឲ្យសេនកៈដើរខាងមុខ ស្ដេចយាងកណ្ដាល ខ្លួនលោកដើរតាមក្រោយ។ ព្រោះហេតុអ្វី? ពីព្រោះសេនាប្រមុខមហោសថគិតថា សូមកុំឲ្យព្រះរាជាស្ដេចយាងសន្សឹមៗក្រឡេកមើលឧម្មង្គដែលប្រដាប់តុបតែងស្អាតសង្ហានោះឡើយ។ នៅខាងក្នុងឧម្មង្គវិញ មានបបរបាយ និងខាទនីយៈជាដើម គ្រឿងបរិភោគឧបភោគគ្រប់មុខ ត្រៀមសម្រាប់មហាជន។ មនុស្សទាំងឡាយនោះ ដើរបណ្ដើរ ហូបបណ្ដើរ ផឹកបណ្ដើរ គយគន់មើលឧម្មង្គបណ្ដើរ។

មហោសថដើរពីក្រោយ តឿនស្តេចឲ្យយាងថា "សូមយាងទៅ មហារាជ សូមយាងទៅ មហារាជ"។ ព្រះរាជាយាងបណ្តើរគយគន់មើលឧម្មង្គដែលល្អល្អះដូចជាទេវសភាបណ្តើរ។ អាចារ្យសេនកៈដើរនៅខាងមុខ មហោសថដើរនៅខាងក្រោយ ស្តេចវិទេហៈយាងនៅកណ្តាល ពួកនាហ្មឺនសព្វមន្ត្រីហែហមអមដំណើរជុំវិញ"។

## ពិធីអភិសេកស្តេចវិទេហៈនឹងព្រះរាជធីតាបញ្ចាលចន្ទី

ពួកទាហានទាំងឡាយរបស់លោកសេនាប្រមុខមហោសថ បានដឹងថា ព្រះរាជារបស់ខ្លួនយាងមកហើយ ក៏បានយាងព្រះរាជមាតា ព្រះអគ្គមហេសី ព្រះរាជបុត្រ និងព្រះរាជធីតារបស់ស្តេចចូឡនី ចេញអំពីឧម្មង្គមកគង់ប្រថាប់នៅក្នុងបន្ទប់ទទួលភ្ញៀវដ៏ធំទូលាយ[១៨៨]។ រីឯព្រះបាទវិទេហរាជ ក៏ទ្រង់យាងចេញអំពីឧម្មង្គជាមួយនឹងសេនាប្រមុខមហោសថ។ ក្សត្រទាំង ៤ អង្គ លុះឃើញព្រះបាទវិទេហៈ និងលោកសេនាប្រមុខមហោសថហើយ មួយអង្គៗទ្រង់ព្រះតម្រិះថា "ពួកយើងពិតជាធ្លាក់ក្នុងកណ្តាប់ដៃសត្រូវ ដោយឥតសង្ស័យឡើយ ពួកទាហានរបស់សេនាប្រមុខមហោសថ ជាក់ជាមកចាប់ពួកយើងពុំខាន" ដូច្នេះហើយក្សត្រិយ៍ទាំងនោះខ្លាចចំពោះមរណៈ ក៏ទ្រង់ព្រះកន្សែងខ្លាំងៗ។

---

[១៨៨] មហាវិសាលមាឡក

ឯស្ដេចចូឡនីកំពុងតែឈរក្នុងទីចម្ងាយមួយគាវុតអំពីទន្លេគង្គា ពីព្រោះទ្រង់ខ្លាចក្រែងលោស្ដេចវិទេហរាជរត់គៀសខ្លួនបាត់។ ក្នុងរាត្រីដ៏សែនស្ងាត់ជ្រងំនោះ ស្ដេចចូឡនីពុទ្ធនូវសម្រែករបស់ក្សត្រិយ៍ទាំង ៤ អង្គទ្រង់មានរាជបំណាងនឹងត្រាស់ថា សំឡេងទ្រហឹះ ដូចជាសំឡេងរបស់ព្រះអគ្គមហេសីនន្ទាទេវី តែទ្រង់មិនមានបន្ទូលអ្វីឡើយ ក្រែងលោកើតការចោទ្យាឡើងថា "ព្រះអគ្គមហេសីនន្ទាទេវីនៅឯណា? ពួកអ្នកចូររកមើល"។

ចំណែកសេនាប្រមុខមហោសថ បានអភិសេករាជធីតាក្រមុំនាមបញ្ចាលចន្ទីឲ្យជាអគ្គមហេសីរបស់ព្រះបាទវិទេហរាជ ក្នុងទីនោះហើយប្រកាសជាឱឡារិក[១៨៩]ថា "បពិត្រមហារាជ ព្រះអង្គស្ដេចយាងមកទីនេះ ដើម្បីព្រះរាជធីតាបញ្ចាលចន្ទី ចាប់ពីថ្ងៃនេះតទៅ ព្រះនាងក្លាយជាអគ្គមហេសីពេញសិទ្ធិរបស់ព្រះអង្គហើយ"។ ពេលនោះ ពួកទ័ពជើងទឹកបានបង្ហាញមុខចំពោះព្រះកក្រ្កព្រះរាជា ដោយមានសំពៅ ៣០០ រៀបបន្តគ្នា ត្រៀមជាស្រេចនៅតាមទន្លេគង្គា។ ព្រះរាជាទ្រង់ចុះចាកពីកន្ទ្រែងទទួលភ្ញៀវ យាងឡើងគង់លើសំពៅ ដែលតុបតែងល្អ

---

[១៨៩] ឱឡារិក (បា.សំ., គុ.) គ្រោតៗ, គ្រោតគ្រាត, ច្បាស់លាស់។ ពាក្យផ្ទុយគឺ សុខុម។ ធំដុំ, យ៉ាងធំ, ហ៊ឹកហ៊ាក់, ឧ. បុណ្យខណ្ឌសីមាដ៏ឱឡារិកអធិកអធម។

ឥតខ្ចោះ។ ចំណែកក្សត្រិយ៍ទាំង ៤ អង្គនោះ ក៏ត្រូវយាងឡើងលើសំពៅទៅជាមួយដែរ។

**ឱវាទមហោសថផ្ដាំចំពោះព្រះបាទវិទេហៈ**

កាលព្រះបាទវិទេហៈ ទ្រង់ចេញពីឧម្មង្គឡើងគង់លើព្រះទីនាំងនាវា មហោសថក៏ក្រាបទូលថា៖

"បពិត្រព្រះសម្មតិទេព ព្រះបាទចូឡនីព្រហ្មទត្តនោះ ត្រូវជាព្រះបិតាក្មេករបស់ព្រះអង្គ។ បពិត្រព្រះអង្គជាធំជាងពួកជន ព្រះមហាក្សត្រីនន្ទាទេវីនេះ ត្រូវជាព្រះមាតាក្មេករបស់ព្រះអង្គ។ ព្រះអង្គគប្បីប្រតិបត្តិព្រះមាតាក្មេក ឲ្យដូចព្រះអង្គប្រតិបត្តិព្រះវរមាតាបង្កើតរបស់ព្រះអង្គ។ ព្រះអង្គគប្បីគោរពស្រឡាញ់បញ្ចាលចន្ទរាជកុមារ ឲ្យដូចព្រះអង្គគោរពព្រះរាជបុត្រច្បងរួមឧទរមានព្រះមាតាតែមួយរបស់ព្រះអង្គ។ បពិត្រព្រះអង្គដ៏ប្រសើរ ព្រះនាងបញ្ចាលចន្ទីទេវីដែលព្រះអង្គទ្រង់ប្រតិព័ទ្ធនេះ ជាព្រះរាជបុត្រីរបស់ស្ដេចចូឡនី ឥឡូវព្រះនាងបានជាមហេសីរបស់ព្រះអង្គហើយ ព្រះអង្គគប្បីមានព្រះហឫទ័យស្រឡាញ់ សន្ដោសត្រាប្រណីប្រកបដោយភក្តីភាពចំពោះព្រះនាង"។

**មហោសថជាមេទ័ពមិនរត់ចោលកូនទាហាន**

ចំណែកព្រះបាទវិទេហៈ ទ្រង់យល់ព្រមធ្វើតាមប្រសាសន៍របស់លោកសេនាប្រមុខទាំងអស់។ ប៉ុន្តែទ្រង់មិនបានត្រាស់អ្វីប្រាប់ពួកនឹងរាជមាតាសោះ។ ព្រោះហេតុអ្វី? ពីព្រោះថា ព្រះនាងមានវ័យចំណាស់ហើយ។ ព្រះរាជាមានបំណងយាងទៅឲ្យផុតពីទុក្ខមហន្តរាយភ្លាមៗ ទើបទ្រង់ត្រាស់នឹងមហោសថ ដែលឈរនិយាយនៅទៀបធ្នេរទន្ទេគន្ធាថា៖

"នែបា នៅអល់អែកធ្វើអ្វីទៀត ប្រញាប់ឡើងទូកឲ្យលឿនមក នៅឈរធ្វើអ្វី ពួកយើងរួចផុតពីគ្រោះថ្នាក់ហើយ តោះយើងទៅឥឡូវនេះទាំងអស់គ្នា"។

មហោសថក្រាបទូលថា៖

"បពិត្រព្រះសម្មតិទេព ដំណើរដែលទូលបង្គំជាខ្ញុំទៅជាមួយនឹងព្រះអង្គឥឡូវនេះ មិនជាការត្រឹមត្រូវចំពោះទូលបង្គំជាខ្ញុំឡើយ។ បពិត្រមហារាជ ទូលបង្គំជាខ្ញុំដែលជាអ្នកដឹកនាំកងទ័ព លះបង់ចោលពួកកងទ័ព ដោះយករួចខ្លួនតែម្នាក់ឯង នេះមិនមែនជាទំនៀមរបស់មេទ័ពទេ។ បពិត្រព្រះសម្មតិទេព ទូលបង្គំជាខ្ញុំនឹងដឹកនាំកងទ័ពដែលនៅសល់ក្នុងព្រះរាជនិវេសន៍ និងយកទ្រព្យ

ដែលស្ដេចចូឡនីប្រទានឲ្យសិន សឹមទូលបង្គំជាខ្ញុំនឹងចេញដំណើរទៅតាមក្រោយ"។

ព្រះរាជាតបថា៖

"ម្នាលបណ្ឌិត សេនារបស់អ្នកមានតិច តើអ្នកទប់ទល់ជាមួយនឹងស្ដេចចូឡនីព្រហ្មទត្ត ដែលមានសេនាច្រើនដូចម្ដេចបាន? អ្នកមានកម្លាំងខ្សោយ មុខជាលំបាកទប់ទល់ នឹងស្ដេចចូឡនីព្រហ្មទត្តដែលមានកម្លាំងខ្លាំងមិនខាន"។

សេនាប្រមុខមហោសថទូលតបវិញថា៖

"បុគ្គលមានប្រាជ្ញា សូម្បីមានសេនាតិច រមែងឈ្នះបុគ្គលឥតប្រាជ្ញាដែលមានសេនាច្រើន។ ព្រះរាជាតែមួយព្រះអង្គ ជាអ្នកឈ្លាសក្នុងឧបាយកល រមែងឈ្នះព្រះរាជាទាំងឡាយ ជាអ្នកមិនឈ្លាសក្នុងឧបាយកល ដូចជាព្រះអាទិត្យមានតែមួយដួងសោះរះឡើងកាលណា តែងកម្ចាត់បង់ងងឹតអន្ធការ ធ្វើឲ្យមានពន្លឺភ្លឺស្វាង ដូច្នោះដែរ"។

លុះនិយាយដូច្នេះហើយ លោកសេនាប្រមុខលើកដៃប្រណម្យតម្កល់លើត្បូង ថ្វាយបង្គំលាព្រះរាជា ក្រាបទូលស្ដេចឲ្យយាងទៅថា៖

"សូមស្ដេចយាងទៅចុះ ព្រះសម្មតិទេព"។

## ព្រះបាទវិទេហៈយាងដល់នគរដោយសុវត្ថិភាព

ព្រះបាទវិទេហរាជមានព្រះតម្រិះថា "ខ្ញុំអញពេលនេះ បានរួចផុតពីកណ្ដាប់ដៃនៃសត្រូវហើយ ទាំងគោលបំណងរបស់អញ ក៏បានសម្រេចដល់ទីបំផុត ព្រោះអញបានស្រីកែវនេះហើយ"។ ព្រះអង្គរលឹកនឹកគុណលោកសេនាប្រមុខមហោសថ ហើយកើតបីតិបាមោជ្ជៈ ទ្រង់សរសើរគុណរបស់មហោសថឲ្យសេនកៈស្ដាប់ថា៖

"នែអាចារ្យសេនកៈ ការនៅរួមជាមួយនឹងពួកបណ្ឌិត នាំមកនូវសេចក្ដីសុខស្រួលណាស់ហ្ន៎ ព្រោះថា មហោសថបានរំដោះពួកយើងចេញពីក្នុងកណ្ដាប់ដៃនៃសត្រូវឲ្យរួចបាន ដូចគេដោះហ្វូងបក្សីដែលជាប់នៅក្នុងទ្រុង ឬដូចគេដោះហ្វូងត្រីដែលជាប់នៅក្នុងសំណាញ់ដូច្នោះ"។

ឮព្រះរាជឱង្ការត្រាស់សរសើរដូច្នោះ អាចារ្យសេនកៈ ក៏និយាយសរសើរអំពីគុណរបស់មហោសថដែរថា៖

"បពិត្រមហារាជ ពិតមែនហើយ បណ្ឌិតទាំងឡាយតែងនាំមកនូវសេចក្ដីសុខយ៉ាងនេះឯង មហោសថបានជួយរំដោះព្រះអង្គនិងពួកទូលបង្គំដែលនៅក្នុងកណ្ដាប់ដៃនៃសត្រូវឲ្យរួចបាន

ដូចគេដោះហ្វូងបក្សីដែលជាប់នៅក្នុងទ្រុង ឬដូចគេដោះហ្វូងត្រី ដែលជាប់នៅក្នុងសំណាញ់ ដូច្នោះ”។

បន្ទាប់មក ព្រះបាទវិទេហរាជ បានឆ្លងផុតអំពីទន្លេគង្គាដល់ស្រុក ដែលមហោសថបានរៀបចំរួចជាស្រេច ចម្ងាយមួយយោជន៍ស្រុកមួយ មួយយោជន៍ស្រុកមួយៗ ពួកមន្ត្រីដែលលោកសេនាប្រមុខមហោសថ ដាក់ឲ្យត្រួតការងារនៅក្នុងតំបន់នោះៗ បានរៀបចំដំរីនិងពាហនៈជាដើម ផង បាយទឹកជាដើមផង សម្រាប់ព្រះរាជានិងកងទ័ពកំពុងធ្វើដំណើរ។ ដំរីសេះនិងរថជាដើមណាដែលមានកម្លាំងខ្សោយ បានទុកដំរីសេះរទេះ ជាដើមនោះនៅតំបន់នោះៗ ហើយយកដំរីសេះរទេះថ្មីធ្វើដំណើរឆ្ពោះ ទៅតំបន់មួយទៀត។ ព្រះបាទវិទេហរាជទ្រង់បានធ្វើដំណើរអស់ចម្ងាយ ផ្លូវ ១០០ យោជន៍ទើបទៅដល់ក្រុងមិថិលា ក្នុងពេលព្រឹកថ្ងៃបន្ទាប់។

ចំណែកសេនាប្រមុខមហោសថ បានដើរទៅកាន់ទ្វារឧមង្គ បាន ដកព្រះខាន់ដែលសៀតជាប់នឹងខ្លួន រួចកប់ទុកក្នុងពំនូកដីខ្សាច់ទៀបទ្វារ ឧមង្គ ហើយបានចូលទៅកាន់ឧមង្គ ដើរក្នុងឧមង្គចូលទៅនគរ រួចឡើង លើប្រាសាទ ងូតទឹកក្រអូប ពិសាភោជនដែលមានរសជាតិឆ្ងាញ់ៗ រួចលោកសម្រាន្តលើគ្រែដ៏វិចិត្រ ពិចារណាថា “គោលបំណងរបស់ អាត្មាអញបានសម្រេចហើយ”។

**ព្រះបាទចូឡនីបញ្ជាកងទ័ពវាយលុករាជដំណាក់ថ្មី**

ព្រះបាទចូឡនីព្រហ្មទត្តឡោមព័ទ្ធរាជដំណាក់ថ្មីរបស់ព្រះបាទវិទេហៈ អស់មួយរាត្រី លុះដល់អរុណរះឡើង ព្រះអង្គឡើងគង់លើដំរីដ៏ប្រសើរ ជាដំរីខ្លាំងក្លៀវក្លាមានអាយុ ៦០ ឆ្នាំ ទ្រង់ពាក់គ្រឿងក្រោះជាវិការៈនៃកែវមណី ព្រះហស្ដកាន់សរ បានត្រាស់បញ្ជារេហ៍ពលទាំងឡាយ មាន ពលដំរី ពលសេះ ពលរថ ពលថ្មើរជើង និងពួកខ្មាន់ធ្នូ ដែលស្ទាត់ជំនាញក្នុងការបាញ់ សូម្បីតែរោមមួយសរសៃក៏អាចបាញ់ត្រូវ ឲ្យមកជួបជុំគ្នាត្រៀមខ្លួនប្រយុទ្ធ រីឯព្រះអង្គផ្ទាល់ស្ដេចយាងចូលទៅជិតរាជដំណាក់ថ្មីដែលមហោសថសាងសង់ថ្វាយព្រះបាទវិទេហៈ ហើយ បានបញ្ជាឲ្យពួកទាហានព័ទ្ធចាប់ព្រះបាទវិទេហរាជទាំងរស់ថា៖

"អ្នកទាំងឡាយ ចូរបញ្ជាដំរីទាំងឡាយដែលមានភ្លុកដ៏រឹងមាំ មានកម្លាំងដ៏ខ្លាំងក្លា មានអាយុ ៦០ ឆ្នាំ ឲ្យចូលជាន់កម្ទេចរាជដំណាក់ ដែលមហោសថបានសាងថ្វាយស្ដេចវិទេហៈ។ ចូរបាញ់ព្រួញ ដែលមានពណ៌ស មានមុខដូចពន្លាក មានចុងដ៏មុត អាចទម្លុះទម្លាយឆ្អឹងបាន ទៅពីគ្រប់ទិសឲ្យបានព្រមៗគ្នា កុំឲ្យសត្រូវគេចរួចឲ្យសោះ។ ឯពួកទាហានក្មេងៗក្លៀវក្លា

ពាក់គ្រឿងក្រោះ មានអាវុធប្រកបដោយជនដ៏វិចិត្រ កាលបើ
ពួកដំរីធំស្ទុះចូលមក ចូរអ្នកនាំគ្នាតស៊ូប្រយុទ្ធ ចំពោះមុខដំរី
ទាំងឡាយៗ លំពែងទាំងឡាយ ដែលគេលាងជម្រះដោយប្រេង
មានរស្មីភ្លឺផ្លេក រុងរឿងដូចជាផ្កាយព្រឹកៗ ពួកយោធារបស់
យើងដែលមានអាវុធ និងគ្រឿងក្រោះការពារគ្រប់គ្រាន់ដូច្នេះ
មិនត្រូវរត់ចោលសង្គ្រាមឡើយ ស្តេចវិទេហៈនឹងមិនអាចគេច
ផុតពីកណ្តាប់ដៃយើងបានទេ ល្អីកណាតែស្តេចវិទេហៈមាន
ស្លាបហើរដូចបក្សី ទើបរួចបានៗ ទ័ពរបស់យើង សរុបចំនួន
៣៩.០០០ នាក់ អាចកាត់ក្បាលសត្រូវបាន យើងបានដើរសព្វ
លើផែនដីហើយ មិនដែលធ្លាប់ឃើញទ័ពណា មានចំនួនស្មើ
នឹងទ័ពរបស់យើងឡើយៗ ដំរីទាំងឡាយមានភ្លុកប្រដាប់ ហើយ
មានកម្លាំង មានអាយុ ៦០ ឆ្នាំ ទ័ពនៅក្មេងៗមានរូបល្អ សម្បុរ
ស្អាតជិះដំរីទាំងឡាយៗ ទ័ពទាំងឡាយ មានគ្រឿងអលង្ការ
ពណ៌លឿង ស្លៀកសំពត់ពណ៌លឿង ដណ្តប់សំពត់ពណ៌លឿង
ជិះដំរីទាំងឡាយ មានគួរនាដូចទេវបុត្រទាំងឡាយ ក្នុងសួននន្ទវ័នៗ
ព្រះខាន់ទាំងឡាយមានមុខសស្វាចដូចសម្បុរត្រីស្វាត ដែលគេ
លាងជម្រះដោយប្រេង មានពន្លឺចាំងភ្លឺផ្លេក ជាស្នាដៃរបស់ពួក
ជាងមានជំនាញព្យាយាមធ្វើឲ្យសម្រេច មានមុខស្មើ ជាព្រះខាន់

ដែលគេសំលៀងឲ្យមុតល្អហើយ។ ព្រះខាន់ទាំងនោះ គេធ្វើដោយដែកថែបដ៏មាំ មិនមានស្នឹម មានរស្មីចែងចាំងដូចមានព្រះអាទិត្យឋិតនៅក្នុងទីពាក់កណ្ដាល គឺពួកទ័ពមានកម្លាំងខ្លាំងមានជំនាញក្នុងការប្រហារ កាន់យ៉ាងមាំៗ ព្រះខាន់ទាំងឡាយបរិបូរដោយដងជាវិការៈនៃមាស មានស្រោមពណ៌ក្រហម កាលបើគេគ្រវីឡើង រមែងជះពន្លឺដូចជាផ្លេកបន្ទោរ ភ្លឺចាំងក្នុងចន្លោះនៃពពក។ ពួកខ្មាន់ធ្នូ អ្នកក្លៀវក្លាពាក់គ្រឿងក្រោះ អាចលោតបំផ្លោងខ្លួនទៅឰដ៏អាកាសបាន អ្នកឈ្លាសក្នុង ការកាន់ដាវនិងខែល ជាអ្នកហាត់ក្នុងការកាន់ធ្នូយ៉ាងស្ទាត់ជំនាញ អាចកាត់ផ្ដាច់នូវកដំរីបាន។ នៃស្ដេចវិទេហៈ ឯងត្រូវពួកទ័ពខ្លាំងៗ ដូច្នេះហ៊ុំព័ទ្ធហើយ ឯងចេញអំពីទីនេះមិនរួចទេ យើងឃើញយ៉ាងច្បាស់ថា ឯងគឺពិតជាគ្មានឫទ្ធានុភាព អាចត្រឡប់ទៅកាន់ក្រុងមិថិលាវិញបានឡើយ"។

**មហោសថគំរាមស្ដេចចូឡនី**

ស្ដេចចូឡនី គំរាមស្ដេចវិទេហៈថា "យើងនឹងចាប់ឯងឥឡូវ" ទ្រង់ដេញដំរីដោយកន្ត្រៃពេជ្រ បញ្ជាទាហានថា "ទាហាន ចូរចាប់ ចូរបំបែក ចូរបាញ់" ហើយទ្រង់ចេះតែបញ្ជាកងទ័ពឲ្យសម្រុកចូលទៅមុខ

ដើម្បីគ្រប់សង្កត់នគរថ្មីទាំងមូល។ គ្រានោះ បុរសឈ្លបការណ៍របស់លោកសេនាប្រមុខមហោសថ បានយកពួកអ្នកបម្រើរបស់ខ្លួនទៅចោមរោមស្តេចចូឡនីព្រហ្មទត្តនោះ ដោយពួកគេគិតថា "នរណានឹងដឹងថាមានគ្រោះថ្នាក់អ្វីកើតឡើងចំពោះព្រះបាទវិទេហៈ និងលោកសេនាប្រមុខ?" ក្នុងខណៈនោះ លោកសេនាប្រមុខមហោសថក្រោកពីសិរីសយនា ធ្វើកិច្ចជម្រះសរីរកាយរួចហើយ ពិសាអាហារពេលព្រឹក តុបតែងខ្លួនស្លៀកពាក់សំពត់ មានតម្លៃជាប្រាក់ ១០០.០០០ កហាបណៈ ទិញមកអំពីដែនកាសី និងយកសំពត់កម្ពលមួយមានពណ៌ក្រហម មកពាក់ចៀងស្មាម្ខាង កាន់ឈើច្រត់វិចិត្រដោយរតនៈ៧ប្រការ ជាគ្រឿងសម្គាល់ឋានៈខ្លួន[១៩០] ពាក់ទ្រនាប់ជើងមាស មានស្រីតុបតែងខ្លួនស្អាតៗដូចទេពអប្សរកំពុងបក់ផ្លិតវាលវីជនី[១៩១]ជូន ហើយលោកបើកសីហបញ្ជរនៅលើប្រាសាទ មានក្បាច់ដ៏វិចិត្រ បង្ហាញខ្លួនឲ្យស្តេចចូឡនីឃើញ ហើយលោកដើរទៅមក ដោយដំណើរល្ងាសល្ងទ់យាងយាសដូចសក្កទេវរាជ។ រីឯព្រះបាទចូឡនីព្រហ្មទត្ត សម្លឹងមើលរូបសម្បត្តិរបស់មហោសថហើយ ទ្រង់មិនអាចធ្វើព្រះទ័យឲ្យរីករាយបានទេ រីតែខំបំបោលដំរីដែលទ្រង់ជិះឲ្យសម្រុកចូលទៅមុខកាន់តែលឿន ក្នុង

[១៩០] សត្តរតនវិចិត្តំ វលញ្ជនទណ្ឌកំ អាទាយ។

[១៩១] ផ្លិតធ្វើអំពីរោមសត្វ។

គោលបំណងថា នឹងចាប់មហោសថឲ្យបានឥឡូវនេះ។ ចំណែកសេនាប្រមុខមហោសថគិតថា ស្ដេចចូឡនីនេះស្ទុះសម្រុកមកយ៉ាងលឿនដោយសម្គាល់ថា ព្រះអង្គនឹងចាប់ស្ដេចវិទេហៈ ប៉ុន្តែទ្រង់មិនដឹងថាកូនប្រពន្ធរបស់ព្រះអង្គ ត្រូវព្រះរាជារបស់យើងនាំយកទៅកាន់នគរមិថិលាហើយទេ។ អញនឹងទូលស្ដេចចូឡនីឲ្យទ្រង់បានជ្រាបពីការពិតដូចធ្នុះមុខនឹងកញ្ចក់ដ៏ថ្លា[១៩២]”។ គិតដូច្នេះហើយ មហោសថឈរត្រង់បង្អួច បញ្ចេញសំឡេងផ្អែមដូចទឹកឃ្មុំទៅនឹងព្រះបាទចូឡនីថា៖

“ព្រះអង្គទ្រង់ប្រញាប់ប្រញាល់បញ្ជូនដំរីដ៏ប្រសើរមក ព្រះអង្គមានហឫទ័យរីករាយយាងមក ហើយទ្រង់សម្គាល់ថា ព្រះអង្គនឹងបានសម្រេចប្រយោជន៍តាមព្រះរាជបំណងឬ? សូមព្រះអង្គទម្លាក់ចុះនូវធ្នូនិងបំពង់ព្រួញ សូមព្រះអង្គទម្លាក់ចុះនូវកូនសរ សូមព្រះអង្គដាក់ចុះនូវគ្រឿងក្រោះដ៏ល្អស្មើនឹងកែវពៃទូរ្យនិងកែវមណី”។

ព្រះបាទចូឡនីទ្រង់សណ្ដាប់សម្ដីរបស់មហោសថ ទ្រង់ក៏មានព្រះតម្រិះថា “មហោសថកូនគហបតីកំពុងនិយាយលេងជាមួយនឹង

---

[១៩២] សុវណ្ណាទាសសទិសំ មុខំ ទស្សេត្វា។

អញតើ។ ថ្ងៃនេះ អញនឹងធ្វើឲ្យមហោសថដឹងពីថ្វីដៃអញម្ដង” រួចទ្រង់គំរាមមហោសថថា៖

“អ្នកឯងមានសម្បុរមុខស្រស់បស់ ទាំងនិយាយក៏ញញឹមញញែមជាប់។ ធម្មតាមនុស្ស នៅពេលសេចក្ដីស្លាប់មិនទាន់មកដល់ តែងតែមានទឹកមុខញញឹមស្រស់បស់បែបនេះឯង តែពេលសេចក្ដីស្លាប់មកដល់ប្រាកដជាគ្មានទឹកមុខបែបនេះទៀតទេ”។

ក្នុងពេលស្ដេចចូឡនីត្រាស់ជាមួយនឹងមហោសថយ៉ាងនេះ ពួកទាហានជាច្រើន មើលឃើញនូវរូបសម្បត្តិរបស់មហោសថ ហើយក៏នាំគ្នាមកកាន់សម្នាក់របស់ព្រះរាជា ដោយបបួលគ្នាថា “នៃវ៉ឺយកនយើងព្រះរាជារបស់យើង កំពុងប្រឹក្សាជាមួយនឹងមហោសថបណ្ឌិត តើព្រះអង្គចរចាអំពីអ្វី? តោះយើងនាំគ្នាទៅស្ដាប់មើល”។

ចំណែកសេនាប្រមុខមហោសថប្រកាសថា៖

“ព្រះអង្គមិនស្គាល់ទូលបង្គំថាជាមហោសថបណ្ឌិតទេឬ? ទូលបង្គំមិនឲ្យព្រះអង្គសម្លាប់ខ្ញុំទូលបង្គំបានឡើយ។ បពិត្រព្រះសម្មតិទេព ការប្រឹក្សារបស់ព្រះអង្គបែកការណ៍ហើយ។ ផែនការដែលទ្រង់គ្រោងទុកក្នុងព្រះទ័យនិងក្នុងចិត្តរបស់កេវដ្តព្រាហ្មណ៍នោះ ពុំបានសម្រេចឡើយ”។

រួចមហោសថបានពោលបន្តថា៖

"បពិត្រព្រះរាជា ពាក្យដែលព្រះអង្គគំរាមនោះជាពាក្យសោះសូន្យទទេ រឿងសម្ងាត់របស់ព្រះអង្គបានបែកការហើយ។ ព្រះអង្គមិនអាចចាប់ព្រះរាជារបស់យើងបានដោយងាយៗទេ ដូចសេះខ្ចកដេញតាមសេះសិន្ធព។ ព្រះរាជាក្រុងមិថិលា ព្រមទាំងអាមាត្យនិងរាជបរិស័ទ ធ្វងស្ទឹងគង្គាតាំងពីថ្ងៃម្សិលមិញម្ល៉េះ ក្អែកស្មុះតាមរាជហង្សនឹងធ្លាក់ចុះក្នុងពាក់កណ្ដាលផ្លូវយ៉ាងណាមិញ បើព្រះអង្គ នឹងតាមព្រះរាជានោះ នឹងដល់សេចក្ដីវិនាសក្នុងពាក់កណ្ដាលផ្លូវ ក៏យ៉ាងនោះដែរ"។

តទៅនេះ មហោសថទាញយកឧទាហរណ៍មកពោល បីដូចសត្វកេសរសីហៈដែលមិនខ្លាចញញើត ដោយពាំនោលដូច្នេះថា៖

"ឆ្កែចចកទាំងឡាយជាសត្វថោកទាប ឃើញផ្កាចារដែលរីកក្នុងពេលរាត្រី ក៏សម្គាល់ថាដុំសាច់ ហើយនាំគ្នាចោមរោម។ ឆ្កែចចកទាំងនោះ ជាសត្វថោកទាប កាលបើរាត្រីកន្លងផុតហើយ ព្រះអាទិត្យក៏រះឡើង ទើបឃើញច្បាស់ថាជាផ្កាចាររីក ក៏អស់សេចក្ដីប្រាថ្នា ហើយរត់ទៅយ៉ាងណាមិញ។ បពិត្រមហារាជ

ព្រះអង្គចោមពទ្ធព្រះបាទវិទេហៈ នឹងអស់សេចក្តីប្រាថ្នាហើយ ដូចពួកខ្លែងចចក ចោមរោមនូវផ្កាចារ ក៏ដូច្នោះដែរ”។

ស្តេចចូឡនីព្រហ្មទត្តដូច្នោះ មិនកោតញញើតសេនាប្រមុខមហោសថ ហើយទ្រង់មានព្រះតម្រិះថា “មហោសថនេះនិយាយចេញមកក្អៀវក្លា ណាស់ ស្តេចវិទេហៈប្រាកដជាគេរំដោះទ្រង់ឲ្យរត់រួចផុតបាត់ទៅមិន ខានឡើយ”។ ទ្រង់ព្រះតម្រិះដូច្នេះហើយ ស្តេចចូឡនីពិរោធខ្លាំង ណាស់ថា “កាលដើមឡើយ ពួកអញបែកបាក់កងទ័ពបាត់មេបាត់ កោយ រត់ទាំងស្លៀកពាក់ខោអាវមិនទាន់រួចរាល់ ក៏ព្រោះតែមហោសថ នេះឯង។ ឥឡូវនេះ បច្ចាមិត្រធ្លាក់ក្នុងកណ្តាប់ដៃយើងហើយ ត្រូវបាន វារំដោះឲ្យរួចផុតទៀត វាធ្វើឲ្យអញបាត់បង់ប្រយោជន៍ច្រើនលើក ណាស់មកហើយ។ ទារុណកម្មត្រូវធ្វើចំពោះមនុស្សពីរនាក់ អញនឹង យកមកធ្វើចំពោះមហោសថតែម្នាក់ចុះ”។ ទ្រង់មានព្រះតម្រិះដូច្នេះ ហើយ ស្តេចចូឡនីបានបញ្ជាពួកទាហាន ដើម្បីធ្វើទារុណកម្មចំពោះ មហោសថនោះដូច្នេះថា៖

“អ្នកទាំងឡាយ ចូរកាត់ដៃកាត់ជើង កាត់ត្រចៀក កាត់ច្រមុះ របស់មហោសថនេះ ព្រោះវាធ្វើព្រះបាទវិទេហៈជាសត្រូវដែល នៅក្នុងកណ្តាប់ដៃយើងឲ្យរួចទៅវិញ។ សេនាទាំងឡាយ ចូរនាំ

គ្នាយកឈើស្រួចដោតមហោសថនេះ ហើយចម្អិនវា ដូចគេចម្អិនសាច់ដែលគួរចម្អិន ព្រោះវាបានរំដោះព្រះបាទវិទេហៈជាសត្រូវ ដែលនៅក្នុងកណ្តាប់ដៃយើងឲ្យរួចទៅវិញ។ បុគ្គលដោតសន្ទឹងស្បែកគោលើផែនដី ពុំនោះសោត ថ្ពក់ស្បែកសីហៈ ឬខ្លាធំ ដោយកង្វេរយ៉ាងណាមិញ យើងនឹងចាក់ដោតមហោសថដោយលំពែងយ៉ាងនោះដែរ ព្រោះវារំដោះព្រះបាទវិទេហៈជាសត្រូវ ដែលនៅក្នុងកណ្តាប់ដៃយើងឲ្យរួចទៅវិញ”។

ព្រះរាជបញ្ជាដូច្នោះ សេនាប្រមុខមហោសថអស់សំណើចថា “ព្រះរាជានេះមិនដឹងថា អគ្គមហេសីព្រះអង្គ និងព្រះញាតិវង្សរបស់ព្រះអង្គត្រូវអញចាប់បានបញ្ជូនទៅក្រុងមិថិលាអស់ហើយទេ ព្រោះហេតុតែព្រះអង្គមិនជ្រាបរឿងនោះ ទើបព្រះអង្គក្តៅក្រហាយ បញ្ជាឲ្យគេធ្វើទារុណកម្មបែបនេះចំពោះអញ។ ប៉ុន្តែ មហោសថបានដឹងថា ព្រះរាជាបញ្ចេញអាការយ៉ាងនេះដោយអំណាចសេចក្តីក្រោធ ណ្ហើយចុះទោះបីស្តេចអង្គនេះ បាញ់អញដោយផ្លែសរក្តី, ធ្វើទារុណកម្មផ្សេងៗដែលជាទីគាប់ព្រះទ័យរបស់ព្រះអង្គក្តី អញនឹងធ្វើស្តេចអង្គនេះឲ្យកើតជំងឺសោកស្តាយ វេទនាទុក្ខ[១៩៣] រួចប្រាប់នូវទារុណកម្មបែបនោះវិញ

[១៩៣] សោកាតុំ ឥមំ វេទនាប្បត្តំ កត្វា ហត្ថិបិដ្ឋេយេវ វិសញ្ញី នំ និបជ្ជាបេតុំ។

ដើម្បីឲ្យព្រះអង្គសន្ទប់លើខ្នងដំរី” គិតដូច្នេះហើយ មហោសថក៏ថ្លែងតបទៅស្តេចចូឡនីថា៖

“បើព្រះអង្គកាត់ដៃ ជើង ត្រចៀក និងច្រមុះរបស់ទូលបង្គំជាខ្ញុំ ព្រះបាទវិទេហៈមុខជានឹងកាត់ដៃ ជើង ត្រចៀក និងច្រមុះរបស់ព្រះរាជបុត្រ ព្រះនាមបញ្ចាលចន្ទៈ យ៉ាងហ្នឹងដែរ។ បើព្រះអង្គកាត់ដៃ ជើង ត្រចៀក និងច្រមុះរបស់ទូលបង្គំ ព្រះបាទវិទេហៈមុខតែនឹងកាត់ដៃ ជើង ត្រចៀក និងច្រមុះ របស់ព្រះរាជធីតា ព្រះនាមបញ្ចាលចន្ទី ក៏យ៉ាងហ្នឹងដែរ។ បើព្រះអង្គកាត់ដៃ ជើង ត្រចៀក និងច្រមុះរបស់ទូលបង្គំ ព្រះបាទវិទេហៈមុខតែនឹងកាត់ដៃ ជើង ត្រចៀក និងច្រមុះរបស់អគ្គមហេសីព្រះនាមនន្ទាទេវី ក៏ដូចគ្នាដែរ។ បើព្រះអង្គកាត់ដៃ ជើង ត្រចៀក និងច្រមុះរបស់ទូលបង្គំ ព្រះបាទវិទេហៈមុខតែនឹងកាត់ដៃ ជើង ត្រចៀក និងច្រមុះរបស់ព្រះរាជបុត្រនិងព្រះមហេសីរបស់ព្រះអង្គ ក៏យ៉ាងហ្នឹងដែរ។ បើព្រះអង្គដោតទូលបង្គំដោយឈើអណ្តោត[១៩៤]

---

[១៩៤] សូមកុំច្រឡំន័យនៃពាក្យ អណ្តោត និង ត្រណោត។ អណ្តោត បានដល់ឈើឬដែកជាដើមដែលមានមុខស្រួចវែងប្រើសម្រាប់ដោតឬជង់ យើងប្រើជាគុណនាមក៏បាន ឧ. ឈើអណ្តោត, ដែកអណ្តោត។ ក្នុងបុរាណសម័យ មានឧក្រិដ្ឋជនខ្លះត្រូវរដ្ឋអំណាចដាក់ទោសដោយប្រើឈើឬដែកអណ្តោតដោតជង់គគូទ ហើយលើកឡើង

ហើយចម្អិន ដូចគេចម្អិនសាច់ ព្រះបាទវិទេហៈ មុខតែនឹងបញ្ជា គេឲ្យដោតព្រះរាជបុត្រព្រះនាមបញ្ចាលចន្ទៈដោយឈើអណ្ដាត ហើយចម្អិន យ៉ាងដូច្នោះដែរ។ បើព្រះអង្គដោតទូលបង្គំដោយឈើអណ្ដាត ហើយចម្អិន ដូចគេចម្អិនសាច់ ព្រះបាទវិទេហៈ មុខតែបញ្ជាគេឲ្យដោតព្រះរាជធីតាព្រះនាមបញ្ចាលចន្ទី ដោយឈើអណ្ដាត ហើយចម្អិន យ៉ាងហ្នឹងដែរ។ បើព្រះអង្គដោតទូលបង្គំដោយឈើអណ្ដាត ហើយចម្អិន ដូចគេចម្អិនសាច់ ព្រះបាទវិទេហៈមុខតែ បញ្ជាគេឲ្យដោតព្រះអគ្គមហេសីនន្ទាទេវី ដោយឈើអណ្ដាត ហើយចម្អិន យ៉ាងហ្នឹងដែរ។ បើព្រះអង្គដោតទូលបង្គំដោយឈើអណ្ដាត ហើយចម្អិន ដូចគេចម្អិនសាច់ ព្រះបាទវិទេហៈមុខតែបញ្ជាគេឲ្យដោតព្រះរាជបុត្រ និងព្រះមហេសី ដោយឈើអណ្ដាត ហើយចម្អិន ក៏យ៉ាងហ្នឹងដែរ។ បើព្រះអង្គចាក់ទូលបង្គំ ដោយលំពែង ព្រះបាទវិទេហៈមុខតែបញ្ជាគេឲ្យដោតព្រះរាជបុត្រព្រះនាមបញ្ចាលចន្ទៈដោយលំពែង យ៉ាងនោះដែរ។ បើព្រះអង្គចាក់ ទូលបង្គំដោយលំពែង ព្រះបាទ

---

ទៅលើ អ្នកទោសឈឺវេទនាណាស់រហូតស្លាប់។ រីឯពាក្យ ត្រណោត គឺជាវល្លិ ឬខ្សែ ឬក៏ដើមរពាក់ ពុំនោះទេ ចម្រៀកផ្ដៅជាដើម ដែលគេប្រើដោតអ្វីៗឲ្យជាចង្កោម ជាកួង ឬជាកម្រង ឧ. ត្រីមួយត្រណោត។

វិទេហៈមុខតែដោតព្រះរាជធីតាបញ្ចាលចន្ទីដោយលំពែង យ៉ាងហ្នឹងដែរ។ បើព្រះអង្គចាក់ទូលបង្គំដោយលំពែង ព្រះបាទវិទេហៈមុខតែបញ្ជាគេឲ្យចាក់អគ្គមហេសីនន្ទាទេវីដោយលំពែង យ៉ាងហ្នឹងដែរ។ បើព្រះអង្គចាក់ទូលបង្គំដោយលំពែង ព្រះបាទវិទេហៈមុខតែចាក់ព្រះរាជបុត្រនិងព្រះមហេសីដោយលំពែង យ៉ាងហ្នឹងដែរ។ យើងទាំងពីរនាក់ គឺព្រះបាទវិទេហៈ និងទូលព្រះបង្គំជាខ្ញុំ ប្រឹក្សាគ្នារួចស្រេចក្នុងទីស្ងាត់យ៉ាងនេះហើយ ខែលស្បែកទម្ងន់ ១០០ បលៈ[១៩៥] ដែលជាងស្បែកធ្វើឲ្យសម្រេចដោយឧបករណ៍របស់ជាងស្បែក អាចជួយការពារខ្លួនទប់រងនូវកូនសរទាំងឡាយបាន យ៉ាងណាមិញ ទូលព្រះបង្គំជាខ្ញុំ ជាអ្នកកម្ចាត់បង់នូវសេចក្តីទុក្ខ និងជាអ្នកនាំសេចក្តីសុខមកថ្វាយព្រះបាទវិទេហៈដ៏មានយស តែងទប់ទល់ការពារនូវកូនសរ គឺព្រះតម្រិះកិច្ចកលរបស់ព្រះអង្គ និងអាចារ្យកេវដ្តៈ ដោយខែលស្បែកទម្ងន់ ១០០ បលៈ គឺគំនិតប្រាជ្ញាដ៏ជ្រាលជ្រៅរបស់ទូលព្រះបង្គំ ក៏ដូច្នោះឯង”។

[១៩៥] បលៈ ជាមាត្រាថ្លឹងរបស់បុរាណដែល ១ បលៈ ស្មើនឹងទម្ងន់ស្រូវ១៦០០គ្រាប់។

សណ្ដាប់ដូច្នោះហើយ ព្រះបាទចូឡនីមានព្រះតម្រិះថា "មហោសថនិយាយអ្វី ពួថាស្ដេចវិទេហៈនឹងធ្វើទារុណកម្ម[១៩៦] ចំពោះបុត្រនិងមហេសីរបស់អញ ដូចដែលអញនឹងធ្វើចំពោះមហោសថនេះ។ មហោសថមិនដឹងថា អញរៀបចំគ្រប់គ្រងរក្សាកូនប្រពន្ធយ៉ាងហ្មត់ចត់ទេដឹង។ មហោសថសោកស្ដាយ ព្រោះគេខ្លាចស្លាប់ ជ្បិតគេគិតថាគេនឹងស្លាប់ឥឡូវនេះ។ អញមិនជឿសម្ដីគេទេ"។

ចំណែកមហោសថគិតថា "ស្ដេចអង្គនេះស្មានថា អញនិយាយដូច្នេះ ដោយសារខ្លាចស្លាប់ទេដឹង អញនឹងធ្វើឲ្យព្រះអង្គភ្ញាក់ខ្លួនម្ដង" រួចមហោសថពោលតបទៅស្ដេចចូឡនីថា ៖

"បពិត្រមហារាជ សូមយាងព្រះអង្គស្ដេចទតព្រះនេត្រមើលព្រះរាជវាំងរបស់ព្រះអង្គដែលស្ងាត់ជ្រងំចុះ បពិត្រមហារាជ ស្រីស្នំ និងកុមារទាំងឡាយ ព្រមទាំងព្រះវររាជមាតារបស់ព្រះអង្គ ទូលបង្គំបានឲ្យពួកទាហានរបស់ទូលបង្គំនាំចេញតាមឧមង្គទៅថ្វាយដល់ព្រះបាទវិទេហៈអស់ទៅហើយ ក្រាបទូល"។

ព្រះបាទចូឡនី ទ្រង់សណ្ដាប់ដូច្នោះ មានព្រះតម្រិះថា "មហោសថនិយាយប្រមាថមើលងាយអញកាន់តែខ្លាំង ប៉ុន្តែអញក៏ហាក់ដូចជា

---

[១៩៦] កម្មការណាំ។

បានឮសូរសំឡេងនៃព្រះនាងនន្ទាទេវី នៅប៉ែកទន្លេគង្គាកាលពីយប់មិញផងដែរ មហោសថបណ្ឌិតមានបញ្ញាច្រើន ទោះបីស្ថិតនៅក្នុងកាលៈទេសៈដ៏តឹងតែងបែបនេះក៏ដោយ គេក៏នៅតែនិយាយពាក្យពិតដដែល”។ ស្តេចចូឡនី ទ្រង់មានសេចក្តីសោកស្តាយខ្លាំងណាស់ ប៉ុន្តែទ្រង់ទប់ស្មារតី ធ្វើដូចជាមិនសោកស្តាយ ត្រាស់បញ្ជាមន្ត្រីម្នាក់ឲ្យចូលមកគាល់ រួចទ្រង់បញ្ជូនទៅ ដើម្បីស្វែងយល់ស្ថានការណ៍នោះថា៖

> “បើដូច្នោះ អ្នកទាំងឡាយ ចូរទៅឯព្រះរាជវាំងរបស់យើង ហើយពិនិត្យមើលហេតុនោះ តើសមដូចពាក្យរបស់មហោសថនិយាយដែរទេ?”

មន្ត្រីនោះ រួមជាមួយនឹងបរិវារ ធ្វើដំណើរទៅកាន់រាជនិវេសន៍ បើកទ្វារចូលទៅខាងក្នុង ឃើញពួកអ្នកយាមខាងក្នុងបុរីនិងមនុស្សគមតឿជាដើម ជាប់ចំណងជើង ដៃ មាត់ជាប់ធ្នាក់ ចងទុកជាប់នឹងភ្លុកដំរី[១៩៧] ឃើញភាជន៍បែក បាយទឹកនំចំណីផ្លែឈើរាយប៉ាយ ឃើញទ្វារឃ្លាំងរតនៈរបើកមានស្នាមថ្មីៗ ឃើញបន្ទប់ក្រឡាបន្ទំរបើកទ្វារអស់ ឃើញហ្វូងក្អែកហើរចូលតាមបង្អួចដែលរបើកនិងឃើញរាជនិវេសន៍ទទេស្អាត ឥតសិរីសួស្តី ស្មើនឹងស្រុកដែលគេបោះបង់ចោល និងដូចព្រៃ

---

[១៩៧] នាគទន្តកេសុ ឱលគ្គិតេ។

ស្មសាន[១៩៨]។ បន្ទាប់ពីឃើញទិដ្ឋភាពដូច្នេះ មន្ត្រីនោះត្រឡប់មកវិញ ក្រាបទូលថ្វាយដំណឹងចំពោះព្រះបាទចូឡនីថា៖

“បពិត្រមហារាជ សេចក្ដីដែលមហោសថទូល សុទ្ធតែជាការពិត ព្រោះថា ព្រះរាជវាំងទាំងមូលស្ងាត់ឈឹងដូចទីរហោឋាន”។

## មហោសថពណ៌នាសម្រស់មហេសីស្ដេចចូឡនី

ព្រះបាទចូឡនីទ្រង់ព្រះសណ្ដាប់ដូច្នោះ ទ្រង់ញ័រព្រះកាយ ដូចជាអាសិរ្ពិសត្រូវគេវាយដោយដំបង ព្រោះសោកស្ដាយក្សត្រទាំង ៤ អង្គ ជាទីស្រឡាញ់ដែលព្រាត់ប្រាសទៅ ទ្រង់ពិរោធយ៉ាងខ្លាំងនៅចំពោះមុខលោកសេនាប្រមុខមហោសថ ហើយបានពោលថា “សេចក្ដីទុក្ខរបស់អញនេះ បានកើតឡើងអាស្រ័យមហោសថ”។ ចំណែកមហោសថឃើញអាការរបស់ស្ដេចចូឡនីដូច្នោះ គិតថា “ស្ដេចអង្គនេះជាអ្នកមានយសធំ អាចបៀតបៀនអញក្នុងពេលណាក៏បាន ដោយមានះថា ទ្រង់ជាអគ្គរាជ។ ក្សត្រទាំង ៤ អង្គនោះ នឹងមានប្រយោជន៍ដល់ទ្រង់ ដូច្នោះមានតែអញពណ៌នាពីសម្បុរនៃសរីរកាយរបស់ព្រះមហេសីនន្ទាទេវី ធ្វើឲ្យដូចជាស្ដេចអង្គ នេះមិនធ្លាប់ឃើញព្រះនាងពីមុនមក។ កាលបើដូច្នេះ ស្ដេចចូឡនីអង្គនោះនឹងនឹកព្រះនាងនន្ទាទេវី ទ្រង់នឹងមានព្រះ

[១៩៨] ឆ្ឌិតគាមសទិសំ សុសានភូមិយំ វិយ ច និស្សិរិកំ រាជនិវេសនញ្ច ទិស្វា។

តម្រិះថា ប្រសិនបើអញសម្លាប់មហោសថ អញនឹងមិនបានស្រីកែវបែបនោះទេ តែបើអញមិនសម្លាប់គេទេ អញនឹងបានស្រីកែវនោះទៀត ដោយសេចក្ដីស្រឡាញ់មហេសីរបស់ខ្លួនៗ ព្រះអង្គនឹងមិនធ្វើអ្វីៗ ចំពោះអញឡើយ”ៗ លុះគិតដូច្នេះហើយ មហោសថឈរលើប្រាសាទដើម្បីការពារខ្លួន បានបញ្ចេញដើមដៃមានពណ៌ដូចមាស ចេញអំពីចន្លោះសំពត់កម្ពលពណ៌ក្រហម ត្បារដៃពិពណ៌នាទាក់ទងនឹងការឃើញផ្លូវទៅរបស់ព្រះអគ្គមហេសីនន្ទាទេវីថា៖

“បពិត្រមហារាជ ព្រះនាងនន្ទាទេវី មានព្រះសព៌ាង្គកាយដ៏ល្អ មានព្រះសោណី(ត្រគាក)ដ៏ល្អដូចជំបារមាស[១៩៩] មានប្រក្រតីពោលពាក្យពីរោះ ដូចសំឡេងសត្វហង្ស បានយាងចេញពីរាជវាំងនេះហើយៗ បពិត្រមហារាជ ព្រះនាងមានសព៌ាង្គកាយដ៏ល្អល្អះ ទ្រទ្រង់កោសេយ្យពស្ត្រ(សំពត់សូត្រ) មានសរីរៈដូចមាស មានខ្សែរឹតព្រះកាយដ៏ល្អវិចិត្រដោយមាសៗ ព្រះនាងមានព្រះបាទក្រហមល្អ ប្រកបដោយលម្អ ៥ យ៉ាង មានខ្សែរឹតដែលធ្វើពីមាសនិងកែវមណី មានដួងព្រះនេត្រាហាក់ដូចជាភ្នែកសត្វព្រាប មានសរីរៈដ៏ល្អ មានរីមព្រះឱស្ឋ(បបូរមាត់)

---

[១៩៩] ជំបារមាស (ន.) ផ្ទាំងមាសៗ

រលីងល្អដូចផ្លែទន្លាប់ៗ ព្រះនាងមានចង្កេះរាងរៀវ ដូចវល្លិនាគលតា ដែលលូតលាស់ល្អ ដូចក្ដារហ៊ឹងជាវិការៈនៃមាស ព្រះកេសាវែង មានចុងខ្មៅបន្តិចដូចចុងកាំបិតៗ ព្រះនាងនន្ទាទេវី មានដួងព្រះនេត្រថ្លាយង់ ហាក់ដូច ជាភ្នែកនៃកូនម្រឹគកើតបាន មួយខួបឬដូចជាអណ្ដាតភ្លើងក្នុងហេមន្តរដូវ ពុំនោះសោតបីដូច ជាស្ទឹងដ៏ដេរដាសដោយដើមឫស្សីតូចៗ ទាំងឡាយនៅទៀប ជ្រោះភ្នំៗ ព្រះនាងនន្ទាទេវី មានព្រះឧរូ[២០០]ល្អ ដូចប្រមោយដំរី ព្រះស្ដន[២០១] ទាំងគូល្អដូចផ្លែទន្លាប់ដ៏ប្រសើរ មិនធំពេក មិនតូចពេក មានព្រះលោមា មិនច្រើនពេក មិនតិចពេក”ៗ

កាលមហោសថពណ៌នាពីរូបសម្បត្តិ របស់ព្រះមហេសីនន្ទាទេវី យ៉ាងនេះ រូបរាងព្រះនាងហាក់ដូចអប្សរមួយរូប ដែលស្ដេចចូឡនីអគ្គ

---

[២០០] ឧរូ នេះជារាជសព្ទប្រើហៅប៉ែកជើងពីត្រឹមខាងលើជង្គង់ឡើងមកដល់ក្រលៀនៗ សាមញ្ញជនយើង ហៅថា ភ្លៅៗ នេះឯងៗ

[២០១] ដោះឬកន្សោមដោះៗ គួរឈប់សរសេរឬនិយាយថាសុដន់ៗទៀតទៅៗ ដូចបាន ពន្យល់ខាងដើមហើយថា ត របស់ភាសាបាលីឬសំស្ក្រឹត កាលអានជាខ្មែរត្រូវអាន ជាសំនៀង ដ ជាដរាប ដូច្នេះពាក្យ ស្ដន នេះត្រូវអានជាជើងដ អានឲ្យរហ័ស ដូច យើងអាន សសរស្ដម្ភ, ស្ដុកស្ដម្ភ អ៊ីចឹងៗ យើងមិនអានសសរសុដំឬសុដុកសុដំទេ តាមក្បួនដូច្នេះ ស ជើង ត ដល់ ន នេះ (ស្ដន) ហាមអាន សុដន់ៗ ដាច់ខាតៗ

នោះមិនធ្លាប់បានទតពីមុនមក និងហាក់ដូចលេចធ្លោចំពោះព្រះកក្រួផង ដែរ ដូច្នេះហើយ ទ្រង់រឹងរឹតតែមានសេចក្ដីស្នេហាខ្លាំងឡើងៗចំពោះ ព្រះអគ្គមហេសី។ មហោសថដឹងថា ស្ដេចចូឡនីកើតសេចក្ដីស្នេហា រឹតតែខ្លាំងចំពោះអគ្គមហេសី ក៏បានពោលបន្ថែមដូច្នេះថា៖

"បពិត្រព្រះអង្គមានពាហនៈនិងសម្បត្តិដ៏ច្រើន ព្រះអង្គពិតជា សប្បាយព្រះទ័យនឹងព្រះអគ្គមហេសីនន្ទាទេវី ដែលសោយព្រះ វិលាល័យជាមួយនឹងទូលបង្គំ បើដូច្នេះ ទូលព្រះបង្គំជាខ្ញុំនិងព្រះ នាងនន្ទាទេវីច្បាស់ជាបានទៅកាន់ឋានយមរាជជាមួយគ្នាពុំខាន"។

ការពណ៌នាទាំងប៉ុន្មានដែលលើកមកខាងលើនេះ គឺមហោសថ ពណ៌នាតែពីព្រះនាងនន្ទាទេវី ក្នុងទិដ្ឋភាពជាក់ស្ដែងប៉ុណ្ណោះ មិនបាន ពណ៌នាក្សត្រិយ៍ ៣ អង្គទៀតទេ។ ព្រោះហេតុអ្វី? ពីព្រោះថា ជាធម្មតា សត្វទាំងឡាយ មិនធ្វើសេចក្ដីអាឡោះអាល័យចំពោះមនុស្សផ្សេងៗ ឲ្យស្មើនឹងកិរិយាជាទីស្រឡាញ់ឡើយ។ កាលរលឹកម្ដាយហើយ មុខតែ ព្រះរាជានឹកដល់ព្រះរាជបុត្ររាជធីតាពុំខាន ព្រោះហេតុនោះហើយ មហោសថពណ៌នាតែព្រះមហេសីនន្ទាទេវី ប៉ុន្តែព្រះរាជមាតាលោកក៏ មិនបានពណ៌នាដែរ ព្រោះព្រះមាតាមានវ័យចាស់ហើយ។ មហោសថ

ជាមនុស្សមានប្រាជ្ញាច្រើន ពណ៌នាដោយសម្ដីផ្អែមដូចទឹកឃ្មុំ ហាក់ដូចជាព្រះអគ្គមហេសីនន្ទាទេវីឈរចំពោះព្រះភក្ត្រនៃស្ដេចចូឡនី។

**មហោសថលួងលោមស្ដេចចូឡនី**

គ្រានោះ ស្ដេចចូឡនីគិតថា "លើកលែងមហោសថចេញ ពុំមានអ្នកណាមានសមត្ថភាពអាចនាំមហេសីរបស់អញមកវិញបានទេ"។ គ្រានោះ ស្ដេចចូឡនីសោកស្ដាយមហេសីនន្ទាទេវីខ្លាំងណាស់ ទ្រង់ពុំគិតពីអ្វីឡើយ នឹកតែព្រះមហេសីតែម្យ៉ាង។ ទើបមហោសថលួងលោមស្ដេចចូឡនីនោះថា៖

"កុំបារម្ភអ្វីឡើយមហាបពិត្រ ក្សត្រិយ៍ទាំង ៣ អង្គគឺ ព្រះទេវី១ រាជបុត្រ១ ព្រះមាតា១ នឹងយាងមករកព្រះអង្គវិញ លុះតែមានដំណើរនៃទូលបង្គំជាខ្ញុំ ទៅដល់ទីនោះជាកំហិតសិន[២០២] ព្រោះហេតុនោះ សូមព្រះអង្គចូរព្រះទ័យវិញចុះ ព្រះនរិន្ទ"។

គ្រានោះ ស្ដេចចូឡនីព្រះតម្រិះថា "អញបានឲ្យគេគ្រប់គ្រងរក្សានគររបស់អញយ៉ាងល្អហើយ ទើបអញដឹកនាំទ័ពនិងពាហនៈប៉ុណ្ណេះមកឈរជើងឡោមព័ទ្ធនូវរាជដំណាក់ថ្មីនេះ ចុះហេតុដូម្ដេចបានជា

---

[២០២] ទេវី ច តេ បុត្តោ ច មាតា ច តយោបិ អាគច្ឆិស្សន្តិ មម គមនមេវេត្ថ បមាណំ។

មហោសថបណ្ឌិតនេះ គេចាប់អគ្គមហេសីអញ កូនអញ ម្ដាយអញ អំពីនគរអញ ដែលគ្រប់គ្រងយ៉ាងតឹងរឹងបែបនេះ ទៅថ្វាយដល់ស្ដេចវិទេហៈរបស់គេបាន? មួយវិញទៀត កាលបើអញកំពុងឈរជើងឡោមព័ទ្ធជុំជិតយ៉ាងនេះ ហេតុអ្វីបានគេរំដោះស្ដេចវិទេហៈ ព្រមទាំងទាហាននិងពាហនៈ ឲ្យរត់រួចខ្លួនបានដោយគ្មានទាហានអញណាម្នាក់ដឹងឡើយ គេចេះកលល្បិចទិព្វ ឬចេះវិជ្ជាបំបាំងភ្នែកទេដឹង?" ទើបសួរទៅមហោសថថា៖

"តើអ្នកបានរៀនកលល្បិចទិព្វ ហើយបានធ្វើឧបាយបំបាំងភ្នែក ឬបានជាអ្នករំដោះព្រះបាទវិទេហៈជាសត្រូវនៅក្នុងកណ្ដាប់ដៃរបស់យើងបាន?"

លោកសេនាប្រមុខមហោសថក្នុងប្រាជ្ញ បានក្រាបទូលតបថា៖

"ទូលបង្គំជាខ្ញុំ ចេះនូវកលឧបាយទិព្វពិតមែន ដែលហៅថាបណ្ឌិតរមែងរៀននូវកលឧបាយទិព្វ កាលបើភ័យមកដល់បណ្ឌិតនោះតែងញ៉ាំងខ្លួនផង អ្នកដទៃផងឲ្យរួចចាកទុក្ខបាន"។

រួចមហោសថពោលបន្តថា៖

"បពិត្រមហារាជ បណ្ឌិតទាំងឡាយក្នុងលោកនេះ រមែងរៀននូវកលល្បិចជាទិព្វដោយពិត ពួកបណ្ឌិតជនអ្នកមានវិជ្ជាខ្ពស់នោះ

ទើបដោះខ្លួនចាកទុក្ខបាន។ ពួកយោធាក្មេងៗ ជាអ្នកបម្រើរបស់ទូលព្រះបង្គំ សុទ្ធសឹងតែជាអ្នកឈ្លាស ជាអ្នកកាត់ផ្តាច់នូវទីត (ទម្លាយនូវឧបសគ្គ)។ ពួកទាហានទាំងនោះបានយាងព្រះបាទវិទេហៈទៅកាន់ក្រុងមិថិលាតាមឧម្មង្គដែលទូលបង្គំបានរៀបចំទុកហើយ”។

## មហោសថយាងស្ដេចចូឡនីទតឧម្មង្គ

ស្ដេចចូឡនីសណ្ដាប់ដូច្នោះ ទ្រង់មានបំណងចង់ទតនូវឧម្មង្គនោះ បានត្រាស់នឹងមហោសថថា “បានឮថាស្ដេចវិទេហៈយាងទៅតាមឧម្មង្គ តើឧម្មង្គនោះមានលក្ខណៈយ៉ាងម៉េចទៅ?” គ្រានោះ លោកសេនាប្រមុខមហោសថ ដឹងព្រះរាជបំណងរបស់ព្រះបាទចូឡនីថា “ព្រះអង្គមានរាជបំណងចង់ទតមើលនូវឧម្មង្គ បើដូច្នេះ អញនឹងយាងព្រះអង្គទតឧម្មង្គនោះ” រួចលោកសេនាប្រមុខបានក្រាបទូលស្ដេចថា៖

> “បពិត្រមហារាជ សូមព្រះអង្គស្ដេចទតនូវឧម្មង្គដ៏ល្អ ដែលពួកជាងសាងហើយ មានពន្លឺតែមួយ ប្រាកដដូចទេវសភាដ៏ស្រស់ត្រកាល ល្អៗ រំលេចដោយរបៀបនៃដំរី សេះ រថ និងពលថ្មើរជើង”។

លុះពេលយ៉ាងនេះហើយ មហោសថបានបញ្ជាពួកឆ្មាំទ្វារឲ្យបើកទ្វារព្រះរាជដំណាក់ ទូលស្តេចចូឡនីឲ្យយាងចូលដោយពាក្យថា៖

"បពិត្រមហារាជ ឧម្មង្គដ៏ស្រស់ត្រកាលប្រាកដដូចទីរះឡើងនៃព្រះចន្ទនិងព្រះអាទិត្យ គឺស្ថាបនាឡើងដោយប្រាជ្ញារបស់ទូលព្រះបង្គំជាខ្ញុំ។ ក្នុងនោះមានទ្វារធំ ៨០ ទ្វារតូច ៦៤ បន្ទប់ជាក្រឡាបន្ទំ ១០១ បន្ទប់ អំពូលភ្លើង[២០៣]រាប់រយ សូមស្តេចយាងទតក្រាបទូល។ សូមព្រះអង្គ ព្រមទាំងពួកទ័ពព្រះអង្គយាងទតឧម្មង្គដោយសេចក្តីសប្បាយរីករាយជាមួយនឹងទូលបង្គំចុះក្រាបទូល"។

ស្តេចចូឡនី យាងចូលឧម្មង្គ ដោយមានស្តេច ១០១ អង្គជាបរិវារ។ ព្រះអង្គទ្រង់បានទតឃើញឧម្មង្គដូចជាទេវសភា ទ្រង់បានសរសើរគុណរបស់លោកសេនាប្រមុខមហោសថថា៖

"ម្នាលមហោសថ លោកជាលាភរបស់អ្នកជនបទដែលជាទីកើតឡើងនៃសួយសាអាករក្នុងដែនវិទេហៈដោយពិត។ បណ្ឌិតទាំងឡាយដែលឈ្លាសក្នុងយុទ្ធសាស្ត្រ ដូចជាអ្នកនេះ ទោះនៅក្នុងសម្នាក់ក្តី ផ្ទះមួយក្តី ជនបទមួយក្តី រដ្ឋមួយក្តី គឺជាលាភដោយ

---

[២០៣] អនេកសតទីបគព្ភោ។

ពិតរបស់ព្រះរាជាអង្គនោះ។ អ្នកដែន អ្នកជនបទ អ្នកនគរ ឬមនុស្សក្នុងគ្រួសារ ដែលបាននៅរួមជាមួយនឹងបណ្ឌិតដូចជារូបអ្នក គឺពួកគេហៅពេញជាបានលាភ។ អ្នកដែនវិទេហៈផងអ្នកក្រុងមិថិលាផង ដែលពួកគេបានរស់នៅរួមជាមួយនឹងអ្នក ហៅពេញជាអ្នកមានលាភណាស់ហ្ន៎”។

**មហោសថខាងជាង[២០៤]គំរាមស្ដេចចូឡនី**

តមក មហោសថបង្ហាញបន្ទប់ក្រឡាបន្ទំ ១០១ បន្ទប់ ថ្វាយព្រះបាទចូឡនីទ្រង់ទត។ កាលដែលទ្វារបន្ទប់មួយបើក ទ្វារបន្ទប់ទាំងអស់ក៏បើកព្រមគ្នា។ កាលដែលទ្វារបន្ទប់មួយបិទ ទ្វារបន្ទប់ទាំងអស់ក៏បិទព្រមគ្នាដែរ។ ព្រះរាជាទតមើលឧម្មង្គបណ្ដើរ ទ្រង់យាងទៅមុខបណ្ដើរ ចំណែកមហោសថដើរតាមពីខាងក្រោយជាប់។ កងប្រដាប់អាវុធគ្រប់ជាន់ថ្នាក់ទាំងអស់ ក៏ចូលទៅកាន់ឧម្មង្គហ្នឹងដែរ។ ព្រះបាទចូឡនី ទ្រង់យាងចេញផុតពីឧម្មង្គ។ លោកសេនាប្រមុខមហោសថ ដឹងថាស្ដេចអង្គនោះចេញផុតពីឧម្មង្គហើយ លោកក៏ចេញទៅតាមដែរ ព្រមទាំងបានជាន់គន្លឹះបិទទ្វារឧម្មង្គមិនឲ្យជនផ្សេងៗក្នុងនោះចេញមកបាន”។ រំពេចនោះឯង ទ្វារធំ ៨០ ទ្វារតូច ៦៤ ទ្វារបន្ទប់ក្រឡាបន្ទំ ១០១ និង

[២០៤] ងា (កិ.) លើដៃឡើងជន្ទ ឬលើកដៃវាសវង់លំទាំគុន : ងាដៃ, ងាដាវជន្ទ។

អំពូលភ្លើងរាប់រយនោះ បានបិទនិងរលត់ជំណាលគ្នា។ ឧមង្គទាំងមូល ប្រែក្លាយជាងងឹតសូន្យឈឹង បីដូចលោកន្តរនរក។ មហាជនដែលជាប់ នៅក្នុងនោះម្នាក់ៗភិតភ័យតក់ស្លុត។ លោកសេនាប្រមុខមហោសថ ចាប់ទាញព្រះខាន់ដែលកប់ទុកក្នុងដីខ្សាច់ ដែលលោកបានលាក់ទុក កាលពីម្សិលមិញ រួចលោកលោតបំផ្លោងខ្លួនទៅឰដ៏អាកាសបាន កម្ពស់ ១៨ ហត្ថអំពីផែនដី រួចលោកបាន ចាប់ព្រះហស្តរបស់ស្តេច ចូឡនីជាប់ ងាដាវឡើងសួរសម្លុតព្រះអង្គថា៖

"បពិត្រមហារាជ រាជសម្បត្តិក្នុងសកលជម្ពូទ្វីប តើជារបស់ នរណា?"

ស្តេចចូឡនីភ័យញ័រមាត់ត្រាស់រដិបរដុបថា៖

"បពិត្របណ្ឌិត របស់លោកៗ សូមលោកឲ្យអភ័យដល់យើង ផង កុំសម្លាប់យើង"។

មហោសថទូលតបថា៖

"កុំខ្លាចឡើយ មហារាជ មិនមែនទូលបង្គំចាប់ដាវងាឡើង ដោយមានបំណងធ្វើឃាតព្រះអង្គទេ ទូលបង្គំគ្រាន់តែងាឡើង ក្នុងគោលបំណងបង្ហាញអានុភាពនៃបញ្ញារបស់ទូលបង្គំប៉ុណ្ណោះ"។

និយាយដូច្នេះហើយ សេនាប្រមុខហុចព្រះខាន់ថ្វាយទៅព្រះបាទចូឡនី ហើយមហោសថពោលថា៖

"បពិត្រមហារាជ ប្រសិនបើព្រះអង្គមានបំណងចង់សម្លាប់ទូលបង្គំ សូមព្រះអង្គសម្លាប់ទូលបង្គំដោយព្រះខាន់នេះ ឥឡូវនេះមកចុះ ក្រាបទូល បើព្រះអង្គចង់ប្រទានអភ័យ សូមប្រទានអភ័យមកចុះ មហាបពិត្រ"។

**មហោសថនិងស្តេចចូឡនីធ្វើសម្បថ**

ព្រះបាទចូឡនីទ្រង់ដាក់ដាវចុះ ហើយត្រាស់ថា៖

"បពិត្របណ្ឌិត សូម្បីយើងក៏ប្រទានអភ័យចំពោះអ្នកដែរ អ្នកកុំព្រួយបារម្ភអ្វីឡើយ"។

ជនទាំងពីររូប បានធ្វើសម្បថចំពោះគ្នាទៅវិញទៅមកថា នឹងមិនឲ្យមានភាពប្រទូសរ៉ាយគ្នាតទៅថ្ងៃក្រោយទៀតឡើយ។ គ្រានោះ ស្តេចចូឡនីត្រាស់សួរមហោសថថា៖

"បពិត្របណ្ឌិត លោកបរិបូរដោយកម្លាំងញាណ ហេតុម្តេចបានជាអ្នកមិនច្បាំងដណ្តើមយករាជ្យពីយើងទៅ?"

មហោសថ ក្រាបទូលថា៖

"បពិត្រមហារាជ បើទូលព្រះបង្គំជាខ្ញុំប្រាថ្នាធ្វើឃាតស្តេចទូទាំងជម្ពូទ្វីបក្នុងថ្ងៃនេះ ហើយយករាជ្យឥឡូវនេះក៏បានដែរ ក៏ប៉ុន្តែការដណ្តើមយសដោយសម្លាប់អ្នកដទៃ គឺបណ្ឌិតទាំងឡាយមិនសរសើរទេ"។

## ស្តេច ១០១ អង្គ ស្ញើចសរសើរមហោសថ

ស្តេចចូឡនីទ្រង់មានបន្ទូលថា៖

"បពិត្របណ្ឌិត មហាជនដែលជាប់ក្នុងឧមង្គ ចេញមកក្រៅមិនរួច មុខតែពួកគេខ្សឹកខ្សួលខ្លាំងហើយ សូមលោកអញ្ជើញបើកទ្វារឧមង្គឲ្យជីវិតដល់មហាជនផង"។

មហោសថបានបើកទ្វារឧមង្គទាំងមូល ឲ្យមានពន្លឺឱកាស ភ្លឺមូលធ្លុងតែមួយ។ មហាជន បានដកដង្ហើមធូរស្រួល។ ស្តេចទាំងឡាយបានចេញមកជាមួយនឹងសេនារបស់ខ្លួន ហើយយាងមកជួបមហោសថ និងស្តេចចូឡនីក្នុងបន្ទប់ទទួលភ្ញៀវ។ គ្រានោះ ស្តេចទាំងឡាយនោះត្រាស់នឹងមហោសថថា៖

"បពិត្របណ្ឌិត ពួកយើងបានព្រះជន្មរស់ព្រោះអាស្រ័យអ្នក បើកុំតែបានអ្នកបើកទ្វារឧមង្គឲ្យធាប់ ម្ល៉េះសមពួកយើងសោយទិវង្គត នៅទីនោះបាត់អស់ទៅហើយ"។

មហោសថទូលតបវិញថា៖

"មិនមែនតែក្នុងកាលឥឡូវនេះទេ ក្រាបទូល ដែលពួកព្រះអង្គបានព្រះជន្ម ព្រោះអាស្រ័យទូលបង្គំ សូម្បីពីលើកមុន ក៏ពួកព្រះអង្គបានព្រះជន្ម ព្រោះអាស្រ័យទូលបង្គំដែរ"។

"ពីអង្កាល់ទៅ បណ្ឌិត?" ពួកស្ដេចសួរដោយឆ្ងល់។

មហោសថទូលថា៖

"ក្នុងកាលដែលស្ដេចចូឡនីជណ្ដីមរាជ្យបានទូទាំងសកលជម្ពូទ្វីប លើកលែងតែនគររបស់ទូលបង្គំមួយ ហើយទ្រង់យាងទៅកាន់ឧត្តរបញ្ចាលនគរ ចាត់ចែងរោងសុរាដើម្បីជប់លៀងសោយទឹកជយបានក្នុងឧទ្យាន តើពួកព្រះអង្គនឹកឃើញកាលនុះឬទេ?"

ពួកស្ដេចឆ្លើយថា៖

"អើមែនបណ្ឌិត ពួកយើងនឹកឃើញហើយ"។

មហោសថទូលបន្តថា៖

“ក្នុងកាលណោះ ព្រះបាទចូឡនីអង្គនេះ ហេតុតែទ្រង់ប្រឹក្សាខុសជាមួយនឹងកេវដ្តព្រាហ្មណ៍ ទ្រង់បានធ្វើកិច្ចដើម្បីធ្វើគុតពួកព្រះអង្គទាំងអស់ ដោយសុរាផង ដោយត្រីសាច់ផង ដែលសុទ្ធសឹងតែលាយដោយថ្នាំពុល។ កាលបើដូច្នេះ ខ្ញុំទូលបង្គំគិតថា កាលបើបណ្ឌិតដូចជាអញនៅមានជីវិតរស់ សូមស្ដេចទាំងនេះកុំសោយទិវង្គតឡើយ ទូលបង្គំបានបញ្ជូនពួកទាហានរបស់ទូលបង្គំ ឲ្យទៅវាយបំបែកកាជន៍ទាំងអស់ បំផ្លាញផែនការរបស់ស្ដេចចូឡនី និងកេវដ្តព្រាហ្មណ៍ចោល ថ្វាយជីវិតចំពោះព្រះអង្គគ្រប់ៗអង្គ”។

ស្ដេចទាំងអស់នោះ មានព្រះទ័យតក់ស្លុត រួចសួរទៅស្ដេចចូឡនីថា៖

“តើពិតដូចសម្ដីមហោសថមែនឬ មហាបពិត្រ?”

ស្ដេចចូឡនីត្រាស់ថា៖

“អើពិតដូច្នោះមែនហើយ យើងបានធ្វើអ៊ីចឹងដោយជឿសម្ដីកេវដ្ដៈ មហោសថនិយាយនោះ ពិតប្រាកដមែន មិនខុសទេ”។

ស្ដេចទាំងអស់ បានស្ទុះមកចោមរោមឱបមហោសថ ទាំងមានបន្ទូលយ៉ាងរំភើបថា៖

"បពិត្របណ្ឌិត លោកជាទីពឹងនៃយើងរាល់គ្នា យើងបានព្រះជន្មរស់វិញ ព្រោះអាស្រ័យលោកជាអ្នកការពារ"។

ត្រាស់ដូច្នេះហើយ ស្តេចទាំងឡាយបានធ្វើការបូជា ចំពោះមហោសថដោយគ្រឿងប្រដាប់ទាំងពួង យ៉ាងអធិកអធម។

មហោសថក្រាបទូលព្រះបាទចូឡនីថា៖

"បពិត្រមហារាជ កុំព្រួយព្រះទ័យអ្វីឡើយ នុ៎ះជាទោសនៃការគប់រកបាបមិត្រ គឺវាអ៊ីចឹងឯង។ សូមព្រះអង្គសូមខមាទោសចំពោះស្តេចទាំងឡាយនេះចុះ ក្រាបទូល"។

ព្រះបាទចូឡនីខមាទោសចំពោះមុខព្រះកក្រ្តស្តេចទាំងអស់ថា៖

"ទូលបង្គំបានធ្វើអំពើបែបនេះចំពោះពួកព្រះអង្គ ដោយអាស្រ័យបុរសថោកទាប។ នុ៎ះជាកំហុសរបស់ទូលបង្គំ។ សូមពួកព្រះអង្គមេត្តាអត់ទោសចំពោះទូលបង្គំ។ តទៅ ទូលបង្គំនឹងមិនធ្វើអំពើបែបនោះទៀតទេ"។

ស្តេចទាំងឡាយនោះ ខមាទោសចំពោះគ្នាទៅវិញទៅមក ព្រមព្រៀងគ្នាដោយសុទ្ធចិត្ត រីករាយសប្បាយឥតឧបមា។ គ្រានោះ ព្រះបាទចូឡនីបង្គាប់ឲ្យអ្នកបម្រើ នាំមកនូវខាទនីយភោជនីយាហារ (បាយ

ទឹក នំចំណី) គ្រឿងក្រអូប និងផ្កាកម្រងជាដើម ហើយទ្រង់ក្រសាល សប្បាយក្នុងឧម្មង្គនោះ ៧ ថ្ងៃ ជាមួយនឹងមហោសថព្រមទាំងពួកស្តេច និងកងប្រដាប់អាវុធទាំងអស់។ ស្តេចចូឡនី រៀបពិធីធ្វើសក្ការៈដ៏ ឧឡារិកជូនចំពោះលោកសេនាប្រមុខមហោសថ រួចទ្រង់គង់ប្រថាប់ ក្នុងប្រាសាទទេវាវិនិច្ឆ័យ មានស្តេច ១០១ អង្គជាបរិវារ។ គ្រានោះ ព្រះអង្គទ្រង់មានបំណងអញ្ជើញមហោសថឲ្យរស់នៅក្នុងសម្នាក់របស់ ព្រះអង្គ ដោយទ្រង់ត្រាស់ថា៖

> “យើងនឹងឲ្យគ្រឿងចិញ្ចឹមជីវិតនិងវត្ថុ គ្រឿងរក្សាគឺស្រុកនិង និគមទាំងបាយនិងថ្លៃឈ្នួលជាទ្វេគុណដល់អ្នក ទាំងឲ្យភោគ សម្បត្តិដ៏ច្រើនសន្ធឹកសន្ធាប់ទៀត។ អ្នកចូរបរិភោគ ចូររីករាយ តាមប្រាថ្នាចុះ អ្នកកុំទៅរកព្រះបាទវិទេហៈឡើយ តើព្រះបាទ វិទេហៈនឹងធ្វើអ្វីដល់អ្នក? យើងនឹងឲ្យអ្នកនូវភោគៈផ្សេងៗ យ៉ាងធំទូលាយ”។

**មហោសថសន្យានឹងស្តេចចូឡនី**

សេនាប្រមុខមហោសថ ក្រាបទូលជំទាស់នូវសេចក្តីស្នើនោះថា៖

> “បពិត្រមហារាជ បុគ្គលណា លះបង់នូវបុគ្គលអ្នកចិញ្ចឹម ព្រោះ ហេតុនៃទ្រព្យ បុគ្គលនោះត្រូវជនទាំងពីរគឺ ខ្លួនឯង១ អ្នកដទៃ១

តិះដៀល។ ព្រះបាទវិទេហៈទ្រង់គង់ព្រះជន្មនៅដរាបណា ទូលបង្គំ មិនគប្បីនៅក្នុងដែននៃព្រះរាជាដទៃ ដរាបនោះ។ បពិត្រមហារាជ បុគ្គលណាលះបង់នូវបុគ្គលអ្នកចិញ្ចឹមព្រោះហេតុនៃទ្រព្យ បុគ្គលនោះត្រូវជនទាំងពីរ គឺខ្លួនឯង១ អ្នកដទៃ១ តិះដៀល។ ព្រះបាទវិទេហៈឋិតនៅដរាបណា ទូលបង្គំមិនត្រូវជាមនុស្សរបស់បុគ្គលដទៃដរាបនោះ។ ខ្លួននឹងតិះដៀលខ្លួនឯងថា អញលះបង់បុគ្គលអ្នកចិញ្ចឹមខ្លួន ព្រោះហេតុតែទ្រព្យ អញឈ្មោះថាជាអ្នកធ្វើអំពើអាក្រក់។ ចំណែកអ្នកដទៃវិញ ក៏គង់តែតិះដៀលផងដែរថា នេះជាមនុស្សមានធម៌លាមក មនុស្សនេះលះបង់ចោលនូវបុគ្គល អ្នកចិញ្ចឹមខ្លួន ព្រោះហេតុតែទ្រព្យ។ ព្រោះហេតុដូច្នោះ កាលបើ ព្រះបាទវិទេហៈនៅមានព្រះជន្មនៅឡើយ គឺទូលបង្គំមិនអាច ដើម្បីនឹងរស់នៅក្នុងដែននៃស្តេចដទៃទេ ក្រាបទូល”។

គ្រានោះ ព្រះបាទចូឡនី ត្រាស់នឹងមហោសថថា៖

“ម្នាលបណ្ឌិត បើអ៊ីចឹង ចូរអ្នកប្តេជ្ញាចិត្តថាមកទីនេះចុះ ក្នុងពេលណាដែលស្តេចរបស់អ្នកចូលទិវង្គត”។

មហោសថក្រាបទូលថា៖

*"ប្រពៃណាស់ ព្រះសម្មតិទេព បើទូលបង្គំនៅរស់ ច្បាស់ជាទូលបង្គំនឹងត្រឡប់មកបម្រើព្រះអង្គវិញជាមិនខាន"។*

**មហោសថធ្វើមាតុភូមិនិវត្តន៍**

*លំដាប់នោះ ស្តេចចូឡនីធ្វើមហាសក្ការៈ ៧ ថ្ងៃ ជូនដល់សេនាប្រមុខមហោសថ។ លុះ ៧ ថ្ងៃនោះកន្លងផុតទៅ មហោសថក្រាបបង្គំលាព្រះអង្គធ្វើមាតុភូមិនិវត្តន៍វិលទៅប្រទេសកំណើតវិញ។ ស្តេចចូឡនីទ្រង់ត្រាស់ថា "ម្នាលបណ្ឌិត យើងនឹងប្រទានវត្ថុផ្សេងៗ មួយចំនួនដល់អ្នក" រួចទ្រង់ត្រាស់បន្តថា៖*

*"ម្នាលមហោសថ យើងប្រទាននូវមាសត្តោរ ១.០០០ និងស្រុកចំនួន ៨០ ដែលតែងបានសួយសាអាករ ១.០០០ កហាបណៈរៀងរាល់ឆ្នាំក្នុងដែនកាសី ជិតដែនស្តេចវិទេហៈរបស់អ្នកស្រាប់ យើងប្រទាននូវទាសី ៤០០ នាក់ និងភរិយា ១០០ នាក់ អ្នកចូរនាំអង្គនៃសេនាទាំងពួងទៅដោយសិរីសួស្តីចុះ"។*

*ចំណែកមហោសថវិញ បានក្រាបទូលស្តេចចូឡនីដែរថា៖*

*"បពិត្រមហារាជ សូមព្រះអង្គកុំព្រួយបារម្ភអំពីគ្រួសាររបស់ព្រះអង្គឲ្យសោះ ដ្បិតថា ក្នុងពេលស្តេចរបស់ទូលបង្គំរៀបចំដំណើរចេញទៅ ទូលបង្គំបានទូលផ្តែផ្តាំឲ្យស្តេចទូលបង្គំគោរព*

ព្រះមហេសីនន្ទាទេវីក្នុងឋានៈជាព្រះមាតា បញ្ចាលចន្ទក្នុងឋានៈជាប្អូនៗ ទូលបង្គំជាខ្ញុំ បានរៀបអភិសេករាជពិធីតារបស់ព្រះអង្គជាមួយស្តេចទូលបង្គំរួចស្រេចហើយ ទើបទូលបង្គំយាងស្តេចត្រឡប់ទៅនគរវិទេហៈវិញៗ ទូលបង្គំនឹងយាងព្រះមាតា ព្រះទេវី និងរាជបុត្រមកថ្វាយព្រះអង្គវិញ ក្នុងពេលឆាប់ៗខាងមុខនេះ ក្រាបទូល"ៗ

ស្តេចចូឡនីទ្រង់មានព្រះបន្ទូលថា៖

"ប្រពៃណាស់ បណ្ឌិត"ៗ

បន្ទាប់មក ព្រះអង្គបានផ្ញើវត្ថុផ្សេងៗ ចំពោះរាជពិធីតារបស់ព្រះអង្គ មានទាសី ទាសា ពស្ត្រាលង្ការ មាស ប្រាក់ ដំរី សេះ រទេះជាដើម ដែលសុទ្ធសឹងតែបានតុបតែងស្អាតស្រោប់ តាមរយៈមហោសថ ហើយទ្រង់ផ្តាំថា៖

"សូមបណ្ឌិត មេត្តាប្រគល់របស់អស់ទាំងនេះ ចំពោះបុត្រីយើងផង"ៗ

រួចទ្រង់ប្រកាសនូវកិច្ចការដែលត្រូវធ្វើ ចំពោះកងទ័ព និងពួកពាហនៈថា៖

"ជនទាំងឡាយ ចូរឲ្យវត្ថុផ្សេងៗជាទេយ្យគុណដល់ពួកដំរី ពួកសេះជាកំណត់ ចូរញ៉ាំងពលរថនិងពលថ្មើរជើង ដែលធ្វើដំណើរហត់នឿយតាមផ្លូវឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹកចុះ"។

លុះប្រកាសយ៉ាងនេះហើយ ទ្រង់បញ្ជូនបណ្ឌិតមហោសថទៅ ដោយត្រាស់ថា៖

"ម្នាលបណ្ឌិត អ្នកចូរនាំយកទ័ពដំរី ទ័ពសេះ ទ័ពរថ និងពួកពលថ្មើរជើងទៅ សូមថ្វាយព្រះពរដល់ព្រះបាទវិទេហមហារាជ សូមឲ្យព្រះអង្គបានទតឃើញអ្នកទៅដល់ក្រុងមិថិលានោះវិញដោយសុវត្ថិភាព"។

ដោយប្រការដូចដែលថ្លែងមកនេះ ស្តេចចូឡនីអង្គនោះ បានធ្វើសក្ការៈជាច្រើនដល់មហោសថបណ្ឌិត រួចអនុញ្ញាតឲ្យលោកចេញទៅ។ រីឯស្តេច ១០១ អង្គ ក៏ធ្វើសក្ការៈចំពោះមហោសថដែរ ទាំងបានប្រទាននូវគ្រឿងបណ្ណាការជាច្រើនផងដែរ។ និយាយពីបុរសឈ្លបការណ៍ដែលបង្កប់ខ្លួនក្នុងសម្នាក់ស្តេចទាំងនោះ ក៏តែងចោមរោមហែហមសេនាប្រមុខមហោសថ មិនលះបង់ចោលលោកឲ្យនៅម្នាក់ឯងមួយជំហានឡើយ។ មហោសថ កាលដែលមានបរិវារជាច្រើនហែហមហើយ លោកបានចេញដំណើរទៅ។ នៅតាមផ្លូវលោកតែងប្រើកងទ័ពមួយ

ចំនួនឲ្យទៅនាំយកសួយសារអាករអំពីស្រុកដែលស្ដេចចូឡនីប្រទាន ជាបណ្ដើរៗ រៀងរហូតដល់ដែនវិទេហៈ។ ចំណែកសេនកៈ បានប្រើ ពួកបុរសជំនិតរបស់ខ្លួនថា៖

"តើស្ដេចចូឡនី ដឹកនាំកម្លាំងទ័ពដេញតាមមកទៀត ឬក៏អត់ទេ បើដឹងហើយចូរមកប្រាប់យើងវិញភ្លាម ថាតើនរណាមកអឹក-អធិក ម្ល៉េះ?"

អ្នកបម្រើនោះបានទៅអស់ចម្ងាយផ្លូវ ៣ យោជន៍ បានជួបនឹង លោកសេនាប្រមុខមហោសថ រួចវិលត្រឡប់មកប្រាប់លោកសេនកៈ វិញថា៖

"លោកសេនាប្រមុខមហោសថ កំពុងតែធ្វើដំណើរមកហើយ ដោយមានកងទ័ពនិងបរិវារជាច្រើនមកជាមួយផង"។

លោកសេនកៈឮពត៌មាននោះហើយ លោកទៅកាន់ព្រះបរមរាជ វាំង។ គាប់ចួនពេលនោះ ព្រះបាទវិទេហរាជ កំពុងប្រថាប់ឈរលើផ្ទៃ ប្រាសាទ ចោលក្រសែនេត្រាគយគន់មើលទៅតាមបង្អួច ក៏ទ្រង់ទត យល់ជាក់ច្បាស់នឹងព្រះនេត្រ នូវកងទ័ពកំពុងធ្វើដំណើរមកយ៉ាង គគ្រឹកគគ្រេង ណែនណាន់តាន់តាប់ ទ្រង់ភ័យស្លុតថា "ទាហានរបស់

មហោសថបណ្ឌិតមានចំនួនតិចទេ ទាហាននេះមានចំនួនច្រើនក្រៃលែង ម៉្លេះ ស្តេចចូឡនីដឹកនាំកម្លាំងទ័ពមកទេដឹងហ្ន៎" រួចទ្រង់ត្រាស់សួរថា៖

"សេនាប្រកបដោយអង្គ ៤ គឺសេនាដំរី សេនាសេះ សេនារថ និងសេនាថ្មើរជើងនោះ ប្រាកដជាមានច្រើន មានសភាពគួរខ្លាច តើបណ្ឌិតទាំងឡាយសម្គាល់ដូចម្តេចហ្ន៎?"

គ្រានោះ សេនកៈក្រាបទូលថ្វាយព្រះរាជាឲ្យទ្រង់ជ្រាបថា៖

"បពិត្រមហារាជ សេចក្តីត្រេកអរយ៉ាងក្រៃលែង រមែងប្រាកដដល់ព្រះអង្គហើយ មហោសថកំពុងតែដឹកនាំអង្គសេនាទាំងពួងមកដល់ដោយសុវត្ថិភាពហើយ"។

ឮដូច្នោះ ស្តេចទ្រង់ត្រាស់តបថា៖

"នែសេនកៈ ទ័ពរបស់មហោសថ មានចំនួនតិចទេ ប៉ុន្តែនេះមានទ័ពដ៏ច្រើន"។

សេនកៈទូលតបថា៖

"បពិត្រមហារាជ ស្តេចចូឡនីអង្គនោះ ត្រូវលោកសេនាប្រមុខមហោសថធ្វើឲ្យជ្រះថ្លា ដោយសេចក្តីជ្រះថ្លានោះ ទ្រង់បានព្រះរាជទាននូវចតុរង្គសេនាចំពោះមហោសថថែមទៀត"។

**ពិធីស្វាគមន៍លោកសេនាប្រមុខមហោសថ**

ព្រះបាទវិទេហរាជ ចេញព្រះរាជបញ្ជាឲ្យគេទូងស្គរ ក្នុងនគរទាំងមូល ប្រកាសសេចក្ដីជូនដំណឹងថា៖

"សូមអ្នកក្រុងទាំងឡាយ តុបតែងលម្អនគរឲ្យមានសោភណភាព ធ្វើបដិសណ្ឋារៈទទួលស្វាគមន៍ដល់សេនាប្រមុខមហោសថបណ្ឌិត"។

អ្នកក្រុងទាំងឡាយបានធ្វើតាមព្រះរាជឱង្ការ។ លោកសេនាប្រមុខបានចូលទៅកាន់នគរ រួចឡើងទៅកាន់ព្រះបរមរាជវាំង ថ្វាយបង្គំព្រះមហាក្សត្រ ហើយអង្គុយក្នុងទីដ៏សមគួរ។ គ្រានោះ ព្រះរាជាក្រោកចាកបល្ល័ង្ក មកឱបលោកសេនាប្រមុខ ហើយទ្រង់យាងគង់លើបល្ល័ង្កវិញ ធ្វើសេចក្ដីសំណេះសំណាលថា៖

"ម្នាលមហោសថ ជន ៤ នាក់ សែងមនុស្សស្លាប់ទៅចោលក្នុងព្រៃស្មសាន ហើយត្រឡប់មកយ៉ាងណា ពួកយើងបោះបង់អ្នកចោលក្នុងដែនដែលគប្បីលះ ត្រឡប់មកក្នុងទីនេះក៏ដូច្នោះដែរ។ កាលបើដូច្នេះ អ្នកចេះរំដោះខ្លួនឲ្យរួចមក ដោយហេតុដូចម្ដេច ដោយបច្ច័យដូចម្ដេច ដោយដំណើរដូចម្ដេច?"

គ្រានោះ មហោសថក្រាបទូលតបថា៖

"បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំបានការពារនូវសេចក្ដី ដោយសេចក្ដីនូវការប្រឹក្សា ដោយការប្រឹក្សា ទូលព្រះបង្គំបានការពារស្ដេចដូចជាសាគរការពារជម្ពូទ្វីបដូច្នោះដែរ"។

សណ្ដាប់ដូច្នោះហើយ ព្រះរាជាត្រេកអរយ៉ាងខ្លាំង។ គ្រានោះមហោសថ បង្ហាញបណ្ណាការដែលស្ដេចចូឡនីប្រទានដល់ខ្លួនថា៖

"ព្រះបាទចូឡនី បានប្រទានមាសគ្ដោរ ១.០០០ និងស្រុកចំនួន ៨០ ក្នុងដែនកាសី ថែមទាំងប្រទានទាសី ៤០០ នាក់ និងករិយា ១០០ នាក់ ដល់ទូលព្រះបង្គំទៀតផង។ ទូលព្រះបង្គំជាអ្នកនាំអង្គសេនាទាំងពួងមកក្នុងទីនេះ ដោយសិរីសួស្ដី"។

គ្រានោះ ព្រះរាជារឹតតែត្រេកអរខ្លាំង បានបន្លឺនូវឧទាន សរសើរគុណរបស់មហោសថយ៉ាងនេះថា៖

"នៃសេនកៈ ការនៅរួមជាមួយនឹងអ្នកប្រាជ្ញ នាំមកនូវសេចក្ដីសុខស្រួលណាស់ហ្ន៎! មហោសថបានរំដោះពួកយើងដែលឋិតនៅក្នុងសេចក្ដីវិនាស គឺកណ្ដាប់ដៃនៃសត្រូវ ដូចជាគេដោះហ្វូងបក្សីជាប់នៅក្នុងទ្រុង ឬដូចជាគេដោះត្រីដែលជាប់នៅក្នុងសំណាញ់"។

សេនកៈ ពោលស្របតាមពាក្យរបស់ព្រះរាជាដែរថា៖

“បពិត្រមហារាជ ពិតមែន ការនៅរួមជាមួយនឹងអ្នកប្រាជ្ញ នាំមកនូវសេចក្ដីសុខស្រួលណាស់ហ្ន៎! មហោសថបានរំដោះពួកយើង ដែលឋិតនៅក្នុងសេចក្ដីវិនាស គឺកណ្ដាប់ដៃនៃសត្រូវដូចជាគេដោះហ្វូងបក្សី ដែលជាប់នៅក្នុងទ្រុង ឬដូចជាគេដោះត្រី ដែលជាប់នៅក្នុងសំណាញ់”។

គ្រានោះ ព្រះរាជាប្រកាសឲ្យអ្នកក្រុងលេងមហោស្រពទូទាំងនគរថា៖

“ចូរអ្នកក្រុងទាំងឡាយ លេងមហោស្រព ៧ ថ្ងៃ ជនទាំងឡាយណាដែលមានសេចក្ដីស្រឡាញ់ចំពោះយើង ជនទាំងអស់នោះ ចូរធ្វើសក្ការៈ សេចក្ដីរាប់អាន ចំពោះមហោសថចុះ”

ហើយទ្រង់ត្រាស់បន្ថែមថា៖

“ពួកជនចូរដេញពិណ ចូរវាយស្គរតូចនិងស្គរធំ ផ្លុំសង្ខដែលទិញពីដែនមគធៈ និងចូរវាយស្គរធំមានសំឡេងពីរោះ”។

គ្រានោះ អ្នកក្រុងផង អ្នកជនបទផង ដែលមានបំណងចង់ធ្វើសក្ការៈដល់មហោសថស្រាប់ លុះដល់ឮស្គរប្រកាសដំណឹងដូច្នោះ ពួកគេនាំគ្នាសម្រុកធ្វើយ៉ាងអឺកអធិកមែនទែន។

មុននឹងប្រកាសសេចក្តីនោះឲ្យជាក់ច្បាស់ ព្រះសាស្តាទ្រង់ត្រាស់ថា៖

*"ពួកស្រីស្នំ ពួកកុមារ ពួកវេស្សៈនិងពួកព្រាហ្មណ៍យកបាយនិងទឹកជាច្រើនមកជូនមហោសថបណ្ឌិត។ ពលដំរី ពលសេះ ពលរថ និងពលថ្មើរជើង យកបាយនិងទឹកជាច្រើន មកជូនមហោសថបណ្ឌិត។ ពួកអ្នកជនបទប្រជុំគ្នា និងអ្នកនិគមមកប្រជុំគ្នា យកបាយនិងទឹកជាច្រើន មកជូនមហោសថបណ្ឌិត។ ជនជាច្រើន កាលបើបានឃើញមហោសថបណ្ឌិតមកដល់ក៏មានសេចក្តីជ្រះថ្លា នាំគ្នាលើកទង់ឡើង ដើម្បីជាការអបអរសាទរចំពោះដំណើរ មាតុភូមិនិវត្តន៍របស់លោកសេនាប្រមុខមហោសថ"។*

## រាជវង្សស្តេចចូឡនីយានទៅនគរវិញ

ក្នុងពេលចប់មហោស្រព លោកសេនាប្រមុខមហោសថ មកកាន់ព្រះបរមរាជវាំង ក្រាបទូលព្រះបាទវិទេហៈថា៖

*"បពិត្រមហារាជ យើងគួរប្រញាប់យាងព្រះរាជមាតា ព្រះអគ្គមហេសីនន្ទាទេវី និងព្រះរាជបុត្ររបស់ព្រះបាទចូឡនី ទៅថ្វាយព្រះបាទចូឡនីវិញ ក្រាបទូល"។*

ព្រះបាទវិទេហៈទ្រង់ត្រាស់តបថា៖

“មិនជាប្លឺទេ ប៉ា ចូរអ្នកយាងក្សត្រទាំង ៣ អង្គទៅចុះ”។

លោកសេនាបតីមហោសថ បានធ្វើសក្ការៈដ៏ធំថ្វាយក្សត្រទាំង ៣ អង្គ និងបង្គាប់ឲ្យមន្ត្រីធ្វើសក្ការៈ និងធ្វើសេចក្តីរាប់អាន ដល់កងទ័ពទាំងឡាយ ដែលធ្វើដំណើរជាមួយនឹងខ្លួន រួចយាងក្សត្រទាំង ៣ អង្គនោះ ឲ្យទៅជាមួយនឹងពួកទ័ពរបស់ខ្លួន ដោយមានបរិវារជាច្រើនទៅជាមួយៗ រីឯកវិយាទាំង ១០០ នាក់ និងទាសាទាសី ៤០០ នាក់ ដែលស្តេចចូឡនីប្រទានដល់ខ្លួនផ្ទាល់នោះ មហោសថបានបញ្ជូនឲ្យទៅជាមួយនឹងព្រះមហេសីនន្ទាទេវីដែរៗ រីឯពួកកងទ័ពដែលមកជាមួយនឹងមហោសថនោះ មហោសថក៏បញ្ជូនឲ្យត្រឡប់ទៅក្រុងឧត្តរបញ្ចាលជាមួយនឹងពួកជនទាំងនោះដែរៗ ជនទាំងឡាយ និងបរិវារជាច្រើននោះបានធ្វើដំណើររហូតទៅដល់ឧត្តរបញ្ចាលនគរដោយសុវត្ថិភាពៗ

គ្រានោះ ព្រះបាទចូឡនីទូលសួរព្រះមាតាថា៖

“បពិត្រព្រះមាតា ស្តេចវិទេហៈ បានធ្វើសេចក្តីសង្គ្រោះដូចម្តេចខ្លះ ចំពោះព្រះមាតា?”

ព្រះរាជមាតាមានព្រះសវនីយ៍ថា ៖

"ថាម៉េចបុត្រ ស្តេចវិទេហរាជ បានតាំងទុកមាតាក្នុងឋានៈដូចជាទេវតា ហើយបានធ្វើនូវសក្ការៈ សុណិសានន្ទាទេវី តាំងទុកដូចម្តាយ បញ្ចាលចន្ទតាំងទុកដូចប្អូនប្រុសពៅ"។

ទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ព្រះបាទចូឡនីមានសោមនស្សត្រេកអរជាខ្លាំង។ បន្ទាប់មក ព្រះរាជាបានបញ្ជូនគ្រឿងបណ្ណាការជាច្រើនទៅថ្វាយដល់ព្រះបាទវិទេហរាជបន្ថែមទៀត។ តាំងពីគ្រានោះមក នគរទាំងពីរនោះ មានសេចក្តីរាប់អានគ្នា ព្រមព្រៀងគ្នា រីករាយស្រស់ស្រាយរកគ្នា រស់នៅជាសុខសន្តិភាពដ៏ក្សេមក្សាន្ត។

មហាឧមង្គកណ្ឌ ចប់ ។

# ជំពូកទី ១១

## ភក្ដីភាពរបស់មហោសថចំពោះស្ដេចចូឡនីព្រហ្មទត្ត

## ទករក្ខសបញ្ហា (ប្រស្នាអារក្សទឹក)

### មហោសថចូលគាល់បម្រើស្ដេចចូឡនី

*ព្រះនាងបញ្ចាលចន្ទី បានជាទីស្រឡាញ់ ជាទីសព្វព្រះហឫទ័យរបស់ព្រះបាទវិទេហៈ។ ក្នុងឆ្នាំទី ២ ព្រះនាងប្រសូតបានរាជបុត្រមួយអង្គ។ ក្នុងពេលរាជបុត្រនោះ ព្រះជន្ម ១០ វស្សា ព្រះបាទវិទេហៈទ្រង់សោយទិវង្គត។ លោកសេនាប្រមុខមហោសថ បានរៀបចំធ្វើពិធីរាជាភិសេកថ្វាយស្វេតច្ឆត្រ ចំពោះរាជបុត្រនោះឲ្យឡើងគ្រងរាជសម្បត្តិស្នងព្រះបិតា ទើបលោកក្រាបទូលលាព្រះរាជាថ្មីអង្គនោះថា៖*

*"បពិត្រព្រះសម្មតិទេព ទូលបង្គំជាខ្ញុំនឹងទៅកាន់សម្នាក់របស់ព្រះបាទចូឡនីដែលត្រូវជាព្រះអយ្យកោរបស់ព្រះអង្គ"។*

*ព្រះរាជាមានបន្ទូលថា៖*

*"បពិត្រលោកបណ្ឌិត សូមលោកកុំទៅចោលយើងឡើយ យើងនៅក្មេងណាស់ យើងនឹងតែងតាំងលោកក្នុងឋានៈជាព្រះបិតា នឹងរៀបចំធ្វើសក្ការៈជូនលោក"។*

*សុម្បីព្រះអង្គម្ចាស់ក្សត្រីបញ្ចាលចន្ទីក៏អង្វរមហោសថដែរថា៖*

"បពិត្របណ្ឌិត ក្នុងពេលលោកទៅបាត់ ពួកយើងនឹងពុំមាន
អ្នកណាម្នាក់ជាទីពឹងទេ សូមលោកកុំអញ្ជើញទៅអី"។

មហោសថទូលតបថា៖

"ទូលបង្គំបានសន្យា ចំពោះព្រះបាទចូឡនីរួចទៅហើយ ថានឹង
ត្រឡប់ទៅបម្រើព្រះអង្គវិញ នៅពេលដែលអស់ពីរជ្ជកាលព្រះ
បាទវិទេហៈ ដូច្នេះទូលបង្គំមិនអាចក្បត់ពាក្យសន្យានេះបានទេ"។

មហាជនកំពុងតែខ្សឹកខ្សួលមិនទាន់ស្រាកស្រាន្តផង មហោសថ
បាននាំពួកអ្នកបម្រើរបស់ខ្លួនចេញចាកមិថិលានគរ ធ្វើដំណើរទៅកាន់
ឧត្តរបញ្ចាលនគរ។ រីឯព្រះបាទចូឡនីទ្រង់បានជ្រាបនូវដំណើរមកដល់
របស់មហោសថ ព្រះអង្គទ្រង់បានយាងមកទទួលស្វាគមន៍ភ្លាម
អញ្ជើញមហោសថឲ្យចូលទៅកាន់នគរដោយរៀបចំទទួលយ៉ាងអធិក
អធម។ បន្ទាប់ពីនោះ ទ្រង់បានប្រទានគេហដ្ឋានដ៏ធំមួយដល់មហោសថ
សម្រាប់រស់នៅ បូករួមនឹងស្រុក ៨០ ដែលទ្រង់ព្រះរាជទានកាលពី
គ្រាមុន ចំណែកឋានៈឬព្រះរាជទ្រព្យក្រៅពីនេះ ទ្រង់មិនទាន់បាន
ប្រទាននៅឡើយ។ មហោសថ បាននៅបម្រើព្រះបាទចូឡនីអង្គនោះ
ចាប់ពីពេលនោះរៀងមក។

**ដូនជីបរិព្វាជិកាភេរី**

គ្រានោះ ដូនជីបរិព្វាជិកាម្នាក់ឈ្មោះ ភេរី ជាបណ្ឌិតមានប្រាជ្ញាវាងវៃ តែងនិមន្តមកឆាន់ចង្ហាន់ក្នុងព្រះរាជវាំង។ បរិព្វាជិកាភេរីនោះមិនធ្លាប់បានឃើញមហោសថទេ គឺគ្រាន់តែឮពាក្យតៗគ្នាមកថា "មហោសថបានមកនៅបម្រើព្រះបាទចូឡនី"។ ចំណែកមហោសថលោកក៏មិនធ្លាប់ឃើញបរិព្វាជិកាភេរីដែរ គ្រាន់តែធ្លាប់ឮពាក្យបរម្បរា (ឮតៗគ្នា)ថា "មានដូនជីបរិព្វាជិកាម្នាក់ឈ្មោះ ភេរី តែងនិមន្តមកឆាន់ចង្ហាន់ក្នុងព្រះបរមរាជវាំង"។

**មហាក្សត្រីនន្ទាទេវីរកកំហុសមហោសថ**

និយាយពីព្រះមហេសីនន្ទាទេវីវិញ មានព្រះទ័យមិនសប្បាយចំពោះមហោសថសោះ ពីព្រោះព្រះមហាក្សត្រីទ្រង់បានគិតថា "មហោសថធ្វើឲ្យយើងព្រាត់ប្រាសព្រះរាជធីតាជាទីស្រឡាញ់ យើងមានក្តីលំបាកដោយសារគេ"។ ដូច្នេះ ម្ចាស់ក្សត្រីបានបង្គាប់ស្ត្រីជំនិតចំនួន ៥០០ នាក់ ឲ្យព្យាយាមតាមដានចាប់កំហុសណាមួយរបស់មហោសថ ដើម្បីកម្ចាត់កម្ចាយគេចេញអំពីព្រះមហាក្សត្រ។ ស្ត្រី ៥០០ នាក់នោះ តែងដើរឃ្លាំមើលកំហុសរបស់មហោសថរហូត។

**មហោសថឆ្លើយសំណួរបរិព្វាជិកាភេរី**

តមកក្នុងថ្ងៃមួយ ដូនជីបរិព្វាជិកាភេរី ក្រោយពីឆាន់ចង្ហាន់រួចនាងបានចេញពីព្រះបរមរាជវាំង ប្រទះឃើញមហោសថកំពុងតែដើរមកកាន់រាជុបដ្ឋាន នៅនាព្រះលានហ្លួង។ រីឯមហោសថ ក៏បានឈរលើកដៃប្រណម្យសំពះដូនជីបរិព្វាជិកាភេរីនោះ។ បរិព្វាជិកាគិតថា "ព្រះគេនិយាយថា បុរសនេះជាបណ្ឌិត ដូច្នេះ អញនឹងល្បងមើលថាតើគេជាបណ្ឌិតមែនឬក៏មិនមែនហ្ន៎?" គិតដូច្នេះហើយ ក៏ក្រឡេកមើលទៅមហោសថ រួចសួរប្រស្នាដោយលាដៃឲ្យឃើញ។

ការលាដៃនោះជាសំណួរដែលដូនជីបានសួរតាមផ្លូវចិត្តថា៖

"យ៉ាងម៉េចដែរលោកបណ្ឌិត ព្រះរាជានាំអ្នកមកអំពីមិថិលានគរ

តើឥឡូវនេះ ព្រះអង្គបានទំនុកបម្រុងអ្នកហើយ ឬនៅ?"

មហោសថដឹងថា "បរិព្វាជិកានេះ សួរសំណួរអញដោយប្រើដៃជាកាយវិការទេតើ" លោកយល់ប្រស្នា ក៏ក្តាប់ដៃបង្ហាញវិញ។

មហោសថ ឆ្លើយប្រស្នានោះដោយចិត្តថា៖

"បពិត្រព្រះម៉ែម្ចាស់ ព្រះរាជាបានទទួលយកសេចក្តីប្តេជ្ញាអំពីខ្ញុំ

រួចទ្រង់ហៅខ្ញុំមក ឥឡូវនេះ ទ្រង់ក្តោបក្តាប់មាំទាំណាស់

មិនទាន់ព្រះរាជទានអ្វីៗ ដែលជាវត្ថុពិសេសដល់ខ្ញុំនៅឡើយទេ”។

បរិព្វាជិកាកេរី យល់ស្ថានការណ៍នោះហើយ ក៏លើកដៃអង្អែលក្បាលខ្លួនមុន ដែលនេះជាសញ្ញាបង្ហាញសំណួរថា៖

“បពិត្របណ្ឌិត ប្រសិនបើអ្នកលំបាក ម្ដេចក៏មិនបួសដូចខ្ញុំទៅ?”

មហោសថ យល់សំណួរយកដៃអង្អែលក្បាលពោះរបស់ខ្លួនជាសញ្ញាបង្ហាញនូវចម្លើយតបវិញថា៖

“បពិត្រព្រះម៉ែម្ចាស់ ប្រពន្ធ កូនដែលត្រូវចិញ្ចឹមរបស់ខ្ញុំមានចំនួនច្រើន ដូច្នោះ ខ្ញុំពុំអាចបួសបានទេ”។

ដូនជីបរិព្វាជិកាកេរីសួរប្រស្នាដោយប្រើដៃជាកាយវិការមានប្រមាណប៉ុណ្ណោះ ហើយក៏ដើរទៅកាន់លំនៅឋានរបស់ខ្លួន។ ចំណែកមហោសថ សំពះលាដូនជីបរិព្វាជិកាកេរីនោះ ហើយឡើងទៅកាន់រាជុបដ្ឋាន។

## កំណត់សម្គាល់

ដូនជីបរិព្វាជិកាកេរី ជាអ្នកមានបញ្ញាច្រើន ហើយជាទីប្រឹក្សាគួរជាទីទុកព្រះទ័យរបស់ព្រះបាទចូឡនី។

**ពួកស្ត្រីជំនិតញុះញង់ព្រះបាទចូឡនី**

និយាយពីពួកស្ត្រីជំនិតរបស់ម្ចាស់ក្សត្រីនន្ទាទេវី ដែលមានបេសកកម្មតាមដានទោះ ពួកនាងកំពុងតែឈរនៅត្រង់បង្អួច បានប្រទះឃើញនូវកិរិយារបស់បណ្ឌិតទាំងពីរនាក់ដូច្នោះ ក៏នាំគ្នាទៅកាន់សម្នាក់របស់ព្រះបាទចូឡនី ហើយញុះញង់ថា៖

"បពិត្រព្រះសម្មតិទេព មហោសថមានបំណងពួតដៃគ្នាជាមួយនឹងបរិព្វាជិកាកេវដ្ដដណ្ដើមរាជាណាចក្ររបស់ព្រះអង្គ គេពិតជាសត្រូវរបស់ព្រះអង្គហើយ"។

ព្រះរាជាត្រាស់សួរថា៖

"តើពួកនាងបានឃើញ ឬឮហេតុដូចម្ដេច បានជានាំគ្នានិយាយដូច្នេះ?"

ស្ត្រីទាំងនោះក្រាបទូលថា៖

"បពិត្រមហារាជ បរិព្វាជិកាធាន់ហើយ ដើរចុះមកជួបមហោសថចាត់ទុកព្រះអង្គស្មើនឹងបាតដៃ និងដូចជាលានស្រូវ[២០៥] នាងបានលាដៃជាសញ្ញាថា លោកមហោសថ អាចដណ្ដើមយករាជ្យ

[២០៥] ខលមណ្ឌល។

របស់ព្រះអង្គ ឲ្យនៅក្នុងកណ្ដាប់ដៃគេបាន។ រីឯមហោសថវិញ គាត់បានបង្ហាញនូវអាការៈកាន់ព្រះខាន់ គាត់បានធ្វើអាការៈក្ដាប់ដៃថា ពីរបីថ្ងៃទៀត គាត់នឹងកាត់ព្រះសិរសៈព្រះអង្គ ហើយដណ្ដើមយករាជាណាចក្រឲ្យនៅក្នុងកណ្ដាប់ដៃរបស់ខ្លួន។ បរិព្វាជិកានោះ លើកដៃខ្លួនអង្អែលក្បាលជាសញ្ញាប្រាប់មហោសថថា លោកចូរកាត់ក្បាលស្ដេចវិញ។ មហោសថអង្អែលពោះជាសញ្ញាថា ទេ គាត់នឹងកាត់ស្ដេចត្រង់ពាក់កណ្ដាលខ្លួនវិញ។ បពិត្រមហារាជ សូមព្រះអង្គកុំប្រហែសធ្វេសឲ្យសោះ គួរណាស់តែសម្លាប់ មហោសថនោះចោលទៅ”។

## ព្រះបាទចូឡនីសួរបរិព្វាជិកានិងមហោសថ

ព្រះបាទចូឡនីទ្រង់ព្រះសណ្ដាប់សម្ដីរបស់ស្ត្រីទាំងនោះហើយ ទ្រង់ព្រះតម្រិះថា “មហោសថបណ្ឌិត មិនអាចប្រទូស្តចំពោះអញបានទេ ចាំអញសួរបរិព្វាជិកានោះលមើល”។

ក្នុងថ្ងៃបន្ទាប់ ព្រះបាទចូឡនី ចូលទៅរកបរិព្វាជិកាភេរីក្នុងកាលដែលនាងឆាន់រួចហើយ ទ្រង់សាកសួរថា៖

“ព្រះម៉ែម្ចាស់ តើព្រះម៉ែម្ចាស់បានជួបមហោសថដែរឬទេ?”

បរិព្វាជិកាឆ្លើយថា៖

"មហាបពិត្រ កាលពីម្សិលមិញ បន្ទាប់ពីធាន់ទីនេះរួច នាងខ្ញុំចេញទៅ បានជួបមហោសថនៅតាមផ្លូវ"។

ព្រះរាជាសួរថា៖

"ចុះព្រះម៉ែម្ចាស់ បានសំណេះសំណាលអ្វីខ្លះជាមួយនឹងគេ?"

បរិព្វាជិកាឆ្លើយថា៖

"បពិត្រមហារាជ មិនមានការបរចាឆ្លើយឆ្លងគ្នាទេ ប៉ុន្តែនាងខ្ញុំឮអ្នកផងនិយាយថា គេជាបណ្ឌិត ដូច្នេះក៏បានសួរប្រស្នាគេដោយប្រើដៃជាកាយវិការ ក្នុងគោលបំណងថា បើគេជាបណ្ឌិតមែនគេនឹងយល់ប្រស្នានេះ នាងខ្ញុំបានលាដៃជាសញ្ញាសួរសំណួរថា នែបណ្ឌិត តើព្រះអង្គមានព្រះហស្តលាចំពោះអ្នកខ្លះឬទេ? ព្រះអង្គមិនមានព្រះហស្តក្តាប់ណែនទេឬ? តើទ្រង់បានសង្គ្រោះអ្វីខ្លះដល់អ្នកឬទេ? មហោសថ បានក្តាប់ដៃធ្វើជាសញ្ញាថា ព្រះអង្គទទួលសេចក្តីប្តេជ្ញាអំពីខ្ញុំ ទ្រង់ហៅខ្ញុំមក ព្រះអង្គមិនទាន់ប្រទានអ្វីនៅឡើយទេឥឡូវនេះ។ កាលបើដូច្នេះ នាងខ្ញុំអង្អែលក្បាល ជាសំណួរថា បើអ្នកលំបាកអ៊ីចឹង ម្តេចក៏មិនបួសដូចជានាងខ្ញុំទៅ? មហោសថអង្អែលពោះរបស់គេ

ជាចម្លើយថា គេពុំអាចបួសបានទេ ពីព្រោះគេមានប្រពន្ធកូនដែលត្រូវចិញ្ចឹមមានចំនួនច្រើន"។

ព្រះរាជាសួរថា៖

"បពិត្រព្រះម៉ែម្ចាស់ មហោសថជាបណ្ឌិតមែនឬទេ?"

បរិព្វាជិកាឆ្លើយថា៖

"ពិតមែនហើយ មហាបពិត្រ បុគ្គលលើផែនដីនេះ ដែលមានប្រាជ្ញាស្មើនឹងមហោសថនោះ មិនមានទេ"។

ព្រះរាជាព្រួសម្តីរបស់បរិព្វាជិកានោះហើយ ទ្រង់ថ្វាយបង្គំនិមន្តនាងត្រឡប់ទៅវិញ។

ក្នុងពេលនាងចេញផុត មហោសថចូលមកកាន់រាជុបដ្ឋាន។ គ្រានោះ ព្រះរាជាសួរគេថា៖

"នែបណ្ឌិត តើអ្នកបានជួបបរិព្វាជិកាភេរីដែរឬទេ?"

មហោសថឆ្លើយថា៖

"ព្រះករុណាថ្លៃវិសេស មហាបពិត្រ កាលពីម្សិលមិញ ទូលបង្គំជាខ្ញុំបានជួបនាងចេញពីទីនេះ នាងបានសួរប្រស្នាចំពោះទូលបង្គំ

ដោយប្រើដៃជាកាយវិការយ៉ាងនេះៗ ឯទូលបង្គំវិញ បានឆ្លើយប្រស្នានាង ដោយប្រើដៃជាកាយវិការតបទៅវិញដូចគ្នា"។

បន្ទាប់មក មហោសថបានក្រាបទូលរៀបរាប់តាមទំនងដែលដូនជីបរិព្វាជិកានោះបានក្រាបទូលរួចមួយសាហើយ។

## មហោសថទទួលតំណែងជាសេនាប្រមុខជាលើកទី ២

ក្នុងថ្ងៃនោះ ព្រះបាទចូឡនី ទ្រង់សព្វព្រះរាជហឫទ័យ ប្រោសប្រទាននូវឋានៈជាសេនាបតី និងប្រគល់កិច្ចការទាំងពួងដល់មហោសថបណ្ឌិត។ មហោសថ ក៏បានទទួលសក្តិយសដ៏ធំ។

ក្រោយពីបានទទួលឋានៈជាសេនាបតីហើយ មហោសថត្រិះរិះថា "ឋានៈបុណ្យសក្តិដ៏អស្ចារ្យដែលអញបានទទួលក្នុងពេលនេះ គឺជាបុញ្ញលាភដ៏ប្រសើរក្រៃលែង។ រីឯក្សត្រទាំងឡាយផ្សេងៗទៀត ប្រសិនបើមានព្រះបំណងនឹងសម្លាប់អញ ពួកទ្រង់ប្រាកដជាប្រើឧបាយដូចព្រះបាទចូឡនីដែរ។ ដើម្បីដឹងព្រះទ័យព្រះបាទចូឡនីថាតើព្រះអង្គសព្វព្រះរាជហឫទ័យចំពោះអញពិតមែនឬក៏អត់នោះ អញត្រូវតែធ្វើការពិសោធព្រះទ័យព្រះរាជា។ ឯឧបាយដែលត្រូវពិសោធនោះ មានតែដូនជីភេរីជាបរិព្វាជិកាម្នាក់ប៉ុណ្ណោះ ដែលអាចដឹង អ្នកដទៃក្រៅពីនេះមិនអាចដឹងបានឡើយ"។ លុះគិតដូច្នេះហើយ លោកបានយកនូវ

បូជនីយវត្ថុដ៏ច្រើន មានគ្រឿងក្រអូបនិងផ្កាកម្រងជាដើម ទៅបូជានាងបរិព្វាជិកា ហើយនិយាយថា "បពិត្រព្រះម៉ែម្ចាស់ តាំងពីថ្ងៃ ដែលព្រះនាងបានក្រាបទូលពណ៌នាគុណរបស់ខ្ញុំ ថ្វាយព្រះមហាក្សត្រមក ព្រះអង្គទ្រង់សព្វព្រះទ័យយ៉ាងខ្លាំង ហើយប្រទានទូវយសដ៏ធំក្រៃលែងដល់ខ្ញុំ ប៉ុន្តែខ្ញុំមិនដឹងថា តើទ្រង់ប្រទានដោយភាពស្មោះត្រង់ពិត ឬក៏យ៉ាងណាទេ រឿងនេះមានតែព្រះម៉ែម្ចាស់ជួយរកឧបាយណាមួយ ដោយព្រះតម្រិះរបស់ព្រះនាងដើម្បីស្វែងយល់អំពីសេចក្ដីស្រឡាញ់របស់ព្រះអង្គ ដែលមានចំពោះខ្ញុំ"។

**បរិព្វាជិកាសួរប្រស្នាអារក្សទឹកចំពោះស្តេចចូឡនី**

បរិព្វាជិកាព្រមទទួលធ្វើកិច្ចការជូនមហោសថ។ លុះថ្ងៃបន្ទាប់កាល នាងកំពុងដើរទៅកាន់ព្រះបរមរាជវាំង នាងបាននឹករកឃើញនូវប្រស្នាមួយ ហៅថា ទករក្ខសបញ្ហា គឺប្រស្នានិយាយពីអារក្សទឹកចាប់មនុស្សយកទៅស៊ី។ នាងមានសេចក្ដីត្រិះរិះយ៉ាងនេះថា "អញនឹងធ្វើជាចារបុរសសួរប្រស្នា ចំពោះព្រះរាជាដោយចង់ដឹងថា ព្រះរាជាមានព្រះទ័យស្មោះត្រង់ចំពោះសេនាបតីមហោសថ ឬក៏អត់ទេ"។ លុះទៅដល់រាជវាំង ឆាន់រួច នាងមិនបានត្រឡប់ទៅវិញភ្លាមៗទេ នៅរង់ចាំ

ទូលសួរព្រះរាជាសិន។ ចំណែកព្រះរាជាថ្វាយបង្គំនាងហើយទ្រង់ប្រថាប់គង់ ក្នុងទីដ៏សមគួរ។ បរិព្វាជិកាមានសេចក្តីត្រិះរិះដូច្នេះថា៖

“ប្រសិនណាបើ ព្រះរាជាមានហឫទ័យប្រទូស្តទៅលើមហោសថបណ្ឌិត ដូច្នេះនៅពេល ដែលអញសួរប្រស្នាហើយ ទ្រង់នឹងប្រាប់នូវភាពនៃចិត្តប្រទូស្តរបស់ព្រះអង្គក្នុងចំណោមមហាជនហ្នឹងឯង នោះជារឿងមិនសមរម្យទាល់តែសោះ អញនឹងសួរប្រស្នាព្រះអង្គ ក្នុងទីស្ងាត់វិញ” រួចនាងពោលថា៖

“នាងខ្ញុំត្រូវការទីស្ងាត់ដើម្បីពិគ្រោះជាមួយនឹងមហាបពិត្រ”។ ព្រះរាជាបញ្ជាឲ្យមនុស្សទាំងឡាយចាកចេញពីទីនោះសិន។ គ្រានោះបរិព្វាជិកាមានប្រសាសន៍នឹងព្រះរាជាថា៖

“បពិត្រមហារាជ នាងខ្ញុំសូមសួរនូវប្រស្នាមួយចំពោះព្រះអង្គ”។ ព្រះរាជាទ្រង់ត្រាស់ថា៖

“អញ្ជើញសួរមកចុះ ព្រះម៉ែម្ចាស់ បើខ្ញុំដឹង ខ្ញុំនឹងឆ្លើយ”។ គ្រានោះ បរិព្វាជិកាសួរទាក់ទងនឹងអារក្សទឹកដូច្នេះថា៖

“កាលពួកជនទាំង ៧ នាក់ របស់ព្រះអង្គ គឺព្រះរាជមាតារបស់ព្រះអង្គ១ មហេសីនន្ទាទេវី១ តិខិណមន្តិកុមារ១ ធនុសេខសម្លាញ់

១ បុរោហិត១ មហោសថ១ ខ្លួនព្រះអង្គផ្ទាល់១ ជិះទូកជាមួយគ្នា បានរសាត់ទៅក្នុងអន្លង់ទឹកដ៏ជ្រៅ។ អារក្សទឹក មានមហិទ្ធិឫទ្ធិ និងថាមពលខ្លាំងក្លា កាលស្វែងរកសំណែនរបស់មនុស្ស ក៏ជ្រែកទឹកចេញមកចាប់ទូករបស់ព្រះអង្គ លុះចាប់បានហើយ និយាយនឹងព្រះអង្គថា បពិត្រមហារាជ សូមព្រះអង្គប្រគល់ជន ទាំង ៦ នាក់នេះដល់ទូលបង្គំតាមលំដាប់មុនក្រោយ ទូលបង្គំ នឹងដោះលែងព្រះអង្គឲ្យមានសេរីភាព។ កាលបើដូច្នេះ តើព្រះ អង្គគប្បីឲ្យនរណាមុនគេដល់អារក្សទឹក ព្រះអង្គគប្បីឲ្យនរណា លើកទី ៦ ទើបអារក្សទឹកដោះលែងព្រះអង្គឲ្យមានសេរីភាព"។

ទ្រង់ព្រះសណ្តាប់នូវសំណួរនោះហើយ ព្រះបាទចូឡនីទ្រង់ឆ្លើយតាម អធ្យាស្រ័យរបស់ព្រះអង្គ ដោយពាក្យខាងក្រោមនេះថា៖

"ខ្ញុំឲ្យមាតាជាមុន រួចឲ្យអគ្គមហេសី ឲ្យប្អូន លំដាប់អំពីនោះ ឲ្យសម្លាញ់ និងឲ្យព្រាហ្មណ៍ជាគម្រប់ ៥ ។ បពិត្រព្រះម៉ែម្ចាស់ កាលបើអារក្សទឹកស៊ីមនុស្សជាគម្រប់ ៥ ហើយ ខ្ញុំនឹងនិយាយ នៅពេលនោះថា នែអារក្សទឹក ចូរឯងហាមាត់ទៅ កាលបើ អារក្សទឹកនោះកំពុងតែហាមាត់ ខ្ញុំនឹងចងក្បិនឲ្យតឹង មិនគិត អាល័យដល់រាជសម្បត្តិនេះទេ ខ្ញុំនឹងលោតចូលមាត់អារក្សទឹក

នោះ ឲ្យវាស៊ីខ្លួនខ្ញុំ ជាគម្រប់ ៦ ក្នុងគ្រានោះ ខ្ញុំមិនឲ្យមហោសថដល់វាទេ"។

បរិញ្វជិកាដឹងភាពស្មោះត្រង់របស់ព្រះរាជា ដែលមានមកលើលោកសេនាបតីមហោសថយ៉ាងនេះ ប៉ុន្តែដោយហេតុត្រឹមតែប៉ុណ្ណោះ គុណរបស់សេនាបតីមហោសថនោះ មិនទាន់ប្រាកដច្បាស់ដូចជាព្រះចន្ទទេ។ ព្រោះហេតុនោះ បរិញ្វជិកាមានសេចក្តីត្រិះរិះដូច្នេះ "អញនឹងថ្លែងនូវគុណរបស់ជនទាំងនេះ ក្នុងកណ្តាលមហាជន ព្រះរាជាទ្រង់នឹងពោលទោសរបស់ជនទាំងនោះ នឹងពោលគុណរបស់មហោសថបណ្ឌិត។ មានតែមធ្យោបាយនេះឯង ទើបធ្វើឲ្យគុណរបស់មហោសថប្រាកដជាក់ច្បាស់ដូចព្រះចន្ទពេញវង់ក្នុងនភាល័យ"។

ដូនជីបរិញ្វជិកាភេរីនោះបានអញ្ជើញប្រជាជនខាងក្នុងបុរីទាំងអស់ឲ្យប្រជុំគ្នា រួចបានសួរប្រស្នានោះដដែល ចំពោះព្រះរាជាម្តងទៀត តាំងពីដើមរហូតដល់ចប់។ កាលបើព្រះរាជាឆ្លើយយ៉ាងនោះដដែល បរិញ្វជិកាពោលគុណព្រះមាតាចលាកទេវីដូច្នេះថា៖

"បពិត្រមហារាជ ព្រះអង្គមានព្រះបន្ទូលថា ព្រះអង្គនឹងឲ្យព្រះមាតាមុន។ ជាធម្មតា ដែលហៅម្តាយៗ មានគុណធ្ងន់ណាស់

ចំណែកព្រះមាតារបស់ព្រះអង្គ ពុំមែនដូចម្ដាយរបស់ជនទាំងឡាយដទៃទេ ព្រះនាងមានឧបការៈច្រើនចំពោះព្រះអង្គ"។

រូបបរិញ្ញាជិកាពោលបន្ថែមថា៖

"ក្នុងកាលព្រះអង្គនៅក្មេង ព្រះមាតាងូតទឹកឲ្យពីរបីដងក្នុងមួយថ្ងៃ ឲ្យទឹកឲ្យបាយទំចំណី ជាអ្នកចិញ្ចឹមព្រះអង្គផង ជាអ្នកបង្កើតផង អនុគ្រោះព្រះអង្គដោយទឹកចិត្តដ៏ទន់ ប្រាថ្នាប្រយោជន៍អស់កាលដ៏យូរផង កាលដែលចត្តព្រាហ្មណ៍ប្រទូស្តចំពោះព្រះអង្គពេលនោះ ព្រះមាតាជាបណ្ឌិត ជាអ្នកស្គាល់ឧបាយ ជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ព្រះអង្គជាប្រក្រតី បានយករបស់ដទៃទៅបន្ទំប្តូរយកព្រះអង្គ ឲ្យរួចផុតពីការសម្លាប់។ ព្រះអង្គឲ្យព្រះមាតាដែលមានព្រះគុណប្រាកដដូច្នោះ ជាអ្នកឲ្យនូវជីវិត ជាអ្នកឲ្យព្រះអង្គកើតអំពីឱរា ជាអ្នកទ្រទ្រង់នូវគភ៌នោះ ដល់អារក្សទឹក តើព្រះមាតានោះមានទោសដូចម្ដេច?"

## ប្រវត្តិព្រះមាតានៃស្ដេចចូឡនី

ប្រវត្តិពិតថែងថា ព្រះរាជបិតារបស់ស្ដេចចូឡនីព្រះនាមមហាចូឡនី។ ក្នុងកាលស្ដេចចូឡនីនៅក្មេង ម្ចាស់ក្សត្រីចលាកទេវីជាមហេសី បានលួចមានសហាយស្មន់ជាមួយនឹងបុរោហិតម្នាក់ ហើយ

បានធ្វើគុតព្រះរាជាដែលជាស្វាមីរបស់ខ្លួនដោយដាក់ថ្នាំបំពុល លើក ស្ដេចបច្ចត្រឲ្យតាព្រាហ្មណ៍បុរោហិតនោះឡើងគ្រងរាជ្យ ហើយខ្លួនព្រះនាងផ្ទាល់បានឋានៈជាអគ្គមហេសីរបស់ស្ដេចថ្មីនោះ។ ក្នុងថ្ងៃមួយ រាជកុមារចូឡនីទូលមាតាថា "ព្រះមាតា ទូលបង្គំឃ្លានហើយ" ព្រះនាងបានប្រើអ្នកបម្រើឲ្យផ្ដល់នំ និងបង្អែមជាមួយនឹងទឹកអំពៅដល់រាជបុត្រ។ គ្រានោះ សត្វរុយជាច្រើន ហើរមករោមរាជកុមារចូឡនីយ៉ាងប្រសេចប្រសាច។ រាជកុមារចូឡនីគិតថា "អញនឹងបរិភោគរបស់នេះ កុំឲ្យមានរុយតាមរោម"។ គិតដូច្នេះហើយ ខ្លួនក៏បានធ្វើឲ្យកំពប់ទឹកអំពៅ ទៅលើដីជាច្រើនដំណក់ រាជកុមារចូឡនីដេញហ្វូងរុយក្នុងកន្ទែងរបស់ខ្លួន។ រុយទាំងនោះក៏ហើរមករោមទឹកអំពៅដែលនៅសល់នោះទៀត។ រាជកុមារចូឡនីបានបក់រុយឲ្យហើរអស់ ទើបបានបរិភោគបង្អែម រួចលាងព្រះហស្តខ្លួនព្រះឱស្ឋ ហើយយាងចេញទៅ។ ព្រាហ្មណ៍ឃើញកិរិយារបស់រាជកុមារចូឡនី ក៏គិតថា "ក្មេងនេះ ឥឡូវចេះបរិភោគទឹកអំពៅបក់រុយចេញ លុះដល់ពេលវាធំឡើង វានឹងមិនឲ្យរាជសម្បត្តិដល់អញទេ អញនឹងសម្លាប់វាចោលនៅពេលនេះឲ្យហើយ"។ គិតរួច ព្រាហ្មណ៍នោះបានប្រាប់សេចក្ដីនោះដល់ព្រះទេវី។ ព្រះទេវីបញ្ឆោតព្រាហ្មណ៍ថា៖

"បពិត្រព្រះសម្មតិទេព ខ្ញុំហ៊ានសម្លាប់ស្វាមីដើមរបស់ខ្ញុំ ព្រោះហេតុសេចក្ដីស្រឡាញ់ព្រះអង្គ ចុះបើគ្រាន់តែកូននេះមាន ប្រយោជន៍អ្វីដល់ខ្ញុំទៅ។ បពិត្រមហារាជ ខ្ញុំនឹងសម្លាប់វាដោយ កំបាំងមិនឲ្យនរណាម្នាក់ដឹងឡើយ"។

ព្រះនាងចលាកទេវី រកឧបាយដើម្បីបំភាន់ភ្នែកស្វាមីក្រោយ បានប្រើឲ្យគេហៅចុងភៅម្នាក់ ជាបណ្ឌិតឈ្លាសក្នុងឧបាយ ចូលមក គាល់ ហើយប្រាប់រឿងរ៉ាវថា៖

"នែសម្លាញ់ បុត្ររបស់ខ្ញុំគឺចូឡនីកុមារ ទាំងកូនរបស់អ្នក គឺ ធនុសេខកុមារ ពួកគេកើតក្នុងថ្ងៃជាមួយគ្នា ពេញវ័យឡើង ដោយគ្រឿងរក្សារបស់កុមារក្នុងកន្លែងតែមួយ ពួកគេជាសម្លាញ់ នឹងគ្នា។ ឥឡូវ ធព្កិព្រាហ្មណ៍ចង់សម្លាប់បុត្ររបស់ខ្ញុំ សូមអ្នក ជួយថែរក្សាជីវិតរាជបុត្រខ្ញុំផង"។

ចុងភៅក្រាបទូលសួរថា៖

"បពិត្រព្រះទេវី តើទូលបង្គំជាខ្ញុំនឹងធ្វើដូចម្ដេច?"

ព្រះនាងចលាកទេវីប្រាប់ថា៖

"ចូរអ្នកនាំរាជបុត្ររបស់ខ្ញុំ ទៅនៅផ្ទះរបស់អ្នកឲ្យបានញឹកញាប់ ទាំងអ្នកទាំងពួកគេ ចូរនាំគ្នាដេកនៅរោងបាយពីរបីថ្ងៃ ក្នុងលក្ខណៈចំហ ដើម្បីកុំឲ្យគេមានសេចក្ដីសង្ស័យ។ បន្ទាប់មក លុះដឹងថាឥតមានអ្នកសង្ស័យហើយ អ្នកចូរដាក់ធ្យូងពពែឲ្យបានច្រើននៅកន្លែងដេករបស់អ្នក។ ក្នុងវេលាពួកមនុស្សដេកលក់ស្កាត់អស់ អ្នកចូរដុតរោងបាយ ហើយយកបុត្រខ្ញុំនិងកូនរបស់អ្នក រត់ចេញទៅតាមទ្វារសម្ងាត់[២០៦] ភៀសខ្លួនទៅប្រទេសក្រៅ និងកុំឲ្យមាននរណាម្នាក់ដឹងថា កូននេះជាព្រះរាជបុត្រឲ្យសោះ ហើយចូរយកចិត្តទុកដាក់ជួយរក្សាជីវិតរបស់ពួកគេផង"។

ចុងភៅបានធ្វើតាមរាជបញ្ជា។ គ្រានោះ ព្រះនាងចលាកទេវី បានប្រទានរតនៈថ្លៃៗ ឲ្យចុងភៅនោះសម្រាប់ចិញ្ចឹមខ្លួននិងក្មេងៗ ពេលភៀសខ្លួនទៅប្រទេសក្រៅ។ ចុងភៅ បាននាំយកព្រះរាជកុមារនិងកូនរបស់ខ្លួន ភៀសខ្លួនទៅកាន់សាគលនគរក្នុងដែនមទ្ទរដ្ឋ ទាំងបានចូលខ្លួនទៅបម្រើព្រះរាជាក្នុងប្រទេសនោះទៀតផង។ ព្រះរាជានគរនោះ បានបួរចុងភៅចាស់ចេញ ហើយបានប្រទានឋានៈនោះ ចំពោះចុងភៅ

---

[២០៦] អគ្គទ្វារនេវ។

ថ្មីៗ កុមារទាំងពីរ តែងតែទៅកាន់រាជនិវេសន៍ ជាមួយនឹងចុងភៅនោះ ដែរៗ គ្រានោះក៏មានការសន្ទនារវាងព្រះរាជានិងចុងភៅដូច្នេះថា៖

ព្រះរាជា “កុមារទាំងពីរនេះ ជាកូនរបស់អ្នកឬ?”

ចុងភៅ “ពួកគេ ជាកូនរបស់ទូលបង្គំជាខ្ញុំ ក្រាបទូល”ៗ

ព្រះរាជា “ហេតុអ្វីបានគេទាំងពីរមិនដូចគ្នា?”

ចុងភៅ “មកពីពួកគេមានម្តាយផ្សេងគ្នា ព្រះសម្មតិទេព”ៗ

ចំណេរកាលតមក ក្មេងទាំងពីរនាក់នោះ មានសេចក្តីស្និទ្ធស្នាលនឹងគ្នាណាស់ តែងលេងក្នុងរាជវិវេសន៍ជាមួយនឹងរាជធីតានៃស្តេចមទូរាជៗ

ដោយការឃើញគ្នាជារឿយៗ ចូឡនីកុមារនិងព្រះរាជធីតា មានចិត្តប្រតិព័ទ្ធគ្នាទៅវិញទៅមកៗ រាជកុមារចូឡនីតែងប្រើឲ្យរាជធីតាយកកូនឃ្លីផង បាស្កាផង មកលេងក្នុងកីឡដ្ឋានៗ កាលបើរាជធីតាមិនបានយកមក កុមារចូឡនីតែងខោកក្បាលរាជធីតាពីរបីក្រញូវដៃបណ្តាលឲ្យរាជធីតាស្រែកយំៗ គ្រានោះព្រះរាជាឮសំឡេងយំរបស់ព្រះរាជកុមារី ក៏បានត្រាស់សួរថា “តើនរណាវាយបុត្រីយើងយំ?” ពួកមេដោះ នាំគ្នាមកសួររាជធីតាៗ រាជធីតាមិនប្រាប់ដោយត្រង់ទេ

ព្រោះតែសេចក្ដីស្នេហា ក៏ប្រាប់ទៅវិញថា "បើអញប្រាប់ថាចូឡនីវាយអញ ព្រះបិតាមុខតែប្រើរាជអាជ្ញាចំពោះចូឡនីនោះពុំខាន"។ គិតដូច្នេះរួច ក៏ប្រាប់ទៅពួកមេដោះថា "មិនមាននរណាវាយខ្ញុំទេ"។

តមកក្នុងថ្ងៃមួយ ព្រះបាទមទ្ទរាជទតឃើញកុមារចូឡនីកំពុងតែវាយព្រះបុត្រី។ លុះឃើញហើយ ព្រះអង្គមានសេចក្ដីត្រិះរិះដូច្នេះថា៖

"កុមារនេះ មុខមាត់មិនកាត់ដូចចុងភៅទេ វាមានរូបស្អាតសង្ហាគួរឲ្យស្រឡាញ់ វាក្លាហានអង់អាចណាស់។ កុមារនេះ ប្រាកដជាមិនមែនកូនរបស់ចុងភៅនុ៎ះទេ"។

តាំងពីគ្រានោះមក ព្រះអង្គតែងតែឃ្លាំមើលកុមារចូឡនីនោះ។ មេដោះទាំងឡាយ តែងនាំយកចំណីមកក្នុងកីឡដ្ឋាន ថ្វាយដល់ព្រះរាជធីតា។ រាជធីតាតែងចែករំលែក[២០៧] ដល់កុមារទាំងឡាយផ្សេងៗ។ កុមារទាំងឡាយនោះ តែងលុតជង្គង់ឱនខ្លួនទទួលយក។ ប៉ុន្តែចូឡនីកុមារវិញ ឈរកញ្ឆក់យកអំពីដៃរបស់រាជធីតា ដោយមិនមានការ

[២០៧] គួរប្រយត្នប្រើពាក្យ ចែករលែក និងចែករំលែក។ ចែករលែក គឺ ចែកឲ្យបានគ្រប់គ្នា ទោះបានស្មើគ្នាក្ដី តិចច្រើនជាងគ្នាក្ដី។ ចែករំលែក គឺចែកដោយរំលែកឲ្យខ្លះតាមការគួរ អំពីរបស់ដែលខ្លួនមាន។

គោរពរាជធីតាសោះ។ ព្រះរាជា ទ្រង់ក៏បានទតឃើញនូវអាកប្បកិរិយានោះដែរ។

តមកក្នុងថ្ងៃមួយ កូនឃ្វី[២០៨]របស់ចូឡនីកុមារ រមៀលចូលទៅខាងក្រោមគ្រែរបស់ព្រះបាទមទូរាជ។ កាលនឹងរើសយក ចូឡនីកុមារគិតដោយឥស្សរមានះខ្លួនថា "អញនឹងមិនចូលទៅខាងក្រោមគ្រែរបស់ស្ដេចបច្ចន្តប្បទេសនេះទេ" ហើយក៏យកឈើគ្គុះប្រមៀលកូនឃ្វីនោះយកមក។ ព្រះរាជាឃើញកិរិយានោះទៀត ទ្រង់មានព្រះតម្រិះថា៖ "កូននោះ ច្បាស់ជាមិនមែនជាកូនរបស់ចុងភៅទេ យើងពុំមានសង្ស័យឡើយ" ក៏ប្រើអ្នកបម្រើទៅហៅចុងភៅនោះចូលមកគាល់ រួចទ្រង់ត្រាស់សួរថា៖

"នុ៎ះជាកូនរបស់អ្នកណា?"

"កូនរបស់ទូលបង្គំជាខ្ញុំ ព្រះសម្មតិទេព" ចុងភៅក្រាបទូល។ ស្ដេចងាព្រះខាន់ឡើងគំរាមថា៖

[២០៨] គេណ្ឌុកោ។

"យើងស្គាល់អ្នកណាជាកូនរបស់ឯង អ្នកណាមិនមែនជាកូនរបស់ឯងហើយ ឯងចូរប្រាប់យើងតាមត្រង់[២០៩] បើឯងមិនប្រាប់ទេ ជីវិតរបស់ឯងមុខតែក្ស័យពុំខាន"ៗ

ចុងភៅញ័រខ្លួនខ្លាចស្លាប់យ៉ាងខ្លាំង ក្រាបទូលស្ដេចថា៖

"ទូលបង្គំនឹងទូលព្រះសម្មតិទេព ប៉ុន្តែទូលបង្គំត្រូវការទីស្ងាត់"ៗ

កាលបើព្រះរាជាផ្ដល់ឱកាសឲ្យ ចុងភៅនោះបានសូមព្រះរាជទានទោស ហើយបានក្រាបទូលឲ្យព្រះអង្គទ្រង់ជ្រាប តាមរឿងរ៉ាវដែលបានកើតឡើងពីដើមដល់ចប់[២១០]ៗ

ព្រះបាទមទូរាជ ដឹងសេចក្ដីពិតដូច្នោះ ទ្រង់តុបតែងជីតារបស់ព្រះអង្គ ហើយបានប្រទានឲ្យធ្វើជាភរិយារបស់ចូឡនីកុមារនោះៗ

និយាយពីថ្ងៃដែលជនទាំងនេះរត់កៀសខ្លួនវិញ មានកោលាហលកើតឡើងទូទាំងនគរថា "ចុងភៅ ចូឡនីកុមារ និងកូនរបស់ចុងភៅបានឆេះក្នុងរោងបាយស្លាប់អស់ហើយ"ៗ ចំណែកព្រះនាងចលាកទេវីឮដំណឹងនោះហើយ បានទៅក្រាបទូលស្វាមីជាព្រាហ្មណ៍បុរោហិតថា

[២០៩] សភាវំ មេ កថេហិ នោ ចេ កថេសិ ជីវិតំ តេ នត្ថិៗ

[២១០] អភយំ យាចិត្វា យថាភូតំ អារោចេសិៗ

"បពិត្រព្រះសម្មតិទេព គោលបំណងរបស់ព្រះអង្គ បានសម្រេចហើយ ពួថាអ្នកទាំង ៣ នាក់នោះ បានឆេះស្លាប់ក្នុងផ្ទះបាយហ្នឹងអស់ហើយ"។ ព្រាហ្មណ៍បុរោហិតនោះ មានសេចក្តីត្រេកអរយ៉ាងខ្លាំង។ ព្រះនាងចលាកទេវី ប្រើឲ្យគេយកឆ្អឹងពពែមកបង្ហាញព្រាហ្មណ៍ថា "ទាំងនេះ ជាឆ្អឹងចូឡនីកុមារ" រួចឲ្យគេបោះចោលទៅ។

## មូលហេតុឱ្យព្រះមាតាដល់អារក្សទឹកក្នុងលំដាប់ទី ១

បរិព្វាជិកាភេរី បានមានប្រសាសន៍ដូច្នោះ នាងសំដៅយករឿងរ៉ាវនេះឯង។ ជាការពិតណាស់ ព្រះនាងចលាកទេវីបានបង្ហាញឆ្អឹងពពែកុហកគេថា ឆ្អឹងមនុស្ស គឺដើម្បីរំដោះបុត្រឲ្យរួចអំពីការសម្លាប់។ ព្រះអង្គចម្រើនវ័យក្នុងទ្រូងព្រះមាតា ព្រះអង្គជាឱរសជាទីស្រឡាញ់ពេញព្រះទ័យ ព្រះអង្គត្រូវព្រះមាតាទ្រទ្រង់ដោយផ្ទៃ។ តើព្រះអង្គនឹងឲ្យព្រះមាតា មានគុណបែបនេះដល់អារក្សទឹក ព្រោះទ្រង់ឃើញទោសដូចម្តេច?"

ទ្រង់ព្រះសណ្តាប់សេចក្តីនោះហើយ ព្រះបាទចូឡនីត្រាស់ថា៖

"បពិត្រព្រះម៉ែម្ចាស់ គុណនៃព្រះមាតាខ្ញុំ មានច្រើនណាស់ ទាំងខ្ញុំក៏ដឹងនូវឧបការគុណរបស់ព្រះមាតានោះមានមកលើខ្ញុំ ប៉ុន្តែគុណរបស់ខ្ញុំមានច្រើនជាងនោះទៅទៀត[២១១]"។

កាលនឹងពោលទោសនៃព្រះមាតា ស្តេចបានត្រាស់បន្តដូច្នេះថា៖

"ព្រះមាតាខ្ញុំ ទ្រទ្រង់គ្រឿងអលង្ការដែលមិនគួរតាក់តែងដូចស្ត្រីក្មេង សើចក្អាកក្អាយហួសវេលាជាមួយនឹងនាយឆ្មាំទ្វារ និងពពួកពលសេនា មិនតែប៉ុណ្ណោះ ថែមទាំងបញ្ជូនទូតទាំងឡាយដល់ពួកបដិរាជ(ស្តេចជាសត្រូវ) ព្រះរាជានៅក្រោមអំណាចដោយខ្លួនឯង ខ្ញុំឲ្យព្រះមាតាដល់អារក្សទឹក ព្រោះទោសនោះឯង"។

តាមការសម្គាល់ ព្រះរាជមាតាចលាកទេវីនោះ ទោះបើមានវ័យចាស់ហើយក៏ដោយ ខំធ្វើខ្លួនដូចស្រីក្រមុំ ទ្រទ្រង់គ្រឿងអលង្ការដែលមិនគួរប្រដាប់សោះ។ ក្នុងថ្ងៃមួយនោះ ព្រះបាទចូឡនីកំពុងតែប្រថាប់គង់ក្នុងប្រាសាទទេវវិនិច្ឆ័យជាមួយនឹងគណៈមន្ត្រី ស្រាប់តែព្រះរាជមាតា ក្រវាត់ខ្សែក្រវាត់មាស ដែលដាំពេញសុទ្ធតែគ្រាប់ពេជ្រ មកដើរ

---

[២១១] "អយ្យេ, ពហូ មម មាតុ គុណា, អហញ្ហស្សា មម ឧបការកោ ជានាមិ, ត តោបិ បន មមេវ គុណា ពហុតរា"តិ។

សម្រែងខ្លួនទៅមកៗ។ ស្នូរខ្សែក្រវាត់បណ្ដាលឲ្យរាជនិវេសន៍ លាន់ឮសូរសព្ទទ្រហឹង កើតក្ដីរំខានដល់ស្ដេចនិងមន្ត្រីដែលកំពុងជំនុំៗ មួយទៀត រាជមាតានោះ ជាមនុស្សមិនគួរបរិភោគនូវរបស់សល់ពីគេទេ ព្រះនាងថែមទាំង ទៅហៅពួកនាយកងទ័ពឆ្មាំទ្វារនិងពួកហ្មជីវជាដើម មកលេងសើចក្អាកក្អាយ ហួសវេលា ជាមួយនឹងអ្នកទាំងអស់នោះៗ ក្នុងថ្ងៃមួយ ព្រះរាជមាតា សរសេរសំបុត្រមួយច្បាប់ដោយខ្លួនព្រះនាងផ្ទាល់[២១២] រួចចុះហត្ថលេខា ដាក់នាមថាព្រះបាទចូឡនីជាអ្នកឡាយព្រះហស្ត រួចព្រះនាងប្រើទូតទាំងឡាយឲ្យយកទៅថ្វាយដល់ស្ដេចផ្សេងៗ ដែលក្នុងសំបុត្រមានខ្លឹមសារថា “ព្រះមាតារបស់ខ្ញុំ ឋិតនៅក្នុងវ័យបរិភោគកាមនៅឡើយទេ សូមព្រះអង្គមកចូលស្ដីដណ្ដឹងព្រះមាតារបស់ខ្ញុំ”។ ស្ដេចទាំងឡាយ ក៏បញ្ជូនសំបុត្រតបរៀងៗខ្លួន ផ្ញើទៅថ្វាយដល់ស្ដេចចូឡនីដែលមិនដឹងខ្លួនវិញថា “ទូលបង្គំយើងខ្ញុំ ជាអ្នកបម្រើរបស់ព្រះអង្គទេ ព្រះអង្គចារលិខិតដល់ពួកទូលបង្គំយ៉ាងនេះ ព្រោះហេតុអ្វី?” លិខិតទាំងនោះ ត្រូវបានពួកទូតអានឲ្យឮ ក្នុងកណ្ដាលរាជបរិស័ទ ស្ដេចចូឡនីមានសេចក្ដីអាម៉ាស់មុខខ្មាសអស់ពួកមន្ត្រី ស្ទើរតែដាច់ក្បាលធ្លាក់ពីលើស្មាៗ ព្រោះហេតុនេះហើយ ព្រះបាទចូឡនីមាន

[២១២] មម វចនេន សយំ បណ្ណំ លិខិត្វា ទូតេបិ បេសេតិ។

ព្រះបន្ទូលនឹងជូនជីបរិញ្វជិកាកេរីថា “ខ្ញុំឲ្យព្រះមាតាដល់អារក្សទឹក ព្រោះទោសនោះឯង”។

គ្រានោះ បរិញ្វជិកាក្រាបទូលថា៖

“បពិត្រមហារាជ សូមព្រះអង្គឲ្យព្រះមាតាមុន ដោយទោសនេះចុះ ប៉ុន្តែព្រះអគ្គមហេសីរបស់ព្រះអង្គ ព្រះនាងមានឧបការៈច្រើន”។

រួចបរិញ្វជិកាបានពោលសរសើរគុណដូច្នេះថា៖

“អគ្គមហេសី ជាស្ត្រីដ៏ប្រសើរជាងពួកស្ត្រីនានា ពោលពាក្យជាទីស្រឡាញ់ដ៏ក្រៃលែង ជាស្ត្រីមានសណ្តាប់ធ្នាប់ល្អ មានសីលធម៌ ធ្លាប់ដង្ហែតាមព្រះអង្គជាប់ដូចជាស្រមោល តាំងពីនៅកុមារវ័យ ជាស្ត្រីមិនក្រេវក្រោធ ក្នុងកាលដែលព្រះអង្គនៅសាគលនគរដែនមទ្ទរដ្ឋ បើទុកណាជាព្រះអង្គវាយនាងយំក៏ព្រះនាងមិនដែលហ៊ានប្រាប់ព្រះមាតាព្រះបិតា ព្រោះសេចក្តីស្រឡាញ់ព្រះអង្គ ដោយខ្លាចរាជបិតាដាក់រាជអាជ្ញាចំពោះព្រះអង្គ។ ព្រះនាងជាអ្នកមានបុណ្យ ជាបណ្ឌិត ឃើញនូវប្រយោជន៍ជាប្រក្រតី។ តើព្រះអង្គ ព្រះរាជទានព្រះនាងនន្ទាទេវី ជាស្ត្រី

បរិបូរដោយគុណធម៌យ៉ាងនេះ ដល់អារក្សទឹក តើព្រោះទោសដូចម្ដេច?”

**មូលហេតុឱ្យគរិយារដល់អារក្សទឹកក្នុងលំដាប់ទី ២**

ព្រះបាទចូឡនី បានពោលទោសរបស់ព្រះអគ្គមហេសីថា៖

“មហេសីនន្ទាទេវីនោះ បានដឹងច្បាស់ថាខ្ញុំជាអ្នកប្រកបដោយសេចក្ដីត្រេកអរក្នុងល្បែង ទាំងជាអ្នកលុះក្នុងអំណាចនៃកិលេស ដែលមិនមានប្រយោជន៍ ក្នុងការលេងកាម[២១៣]។ កាលខ្ញុំប្រទាន គ្រឿងប្រដាប់ដល់ពួករាជបុត្រធីតានិងករិយាទាំងឡាយ នន្ទាទេវីមានចិត្តប្រណែនឈ្នានីស បានទទូចសូមនូវគ្រឿងប្រដាប់នោះ ដែលជាទ្រព្យមិនគួរចង់បានសោះ គិតតែពីទទូចថា “ឲ្យខ្ញុំៗ”។ កាលខ្ញុំគាប់ព្រះទ័យនឹងនាង ខ្ញុំក៏បានប្រទានទ្រព្យយ៉ាងច្រើន ដល់នន្ទាទេវី។ ក្រោយមកទៀត ខ្ញុំលះបង់ចែករំលែកនូវទ្រព្យខ្លះ ដល់ករិយាផ្សេងៗ ស្រាប់តែនន្ទាទេវីទៅគំរាមពួកគេថា “របស់ទាំងនេះ គឺព្រះរាជាប្រទានដល់យើងទេ ចូរឲ្យវាមកខ្ញុំ” នន្ទាទេវី បានដណ្ដើមដោះយកពីគេ ទោះបីជាពួកគេយំក៏ដោយ។ គ្រានោះ ខ្ញុំបានឃើញបុត្រ

---

[២១៣] កាមកីឡាយ។

កិរិយាទាំងឡាយយាំយែក ដើរមកសម្នាក់របស់ខ្ញុំ ខ្ញុំក៏មានការអាក់អន់ចិត្ត សោកស្ដាយ ក្នុងកាលជាខាងក្រោយ។ នន្ទាទេវីនុ៎ះបានធ្វើនូវកំហុសយ៉ាងនេះ ខ្ញុំឲ្យដល់អារក្សទឹក ព្រោះទោសនោះឯង"។

**មូលហេតុឱ្យប្អូនដល់អារក្សទឹកក្នុងលំដាប់ទី ៣**

គ្រានោះ បរិព្វាជិកាទូលសួរថា៖

"សូមព្រះអង្គឲ្យអគ្គមហេសីនេះ ដោយទោសនេះចុះ ប៉ុន្តែប្អូនពៅរបស់ព្រះអង្គឈ្មោះតិខិណមន្តិកុមារ ជាអ្នកមានឧបការៈដែរ តើព្រះអង្គនឹងឲ្យគេទៅអារក្សទឹក ដោយទោសដូចម្ដេច?"

រួចដូនជីបរិព្វាជិកាបានក្រាបទូលបន្តថា៖

"ពួកអ្នកជនបទចម្រើនហើយ ព្រោះព្រះកនិដ្ឋភាតា(ប្អូនប្រុសឬព្រះអនុជ) ទាំងព្រះអង្គផ្ទាល់ ក៏ព្រះកនិដ្ឋភាតានោះនាំមកកាន់ព្រះរាជដំណាក់វិញ។ ព្រះរាជទ្រព្យជាច្រើន ព្រះកនិដ្ឋភាតាបានដណ្ដើមអំពីពួកស្ដេចដទៃ មកថ្វាយចំពោះព្រះអង្គវិញ។ ព្រះអង្គព្រះរាជទានព្រះកនិដ្ឋភាតា ជាបុគ្គលប្រសើរជាងពួកខ្មាន់ធ្នូ ជាអ្នកក្លៀវក្លា មានប្រាជ្ញាដ៏មុត ដល់អារក្សទឹក តើព្រោះទោសដូចម្ដេច?"

បានឮមកថា តិរិណមន្តិកុមារនោះប្រសូតក្នុងពេលនៃព្រះមាតា នៅជាមួយនឹងព្រាហ្មណ៍ៗ លុះដល់តិរិណមន្តិកុមារធំពេញវ័យ តាព្រាហ្មណ៍បានប្រទានព្រះខាន់ដល់ដៃ និងប្រាប់ថា "ឯងចូរយកព្រះខាន់នេះបម្រើយើង"ៗ តិរិណមន្តិ នៅបម្រើព្រាហ្មណ៍នោះដោយសម្គាល់ថា គាត់ជាព្រះបិតារបស់ខ្លួនៗ គ្រានោះ អាមាត្យម្នាក់បានប្រាប់តិរិណមន្តិកុមារថា "បពិត្រព្រះកុមារ ព្រះអង្គមិនមែនជាបុត្ររបស់ព្រាហ្មណ៍នោះទេ ក្នុងកាលព្រះអង្គនៅក្នុងផ្ទៃនៅឡើយ មហាក្សត្រិយានីចលាកទេវីសម្លាប់ព្រះរាជាជាព្រះបិតាព្រះអង្គ ហើយបង្គាប់ឲ្យគេលើកស្វេតច្ឆត្រដល់ព្រាហ្មណ៍ឡើងគ្រងរាជ្យ ព្រះអង្គគឺជាបុត្ររបស់ព្រះបាទមហាចូឡនីរាជាទេ"ៗ តិរិណមន្តិខឹងខ្លាំង ចូលទៅកាន់ព្រះបរមរាជវាំងប៉ុនប៉ងនឹងសម្លាប់ព្រាហ្មណ៍នោះឲ្យបានដោយឧបាយណាមួយ ហើយបានហុចព្រះខាន់នោះឲ្យអ្នកបម្រើម្នាក់ រួចប្រាប់អ្នកបម្រើម្នាក់ទៀតថា "ឯងចូរធ្វើជាឈ្លោះជាមួយនឹងបុរសនោះនៅទៀបទ្វារវាំង ដោយលើកឡើងថា ព្រះខាន់នុ៎ះ ជារបស់ឯង" បង្គាប់ដូច្នេះហើយ តិរិណមន្តិកុមារចូលទៅកាន់ព្រះបរមរាជវាំងៗ បុរសទាំងពីរនាក់នោះ ក៏ធ្វើជាប្រឈ្លោះគ្នាមែនៗ ព្រាហ្មណ៍ ប្រើបុរសម្នាក់ឲ្យទៅសួរថា តើមានជម្លោះរឿងអ្វី? បុរសនោះមកក្រាបទូលថា "ពួកគេឈ្លោះគ្នាដណ្តើមព្រះខាន់"ៗ ព្រាហ្មណ៍ឮដូច្នោះ សួរតិរិណមន្តិកុមារថា "ម៉េចបានជាកើតមានរឿង

អីចឹង?" តិរិណាមន្ត្រិកុមារបានក្រាបទូលថា "ឮថាព្រះខាន់ដែលព្រះអង្គប្រទានដល់ទូលបង្គំនោះ ធ្លាក់ទៅក្នុងដៃរបស់ជនដទៃហើយ"។ ស្ដេចព្រាហ្មណ៍ថា "ថាម៉េចបា បើដូច្នោះបាឯងចូរទៅយកវាមកវិញឲ្យបាន យើងស្គាល់ព្រះខាន់នោះច្បាស់ណាស់"។ តិរិណាមន្ត្រិកុមារបញ្ជាគេឲ្យនាំព្រះខាន់នោះមក រួចដកព្រះខាន់ចេញពីស្រោម ដើរចូលទៅជិត ហើយបង្ហាញស្ដេច ឲ្យទ្រង់ទតថា "ព្រះអង្គទតៗ ក្រាបទូល" ហើយក៏កាប់ស្ដេចព្រាហ្មណ៍នោះមួយព្រះខាន់ចំកញ្ចឹងក ដាច់កធ្លាក់ក្បាលពីស្មា រមៀលមកជិតជើងរបស់ខ្លួនភ្លាមៗ បន្ទាប់មកតិរិណាមន្ត្រិកុមារជួសជុលព្រះបរមរាជវាំង តុបតែងលម្អនគរ ឲ្យមានសោភណភាព គ្រោងនឹងអភិសេកឡើងសោយរាជ្យជាស្ដេចផែនដី។ ព្រះមាតាក៏ប្រាប់ដំណឹងថារាជកុមារចូឡនីជាបងនៅរស់នៅឡើយទេ គេកំពុងតែបិតនៅក្រៅនគរក្នុងដែនមទ្ទរដ្ឋឯណោះ។ ឮថាបងនៅរស់ដូច្នោះ តិរិណាមន្ត្រិកុមារ រៀបទ័ពដំរី ទ័ពសេះ ទ័ពរទេះ ទ័ពថ្មើរជើងចេញដំណើរទៅកាន់ដែនមទ្ទរដ្ឋ នាំបងប្រុសចូឡនី មកនគរវិញ ហើយយាងព្រះរៀមឲ្យទទួលរាជ្យធ្វើជាស្ដេចគ្រប់គ្រងរាជាណាចក្រតទៅ។ ដោយមានរឿងរ៉ាវបែបនេះ ទើបបរិព្វាជិកាទូលសួរស្ដេចចូឡនីថា៖

"ប្អូនប្រុសដែលមានគុណបែបនោះ តើព្រះអង្គនឹងឲ្យដល់អាវក្សទឹក ព្រោះទោសដូចម្ដេច?"

ព្រះរាជាពោលទោសរបស់តិខិណមន្តិកុមារថា៖

"ពួកអ្នកជនបទចម្រើនហើយ ព្រោះព្រះកនិដ្ឋភាតា ទាំងខ្ញុំក៏ព្រះកនិដ្ឋភាតានោះ នាំមកកាន់ព្រះរាជដំណាក់វិញ ព្រះកនិដ្ឋភាតាបាននាំរាជទ្រព្យជាច្រើន អំពីពួកស្ដេចដទៃ។ កនិដ្ឋភាតានោះតែងនិយាយថា ចូឡនីនេះនៅនគរផ្សេងទេ គឺអញនាំមករាជវាំងនេះសាជាថ្មី ដែលឡើងជាស្ដេចអង្គនុ៎ះ គឺអញទេអ្នកតែងតាំងក្នុងយសដ៏ធំ និងតែងមើលងាយថា អញប្រសើរជាងពួកខ្មាន់ធ្នូជាអ្នកក្លៀវក្លា មានប្រាជ្ញាដ៏មុត ឯព្រះរាជានេះដូចជាក្មេង បានសេចក្ដីសុខព្រោះតែអញ។ បពិត្រជូនជី មិនតែប៉ុណ្ណោះ ព្រះកនិដ្ឋភាតានោះ មិនមកកាន់ទីបម្រើខ្ញុំដូចក្នុងកាលពីដើមទេ ពីដើម គេមកពីព្រលឹម ប៉ុន្តែឥឡូវនេះ គេមិនមកដូចសព្វដងទេ។ ខ្ញុំឲ្យព្រះកនិដ្ឋភាតានោះដល់អាវក្សទឹក ព្រោះទោសនេះឯង"។

**មូលហេតុឱ្យស្រឡាញ់ដល់អារក្សទឹកក្នុងលំដាប់ទី ៤**

គ្រានោះ ដូនជីបរិព្វាជិកាមានប្រសាសន៍ថា៖

"អ្វីជាទោសរបស់ប្អូនប្រុស ឈប់និយាយប៉ុណ្ណេះសិនចុះ ចំណែកឯធនុសេខ គេមានសេចក្តីស្រឡាញ់ចំពោះព្រះអង្គ ចាត់ថាជាគុណនិងមានឧបការៈច្រើនណាស់ដល់ព្រះអង្គ"។

រូបបរិព្វាជិកាពោលគុណរបស់ធនុសេខបន្តថា៖

"ជនទាំងពីរនាក់ គឺព្រះអង្គនិងធនុសេខ ជាសម្លាញ់ដែលមានវ័យស្មើគ្នា ធ្លាប់នៅក្នុងឧត្តរបញ្ចាលនគរ ជាបុគ្គលពីរនាក់កើតក្នុងបញ្ចាលនគរក្នុងរាត្រីតែមួយៗ ធនុសេខរួមសុខរួមទុក្ខជាមួយគ្នានឹងព្រះអង្គ ដង្ហែតាមព្រះអង្គ ក្នុងការយាងទៅកាន់ជនបទជាអ្នកខ្មីឃ្មាតខ្វល់ខ្វាយក្នុងកិច្ចទាំងពួង ដើម្បីទំនុកបម្រុងព្រះអង្គទាំងថ្ងៃទាំងយប់ៗ ព្រះអង្គឲ្យសម្លាញ់នេះដល់អារក្សទឹកតើព្រោះហេតុដូចម្តេច?"

គ្រានោះ ព្រះរាជាពោលទោសរបស់ធនុសេខថា៖

"បពិត្រដូនជី ធនុសេខនេះ ដើមឡើយតែងទៅតាមដង្ហែខ្ញុំក្នុងពេលដើរលេង គេហូប ដេកជាមួយនឹងខ្ញុំ កាលនៅកម្សត់

ក្នុងដែនមទុរដ្ឋ គេទះដៃសើចក្អាកក្អាយជាមួយនឹងខ្ញុំ។ សូម្បី
សព្វថ្ងៃនេះ គេក៏នៅតែសើចក្អាកក្អាយហួសខុសទំនង គេមើល
ងាយខ្ញុំ ដូចពេលនៅទុគ៌ត មិនលះទម្លាប់ចាស់។ បពិត្រដូនជី
កាលខ្ញុំនៅក្នុងទីស្ងាត់ កំពុងតែប្រឹក្សាជាមួយនឹងអគ្គមហេសី
នន្ទាទេវី ស្រាប់តែជនុសេខចូលមកភ្លាម មិនគោះទ្វារឲ្យខ្ញុំដឹង
ជាមុនទេ ខ្ញុំមិនបានហៅចូល ទាំងគេក៏មិនបានឲ្យដំណឹងខ្ញុំជាមុន
ស្រាប់តែចូលមក ភ្លាមតែម្តង ចង់ចេញចូលស្រេចតែចិត្ត។
ខ្ញុំឲ្យសម្លាញ់ដែលជា មនុស្សមិនមានសេចក្តីអៀនខ្មាស
មិនចេះអើពើនោះ ដល់អារក្ស ទឹក ព្រោះទោសនោះឯង”។

**មូលហេតុឱ្យបុរោហិតដល់អារក្សទឹកក្នុងលំដាប់ទី ៥**

គ្រានោះ បរិព្វាជិកាមានប្រសាសន៍ថា៖

“បពិត្រមហារាជ ទុំះចាត់ថាជាទោសនៃសម្លាញ់របស់ព្រះអង្គចុះ
ចុះឯបុរោហិតរបស់ព្រះអង្គ គេក៏មានឧបការៈច្រើនដែរ”។

រួចបរិព្វាជិកាពោលគុណរបស់បុរោហិតនោះបន្តដូច្នេះថា៖

“ព្រាហ្មណ៍បុរោហិត ជាអ្នកឈ្លាសវៃក្នុងនិមិត្តទាំងពួង ជាអ្នក
ដឹងនូវសម្រែកទាំងពួង ជាអ្នកឈ្លាសក្នុងឧត្បាតមានចន្ទគ្រាស

សូរ្យគ្រាស ឧក្កាបាត[២១៤] និងទិសាឌហាជាដើម ជាអ្នកចេះកាត់សុបិន ថែមទាំងជាអ្នកឈ្លាសវៃក្នុងការចេញនិងការចូលផង លើផែនដី និងលើអាកាសផង ជាអ្នកឈ្លាសវៃខាងនក្ខត្តឫក្ស ២៨ ផង។ ព្រះអង្គឲ្យព្រាហ្មណ៍បុរោហិតដល់អារក្សទឹក តើព្រោះទោសដូចម្តេច?”

ព្រះបាទចូឡនីពោលទោសរបស់បុរោហិតនោះថា៖

“បពិត្រនាងម្ចាស់ ព្រាហ្មណ៍បុរោហិត បើកក្អែកសម្លក់ចំពោះខ្ញុំក្នុងកណ្តាលជំនុំមហាជន ដូចនាយព្រានចិញ្ចើមឈរ ចិញ្ចើមបះដោយសេចក្តីមិនពេញចិត្តអ្វីមួយ មានមុខគួរឲ្យខ្លាច ព្រោះហេតុនោះ ទើបខ្ញុំឲ្យបុរោហិតអាក្រក់មានចិញ្ចើមក្រញូវដល់អារក្សទឹក”។

---

[២១៤] ឧក្កាបាត អ៊ុក-កា-បាត បា. ឬ សំ. ( ន. ) គប់ភ្លើងដែលធ្លាក់ពីអាកាស គឺកេតុធ្លាក់ឬកេតុជំដួល : មានឧក្កាបាត (បារ. Aérolithe) ។

**មូលហេតុឱ្យខ្លួនព្រះអង្គដល់អារក្សទឹកក្នុងលំដាប់ទី ៦**

បន្ទាប់មក ដូនជីបរិព្វាជិកាពោលថា៖

"បពិត្រមហារាជ ព្រះអង្គត្រាស់ថា ព្រះអង្គនឹងឲ្យនូវជន៥នាក់ មានព្រះមាតាជាដើមដល់អារក្សទឹក ទាំងព្រះអង្គក៏ត្រាស់ថា ព្រះអង្គមិនអាឡោះអាល័យនូវរាជសម្បត្តិបែបនេះ ហើយទ្រង់នឹងឲ្យជីវិតរបស់ព្រះអង្គដល់មហោសថផង តើព្រះអង្គបានយល់ឃើញនូវឧបការគុណរបស់មហោសថដូចម្តេច?"

រួចបរិព្វាជិកានោះពោលបន្តដូច្នេះថា៖

"ព្រះអង្គគ្រប់គ្រងនូវផែនដីដ៏ធំ មានសមុទ្រព័ទ្ធជុំវិញជាកុណ្ឌលរបស់សាគរ ព្រះអង្គមានអាមាត្យចោមរោម ជាឥស្សរៈលើផែនដី មានសមុទ្រទាំង ៤ ជាទីបំផុត មានដែនដ៏ច្រើន ជាអ្នកឈ្នះសង្គ្រាម មានពលច្រើន ជាព្រះរាជាឯក លើផែនដី យសរបស់ព្រះអង្គក៏ដល់នូវភាពដ៏ធំថ្កើង មានពួកនារីមកអំពីជនបទផ្សេងៗ ជាស្រីស្នំ ១៦ ពាន់នាក់ ពាក់គ្រឿងកុណ្ឌលជាវិការៈនៃកែវមណី ល្អល្អះដូចស្រីទេពកញ្ញា។ មហាបពិត្រ អ្នកប្រាជ្ញទាំងឡាយបានពោលចំពោះជីវិតដែលវែង បរិបូណ៌ដោយអង្គទាំងពួង សម្រេចនូវសេចក្តីប្រាថ្នាទាំងពួងថា ជាទីស្រឡាញ់របស់សត្វទាំងឡាយ

អ្នកដល់នូវសេចក្ដីសុខយ៉ាងនេះៗ កាលបើដូច្នេះ ព្រះអង្គរក្សា ទុកនូវបណ្ឌិត ស៊ូលះបង់ព្រះជន្ម ដែលគេលះបង់បានដោយ កម្រ តើដោយដំណើរដូចម្ដេច ឬក៏ដោយហេតុដូចម្ដេច?”

ព្រះរាជាទ្រង់ព្រះសណ្ដាប់សម្ដីរបស់បរិញ្វជិកាហើយ ទ្រង់ត្រាស់ សរសើរនូវគុណារបស់សេនាប្រមុខមហោសថថា៖

“បពិត្រដូនជី តាំងពីពេលដែលមហោសថបណ្ឌិតមកឋិតនៅ ក្នុងការគ្រប់គ្រងរបស់ខ្ញុំ ខ្ញុំផ្ទាល់ក៏មិនដែលឃើញនូវអំពើ អាក្រក់ មានកាយកម្មជាដើម សូម្បីតែបន្តិចបន្តួចរបស់ មហោសថបណ្ឌិត ជាអ្នកប្រាជ្ញទេៗ ប្រសិនបើសេចក្ដីស្លាប់ នឹងមានដល់ខ្ញុំមុន ទោះក្នុងកាលណាមួយ មហោសថបណ្ឌិត ប្រាកដជាញ៉ាំងបុត្រទាំងឡាយនិងចៅទាំងឡាយរបស់ខ្ញុំ ឲ្យបាន នូវសេចក្ដីសុខ មហោសថបណ្ឌិតតែងពិចារណាឃើញនូវ ប្រយោជន៍ទាំងពួង ទាំងអតីតៈ បច្ចុប្បន្ន និងអនាគត ប្រៀបដូច ជាព្រះសព្វញ្ញុពុទ្ធ ព្រោះហេតុនោះ ខ្ញុំមិនឲ្យនូវមហោសថបណ្ឌិត ជាអ្នកមានការងារ មិនដែលភ្លាត់ខុសដល់អារក្សទឹកទេ”ៗ

សរុបសេចក្តីមកថា ព្រះបាទចូឡនីបានលើកឡើងនូវគុណទាំងឡាយរបស់សេនាប្រមុខមហោសថ ឲ្យលេចត្រចះត្រចង់ បីដូចលើកវង់ព្រះចន្ទ្រដាក់នៅកណ្តាលនភាល័យ។

ជាតកនេះឈ្មោះថា **យថានុសន្ធិ**។ គ្រានោះដូនជីបរិព្វាជិកាគិតថា "ដោយហេតុត្រឹមប៉ុណ្ណេះ គុណទាំងឡាយរបស់មហោសថបណ្ឌិត មិនទាន់ប្រាកដច្បាស់ទេ អញនឹងធ្វើគុណរបស់មហោសថនោះ ឲ្យល្បីរន្ទឺក្នុងកណ្តាលពួកអ្នកនគរទូទៅ បីដូចចាក់ប្រេងថ្កូនទៅលើផ្ទៃសាគរ"។ គិតហើយ ដូនជីបរិព្វាជិកាយាងព្រះរាជាចុះចាកប្រាសាទ បង្គាប់ឲ្យគេក្រាលអាសនៈនៅព្រះលានហ្លួង យាងព្រះរាជាឲ្យប្រថាប់គង់នៅទីនោះ ហើយអញ្ជើញអ្នកនគរទាំងឡាយឲ្យមកជួបជុំគ្នា រួចដូនជីបរិព្វាជិកាសួរប្រស្នាស្តីពីអារក្សទឹកដដែលនោះតាំងអំពីដើមរហូតដល់ចប់។ ព្រះរាជាទ្រង់ឆ្លើយដូចចម្លើយខាងលើទាំងអស់ បរិព្វាជិកាបានពោលជាមួយនឹងពួកអ្នកនគរថា៖

"ពួកអ្នកបញ្ចាលនគរទាំងឡាយ ចូរស្តាប់នូវភាសិតនេះរបស់ព្រះបាទចូឡនីចុះ ព្រះរាជាទ្រង់រក្សានូវបណ្ឌិត ស៊ូលះបង់នូវព្រះជន្មដែលគេលះបានដោយកម្រ ព្រះរាជាក្នុងបញ្ចាលនគរ លះបង់នូវជីវិតរបស់ជន ៦ រូប គឺ ព្រះមាតា១ ព្រះមហេសី១

ព្រះកនិដ្ឋកាតា១ សម្ងាត់១ ព្រាហ្មណ៍១ ខ្ទួនព្រះអង្គ១ ទុក មហោសថបណ្ឌិតជាអ្នកមានបញ្ញា។ បញ្ញាជាគុណជាតិដ៏ល្អិត សម្រាប់គិត នូវប្រយោជន៍ដ៏ល្អ មានឫទ្ធិច្រើនយ៉ាងនេះ ប្រព្រឹត្ត ទៅដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ននេះផង ដើម្បីសេចក្តីសុខក្នុង បរលោកផង”។

## ព្រះសាស្តាប្រជុំជាតក

ព្រះសាស្តាបរមគ្រូនៃយើង លុះនាំធម្មទេសនានេះមកសម្តែង ហើយ ទ្រង់បញ្ជាក់ថា “ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនមានបញ្ញា តែឥឡូវនេះទេ សូម្បីក្នុងអតីតជាតិក៏តថាគតធ្លាប់មានបញ្ញាអ៊ីចឹងដែរ”។ ក្នុងទីបញ្ចប់នៃទេសនា ព្រះបរមសាស្តាចារ្យបានប្រជុំជាតកថា៖

- បរិព្វាជិកាភេរី គ្រានោះ បានមកជា ឧប្បលវណ្ណាភិក្ខុនី
- សិរីវឌ្ឍនសេដ្ឋី បានមកជា ព្រះបាទសុទ្ធោទនពុទ្ធបិតា
- សុមនទេវី បានមកជា សិរិមហាមាយាពុទ្ធមាតា
- នាងអមរា បានមកជា ពិម្ពាយសោធរា រាហុលមាតា
- សេកមាធុរៈ បានមកជា អានន្ទ ពុទ្ធុបដ្ឋាក
- ព្រះបាទចូឡនី បានមកជា សារីបុត្តត្ថេរ
- កេវដ្តព្រាហ្មណ៍ បានមកជា ភិក្ខុទេវទត្ត

- ចលាកទេវី បានមកជា ថុល្លនន្ទាភិក្ខុនី
- បញ្ចាលចន្ទី បានមកជា សុន្ទរី
- សារិកា បានមកជា មល្លិកា
- អាចារ្យកាមិន្ទៈ បានមកជា អម្ពដ្ឋៈ
- អាចារ្យបុក្កុសៈ បានមកជា ពោដ្ឋបាទា
- អាចារ្យទេវិន្ទៈ បានមកជា បិលោតិកត្ថេរ
- អាចារ្យសេនកៈ បានមកជា មហាកស្សបត្ថេរ
- ឧទុម្ពរទេវី បានមកជា គោតមី
- ព្រះបាទវិទេហៈ បានមកជា កាឡុទាយី
- តិខិណមន្ត្រិកុមារ បានមកជា ឆន្នភិក្ខុ
- ធនុសេខៈ បានមកជា រាហុល
- អនុកេវដ្តៈ បានមកជា មោគ្គល្លាន
- បញ្ចាលចន្ទ បានមកជា អនុរុទ្ធ
- មហោសថ បានមកជា អង្គអញ្ជតថាគតលោកនាថ នេះឯង។

អ្នកទាំងឡាយ ចូរចងចាំនូវមហោសថជាតក ដោយប្រការយ៉ាងនេះ។

ព្រះមហោសថជាតកពិស្តារ ចប់តែប៉ុណ្ណេះ។

PAÑÑĀSĀSTRA UNIVERSITY





ISBN 9789995094690

PUC Press